

ឯកសារគម្ពីរព្រះត្រៃបិដកស្កាននេះ
ត្រូវបានថតចេញពីច្បាប់គម្ពីរព្រះត្រៃបិដកដើម ៗ

ឯកសារគម្ពីរព្រះត្រៃបិដកនេះ ចាប់ពីភាគ១ ដល់ ភាគ៥០
គឺជារបស់ ឧបាសិកា កាំង ហ្គិចណៃ និងស្វាមី ព្រមទាំងបុត្រធីតា,
ធ្វើជូនលោកគ្រូអគ្គបណ្ឌិត ប៊ុត-សាវង្ស ៗ និងទុកក្នុង
គេហទំព័រ៥០០០ឆ្នាំ សម្រាប់ជាធម្មទាន ៗ

កែសម្រួលតាមកុំព្យូទ័រ តម្រូវឧបករណ៍អានអេឡិត្រូនិច
ដោយខ្ញុំព្រះករុណា ខ្ញុំបាទ ស្រុង-ចាន់ណា ៗ

www.5000-years.org

# ព្រះ
# ត្រៃបិដកបាលី
# នឹង
# សេចក្ដីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# ទីឃនិកាយ បឋមភាគ
# សីលក្ខន្ធវគ្គ
# ១៨

ព្រហ្មជាលសូត្រ សាមញ្ញផលសូត្រ
អម្ពដ្ឋសូត្រ និង សោណទណ្ឌសូត្រ

ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ
ព.ស. ២៥០២

# ស្រៈពេញតួ

# *Voyelles:*

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ខ្មែរ Cambodgien | អ | អា | ឥ | ឦ | ឧ | ឩ | ឯ | ឱ |
| ឧរុប Romain | *a* | *ā* | *i* | *ī* | *u* | *ū* | *e* | *o* |
| សៀម Siamois | อ | อา | อิ | อี | อุ | อู | เอ | โอ |
| លាវ Laotien | ອ | ອາ | ອິ | ອີ | ອຸ | ອູ | ເອ | ໂອ |
| លង្កា Cinghalais | අ | ආ | ඉ | ඊ | උ | ඌ | එ | ඔ |
| ភូមា Birman | အ | အာ | ဣ | ဤ | ဥ | ဦ | ဧ | ဩ |

# ស្រៈនិងសញ្ញា

# *Signes et accents.*



# ព្យញ្ជនៈ

# Consonnes.

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ក | ខ | គ | ឃ | ង |
| ឡូប<br>Romain | **k** | **kh** | **g** | **gh** | **ṅ** |
| សៀម<br>Siamois | ก | ข | ค | ฆ | ง |
| លាវ<br>Laotien | ກ | ຂ | ຄ | ຆ | ງ |
| លង្កា<br>Cinghalais | ක | ඛ | ග | ඝ | ඞ |
| ភូមា<br>Birman | က | ခ | ဂ | ဃ | င |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ<br>Cambodgien | ច | ឆ | ជ | ឈ | ញ |
| ឡរូម<br>Romain | *c* | *ch* | *j* | *jh* | *ñ* |
| សៀម<br>Siamois | จ | ฉ | ช | ฌ | ญ |
| លាវ<br>Laotien | ຈ | ສ | ຊ | ຌ | ຍ |
| លង្កា<br>Cinghalais | ච | ඡ | ජ | ඣ | ඤ |
| ភូមា<br>Birman | စ | ဆ | ဇ | ဈ | ည |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ដ | ឋ | ឌ | ឍ | ណ |
| រូប Romain | *ṭ* | *ṭh* | *ḍ* | *ḍh* | *ṇ* |
| សៀម Siamois | ฏ | ฐ | ฑ | ฒ | ณ |
| លាវ Laotien | ຏ | ຐ | ຑ | ຒ | ຓ |
| សិង្ហ Cinghalais | ට | ඨ | ඩ | ඪ | ණ |
| ភូមា Birman | ဋ | ဌ | ဍ | ဎ | ဏ |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ត | ថ | ទ | ធ | ន |
| ទ្រូប Romain | *t* | *th* | *d* | *dh* | *n* |
| សៀម Siamois | ต | ถ | ท | ธ | น |
| លាវ Laotien | ᨲ | ᨳ | ᨴ | ᨵ | ᨶ |
| បេឆ្ក Cinghalais | ත | ථ | ද | ධ | න |
| ភូមា Birman | တ | ထ | ဒ | ဓ | န |

| | | | | | |
|---|---|---|---|---|---|
| ខ្មែរ Cambodgien | ប | ផ | ព | ភ | ម |
| ឱរុប Romain | *p* | *ph* | *b* | *bh* | *m* |
| សៀម Siamois | ป | ผ | พ | ภ | ม |
| លាវ Laotien | ບ | ຜ | ພ | ຟ | ມ |
| លង្កា Cinghalais | ප | ඵ | බ | භ | ම |
| ភូមា Birman | ပ | ဖ | ဗ | ဘ | မ |

| | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| ខ្មែរ CAMBODGIEN | យ | រ | ល | វ | ស | ហ | ឡ | ំ | ៕ |
| រូប Romain | *y* | *r* | *l* | *v* | *s* | *h* | *ḷ* | *ṃ* | ./. |
| សៀម Siamois | ย | ร | ล | ว | ส | ห | ฬ | ํ | ฯ |
| លាវ Laotien | ຍ | ຣ | ລ | ວ | ສ | ຫ | ຬ | ໍ | ຯ |
| លង្កា Cinghalais | ය | ර | ල | ව | ස | හ | ළ | ං | \|\| |
| ភូមា Birman | ယ | ရ | လ | ဝ | သ | ဟ | ဠ | ံ | \|\| |

# សុត្តន្តបិដកេ ទីឃនិកាយស្ស

# បឋមោ ភាគោ

---

## សីលក្ខន្ធវគ្គោ

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## ព្រហ្មជាលសុត្តំ បឋមំ

(១) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា អន្តរា ច រាជគហំ អន្តរា ច នាឡន្ទំ អទ្ធានមគ្គប្បដិបន្នោ ហោតិ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ ។ សុប្បិយោបិ ខោ បរិព្វាជកោ អន្តរា ច រាជគហំ អន្តរា ច នាឡន្ទំ អទ្ធានមគ្គប្បដិបន្នោ ហោតិ សទ្ធឹ អន្តេវាសិនា ព្រហ្មទត្តេន មាណវេន ។ តត្រ សុទំ សុប្បិយោ បរិព្វាជកោ អនេកបរិយាយេន

# សុត្តន្តបិដក ទីឃនិកាយ

## បឋមភាគ

---

## សីលក្ខន្ធវគ្គ

*សូមនមស្ការ ចំពោះព្រះមានព្រះភាគ*

*ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។*

## ព្រហ្មជាលសូត្រ ទី ១

[១] (សូត្រនេះ(១)) ខ្ញុំបានស្តាប់មកយ៉ាងនេះ(២) ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ផ្លូវឆ្ងាយ ក្នុងចន្លោះនៃក្រុងរាជ-គ្រឹះនឹងចន្លោះនៃនាឡន្ទគ្រាម ជាមួយនឹងភិក្ខុសង្ឃច្រើន ចំនួន៥០០រូប ។ ចំណែកខាងសុប្បិយបរិញ្វាជក ក៏បានដើរទៅកាន់ផ្លូវឆ្ងាយ ក្នុងចន្លោះនៃក្រុងរាជគ្រឹះនឹងចន្លោះនៃនាឡន្ទគ្រាម ជាមួយនឹងព្រហ្មទត្តមាណពដែលជាកូនសិស្សដែរ ។ បានឮថា ក្នុងផ្លូវឆ្ងាយនោះ សុប្បិយបរិញ្វាជក

---

១ សព្ទដែលប្រែថា សូត្រនេះ នោះ មិនមានក្នុងបាលីទេ តែអ្នកជាប់រៀនល្យល់ហើយឲ្យដាក់បញ្ចូលមកប្រែ ដើម្បីសម្រួលសេចក្តីឲ្យងាយស្តាប់ យើងក៏បានយកសព្ទនេះមកដាក់ខាងដើមសូត្រទាំង ៤ ដែលមានក្នុងសៀវភៅសុត្តន្តបិដកបឋមភាគនេះ ដល់ទៅសៀវភៅខាងមុខ ៗ ទៀត មិនបាច់ដាក់សព្ទនុ៎ះបញ្ចូលមកប្រែទៀតឡើយ គឺប្រែតែប៉ុនបាលីប៉ុណ្ណោះ ។ ២ ជាពាក្យព្រះអានន្ទ ព្រោះព្រះសូត្រក្នុងសុត្តន្តបិដកទាំងមូលនេះ សុទ្ធតែជាសូត្រដែលព្រះអានន្ទត្ថេរបានស្តាប់មក ដូចមានបាលីប្រកាសខ្លួនរបស់លោកក្នុងខាងដើមនៃសូត្រទាំងនោះថា ឯវម្មេ សុតំ ៗ ដូច្នេះ ។

ពុទ្ធស្ស អវណ្ណំ ភាសតិ ធម្មស្ស អវណ្ណំ ភាសតិ សង្ឃស្ស អវណ្ណំ ភាសតិ ។ សុប្បិយស្ស បន បរិព្វាជកស្ស អន្តេវាសី ព្រហ្មទត្តោ មាណវោ អនេកបរិយាយេន ពុទ្ធស្ស វណ្ណំ ភាសតិ ធម្មស្ស វណ្ណំ ភាសតិ សង្ឃស្ស វណ្ណំ ភាសតិ ។ ឥតិហ តេ ឧភោ អាចរិយន្តេវាសី អញ្ញមញ្ញស្ស ឧជុវិបច្ចនិកវាទា ភគវន្តំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធា(១) ហោន្តិ ភិក្ខុសង្ឃញ្ច ។ អថ ខោ ភគវា អម្ពលដ្ឋិកាយំ រាជាគារកេ ឯករត្តិវាសំ ឧបគញ្ឆិ(២) សទ្ធឹ ភិក្ខុសង្ឃេន ។ សុប្បិយោបិ ខោ បរិព្វាជកោ អម្ពលដ្ឋិកាយំ រាជាគារកេ ឯករត្តិវាសំ ឧបគញ្ឆិ(៣) សទ្ធឹ អន្តេវាសិនា ព្រហ្មទត្តេន មាណវេន ។ តត្របិ សុទំ សុប្បិយោ បរិព្វាជកោ អនេកបរិយាយេន ពុទ្ធស្ស អវណ្ណំ ភាសតិ ធម្មស្ស អវណ្ណំ ភាសតិ សង្ឃស្ស អវណ្ណំ ភាសតិ ។ សុប្បិយស្ស បន បរិព្វាជកស្ស អន្តេវាសី ព្រហ្មទត្តោ មាណវោ អនេកបរិយាយេន ពុទ្ធស្ស វណ្ណំ ភាសតិ ធម្មស្ស វណ្ណំ ភាសតិ សង្ឃស្ស វណ្ណំ ភាសតិ ។

---

១ ឱ អនុពទ្ធា ។ ២-៣ ឧបគញ្ឆីតិ ឃោ ។

ពោលតិះដៀលព្រះពុទ្ធ ពោលតិះដៀលព្រះធម៌ ពោលតិះដៀលព្រះសង្ឃ ដោយអនេកបរិយាយ ៗ ឯព្រហ្មទត្តមាណពដែលជាកូនសិស្សរបស់សុប្បិយបរិព្វាជក ក៏ពោលសរសើរគុណព្រះពុទ្ធ ពោលសរសើរគុណព្រះធម៌ ពោលសរសើរគុណព្រះសង្ឃ ដោយអនេកបរិយាយវិញ ៗ ព្រោះហេតុយ៉ាងនេះ បានជាបរិព្វាជកទាំងពីរនាក់ គឺអាចារ្យនឹងកូនសិស្សនោះ ពោលពាក្យជាសឹកសត្រូវទៅរកគ្នានឹងគ្នាដោយត្រង់ (ឥតមានបញ្ចៀសវាសវាង) ហើយដើរជាប់តាមក្រោយ ៗ ព្រះមានព្រះភាគនឹងភិក្ខុសង្ឃទៅ ៗ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ស្តេចចូលទៅគង់នៅក្នុងរាជដំណាក់ ក្នុងសួនឈ្មោះអម្ពលដ្ឋិកា នៅអស់មួយរាត្រីជាមួយនឹងភិក្ខុសង្ឃ ៗ ឯសុប្បិយបរិព្វាជក ក៏បានចូលទៅនៅក្នុងរាជដំណាក់ ក្នុងសួនឈ្មោះអម្ពលដ្ឋិកា នៅអស់មួយរាត្រីជាមួយនឹងព្រហ្មទត្តមាណពដែលជាកូនសិស្សដែរ ៗ ក្នុងរឿងនោះ បានឮថា សុប្បិយបរិព្វាជកពោលតិះដៀលព្រះពុទ្ធ ពោលតិះដៀលព្រះធម៌ ពោលតិះដៀលព្រះសង្ឃ ដោយអនេកបរិយាយ ៗ ឯព្រហ្មទត្តមាណពជាកូនសិស្ស របស់សុប្បិយបរិព្វាជក ក៏ពោលសរសើរគុណព្រះពុទ្ធ ពោលសរសើរគុណព្រះធម៌ ពោលសរសើរគុណព្រះសង្ឃ ដោយអនេកបរិយាយវិញ ៗ

## ព្រហ្មជាលសុត្តេ សុត្តនិទានំ

ឥតិហ តេ ឧភោ អាចរិយន្តេវាសី អញ្ញមញ្ញស្ស ឧជុវិបច្ចនីកវាទា ភគវន្តំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធា ហោន្តិ ភិក្ខុសង្ឃញ្ច ។ អថខោ សម្ពហុលានំ ភិក្ខូនំ រត្តិយា បច្ចូសសមយំ បច្ចុដ្ឋិតានំ មណ្ឌលមាឡេ សន្និសិន្នានំ សន្និបតិតានំ អយំ សង្ខិយធម្មោ[១] ឧទបាទិ អច្ឆរិយំ អាវុសោ អព្ភុតំ[២] អាវុសោ យាវញ្ចិទំ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សត្តានំ នានាធិមុត្តិកតា សុបដិវិទិតា[៣] អយំ ហិ សុប្បិយោ បរិព្វាជកោ អនេកបរិយាយេន ពុទ្ធស្ស អវណ្ណំ ភាសតិ ធម្មស្ស អវណ្ណំ ភាសតិ សង្ឃស្ស អវណ្ណំ ភាសតិ សុប្បិយស្ស បន បរិព្វាជកស្ស អន្តេវាសី ព្រហ្មទត្តោ មាណវោ អនេកបរិយាយេន ពុទ្ធស្ស វណ្ណំ ភាសតិ ធម្មស្ស វណ្ណំ ភាសតិ សង្ឃស្ស វណ្ណំ ភាសតិ ឥតិហ ឥមេ ឧភោ[៤] អាចរិយន្តេវាសី អញ្ញមញ្ញស្ស ឧជុវិបច្ចនីកវាទា ភគវន្តំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធា ហោន្តិ

---

១ សង្ខិយាធម្មោតិបិ បាឋោ ។ ២ ខ. អព្ភុតំ ។ ៣ សុប្បដិវិទិតាតិបិ បាឋោ វិធានេន យុត្តតរោ ។ ៤ ឥតិហ តេ ឥមេ ឧភោតិបិ បាឋោ ។ ខ. ម. ឥតិហ មេ ។

ព្រោះហេតុយ៉ាងនេះ បានជាបរិព្វាជកទាំង ២ រូប គឺអាចារ្យនឹងកូនសិស្ស នោះ ពោលពាក្យជាសឹកសត្រូវ ទៅរកគ្នានឹងគ្នាដោយត្រង់ ដើរជាប់តាមក្រោយ ៗ ព្រះមានព្រះភាគនឹងភិក្ខុសង្ឃទៅ ៗ គ្រានោះឯង ភិក្ខុទាំងឡាយច្រើនរូបក្រោកឡើង ក្នុងបច្ចូសសម័យនៃរាត្រី ហើយអង្គុយប្រជុំគ្នាក្នុងរោងសម្រាប់សម្រាកកាយ បានផ្តើមពាក្យស្ទើបនេះឡើងថា ម្នាលអាវុសោទាំងឡាយ អស្ចារ្យណាស់តើហ្ន៎ ម្នាលអាវុសោទាំងឡាយ ហេតុនេះមិនធ្លាប់កើត បែរជាកើតឡើងបាន ព្រះមានព្រះភាគ អង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាប ទ្រង់ឃើញច្បាស់ ទ្រង់ជ្រាបចំពោះនូវភាវៈនៃសត្វទាំងឡាយ ដែលមានអធ្យាស្រ័យផ្សេង ៗ គ្នាដោយពិតប្រាកដ ព្រោះថា សុប្បិយបរិព្វាជកនេះ ពោលតិះដៀលព្រះពុទ្ធ ពោលតិះដៀលព្រះធម៌ ពោលតិះដៀលព្រះសង្ឃ ដោយអនេកបរិយាយ ចំណែកខាងព្រហ្មទត្តមាណព ជាកូនសិស្ស របស់សុប្បិយបរិព្វាជក ពោលសរសើរគុណព្រះពុទ្ធ ពោលសរសើរគុណព្រះធម៌ ពោលសរសើរគុណព្រះសង្ឃ ដោយអនេកបរិយាយវិញ ព្រោះហេតុយ៉ាងនេះ បានជាបរិព្វាជកទាំងពីរនាក់ គឺអាចារ្យនឹងកូនសិស្សនេះ ពោលពាក្យជាសឹកសត្រូវ ទៅរកគ្នានឹងគ្នាដោយត្រង់ ដើរជាប់តាមក្រោយ ៗ នៃព្រះមានព្រះភាគ

ភិក្ខុសង្ឃញ្ចាតិ ។ អថខោ ភគវា តេសំ ភិក្ខូនំ ឥមំ សង្ខិយធម្មំ វិទិត្វា យេន មណ្ឌលមាឡោ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ កាយ នុត្ថ ភិក្ខវេ ឯតរហិ កថាយ សន្និសិន្នា សន្និបតិតា កា ច បន វោ អន្តរាកថា វិប្បកតាតិ ។ ឯវំ វុត្តេ តេ ភិក្ខូ ភគវន្តំ ឯត-ទវោចុំ ឥធ ភន្តេ អម្ហាកំ រត្តិយា បច្ចូសសមយំ បច្ចុដ្ឋិ-តានំ មណ្ឌលមាឡេ សន្និសិន្នានំ សន្និបតិតានំ អយំ សង្ខិយធម្មោ ឧទបាទិ អច្ឆរិយំ អាវុសោ អព្ភុតំ អាវុសោ យាវញ្ចិទំ តេន ភគវតា ជានតា បស្សតា អរហតា សម្មាសម្ពុទ្ធេន សត្តានំ នានាធិមុត្តិកតា សុប្បដិវិទិតា អយំ ហិ សុប្បិយោ បរិព្វាជកោ អនេកបរិយាយេន ពុទ្ធស្ស អវណ្ណំ ភាសតិ ធម្មស្ស អវណ្ណំ ភាសតិ

នឹងភិក្ខុសង្ឃទៅ ។ គ្រានោះឯង ព្រះមានព្រះភាគទ្រង់ជ្រាបច្បាស់នូវពាក្យស្ទើចនេះរបស់ភិក្ខុទាំងឡាយនោះ ហើយទ្រង់យាងចូលទៅក្នុងរោងសម្រាប់សម្រាកកាយ លុះយាងទៅដល់ហើយ ទ្រង់គង់លើអាសនៈដែលគេតែងតាំងថ្វាយ ។ លុះព្រះមានព្រះភាគគង់ហើយ ក៏ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយមកអង្គុយប្រជុំគ្នាក្នុងទីនេះ និយាយពីរឿងអ្វីដូចម្ដេច ចុះពាក្យជាចន្លោះ(១) ដូចម្ដេច ដែលអ្នកទាំងឡាយនិយាយមិនទាន់ចប់ ។ កាលព្រះមានព្រះភាគទ្រង់សួរយ៉ាងនេះហើយ ភិក្ខុទាំងនោះក៏បានក្រាបបង្គំទូលសេចក្ដីនុ៎ះចំពោះព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន កាលខ្ញុំព្រះអង្គទាំងឡាយក្រោកឡើងក្នុងបច្ចូសសម័យនៃរាត្រី ហើយអង្គុយប្រជុំគ្នាក្នុងរោងសម្រាប់សម្រាកកាយនេះ បានផ្ដើមពាក្យស្ទើចនេះឡើងថា ម្នាលអាវុសោទាំងឡាយ អស្ចារ្យណាស់តើហ្ន៎ ម្នាលអាវុសោទាំងឡាយហេតុនេះ មិនធ្លាប់កើត ក៏បែរជាកើតឡើងបាន ព្រះមានព្រះភាគអង្គនោះជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់ជ្រាបឃើញច្បាស់ ទ្រង់ជ្រាបច្បាស់លាស់នូវភាវៈនៃសត្វទាំងឡាយ ដែលមានអធ្យាស្រ័យផ្សេង ៗ គ្នា ដោយពិតប្រាកដ ព្រោះថាសុប្បិយបរិព្វាជកនេះ ពោលតិះដៀលព្រះពុទ្ធ ពោលតិះដៀលព្រះធម៌ ពោលតិះដៀលព្រះសង្ឃ ដោយអនេកបរិយាយ

---

១ អដ្ឋកថា ថា ពាក្យជាបន្លោះអំពីគុណកថា មានកម្មដ្ឋានមនសិការនឹងបាលីនឹងអដ្ឋកថាជាដើម ។

ព្រហ្មជាលសុត្តេ សុត្តនិទានំ

សង្ឃស្ស អវណ្ណំ ភាសតិ សុប្បិយស្ស បន បរិព្វាជ-
កស្ស អន្តេវាសី ព្រហ្មទត្តោ មាណវោ អនេកបរិ-
យាយេន ពុទ្ធស្ស វណ្ណំ ភាសតិ ធម្មស្ស វណ្ណំ ភាសតិ
សង្ឃស្ស វណ្ណំ ភាសតិ ឥតិហ តេ ឧភោ អាចរិយន្តេ-
វាសី អញ្ញមញ្ញស្ស ឧជុវិបច្ចនិកវាទា ភគវន្តំ បិដ្ឋិតោ
បិដ្ឋិតោ អនុពន្ធា ហោន្តិ ភិក្ខុសង្ឃញ្ចាតិ អយំ ខោ នោ
ភន្តេ អន្តរា កថា វិប្បកតា អថ ភគវា អនុប្បត្តោតិ ។
មមំ វា ភិក្ខវេ បរេ អវណ្ណំ ភាសេយ្យុំ ធម្មស្ស វា
អវណ្ណំ ភាសេយ្យុំ សង្ឃស្ស វា អវណ្ណំ ភាសេយ្យុំ
តត្រ តុម្ហេហិ ន អាឃាតោ ន អប្បច្ចយោ ន ចេត-
សោ អនភិរទ្ធិ ករណីយា ។ មមំ វា ភិក្ខវេ បរេ
អវណ្ណំ ភាសេយ្យុំ ធម្មស្ស វា អវណ្ណំ ភាសេយ្យុំ សង្ឃ-
ស្ស វា អវណ្ណំ ភាសេយ្យុំ តត្រ ចេ តុម្ហេ អស្សថ
កុបិតា វា អនត្តមនា វា តុម្ហាញ្ញេវស្ស[១] តេន អន្ត-
រាយោ ។ មមំ វា ភិក្ខវេ បរេ អវណ្ណំ ភាសេយ្យុំ

១ ឱ. ម. តុម្ហំ យេវស្ស ។

## ព្រហ្មជាលសូត្រ សុត្តនិទាន

ឯព្រហ្មទត្តមាណពដែលជាកូនសិស្ស របស់សុប្បិយបរិព្វាជក ក៏ពោលសរសើរគុណព្រះពុទ្ធ ពោលសរសើរគុណព្រះធម៌ ពោលសរសើរគុណព្រះសង្ឃ ដោយអនេកបរិយាយវិញ ព្រោះហេតុយ៉ាងនេះ បានជាបរិព្វាជកទាំង ២ នាក់ គឺអាចារ្យនឹងកូនសិស្សនោះ ពោលពាក្យជាសឹកសត្រូវទៅរកគ្នានឹងគ្នាដោយត្រង់ ដើរជាប់តាមក្រោយ ៗ នៃព្រះមានព្រះភាគនឹងភិក្ខុសង្ឃទៅ បណ្ឌិតព្រះអង្គដ៏ចំរើន ពាក្យជាបន្ទោះនេះឯង ដែលខ្ញុំព្រះអង្គទាំងឡាយ និយាយមិនទាន់ចប់នៅឡើយ ទទួលព្រះមានព្រះភាគស្តេចមកដល់ ៗ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទោះបីពួកសត្វដទៃ ពោលតិះដៀលតថាគតក្តី ពោលតិះដៀលព្រះធម៌ក្តី ពោលតិះដៀលព្រះសង្ឃក្តី អ្នកទាំងឡាយមិនគួរធ្វើគំនុំ មិនគួរធ្វើសេចក្តីមិនត្រេកអរ មិនគួរធ្វើសេចក្តីអាក់អន់ចិត្ត ចំពោះពួកសត្វទាំងនោះឡើយ ៗ ម្នាលភិក្ខុទាំងឡាយ ទោះបីពួកសត្វដទៃ ពោលតិះដៀលតថាគតក្តី ពោលតិះដៀលព្រះធម៌ក្តី ពោលតិះដៀលព្រះសង្ឃក្តី បើអ្នកទាំងឡាយក្រោធ ឬអាក់អន់ចិត្តចំពោះពួកសត្វទាំងនោះហើយ មុខជាសេចក្តីអន្តរាយ (នៃគុណទាំងឡាយមានបឋមជ្ឈានជាដើម) នឹងកើតមានប្រាកដដល់អ្នកទាំងឡាយ ដោយសេចក្តីក្រោធនឹងសេចក្តីអាក់អន់ចិត្តនោះ ៗ ម្នាលភិក្ខុទាំងឡាយ ទោះបីពួកសត្វដទៃពោលតិះដៀលតថាគតក្តី

ធម្មស្ស វា អវណ្ណំ ភាសេយ្យុំ សង្ឃស្ស វា អវណ្ណំ ភាសេយ្យុំ តត្រ ចេ តុម្ហេ អស្សថ កុបិតា វា អនត្តមនា វា អបិ នុ តុម្ហេ បរេសំ សុភាសិតំ វា ទុព្ភាសិតំ វា អាជានេយ្យាថាតិ ។ នោ ហេតំ ភន្តេ ។ មមំ វា ភិក្ខវេ បរេ អវណ្ណំ ភាសេយ្យុំ ធម្មស្ស វា អវណ្ណំ ភាសេយ្យុំ សង្ឃស្ស វា អវណ្ណំ ភាសេយ្យុំ តត្រ តុម្ហេហិ អភូតំ អភូតតោ និព្វេឋេតព្វំ ឥតិបេតំ(១) អភូតំ ឥតិបេតំ អតច្ឆំ នត្ថិ ចេតំ អម្ហេសុ ន ច បនេតំ អម្ហេសុ សំវិជ្ជតីតិ ។ មមំ វា ភិក្ខវេ បរេ វណ្ណំ ភាសេយ្យុំ ធម្មស្ស វា វណ្ណំ ភាសេយ្យុំ សង្ឃស្ស វា វណ្ណំ ភាសេយ្យុំ តត្រ តុម្ហេហិ ន អានន្ទោ ន សោមនស្សំ ន ចេតសោ ឧប្បិលាវិតត្តំ ករណីយំ ។ មមំ វា ភិក្ខវេ បរេ វណ្ណំ ភាសេយ្យុំ ធម្មស្ស វា វណ្ណំ ភាសេយ្យុំ សង្ឃស្ស វា វណ្ណំ ភាសេយ្យុំ តត្រ ចេ តុម្ហេ ភិក្ខវេ អស្សថ អានន្ទិនោ សុមនា ឧប្បិលាវិតត្តា

---

១ ម. ឥតិបិ ឯតំ ។

ពោលតិះដៀលព្រះធម៌ក្តី ពោលតិះដៀលព្រះសង្ឃក្តី បើអ្នកទាំងឡាយ ក្រោធ ឬអាក់អន់ចិត្តចំពោះពួកសត្វទាំងនោះហើយ អ្នកទាំងឡាយនឹង បានដឹងច្បាស់នូវសេចក្តីនៃពាក្យពីរោះឬពាក្យអាក្រក់ របស់ពួកសត្វដទៃ ដែរឬ ។ ពួកភិក្ខុក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន យើងខ្ញុំ មិនអាចដឹងច្បាស់ នូវសេចក្តីនៃពាក្យនោះទេ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ទោះបីពួកសត្វដទៃ ពោលតិះ ដៀលតថាគតក្តី ពោលតិះដៀលព្រះធម៌ក្តី ពោលតិះដៀលព្រះសង្ឃ ក្តី អ្នកទាំងឡាយគប្បីឃាត់ពាក្យមិនពិត ដោយពាក្យមិនពិត ចំពោះ ពួកសត្វទាំងនោះថា ពាក្យនេះមិនពិត ដោយហេតុនេះ ពាក្យនេះមិន ប្រាកដដោយហេតុនេះ ហេតុនេះឥតមានក្នុងពួកយើង មួយវិញទៀត ពាក្យនេះរកមិនបានក្នុងពួកយើងទេ ។ ម្នាលភិក្ខុទាំងឡាយ ទោះបីពួក សត្វដទៃ ពោលសរសើរគុណតថាគតក្តី ពោលសរសើរគុណព្រះធម៌ក្តី ពោលសរសើរគុណព្រះសង្ឃក្តី អ្នកទាំងឡាយមិនគួរធ្វើសេចក្តីរីករាយ មិនគួរធ្វើសោមនស្ស មិនគួរធ្វើសេចក្តីព្រើលចិត្ត ចំពោះពួកសត្វទាំង នោះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ទោះបីពួកសត្វដទៃ ពោលសរសើរ គុណតថាគតក្តី ពោលសរសើរគុណព្រះធម៌ក្តី ពោលសរសើរគុណព្រះ សង្ឃក្តី ម្នាលភិក្ខុទាំងឡាយ បើអ្នកទាំងឡាយមានចិត្តរីករាយ ត្រេកអរ

## ព្រហ្មជាលសុត្តំ  ចូឡសីលំ

តុម្ហញ្ញេវស្ស តេន អន្តរាយោ ។ មមំ វា ភិក្ខវេ បរេ វណ្ណំ ភាសេយ្យុំ ធម្មស្ស វា វណ្ណំ ភាសេយ្យុំ សង្ឃស្ស វា វណ្ណំ ភាសេយ្យុំ តត្រ តុម្ហេហិ ភូតំ ភូតតោ បដិជានិតព្វំ ឥតិបេតំ ភូតំ ឥតិបេតំ តច្ឆំ អត្ថិ ចេតំ អម្ហេសុ សំវិជ្ជតិ ច បនេតំ អម្ហេសូតិ ។

(២) អប្បមត្តកំ ខោ បនេតំ ភិក្ខវេ ឱរមត្តកំ សីលមត្តកំ យេន បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។ កតមញ្ចេតំ[1] ភិក្ខវេ អប្បមត្តកំ ឱរមត្តកំ សីលមត្តកំ យេន បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

---

១ ឱ. ម. កតមញ្ចតំ ។

ត្រេកអរចិត្ត ចំពោះពួកសត្វទាំងនោះហើយ សេចក្តីអន្តរាយ (នៃគុណទាំងឡាយមានបឋមជ្ឈានជាដើម) នឹងកើតមានប្រាកដ ដល់អ្នកទាំងឡាយ ព្រោះសេចក្តីត្រេកអរនោះឯង ។ ម្នាលភិក្ខុទាំងឡាយ ទោះបីពួកសត្វដទៃ ពោលសរសើរគុណតថាគតក្តី ពោលសរសើរគុណព្រះធម៌ក្តី ពោលសរសើរគុណព្រះសង្ឃក្តី អ្នកទាំងឡាយត្រូវធ្វើជាពាក្យពិតតាមពាក្យពិត ចំពោះពួកសត្វទាំងនោះថា ពាក្យនេះពិតដោយហេតុនេះមែន ពាក្យនេះប្រាកដដោយហេតុនេះមែន ពាក្យនេះតែងមាន ក្នុងពួកយើងមែន មួយវិញទៀត ពាក្យនេះ រមែងរកបាន ក្នុងពួកយើងមែន ។

(២) ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលបើពោលសរសើរគុណរបស់តថាគត តែងសរសើរដោយគុណជាតណា គុណជាតនុ៎ះមានប្រមាណតិច មានប្រមាណស្តួចស្តើងបានត្រឹមតែសីលប៉ុណ្ណោះ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលបើពោលសរសើរគុណរបស់តថាគត ដោយគុណជាតណា គុណជាតនុ៎ះមានប្រមាណតិច មានប្រមាណស្តួចស្តើងបានត្រឹមតែសីលប៉ុណ្ណោះ តើដូចម្តេច ។

(៣) បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ សមណោ គោតមោ និហិតទណ្ឌោ និហិតសត្ថោ លជ្ជី ទយាបន្នោ សព្វបាណភូតហិតានុកម្បី វិហរតីតិ ។ ឥតិ វា ហិ ភិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតោ សមណោ គោតមោ ទិន្នាទាយី ទិន្នបាដិកង្ខី អថេនេន សុចិភូតេន អត្តនា វិហរតីតិ ។ ឥតិ វា ហិ ភិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។ អព្រហ្មចរិយំ បហាយ ព្រហ្មចារី សមណោ គោតមោ អារាចារី វិរតោ មេថុនា គាមធម្មាតិ ។ ឥតិ វា ហិ ភិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

(៤) មុសាវាទំ បហាយ មុសាវាទា បដិវិរតោ សមណោ គោតមោ សច្ចវាទី សច្ចសន្ធោ ថេតោ បច្ចយិកោ

(៣) (បុថុជ្ជន តែងពោលសរសើរថា) ព្រះសមណគោតម លះបង់បាណាតិបាតហើយ វៀរស្រឡះចាកបាណាតិបាតហើយ មានដំបង ដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប ដល់នូវសេចក្តីអាណិតអាសូរ មានសេចក្តីអនុគ្រោះ ដោយប្រយោជន៍ ដល់សព្វសត្វ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណ របស់តថាគត តែងពោលដូច្នេះក៏មាន ។ ថា ព្រះសមណគោតម លះបង់ នូវអទិន្នាទានហើយ វៀរស្រឡះចាកអទិន្នាទានហើយ ព្រះអង្គកាន់យក តែរបស់ដែលគេឲ្យ ប្រាថ្នាតែរបស់ដែលគេឲ្យ មានអត្តភាពជាអ្នកមិន លួច មានសភាពដ៏ស្អាត ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោល សរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។ ថា ព្រះសមណ-គោតម លះបង់អព្រហ្មចរិយៈហើយ ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ព្រះ អង្គបៀសវាង (អំពីអព្រហ្មចរិយៈ) វៀរចាកមេថុនធម្ម ជាធម៌របស់អ្នក ស្រុកហើយ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរ គុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។

(៤) (បុថុជ្ជន តែងពោលសរសើរថា) ព្រះសមណគោតម លះបង់មុសាវាទហើយ វៀរស្រឡះចាកមុសាវាទហើយ ព្រះអង្គពោលតែ ពាក្យពិត តពាក្យពិត មានវាចាខ្ជាប់ខ្ជួន គួរអ្នកផងជឿបាន មិនពោល

## ព្រហ្មជាលសុត្ត ចូឡសីលំ

អវិសំវាទកោ លោកស្សាតិ ។ ឥតិ វា ហិ ភិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។ បិសុណំ វាចំ បហាយ បិសុណាយ វាចាយ បដិវិរតោ សមណោ គោតមោ ឥតោ សុត្វា ន អមុត្រ អក្ខាតា ឥមេសំ ភេទាយ អមុត្រ វា សុត្វា ន ឥមេសំ អក្ខាតា អមូសំ ភេទាយ ។ ឥតិ ភិន្នានំ វា សន្ធាតា សហិតានំ វា អនុប្បទាតា សមគ្គារាមោ សមគ្គរតោ សមគ្គនន្ទី សមគ្គករណឹ វាចំ ភាសិតាតិ ។ ឥតិ វា ហិ ភិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។ ផរុសំ វាចំ បហាយ ផរុសាយ វាចាយ បដិវិរតោ សមណោ គោតមោ យា សា វាចា នេលា កណ្ណសុខា បេមនីយា ហទយង្គមា បោរី ពហុជនកន្តា ពហុជនមនាបា តថារូបឹ វាចំ ភាសិតាតិ ។ ឥតិ វា ហិ ភិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

បំភ្លាត់សត្វលោក ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។ ថា ព្រះសមណគោតម ព្រះអង្គលះបង់បិសុណាវាចាហើយ វៀរស្រឡះចាកបិសុណាវាចាហើយ ព្រះអង្គឮពាក្យក្នុងសំណាក់នៃពួកជនឯណោះហើយ មិននាំយកទៅប្រាប់ដល់ពួកជនឯណោះ ដើម្បីបំបែកពួកជននេះឡើយ ឬឮពាក្យក្នុងសំណាក់នៃពួកជនឯណោះហើយ មិននាំយកមកប្រាប់ដល់ពួកជននេះ ដើម្បីបំបែកពួកជនឯណោះឡើយ ។ ព្រះអង្គជាអ្នកផ្សះផ្សានូវពួកជន ដែលបែកគ្នាហើយផង ជាអ្នកបន្ថែមកំឡាំងឲ្យដល់ពួកជន ដែលព្រមព្រៀងគ្នាហើយផង ព្រះអង្គមានសេចក្ដីព្រមព្រៀងជាទីត្រេកអរ ត្រេកអរក្នុងសេចក្ដីព្រមព្រៀង រីករាយក្នុងការព្រមព្រៀង ទ្រង់ពោលវាចាដែលធ្វើឲ្យព្រមព្រៀងគ្នា ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន។ ថា ព្រះសមណគោតម ទ្រង់លះបង់នូវផរុសវាចាហើយ វៀរស្រឡះចាកផរុសវាចាហើយ ក៏វាចាណាដែលជាសំដីឥតមានទោស ជាសុខដល់ត្រចៀក គួរឲ្យអ្នកផងស្រឡាញ់ពេញហឫទ័យ ជាសំដីរបស់អ្នកសប្បុរស ជាទីត្រេកអរនៃជនច្រើននាក់ ពេញចិត្តនៃជនច្រើននាក់ ទ្រង់ពោលតែវាចាបែបនោះឯង ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។

សម្ផប្បលាបំ បហាយ សម្ផប្បលាបា បដិវិរតោ សម-ណោ គោតមោ កាលវាទី ភូតវាទី អត្ថវាទី ធម្មវាទី វិនយវាទី និធានវតី វាចំ ភាសិតា កាលេន សាប-ទេសំ បរិយន្តវតី អត្ថសញ្ហិតន្តិ ។ ឥតិ វា ហិ ភិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

(៥) ពីជគាមភូតគាមសមារម្ភា បដិវិរតោ សមណោ គោតមោតិ ។ ឥតិ វា ហិ ភិក្ខវេ ។ បេ ។

(៦) ឯកភត្តិកោ សមណោ គោតមោ រត្តូបរតោ វិរតោ វិកាលភោជនា ។ នច្ចគីតវាទិតវិសូកទស្សនា បដិវិរតោ សមណោ គោតមោ ។ មាលាគន្ធវិលេបន-ធារណមណ្ឌនវិភូសនដ្ឋានា បដិវិរតោ សមណោ គោ-

ថា ព្រះសមណគោតម ទ្រង់លះបង់នូវសម្ផប្បលាបៈហើយ វៀរស្រឡះចាកសម្ផប្បលាបៈហើយ ព្រះអង្គពោលពាក្យក្នុងកាលគួរ ពោលតែពាក្យពិតប្រាកដ ពោលតែពាក្យដែលជាអត្ថ ពោលតែពាក្យដែលជាធម៌ ពោលតែពាក្យដែលជាវិន័យ ពោលតែពាក្យមានឱកាសជាទីដំកល់ទុកក្នុងហឫទ័យ ប្រកបដោយគ្រឿងអាងមានគ្រឿងកំណត់ ប្រកបដោយប្រយោជន៍ ដោយកាលដ៏គួរ ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។

(៥) ថា ព្រះសមណគោតម វៀរស្រឡះចាកការធ្វើពីជគាមនិងភូតគាម[១] ឲ្យវិនាសហើយ ។ ម្នាលភិក្ខុទាំងឡាយ ដូច្នេះក៏មាន ។បេ។

(៦) ថា ព្រះសមណគោតម ព្រះអង្គបរិភោគភត្តតែ ១ ពេល វៀរលែងបរិភោគក្នុងរាត្រី វៀរលែងបរិភោគក្នុងកាលខុស ។ ព្រះសមណគោតម វៀរស្រឡះចាកកិរិយាមើលនូវរបាំ និងការស្តាប់នូវចម្រៀងនិងភ្លេងប្រគំ ដែលជាសត្រូវដល់កុសលធម៌ ។ ព្រះសមណគោតម វៀរស្រឡះចាកកិរិយាទ្រទ្រង់ ប្រដាប់ស្អិតស្អាងក្នុងកាយ ដោយផ្កាកម្រង

---

១ វត្ថុដែលមានពូជដុះឡើងបាន តែមិនដុះជាប់នឹងផែនដី មានគ្រាប់ឈើជាដើម ហៅថា ពីជគាម , ឈើស្មៅជាដើម ដែលដុះជាប់នឹងផែនដី ហៅថា ភូតគាម ។

តមោ ។ ឧច្ចាសយនមហាសយនា បដិវិរតោ សមណោ គោតមោ ។ ជាតរូបរជតប្បដិគ្គហណា បដិវិរតោ សមណោ គោតមោ ។

(៧) អាមកធញ្ញប្បដិគ្គហណា បដិវិរតោ សមណោ គោតមោ ។ អាមកមំសប្បដិគ្គហណា បដិវិរតោ សមណោ គោតមោ ។ ឥត្ថីកុមារិកប្បដិគ្គហណា បដិវិរតោ សមណោ គោតមោ ។ ទាសីទាសប្បដិគ្គហណា បដិវិរតោ សមណោ គោតមោ ។ អជេឡកប្បដិគ្គហណា បដិវិរតោ សមណោ គោតមោ ។ កុក្កុដសូករប្បដិគ្គហណា បដិវិរតោ សមណោ គោតមោ ។ ហត្ថិគវស្សវឡវប្បដិគ្គហណា បដិវិរតោ សមណោ គោតមោ ។ ខេត្តវត្ថុប្បដិគ្គហណា បដិវិរតោ សមណោ គោតមោ ។

(៨) ទូតេយ្យបហិណគមនានុយោគា បដិវិរតោ សមណោ គោតមោ ។ កយវិក្កយា បដិវិរតោ សមណោ គោតមោ ។ តុលាកូដកំសកូដមានកូដា បដិវិ-

នឹងគ្រឿងក្រអូបនឹងគ្រឿងលាបផ្សេង ៗ ។ ព្រះសមណគោតម វៀរស្រឡះចាកទីដេកទីអង្គុយដ៏ខ្ពស់ នឹងទីដេកទីអង្គុយដ៏ប្រសើរ ។ ព្រះសមណគោតម វៀរស្រឡះចាកកិរិយាទទួលមាសនឹងប្រាក់ ។

(៧) ថា ព្រះសមណគោតម វៀរស្រឡះចាកកិរិយាទទួលធញ្ញជាតឆៅ ។ ព្រះសមណគោតម វៀរស្រឡះចាកកិរិយាទទួលសាច់ឆៅ ។ ព្រះសមណគោតម វៀរស្រឡះចាកកិរិយាទទួលស្រីនឹងក្មេងស្រី ។ ព្រះសមណគោតម វៀរស្រឡះចាកកិរិយាទទួលខ្ញុំស្រីនឹងខ្ញុំប្រុស ។ ព្រះសមណគោតម វៀរស្រឡះចាកកិរិយាទទួលពពែនឹងចៀម ។ ព្រះសមណគោតម វៀរស្រឡះចាកកិរិយាទទួលមាន់នឹងជ្រូក ។ ព្រះសមណ·គោតម វៀរស្រឡះចាកកិរិយាទទួលដំរី គោ សេះ ឈ្មោលញី ។ ព្រះសមណគោតម វៀរស្រឡះចាកកិរិយាទទួលស្រែនឹងចំការ ។

(៨) ព្រះសមណគោតម វៀរស្រឡះចាកកិរិយាប្រកបនូវទូតកម្ម គឺនាំសំបុត្រឬពាក្យបណ្ដាំដល់គ្រហស្ថ នឹងទៅដោយគេបញ្ជូន អំពីផ្ទះ១ ទៅផ្ទះ១ ។ ព្រះសមណគោតម វៀរស្រឡះចាកការទិញនឹងការលក់ ។ ព្រះសមណគោតម វៀរស្រឡះចាកការឆបោកឬបន្លំដោយជញ្ជីង នឹង

តោ សមណោ គោតមោ ។ ឧក្កោដនវញ្ចននិកតិ-

សាចិយោគា បដិវិរតោ សមណោ គោតមោ ។ ឆេទន-

វធពន្ធនវិបរាមោសអាលោបសហសាការា បដិវិរតោ

សមណោ គោតមោតិ ។ ឥតិ វា ហិ ភិក្ខវេ បុថុជ្ជ-

នោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

ចូឡសីលំ និដ្ឋិតំ ។

ឆបោកដោយភាជន៍មាស ឆបោកដោយរង្វាស់រង្វាល់(១) ។ ព្រះសមណគោតម វៀរស្រឡះចាកកិរិយាប្រកបនូវអំពើវៀច គឺការបង្ខុសបំភាន់ បញ្ឆោតបោកប្រាស បន្លំដោយរបស់បួម ។ ព្រះសមណគោតម វៀរស្រឡះចាកកិរិយាកាត់ (នូវអវៈយវៈមានដៃជាដើម) នឹងការសម្លាប់ ចងធ្វើមនុស្សឲ្យវង្វេងផ្លូវ ប្លន់អ្នកស្រុក កំហែងយកទ្រព្យ ។ បុថុជ្ជន កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។

ចប់ ចូឡសីល ។

---

១ ការឆបោកឬបន្លំដោយជញ្ជីងមាន ៤ យ៉ាង គឺបន្លំដោយរូប ១ បន្លំដោយអវយវៈ ១ បន្លំដោយការកាន់យក ១ បន្លំដោយការបិទបាំង ១ ។ អធិប្បាយ បុគ្គលធ្វើជញ្ជីងពីរមានរូបប៉ុនគ្នាដូចគ្នាតែធ្ងន់ស្រាលជាងគ្នា វេលាទិញប្រើជញ្ជីងធ្ងន់ វេលាលក់ប្រើជញ្ជីងស្រាល ហៅថា បន្លំដោយរូបគឺរូបជញ្ជីង ។ វេលាទិញ ថ្លឹងរបស់យកដៃសង្កត់ជញ្ជីងពីខាងក្រោយ វេលាលក់យកដៃសង្កត់ជញ្ជីងពីខាងមុខហៅថា បន្លំដោយអវយវៈគឺដៃ ។ វេលាទិញ ថ្លឹងរបស់កាន់ខ្សែជញ្ជីងខាងគល់ដង វេលាលក់ កាន់ខ្សែខាងចុងដង ហៅថា បន្លំដោយការកាន់យក ។ ធ្វើដងជញ្ជីងឲ្យមានប្រហោងខាងក្នុង ហើយច្រកកំទេចដែកក្នុងប្រហោងនោះ វេលាទិញ ធ្វើឲ្យដែករត់មកខាងក្រោយ វេលាលក់ ធ្វើឲ្យដែករត់មកខាងមុខ ហៅថា បន្លំដោយការបិទបាំង ។ ធ្វើភាជន៍ដោយមាសសុទ្ធតែ ១ ហើយធ្វើភាជន៍ក្រឡៃជាច្រើន ឲ្យមានពណ៌ប្រហែលគ្នាហើយលក់យកថ្លៃស្មើគ្នានឹងមាស ហៅថា បន្លំដោយមាស ។ វេលាទិញ ប្រើរង្វាល់ធំ វេលាលក់ប្រើរង្វាល់តូច ហៅថា បន្លំដោយរង្វាល់ ។ វេលាបានសំណូក វាស់ដីស្រែចម្ការធំឲ្យទៅជាតូច វេលាមិនបានសំណូកវាស់ដីតូចឲ្យទៅជាធំ ដើម្បីឲ្យបំរើនពន្ធ ឬស្ទួយហៅថាបន្លំដោយរង្វាស់ ។

(៩) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ ពីជគាមភូតគាមសមារម្ភំ អនុយុត្តា វិហរន្តិ ។ សេយ្យថីទំ ។ មូលពីជំ ខន្ធពីជំ ផលុពីជំ អគ្គពីជំ ពីជពីជមេវ បញ្ចមំ ឥតិ វា ។ ឥតិ ឯវរូបា ពីជគាមភូតគាមសមារម្ភា បដិវិរតោ សមណោ គោតមោតិ ។ ឥតិ វា ហិ ភិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

(១០) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ សន្និធិការបរិភោគំ[១] អនុយុត្តា វិហរន្តិ ។ សេយ្យថីទំ ។ អន្នសន្និធិំ[២] បានសន្និធិំ វត្ថសន្និធិំ យានសន្និធិំ សយនសន្និធិំ វិលេបនសន្និធិំ គន្ធសន្និធិំ អាមិសសន្និធិំ ឥតិ វា ។ ឥតិ ឯវរូបា សន្និធិការបរិភោគា បដិវិរតោ សមណោ គោតមោតិ ។ ឥតិ វា ហិ ភិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

---

១ សន្និធិការបរិភោគន្តិបិ បា.ហ. ។ ២ អន្នសន្និធិន្តិបិ អន្នសន្និធីតិបិ ទិស្សតិ ។

(៩) ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ដ៏ចំរើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយ ៗ នូវកិរិយាធ្វើពីជគាមនឹងភូតគាមឲ្យវិនាស ៗ ពីជគាមនឹងភូតគាមនោះ តើដូចម្តេចខ្លះ ៗ គឺ ពូជគឺមើម ឬឫស ១ ពូជគឺដើម ១ ពូជគឺថ្នាំង ១ ពូជគឺចុង ឬត្រួយ ១ ពូជគឺគ្រាប់ ១ ជាគំរប់ ៥ ៗ ព្រះសមណគោតម ទ្រង់វៀរស្រឡះចាកកិរិយាធ្វើពីជគាមនឹងភូតគាមឲ្យវិនាស មានសភាពដូច្នេះ ៗ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនកាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ៗ

(១០) ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ដ៏ចំរើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយ ៗ នូវការបរិភោគវត្ថុដែលសន្សំទុក មានសភាពយ៉ាងនេះ ៗ ការសន្សំទុកនោះ តើដូចម្តេចខ្លះ ៗ គឺ ការសន្សំគ្រឿងស៊ីខ្លះ សន្សំទឹកផឹកខ្លះ សន្សំសំពត់ខ្លះ សន្សំយានខ្លះ សន្សំទីដេកខ្លះ សន្សំគ្រឿងលាបខ្លះ សន្សំគ្រឿងក្រអូបខ្លះ សន្សំសាមិសៈខ្លះ ៗ ព្រះសមណគោតម ទ្រង់វៀរស្រឡះចាកការបរិភោគវត្ថុដែលសន្សំទុក មានសភាពដូច្នេះឯង ៗ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនកាលពោលសរសើរគុណ របស់តថាគត តែងពោលដូច្នេះក៏មាន ៗ

(១១) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ វិសូកទស្សនំ អនុយុត្តា វិហរន្តិ ។ សេយ្យថីទំ ។ នច្ចំ គីតំ វាទិតំ បេក្ខំ អក្ខានំ បាណិស្សរំ វេតាឡំ កុម្ភថូណំ សោភនករកំ(១) ចណ្ឌាលំ វំសំ ធោវនំ ហត្ថិយុទ្ធំ អស្សយុទ្ធំ មហិំសយុទ្ធំ ឧសភយុទ្ធំ អជយុទ្ធំ មេណ្ឌយុទ្ធំ កុក្កុដយុទ្ធំ វដ្ដកយុទ្ធំ ទណ្ឌយុទ្ធំ មុដ្ឋិយុទ្ធំ និព្ពុទ្ធំ ឧយ្យោធិកំ ពលគ្គំ សេនាព្យូហំ អនីកទស្សនំ ឥតិ វា ។ ឥតិ ឯវរូបា វិសូកទស្សនា បដិវិរតោ សមណោ គោតមោតិ ។ ឥតិ វា ហិ ភិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

---

១ សោភនខន្ធករកន្តិបិ សោភណគរកន្តិបិ សោភណករណន្តិបិ សោភណកន្តិបិ បាឋន្តរំ ។

(១១) ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ដ៏ចំរើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយ ៗ នូវការស្តាប់នឹងការមើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌ មានសភាពយ៉ាងនេះ ។ ឯល្បែងដែលជាសត្រូវដល់កុសលធម៌នោះតើដូចម្តេចខ្លះ ។ គឺល្បែងរាំខ្លះ ច្រៀងខ្លះ ប្រគំខ្លះ មហោស្រពខ្លះ បម្យាំងស្តេចភារតនឹងព្រះរាមជាដើមខ្លះ គងខ្លះ រគាំងខ្លះ ស្គរមានជើង ៤ ខ្លះ រូបគំនូរខ្លះ ល្បែងដុំដែកខ្លះ ល្បែងរ៉ាខ្លះ ល្បែងលាងឆ្អឹងខ្លះ ដំរីជល់គ្នាខ្លះ សេះប្រខាំគ្នាខ្លះ ក្របីជល់គ្នាខ្លះ គោជល់គ្នាខ្លះ ពពែជល់គ្នាខ្លះ កែះជល់គ្នាខ្លះ មាន់ជល់គ្នាខ្លះ ចាបជល់គ្នាខ្លះ ល្បែងគុណដំបងខ្លះ ប្រដាល់ខ្លះ ចំបាប់ខ្លះ ទីសម្រាប់ច្បាំងគ្នាខ្លះ ទីសម្រាប់រៀបពលខ្លះ លំនៅកងទ័ពខ្លះ ទីមើលសេនាប្រកបដោយអង្គ ៤ ខ្លះ(១) ។ ឯព្រះសមណមគោតម ទ្រង់វៀរស្រឡះចាកកិរិយាស្តាប់នឹងការមើលល្បែង ដែលជាសត្រូវដល់កុសលធម៌ មានសភាពដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។

---

១ សេនាដំរី ១ សេនាសេះ ១ សេនារទេះ ១ សេនាថ្មើរជើង ១ ។

[១៤] យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ ជូតប្បមាទដ្ឋានានុយោគមនុយុត្តា វិហរន្តិ ។ សេយ្យថីទំ ។ អដ្ឋបទំ ទសបទំ អាកាសំ បរិហារបថំ សន្តិកំ ខលិកំ(១) ឃដិកំ សលាកហត្ថំ អក្ខំ បង្គចីរំ វង្កកំ មោក្ខចិកំ ចិង្គុលិកំ(២) បត្តាឡ្ហកំ រថកំ ធនុកំ អក្ខលិកំ មនេសិកំ(៣) យថាវជ្ជំ ឥតិ វា ។ ឥតិ ឯវរូបា ជូតប្បមាទដ្ឋានានុយោគា បដិវិរតោ សមណោ គោតមោតិ ។ ឥតិ វា ហិ ភិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

---

១ ឃលិកំ ។ ២ ចិង្គុលកំ ។ ៣ មានេសិកំ ។

## ព្រហ្មជាលសូត្រ បឋមសីល ការប្រកបល្បែងជាស្ថានទីតាំងនៃសេចក្តីប្រមាទ

(១៦) ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ដ៏ចំរើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយ ៗ នូវល្បែងបាស្កា ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទ ។ ល្បែងបាស្កានោះ តើដូចម្តេចខ្លះ ។ គឺបាស្កាមានក្រឡា ៨ ខ្ទះ បាស្កាមានក្រឡា ១០ ខ្ទះ បាស្កាដែលលេងឮដ៏អាកាសខ្លះ ល្បែងរេងផ្លូវ ដែលគូររេងខ្លះ ល្បែងផ្ចាត់គ្រាប់មានគ្រាប់ក្រួសជាដើមខ្លះ លេងបាស្កាក្នុងទីលានសម្រាប់លេងខ្លះ ល្បែងហ៊ឹង ឬក្លូនគោលខ្លះ ល្បែងរលាស់ទឹកលាក់ឲ្យទាយរូបខ្លះ ល្បែងអង្គញ់ខ្លះ ល្បែងប៉ីស្លឹកខ្លះ ល្បែងនង្គ័លតូចខ្លះ ល្បែងដាំដូងខ្លះ ល្បែងកង្ហារខ្លះ ល្បែងវាល់ដីខ្សាច់ (បាយឡុក បាយឡ)ខ្លះ ល្បែងរថតូចខ្លះ ល្បែងធ្នូតូចខ្លះ ល្បែងសរសេរអក្សរខ្យល់ឲ្យទាយខ្លះ ល្បែងទាយចិត្ត (ស្តេចចង់)ខ្លះ ល្បែងកំប្លែងត្រាប់គេខ្លះ ។ ឯព្រះសមណគោតម ទ្រង់វៀរស្រឡះចាកកិរិយាប្រកបរឿយ ៗ នូវល្បែងបាស្កា ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទ មានសភាពដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណ របស់តថាគត តែងពោលដូច្នេះក៏មាន ។

(១៣) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ ឧច្ចាសយនមហាសយនំ អនុយុត្តា វិហរន្តិ ។ សេយ្យថីទំ ។ អាសន្ទឹ បល្លង្កំ គោណកំ ចិត្តកំ បដិកំ បដលិកំ តូលិកំ វិកតិកំ ឧទ្ធលោមឹ(១) ឯកន្តលោមឹ កដ្ឋិស្សំ(២) កោសេយ្យំ កុត្តកំ(៣) ហត្ថត្ថរំ អស្សត្ថរំ

---

១. ឧទ្ទលោមឹ ។ ២. កដ្ដិស្សំ ។ ៣ កុដ្ដកំ ។

(១៣) ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ដ៏ចំរើនពួកមួយ បរិភោគភោជនដែលគេឲ្យ ដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយ ៗ នូវឧច្ចាសយនមហាសយនៈ (ទីដេកទីអង្គុយដ៏ខ្ពស់និងទីដេកទីអង្គុយដ៏ប្រសើរ) មានសភាពយ៉ាងនេះ ៗ ឧច្ចាសយន-មហាសយនៈនោះតើដូចម្តេចខ្លះ ៗ គឺ អាសនៈដែលខ្ពស់ហួសប្រមាណខ្លះ គ្រែដែលមានជើងវិចិត្រដោយរូបសត្វសាហាវខ្លះ ព្រំដែលមានរោមវែងជាងបួនធ្នាប់ខ្លះ កម្រាលដែលគេធ្វើដោយរោមវិចិត្រ ដោយរូបសត្វសា-ហាវខ្លះ កម្រាលមានពណ៌សដែលគេធ្វើដោយរោមសត្វខ្លះ កម្រាលដែលធ្វើដោយរោមសត្វមានផ្កាដេរដាសខ្លះ កម្រាលដែលញាត់ដោយសំឡីជាប្រក្រតីខ្លះ កម្រាលដែលធ្វើដោយរោមសត្វ វិចិត្រដោយរូបសត្វសាហាវ (មានសីហៈនិងខ្លាធំជាដើម)ខ្លះ កម្រាលដែលធ្វើដោយរោមសត្វមានរោមប្រាងឡើងតែម្ខាងខ្លះ កម្រាលដែលធ្វើដោយរោមសត្វ មានរោមប្រាងឡើងទាំងសងខាងខ្លះ កម្រាលដែលធ្វើដោយឱនខ្សែស្រយមាស និងសូត្រ ចាក់ស្រេះដោយរតនវត្ថុ មានមាសជាដើមខ្លះ កម្រាលដែលធ្វើដោយសរសៃសូត្រ ចាក់ស្រេះដោយរតនៈខ្លះ កម្រាលដែលធ្វើដោយរោមសត្វ ល្មមចុះពួកស្រីរាំ ១៦ នាក់ឈររាំបានខ្លះ កម្រាលសម្រាប់ក្រាលលើខ្នងដំរីខ្លះ កម្រាលសម្រាប់ក្រាលលើខ្នងសេះខ្លះ កម្រាលសម្រាប់ក្រាល

រថត្ថរំ[១] អជិនប្បវេណឹ កាទលិមិគបវរប្បច្ចត្ថរណំ ស-

ឧត្តរច្ឆទំ ឧភតោលោហិតកូបធានំ ឥតិ វា ។ ឥតិ ឯវ-

រូបា ឧច្ចាសយនមហាសយនា បដិវិរតោ សមណោ

គោតមោតិ ។ ឥតិ វា ហិ ភិក្ខវេ បុថុជ្ជនោ តថា-

គតស្ស វណ្ណំ វទមានោ វទេយ្យ ។

(១៨) យថា វា បនេកេ ភោន្តោ សមណព្រាហ្ម-

ណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ

មណ្ឌនវិភូសនដ្ឋានានុយោគំ អនុយុត្តា វិហរន្តិ ។ សេយ្យ-

ថីទំ ។ ឧច្ឆាទនំ បរិមទ្ទនំ នហាបនំ សម្ពាហនំ អាទាសំ

អញ្ជនំ មាលា វិលេបនំ មុខចុណ្ណកំ មុខាលេបំ[២]

ហត្ថពន្ធំ សិខាពន្ធំ ទណ្ឌំ នាឡិកំ អសឹ ខគ្គំ ឆត្តំ

១ ម. ហត្ថត្ថរណំ អស្សត្ថរណំ រថត្ថរណំ ។ ២ ឱ. ម. មុខាលេបនំ ។

ព្រហ្មជាលសូត្រ មជ្ឈិមសីល ការប្រកបនូវវត្ថុជាទីតាំងនៃការស្អិតស្អាងរាងកាយ

លើរថខ្លះ កម្រាលដែលគេធ្វើដោយស្បែកខ្លាខ្លះ កម្រាលដ៏ឧត្តមដែលគេធ្វើដោយស្បែកសត្វឈ្លូសខ្លះ ទីដេកដែលមានពិតានក្រហមពីខាងលើខ្លះ ខ្នើយមានពណ៌ក្រហមទាំងពីរខាង គឺខ្នើយក្បាលនឹងខ្នើយជើងព្រមទាំងពិតានមានពណ៌ក្រហមខ្លះ ។ ឯព្រះសមណគោតម ទ្រង់វៀរស្រឡះចាកឧច្ចាសយនមហាសយនៈ មានសភាពដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។

(១៨) ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ដ៏ចំរើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះតែងប្រកបរឿយៗ នូវវត្ថុជាទីតាំងនៃការប្រដាប់ស្អិតស្អាងរាងកាយ មានសភាពយ៉ាងនេះ ។ វត្ថុជាទីតាំងនៃការប្រដាប់ស្អិតស្អាងរាងកាយនោះតើដូចម្តេច ។ គឺការផ្ទុសខាត់បំបាត់ក្លិនអាក្រក់(១)ខ្លះ ការច្របាច់រឹត(២)ខ្លះ ការផ្ងូតទឹកខ្លះ ការគក់ច្របាច់(៣)ខ្លះ កញ្ចក់ខ្លះ វត្ថុសម្រាប់លាបគ្រឿងប្រដាប់ខ្លះ ផ្កាកម្រងខ្លះ គ្រឿងលាបខ្លះ គ្រឿងលំអិតសម្រាប់ប្រស់មុខខ្លះ វត្ថុសម្រាប់លាបមុខខ្លះ គ្រឿងប្រដាប់ដៃខ្លះ បំណងផ្លងសក់ខ្លះ ដំបងខ្លះ បំពង់ថ្នាំខ្លះ ដាវខ្លះ ព្រះខាន់ខ្លះ ឆត្រខ្លះ ស្បែកជើង

---

១ អដ្ឋកថាថា ផុសខាត់ឬប្រស់ព្រំដោយវត្ថុ មានគ្រឿងក្រអូបនឹងលំអិតជាដើម ដើម្បីបន្ថោ.បង់នូវក្លិនអាក្រក់ក្នុងសរីរៈ ។ ២ ដូចយ៉ាងទារកដែលមានបុណ្យ គេយកមកផ្តេកលើភ្លៅលាបប្រេងហើយច្របាច់រឹត ដើម្បីធ្វើទ្រង់ទ្រាយនៃអវយវៈមានដៃជើងជាដើម ឲ្យសមរម្យល្អ ។

៣ ការវាយដៃជើងដោយវត្ថុមានអន្ទូងជាដើម ធ្វើឲ្យដៃជើងចំរើនមាំមួន ដូចជាអ្នកចំបាប់ ។ តែក្នុងមង្គលត្ថទីបនីថា ការដកទាញដៃជើងជាដើម ដើម្បីបន្ថោបង់នូវរោគចុកសៀត ។

ចិត្រុបាហនំ ឧណ្ហីសំ មណិំ វាលវីជនិំ ឱទាតានិ វត្ថានិ ទីឃទសានិ ឥតិ វា ។ ឥតិ ឯវរូបា មណ្ឌនវិភូសនដ្ឋានានុយោគា បដិវិរតោ សមណោ គោតមោតិ ។ ឥតិ វា ហិ ភិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

(១៥) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ តិរច្ឆានកថំ អនុយុត្តា វិហរន្តិ ។ សេយ្យថីទំ ។ រាជកថំ ចោរកថំ មហាមត្តកថំ សេនាកថំ ភយកថំ យុទ្ធកថំ អន្នកថំ បានកថំ វត្ថកថំ សយនកថំ មាលាកថំ គន្ធកថំ ញាតិកថំ យានកថំ គាមកថំ និគមកថំ នគរកថំ ជនបទកថំ ឥត្ថីកថំ បុរិសកថំ សូរកថំ

ដំរីចិត្រខ្លះ មក្កុដប្អូកក្រាំងមុខខ្លះ (ស្នៀតសក់) កែវមណីខ្លះ ផ្ចិតធ្វើពីរោមកន្ទុយសត្វខ្លះ សំពត់សខ្លះ សំពត់មានជាយវែងខ្លះ ៗ ឯព្រះសមណគោតមទ្រង់វៀរស្រឡះចាកការប្រកបរឿយ ៗ នូវវត្ថុជាទីតាំងនៃការប្រដាប់ស្អិតស្អាងរាងកាយ មានសភាពដូច្នេះឯង ៗ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនកាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ៗ

(១៩) ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយ ៗ នូវតិរច្ឆានកថា (ពាក្យនិយាយទទឹងផ្លូវសួគ៌ ទទឹងផ្លូវព្រះនិព្វាន) មានសភាពយ៉ាងនេះ ៗ តិរច្ឆានកថានោះតើដូចម្តេច ៗ គឺ និយាយអំពីស្តេចខ្លះ និយាយអំពីចោរខ្លះ និយាយអំពីអាមាត្រធំខ្លះ និយាយអំពីសេនាទាហានខ្លះ និយាយអំពីភ័យខ្លះ និយាយអំពីចម្បាំងខ្លះ និយាយអំពីបាយម្ហូបចំណីខ្លះ និយាយអំពីទឹកផឹកខ្លះ និយាយអំពីសំពត់ខ្លះ និយាយអំពីទីដេកខ្លះ និយាយអំពីផ្កាកម្រងខ្លះ និយាយអំពីគ្រឿងក្រអូបខ្លះ និយាយអំពីញាតិខ្លះ និយាយអំពីយានខ្លះ និយាយអំពីស្រុកខ្លះ និយាយអំពីនិគមខ្លះ និយាយអំពីនគរខ្លះ និយាយអំពីជនបទខ្លះ និយាយអំពីស្រីខ្លះ និយាយអំពីបុរសខ្លះ និយាយអំពីយោធាដែលក្លៀវក្លា[១]ខ្លះ

---

១ ក្នុងវិន័យថា សុរាកថំ និយាយអំពីសុរា ដូច្នេះវិញ ។

វិសិខាកថំ កុម្ភដ្ឋានកថំ បុព្វបេតកថំ នានត្តកថំ លោកក្ខាយិកំ សមុទ្ទក្ខាយិកំ ឥតិ ភវាភវកថំ ឥតិ វា ។ ឥតិ ឯវរូបាយ តិរច្ឆានកថាយ បដិវិរតោ សមណោ គោតមោតិ ។ ឥតិ វា ហិ ភិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

(១៦) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ វិគ្គាហិកកថំ អនុយុត្តា វិហរន្តិ ។ សេយ្យថីទំ ។ ន ត្វំ ឥមំ ធម្មវិនយំ អាជានាសិ អហំ ឥមំ ធម្មវិនយំ អាជានាមិ ។

និយាយអំពីច្រកផ្លូវខ្លះ និយាយអំពីកំពង់ទឹកខ្លះ និយាយអំពីញាតិដែលចែកឋានទៅកាន់បរលោកហើយខ្លះ និយាយអំពីពាក្យដែលឥតប្រយោជន៍មានសភាពផ្សេង ៗ ខ្លះ និយាយអំពីលោក(១)ខ្លះ និយាយអំពីរឿងដីកសមុទ្រ(២)ខ្លះ និយាយអំពីសេចក្ដីចំរើននឹងមិនចំរើន(៣)ខ្លះ ដែលជាហេតុឥតប្រយោជន៍ដូច្នេះខ្លះ ដូច្នោះខ្លះ ៗ ឯព្រះសមណគោតម ទ្រង់វៀរស្រឡះចាកតិរច្ឆានកថា មានសភាពដូច្នេះឯង ៗ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ៗ

[១៦] ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ដ៏ចំរើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយ ៗ នូវពាក្យប្រណាំងប្រជែង មានសភាពយ៉ាងនេះ ៗ ពាក្យប្រណាំងប្រជែងនោះ តើដូចម្ដេច ៗ គឺនិយាយថា អ្នកមិនមែនចេះដឹងធម៌នឹងវិន័យនេះទេ ខ្ញុំទើបបានចេះដឹងធម៌នឹងវិន័យនេះ ៗ

---

១ អដ្ឋកថា ថា និយាយប្រាប្រូវអំពីលោកថា លោកនេះអ្នកណាតាក់តែង អ្នកឯណោះតាក់តែង មួយទៀតក្អែកស ៗ ពិតមែន ព្រោះឆ្អឹងវាស កុករនាលក្រហម ៗ ពិតមែន ព្រោះឈាមវាក្រហម ដូច្នេះជាដើម ។ ២ និយាយថា សមុទ្រហេតុអ្វីបានហៅថាសាគរ បានជាហៅដូច្នោះ ព្រោះសាគរទេវតាបានជីក ជាដើម ។ ៣ មើលន័យលក្ខណៈសិក្ខាបទទី ៣ នៃរតនវគ្គ ក្នុងមហាវិភង្គ ចតុត្ថភាគ ។

កឹ ត្វំ ឥមំ ធម្មវិនយំ អាជានិស្សសិ មិច្ឆាបដិបន្នោ ត្វមសិ អហមស្មិ សម្មាបដិបន្នោ ។ សហិតំ មេ អសហិតន្តេ ។ បុរេ វចនីយំ បច្ឆា អវច ។ បច្ឆា វចនីយំ បុរេ អវច ។ អធិចិណ្ណន្តេ វិបរាវត្តំ ។ អារោបិតោ តេ វាទោ ។ និគ្គហិតោ ត្វមសិ ។ ចរ វាទប្បមោក្ខាយ និព្វេឋេហិ វា សចេ បហោសីតិ ។ ឥតិ ឯវរូបាយ វិគ្គាហិកកថាយ បដិវិរតោ សមណោ គោតមោតិ ។ ឥតិ វា ហិ ភិក្ខវេ បុថុជ្ជនោ តថាគ-តស្ស វណ្ណំ វទមានោ វទេយ្យ ។

(១៧) យថា វា បនេកេ ភោន្តោ សមណព្រាហ្ម-ណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ ទូតេយ្យបហិណគមនានុយោគំ អនុយុត្តា វិហរន្តិ ។

អ្នកនឹងបានឈ្មោះថា ចេះដឹងធម៌វិន័យនេះដូចម្ដេចបាន អ្នកជាអ្នកប្រតិ-បត្តិខុស ខ្ញុំទើបជាអ្នកប្រតិបត្តិត្រឹមត្រូវ ៗ ពាក្យរបស់ខ្ញុំទើបប្រកបដោយប្រយោជន៍ ពាក្យរបស់អ្នកមិនប្រកបដោយប្រយោជន៍ទេ ៗ សំដីដែលគេត្រូវនិយាយមុន អ្នកយកមកនិយាយក្រោយវិញ ៗ សំដីដែលគេត្រូវនិយាយក្រោយ អ្នកយកមកនិយាយមុនវិញ ៗ ពាក្យផ្ទុយអ្នកប្រព្រឹត្តមកជាយូរអង្វែងហើយ(១) ៗ ទោសក្នុងសំដីរបស់អ្នក ខ្ញុំបានលើកឡើងហើយ ៗ អ្នកជាមនុស្ស ត្រូវខ្ញុំសង្កត់សង្កិនបានហើយ ៗ អ្នកចូរទៅសិក្សាដើម្បីដោះស្រាយនូវទោសក្នុងសំដី ឬបើអ្នកអាច ចូរអ្នកដោះស្រាយឲ្យរួចទោសចុះ ៗ ឯព្រះសមណគោតម ទ្រង់វៀរស្រឡះហើយ ចាកពាក្យពោលប្រណាំងប្រជែង មានសភាពដូច្នេះឯង ៗ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មានៗ

(១៧) ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ដ៏ចំរើនពួកមួយ បរិ-ភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះរមែងប្រកបរឿយ ៗ នូវទូតកម្ម គឺនាំសំបុត្រ ឬពាក្យបណ្ដាំនៃគ្រហស្ថ ឬទៅដោយគេបញ្ជូនអំពីផ្ទះមួយទៅផ្ទះមួយ មានសភាពយ៉ាងនេះ ៗ

---

១ អដ្ឋកថាថា ពាក្យណាដែលស្ទាត់ក្អួរដោយអ្នកប្រព្រឹត្តមកជាយូរអង្វែង ពាក្យនោះខុសទាស់ផ្ទុយនឹងពាក្យយើងតែ១ម៉ាត់ អ្នកមិនដឹងឡើយ ។

សេយ្យថីទំ ។ រញ្ញំ រាជមហាមត្តានំ ខត្តិយានំ ព្រាហ្មណានំ គហបតិកានំ កុមារានំ ឥធ គច្ឆ អមុត្រ គច្ឆ ឥទំ ហរ អមុត្រ ឥទំ អាហរាតិ ។ ឥតិ ឯវរូបា ទូតេយ្យបហិណគមនានុយោគា បដិវិរតោ សមណោ គោតមោតិ ។ ឥតិ វា ហិ ភិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

(១៨) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ កុហកា ច ហោន្តិ លបកា ច នេមិត្តិកា ច និប្បេសិកា ច លាភេន ច លាភំ និជិគីសិតារោ ។ ឥតិ ឯវរូបា កុហនលបនា បដិវិរតោ សមណោ គោតមោតិ ។ ឥតិ វា ហិ ភិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

មជ្ឈិមសីលំ និដ្ឋិតំ ។

ទូតកម្មនោះតើដូចម្តេចខ្លះ ៗ គឺទៅដោយពាក្យប្រើរបស់ពួកស្តេច ពួកអាមាត្រធំនៃស្តេច ពួកក្សត្រិយ៍ ពួកព្រាហ្មណ៍ ពួកគហបតិឬពួកកុមារថា លោកចូរទៅកន្លែងនេះ លោកចូរទៅកន្លែងឯណោះ លោកចូរនាំយករបស់នេះទៅ លោកចូរនាំយករបស់នេះ ពីទីឯណោះមក ៗ ឯព្រះសមណគោតម ទ្រង់វៀរស្រឡះហើយចាកការប្រកបនូវទូតកម្ម គឺនាំសំបុត្រ ឬពាក្យបណ្តាំនៃគ្រហស្ថ ឬទៅដោយគេបញ្ជូនអំពីផ្ទះមួយទៅផ្ទះមួយ មានសភាពដូច្នេះឯង ៗ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ៗ

(១៨) ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើនពួកមួយ បរិភោគភោជន ដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះជាអ្នកកុហក គឺញុំាងគេឲ្យភាន់ប្រឡំ (ឲ្យជ្រះថ្លាដោយការប្រើប្រាស់បច្ច័យជាដើម) ខ្លះ ជាអ្នកពោលពាក្យពក់ទាក់ (នឹងគ្រហស្ថ) ខ្លះ ជាអ្នកធ្វើនិមិត្ត គឺពោលបញ្ចិតបញ្ចៀងខ្លះ ជាអ្នកជេរប្រទេចខ្លះ ជាអ្នកស្វែងរកលាភដោយលាភខ្លះ ៗ ឯព្រះសមណគោតម ទ្រង់វៀរស្រឡះហើយចាកការកុហក នឹងពាក្យពក់ទាក់ មានសភាពដូច្នេះឯង ៗ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណ របស់តថាគត តែងពោលដូច្នេះក៏មាន ៗ

ចប់ មជ្ឈិមសីល ។

(១៩) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិកំ[១] កប្បេន្តិ ។ សេយ្យថីទំ ។ អង្គំ និមិត្តំ ឧប្បាតំ សុបិនំ លក្ខណំ មូសិកច្ឆិន្នំ អគ្គិហោមំ ទព្វិហោមំ ថុសហោមំ កណហោមំ តណ្ឌុលហោមំ សប្បិហោមំ តេលហោមំ មុខហោមំ លោហិតហោមំ អង្គវិជ្ជា វត្ថុវិជ្ជា ខេត្តវិជ្ជា សិវវិជ្ជា ភូតវិជ្ជា ភូរិវិជ្ជា អហិវិជ្ជា វិសវិជ្ជា វិច្ឆិកវិជ្ជា មូសិកវិជ្ជា

១ ជីវិកត្ថិ កត្ថចិ ពោត្ថកេ ទិស្សតិ ។

(១៩) ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ដ៏ចំរើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពយ៉ាងនេះ ៗ តិរច្ឆានវិជ្ជានោះតើដូចម្តេច ៗ គឺការទាយអវយវៈខ្លះ ទាយនិមិត្ត (ហេតុ) ខ្លះ ទាយឧត្បាត គឺធ្លាក់ចុះនៃហេតុធំ ៗ មានរន្ទះបាញ់ជាដើមខ្លះ ទាយយល់សប្តិខ្លះ ទាយលក្ខណៈខ្លះ ទាយតែមានសំពត់ជាដើម ដែលកណ្តុរកាត់ខ្លះ និយាយអំពីការបូជាដោយភ្លើងខ្លះ និយាយអំពីការបូជាដោយវែក(១)ខ្លះ និយាយអំពីការបូជាដោយអង្កាមខ្លះ និយាយអំពីការបូជាដោយកុណ្ឌកខ្លះ និយាយអំពីការបូជាដោយអង្ករខ្លះ និយាយអំពីការបូជាដោយទឹកដោះរាវខ្លះ និយាយអំពីការបូជាដោយប្រេងខ្លះ និយាយអំពីការបូជាដោយមាត់(២)ខ្លះ និយាយអំពីការបូជាដោយឈាមខ្លះ វិជ្ជាសម្រាប់ទាយអវយវៈខ្លះ វិជ្ជាសម្រាប់ទាយទីភូមិឋាន (ថាឲ្យទុក្ខឲ្យសុខ) ខ្លះ វិជ្ជាសម្រាប់ទាយទីស្រែចម្ការខ្លះ វិជ្ជាស្គាល់ព្រៃខ្មោច(៣)ខ្លះ វិជ្ជាចាប់ខ្មោចខ្លះ វិជ្ជាសម្រាប់ការពាររក្សាភូមិផ្ទះខ្លះ វិជ្ជាស្តោះពស់(៤)ខ្លះ វិជ្ជារក្សាពិសខ្លះ វិជ្ជាស្តោះខ្ទួយទិចខ្លះ វិជ្ជាស្តោះកណ្តុរខាំខ្លះ វិជ្ជាសម្រាប់ទាយ

---

១ ប្រែថា បង្វិលពពិលក៏បាន ។ ២ អដ្ឋកថាថា យកអក់ខាំវត្ថុមានគ្រាប់ស្ពៃជាដើមយកទៅដាក់ក្នុងភ្លើង ឬ សូត្ររបៀនបូជាដោយមាត់ ។ ៣ វិជ្ជាសម្រាប់រម្ងាប់ចង្រៃដែលចូលទៅក្នុងព្រៃស្មសានហើយចេញមកវិញ ។ ៤ វិជ្ជាមើលសត្វដែលពស់ខាំឬមន្តហៅពស់ ។

សកុណវិជ្ជា វាយសវិជ្ជា បក្កជ្ឈានំ សរបរិត្តានំ មិគចក្កំ ឥតិ វា ។ ឥតិ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវា បដិវិរតោ សមណោ គោតមោតិ ។ ឥតិ វា ហិ ភិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

(២០) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិកំ កប្បេន្តិ ។ សេយ្យថីទំ ។ មណិលក្ខណំ ទណ្ឌលក្ខណំ វត្ថលក្ខណំ សត្ថលក្ខណំ [1] អសិលក្ខណំ ឧសុលក្ខណំ ធនុលក្ខណំ អាវុធលក្ខណំ ឥត្ថីលក្ខណំ បុរិសលក្ខណំ កុមារលក្ខណំ កុមារីលក្ខណំ ទាសលក្ខណំ ទាសីលក្ខណំ ហត្ថិលក្ខណំ អស្សលក្ខណំ មហិសលក្ខណំ

---

១ ឱ. សត្ថលក្ខណន្តិ ឥទំ ន ទិស្សតិ ។

សម្រែកសត្វស្លាប(១)ខ្លះ វិជ្ជាសម្រាប់ទាយសម្រែកក្អែកខ្លះ វិជ្ជាសម្រាប់ទាយអាយុខ្លះ វិជ្ជាសម្រាប់ពកាំងសរខ្លះ វិជ្ជាសម្រាប់មើលនូវស្នាមជើងម្រឹគគឺសត្វជើង ៤ ទាំងអស់ខ្លះ ៗ ឯព្រះសមណគោតម ទ្រង់វៀរស្រឡះ ហើយចាកមិច្ឆាជីវៈព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ៗ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ៗ

(២០) ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជាមានសភាពយ៉ាងនេះ ៗ តិរច្ឆានវិជ្ជានោះតើដូចម្តេច ៗ គឺ ការទាយលក្ខណៈកែវមណីខ្លះ ទាយលក្ខណៈដំបងឬឈើច្រត់ខ្លះ ទាយលក្ខណៈសំពត់ខ្លះ ទាយលក្ខណៈសស្ត្រាខ្លះ ទាយលក្ខណៈដាវខ្លះ ទាយលក្ខណៈសរខ្លះ ទាយលក្ខណៈធ្នូខ្លះ ទាយលក្ខណៈអាវុធខ្លះ ទាយលក្ខណៈស្រីខ្លះ ទាយលក្ខណៈប្រុសខ្លះ ទាយលក្ខណៈក្មេងប្រុសខ្លះ ទាយលក្ខណៈក្មេងស្រីខ្លះ ទាយលក្ខណៈខ្ញុំប្រុសខ្លះ ទាយលក្ខណៈខ្ញុំស្រីខ្លះ ទាយលក្ខណៈដំរីខ្លះ ទាយលក្ខណៈសេះខ្លះ ទាយ

---

១ វិជ្ជាសម្រាប់ទាយនូវសម្រែកនឹងគតិជាដើម របស់សត្វស្លាប ឬសត្វឥតស្លាបនឹងសត្វជើង ២ ជើង ៤ ៗ

ឧសភលក្ខណំ គោលក្ខណំ អជលក្ខណំ មេណ្ឌលក្ខណំ កុក្កុដលក្ខណំ វដ្ដកលក្ខណំ គោធាលក្ខណំ កណ្ណិកាលក្ខណំ កច្ឆបលក្ខណំ មិគលក្ខណំ ឥតិ វា ។ ឥតិ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវា បដិវិរតោ សមណោ គោតមោតិ ។ ឥតិ វា ហិ ភិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

(២១) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិកំ កប្បេន្តិ ។ សេយ្យថីទំ ។ រញ្ញំ និយ្យានំ ភវិស្សតិ ។ រញ្ញំ អនិយ្យានំ ភវិស្សតិ ។ អព្ភន្តរានំ រញ្ញំ ឧបយានំ ភវិស្សតិ ។ ពាហិរានំ រញ្ញំ អបយានំ ភវិស្សតិ ។ ពាហិរានំ រញ្ញំ ឧបយានំ ភវិស្សតិ ។ អព្ភន្តរានំ រញ្ញំ អបយានំ ភវិស្សតិ ។

លក្ខណៈក្របីខ្លះ ទាយលក្ខណៈគោឧសភខ្លះ ទាយលក្ខណៈគោខ្លះ ទាយលក្ខណៈពពែខ្លះ ទាយលក្ខណៈកែះខ្លះ ទាយលក្ខណៈមាន់ខ្លះ ទាយលក្ខណៈចាបក្រួចខ្លះ ទាយលក្ខណៈទន្សង[1]ខ្លះ ទាយលក្ខណៈគ្រឿងប្រដាប់ប្តកំពូលផ្ទះ[2]ខ្លះ ទាយលក្ខណៈអណ្តើក[3]ខ្លះ ទាយលក្ខណៈម្រឹគខ្លះ ៗ ឯព្រះសមណគោតម ទ្រង់វៀរស្រឡះចាកមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជាមានសភាពដូច្នេះឯង ៗ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ៗ

(២១) ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជាមានសភាពយ៉ាងនេះ ៗ តិរច្ឆាន-វិជ្ជានោះតើដូចម្តេច ៗ គឺទាយការលើកទ័ពថា ព្រះរាជា គួរស្តេចចេញទៅ (ក្នុងថ្ងៃនោះ) ៗ ព្រះរាជា គួរស្តេចចូលមកវិញ (ក្នុងថ្ងៃនោះ) ៗ ព្រះរាជាខាងក្នុងនឹងរុករានចូលទៅ ៗ ព្រះរាជាខាងក្រៅនឹងថយចេញទៅ ៗ ព្រះរាជាខាងក្រៅនឹងរុករានចូលមក ៗ ព្រះរាជាខាងក្នុងនឹងថយចេញទៅ ៗ

---

១ អដ្ឋកថា ថា វិជ្ជាស្គាល់លក្ខណៈរូបគំនូរនឹងគ្រឿងប្រដាប់ដាដើម ដែលគេធ្វើជារូបទន្សង ។
២ ប្រែថា ទាយលក្ខណៈនៃសត្វពួកមួយ ដែលហៅថាកណ្ណិកាក៏បាន ។ ៣ វិជ្ជាស្គាល់លក្ខណៈរូបគំនូរនឹងគ្រឿងប្រដាប់ដាដើម ដែលគេធ្វើជារូបអណ្តើក ។

អព្ភន្តរានំ រញ្ញំ ជយោ ភវិស្សតិ ។ ពាហិរានំ រញ្ញំ បរាជយោ ភវិស្សតិ ។ ពាហិរានំ រញ្ញំ ជយោ ភវិស្សតិ ។ អព្ភន្តរានំ រញ្ញំ បរាជយោ ភវិស្សតិ ។ ឥតិ ឥមស្ស ជយោ ភវិស្សតិ ឥមស្ស បរាជយោ ភវិស្សតិ ឥតិ វា ។ ឥតិ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវា បដិវិរតោ សមណោ គោតមោតិ ។ ឥតិ វា ហិ ភិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

(២៦) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិកំ កប្បេន្តិ ។ សេយ្យថីទំ ។ ចន្ទគ្គាហោ ភវិស្សតិ ។ សុរិយគ្គាហោ ភវិស្សតិ ។ នក្ខត្តគ្គាហោ ភវិស្សតិ ។ ចន្ទិមសុរិយានំ បថគមនំ ភវិស្សតិ ។ ចន្ទិមសុរិយានំ ឧប្បថគមនំ ភវិស្សតិ ។ នក្ខត្តានំ បថគមនំ ភវិស្សតិ ។ នក្ខត្តានំ ឧប្បថគមនំ ភវិស្សតិ ។ ឧក្កាបាតោ ភវិស្សតិ ។ ទិសាឌាហោ ភវិស្សតិ ។ ភូមិចាលោ ភវិស្សតិ ។ ទេវទុន្ទុភិ ភវិស្សតិ ។

ព្រហ្មជាលសូត្រ មហាសីល តិរច្ឆានវិជ្ជា

ព្រះរាជាខាងក្នុងនឹងមានជ័យជំនះ ។ ព្រះរាជាខាងក្រៅនឹងបរាជ័យ ។ ព្រះរាជាខាងក្រៅនឹងមានជ័យជំនះ ។ ព្រះរាជាខាងក្នុងនឹងបរាជ័យ ។ ព្រះរាជាអង្គនេះនឹងមានជ័យជំនះ ឯព្រះរាជាអង្គនេះនឹងបរាជ័យ ។ ឯព្រះសមណគោតម ទ្រង់វៀរស្រឡះចាកមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។

(២៦) ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ដ៏ចំរើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពយ៉ាងនេះ ។ តិរច្ឆានវិជ្ជានោះតើដូចម្ដេច ។ គឺការទាយថា (ក្នុងថ្ងៃណោះ) នឹងមានចន្ទ្រគ្រាះ ។ នឹងមានសូរ្យគ្រាះ ។ នឹងមាននក្សត្រគ្រាះ គឺផ្កាយព្រះគ្រោះដើររួមចូលគ្នា ឬដើររំលងព្រះអាទិត្យព្រះចន្ទ្រ ឬផ្កាយណាមួយ ។ ព្រះចន្ទ្រព្រះអាទិត្យនឹងដើរតាមផ្លូវត្រូវគ្នា ។ ព្រះចន្ទ្រព្រះអាទិត្យនឹងដើរខុសផ្លូវគ្នា ។ ផ្កាយទាំងឡាយនឹងដើរតាមផ្លូវត្រូវគ្នា ។ ផ្កាយទាំងឡាយនឹងដើរខុសផ្លូវគ្នា ។ នឹងមានឧក្កាបាត(១) ។ នឹងកើតមានកំដៅក្នុងទិស ។ នឹងមានកម្រើកផែនដី ។ នឹងមានផ្គរលាន់ (ឥតមានភ្លៀង) ។

១ ឧក្កាបាតនោះ ប្រែថា ធ្លាក់នៃពន្លឺគប់ភ្លើង សេចក្ដីថា កាលបើអាកាសមានខ្យល់ទង្គិចគ្នាខ្លាំងក៏កើតមានពន្លឺស្មើដូចជាពន្លឺប្រទីបធ្លាក់ចុះមកអំពីអាកាស តាមលោកវោហារ ហៅថា ឧក្កាបាត ។ (លីនត្ថប្បកាសនាដីកា) ។ បុរាណ ហៅថា កេតុជំរួល សំស្ក្រឹតថា ឧល្កាបាត ។

ចន្ទិមសុរិយនក្ខត្តានំ ឧគ្គមនំ ឱគ្គមនំ សំកិលេសំ វោ-
ទានំ ភវិស្សតិ ។ ឯវំវិបាកោ ចន្ទគ្គាហោ ភវិស្សតិ ។
ឯវំវិបាកោ សុរិយគ្គាហោ ភវិស្សតិ ។ ឯវំវិបាកោ
នក្ខត្តគ្គាហោ ភវិស្សតិ ។ ឯវំវិបាកំ ចន្ទិមសុរិយានំ
បថគមនំ ភវិស្សតិ ។ ឯវំវិបាកំ ចន្ទិមសុរិយានំ ឧប្បថ-
គមនំ ភវិស្សតិ ។ ឯវំវិបាកំ នក្ខត្តានំ បថគមនំ
ភវិស្សតិ ។ ឯវំវិបាកំ នក្ខត្តានំ ឧប្បថគមនំ ភវិស្សតិ ។
ឯវំវិបាកោ ឧក្កាបាតោ ភវិស្សតិ ។ ឯវំវិបាកោ ទិសា-
ឌាហោ ភវិស្សតិ ។ ឯវំវិបាកោ ភូមិចាលោ ភវិស្សតិ ។
ឯវំវិបាកោ ទេវទុន្ទុភិ ភវិស្សតិ ។ ឯវំវិបាកំ ចន្ទិមសុ-
រិយនក្ខត្តានំ ឧគ្គមនំ ឱគ្គមនំ សំកិលេសំ វោទានំ
ភវិស្សតិ ឥតិ វា ។ ឥតិ ឯវរូបាយ តិរច្ឆានវិជ្ជាយ
មិច្ឆាជីវា បដិវិរតោ សមណោ គោតមោតិ ។ ឥតិ វា ហិ
ភិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

ព្រះចន្ទ្រ ព្រះអាទិត្យ ផ្កាយនឹងរះឡើង ឬអស្តង្គតទៅវិញ នឹងសៅហ្មង ឬផូរផង់ ៗ ចន្ទ្រគ្រាះ នឹងបណ្តាលឲ្យបានសុខទុក្ខយ៉ាងនេះ (ដល់សត្វលោក) ៗ សូរ្យគ្រាះនឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ៗ នក្សត្រគ្រាះ នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ៗ ព្រះចន្ទ្រនឹងព្រះអាទិត្យ ដើរតាមផ្លូវត្រូវគ្នា នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ៗ ព្រះចន្ទ្រនឹងព្រះអាទិត្យ ដើរខុសផ្លូវគ្នា នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ៗ ពួកផ្កាយ ដើរតាមផ្លូវត្រូវគ្នា នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ៗ ពួកផ្កាយដើរខុសផ្លូវគ្នា នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ៗ ឧក្កាបាត នឹងបណ្តាលឲ្យមានទុក្ខសុខយ៉ាងនេះ ៗ កំដៅក្នុងទិស នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ៗ ការកម្រើកផែនដី នឹងបណ្តាលឲ្យសុខទុក្ខយ៉ាងនេះ ៗ ផ្គរលាន់ (ឥតមានភ្លៀង) នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ៗ ព្រះចន្ទ្រព្រះអាទិត្យនឹងផ្កាយរះឡើង ឬអស្តង្គតទៅវិញ សៅហ្មងឬផូរផង់ នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ៗ ឯព្រះសមណគោតម ទ្រង់វៀរស្រឡះចាកមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជាមានសភាពដូច្នេះឯង ៗ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ៗ

(២៣) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិកំ កប្បេន្តិ ។ សេយ្យថីទំ ។ សុវុដ្ឋិកា(១) ភវិស្សតិ ។ ទុព្ពុដ្ឋិកា ភវិស្សតិ ។ សុភិក្ខំ ភវិស្សតិ ។ ទុព្ភិក្ខំ ភវិស្សតិ ។ ខេមំ ភវិស្សតិ ។ ភយំ ភវិស្សតិ ។ រោគោ ភវិស្សតិ ។ អារោគ្យំ ភវិស្សតិ ។ មុទ្ទា គណនា សំខានំ កាវេយ្យំ លោកាយតំ ឥតិ វា ។ ឥតិ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវា បដិវិរតោ សមណោ គោតមោតិ ។ ឥតិ វា ហិ ភិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

(២៤) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិកំ កប្បេន្តិ ។ សេយ្យថី-

១ ឱ. ម. សុពុដ្ឋិកា ។

ព្រហ្មជាលសូត្រ មហាសីល តិរច្ឆានវិជ្ជា

(២៣) ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជាមានសភាពយ៉ាងនេះ ៗ តិរច្ឆានវិជ្ជានោះតើដូចម្តេច ៗ គឺការទាយថា (ក្នុងឆ្នាំនេះ) ភ្លៀងស្រួល ៗ នឹងមានភ្លៀងធ្លាក់មិនស្រួល ៗ នឹងមានបាយសម្បូណ៌ ៗ នឹងមានបាយក្រ ៗ នឹងមានសេចក្តីក្សេមក្សាន្ត ៗ នឹងមានភ័យ ៗ នឹងមានរោគ ៗ នឹងមិនមានរោគ ៗ ការរាប់ដោយដៃទទេ ការរាប់ដោយវិធីទន្ត រាប់បូក(១) កាព្យឃ្លោង គម្ពីរលោកាយតៈ(២) ៗ ឯព្រះសមណគោតម ទ្រង់វៀរស្រឡះចាកមិច្ឆាជីវៈព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ៗ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណ របស់តថាគត តែងពោលដូច្នេះក៏មាន ៗ

(២៤) ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ដ៏ចំរើនពួកមួយ បរិភោគភោជនដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈព្រោះតិរច្ឆានវិជ្ជាមានសភាពយ៉ាងនេះៗតិរច្ឆាន-

---

១ អដ្ឋកថា ថា ការរាប់នោះ បើស្ទាត់ដល់បុគ្គលណា បុគ្គលនោះកាលបើឃើញដើមឈើក៏អាចនឹងដឹងថា ឈើនេះមានស្លឹកប៉ុណ្ណេះប៉ុណ្ណោះបាន ។ ២ គម្ពីរនិយាយថា លោកនេះអ្នកណាសាង អ្នកឯណោះសាង បានជាហៅថា ក្អែកសព្រោះឆ្អឹងវាស បានជាហៅថា កុកក្រហមព្រោះឈាមវាក្រហម ដូច្នេះជាដើម ។

នំ ។ អាវាហនំ វិវាហនំ សំវទនំ វិវទនំ សង្កិរណំ វិកិរណំ សុភគករណំ ទុព្ភគករណំ វិរុទ្ធគព្ភករណំ ជិវ្ហានិពន្ធនំ ហនុសំហននំ ហត្ថាភិជប្បនំ កណ្ណជប្បនំ អាទាសបញ្ហំ កុមារិបញ្ហំ ទេវបញ្ហំ អាទិច្ចុបដ្ឋានំ មហតុបដ្ឋានំ អព្ភុជ្ជលនំ សិរិវ្ហាយនំ ឥតិ វា ។ ឥតិ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវា បដិវិរតោ សមណោ គោតមោតិ ។ ឥតិ វា ហិ ភិក្ខវេ បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

វិជ្ជានោះតើដូចម្តេច ។ គឺវិធីរៀបអាវាហមង្គលខ្លះ(១) វិធីរៀបវិវាហមង្គលខ្លះ(២) វិធីធ្វើឲ្យព្រមព្រៀងគ្នា (ស្នេហ៍) ខ្លះ វិធីធ្វើឲ្យព្រាត់ប្រាសគ្នា (បង់ចំណែង) ខ្លះ វិធីប្រមូលទ្រព្យខ្លះ វិធីប្រកបជំនួញខ្លះ វិធីធ្វើឲ្យចូលចិត្តស្រឡាញ់គ្នា ឬធ្វើឲ្យមានសិរីខ្លះ វិធីធ្វើឲ្យស្អប់គ្នាខ្លះ វិធីធ្វើគភ៌ដែលបំរុងនឹងវិនាសមិនឲ្យវិនាសខ្លះ វិធីចងអណ្តាតឲ្យរឹងដោយមន្តខ្លះ វិធីចងចង្កាឲ្យរឹងខ្លះ វិធីសូត្ររៀនដើម្បីផ្លាស់ប្តូរដៃខ្លះ វិធីសូត្ររៀនដើម្បីមិនឲ្យឮសំឡេងដោយត្រចៀកខ្លះ(៣) ប្រស្នាកញ្ចក់ គឺមន្តខាបយកទេវតាឲ្យមកនៅនឹងកញ្ចក់ ហើយសួរប្រស្នាខ្លះ ប្រស្នាកុមារី គឺមន្តបញ្ចូលទេវតាក្នុងសរីរៈនៃកុមារីហើយសួរប្រស្នាខ្លះ ប្រស្នាទេវតា គឺមន្តបញ្ចូលទេវតាក្នុងសរីរៈនៃទាសី ហើយសួរប្រស្នាខ្លះ វិធីបម្រើព្រះអាទិត្យខ្លះ វិធីបម្រើមហាព្រហ្មខ្លះ វិធីបញ្ចេញភ្លើងអំពីមាត់ដោយមន្តខ្លះ វិធីហៅសិរីឲ្យមកឋិតក្នុងសរីរៈខ្លះ ។ ឯព្រះសមណគោតម ទ្រង់វៀរស្រឡះចាកមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនកាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។

---

១ អដ្ឋកថា ថា មាតាបិតាខាងប្រុសនាំយកនាងទារិកាអំពីត្រកូលដទៃមករៀបការឯផ្ទះរបស់ខ្លួន ហៅថាអាវាហមង្គល ។ ២ មាតាបិតាខាងស្រីរៀបចំបញ្ជូនកូនស្រីខ្លួនឲ្យទៅកាន់ត្រកូលប្តី ហៅថាវិវាហមង្គល ។ មានន័យផ្សេងទៀតថា បើស្រីមកការឯផ្ទះប្រុស ហៅថា អាវាហៈ បើប្រុស ទៅការឯផ្ទះស្រី ហៅថា វិវាហៈ ។ ៣ បុគ្គលសូត្ររៀនទោះក្នុងសាលាក្តី ចង់និយាយពាក្យណាក៏និយាយពាក្យនោះទៅ អ្នកក្តីម្ខាងស្តាប់មិនឮ ក៏មិនអាចនឹងនិយាយឆ្លើយឆ្លងបាន។

(២៩) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិកំ កប្បេន្តិ ។ សេយ្យថីទំ ។ សន្តិកម្មំ បណិធិកម្មំ ភូតិកម្មំ(១) ភូរិកម្មំ វស្សកម្មំ វោស្សកម្មំ វត្ថុកម្មំ វត្ថុបរិករណំ អាចមនំ នហាបនំ ជុហនំ វមនំ វិរេចនំ ឧទ្ធំវិរេចនំ អធោវិរេចនំ សីសវិរេចនំ កណ្ណតេលំ នេត្តប្បានំ នត្ថុកម្មំ អញ្ជនំ បច្ចញ្ជនំ សាលាកិយំ សល្លកត្តិយំ ទារកតិកិច្ឆា មូលភេសជ្ជានំ អនុប្បទានំ ឱសធីនំ បដិមោក្ខោ ឥតិ វា ឥតិ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវា បដិវិរតោ សមណោ គោតមោតិ ។ ឥតិ វា ហិ ភិក្ខវេ បុថុជ្ជនោ

---

១ ឧ. ភូតិកម្មន្តិ ឥទំ នត្ថិ ។

ព្រហ្មជាលសូត្រ មហាសីល តិរច្ឆានវិជ្ជា

(២៥) ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ដ៏ចំរើនពួកមួយ បរិភោគភោជន ដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពយ៉ាងនេះ ៗ តិរច្ឆានវិជ្ជានោះ តើដូចម្តេច ៗ គឺការបន់ស្រន់ខ្លះ លាបំណន់ខ្លះ ធ្វើមន្តសម្រាប់ការពារបិសាចខ្លះ ធ្វើមន្តសម្រាប់ការពារផ្ទះខ្លះ ធ្វើខ្ទើយឲ្យដូចជាប្រុសខ្លះ ធ្វើប្រុសឲ្យដូចជាខ្ទើយ(១) គឺក្រៀវខ្លះ ធ្វើពិធីសង់ផ្ទះលើទីដីដែលមិនធ្លាប់បានធ្វើខ្លះ ធ្វើពលិកម្មនៅទីដីសង់ផ្ទះខ្លះ ជំរះមុខឲ្យស្អាតដោយទឹកឲ្យគេខ្លះ ស្រោចទឹកបង្ហក់ប្រសិទ្ធិឲ្យគេខ្លះ បូជាភ្លើងឲ្យគេខ្លះ ផ្សំថ្នាំសម្រាប់ឲ្យក្អួតខ្លះ ផ្សំថ្នាំបញ្ចុះខ្លះ ផ្សំថ្នាំកំចាត់បង់នូវទោសខាងលើខ្លះ ផ្សំថ្នាំកំចាត់បង់នូវទោសខាងក្រោមខ្លះ ផ្សំថ្នាំកំចាត់បង់នូវទោសក្នុងក្បាលខ្លះ ស្លប្រេងសម្រាប់បន្តក់ត្រចៀកខ្លះ ស្លប្រេងសម្រាប់ស្អំភ្នែកខ្លះ ផ្សំថ្នាំសម្រាប់ហិតខ្លះ ផ្សំថ្នាំសម្រាប់លាបបង្ហាត់ខ្លះ ផ្សំថ្នាំត្រជាក់សម្រាប់លាបស្រលាបខ្លះ ធ្វើវេជ្ជកម្មរោគភ្នែកខ្លះ ធ្វើកម្មរបស់ពេទ្យខ្លះ ធ្វើពេទ្យរោគកូនក្មេងខ្លះ ដាក់ថ្នាំក្រោយឲ្យជួយកំឡាំងថ្នាំមុនខ្លះ លាងថ្នាំដើមចេញ(២)ខ្លះ ៗ ឯព្រះសមណគោតម ទ្រង់វៀរស្រឡះចាកមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ៗ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន

១ អដ្ឋកថា ថា ធ្វើថ្លុះក្ពោះដើម្បីមិនឲ្យស្រីស្រឡាញ់ក្លុលចិត្ត មិនមែនធ្វើឲ្យភេទក្លាយទេ ។

២ អដ្ឋកថា ថា កាលបើមានជម្ងឺ ដាក់ថ្នាំមានថ្នាំផ្សាជាដើមក្នុងជម្ងឺនោះ កាលបើជម្ងឺស្រួលសមគួរហើយ ក៏នាំយកថ្នាំនោះចេញ ។

តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។ ឥទំ ខោ តំ ភិក្ខវេ អប្បមត្តកំ ឱរមត្តកំ សីលមត្តកំ យេន បុថុជ្ជនោ តថាគតស្ស វណ្ណំ វទមានោ វទេយ្យ ។

មហាសីលំ និដ្ឋិតំ ។

(២៦) អត្ថិ ភិក្ខវេ អញ្ញេវ ធម្មា គម្ភីរា ទុទ្ទសា ទុរនុពោធា សន្តា បណីតា អតក្កាវចរា និបុណា បណ្ឌិតវេទនីយា យេ តថាគតោ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ យេហិ តថាគតស្ស យថាភុច្ចំ វណ្ណំ សម្មា វទមានា វទេយ្យុំ ។ កតមេ ច[១] តេ ភិក្ខវេ ធម្មា គម្ភីរា ទុទ្ទសា ទុរនុពោធា សន្តា បណីតា អតក្កាវចរា និបុណា បណ្ឌិតវេទនីយា យេ តថាគតោ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ យេហិ តថាគតស្ស យថាភុច្ចំ វណ្ណំ សម្មា វទមានា វទេយ្យុំ ។

---

១ ឱ.ម ប បន ។

កាលពោលសរសើរគុណរបស់តថាគត តែងពោលដូច្នេះក៏មាន ។ ម្នាលភិក្ខុទាំងឡាយ បុថុជ្ជន កាលពោលសរសើរគុណរបស់តថាគត តែងពោលសរសើរ ដោយគុណជាតណា គុណជាតនុ៎ះ មានប្រមាណតិច មានប្រមាណស្ដួចស្ដើង បានត្រឹមតែសីលប៉ុណ្ណោះ ។

ចប់ មហាសីល ។

(២៦) ម្នាលភិក្ខុទាំងឡាយ តថាគតធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្ដមដោយខ្លួនឯង ហើយអាចសំដែងបាននូវធម៌ទាំងឡាយណា ពួកជនកាលនិយាយសរសើរគុណ របស់តថាគតតាមសេចក្ដីពិត ដោយធម៌ទាំងឡាយណា ធម៌ទាំងឡាយនោះ ជាធម៌ជ្រាលជ្រៅដទៃអំពីសីលទាំង ៣ នោះ បុគ្គលឃើញបានដោយលំបាក ត្រាស់ដឹងបានដោយកម្រ ជាធម៌ស្ងប់រម្ងាប់ ជាធម៌ដ៏ថ្លៃថ្លា មិនជាទីស្ទង់ប្រមើលដោយសេចក្ដីត្រិះរិះ ជាធម៌ដ៏ល្អិត មានតែអ្នកប្រាជ្ញទើបដឹងបាន ។ ម្នាលភិក្ខុទាំងឡាយ តថាគតធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្ដម ដោយខ្លួនឯង ហើយអាចសំដែងបាននូវធម៌ទាំងឡាយណា ពួកជនកាលបើនិយាយសរសើរគុណ របស់តថាគតតាមសេចក្ដីពិត ដោយធម៌ទាំងឡាយណា ធម៌ទាំងឡាយនោះ ជាធម៌ជ្រាលជ្រៅ បុគ្គលឃើញបានដោយលំបាក ត្រាស់ដឹងបានដោយកម្រ ជាធម៌ស្ងប់រម្ងាប់ ជាធម៌ដ៏ថ្លៃថ្លា មិនជាទីស្ទង់ប្រមើលដោយសេចក្ដីត្រិះរិះ ជាធម៌ដ៏ល្អិត មានតែអ្នកប្រាជ្ញទើបដឹងបាន តើដូចម្ដេចខ្លះ ។

(២៧) សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា បុព្វន្តកប្បិកា បុព្វន្តានុទិដ្ឋិនោ បុព្វន្តំ អារព្ភ អនេកវិហិតានិ អធិមុត្តិបទានិ[១] អភិវទន្តិ អដ្ឋារសហិ[២] វត្ថូហិ ។ តេ ច ភោន្តោ សមណព្រាហ្មណា កិមាគម្ម កិមារព្ភ បុព្វន្តកប្បិកា បុព្វន្តានុទិដ្ឋិនោ បុព្វន្តំ អារព្ភ អនេកវិហិតានិ អធិមុត្តិបទានិ អភិវទន្តិ អដ្ឋារសហិ វត្ថូហិ ។ សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា សស្សតវាទា សស្សតំ អត្តានញ្ច លោកញ្ច បញ្ញាបេន្តិ[៣] ចតូហិ វត្ថូហិ ។ តេ ច ភោន្តោ សមណព្រាហ្មណា កិមាគម្ម កិមារព្ភ សស្សតវាទា សស្សតំ អត្តានញ្ច លោកញ្ច បញ្ញាបេន្តិ ចតូហិ វត្ថូហិ ។ ឥធ ភិក្ខវេ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា អាតប្បមន្វាយ បធានមន្វាយ អនុយោគមន្វាយ អប្បមាទមន្វាយ សម្មាមនសិការមន្វាយ តថារូបំ ចេតោសមាធិំ

---

១ ម. អធិវុត្តិបទានិ ។ ២ ម. អដ្ឋារសហិ ។ ៣ បញ្ញាបេន្តិ ។

(២៧) ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ទាំងឡាយពួកមួយ ជាអ្នកកំណត់នូវចំណែកនៃខន្ធខាងដើម មានសេចក្ដីឃើញរឿយៗនូវចំណែកនៃខន្ធខាងដើម ប្រារព្ធនូវចំណែកនៃខន្ធខាងដើម ហើយពោលនូវចំណែកនៃទិដ្ឋិទាំងឡាយច្រើនបែប ដោយហេតុ ១៨ ។ ចុះពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ដែលជាអ្នកកំណត់នូវចំណែកនៃខន្ធខាងដើម មានសេចក្ដីឃើញរឿយៗនូវចំណែកនៃខន្ធខាងដើម ប្រារព្ធនូវចំណែកនៃខន្ធខាងដើម ហើយពោលនូវចំណែកនៃទិដ្ឋិទាំងឡាយច្រើនបែប ដោយហេតុ ១៨ ព្រោះអាស្រ័យនូវអ្វី ព្រោះប្រារព្ធនូវអ្វី ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ទាំងឡាយពួកមួយ ជាសស្សតវាទ (អ្នកពោលប្រកាន់ថាទៀង) តែងបញ្ញត្តនូវខ្លួននឹងលោកថា ទៀង ដោយហេតុ ៤ យ៉ាង ។ ចុះពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាសស្សតវាទ បញ្ញត្តនូវខ្លួននឹងលោកថា ទៀង ដោយហេតុ ៤ យ៉ាង តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាសមណឬព្រាហ្មណ៍ អាស្រ័យនូវការព្យាយាមជាគ្រឿងដុតកំដៅកិលេស អាស្រ័យនូវការព្យាយាមជាគ្រឿងតំកល់មាំ អាស្រ័យនូវការព្យាយាមជាគ្រឿងប្រកបរឿយៗ អាស្រ័យនូវការមិនធ្វេសប្រហែស អាស្រ័យនូវការយកចិត្តទុកដាក់ដោយល្អ ហើយបាននូវចេតោសមាធិ តាមបែបដែល

ផុសតិ យថា សមាហិតេ ចិត្តេ (បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ) អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ សេយ្យថីទំ ។ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ តឹសម្បិ ជាតិយោ ទសបិ ជាតិយោ វីសម្បិ(១) ជាតិយោ បញ្ចបិ ជាតិយោ ចត្តាឡីសម្បិ(២) ជាតិយោ បញ្ញាសម្បិ ជាតិយោ ជាតិសតម្បិ ជាតិសហស្សម្បិ ជាតិសតសហស្សម្បិ អនេកានិបិ ជាតិសតានិ អនេកានិបិ ជាតិសហស្សានិ អនេកានិបិ ជាតិសតសហស្សានិ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ(៣) តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ សោ ឯវមាហ សស្សតោ

---

១ ឱ. វីសតិម្បិ ។ ២ ឱ. ចត្តាលីសម្បិ ។ ៣ ឧប្បាទិំ ។

(នៃចិត្តរបស់ព្រះយោគី) កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួន (បរិសុទ្ធផូរផង់មិនមានទីទួល ពោលគឺកិលេស ប្រាសចាកឧបក្កិលេស) ហើយ ក៏រលឹកបាននូវខន្ធដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនជាច្រើន ៗ ការរលឹកបាននោះដូចម្ដេច ៗ គឺរលឹកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជាតិខ្លះ ១ ពាន់ជាតិខ្លះ ១ សែនជាតិខ្លះ រលឹកបានច្រើនរយជាតិខ្លះ ច្រើនពាន់ជាតិខ្លះ ច្រើនសែនជាតិខ្លះ ដូច្នេះថា អាត្មាអញបានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណោះ លុះច្យុតចាកអត្តភាពនោះហើយបានទៅកើតក្នុងភពឯណោះ ដែលទៅកើតក្នុងភពនោះ អាត្មាអញក៏មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណោះ លុះច្យុតចាកអត្តភាពនោះហើយ ទើបបានមកកើតក្នុងភពនេះ ៗ រលឹកបាននូវខន្ធ ដែលធ្លាប់អាស្រ័យនៅ ក្នុងកាលមុនជាច្រើន ព្រមទាំងអាការ ព្រមទាំងឧទ្ទេសដូច្នេះឯង ៗ បុគ្គលនោះពោលយ៉ាងនេះថា

អត្តា ច លោកោ ច វញ្ឈោ កូដដ្ឋោ ឯសិកដ្ឋាយី ឋិតោ(១) តេ ច សត្តា សន្ធាវន្តិ សំសរន្តិ ចវន្តិ ឧបបជ្ជន្តិ អត្ថិត្វេវ សស្សតិសមំ ។ តំ កិស្ស ហេតុ ។ អហំ ហិ អាតប្បមន្វាយ បធានមន្វាយ អនុយោគមន្វាយ អប្បមាទមន្វាយ សម្មាមនសិការមន្វាយ តថារូបំ ចេតោសមាធឹ ផុសាមិ យថា សមាហិតេ ចិត្តេ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមិ ។ សេយ្យថីទំ ។ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសម្បិ ជាតិយោ តឹសម្បិ ជាតិយោ ចត្តាឡីសម្បិ ជាតិយោ បញ្ញាសម្បិ ជាតិយោ ជាតិសតម្បិ ជាតិសហស្សម្បិ ជាតិសតសហស្សម្បិ អនេកានិបិ ជាតិសតានិ អនេកានិបិ ជាតិសហស្សានិ អនេកានិបិ ជាតិសតសហស្សានិ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ

---

១ ឯកដ្ឋាយិដ្ឋិតោ ។

ខ្លួននឹងលោកជាសភាវៈទៀងទាត់ ជាសភាវៈផុតពូជ មិនឲ្យផលជាពូជតទៅ[1] (ក) តាំងនៅនឹងថ្កល់ដូចជាកំពូលភ្នំ ឬតាំងនៅនឹងថ្កល់ដូចជាសសរគោល ឯសត្វទាំងនោះតែងអន្ទោលទៅ តែងត្រាច់រង្គាត់ទៅមក តែងច្យុត តែងកើតវិញ ធម្មជាតដែលទៀងស្មើនឹងសស្សតវត្ថុ[2] ក៏មានជាប្រាកដ ៗ រឿងនោះ ព្រោះហេតុដូចម្តេច ៗ ព្រោះថា អាត្មាអញ អាស្រ័យនូវការព្យាយាមជាគ្រឿងដុតកំដៅកិលេស អាស្រ័យនូវការព្យា-យាមជាគ្រឿងតាំងកល់មាំ អាស្រ័យនូវការព្យាយាមជាគ្រឿងប្រកបរឿយ ៗ អាស្រ័យនូវសេចក្តីមិនធ្វេសប្រហែស អាស្រ័យនូវការយកចិត្តទុកដាក់ដោយល្អហើយបាននូវចេតោសមាធិ តាមបែបផែន(នៃចិត្តរបស់យោគី) កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏រលឹកបាននូវខន្ធដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនជាច្រើន ៗ ការរលឹកខន្ធបាននោះដូចម្តេច ៗ គឺរលឹកបាន ១ ជាតិ ២ ជាតិ ៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ ៤០ ជាតិ ៥០ ជាតិ ១០០ ជាតិ ១ ពាន់ជាតិ ១ សែនជាតិ ក៏បាន រលឹកឃើញច្រើនរយជាតិ ច្រើនពាន់ជាតិ ច្រើនសែនជាតិក៏បាន ដូច្នេះថា អាត្មាអញបានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ

---

១ អដ្ឋកថា ថា បុគ្គលនោះពោលបរកាត់ផលនៃគុណធម៌មានឈានជាដើម ដែលញុំាងសត្វឲ្យទៅកើតក្នុងភពមានរូបភពជាដើម ថា មិនមានដូច្នោះឡើយ គឺថាមិនមានផលជាពូជតទៅ ប្រៀបដូចសត្វបិញ្ចឹមដែលអាគ្មានកូន ឬដើមត្នោតដែលគ្មានផ្លែជាដើម ។ ២ ផែនដី ភ្នំសិនេរុ ព្រះចន្ទ្រនឹងព្រះអាទិត្យ ហៅថា សស្សតវត្ថុ ប្រែថា វត្ថុទៀង ។

ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមា-
យុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ
តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ
ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ
ចុតោ ឥធូបបន្នោតិ ។ ឥតិ សាការំ សឧទ្ទេសំ
អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមិ ។ ឥមិនាមហំ
ឯតំ ជានាមិ យថា សស្សតោ អត្តា ច លោកោ
ច វញ្ឈោ កូដដ្ឋោ ឯសិកដ្ឋាយី ឋិតោ តេ ច
សត្តា សន្ធាវន្តិ សំសរន្តិ ចវន្តិ ឧបបជ្ជន្តិ អត្ថិត្វេវ
សស្សតិសមន្តិ ។ ឥទំ ភិក្ខវេ បឋមំ ឋានំ យំ អាគម្ម
យំ អារព្ភ ឯកេ សមណព្រាហ្មណា សស្សតវាទា
សស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ។

មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណោះ លុះច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯណោះ ដែលទៅកើតក្នុងភពនោះ អាត្មាអញក៏មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណោះ លុះច្យុតចាកអត្តភាពនោះហើយ ទើបបានមកកើតក្នុងភពនេះ ៗ អាត្មាអញរលឹកបាននូវខន្ធដែលធ្លាប់អាស្រ័យនៅ ក្នុងកាលមុនជាច្រើន ព្រមទាំងអាការ ព្រមទាំងឧទ្ទេសដូច្នេះឯង ៗ ព្រោះគុណវិសេសនេះ អាត្មាអញក៏បានដឹងនូវខន្ធដែលធ្លាប់អាស្រ័យនៅ ក្នុងកាលមុនទុះ ខ្លួននិងលោកជាសភាវៈទៀងទាត់ ជាសភាវៈផុតពូជ មិនមានផលជាពូជតទៅ (អា) តាំងនៅនឹងថ្កល់ដូចជាកំពូលភ្នំ ឬតាំងនៅនឹងថ្កល់ដូចជាសសរគោល ឯសត្វទាំងនោះ តែងអន្ទោលទៅ តែងត្រាច់រង្គាត់ទៅមក តែងច្យុត តែងកើតវិញ ធម្មជាតដែលទៀងស្មើនឹងសស្សតិវត្ថុក៏មានជាប្រាកដ ៗ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ១ ដែលសមណព្រាហ្មណ៍ ពួកមួយជាសស្សតវាទ អាស្រ័យប្រារព្ធ ទើបបញ្ញត្តនូវខ្លួននិងលោកថាទៀង ៗ

(២៨) ទុតិយេ ច ភោន្តោ សមណព្រាហ្មណា កិមាគម្ម កិមារព្ភ សស្សតវាទា សស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ។ ឥធ ភិក្ខវេ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា អាតប្បមន្វាយ បធានមន្វាយ អនុយោគមន្វាយ អប្បមាទមន្វាយ សម្មាមនសិការមន្វាយ តថារូបំ ចេតោសមាធឹ ផុសតិ យថា សមាហិតេ ចិត្តេ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ សេយ្យថីទំ ។ ឯកម្បិ សំវដ្ដវិវដ្ដំ ទ្វេបិ សំវដ្ដវិវដ្ដានិ តីណិបិ សំវដ្ដវិវដ្ដានិ ចត្តារិបិ សំវដ្ដវិវដ្ដានិ បញ្ចបិ សំវដ្ដវិវដ្ដានិ ទសបិ សំវដ្ដវិវដ្ដានិ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ

(២៨) ក្នុងហេតុទី ២ ទៀតថា សមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើនជាសស្សតវាទ បញ្ញត្តនូវខ្លួននឹងលោកថា ទៀង តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាសមណៈ ឬព្រាហ្មណ៍ អាស្រ័យនូវការព្យាយាមជាគ្រឿងដុតកំដៅកិលេស អាស្រ័យនូវការព្យាយាមជាគ្រឿងតំកល់មាំ អាស្រ័យនូវការព្យាយាមជាគ្រឿងប្រកបរឿយៗ អាស្រ័យនូវសេចក្ដីមិនធ្វេសប្រហែស អាស្រ័យនូវការយកចិត្តទុកដាក់ដោយល្អ ហើយបាននូវចេតោសមាធិ តាមបែបផែន (នៃចិត្តរបស់យោគី) កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏រលឹកបាននូវខន្ធដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនជាច្រើន ៗ ការរលឹកខន្ធបាននោះដូចម្ដេច ៗ គឺរលឹកបាន ១ សំវដ្តវិវដ្តកប្ប[១] ខ្លះ ២ សំវដ្តវិវដ្តកប្បខ្លះ ៣ សំវដ្តវិវដ្តកប្បខ្លះ ៤ សំវដ្តវិវដ្តកប្បខ្លះ ៥ សំវដ្តវិវដ្តកប្បខ្លះ ១០ សំវដ្តវិវដ្តកប្បខ្លះ ដូច្នេះថា អាត្មាអញបានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណោះ លុះច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯណោះ ដែលទៅកើតក្នុងភពនោះ អាត្មាអញក៏មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ

---

១ កប្បដែលវិនាស ហៅថា សំវដ្តកប្ប កប្បដែលតាំងឡើង ហៅថា វិវដ្តកប្ប ។

ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ សោ ឯវមាហ សស្សតោ អត្តា ច លោកោ ច វញ្ឈោ កូដដ្ឋោ ឯសិកដ្ឋាយី ឋិតោ តេ ច សត្តា សន្ធាវន្តិ សំសរន្តិ ចវន្តិ ឧបបជ្ជន្តិ អត្ថិត្វេវ សស្សតិសមន្តិ ។ តំ កិស្ស ហេតុ ។ អហញ្ហិ អាតប្បមន្វាយ បធានមន្វាយ អនុយោគមន្វាយ អប្បមាទមន្វាយ សម្មាមនសិការមន្វាយ តថារូបំ ចេតោសមាធឹ ផុសាមិ យថា សមាហិតេ ចិត្តេ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមិ ។ សេយ្យថីទំ ។ ឯកម្បិ សំវដ្ដវិវដ្ដំ ទ្វេបិ សំវដ្ដវិវដ្ដានិ តីណិបិ សំវដ្ដវិវដ្ដានិ ចត្តារិបិ សំវដ្ដវិវដ្ដានិ បញ្ចបិ សំវដ្ដវិវដ្ដានិ ទសបិ សំវដ្ដវិវដ្ដានិ

មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណោះ លុះច្យុតចាកអត្តភាពនោះហើយ ទើបបានមកកើតក្នុងភពនេះ ៗ បុគ្គលនោះរលឹកបាននូវខន្ធ ដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនជាច្រើន ព្រមទាំងអាការ ព្រមទាំងឧទ្ទេសដូច្នេះឯង ៗ បុគ្គលនោះពោលយ៉ាងនេះថា ខ្លួននឹងលោកជាសភាវៈទៀងទាត់ ជាសភាវៈផុតពូជមិនមានផលជាពូជតទៅ (អា) តាំងនៅនឹងថ្កល់ដូចកំពូលភ្នំ ឬតាំងនៅនឹងថ្កល់ដូចសសរគោល ឯសត្វទាំងនោះ តែងអន្ទោលទៅ តែងត្រាច់រង្គាត់ទៅមក តែងច្យុត តែងកើតវិញ ធម្មជាតដែលទៀងស្មើនឹងសស្សតិវត្ថុ ក៏មានប្រាកដ ៗ រឿងនោះព្រោះហេតុដូចម្តេច ៗ ព្រោះថាអាត្មាអញអាស្រ័យនូវការព្យាយាម ជាគ្រឿងដុតកំដៅកិលេស អាស្រ័យនូវការព្យាយាមជាគ្រឿងតំកល់មាំ អាស្រ័យនូវការព្យាយាម ជាគ្រឿងប្រកបរឿយៗ អាស្រ័យនូវសេចក្តីមិនធ្វេសប្រហែស អាស្រ័យនូវការយកចិត្តទុកដាក់ដោយល្អ ហើយបាននូវចេតោសមាធិតាមបែបផែន (នៃចិត្តរបស់ព្រះយោគី)កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ រលឹកបាននូវខន្ធដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនជាច្រើនប្រការ ៗ ការរលឹកខន្ធបាននោះដូចម្តេច ៗ គឺរលឹកបាន ១ សំវដ្តវិវដ្តកប្បខ្លះ ២ សំវដ្តវិវដ្តកប្បខ្លះ ៣ សំវដ្ត-វិវដ្តកប្បខ្លះ ៤ សំវដ្តវិវដ្តកប្បខ្លះ ៥ សំវដ្តវិវដ្តកប្បខ្លះ ១០ សំវដ្តវិវដ្តកប្បខ្លះ

អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ ឥមិនាបហំ ឯតំ ជានាមិ យថា សស្សតោ អត្តា ច លោកោ ច វញ្ឈោ កូដដ្ឋោ ឯសិកដ្ឋាយីឋិតោ តេ ច សត្តា សន្ធាវន្តិ សំសរន្តិ ចវន្តិ ឧបបជ្ជន្តិ អត្ថិត្វេវ សស្សតិសមន្តិ ។ ឥទំ ភិក្ខវេ ទុតិយំ ឋានំ យំ អាគម្ម យំ អារព្ភ ឯកេ សមណព្រាហ្មណា សស្សតវាទា សស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ។

ដូច្នេះថា អាត្មាអញបានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណោះ លុះច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯណោះ ដែលទៅកើតក្នុងភពនោះ អាត្មាអញក៏មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណោះ លុះច្យុតចាកអត្តភាពនោះហើយ ទើបបានមកកើតក្នុងភពនេះ ។ អាត្មាអញរលឹកបាននូវខន្ធ ដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនជាច្រើន ព្រមទាំងអាការ ព្រមទាំងឧទ្ទេសដូច្នេះឯង ។ ព្រោះគុណវិសេសនេះ អាត្មាអញក៏បានដឹងនូវខន្ធ ដែលធ្លាប់អាស្រ័យនៅក្នុងកាលមុននុះ ខន្ធនឹងលោកជាសភាវៈទៀងទាត់ ជាសភាវៈផុតពូជ មិនមានផលជាពូជតទៅ តាំងនៅនឹងថ្កល់ ដូចកំពូលភ្នំ ឬតាំងនៅនឹងថ្កល់ ដូចសសរគោល ឯសត្វទាំងនោះ តែងអន្ទោលទៅ តែងត្រាច់រង្គាត់ទៅមក តែងច្យុត តែងកើតវិញ ធម្មជាតដែលទៀងស្មើនឹងសស្សតិវត្ថុ ក៏មានប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ២ ដែលសមណព្រាហ្មណ៍ពួកមួយជាសស្សតវាទ អាស្រ័យប្រារព្ធ ទើបបញ្ញត្តនូវខន្ធនឹងលោកថាទៀង ។

(២៩) តតិយេ ច ភោន្តោ សមណព្រាហ្មណា កិមាគម្ម កិមារព្ភ សស្សតវាទា សស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ។ ឥធ ភិក្ខវេ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា អាតប្បមន្វាយ បធានមន្វាយ អនុយោគមន្វាយ អប្បមាទមន្វាយ សម្មាមនសិការមន្វាយ តថារូបំ ចេតោសមាធឹ ផុសតិ យថា សមាហិតេ ចិត្តេ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ សេយ្យថីទំ ។ ទសបិ សំវដ្ដវិវដ្ដានិ វីសម្បិ សំវដ្ដវិវដ្ដានិ តឹសម្បិ សំវដ្ដវិវដ្ដានិ ចត្តាឡីសម្បិ សំវដ្ដវិវដ្ដានិ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ

(២៩) ក្នុងហេតុទី ៣ ទៀតថា សមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើន ជាសស្សតវាទ បញ្ញត្តនូវខ្លួននិងលោកថាទៀង តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍ អាស្រ័យនូវការព្យាយាមជាគ្រឿងដុតកំដៅកិលេស អាស្រ័យនូវការព្យាយាមជាគ្រឿងតំកល់មាំ អាស្រ័យនូវការព្យាយាម ជាគ្រឿងប្រកបរឿយ ៗ អាស្រ័យនូវសេចក្ដីមិនធ្វេសប្រហែស អាស្រ័យនូវការយកចិត្តទុកដាក់ដោយល្អ ហើយបាននូវចេតោសមាធិ តាមបែបផែន (នៃចិត្តរបស់ព្រះយោគី) កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ រលឹកបាននូវខន្ធ ដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនដ៏ច្រើន ។ ការរលឹកនូវខន្ធនោះដូចម្ដេច ។ គឺរលឹកបាន ១០ សំវដ្ដវិវដ្ដកប្បខ្លះ ២០ សំវដ្ដវិវដ្ដកប្បខ្លះ ៣០ សំវដ្ដវិវដ្ដកប្បខ្លះ ៤០ សំវដ្ដវិវដ្ដកប្បខ្លះ ដូច្នេះថា អាត្មាអញបានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណោះ លុះច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯណោះ កាលដែលទៅកើតក្នុងភពនោះ អាត្មាអញមានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណោះ លុះអាត្មាអញ

ព្រហ្មជាលសុត្តេ បុព្វន្តកប្បិកា បុព្វេនិវាសានុស្សតិ

សោ តតោ ចុតោ ឥធូបបន្នោតិ ។ ឥតិ សាការំ ស-
ឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ សោ
ឯវមាហ សស្សតោ អត្តា ច លោកោ ច វញ្ឈោ
កូដដ្ឋោ ឯសិកដ្ឋាយី ឋិតោ តេ ច សត្តា សន្ធាវន្តិ
សំសរន្តិ ចវន្តិ ឧបបជ្ជន្តិ អត្ថិត្វេវ សស្សតិសមំ ។
តំ កិស្ស ហេតុ ។ អហញ្ហិ អាតប្បមន្វាយ បធាន-
មន្វាយ អនុយោគមន្វាយ អប្បមាទមន្វាយ សម្មាមន-
សិការមន្វាយ តថារូបំ ចេតោសមាធឹ ផុសាមិ យថា
សមាហិតេ ចិត្តេ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរា-
មិ ។ សេយ្យថីទំ ។ ទសបិ សំវដ្ដវិវដ្ដានិ វីសម្បិ
សំវដ្ដវិវដ្ដានិ តឹសម្បិ សំវដ្ដវិវដ្ដានិ ចត្តាឡីសម្បិ សំ-
វដ្ដវិវដ្ដានិ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ

ច្យុតចាកអត្តភាពនោះហើយ ទើបបានមកកើតក្នុងភពនេះ ។ បុគ្គលនោះរលឹកបាននូវខន្ធ ដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនជាច្រើន ព្រមទាំងអាការព្រមទាំងឧទ្ទេសដូច្នេះឯង ។ បុគ្គលនោះក៏ពោលយ៉ាងនេះថា ខ្លួននឹងលោកជាសភាវៈទៀងទាត់ ជាសភាវៈផុតពូជ មិនមានផលជាពូជតទៅ តាំងនៅនឹងថ្កល់ ដូចកំពូលភ្នំ ឬតាំងនៅនឹងថ្កល់ ដូចសសរគោល ឯសត្វទាំងនោះ តែងអន្ទោលទៅ តែងត្រាច់រង្គាត់ទៅមក តែងច្យុត តែងកើតវិញ ធម្មជាតដែលទៀងស្មើនឹងសស្សតិវត្ថុ ក៏មានប្រាកដ ។ រឿងនោះព្រោះហេតុអ្វី ។ ព្រោះថា អាត្មាអញ អាស្រ័យនូវការព្យាយាមជាគ្រឿងដុតកំដៅកិលេស អាស្រ័យនូវការព្យាយាមជាគ្រឿងតំកល់មាំ អាស្រ័យនូវការព្យាយាមជាគ្រឿងប្រកបរឿយៗ អាស្រ័យនូវសេចក្តីមិនធ្វេសប្រហែស អាស្រ័យនូវការយកចិត្តទុកដាក់ដោយល្អ ហើយបាននូវចេតោសមាធិតាមបែបផែន (នៃចិត្តរបស់យោគី) កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួន ហើយរលឹកបាននូវខន្ធ ដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនជាច្រើន ។ ការរលឹកខន្ធបាននោះដូចម្តេច ។ គឺរលឹកបាន ១០ សំវដ្តវិវដ្តកប្បខ្លះ ២០ សំវដ្តវិវដ្តកប្បខ្លះ ៣០ សំវដ្តវិវដ្តកប្បខ្លះ ៤០ សំវដ្តវិវដ្តកប្បខ្លះ ដូច្នេះថា អាត្មាអញបានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរ

ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខ-ទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមិ ។ ឥមិនាមហំ ឯតំ ជានាមិ យថា សស្សតោ អត្តា ច លោកោ ច វញ្ឈោ កូដដ្ឋោ ឯសិកដ្ឋាយី ឋិតោ តេ ច សត្តា សន្ធាវន្តិ សំសរន្តិ ចវន្តិ ឧបបជ្ជន្តិ អត្ថិត្វេវ សស្សតិសមន្តិ ។ ឥទំ ភិក្ខវេ តតិយំ ឋានំ យំ អាគម្ម យំ អារព្ភ ឯកេ សមណ-ព្រាហ្មណា សស្សតវាទា សស្សតំ អត្តានញ្ច លោ-កញ្ច បញ្ញបេន្តិ ។

យ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណោះ លុះច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯណោះ កាលដែលកើតក្នុងភពនោះ អាត្មាអញមានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណោះ លុះច្យុតចាកអត្តភាពនោះហើយ ទើបបានមកកើតក្នុងភពនេះ ។ អាត្មាអញរលឹកបាននូវខន្ធដែលធ្លាប់អាស្រ័យនៅក្នុងកាលមុនជាច្រើន ព្រមទាំងអាការ ព្រមទាំងឧទ្ទេសដូច្នេះឯង ។ ព្រោះគុណវិសេសនេះ អាត្មាអញក៏បានដឹងនូវខន្ធដែលធ្លាប់អាស្រ័យនៅក្នុងកាលមុននុ៎ះ ខន្ធនឹងលោកជាសភាវៈទៀង ជាសភាវៈផុតត្បូង មិនមានផលជាត្បូងតទៅ តាំងនៅនឹងថ្កល់ដូចកំពូលភ្នំ ឬតាំងនៅនឹងថ្កល់ដូច សសរគោល ឯសត្វទាំងនោះ តែងអន្ទោលទៅតែងត្រាច់រង្គាត់ទៅមក តែងច្យុត តែងកើតវិញ ធម្មជាតដែលទៀងស្មើនឹងសស្សតិវត្ថុ ក៏មានប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី៣ដែលសមណព្រាហ្មណ៍ពួកមួយ ជាសស្សតវាទ អាស្រ័យប្រារព្ធ ទើបបញ្ញត្តនូវខន្ធនឹងលោកថាទៀង ។

(៣០) ចតុត្ថេ ច ភោន្តោ សមណព្រាហ្មណា កិ-
មាគម្ម កិមារព្ភ សស្សតវាទា សស្សតំ អត្តានញ្ច លោ-
កញ្ច បញ្ញបេន្តិ ។ ឥធ ភិក្ខវេ ឯកច្ចោ សមណោ វា
ព្រាហ្មណោ វា តក្កី ហោតិ វីមំសី សោ តក្កបរិយាហតំ
វីមំសានុចរិតំ សយំ បដិភាណំ ឯវមាហ សស្សតោ
អត្តា ច លោកោ ច វញ្ឈោ កូដដ្ឋោ ឯសិកដ្ឋាយី
ឋិតោ តេ ច សត្តា សន្ធាវន្តិ សំសរន្តិ ចវន្តិ ឧបបជ្ជន្តិ
អត្ថិត្វេវ សស្សតិសមន្តិ ។ ឥទំ ភិក្ខវេ ចតុត្ថំ ឋានំ យំ
អាគម្ម យំ អារព្ភ ឯកេ សមណព្រាហ្មណា សស្សត-
វាទា សស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ។ ឥមេ-
ហិ ខោ តេ ភិក្ខវេ សមណព្រាហ្មណា សស្សតវាទា
សស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ចតូហិ
វត្ថូហិ ។ យេ ហិ កេចិ ភិក្ខវេ សមណព្រាហ្មណា
សស្សតវាទា សស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ

(៣០) ក្នុងហេតុទី ៤ ទៀតថា សមណព្រាហ្មណ៍ទាំងឡាយ ដ៏ចំរើន ជាសស្សតវាទ បញ្ញត្តនូវខ្លួននឹងលោកថាទៀង ព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍ ជាអ្នកមានសេចក្ដីត្រិះរិះពិចារណា ជាប្រក្រតី បុគ្គលនោះ ពោលនូវពាក្យដែលខ្លួនស្រាវជ្រាវ បានមកដោយសេចក្ដីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការពិចារណា ជាពាក្យកើតមាន ដោយប្រាជ្ញារបស់ខ្លួនយ៉ាងនេះថា ខ្លួននឹងលោកជាសភាវៈទៀង ជាសភាវៈផុតពូជ មិនមានផលជាពូជតទៅ តាំងនៅនឹងថ្កល់ដូចកំពូលភ្នំ ឬតាំងនៅនឹងថ្កល់ដូចសសរគោល ឯសត្វទាំងនោះតែងអន្ទោលទៅ តែងត្រាច់រង្គាត់ទៅមក តែងច្យុត តែងកើតវិញ ធម្មជាតដែលទៀងស្មើនឹងសស្សតិវត្ថុ ក៏មានប្រាកដ ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ៤ ដែលសមណព្រាហ្មណ៍ទាំងឡាយពួកមួយ ជាសស្សតវាទ អាស្រ័យប្រារព្ធ ទើបបញ្ញត្តនូវខ្លួននឹងលោកថាទៀង ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ទាំងនោះជាសស្សតវាទ បញ្ញត្តនូវខ្លួននឹងលោកថាទៀង ដោយហេតុ ៤ ប្រការនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សេចក្ដីពិតថា សមណព្រាហ្មណ៍ទាំងឡាយឯណានីមួយ ជាសស្សតវាទ បញ្ញត្តនូវខ្លួននឹងលោកថាទៀង

សព្វេ តេ ឥមេហេវ ចតូហិ វត្ថូហិ ឯតេសំ វា
អញ្ញតរេន នត្ថិ ឥតោ ពហិទ្ធា ។ តយិទំ ភិក្ខវេ តថា-
គតោ បជានាតិ ឥមេ ទិដ្ឋិដ្ឋានា ឯវំគហិតា ឯវំបរាមដ្ឋា
ឯវំគតិកា ភវន្តិ ឯវំអភិសម្បរាយាតិ ។ តញ្ច តថាគតោ
បជានាតិ តតោ ច ឧត្តរិតរំ បជានាតិ តញ្ច បជានំ[១]
ន បរាមសតិ ។ អបរាមសតោ ចស្ស បច្ចត្តញ្ញេវ និព្វុតិ
វិទិតា វេទនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច
អាទីនវញ្ច និស្សរណញ្ច យថាភូតំ វិទិត្វា ។ អនុបាទា
វិមុត្តោ ភិក្ខវេ តថាគតោ ។ ឥមេ ខោ តេ ភិក្ខវេ

---

១ ជានំ ។

សមណព្រាហ្មណ៍ទាំងអស់នោះ រមែងបញ្ញត្តដោយហេតុទាំង ៤ នេះឯង ឬក៏បណ្តាហេតុទាំង ៤ នោះ ដោយហេតុណាមួយ មិនមែនមានហេតុដទៃក្រៅពីហេតុទាំង ៤ នេះទេ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតដឹងច្បាស់នូវហេតុទាំង ៤ ប្រការនោះ ដូច្នេះថា ហេតុនៃទិដ្ឋិទាំងឡាយនេះ ដែលបុគ្គលកាន់យកយ៉ាងនេះ ដែលបុគ្គលប្រកាន់ខុសយ៉ាងនេះ រមែងមានគតិយ៉ាងនេះ មានការប្រព្រឹត្តិទៅក្នុងបរលោកយ៉ាងនេះ ។ ព្រះតថាគតដឹងច្បាស់នូវទិដ្ឋិនោះផង ដឹងច្បាស់ (នូវសីលសមាធិនិងសព្វញ្ញុតញ្ញាណ) ជាគុណជាតលើសលុបជាងនោះទៅទៀតផង កាលបើដឹងច្បាស់នូវគុណ-វិសេសនោះហើយ ៗ ក៏មិនបានប្រកាន់ខុសឡើយ ។ មួយទៀតកាលបើព្រះតថាគតមិនបានប្រកាន់ខុសហើយ ក៏ដឹងនូវព្រះនិព្វានជាគ្រឿងរលត់នៃបាបមាសក្កិលេសដោយខ្លួនឯង ទាំងដឹងច្បាស់នូវហេតុដែលនាំឲ្យកើតឡើងនៃវេទនាផង នូវសេចក្តីអស់ទៅនៃវេទនាផង នូវសេចក្តីឆ្ងាញ់ពិសារបស់វេទនាផង នូវទោសរបស់វេទនាផង នូវកិរិយារលាស់ចោល នូវវេទនាផង ដោយគួរតាមពិត ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតផុតស្រឡះហើយចាកកិលេស ព្រោះមិនប្រកាន់ (នូវធម៌ណាមួយមានខន្ធជាដើម) ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតធ្វើឲ្យជាក់ច្បាស់ដោយបញ្ញា

ធម្មា គម្ភីរា ទុទ្ទសា ទុរនុពោធា សន្តា បណីតា អតក្កាវចរា និបុណា បណ្ឌិតវេទនីយា យេ តថាគតោ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ យេហិ តថាគតស្ស យថាភុច្ចំ វណ្ណំ សម្មា វទមានា វទេយ្យុំ ។

បឋមភាណវារំ ។

(៣១) សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា ឯកច្ចសស្សតិកា ឯកច្ចអសស្សតិកា ឯកច្ចំ សស្សតំ ឯកច្ចំ អសស្សតំ អត្តានញ្ច លោកញ្ច បញ្ញាបេន្តិ ចតូហិ វត្ថូហិ ។ តេ ច ភោន្តោ សមណព្រាហ្មណា កិមាគម្ម កិមារព្ភ ឯកច្ចសស្សតិកា ឯកច្ចអសស្សតិកា ឯកច្ចំ សស្សតំ ឯកច្ចំ អសស្សតំ អត្តានញ្ច លោកញ្ច បញ្ញាបេន្តិ ចតូហិ វត្ថូហិ ។ ហោតិ ខោ សោ ភិក្ខវេ សមយោ យំ កទាចិ ករហចិ ទីឃស្ស អទ្ធុនោ អច្ចយេន អយំ លោកោ សំវដ្តតិ ។

ដ៏ឧត្តម ដោយខ្លួនឯង ហើយអាចនឹងសំដែងបាន នូវធម៌ទាំងឡាយណា មួយវិញទៀត ពួកជន កាលនិយាយសរសើរគុណរបស់តថាគត តាមសេចក្ដីពិត ដោយធម៌ទាំងឡាយណា ធម៌ទាំងឡាយនោះឯង ជាធម៌ជ្រាលជ្រៅ ដែលបុគ្គលឃើញបានដោយលំបាក ត្រាស់ដឹងបានដោយកម្រ ជាធម៌ស្ងប់រម្ងាប់ ជាធម៌ដ៏ថ្លៃថ្លា មិនជាទីស្ទង់ប្រមើលដោយសេចក្ដីត្រិះរិះ ជាធម៌ដ៏ល្អិត មានតែអ្នកប្រាជ្ញ ទើបដឹងបាន ។

ចប់ បឋមភាណវារៈ ។

(៣១) ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ទាំងឡាយ ពួកមួយ ជាអ្នកប្រកបដោយឯកច្ចសស្សតឯកច្ចអសស្សតទិដ្ឋិ គឺ យល់ថា លោកពួកខ្លះទៀង លោកពួកខ្លះមិនទៀង បញ្ញត្តនូវខ្លួននឹងលោកថា ទៀងខ្លះ ថា មិនទៀងខ្លះ ដោយហេតុ៤ យ៉ាង ។ ចុះ ពួកសមណព្រាហ្មណ៍ដ៏ចំរើននោះ ជាអ្នកប្រកបដោយឯកច្ចសស្សតឯកច្ចអសស្សតទិដ្ឋិ ហើយបញ្ញត្តនូវខ្លួននឹងលោកថា ទៀងខ្លះ ថា មិនទៀងខ្លះ ដោយហេតុ៤យ៉ាងតើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ មានសម័យដែលលោកនេះ វិនាសទៅម្ដង ៗ ដោយអំណើះនៃកាលជាអង្វែងទៅ ។

សំវដ្ដមានេ លោកេ យេភុយ្យេន សត្តា អាភស្សរសំវដ្ដនិកា ហោន្តិ ។ តេ តត្ថ ហោន្តិ មនោមយា បីតិភក្ខា សយម្បភា អន្តលិក្ខចរា សុភដ្ឋាយិនោ ចិរំ ទីឃមទ្ធានំ តិដ្ឋន្តិ ។ ហោតិ ខោ សោ ភិក្ខវេ សមយោ យំ កទាចិ ករហចិ ទីឃស្ស អទ្ធុនោ អច្ចយេន អយំ លោកោ វិវដ្ដតិ ។ វិវដ្ដមានេ លោកេ សុញ្ញំ ព្រហ្មវិមានំ បាតុភវតិ ។ អថ អញ្ញតរោ សត្តោ អាយុក្ខយា វា បុញ្ញក្ខយា វា អាភស្សរកាយា ចវិត្វា សុញ្ញំ ព្រហ្មវិមានំ ឧបបជ្ជតិ ។ សោបិ តត្ថ ហោតិ មនោមយោ បីតិភក្ខោ សយម្បភោ អន្តលិក្ខចរោ សុភដ្ឋាយី ចិរំ ទីឃមទ្ធានំ តិដ្ឋតិ ។ តត្ថ តស្ស ឯកកស្ស ទីឃរត្តំ និវុសិតត្តា អនភិរតិ បរិតស្សនា ឧប្បជ្ជតិ អហោ វត អញ្ញេបិ សត្តា ឥត្ថត្តំ អាគច្ឆេយ្យុន្តិ ។ អថ អញ្ញេបិ សត្តា អាយុក្ខយា វា បុញ្ញក្ខយា វា អាភស្សរកាយា ចវិត្វា ព្រហ្មវិមានំ ឧបបជ្ជន្តិ តស្ស សត្តស្ស សហព្យតំ ។

កាលដែលលោកវិនាសទៅ ពួកសត្វច្រើនតែទៅកើតក្នុងអាភស្សរព្រហ្ម ។ ពួកសត្វដែលទៅកើតក្នុងអាភស្សរព្រហ្មនោះ ជាសត្វកើតដោយឈានចិត្ត មានបីតិជាអាហារ មានរស្មីក្នុងខ្លួនឯង ត្រាច់ទៅក្នុងអាកាសបាន ឋិតនៅក្នុងទីដ៏ល្អ តាំងនៅយូរអស់កាលជាអង្វែង(១) ។ ម្នាលភិក្ខុទាំងឡាយ មានសម័យដែលលោកនេះត្រូវកើតឡើងវិញម្តង ៗ ដោយអំណើះនៃកាលជាអង្វែងទៅ ។ កាលដែលលោកកើតឡើង វិមាននៃព្រហ្មដែលសូន្យគ្មានសត្វ ក៏កើតប្រាកដឡើងដែរ ។ គ្រានោះ មានសត្វម្នាក់ច្យុតចាកពួកអាភស្សរព្រហ្ម ព្រោះអស់អាយុ ឬអស់បុណ្យ ហើយទៅកើតក្នុងវិមាននៃព្រហ្មដែលទំនេរនោះ ។ លុះសត្វនោះបានកើតក្នុងវិមាននោះ ក៏ជាសត្វកើតដោយឈានចិត្ត មានបីតិជាអាហារ មានរស្មីក្នុងខ្លួនឯង ត្រាច់ទៅក្នុងអាកាសបាន ឋិតនៅក្នុងទីដ៏ល្អ តាំងនៅយូរអស់កាលជាអង្វែង(២)ដដែល ។ សត្វម្នាក់នោះដែលទៅកើតក្នុងវិមាននោះ ព្រោះនៅអស់កាលយូរអង្វែង ក៏មានសេចក្តីអផ្សុក អន្ទះអន្ទែងកើតឡើង ថា ដូចម្តេចហ្ន៎ នឹងបានសត្វទាំងឡាយឯទៀត មកកាន់អត្តភាព ជាព្រហ្មបែបនេះផង ។ លំដាប់នោះ សត្វទាំងឡាយឯទៀត ច្យុតចាកពួកអាភស្សរព្រហ្ម ព្រោះអស់អាយុ ឬអស់បុណ្យ ហើយមកកើតក្នុងព្រហ្មវិមាន ជាមួយគ្នានឹងសត្វនោះ ។

---

១ ក្នុងអដ្ឋកថាប្រាប់ថា អស់ ៨ កប្បយ៉ាងច្រើន ។ ២ អដ្ឋកថាប្រាប់ថា ឋិតនៅអស់ ១ កប្ប ឬ កន្លះកប្ប ។

តេបិ តត្ថ ហោន្តិ មនោមយា បីតិភក្ខា សយំបភា អន្តលិក្ខចរា សុភដ្ឋាយិនោ ចិរំ ទីឃមទ្ធានំ តិដ្ឋន្តិ ។ តត្រ ភិក្ខវេ យោ សោ សត្តោ បឋមំ ឧបបន្នោ តស្ស ឯវំ ហោតិ អហមស្មិ ព្រហ្មា មហាព្រហ្មា អភិភូ អនភិភូតោ អញ្ញទត្ថុទសោ វសវត្តី ឥស្សរោ កត្តា និម្មិតា(១) សេដ្ឋោ សជ្ជិតា(២) វសី បិតា ភូតភព្យានំ មយា ឥមេ សត្តា និម្មិតា ។ តំ កិស្ស ហេតុ ។ មមំ ហិ បុព្វេ ឯតទហោសិ អហោ វត អញ្ញេបិ សត្តា ឥត្ថត្តំ អាគច្ឆេយ្យុន្តិ ។

---

១ ម. និម្មាតា ។ ២. ម. សជ្ជិតា ។

ឯសត្វទាំងនោះ លុះកើតក្នុងព្រហ្មវិមាននោះហើយ ក៏ជាសត្វកើតដោយឈានចិត្ត មានបីតិជាអាហារ មានរស្មីក្នុងខ្លួនឯង ត្រាច់ទៅក្នុងអាកាសបាន ឋិតនៅក្នុងទីដ៏ល្អ តាំងនៅយូរ អស់កាលជាអង្វែង ៗ ម្នាលភិក្ខុទាំងឡាយ បណ្ដាសត្វទាំងនោះ សត្វណា បានទៅកើតជាដំបូង សត្វនោះ ក៏មានសេចក្ដីត្រិះរិះ យ៉ាងនេះថា អាត្មាអញជាព្រហ្ម ជាមហា. ព្រហ្ម គ្របសង្កត់លើព្រហ្មឯទៀតៗ ព្រហ្មឯទៀត មិនអាចគ្របសង្កត់លើអាត្មាអញបាន អាត្មាអញជាអ្នកឃើញហេតុសព្វគ្រប់ ជាអ្នកធ្វើជនទាំងពួង ឲ្យលុះនៅក្នុងអំណាចខ្លួនជាធំ (ក្នុងលោក) ជាអ្នកសាងលោក តាក់តែងលោក ជាចំបងជាងសត្វលោក ជាអ្នកបញ្ញត្តលោក[១] ជាអ្នកស្ទាត់ជំនាញ ជាបិតានៃពួកភូតនិងពួកភព្យៈ[២] សត្វទាំងនេះ សុទ្ធតែអាត្មាអញ តាក់តែងហើយ ៗ សេចក្ដីនោះ ព្រោះហេតុអ្វី ៗ ព្រោះថា អាត្មាអញមានសេចក្ដីត្រិះរិះ ក្នុងកាលពីដើមមក ដូច្នេះថា ធ្វើដូចម្ដេចហ្ន៎ បានពួកសត្វឯទៀតមកកាន់អត្តភាព ជាព្រហ្មបែបអញនេះផង ៗ

---

១ អ្នកឲ្យឈ្មោះសត្វលោកថា ក្សត្រិយ៍ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ គ្រហស្ថ បព្វជិតជាដើម ។

២ អដ្ឋកថាថា អណ្ឌជសត្វនឹងជលាម្ពុជសត្វ ដែលនៅក្នុងស្រោមស៊ុត ឬស្រោមគភ៌ ហៅថា ភព្យៈ ដែលកើតចេញមកហើយហៅថា ភូត ។ ចំណែកសំសេទជសត្វ ដែលកើតក្នុងខណចិត្តជាបឋមហៅថា ភព្យៈ តាំងពីខណៈចិត្តជាគំរប់ពីរទៅ ហៅថា ភូត ។ ឯឱបបាតិកសត្វវិញ ដែលកើតក្នុងឥរិយាបថជាបឋម ហៅថា ភព្យៈ តាំងអំពីឥរិយាបថជាគំរប់ពីរទៅ ហៅថា ភូត ។

ឥតិ មមំ ច មនោបណិធិ ឥមេ ច សត្តា ឥត្ថត្តំ អាគតា-តិ ។ យេបិ តេ សត្តា បច្ឆា ឧបបន្នា តេសម្បិ ឯវំ ហោតិ អយំ ខោ ភវំ ព្រហ្មា មហាព្រហ្មា អភិភូ អនភិភូតោ អញ្ញទត្ថុទសោ វសវត្តិ ឥស្សរោ កត្តា និម្មិតា សេដ្ឋោ សជ្ជិតា វសី បិតា ភូតភព្យានំ ឥមិនា មយំ ភោតា ព្រហ្មុនា និម្មិតា ។ តំ កិស្ស ហេតុ ។ ឥមញ្ហិ មយំ(១) អទ្ទសាម ឥធ បឋមំ ឧបបន្នំ មយំ បនម្ហា បច្ឆា ឧប-បន្នាតិ ។ តត្រ ភិក្ខវេ យោ សោ សត្តោ បឋមំ ឧបបន្នោ សោ ទីឃាយុកតរោ ច ហោតិ វណ្ណវន្តតរោ ច មហេសក្ខតរោ ច ។ យេ បន តេ សត្តា បច្ឆា ឧបបន្នា តេ អប្បាយុកតរា ច ហោន្តិ ទុព្វណ្ណតរា ច អប្បេសក្ខតរា ច ។ ឋានំ ខោ បនេតំ ភិក្ខវេ វិជ្ជតិ យំ អញ្ញតរោ សត្តោ តម្ហា កាយា ចវិត្វា

---

១ ឱ ឥមំ មយំ ហិ ។

កំពួកសត្វទាំងនេះ មកកាន់អត្តភាពជាព្រហ្ម ត្រូវតាមសេចក្ដីប្រាថ្នារបស់ អាត្មាអញដូច្នេះឯង ។ សត្វទាំងឡាយណា ដែលមកកើតជាខាងក្រោយ សត្វទាំងនោះឯង ក៏មានសេចក្ដីត្រិះរិះយ៉ាងនេះថា ព្រហ្មដ៏ចំរើននេះ ជាមហាព្រហ្ម គ្របសង្កត់លើព្រហ្មឯទៀត ព្រហ្មឯទៀត មិនអាចនឹងគ្របសង្កត់លើបាន ជាអ្នកឃើញហេតុសព្វគ្រប់ ជាអ្នកធ្វើជនទាំងពួង ឲ្យលុះនៅក្នុងអំណាចខ្លួន ជាឥស្សរៈក្នុងលោក ជាអ្នកសាងលោក តាក់តែងលោក ជាចំបងជាងសត្វលោក ជាអ្នកបញ្ញត្តលោក ជាអ្នកស្ទាត់ជំនាញ ជាបិតានៃពួកភូតនឹងពួកភព្យៈ យើងទាំងឡាយ ដែលព្រហ្មដ៏ចំរើននេះបានតាក់តែងហើយ ។ សេចក្ដីនោះព្រោះហេតុអ្វី ។ ព្រោះថា យើងទាំងឡាយបានឃើញព្រហ្មនេះ មកកើតក្នុងទីនេះមុន ឯយើងទាំងឡាយមកកើតខាងក្រោយ ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាសត្វទាំងនោះ សត្វណាបានទៅកើតមុនគេ សត្វនោះឯងមានអាយុវែងជាងគេផង មានសម្បុរល្អជាងគេផង មានយសសក្តិធំជាងគេផង ។ ចំណែកខាងសត្វទាំងឡាយណា ដែលទៅកើតខាងក្រោយគេ សត្វទាំងនោះមានអាយុតិចជាងគេផង មានសម្បុរអន់ជាងគេផង មានយសសក្តិតូចជាងគេផង ។ ម្នាលភិក្ខុទាំងឡាយ ហេតុនុះមានជាប្រាកដ ត្រង់ពាក្យថា សត្វណាមួយ ច្យុតចាកពួកព្រហ្មនោះ

ឥត្ថត្តំ អាគច្ឆតិ ឥត្ថត្តំ អាគតោ សមានោ អគារស្មា អនគារិយំ បព្វជតិ អគារស្មា អនគារិយំ បព្វជិតោ សមានោ អាតប្បមន្វាយ បធានមន្វាយ អនុយោគមន្វាយ អប្បមាទមន្វាយ សម្មាមនសិការមន្វាយ តថារូបំ ចេតោសមាធឹ ផុសតិ យថា សមាហិតេ ចិត្តេ តំ បុព្វេនិវាសំ អនុស្សរតិ តតោ បរំ នានុស្សរតិ[១] ។ សោ ឯវមាហ យោ ខោ សោ ភវំ ព្រហ្មា មហាព្រហ្មា អភិភូ អនភិភូតោ អញ្ញទត្ថុទសោ វសវត្តី ឥស្សរោ កត្តា និម្មិតា សេដ្ឋោ សជ្ជិតា វសី បិតា ភូតភព្យានំ យេន មយំ ភោតា ព្រហ្មុនា និម្មិតា សោ និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោ សស្សតិសមំ តថេវ ឋស្សតិ ។ យេ បន មយំ អហុម្ហា តេន ភោតា ព្រហ្មុនា និម្មិតា

---

១ ឱ. បរំ នានុស្សរតិ ។

ហើយមកកាន់អត្តភាពជាមនុស្ស លុះបានមកកាន់អត្តភាពជាមនុស្សនេះហើយ ក៏ចេញចាកផ្ទះចូលទៅកាន់ផ្នួស លុះបានចេញចាកផ្ទះចូលទៅកាន់ផ្នួសហើយ អាស្រ័យនូវការព្យាយាម ជាគ្រឿងដុតកំដៅកិលេស អាស្រ័យនូវការព្យាយាម ជាគ្រឿងដំកល់មាំ អាស្រ័យនូវការព្យាយាម ជាគ្រឿងប្រកបរឿយៗ អាស្រ័យនូវសេចក្តីមិនធ្វេសប្រហែស អាស្រ័យនូវការយកចិត្តទុកដាក់ដោយល្អ ហើយបាននូវចេតោសមាធិ តាមបែបផែន (នៃចិត្តរបស់យោគី) កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏រលឹកបាននូវខន្ធដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន កំណត់ត្រឹមតែអត្តភាពជាព្រហ្មនោះមិនអាចរលឹកបាន នូវខន្ធហួសអំពីនោះទៅទៀតឡើយ ។ សត្វនោះឯងនិយាយយ៉ាងនេះថា ព្រហ្មដ៏ចំរើនណា ជាមហាព្រហ្ម គ្របសង្កត់ (លើព្រហ្មឯទៀត) ព្រហ្មឯទៀត មិនអាចគ្របសង្កត់លើបាន ជាអ្នកឃើញហេតុសព្វគ្រប់ ជាអ្នកធ្វើជនទាំងពួង ឲ្យលុះក្នុងអំណាចខ្លួន ជាឥស្សរៈ (ក្នុងលោក) ជាអ្នកសាងលោក តាក់តែងលោក ជាចំបង (ជាងសត្វលោក) ជាអ្នកបញ្ញត្តលោក ជាអ្នកស្ទាត់ជំនាញ ជាបិតាពួកភូតនិងពួកភព្យៈយើងទាំងឡាយ ដែលព្រហ្មដ៏ចំរើនណា បានតាក់តែងហើយ ព្រហ្មនោះឯងជាអ្នកទៀងទាត់ ឋិតថេរ មានសភាពមិនប្រែប្រួល តាំងឋិតនៅស្មើដោយសស្សតិវត្ថុ ។ ឯពួកយើងដែលព្រហ្មដ៏ចំរើននោះ បានតាក់តែងហើយ

តេ មយំ អនិច្ចា អទ្ធុវា អប្បាយុកា ចវនធម្មា ឥត្ថត្តំ អាគតាតិ ។ ឥទំ ភិក្ខវេ បឋមំ ឋានំ យំ អាគម្ម យំ អារព្ភ ឯកេ សមណព្រាហ្មណា ឯកច្ចសស្សតិកា ឯកច្ចអសស្សតិកា ឯកច្ចំ សស្សតំ ឯកច្ចំ អសស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ។

(៣២) ទុតិយេ ច ភោន្តា សមណព្រាហ្មណា កិមាគម្ម កិមារព្ភ ឯកច្ចសស្សតិកា ឯកច្ចអសស្សតិកា ឯកច្ចំ សស្សតំ ឯកច្ចំ អសស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ។ សន្តិ ភិក្ខវេ ខិឌ្ឌាបទោសិកា នាម ទេវា ។ តេ អតិវេលំ ហស្សខិឌ្ឌារតិធម្មសមាបន្នា វិហរន្តិ ។ តេសំ អតិវេលំ ហស្សខិឌ្ឌារតិធម្មសមាបន្នានំ វិហរតំ សតិ បម្មុស្សតិ[១] ។ សតិយា សម្មោសា តេ ទេវា តម្ហា កាយា ចវន្តិ ។ ឋានំ ខោ បនេតំ ភិក្ខវេ វិជ្ជតិ យំ អញ្ញតរោ សត្តោ តម្ហា កាយា ចវិត្វា ឥត្ថត្តំ អាគច្ឆតិ ឥត្ថត្តំ អាគតោ សមានោ អគារស្មា អនគារិយំ បព្ពជតិ អគារស្មា

១ សម្មុស្សតិ ។

ឃើញទាំងនោះជាអ្នកមិនទៀងទាត់ទេ មានអាយុខ្លី មានកិរិយាច្យុតិទៅវិញជាធម្មតា ទើបបានមកកាន់អត្តភាពជាមនុស្សនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ១ ដែលសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយឯកច្ចសស្សតឯកច្ចអសស្សតទិដ្ឋិ អាស្រ័យ ប្រារព្ធ ទើបបញ្ញត្តនូវខ្លួននិងលោកថា ទៀងខ្លះ មិនទៀងខ្លះ ។

(៣៦) ក្នុងហេតុទី ២ ទៀតថា សមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើន ជាអ្នកប្រកបដោយឯកច្ចសស្សតឯកច្ចអសស្សតទិដ្ឋិ បញ្ញត្តនូវខ្លួននិងលោកថា ទៀងខ្លះ មិនទៀងខ្លះ នោះតើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ ពួកទេវតាឈ្មោះខិឌ្ឌាបទោសិកា (អ្នកវិនាសខ្លួនព្រោះល្បែង) ក៏មាន ។ ទេវតាទាំងនោះឯង ជាអ្នកខ្វល់ខ្វាយក្នុងល្បែងលេងសើច ត្រេកត្រអាលជាធម្មតាហួសវេលា ។ កាលបើទេវតាទាំងនោះ កំពុងតែខ្វល់ខ្វាយ ក្នុងល្បែងលេងសើច ត្រេកត្រអាលហួសវេលាហើយ ស្មារតីក៏ភ្លេចវង្វេងទៅ(ខានបរិភោគអាហារ) ។ ទេវតាទាំងនោះ ក៏ច្យុតចាកពួកទេវតានោះ ព្រោះភ្លេចស្មារតី ។ ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះមានពិតប្រាកដ ត្រង់ពាក្យថា សត្វណាមួយ ច្យុតចាកពួកទេវតានោះ ហើយមកកាន់អត្តភាពជាមនុស្សនេះ លុះបានមកកាន់អត្តភាពជាមនុស្សនេះហើយ ក៏ចេញចាកផ្ទះបួសទៅកាន់ផ្នួស លុះចេញចាកផ្ទះ

អនគារិយំ បព្វជិតោ សមណោ អាតប្បមន្វាយ បធាន-
មន្វាយ អនុយោគមន្វាយ អប្បមាទមន្វាយ សម្មាមន-
សិការមន្វាយ តថារូបំ ចេតោសមាធឹ ផុសតិ យថា
សមាហិតេ ចិត្តេ តំ បុព្វេនិវាសំ អនុស្សរតិ តតោ
បរន្នានុស្សរតិ ។ សោ ឯវមាហ យេ ខោ តេ ភោន្តោ
ទេវា ន ខិឌ្ឌាបទោសិកា តេ ន អតិវេលំ ហស្សខិឌ្ឌា-
រតិធម្មសមាបន្នា វិហរន្តិ ។ តេសំ ន អតិវេលំ ហស្ស-
ខិឌ្ឌារតិធម្មសមាបន្នានំ វិហរតំ សតិ ន បម្មុស្សតិ ។
សតិយា អសម្មោសា តេ ទេវា តម្ហា កាយា ន ចវន្តិ
និច្ចា ធុវា សស្សតា អវិបរិណាមធម្មា សស្សតិសមំ
តថេវ ឋស្សន្តិ ។ យេ បន មយំ អហុម្ហា ខិឌ្ឌាបទោ-

ចូលទៅកាន់ផ្នួសហើយ ក៏អាស្រ័យនូវការព្យាយាមជាគ្រឿងដុតកំដៅកិលេស អាស្រ័យនូវការព្យាយាមជាគ្រឿងដំកល់មាំ អាស្រ័យនូវការព្យាយាមជាគ្រឿងប្រកបរឿយៗ អាស្រ័យនូវសេចក្ដីមិនធ្វេសប្រហែស អាស្រ័យនូវការយកចិត្តទុកដាក់ដោយល្អ ហើយបាននូវចេតោសមាធិ តាមបែបផែន(នៃចិត្តរបស់យោគី) កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏រលឹកបាននូវខន្ធដែលធ្លាប់អាស្រ័យនៅ ក្នុងកាលមុន កំណត់ត្រឹមអត្តភាពជាទេវតានោះ មិនអាចនឹងរលឹកនូវខន្ធឲ្យហួសអំពីកំណត់នោះ ទៅទៀតបានឡើយ ។ សត្វនោះឯង ក៏ពោលពាក្យយ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏ចំរើន ពួកទេវតាណា មិនវិនាសខ្លួនព្រោះល្បែង ពួកទេវតានោះ ជាអ្នកមិនមានសេចក្ដីខ្វល់ខ្វាយក្នុងល្បែងលេងសើច ត្រេកត្រអាលជាធម្មតា ហួសវេលាឡើយ ៗ កាលបើពួកទេវតានោះ មិនមានសេចក្ដីខ្វល់ខ្វាយក្នុងល្បែងលេងសើច ត្រេកត្រអាលជាធម្មតា ហួសវេលាហើយ ស្មារតីមិនភ្លេចវង្វេងឡើយ ៗ ទេវតាទាំងនោះ មិនច្យុតចាកពួកទេវតានោះ ព្រោះមិនភ្លេចស្មារតីជាអ្នកទៀងទាត់ ឋិតថេរ មានសភាពមិនប្រែប្រួល ទាំងឋិតនៅដោយសស្សតិវត្ថុ ៗ ឯយើងទាំងឡាយណា ជាអ្នកវិនាសខ្លួន ព្រោះល្បែង

សិកា តេ មយំ អតិវេលំ ហស្សខិឌ្ឌារតិធម្មសមាបន្នា វិហរិម្ហា ។ តេសន្នោ អតិវេលំ ហស្សខិឌ្ឌារតិធម្មសមាបន្នានំ វិហរតំ សតិ បម្មុស្សតិ ។ សតិយា សម្មោសា ឯវំ មយំ តម្ហា កាយា ចុតា អនិច្ចា អទ្ធុវា អប្បាយុកា ចវនធម្មា ឥត្ថត្តំ អាគតាតិ ។ ឥទំ ភិក្ខវេ ទុតិយំ ឋានំ យំ អាគម្ម យំ អារព្ភ ឯកេ សមណព្រាហ្មណា ឯកច្ចសស្សតិកា ឯកច្ចអសស្សតិកា ឯកច្ចំ សស្សតំ ឯកច្ចំ អសស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ។

(៣៣) តតិយេ ច ភោន្តោ សមណព្រាហ្មណា កិមាគម្ម កិមារព្ភ ឯកច្ចសស្សតិកា ឯកច្ចអសស្សតិកា ឯកច្ចំ សស្សតំ ឯកច្ចំ អសស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ។ សន្តិ ភិក្ខវេ មនោបទោសិកា នាម ទេវា ។ តេ អតិវេលំ អញ្ញមញ្ញំ ឧបនិជ្ឈាយន្តិ ។ តេ អតិវេលំ អញ្ញមញ្ញំ ឧបនិជ្ឈាយន្តា អញ្ញមញ្ញម្ហិ ចិត្តានិ បទោសេន្តិ ។ តេ អញ្ញមញ្ញំ

យើងទាំងនោះ ជាអ្នកមានសេចក្តីខ្វល់ខ្វាយ ក្នុងល្បែងលេងសើច ត្រេកត្រអាលជាធម្មតា ហួសវេលា ។ កាលបើយើងទាំងឡាយ មានសេចក្តីខ្វល់ខ្វាយក្នុងល្បែងលេងសើច ត្រេកត្រអាលជាធម្មតា ហួសវេលា ហើយ ស្មារតីក៏ភ្លេចវង្វេងទៅ ។ ព្រោះតែភ្លេចស្មារតីយ៉ាងនេះឯង យើងទាំងឡាយដែលច្យុតចាកពួកទេវតានោះយ៉ាងនេះ ព្រោះវង្វេងស្មារតី ជាអ្នកមិនទៀងទាត់ មានអាយុក៏ខ្លី មានកិរិយាច្យុតិជាធម្មតា ទើបបានមកកាន់អត្តភាពជាមនុស្សនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ២ ដែលសមណព្រាហ្មណ៍ទាំងឡាយពួកមួយ ជាអ្នកប្រកបដោយឯកច្ចស-ស្សតឯកច្ចអសស្សតទិដ្ឋិ អាស្រ័យ ប្រារព្ធ ទើបបញ្ញត្តនូវខ្លួននឹងលោកថា ទៀងខ្លះ មិនទៀងខ្លះ ។

(៣៣) ក្នុងហេតុទី ៣ ទៀតថា សមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើន ជាអ្នកប្រកបដោយឯកច្ចសស្សតឯកច្ចអសស្សតទិដ្ឋិ បញ្ញត្តនូវខ្លួននឹងលោកថាទៀងខ្លះ ថាមិនទៀងខ្លះ តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ មានពួកទេវតាឈ្មោះមនោបទោសិកា (ព្រោះចិត្តប្រទូស្ត) ។ ពួកទេវតានោះសំឡឹងរំពៃ (រកទោស) គ្នានឹងគ្នា ហួសវេលា ។ កាលពួកទេវតានោះសំឡឹងរំពៃ (រកទោស) គ្នានឹងគ្នា ហួសវេលា ក៏ធ្វើចិត្តឲ្យប្រទូស្តដល់គ្នានឹងគ្នាទៀត ។ ពួកទេវតានោះ លុះមាន

បទុដ្ឋចិត្តា កិលន្តកាយា កិលន្តចិត្តា ។ តេ ទេវា តម្ហា កាយា ចវន្តិ ។ ឋានំ ខោ បនេតំ ភិក្ខវេ វិជ្ជតិ យំ អញ្ញតរោ សត្តោ តម្ហា កាយា ចវិត្វា ឥត្ថត្តំ អាគច្ឆតិ ឥត្ថត្តំ អាគតោ សមានោ អគារស្មា អនគា-រិយំ បព្វជតិ អគារស្មា អនគារិយំ បព្វជិតោ សមា-នោ អាតប្បមន្វាយ បធានមន្វាយ អនុយោគមន្វាយ អប្បមាទមន្វាយ សម្មាមនសិការមន្វាយ តថារូបំ ចេតោសមាធឹ ផុសតិ យថា សមាហិតេ ចិត្តេ តំ បុព្វេនិវាសំ អនុស្សរតិ តតោ បរំ នានុស្សរតិ ។ សោ ឯវមាហ យេ ខោ តេ ភោន្តោ ទេវា ន មនោបទោ-សិកា តេ នាតិវេលំ អញ្ញមញ្ញំ ឧបនិជ្ឈាយន្តិ ។ តេ នាតិវេលំ អញ្ញមញ្ញំ ឧបនិជ្ឈាយន្តា អញ្ញមញ្ញម្ហិ ចិត្តានិ នប្បទុស្សន្តិ ។ តេ អញ្ញមញ្ញំ អប្បទុដ្ឋ-ចិត្តា អកិលន្តកាយា អកិលន្តចិត្តា ។ តេ ទេវា

ចិត្តប្រទូស្តដល់គ្នានឹងគ្នាហើយ ក៏លំបាកកាយ លំបាកចិត្ត ។ ទេវតាទាំងនោះក៏ច្យុតចាកពួកទេវតានោះមក ។ ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះមានពិតប្រាកដ ត្រង់ពាក្យថា សត្វណាមួយ ច្យុតចាកពួកទេវតានោះមកកាន់អត្តភាពជាមនុស្សនេះ លុះមកកាន់អត្តភាពជាមនុស្សនេះហើយ បានចេញចាកផ្ទះចូលទៅកាន់ផ្នួស លុះចេញចាកផ្ទះចូលទៅកាន់ផ្នួសហើយ អាស្រ័យនូវការព្យាយាម ជាគ្រឿងដុតកំដៅកិលេស អាស្រ័យនូវការព្យាយាមជាគ្រឿងដំកល់មាំ អាស្រ័យនូវការព្យាយាម ជាគ្រឿងប្រកបរឿយៗ អាស្រ័យ នូវសេចក្តីមិនធ្វេសប្រហែស អាស្រ័យ នូវការយកចិត្តទុកដាក់ដោយល្អហើយបាននូវចេតោសមាធិ តាមបែបផែន (នៃចិត្តរបស់យោគី) កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏រលឹកបាននូវខន្ធដែលធ្លាប់អាស្រ័យនៅក្នុងកាលមុន កំណត់ត្រឹមអត្តភាពជាទេវតានោះ មិនអាចនឹងរលឹកឲ្យហួសអំពីកំណត់នោះទៅទៀតបានឡើយ ។ សត្វនោះក៏ពោលពាក្យយ៉ាងនេះថា ម្នាលអ្នកទាំងឡាយដ៏ចំរើន ពួកទេវតាណា មិនបានវិនាស ព្រោះចិត្តប្រទូស្ត ពួកទេវតានោះ មិនសំឡឹងរំពៃនូវគ្នានឹងគ្នាហួសវេលា ។ កាលបើពួកទេវតានោះ មិនសំឡឹងរំពៃនូវគ្នានឹងគ្នាហួសវេលាហើយ ក៏មិនធ្វើចិត្តឲ្យប្រទូស្តគ្នាឡើយ ។ លុះពួកទេវតានោះ មានចិត្តមិនបានប្រទូស្តគ្នានឹងគ្នាហើយ ក៏មិនលំបាកកាយមិនលំបាកចិត្តឡើយ ។ ទេវតាទាំងនោះ

តម្ហា កាយា ន ចវន្តិ និច្ចា ធុវា សស្សតា អវិបរិណាមធម្មា សស្សតិសមំ តថេវ ឋស្សន្តិ ។ យេ បន មយំ អហុម្ហា មនោបទោសិកា តេ មយំ អតិវេលំ អញ្ញមញ្ញំ ឧបនិជ្ឈាយិម្ហា ។ តេ មយំ អតិវេលំ អញ្ញមញ្ញំ ឧបនិជ្ឈាយន្តា អញ្ញមញ្ញម្ហិ ចិត្តានិ បទោសិម្ហា ។ តេ មយំ អញ្ញមញ្ញំ បទុដ្ឋចិត្តា កិលន្តកាយា កិលន្តចិត្តា ។ ឯវំ មយំ តម្ហា កាយា ចុតា អនិច្ចា អទ្ធុវា អប្បាយុកា ចវនធម្មា ឥត្ថត្តំ អាគតាតិ ។ ឥទំ ភិក្ខវេ តតិយំ ឋានំ យំ អាគម្ម យំ អារព្ភ ឯកេ សមណព្រាហ្មណា ឯកច្ចសស្សតិកា ឯកច្ចអសស្សតិកា ឯកច្ចំ សស្សតំ ឯកច្ចំ អសស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ។

(៣៦) ចតុត្ថេ ច ភោន្តោ សមណព្រាហ្មណា កិមាគម្ម កិមារព្ភ ឯកច្ចសស្សតិកា ឯកច្ចអសស្សតិកា ឯកច្ចំ សស្សតំ ឯកច្ចំ អសស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ។ ឥធ ភិក្ខវេ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា តក្កី ហោតិ វីមំសី ។ សោ តក្កប-

មិនបានច្យុតចាកពួកទេវតានោះទេ ជាអ្នកទៀងទាត់ ឋិតថេរ មានសភាពមិនប្រែប្រួលឡើយ នឹងឋិតនៅស្មើដោយសស្សតិវត្ថុ ។ ចំណែកខាងយើងដែលជាអ្នកវិនាសខ្លួនព្រោះចិត្តប្រទូស្ត យើងទាំងនោះសំឡឹងរំពៃគ្នានឹងគ្នាហួសវេលា ។ យើងទាំងឡាយនោះ កាលសំឡឹងរំពៃនូវគ្នានឹងគ្នាហួសវេលាហើយ ក៏ធ្វើចិត្តឲ្យប្រទូស្តគ្នានឹងគ្នា ។ លុះយើងទាំងឡាយនោះ មានចិត្តប្រទូស្តគ្នានឹងគ្នាហើយ ក៏លំបាកកាយ លំបាកចិត្ត ។ យើងទាំងឡាយដែលច្យុតចាកពួកទេវតានោះយ៉ាងនេះហើយ ជាអ្នកមិនទៀងទាត់ មានអាយុខ្លី មានកិរិយាច្យុតិជាធម្មតា ទើបបានមកកាន់អត្តភាពជាមនុស្សនេះ ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ៣ ដែលសមណព្រាហ្មណ៍ទាំងឡាយពួកមួយ ជាអ្នកប្រកបដោយឯកច្ចសស្សតឯកច្ចអសស្សតទិដ្ឋិ អាស្រ័យ ប្រារព្ធ ទើបបញ្ញត្តនូវខ្លួននឹងលោកថា ទៀងខ្លះ មិនទៀងខ្លះ ។

(៣៤) ក្នុងហេតុទី ៤ ទៀតថា សមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើន ជាអ្នកប្រកប ដោយឯកច្ចសស្សតឯកច្ចអសស្សតទិដ្ឋិ បញ្ញត្តនូវខ្លួននឹងលោកថា ទៀងខ្លះ មិនទៀងខ្លះ តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍ មានសេចក្តីត្រិះរិះ ពិចារណាជាប្រក្រតី ។ បុគ្គលនោះក៏ពោលនូវពាក្យ

ព្រហ្មជាលសុត្តំ បុព្វន្តកប្បិកា ចត្តារិ វត្ថូនិ

រិយាហតំ វិមំសានុចរិតំ សយំ បដិភាណំ(១) ឯវមាហ យំ ខោ ឥទំ វុច្ចតិ ចក្ខុន្តិបិ សោតន្តិបិ ឃានន្តិបិ ជិវ្ហាតិបិ កាយោតិបិ អយំ អត្តា អនិច្ចោ អទ្ធុវោ អសស្សតោ វិបរិណាមធម្មោ ។ យញ្ច ខោ ឥទំ វុច្ចតិ ចិត្តន្តិ វា មនោតិ វា វិញ្ញាណន្តិ វា អយំ អត្តា និច្ចោ ធុវោ សស្សតោ អវិបរិណាមធម្មោ សស្សតិសមំ តថេវ ឋស្សតីតិ ។ ឥទំ ភិក្ខវេ ចតុត្ថំ ឋានំ យំ អាគម្ម យំ អារព្ភ ឯកេ សមណព្រាហ្មណា ឯកច្ចសស្សតិកា ឯកច្ចអសស្សតិកា ឯកច្ចំ សស្សតំ ឯកច្ចំ អសស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ។ ឥមេហិ ខោ តេ ភិក្ខវេ សមណព្រាហ្មណា ឯកច្ចសស្សតិកា ឯកច្ចអសស្សតិកា ឯកច្ចំ សស្សតំ ឯកច្ចំ អសស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ចតូហិ វត្ថូហិ ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឯកច្ចសស្សតិកា ឯកច្ចអសស្សតិកា ឯកច្ចំ សស្សតំ ឯកច្ចំ អសស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ សព្វេ តេ ឥមេហេវ ចតូហិ វត្ថូហិ ឯតេសំ វា អញ្ញតរេន នត្ថិ ឥតោ ពហិទ្ធា ។

១ ខ. សយំ បដិភានំ ។

ដែលខ្លួនស្រាវជ្រាវបានមកដោយសេចក្តីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការពិចារណា ជាពាក្យកើតមានដោយប្រាជ្ញារបស់ខ្លួនយ៉ាងនេះថា ធម្ម-ជាតណាដែលហៅថា ភ្នែកខ្លះ ត្រចៀកខ្លះ ច្រមុះខ្លះ អណ្តាតខ្លះ កាយខ្លះ (ធម្មជាតនោះ) គឺខ្លួននេះឯង ជាសភាវៈមិនទៀងទាត់ មិនឋិតថេរ តែងប្រែប្រួលជាធម្មតា ។ មួយវិញទៀត ធម្មជាតណាដែលគេហៅថា ចិត្តក្តី មនោក្តី វិញ្ញាណក្តី (ធម្មជាតនោះ) គឺខ្លួននេះឯង ជាសភាវៈទៀងទាត់ ឋិតថេរ មិនប្រែប្រួលជាធម្មតា នឹងឋិតនៅស្មើដោយសស្សតវត្ថុ ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ៤ ដែលសមណព្រាហ្មណ៍ទាំងឡាយពួកមួយ ជាអ្នកប្រកបដោយឯកច្ចសស្សតឯកច្ចអសស្សតទិដ្ឋិ អាស្រ័យប្រារព្ធ ទើបបញ្ញត្តនូវខ្លួននឹងលោកថា ទៀងខ្លះ មិនទៀងខ្លះ ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ជាអ្នកប្រកបដោយឯកច្ចសស្សតឯកច្ចអស-ស្សតទិដ្ឋិនោះ រមែងបញ្ញត្តនូវខ្លួននឹងលោកថា ទៀងខ្លះ មិនទៀងខ្លះ ដោយហេតុ ៤ ប្រការនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ណានីមួយ ជាអ្នកប្រកបដោយឯកច្ចសស្សតឯកច្ចអសស្សតទិដ្ឋិ បញ្ញត្តនូវខ្លួននឹងលោកថាទៀងខ្លះ មិនទៀងខ្លះ សមណៈឬព្រាហ្មណ៍ទាំងអស់នោះ (រមែងបញ្ញត្ត) ដោយហេតុទាំង ៤ នេះឯង ឬក៏បណ្តាហេតុទាំង ៤ នោះ ដោយហេតុណាមួយ មិនមានហេតុដទៃក្រៅពីហេតុទាំង៤នេះឡើយ ។

តយិទំ ភិក្ខវេ តថាគតោ បជានាតិ ឥម ទិដ្ឋិដ្ឋានា ឯវំគហិតា ឯវំបរាមដ្ឋា ឯវំគតិកា ភវន្តិ[1] ឯវំអភិសម្ប-រាយាតិ ។ តញ្ច តថាគតោ បជានាតិ តតោ ច ឧត្តរិតរំ បជានាតិ តញ្ច បជានំ ន បរាមសតិ ។ អបរាមសតោ ចស្ស បច្ចត្តញ្ញេវ និព្វុតិ វិទិតា វេទនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្ស-រណញ្ច យថាភូតំ វិទិត្វា ។ អនុបាទា វិមុត្តោ ភិក្ខវេ តថាគតោ ។ ឥមេ ខោ ភិក្ខវេ ធម្មា គម្ភីរា ទុទ្ទសា

---

១ ម. ភវិស្សន្តិ ។

ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតដឹងច្បាស់នូវហេតុទាំង ៤ នោះថា ហេតុនៃទិដ្ឋិទាំងនេះ ដែលបុគ្គលកាន់យកយ៉ាងនេះ ប្រកាន់ខុសយ៉ាងនេះ រមែងមានគតិយ៉ាងនេះ មានការប្រព្រឹត្តិទៅក្នុងលោកខាងមុខយ៉ាងនេះ ។ ព្រះតថាគតដឹងច្បាស់នូវទិដ្ឋិនោះផង ដឹងច្បាស់ (នូវសីលសមាធិនិងសព្វញ្ញុតញ្ញាណ) ដែលជាគុណជាតលើសលុបជាងនោះទៅទៀតផង កាលបើដឹងច្បាស់នូវគុណវិសេសនោះហើយ ក៏មិនបានប្រកាន់ខុសឡើយ ។ មួយទៀត កាលបើព្រះតថាគត មិនបានប្រកាន់ខុសហើយ ក៏ដឹងនូវព្រះនិព្វានជាគ្រឿងរលត់ទៅនៃបាបមាសក្កិលេស ដោយខ្លួនឯង ទាំងដឹងច្បាស់នូវហេតុដែលនាំឲ្យកើតឡើងនៃវេទនាផង នូវសេចក្ដីអស់ទៅនៃវេទនាផង នូវសេចក្ដីឆ្ងាញ់ពិសារបស់វេទនាផង នូវទោសរបស់វេទនាផង នូវកិរិយារលាស់ចោលនូវវេទនាផង ដោយគួរតាមពិត ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតផុតស្រឡះហើយ (ចាកកិលេស) ព្រោះមិនប្រកាន់ (នូវធម៌ណាមួយមានខន្ធជាដើម) ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្ដមដោយខ្លួនឯង ហើយអាចនឹងសំដែងបាននូវធម៌ទាំងឡាយណា (មួយទៀត) ពួកជនកាលនិយាយសរសើរគុណរបស់ព្រះតថាគតតាមសេចក្ដីពិត ដោយធម៌ទាំងឡាយណា ធម៌ទាំងឡាយនេះឯង ជាធម៌ជ្រាលជ្រៅ ដែលបុគ្គលឃើញបានដោយលំបាក

ព្រហ្មជាលសុត្តំ បុព្វន្តកប្បិកា ចត្តារិ វត្ថូនិ

ទុរនុពោធា សន្តា បណីតា អតក្កាវចរា និបុណា បណ្ឌិតវេទនីយា យេ តថាគតោ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ យេហិ តថាគតស្ស យថាភុច្ចំ វណ្ណំ សម្មា វទមានា វទេយ្យុំ ។

(៣៨) សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា អន្តានន្តិកា អន្តានន្តំ លោកស្ស បញ្ញបេន្តិ ចតូហិ វត្ថូហិ ។ តេ ច ភោន្តោ សមណព្រាហ្មណា កិមាគម្ម កិមារព្ភ អន្តានន្តិកា អន្តានន្តំ លោកស្ស បញ្ញបេន្តិ ចតូហិ វត្ថូហិ ។ ឥធ ភិក្ខវេ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា អាតប្បមន្វាយ បធានមន្វាយ អនុយោគមន្វាយ អប្បមាទមន្វាយ សម្មាមនសិការមន្វាយ តថារូបំ ចេតោសមាធឹ ផុសតិ យថា សមាហិតេ ចិត្តេ អន្តសញ្ញី លោកស្មឹ វិហរតិ ។ សោ ឯវមាហ អន្តវា អយំ លោកោ បរិវដុមោ ។ តំ កិស្ស ហេតុ ។ អហំ ហិ អាតប្បមន្វាយ បធានមន្វាយ អនុយោគមន្វាយ

ត្រាស់ដឹងបានដោយកម្រ ជាធម៌ស្ងប់រម្ងាប់ ជាធម៌ថ្លៃថ្លា មិនជាទីស្ទង់ប្រមើលដោយសេចក្ដីត្រិះរិះ ជាធម៌ដ៏ល្អិត មានតែអ្នកប្រាជ្ញទើបដឹងបាន ។

(៣៤) ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ ប្រកបដោយអន្តានន្តទិដ្ឋិ បញ្ញត្តថា លោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ដោយហេតុ៤យ៉ាង ។ ចុះសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកប្រកបដោយអន្តានន្តទិដ្ឋិ បញ្ញត្តថាលោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ដោយហេតុ ៤យ៉ាង(នោះ) តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍ អាស្រ័យនូវការព្យាយាមជាគ្រឿងដុតកំដៅកិលេស អាស្រ័យនូវការព្យាយាមជាទីតាំងមាំ អាស្រ័យនូវការព្យាយាមជាគ្រឿងប្រកបរឿយ ៗ អាស្រ័យនូវសេចក្ដីមិនប្រមាទ អាស្រ័យនូវការយកចិត្តទុកដាក់ដោយប្រពៃ ហើយបាននូវចេតោសមាធិ តាមបែបផែន(នៃចិត្តរបស់យោគី)កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ មានសេចក្ដីសំគាល់ថាលោកមានទីបំផុត ។ បុគ្គលនោះក៏និយាយពាក្យយ៉ាងនេះថា លោកនេះមានទីបំផុត មានផ្លូវជុំវិញ គឺមូលជុំវិញ ។ ការនិយាយដូច្នោះ តើព្រោះហេតុអ្វី ។ ព្រោះហេតុថា អាត្មាអញអាស្រ័យនូវការព្យាយាម ជាគ្រឿងដុតកំដៅកិលេស អាស្រ័យនូវការព្យាយាមជាទីតាំងមាំ អាស្រ័យនូវការព្យាយាមជាគ្រឿងប្រកបរឿយ ៗ អាស្រ័យនូវ

អប្បមាទមន្វាយ សម្មាមនសិការមន្វាយ តថារូបំ ចេតោសមាធឹ ផុសតិ យថា សមាហិតេ ចិត្តេ អន្តសញ្ញី លោកស្មឹ វិហរតិ ។ ឥមិនាមហំ ឯតំ ជានាមិ យថា អន្តវា អយំ លោកោ បរិវដុមោតិ ។ ឥទំ ភិក្ខវេ បឋមំ ឋានំ យំ អាគម្ម យំ អារព្ភ ឯកេ សមណព្រាហ្មណា អន្តានន្តិកា អន្តានន្តំ លោកស្ស បញ្ញបេន្តិ ។

(៣៦) ទុតិយេ ច ភោន្តោ សមណព្រាហ្មណា កិមាគម្ម កិមារព្ភ អន្តានន្តិកា អន្តានន្តំ លោកស្ស បញ្ញបេន្តិ ។ ឥធ ភិក្ខវេ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា អាតប្បមន្វាយ បធានមន្វាយ អនុយោគមន្វាយ អប្បមាទមន្វាយ សម្មាមនសិការមន្វាយ តថារូបំ ចេតោសមាធឹ ផុសតិ យថា សមាហិតេ ចិត្តេ អនន្ត-

សេចក្តីមិនប្រមាទ អាស្រ័យនូវការយកចិត្តទុកដាក់ដោយប្រពៃ ហើយបាននូវចេតោសមាធិ តាមបែបផែន (នៃចិត្តរបស់យោគី) កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏មានសេចក្តីសំគាល់ថា លោកមានទីបំផុត ៗ លោកនេះមានទីបំផុត មានផ្លូវជុំវិញយ៉ាងណា អាត្មាអញក៏ដឹងនូវលោកនេះ (យ៉ាងនោះ) ព្រោះគុណវិសេសនេះឯង ៗ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ១ ដែលសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយអន្តានន្តទិដ្ឋិ អាស្រ័យ ប្រារព្ធ ទើបបញ្ញត្តថា លោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ៗ

(៣៦) ក្នុងហេតុទី ២ ទៀតថា ពួកសមណព្រាហ្មណ៍ដ៏ចំរើន ជាអ្នកប្រកបដោយអន្តានន្តទិដ្ឋិ បញ្ញត្តថា លោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ៗ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍ អាស្រ័យនូវការព្យាយាមជាគ្រឿងដុតកំដៅកិលេស អាស្រ័យនូវការព្យាយាមជាទីតាំងមាំ អាស្រ័យនូវការព្យាយាមជាគ្រឿងប្រកបរឿយ ៗ អាស្រ័យនូវសេចក្តីមិនប្រមាទ អាស្រ័យនូវការយកចិត្តទុកដាក់ដោយប្រពៃ ហើយបាននូវចេតោ-សមាធិ តាមបែបផែន (នៃចិត្តរបស់យោគី) កាលបើចិត្តតាំងនៅ ខ្ជាប់ខ្ជួន

សញ្ញី លោកស្មឹ វិហរតិ ។ សោ ឯវមាហ អនន្តោ អយំ លោកោ អបរិយន្តោ យេ តេ សមណព្រាហ្មណា ឯវមាហំសុ អន្តវា អយំ លោកោ បរិវដុមោតិ ។ តេសំ មុសា ។ អនន្តោ អយំ លោកោ អបរិយន្តោ ។ តំ កិស្ស ហេតុ ។ អហំ ហិ អាតប្បមន្វាយ បធានមន្វាយ អនុយោគមន្វាយ អប្បមាទមន្វាយ សម្មាមនសិការមន្វាយ តថារូបំ ចេតោសមាធឹ ផុសាមិ យថា សមាហិតេ ចិត្តេ អនន្តសញ្ញី លោកស្មឹ វិហរាមិ ។ តេនាហំ ឯតំ ជានាមិ យថា អនន្តោ អយំ លោកោ អបរិយន្តោតិ ។ ឥទំ ភិក្ខវេ តតិយំ ឋានំ យំ អាគម្ម យំ អារព្ភ ឯកេ សមណព្រាហ្មណា អន្តានន្តិកា អន្តានន្តំ លោកស្ស បញ្ញបេន្តិ ។

ហើយ ក៏មានសេចក្ដីសំគាល់ថា លោកមិនមានទីបំផុត ។ បុគ្គលនោះឯង ក៏និយាយយ៉ាងនេះថា លោកនេះមិនមានទីបំផុត ឥតមានកំណត់ ពួកសមណព្រាហ្មណ៍ណា និយាយយ៉ាងនេះថា លោកនេះមានទីបំផុត មានផ្លូវជុំវិញដូច្នេះ ។ ពាក្យរបស់ពួកសមណព្រាហ្មណ៍នោះឯង ជាពាក្យមុសាទេ ។ ឯលោកនេះ ប្រាកដជាមិនមានទីបំផុត ឥតមានកំណត់ ។ ការដែលពោលដូច្នោះ តើព្រោះហេតុអ្វី ។ ព្រោះហេតុថា អាត្មាអញ អាស្រ័យនូវការព្យាយាមជាគ្រឿងដុតកំដៅកិលេស អាស្រ័យនូវការព្យាយាមជាទីតាំងមាំ អាស្រ័យនូវការព្យាយាមជាគ្រឿងប្រកបរឿយ ៗ អាស្រ័យនូវសេចក្ដីមិនប្រមាទ អាស្រ័យនូវការយកចិត្តទុកដាក់ដោយប្រពៃ ហើយបាននូវចេតោសមាធិ តាមបែបផែន (នៃចិត្តរបស់យោគី) កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏មានសេចក្ដីសំគាល់ថា លោកមិនមានទីបំផុត ។ លោកនេះមិនមានទីបំផុត ឥតកំណត់យ៉ាងណា អាត្មាអញដឹងច្បាស់នូវលោកនេះ (យ៉ាងនោះ) ព្រោះគុណវិសេសនេះឯង ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ២ ដែលសមណព្រាហ្មណ៍ទាំងឡាយពួកមួយ ជាអ្នកប្រកបដោយអន្តានន្តទិដ្ឋិ អាស្រ័យ ប្រារព្ធ ទើបបញ្ញត្តថា លោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ។

(៣៧) តតិយេ ច ភោន្តោ សមណព្រាហ្មណា កិមាគម្ម កិមារព្ភ អន្តានន្តិកា អន្តានន្តំ លោកស្ស បញ្ញបេន្តិ ។ ឥធ ភិក្ខវេ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា អាតប្បមន្វាយ បធានមន្វាយ អនុយោគមន្វាយ អប្បមាទមន្វាយ សម្មាមនសិការមន្វាយ តថារូបំ ចេតោសមាធឹ ផុសតិ យថា សមាហិតេ ចិត្តេ ឧទ្ធមធោ អន្តសញ្ញី លោកស្មឹ វិហរតិ តិរិយំ អនន្តសញ្ញី ។ សោ ឯវមាហ អន្តវា ច អយំ លោកោ អនន្តោ ច យេ តេ សមណព្រាហ្មណា ឯវមាហំសុ អន្តវា អយំ លោកោ បរិវដុមោតិ ។ តេសំ មុសា ។ យេបិ តេ សមណព្រាហ្មណា ឯវមាហំសុ អនន្តោ អយំ លោកោ អបរិយន្តោតិ ។ តេសំបិ មុសា ។ អន្តវា ច អយំ លោកោ អនន្តោ ច ។ តំ កិស្ស ហេតុ ។

(៣៧) ក្នុងហេតុទី ៣ ទៀតថា ពួកសមណព្រាហ្មណ៍ដ៏ចំរើន ជាអ្នកប្រកបដោយអន្តានន្តទិដ្ឋិ បញ្ញត្តថា លោកមានទីបំផុតខ្លះមិនមានទីបំផុតខ្លះ តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍ អាស្រ័យនូវការព្យាយាមជាគ្រឿងដុតកំដៅកិលេស អាស្រ័យនូវការព្យាយាមជាទីតាំងមាំ អាស្រ័យនូវការព្យាយាមជាគ្រឿងប្រកបរឿយ ៗ អាស្រ័យនូវសេចក្តីមិនប្រមាទ អា· ស្រ័យនូវការយកចិត្តទុកដាក់ដោយប្រពៃ ហើយបាននូវចេតោសមាធិតាមបែបផែន(នៃចិត្តរបស់ព្រះយោគី)កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏មានសេចក្តីសំគាល់ថា លោកមានទីបំផុត ក្នុងទិសខាងលើនិងទិសខាងក្រោម មានសេចក្តីសំគាល់ថា លោកមិនមានទីបំផុត ក្នុងទិសទទឹង(ទិសទាំង៨) ។ បុគ្គលនោះឯង ក៏ពោលយ៉ាងនេះថា លោកនេះមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ពួកសមណព្រាហ្មណ៍ណា និយាយយ៉ាងនេះថា លោកនេះមានទីបំផុត មានផ្លូវជុំវិញដូច្នេះ ។ ពាក្យរបស់ពួកសមណព្រាហ្មណ៍នោះជាពាក្យមុសាទេ ។ ម្យ៉ាងទៀត ពួកសមណព្រាហ្មណ៍ណា និយាយយ៉ាងនេះថា លោកនេះមិនមានទីបំផុត ឥតមានកំណត់ទេ ។ ពាក្យរបស់ពួកសមណព្រាហ្មណ៍នោះឯង ក៏ជាពាក្យមុសាដែរ ។ ឯលោកនេះប្រាកដជាមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ។ ការនិយាយដូច្នោះ តើព្រោះហេតុអ្វី ។

អហំ ហិ អាតប្បមន្វាយ បធានមន្វាយ អនុយោគ-
មន្វាយ អប្បមាទមន្វាយ សម្មាមនសិការមន្វាយ តថា-
រូបំ ចេតោសមាធឹ ផុសាមិ យថា សមាហិតេ ចិត្តេ
ឧទ្ធមធោ អន្តសញ្ញី លោកស្មឹ វិហរាមិ តិរិយំ អនន្ត-
សញ្ញី ។ ឥមិនាមហំ ឯតំ ជានាមិ យថា អន្តវា ច
អយំ លោកោ អនន្តោ ចាតិ ។ ឥទំ ភិក្ខវេ តតិយំ
ឋានំ យំ អាគម្ម យំ អារព្ភ ឯកេ សមណព្រាហ្មណា
អន្តានន្តិកា អន្តានន្តំ លោកស្ស បញ្ញបេន្តិ ។

(៣៨) ចតុត្ថេ ច ភោន្តោ សមណព្រាហ្មណា
កិមាគម្ម កិមារព្ភ អន្តានន្តិកា អន្តានន្តំ លោកស្ស
បញ្ញបេន្តិ ។ ឥធ ភិក្ខវេ ឯកច្ចោ សមណោ វា
ព្រាហ្មណោ វា តក្កី ហោតិ វីមំសី ។ សោ តក្កប-

ព្រោះហេតុថា អាត្មាអញអាស្រ័យនូវការព្យាយាមជាគ្រឿងដុតកំដៅកិលេស អាស្រ័យនូវការព្យាយាមជាទីតាំងមាំ អាស្រ័យនូវការព្យាយាមជាគ្រឿងប្រកបរឿយ ៗ អាស្រ័យនូវសេចក្តីមិនប្រមាទ អាស្រ័យនូវការយកចិត្តទុកដាក់ដោយប្រពៃ ហើយបាននូវចេតោសមាធិតាមបែបផែន (នៃចិត្តរបស់យោគី) កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏មានសេចក្តីសំគាល់ថា លោកមានទីបំផុត ក្នុងទិសខាងលើនិងទិសខាងក្រោម មានសេចក្តីសំគាល់ថា លោកមិនមានទីបំផុតក្នុងទិសទទឹង ៗ លោកនេះមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះយ៉ាងណា អាត្មាអញដឹងច្បាស់នូវលោកនេះ (យ៉ាងនោះ) ព្រោះគុណវិសេសនេះឯង ៗ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ៣ ដែលសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយអន្តានន្តទិដ្ឋិ អាស្រ័យ ប្រារព្ធ ទើបបញ្ញត្តថា លោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ។

(៣៨) ក្នុងហេតុទី ៤ ទៀតថា ពួកសមណព្រាហ្មណ៍ដ៏ចំរើន ជាអ្នកប្រកបដោយអន្តានន្តទិដ្ឋិ បញ្ញត្តថា លោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ៗ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍ ជាអ្នកមានសេចក្តីត្រិះរិះពិចារណាជាប្រក្រតី ៗ បុគ្គលនោះក៏និយាយពាក្យដែលខ្លួនស្រាវជ្រាវ

រិយាហតំ វីមំសានុចរិតំ សយំ បដិភានំ ឯវមាហ
នេវាយំ លោកោ អន្តវា ន បនានន្តោ យេ តេ សមណ-
ព្រាហ្មណា ឯវមាហំសុ អន្តវា អយំ លោកោ បរិវ-
ដុមោតិ ។ តេសម្បិ មុសា ។ យេបិ តេ សមណព្រាហ្ម-
ណា ឯវមាហំសុ អនន្តោ អយំ លោកោ អបរិយន្តោតិ ។
តេសម្បិ មុសា ។ យេបិ តេ សមណព្រាហ្មណា
ឯវមាហំសុ អន្តវា ច អយំ លោកោ អនន្តោ
ចាតិ ។ តេសម្បិ មុសា ។ នេវាយំ លោកោ អន្តវា ន
បនានន្តោតិ ។ ឥទំ ភិក្ខវេ ចតុត្ថំ ឋានំ យំ អាគម្ម
យំ អារព្ភ ឯកេ សមណព្រាហ្មណា អន្តានន្តិកា
អន្តានន្តំ លោកស្ស បញ្ញបេន្តិ ។ ឥមេ ខោ តេ
ភិក្ខវេ សមណព្រាហ្មណា អន្តានន្តិកា អន្តានន្តំ លោ-
កស្ស បញ្ញបេន្តិ ចតូហិ វត្ថូហិ ។ យេ ហិ កេចិ
ភិក្ខវេ សមណា វា ព្រាហ្មណា វា អន្តានន្តិកា

បានមកដោយសេចក្ដីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការពិចារណា ជាពាក្យដែលកើតមាន ដោយប្រាជ្ញារបស់ខ្លួនយ៉ាងនេះថា លោកនេះមានទីបំផុត ក៏មិនមែន មិនមានទីបំផុត ក៏មិនមែន ពួកសមណព្រាហ្មណ៍ណា និយាយយ៉ាងនេះថា លោកនេះមានទីបំផុត មានផ្លូវជុំវិញដូច្នេះ ។ ពាក្យរបស់ពួកសមណព្រាហ្មណ៍នោះ ជាពាក្យមុសាទេ ។ ម្យ៉ាងទៀត ពួកសមណព្រាហ្មណ៍ណា និយាយយ៉ាងនេះថា លោកនេះមិនមានទីបំផុត ឥតមានកំណត់ដូច្នេះ ។ ពាក្យរបស់ពួកសមណព្រាហ្មណ៍នោះ ក៏ជាពាក្យមុសាដែរ ។ មួយទៀត ពួកសមណព្រាហ្មណ៍ណា និយាយយ៉ាងនេះថា លោកនេះមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះដូច្នេះ ។ ពាក្យរបស់ពួកសមណព្រាហ្មណ៍នោះសោត ក៏ជាពាក្យមុសាដែរ ។ ឯលោកនេះប្រាកដជាមានទីបំផុត ក៏មិនមែន មិនមានទីបំផុត ក៏មិនមែនដែរ ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ៤ ដែលសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយអន្តានន្តទិដ្ឋិ អាស្រ័យប្រារព្ធ ទើបបញ្ញត្តថាលោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍ទាំងនោះ ជាអ្នកប្រកបដោយអន្តានន្តទិដ្ឋិ បញ្ញត្តថាលោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ដោយហេតុ ៤ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ឯពួកសមណៈ ឬព្រាហ្មណ៍ឯណានីមួយ ជាអ្នកប្រកបដោយអន្តានន្តទិដ្ឋិ

ព្រហ្មជាលសុត្តេ បុព្វន្តកប្បិកា ចត្តារិ វត្ថូនិ

អន្តានន្តំ លោកស្ស បញ្ញបេន្តិ សព្វេ តេ ឥមេហេវ ចតូហិ វត្ថូហិ ឯតេសំ វា អញ្ញតរេន នត្ថិ ឥតោ ពហិទ្ធា ។ តយិទំ ភិក្ខវេ តថាគតោ បជានាតិ ឥមេ ទិដ្ឋិដ្ឋានា ឯវំគហិតា ឯវំបរាមដ្ឋា ឯវំគតិកា ភវន្តិ ឯវំអភិសម្បរាយាតិ ។ តញ្ច តថាគតោ បជានាតិ តតោ ច ឧត្តរិតរំ បជានាតិ តញ្ច បជាននំ ន បរាមសតិ ។ អបរាមសតោ ចស្ស បច្ចត្តញ្ញេវ និព្វុតិ វិទិតា វេទនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ វិទិត្វា ។ អនុបាទា វិមុត្តោ ភិក្ខវេ តថាគតោ ។ ឥមេ ខោ តេ ភិក្ខវេ ធម្មា

បញ្ញត្តថា លោកមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ពួកសមណព្រាហ្មណ៍ទាំងអស់នោះ រមែងបញ្ញត្តដោយហេតុ ៤ យ៉ាងនេះឯង ឬក៏បណ្តាហេតុទាំង ៤ យ៉ាងនុ៎ះ ដោយហេតុណាមួយ មិនមានហេតុដទៃ ក្រៅពីហេតុ ៤ យ៉ាងនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតដឹងច្បាស់នូវហេតុនៃទិដ្ឋិ៤ប្រការនោះថា ហេតុនៃទិដ្ឋិទាំងនេះ ដែលបុគ្គលកាន់យកយ៉ាងនេះ ដែលបុគ្គលប្រកាន់ខុសយ៉ាងនេះ រមែងមានគតិយ៉ាងនេះ មានការប្រព្រឹត្តទៅកាន់បរលោកយ៉ាងនេះ។ ព្រះតថាគតដឹងច្បាស់នូវទិដ្ឋិនោះផង ដឹងច្បាស់ (នូវសីលសមាធិនឹងសព្វញ្ញុតញ្ញាណ) ដែលជាគុណជាតលើសលុបជាងនោះទៅទៀតផង កាលបើដឹងច្បាស់នូវគុណវិសេសនោះហើយ ក៏មិនបានប្រកាន់ខុសឡើយ ។ មួយទៀត កាលបើព្រះតថាគត មិនបានប្រកាន់ខុសហើយ ក៏ដឹងនូវព្រះនិព្វានជាគ្រឿងរលត់ទៅនៃ (បាបមាសក្កិលេស) ដោយខ្លួនឯង ទាំងដឹងច្បាស់នូវហេតុ ដែលនាំឲ្យកើតឡើងនៃវេទនាផង នូវសេចក្តីអស់ទៅនៃវេទនាផង នូវសេចក្តីឆ្ងាញ់ពិសា របស់វេទនាផង នូវទោសរបស់វេទនាផង នូវកិរិយារលាស់ចោលនូវវេទនាផង ដោយគួរតាមពិត ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតផុតស្រឡះហើយចាកកិលេស ព្រោះមិនប្រកាន់នូវធម៌ណាមួយមានខន្ធជាដើម ។ ម្នាលភិក្ខុទាំងឡាយ

គម្ភីរា ទុទ្ទសា ទុរនុពោធា សន្តា បណីតា អតក្កាវចរា និបុណា បណ្ឌិតវេទនីយា យេ តថាគតោ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ យេហិ តថាគតស្ស យថាភុច្ចំ វណ្ណំ សម្មា វទមានា វទេយ្យុំ ។

(៣៨) សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា អមរាវិក្ខេបិកា តត្ថ តត្ថ បញ្ហំ បុដ្ឋា សមានា វាចាវិក្ខេបំ អាបជ្ជន្តិ អមរាវិក្ខេបំ ចតូហិ វត្ថូហិ ។ តេ ច ភោន្តោ សមណព្រាហ្មណា កិមាគម្ម កិមារព្ភ អមរាវិក្ខេបិកា តត្ថ តត្ថ បញ្ហំ បុដ្ឋា សមានា វាចាវិក្ខេបំ អាបជ្ជន្តិ អមរាវិក្ខេបំ ចតូហិ វត្ថូហិ ។ ឥធ ភិក្ខវេ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា ឥទំ កុសលន្តិ យថាភូតំ នប្បជានាតិ ឥទំ អកុសលន្តិ យថាភូតំ នប្បជានាតិ ។

ព្រះតថាគតបានធ្វើឲ្យជាក់ច្បាស់ដោយបញ្ញាដ៏ឧត្តម ដោយខ្លួនឯងហើយ អាចនឹងសំដែងបាននូវធម៌ទាំងឡាយណា ពួកជនកាលនិយាយសរសើរគុណរបស់ព្រះតថាគត តាមសេចក្តីពិត ដោយធម៌ទាំងឡាយណា ធម៌ទាំងឡាយនេះឯង ជាធម៌ជ្រាលជ្រៅ ដែលបុគ្គលឃើញបានដោយលំបាក ត្រាស់ដឹងបានដោយកម្រ ជាធម៌ស្ងប់រម្ងាប់ ជាធម៌ដ៏ថ្លៃថ្លា មិនជាទីស្ទង់ប្រមើលដោយសេចក្តីត្រិះរិះ ជាធម៌ដ៏ល្អិត មានតែអ្នកប្រាជ្ញទើបដឹងបាន ។

(៣៩) ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិ(១) កាលបើមានអ្នកណាមួយ សាកសួរប្រស្នាក្នុងកុសលនឹងអកុសលនោះ ៗ ក៏ដល់នូវការពោះពាចាពោះសំដីមិនឲ្យស្ដាប់ពាក្យ ដោយហេតុ ៤ យ៉ាង ។ ចុះពួកសមណព្រាហ្មណ៍ដ៏ចំរើននោះ ជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិ កាលបើមានអ្នកណាមួយ សួរប្រស្នាក្នុងកុសលនឹងអកុសលនោះ ៗ ហើយ ក៏ដល់នូវការពោះពាចាពោះសំដី មិនឲ្យស្ដាប់ពាក្យដោយហេតុ ៤ ប្រការ តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍ មិនដឹងតាមពិតថា នេះជាកុសល មិនដឹងតាមពិតថា នេះជាអកុសល ។

---

១ អដ្ឋកថា ថា អ្នកប្រកាន់និយាយពោះសំដី មិនឲ្យស្ដាប់ពាក្យ ។ន័យមួយទៀតថា អ្នកនិយាយពោះសំដីក្រឡិចក្រឡុចមិនឲ្យគេចាប់ពាក្យបាន ដូចជាត្រីមួយបែបឈ្មោះ ត្រីអមរា ដែលស្ទុះទៅស្ទុះមក ភ្លែតចុះភ្លែតឡើង មិនឲ្យគេចាប់ខ្លួនបាន ។

តស្ស ឯវំ ហោតិ អហំ ខោ ឥទំ កុសលន្តិ យថាភូតំ នប្បជានាមិ ឥទំ អកុសលន្តិ យថាភូតំ នប្បជានាមិ អហញ្ចេ ខោ[១] បន ឥទំ កុសលន្តិ យថាភូតំ អប្បជានន្តោ ឥទំ អកុសលន្តិ យថាភូតំ អប្បជានន្តោ ឥទំ កុសលន្តិ វា ព្យាករេយ្យំ ឥទំ អកុសលន្តិ វា ព្យាករេយ្យំ តំ មមស្ស មុសា យំ មមស្ស មុសា សោ មមស្ស វិឃាតោ យោ មមស្ស វិឃាតោ សោ មមស្ស អន្តរាយោតិ ។ ឥតិ សោ មុសាវាទភយា មុសាវាទបរិជេគុច្ឆា នេវិទំ កុសលន្តិ ព្យាករោតិ ន បនិទំ អកុសលន្តិ ព្យាករោតិ តត្ថ តត្ថ បញ្ហំ បុដ្ឋោ សមានោ វាចាវិក្ខេបំ អាបជ្ជតិ អមរាវិក្ខេបំ ឯវម្បិ មេ នោ ។ តថាតិបិ មេ នោ ។ អញ្ញថាតិបិ មេ នោ ។

១ ឱ. អហញ្ចេ ខោ ។

បុគ្គលនោះតែងមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញមិនដឹងតាមពិតថា នេះជាកុសល មិនដឹងតាមពិតថា នេះជាអកុសលទេ កាលបើអាត្មាអញ មិនដឹងតាមពិតថា នេះជាកុសល មិនដឹងតាមពិតថា នេះជាអកុសលទេ នឹងអះអាងថា នេះជាកុសលក្តី នឹងអះអាងថា នេះជាអកុសលក្តី ពាក្យនៃអាត្មាអញនោះ នឹងជាមុសា ពាក្យនៃអាត្មាអញណា ជាមុសា ពាក្យនោះ នឹងជាសេចក្តីបង្អៀតចិត្តនៃអាត្មាអញ សេចក្តីបង្អៀតចិត្តណារបស់អាត្មាអញ សេចក្តីបង្អៀតចិត្តនោះ នឹងជាអន្តរាយនៃអាត្មាអញ ។ ព្រោះតែសេចក្តីត្រិះរិះយ៉ាងនេះ បានជាបុគ្គលនោះមិនអះអាងថា នេះជាកុសលមិនអះអាងថា នេះជាអកុសលឡើយ ព្រោះខ្លាចមុសាវាទ ព្រោះខ្ពើមមុសាវាទ កាលបើមានអ្នកណាមួយ សាកសួរប្រស្នាក្នុងកុសលនឹងអកុសលនោះ ៗ ក៏ដល់នូវការបោះវាចាបោះសំដី មិនឲ្យស្ទាប់ពាក្យថា សេចក្តីយល់ឃើញរបស់ខ្ញុំថា យ៉ាងនេះក៏មិនមែន(១) ៗ សេចក្តីយល់ឃើញរបស់ខ្ញុំថា យ៉ាងនោះក៏មិនមែន(២) ៗ សេចក្តីយល់ឃើញរបស់ខ្ញុំថា យ៉ាងដទៃក៏មិនមែន(៣) ៗ

---

១ អដ្ឋកថា ថា ត្រង់ពាក្យដែលថា យ៉ាងនេះក៏មិនមែន ជាពាក្យឃាត់អាការសួរណា ៗ ដែលមិនមានទីកំណត់ ។ ២ ត្រង់ពាក្យថា យ៉ាងនោះក៏មិនមែន ជាពាក្យឃាត់សស្សតវាទ គឺពាក្យពោលថា លោកទៀង ( បព្ទ: ២៧, ២៨, ២៩, ៣០ ) ។ ៣ ត្រង់ពាក្យថាយ៉ាងដទៃក៏មិនមែន ជាពាក្យឃាត់ឯកច្ចសស្សតឯកច្ចអសស្សតវាទ គឺពាក្យថា លោកទៀងខ្លះ មិនទៀងខ្លះ (បព្ទ: ៣១, ៣២, ៣៣, ៣៤ ) ។

នោតិបិ មេ នោ ។ នោ នោតិបិ មេ នោតិ ។ ឥទំ ភិក្ខវេ បឋមំ ឋានំ យំ អាគម្ម យំ អារព្ភ ឯកេ សមណព្រាហ្មណា អមរាវិក្ខេបិកា តត្ថ តត្ថ បញ្ហំ បុដ្ឋា សមានា វាចាវិក្ខេបំ អាបជ្ជន្តិ អមរាវិក្ខេបំ ។

(៨០) ទុតិយេ ច ភោន្តោ សមណព្រាហ្មណា កិមាគម្ម កិមារព្ភ អមរាវិក្ខេបិកា តត្ថ តត្ថ បញ្ហំ បុដ្ឋា សមានា វាចាវិក្ខេបំ អាបជ្ជន្តិ អមរាវិក្ខេបំ ។ ឥធ ភិក្ខវេ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា ឥទំ កុសលន្តិ យថាភូតំ នប្បជានាតិ ឥទំ អកុសលន្តិ យថាភូតំ នប្បជានាតិ ។ តស្ស ឯវំ ហោតិ អហំ ខោ ឥទំ កុសលន្តិ យថាភូតំ នប្បជានាមិ

សេចក្តីយល់ឃើញរបស់ខ្ញុំថា មិនមែនក៏ទេ(១) ។ សេចក្តីយល់ឃើញរបស់ខ្ញុំថា មិនមែនក៏ទេ ក៏មិនមែនដែរ(២) ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ១ ដែលសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិ អាស្រ័យ ប្រារព្ធ កាលបើមានអ្នកណាមួយ សាកសួរប្រស្នាក្នុងកុសលនិងអកុសលនោះ ៗ ក៏ដល់នូវការបោះពាក្យថាបោះសំដី មិនឲ្យស្លាប់ពាក្យ ។

(៤០) ក្នុងហេតុទី ២ ទៀតថា ពួកសមណព្រាហ្មណ៍ដ៏ចំរើន ជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិ កាលបើមានអ្នកណាមួយសាកសួរប្រស្នាក្នុងកុសលនិងអកុសលនោះ ៗ ក៏ដល់នូវការបោះពាក្យថាបោះសំដី មិនឲ្យស្លាប់ពាក្យ តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍ មិនដឹងតាមពិតថា នេះជាកុសល មិនដឹងតាមពិតថា នេះជាអកុសលទេ ។ បុគ្គលនោះតែងមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញមិនដឹងតាមពិតថា នេះជាកុសល

---

១ ត្រង់ពាក្យថា សូន្យក៏មិនមែនជាពាក្យឃាត់ឧច្ឆេទវាទ គឺពាក្យថា សត្វស្លាប់ទៅសូន្យមិនកើតទៀត ។ ២ ត្រង់ពាក្យថា មិនសូន្យក៏មិនមែន ជាពាក្យឃាត់តក្កីវាទ គឺពាក្យថា សត្វស្លាប់ទៅ មិនមែនជាមាន មិនមែនជាគ្មាន ។

ឥទំ អកុសលន្តិ យថាភូតំ នប្បជានាមិ អហញ្ចេ ខោ(១) បន ឥទំ កុសលន្តិ យថាភូតំ អប្បជានន្តោ ឥទំ អកុសលន្តិ យថាភូតំ អប្បជានន្តោ ឥទំ កុសលន្តិ វា ព្យាករេយ្យំ ឥទំ អកុសលន្តិ វា ព្យា-ករេយ្យំ តត្ថ មេ អស្ស ឆន្ទោ វា រាគោ វា ទោសោ វា បដិឃោ វា យត្ថ មេ អស្ស ឆន្ទោ វា រាគោ វា ទោសោ វា បដិឃោ វា តំ មមស្ស ឧបាទានំ យំ មមស្ស ឧ-បាទានំ សោ មមស្ស វិឃាតោ យោ មមស្ស វិឃាតោ សោ មមស្ស អន្តរាយោតិ ។ ឥតិ សោ ឧបាទានភយា ឧបាទានបរិជេគុច្ឆា នេវិទំ កុសលន្តិ ព្យាករោតិ ន បនិទំ អកុសលន្តិ ព្យាករោតិ តត្ថ តត្ថ បញ្ហំ បុដ្ឋោ សមានោ វាចាវិក្ខេបំ អាបជ្ជតិ អមរាវិក្ខេបំ ឯវន្តិបិ(២) មេ នោ ។ តថាតិបិ មេ នោ ។ អញ្ញថាតិ-បិ មេ នោ ។ នោតិបិ មេ នោ ។ នោ នោតិបិ មេ

១ ឱ. អហញ្ចេវ ខោ ។ ២ ឱ. ឯវម្បិ ។

មិនដឹងតាមពិតថា នេះជាកុសល កាលបើអាត្មាអញមិនដឹងតាមពិតថា នេះជាកុសល មិនដឹងតាមពិតថា នេះជាអកុសលយ៉ាងនេះហើយ នឹងអះអាងថា នេះជាកុសល ឬនឹងអះអាងថា នេះជាអកុសល ឆន្ទៈក្ដី រាគៈក្ដី ទោសៈក្ដី បដិឃៈ[1]ក្ដី នៃអាត្មាអញនឹងមានក្នុងរឿងរ៉ាវណា ឆន្ទៈក្ដី រាគៈក្ដី ទោសៈក្ដី បដិឃៈក្ដី នៃអាត្មាអញនឹងមានក្នុងរឿងរ៉ាវនោះ ធម្មជាតមានឆន្ទៈជាដើមនោះ ជាឧបាទានរបស់អាត្មាអញ ធម៌ណាជាឧបាទាននៃអាត្មាអញ ធម៌នោះ នឹងជាសេចក្ដីចង្អៀតចង្អល់ នៃអាត្មាអញ ធម៌ណាជាសេចក្ដីចង្អៀតចង្អល់របស់អាត្មាអញ ធម៌នោះនឹងជាអន្តរាយ នៃអាត្មាអញ ។ ព្រោះសេចក្ដីត្រិះរិះដូច្នេះ បានជាបុគ្គលនោះ មិនអះអាងថា នេះជាកុសល មិនអះអាងថា នេះជាអកុសលឡើយ ព្រោះខ្លាចឧបាទាន ព្រោះខ្ពើមឧបាទាន កាលបើមានអ្នកណាមួយ សួរប្រស្នាក្នុងកុសលនឹងអកុសលនោះ ៗ ក៏ដល់នូវការបោះវាចាបោះសំដី មិនឲ្យស្ដាប់ពាក្យថា សេចក្ដីយល់ឃើញនៃខ្ញុំថា យ៉ាងនេះ ក៏មិនមែន ៗ សេចក្ដីយល់ឃើញនៃខ្ញុំថាយ៉ាងនោះ ក៏មិនមែន ៗ សេចក្ដីយល់ឃើញរបស់ខ្ញុំថា យ៉ាងដទៃ ក៏មិនមែន ៗ សេចក្ដីយល់ឃើញរបស់ខ្ញុំថាមិនមែនក៏ទេ ៗ សេចក្ដីយល់ឃើញរបស់ខ្ញុំ

---

១ អដ្ឋកថាថា សេចក្ដីត្រេកអរមានកំឡាំងថយ ហៅ ឆន្ទៈ សេចក្ដីត្រេកអរមានកំឡាំងក្លា ហៅ រាគៈ សេចក្ដីក្រោធមានកំឡាំងថយ ហៅ ទោសៈ សេចក្ដីក្រោធមានកំឡាំងក្លា ហៅ បដិឃៈ ។

ហោតិ ។ ឥទំ ភិក្ខវេ ទុតិយំ ឋានំ យំ អាគម្ម យំ អារព្ភ ឯកេ សមណព្រាហ្មណា អមរាវិក្ខេបិកា តត្ថ តត្ថ បញ្ហំ បុដ្ឋា សមានា វាចាវិក្ខេបំ អាបជ្ជន្តិ អមរាវិក្ខេបំ ។

(៦១) តតិយេ ច ភោន្តោ សមណព្រាហ្មណា កិមាគម្ម កិមារព្ភ អមរាវិក្ខេបិកា តត្ថ តត្ថ បញ្ហំ បុដ្ឋា សមានា វាចាវិក្ខេបំ អាបជ្ជន្តិ អមរាវិក្ខេបំ ។ ឥធ ភិក្ខវេ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា ឥទំ កុសលន្តិ យថាភូតំ នប្បជានាតិ ឥទំ អកុសលន្តិ យថាភូតំ នប្បជានាតិ ។ តស្ស ឯវំ ហោតិ អហំ ខោ ឥទំ កុសលន្តិ យថាភូតំ នប្បជានាមិ ឥទំ អកុសលន្តិ យថាភូតំ នប្បជានាមិ អហញ្ចេ ខោ[១] បន ឥទំ កុសលន្តិ យថាភូតំ អប្បជានន្តោ ឥទំ អកុសលន្តិ យថាភូតំ អប្បជានន្តោ ឥទំ កុសលន្តិ វា ព្យាករេយ្យំ ឥទំ អកុសលន្តិ វា ព្យាករេយ្យំ សន្តិ ហិ ខោ សមណព្រាហ្មណា បណ្ឌិតា និបុណា កតបរប្បវាទា វាលវេធិរូបា តេ[២] ភិន្ទន្តា មញ្ញេ ចរន្តិ បញ្ញាគតេន

១ ឱ. អហញ្ចេវ ខោ ។ ២ ឱ. យេ ។

ថា មិនមែនក៏ទេ ក៏មិនមែនដែរ ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ២ ដែលសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិ អាស្រ័យ ប្រារព្ធ កាលបើមានអ្នកណាមួយ សាកសួរប្រស្នាក្នុងកុសលនឹងអកុសលនោះៗហើយ ក៏ដល់នូវការពោះពាចា ពោះសំដីមិនឲ្យស្លាប់ពាក្យ។

(៤១) ក្នុងហេតុទី ៣ ទៀតថា ពួកសមណព្រាហ្មណ៍ដ៏ចំរើនជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិ កាលបើមានអ្នកណាមួយ សាកសួរប្រស្នាក្នុងកុសលនឹងអកុសលនោះ ៗ ហើយ ក៏ដល់នូវការពោះពាចា ពោះសំដីមិនឲ្យស្លាប់ពាក្យ តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍ មិនដឹងតាមពិតថា នេះជាកុសល មិនដឹងតាមពិតថា នេះជាអកុសលទេ ។ បុគ្គលនោះរមែងមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញមិនដឹងតាមពិតថា នេះជាកុសល មិនដឹងតាមពិតថានេះជាអកុសលឡើយ កាលបើអាត្មាអញមិនដឹងតាមពិតថា នេះជាកុសល មិនដឹងតាមពិតថា នេះជាអកុសលដូច្នេះហើយ នឹងអះអាងថា នេះជាកុសលក្តី នឹងអះអាងថា នេះជាអកុសលក្តី ក្រែងមានសមណព្រាហ្មណ៍ទាំងឡាយជាបណ្ឌិត មានប្រាជ្ញាដ៏ល្អិតដឹងច្បាស់នូវវាទៈរបស់អ្នកដទៃ អាចទំលាយនូវទិដ្ឋិ របស់បុគ្គលដទៃបាន ដោយកំឡាំងប្រាជ្ញារបស់ខ្លួន មានសភាពដូចជាខ្មាន់ធ្នូជាអ្នកបាញ់រោមទ្រាយ(១)

១ សព្ទនេះ ប្រែថា មានសភាពដូចខ្មាន់ធ្នូ ជាអ្នកបាញ់រោមចុងកន្ទុយសត្វ ដូច្នេះក៏បាន ។

ទិដ្ឋិគតានិ តេ មំ តត្ថ សមនុយុញ្ជេយ្យុំ សមនុគ្គាហេយ្យុំ សមនុភាសេយ្យុំ យេ មំ តត្ថ សមនុយុញ្ជេយ្យុំ សមនុគ្គាហេយ្យុំ សមនុភាសេយ្យុំ តេសាហំ ន សម្បាយេយ្យំ[1] យញ្ចាហំ[2] ន សម្បាយេយ្យំ សោ មមស្ស វិឃាតោ យោ មមស្ស វិឃាតោ សោ មមស្ស អន្តរាយោតិ ។ ឥតិ សោ អនុយោគភយា អនុយោគបរិជេគុច្ឆា នេវិទំ កុសលន្តិ ព្យាករោតិ ន បនិទំ អកុសលន្តិ ព្យាករោតិ តត្ថ តត្ថ បញ្ហំ បុដ្ឋោ សមានោ វាចាវិក្ខេបំ អាបជ្ជតិ អមរាវិក្ខេបំ ឯវម្បិ មេ នោ ។ តថាតិបិ មេ នោ ។ អញ្ញថាតិបិ មេ នោ ។ នោតិបិ មេ នោ ។ នោ នោតិបិ មេ នោតិ ។

---

១ សម្បាហេយ្យំ សម្បាបេយ្យំ សម្បាយេយ្យំ សម្បាទេយ្យំ ។ ២ ឱ. យេសាហំ ។

សមណព្រាហ្មណ៍ទាំងនោះ គប្បីសាកសួរ គប្បីដដឹកសួរ គប្បីសួរដេញដោល ចំពោះអាត្មាអញ ក្នុងកុសលនឹងអកុសលនោះ (បើ) សមណព្រាហ្មណ៍ណា គប្បីសាកសួរ គប្បីដដឹកសួរ គប្បីសួរដេញដោល ចំពោះអាត្មាអញ ក្នុងកុសលនឹងអកុសលនោះ អាត្មាអញមុខជានឹងមិនអាចដោះស្រាយ នូវប្រស្នារបស់ពួកសមណព្រាហ្មណ៍នោះបានទេ បើអាត្មាអញ មិនអាចនឹងដោះស្រាយ នូវប្រស្នាដោយហេតុណាហើយ ហេតុនោះនឹងជាសេចក្ដីចង្អៀតចិត្ត នៃអាត្មាអញ ធម៌ណាជាសេចក្ដីចង្អៀតចិត្តរបស់អាត្មាអញ ធម៌នោះនឹងជាអន្តរាយ នៃអាត្មាអញ ៗ ព្រោះសេចក្ដីត្រិះរិះយ៉ាងនេះ បានជាបុគ្គលនោះ មិនអះអាងថា នេះជាកុសល មិនអះអាងថា នេះជាអកុសល ព្រោះខ្លាចពាក្យសួរដេញដោល ព្រោះធុញថប់នឹងពាក្យសួរដេញដោល កាលបើមានអ្នកណាមួយ សាកសួរប្រស្នាក្នុងកុសលនឹងអកុសលនោះ ៗ ហើយ ក៏ដល់នូវការបោះវាចា បោះសំដី មិនឲ្យស្ងាប់ពាក្យថា សេចក្ដីយល់ឃើញរបស់ខ្ញុំថា យ៉ាងនេះ ក៏មិនមែន ៗ សេចក្ដីយល់ឃើញរបស់ខ្ញុំថា យ៉ាងនោះ ក៏មិនមែន ៗ សេចក្ដីយល់ឃើញរបស់ខ្ញុំថា យ៉ាងដទៃ ក៏មិនមែន ៗ សេចក្ដីយល់ឃើញរបស់ខ្ញុំថា មិនមែនក៏ទេ ៗ សេចក្ដីយល់ឃើញរបស់ខ្ញុំថា មិនមែនក៏ទេ ក៏មិនមែនដែរ ៗ

ឥទំ ភិក្ខវេ តតិយំ ឋានំ យំ អាគម្ម យំ អារព្ភ ឯកេ សមណព្រាហ្មណា អមរាវិក្ខេបិកា តត្ថ តត្ថ បញ្ហំ បុដ្ឋា សមានា វាចាវិក្ខេបំ អាបជ្ជន្តិ អមរាវិក្ខេបំ ។

(៦២) ចតុត្ថេ ច ភោន្តោ សមណព្រាហ្មណា កិមាគម្ម កិមារព្ភ អមរាវិក្ខេបិកា តត្ថ តត្ថ បញ្ហំ បុដ្ឋា សមានា វាចាវិក្ខេបំ អាបជ្ជន្តិ អមរាវិក្ខេបំ ។ ឥធ ភិក្ខវេ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា មន្ទោ ហោតិ មោមូហោ ។ សោ មន្ទត្តា មោមូហត្តា តត្ថ តត្ថ បញ្ហំ បុដ្ឋោ សមានោ វាចាវិក្ខេបំ អាបជ្ជតិ អមរាវិក្ខេបំ អត្ថិ បរោ លោកោតិ ឥតិ ចេ មំ បុច្ឆសិ អត្ថិ បរោ លោកោតិ ឥតិ ចេ មេ អស្ស អត្ថិ បរោ លោកោតិ ឥតិ តេ នំ(១) ព្យាករេយ្យំ ឯវន្តិបិ មេ នោ ។ តថាតិបិ មេ នោ ។

១ ម. ម. តេនំ ។

ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ៣ ដែលសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិ អាស្រ័យ ប្រារព្ធ កាលបើមានអ្នកណាមួយ សាកសួរប្រស្នាក្នុងកុសលនឹងអកុសលនោះៗ ហើយ ក៏ដល់នូវការពោះវាចា ពោះសំដី មិនឲ្យស្លាប់ពាក្យ ។

(៤២) ក្នុងហេតុទី៤ទៀតថា ពួកសមណព្រាហ្មណ៍ដ៏ចំរើន ជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិ កាលបើមានអ្នកណាមួយ សាកសួរប្រស្នាក្នុងកុសលនឹងអកុសលនោះ ៗ ហើយ ក៏ដល់នូវការពោះវាចា ពោះសំដី មិនឲ្យស្លាប់ពាក្យ តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍ ជាមនុស្សមានប្រាជ្ញាទន់ ជាមនុស្សល្ងង់ខ្លៅ ។ បុគ្គលនោះឯងហេតុតែមានប្រាជ្ញាទន់ ហេតុតែល្ងង់ខ្លៅ កាលបើមានអ្នកណាមួយ សាកសួរប្រស្នាក្នុងកុសលនឹងអកុសលនោះៗហើយ ក៏ដល់នូវការពោះវាចា ពោះសំដី មិនឲ្យស្លាប់ពាក្យថា បើអ្នកសួរខ្ញុំថា លោកខាងមុខមានឬទេ បើសេចក្តីយល់ឃើញរបស់ខ្ញុំយ៉ាងនេះថា លោកខាងមុខមាន ខ្ញុំនឹងមិនអះអាងដល់អ្នកថា លោកខាងមុខមាន (ម្តេចបាន) សេចក្តីយល់ឃើញរបស់ខ្ញុំថា យ៉ាងនេះក៏មិនមែន ។ សេចក្តីយល់ឃើញរបស់ខ្ញុំថា យ៉ាងនោះ ក៏មិនមែន ។

អញ្ញថាតិបិ មេ នោ ។ នោតិបិ មេ នោ ។ នោ នោតិបិ
មេ នោ ។ នត្ថិ បរោ លោកោ ។ បេ ។ អត្ថិ ច នត្ថិ ច
បរោ លោកោ ។ នេវត្ថិ ន នត្ថិ បរោ លោកោ ។ អត្ថិ
សត្តា ឱបបាតិកា ។ នត្ថិ សត្តា ឱបបាតិកា ។ អត្ថិ
ច នត្ថិ ច សត្តា ឱបបាតិកា ។ នេវត្ថិ ន នត្ថិ សត្តា
ឱបបាតិកា ។ អត្ថិ សុកដទុក្កដានំ កម្មានំ ផលំ
វិបាកោ ។ នត្ថិ សុកដទុក្កដានំ កម្មានំ ផលំ វិបា-
កោ ។ អត្ថិ ច នត្ថិ ច សុកដទុក្កដានំ កម្មានំ ផលំ
វិបាកោ ។ នេវត្ថិ ន នត្ថិ សុកដទុក្កដានំ កម្មានំ ផលំ
វិបាកោ ។ ហោតិ តថាគតោ បរម្មរណា ។ ន ហោតិ ត-
ថាគតោ បរម្មរណា ។ ហោតិ ច ន ច ហោតិ តថាគតោ
បរម្មរណា ។ នេវ ហោតិ ន ន ហោតិ តថាគតោ

សេចក្ដីយល់ឃើញរបស់ខ្ញុំថា យ៉ាងដទៃ ក៏មិនមែន ។ សេចក្ដីយល់ឃើញរបស់ខ្ញុំថា មិនមែនក៏ទេ ។ សេចក្ដីយល់ឃើញរបស់ខ្ញុំថា មិនមែនក៏ទេ ក៏មិនមែនដែរ ។ បើអ្នកសួរខ្ញុំថា លោកខាងមុខមិនមានឬ ។ បេ ។ លោកខាងមុខមានខ្លះ មិនមានខ្លះឬ ។ លោកខាងមុខមានក៏មិនមែន មិនមានក៏មិនមែនឬ ។ សត្វទាំងឡាយ ដែលមានកំណើតជាឧបបាតិកៈមានឬ ។ សត្វទាំងឡាយ ដែលជាឧបបាតិកៈមិនមានឬ ។ សត្វទាំងឡាយ ដែលជាឧប-បាតិកៈមានខ្លះ មិនមានខ្លះឬ ។ សត្វទាំងឡាយ ដែលជាឧបបាតិកៈមានក៏មិនមែន មិនមានក៏មិនមែនឬ ។ ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អនឹងអាក្រក់មានឬ ។ ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អនឹងអាក្រក់មិនមានឬ ។ ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អនឹងធ្វើអាក្រក់មានខ្លះ មិនមានខ្លះឬ ។ ផលវិបាករបស់កម្មទាំងឡាយ ដែលសត្វធ្វើល្អនឹងធ្វើអាក្រក់ មានក៏មិនមែន មិនមានក៏មិនមែនឬ ។ សត្វលុះរលាងខន្ធទៅ ខាងមុខអំពីសេចក្ដីស្លាប់ កើតទៀតឬ ។ សត្វលុះរលាងខន្ធទៅ ខាងមុខអំពីសេចក្ដីស្លាប់ មិនកើតទៀតឬ ។ សត្វលុះរលាងខន្ធទៅ ខាងមុខអំពីសេចក្ដីស្លាប់ កើតទៀតខ្លះ មិនកើតទៀតខ្លះឬ ។ សត្វលុះរលាងខន្ធទៅ ខាងមុខអំពីសេចក្ដីស្លាប់ កើតទៀត ក៏មិនមែន

បរម្មរណាតិ ឥតិ ចេ មំ បុច្ឆសិ ។ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ ឥតិ ចេ មេ អស្ស នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ ឥតិ តេ ន(១) ព្យាករេយ្យំ ឯវន្តិបិ មេ នោ ។ តថាតិបិ មេ នោ ។ អញ្ញថាតិបិ មេ នោ ។ នោតិបិ មេ នោ ។ នោ នោតិបិ មេ នោតិ ។ ឥទំ ភិក្ខវេ ចតុត្ថំ ឋានំ យំ អាគម្ម យំ អារព្ភ ឯកេ សមណព្រាហ្មណា អមរាវិក្ខេបិកា តត្ថ តត្ថ បញ្ហំ បុដ្ឋា សមានា វាចាវិក្ខេបំ អាបជ្ជន្តិ អមរាវិក្ខេបំ ។ ឥមេហិ ខោ តេ ភិក្ខវេ សមណព្រាហ្មណា អមរាវិក្ខេបិកា តត្ថ តត្ថ បញ្ហំ បុដ្ឋា សមានា វាចាវិក្ខេបំ អាបជ្ជន្តិ អមរាវិក្ខេបំ ចតូហិ វត្ថូហិ ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា អមរាវិក្ខេបិកា តត្ថ តត្ថ បញ្ហំ បុដ្ឋា សមានា

---

១ តេ នន្តិបិ ត្រេ ឥតិបិ ញាហោ ។

មិនកើតទៀតក៏មិនមែនឬ ។ បើសេចក្ដីយល់ឃើញរបស់ខ្ញុំនឹងមានដូច្នេះថា សត្វលុះរំលាយខន្ធទៅ ខាងមុខអំពីសេចក្ដីស្លាប់ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន ខ្ញុំនឹងមិនអះអាងដល់អ្នកថា សត្វលុះរំលាយខន្ធទៅ ខាងមុខអំពីសេចក្ដីស្លាប់ កើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន (ម្ដេចបាន) សេចក្ដីយល់ឃើញរបស់ខ្ញុំថា យ៉ាងនេះ ក៏មិនមែន ។ សេចក្ដីយល់ឃើញរបស់ខ្ញុំថា យ៉ាងនោះ ក៏មិនមែន ។ សេចក្ដីយល់ឃើញរបស់ខ្ញុំថា យ៉ាងដទៃ ក៏មិនមែន ។ សេចក្ដីយល់ឃើញរបស់ខ្ញុំថា មិនមែនក៏ទេ ។ សេចក្ដីយល់ឃើញរបស់ខ្ញុំថា មិនមែនទេ ក៏មិនមែនដែរ ។ ម្នាលភិក្ខុទាំងឡាយនេះជាហេតុទី ៤ ដែលសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិ អាស្រ័យ ប្រារព្ធ កាលបើមានអ្នកណាមួយ សាកសួរប្រស្នា ក្នុងកុសលនឹងអកុសលនោះ ៗ ហើយ ក៏ដល់នូវការបោះវាចា បោះសំដីមិនឲ្យស្លាប់ពាក្យ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍ទាំងនោះឯង ជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិ កាលបើមានអ្នកណាមួយ សាកសួរប្រស្នា ក្នុងកុសលនឹងអកុសលនោះ ៗ ក៏ដល់នូវការបោះវាចា បោះសំដីមិនឲ្យស្លាប់ពាក្យ ដោយហេតុ ៤ ប្រការនេះឯង ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ណានីមួយ ជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិ កាលបើមានអ្នកណាមួយ សាកសួរប្រស្នា ក្នុងកុសលនឹងអកុសល

នោះៗហើយ ក៏ដល់នូវការបោះវាចាបោះសំដីមិនឲ្យស្ងាប់ពាក្យ សមណៈឬព្រាហ្មណ៍ទាំងអស់នោះ រមែងដល់នូវការបោះវាចា បោះសំដី មិនឲ្យស្ងាប់ពាក្យ ដោយហេតុ ៤ យ៉ាងនេះឯង ឬក៏បណ្ដាហេតុទាំង៤យ៉ាងនោះ ដោយហេតុណាមួយ មិនមានហេតុដទៃក្រៅពីនេះឡើយ ។ បេ ។ ពួកជនកាលនិយាយសរសើរគុណ របស់ព្រះតថាគត តាមសេចក្ដីពិត ដោយធម៌ទាំងឡាយណា ។

(៤៣) ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយអធិច្ចសមុប្បន្នទិដ្ឋិ គឺអ្នកបញ្ញត្តនូវខន្ធនឹងលោកថា កើតឡើងដោយឥតហេតុ ដោយហេតុ ២ យ៉ាង ។ ចុះពួកសមណព្រាហ្មណ៍ដ៏ចំរើននោះ ដែលជាអ្នកប្រកបដោយអធិច្ចសមុប្បន្នទិដ្ឋិ បញ្ញត្តនូវខន្ធនឹងលោកថា កើតឡើងដោយឥតហេតុ ដោយហេតុ២យ៉ាង តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ មានពួកទេវតាឈ្មោះថា អសញ្ញីសត្វ គឺសត្វមិនមានសញ្ញា ទេវតាទាំងនោះ លុះមានសញ្ញាកើតឡើងហើយ ក៏ច្យុតចាកពួកទេវតានោះ ។ ម្នាលភិក្ខុទាំងឡាយ ហេតុនុ៎ះមានប្រាកដត្រង់សេចក្ដីថា សត្វណាមួយច្យុតចាកពួកទេវតានោះ មកកាន់អត្តភាពជាមនុស្សនេះ កាលដែលមកកាន់អត្តភាពជាមនុស្សនេះហើយ ក៏ចេញចាកផ្ទះចូលទៅកាន់ផ្នួស លុះចេញចាកផ្ទះចូលទៅកាន់ផ្នួសហើយ

មរាវិក្ខេបំ អាបជ្ជន្តិ អមរាវិក្ខេបំ សព្វេ តេ ឥមេហេវ ចតូហិ វត្ថូហិ ឯតេសំ វា អញ្ញតរេន នត្ថិ ឥតោ ពហិទ្ធា ។ បេ ។ យេហិ តថាគតស្ស យថាភុច្ចំ វណ្ណំ សម្មា វទមានា វទេយ្យុំ ។

(៦៣) សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា អធិច្ចសមុប្បន្និកា អធិច្ចសមុប្បន្នំ អត្តានញ្ច លោកញ្ច បញ្ញាបេន្តិ ទ្វីហិ វត្ថូហិ ។ តេ ច ភោន្តោ សមណព្រាហ្មណា កិមាគម្ម កិមារព្ភ អធិច្ចសមុប្បន្និកា អធិច្ចសមុប្បន្នំ អត្តានញ្ច លោកញ្ច បញ្ញាបេន្តិ ទ្វីហិ វត្ថូហិ ។ សន្តិ ភិក្ខវេ អសញ្ញីសត្តា[1] នាម ទេវា សញ្ញុប្បាទា ច បន តេ ទេវា តម្ហា កាយា ចវន្តិ ។ ឋានំ ខោ បនេតំ ភិក្ខវេ វិជ្ជតិ យំ អញ្ញតរោ សត្តោ តម្ហា កាយា ចវិត្វា ឥត្ថត្តំ អាគច្ឆតិ ឥត្ថត្តំ អាគតោ សមានោ អគារស្មា អនគារិយំ បព្វជតិ អគារស្មា អនគារិយំ បព្វជិតោ

១ ម. អសញ្ញសត្តា ។

សមានោ អាតប្បមន្វាយ បធានមន្វាយ អនុយោគមន្វា-
យ អប្បមាទមន្វាយ សម្មាមនសិការមន្វាយ តថារូបំ
ចេតោសមាធឹ ផុសតិ យថា សមាហិតេ ចិត្តេ សញ្ញុប្បា-
ទំ អនុស្សរតិ តតោ បរំ នានុស្សរតិ ។ សោ ឯវមាហ
អធិច្ចសមុប្បន្នោ អត្តា ច លោកោ ច ។ តំ កិស្ស
ហេតុ ។ អហំ ហិ បុព្វេ នាហោសឹ សោម្ហិ ឯតរហិ
អហុត្វា សត្តតាយ បរិណតោតិ ។ ឥទំ ភិក្ខវេ បឋមំ
ឋានំ យំ អាគម្ម យំ អារព្ភ ឯកេ សមណព្រាហ្មណា
អធិច្ចសមុប្បន្និកា អធិច្ចសមុប្បន្នំ អត្តានញ្ច លោ-
កញ្ច បញ្ញបេន្តិ ។

(៦៦) ទុតិយេ ច ភោន្តោ សមណព្រាហ្មណា
កិមាគម្ម កិមារព្ភ អធិច្ចសមុប្បន្និកា អធិច្ចសមុប្បន្នំ
អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ។ ឥធ ភិក្ខវេ ឯកច្ចោ

អាស្រ័យនូវការព្យាយាម ជាគ្រឿងដុតកំដៅកិលេស អាស្រ័យនូវការព្យាយាមជាទីតាំងមាំ អាស្រ័យនូវការព្យាយាម ជាគ្រឿងប្រកបរឿយ ៗ អាស្រ័យនូវសេចក្តីមិនប្រមាទ អាស្រ័យនូវការយកចិត្តទុកដាក់ដោយប្រពៃ ហើយបាននូវចេតោសមាធិ តាមបែបផែន(នៃចិត្តរបស់យោគី)កាលបើចិត្តតាំងនៅខ្ជាប់ខ្ជួនហើយ ក៏រលឹកបានកំណត់ត្រឹមកាលដែលខ្លួនមានសញ្ញាកើតឡើង មិនបានរលឹកហួសអំពីកំណត់នោះឡើយ ៗ បុគ្គលនោះពោលយ៉ាងនេះថា ខ្លួននិងលោកកើតឡើងដោយឥតហេតុ ៗ ការពោលដូច្នោះតើព្រោះហេតុអ្វី ៗ ព្រោះថា អាត្មាអញ ក្នុងកាលពីមុន ក៏មិនបានកើតទេ កើតតែក្នុងកាលឥឡូវនេះ តទៅមុខទៀត ក៏មិនបានកើតដែរ ព្រោះបង្អោនចិត្តទៅ ដើម្បីជាអ្នកស្ងប់រម្ងាប់ហើយ ៗ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ១ ដែលសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយអធិច្ចសមុប្បន្នទិដ្ឋិ អាស្រ័យ ប្រារព្ធ ទើបបញ្ញត្តនូវខ្លួននិងលោកថា កើតឡើងដោយឥតហេតុ ៗ

(៤៤) ក្នុងហេតុទី២ទៀតថា ពួកសមណព្រាហ្មណ៍ដ៏ចំរើន ជាអ្នកប្រកបដោយអធិច្ចសមុប្បន្នទិដ្ឋិ បញ្ញត្តនូវខ្លួននិងលោកថា កើតឡើងដោយឥតហេតុ ព្រោះអាស្រ័យអ្វី ប្រារព្ធអ្វី ៗ ម្នាលភិក្ខុទាំងឡាយ បុគ្គល

សមណោ វា ព្រាហ្មណោ វា តក្កី ហោតិ វីមំសី ។ សោ តក្កបរិយាហតំ វីមំសានុចរិតំ សយំ បដិភានំ ឯវមាហ អធិច្ចសមុប្បន្នោ អត្តា ច លោកោ ចាតិ ។ ឥទំ ភិក្ខវេ ទុតិយំ ឋានំ យំ អាគម្ម យំ អារព្ភ ឯកេ សមណព្រាហ្មណា អធិច្ចសមុប្បន្និកា អធិច្ចសមុប្បន្នំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ។ ឥមេហិ ខោ តេ ភិក្ខវេ សមណព្រាហ្មណា អធិច្ចសមុប្បន្និកា អធិច្ចសមុប្បន្នំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ទ្វីហិ វត្ថូហិ ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា អធិច្ចសមុប្បន្និកា អធិច្ចសមុប្បន្នំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ សព្វេ តេ ឥមេហេវ ទ្វីហិ វត្ថូហិ ឯតេសំ វា អញ្ញតរេន នត្ថិ ឥតោ ពហិទ្ធា ។ បេ ។ យេហិ តថាគតស្ស យថាភុច្ចំ វណ្ណំ សម្មា វទមានា វទេយ្យុំ ។ ឥមេហិ ខោ តេ ភិក្ខវេ សមណព្រាហ្មណា

## ព្រហ្មជាលសូត្រ ប្រកបដោយអធិច្ចសមុប្បន្នទិដ្ឋិ

ពួកមួយក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍ ជាអ្នកមានសេចក្តីត្រិះរិះ ពិចារណាជាប្រក្រតី ៗ បុគ្គលនោះ ក៏និយាយពាក្យ ដែលខ្លួនស្រាវជ្រាវបានមកដោយសេចក្តីត្រិះរិះ ដែលខ្លួនស្ទាបស្ទង់ដោយការពិចារណា ជាពាក្យកើតមានដោយបញ្ញា របស់ខ្លួនយ៉ាងនេះថា ខ្លួននឹងលោកកើតឡើងដោយឥតហេតុ ៗ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ២ ដែលសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយអធិច្ចសមុប្បន្នទិដ្ឋិ អាស្រ័យ ប្រារព្ធ ទើបបញ្ញត្តនូវខ្លួននឹងលោកថា កើតឡើងដោយឥតហេតុ ៗ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ទាំងឡាយ ជាអ្នកប្រកបដោយអធិច្ចសមុប្បន្នទិដ្ឋិទាំងនោះ តែងបញ្ញត្តនូវខ្លួននឹងលោកថា កើតឡើងដោយឥតហេតុ ដោយហេតុ ២ យ៉ាងនេះឯង ៗ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ឯណានីមួយ ជាអ្នកប្រកបដោយអធិច្ចសមុប្បន្នទិដ្ឋិ បញ្ញត្តនូវខ្លួននឹងលោកថា កើតឡើងដោយឥតហេតុ សមណព្រាហ្មណ៍ទាំងអស់នោះ រមែងបញ្ញត្តដោយហេតុ ២ យ៉ាងនេះឯង ឬក៏បណ្តាហេតុទាំងពីរនោះ ដោយហេតុណានីមួយ មិនមានហេតុដទៃក្រៅពីហេតុទាំង ២ យ៉ាងនេះឡើយ ៗ បេ ៗ ពួកជនកាលពោលសរសើរគុណ របស់ព្រះតថាគត តាមសេចក្តីពិត ដោយធម៌ទាំងឡាយណា ៗ ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍ទាំងនោះជាអ្នកប្រកប

បុព្វន្តកប្បិកា បុព្វន្តានុទិដ្ឋិនោ បុព្វន្តំ អារព្ភ អនេក-
វិហិតានិ អធិមុត្តិបទានិ អភិវទន្តិ អដ្ឋារសហិ វត្ថូហិ ។
យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា
បុព្វន្តកប្បិកា បុព្វន្តានុទិដ្ឋិនោ បុព្វន្តំ អារព្ភ អនេក-
វិហិតានិ អធិមុត្តិបទានិ អភិវទន្តិ សព្វេ តេ ឥមេហេវ
អដ្ឋារសហិ វត្ថូហិ ឯតេសំ វា អញ្ញតរេន នត្ថិ ឥតោ
ពហិទ្ធា ។ តយិទំ ភិក្ខវេ តថាគតោ បជានាតិ ឥមេ
ទិដ្ឋិដ្ឋានា ឯវំគហិតា ឯវំបរាមដ្ឋា ឯវំគតិកា ភវន្តិ
ឯវំអភិសម្បរាយាតិ ។ តញ្ច តថាគតោ បជានាតិ
តតោ ច ឧត្តរិតរំ បជានាតិ តញ្ច បជាននំ ន បរាម-
សតិ ។ អបរាមសតោ ចស្ស បច្ចត្តញ្ញេវ និព្វុតិ វិទិតា

ដោយបុព្វន្តកប្បទិដ្ឋិ ជាអ្នកមានសេចក្តីយល់ឃើញរឿយ ៗ នូវចំណែកនៃខន្ធខាងដើម ប្រារព្ធនូវចំណែកនៃខន្ធខាងដើម សំដែងនូវចំណែកនៃទិដ្ឋិច្រើនប្រការ ដោយហេតុទាំង ១៨ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ សមណៈឬព្រាហ្មណ៍ឯណានីមួយ ជាអ្នកប្រកបដោយបុព្វន្តកប្បទិដ្ឋិ ជាអ្នកមានសេចក្តីយល់ឃើញរឿយ ៗ នូវចំណែកនៃខន្ធខាងដើម ប្រារព្ធនូវចំណែកនៃខន្ធខាងដើម សំដែងនូវចំណែកនៃទិដ្ឋិច្រើនប្រការ សមណព្រាហ្មណ៍ទាំងអស់នោះ រមែងសំដែងដោយហេតុទាំង ១៨ នេះឯង ឬក៏បណ្តាហេតុទាំង ១៨ នុ៎ះ ដោយហេតុណាមួយ មិនមានហេតុដទៃក្រៅពីហេតុទាំង ១៨ នេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតដឹងច្បាស់ នូវហេតុនៃទិដ្ឋិនោះដូច្នេះថា ហេតុនៃទិដ្ឋិទាំងឡាយនេះ ដែលបុគ្គលកាន់យកយ៉ាងនេះ ប្រកាន់ខុសយ៉ាងនេះ រមែងមានគតិយ៉ាងនេះ មានការប្រព្រឹត្តទៅ ក្នុងលោកខាងមុខយ៉ាងនេះ ៗ ព្រះតថាគត ដឹងច្បាស់នូវហេតុនៃទិដ្ឋិនោះផង ដឹងច្បាស់ (នូវសីលសមាធិនឹងសព្វញ្ញុតញ្ញាណ) ដែលជាគុណជាត លើសលុបក្រៃលែងជាងនោះទៅទៀតផង ។ កាលបើដឹងច្បាស់នូវគុណវិសេសនោះហើយ ក៏មិនបានប្រកាន់ខុសឡើយ ។ មួយទៀត កាលបើព្រះតថាគតមិនបានប្រកាន់ខុសហើយ ក៏ដឹងនូវព្រះនិព្វានជាគ្រឿងរលត់ទៅ (នៃបរាមាសក្កិលេស)

វេទនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីន-វញ្ច និស្សរណញ្ច យថាភូតំ វិទិត្វា ។ អនុបាទា វិមុត្តោ ភិក្ខវេ តថាគតោ ។ ឥមេ ខោ តេ ភិក្ខវេ ធម្មា គម្ភីរា ទុទ្ទសា ទុរនុពោធា សន្តា បណីតា អតក្កាវចរា និបុណា បណ្ឌិតវេទនីយា យេ តថាគតោ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ យេហិ តថាគតស្ស យថាភុច្ចំ វណ្ណំ សម្មា វទមានា វទេយ្យុំ ។

(៤៨) សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា អ-បរន្តកប្បិកា អបរន្តានុទិដ្ឋិនោ អបរន្តំ អារព្ភ អនេក-វិហិតានិ អធិមុត្តិបទានិ អភិវទន្តិ ចតុចត្តាឡីសាយ វត្ថូហិ ។ តេ ច ភោន្តោ សមណព្រាហ្មណា កិមាគម្ម

ដោយខ្លួនឯង តាំងដឹងច្បាស់នូវហេតុដែលនាំឲ្យកើតឡើង នៃវេទនាផង នូវសេចក្តីរលត់ទៅ នៃវេទនាផង នូវសេចក្តីឆ្ងាញ់ពិសា របស់វេទនាផង នូវទោសរបស់វេទនាផង នូវកិរិយារលាស់ចោលនូវវេទនាផង ដោយគួរតាមពិត ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ផុតស្រឡះហើយចាកកិលេសព្រោះមិនប្រកាន់ (នូវធម៌ណាមួយ មានខន្ធជាដើម) ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតបានធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯងហើយ អាចនឹងសំដែងបាននូវធម៌ទាំងឡាយណា ពួកជនកាលពោលសរសើរគុណ របស់ព្រះតថាគត តាមសេចក្តីពិត ដោយធម៌ទាំងឡាយណា ធម៌ទាំងឡាយនេះឯង ជាធម៌ដ៏ជ្រាលជ្រៅ ដែលបុគ្គលឃើញបានដោយលំបាក ត្រាស់ដឹងបានដោយកម្រ ជាធម៌ស្ងប់រម្ងាប់ ជាធម៌ថ្លៃថ្លា មិនជាទីស្ទង់ប្រមើលដោយសេចក្តីត្រិះរិះបាន ជាធម៌ដ៏ល្អិត មានតែអ្នកប្រាជ្ញ ទើបដឹងបាន ។

(៤៩) ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយអបរន្តកប្បទិដ្ឋិ ជាអ្នកមានសេចក្តីយល់ឃើញរឿយ ៗ នូវខន្ធជាចំណែកខាងមុខ (អនាគត) ប្រារព្ធខន្ធជាចំណែកខាងមុខ ហើយសំដែងនូវចំណែកនៃទិដ្ឋិច្រើនប្រការ ដោយហេតុ៤៤ ។ ចុះពួកសមណព្រាហ្មណ៍

កិមារព្ភ អបរន្តកប្បិកា អបរន្តានុទិដ្ឋិនោ អបរន្តំ អារព្ភ អនេកវិហិតានិ អធិមុត្តិបទានិ អភិវទន្តិ ចតុចត្តាឡីសាយ វត្ថូហិ ។

(៤៦) សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា ឧទ្ធមាឃតនិកា សញ្ញីវាទា ឧទ្ធមាឃតនំ សញ្ញឹ អត្តានំ[១] បញ្ញបេន្តិ សោឡសហិ វត្ថូហិ ។ តេ ច ភោន្តោ សមណព្រាហ្មណា កិមាគម្ម កិមារព្ភ ឧទ្ធមាឃតនិកា សញ្ញីវាទា ឧទ្ធមាឃតនំ សញ្ញឹ អត្តានំ បញ្ញបេន្តិ សោឡសហិ វត្ថូហិ ។ រូបី អត្តា ហោតិ អរោគោ បរំ មរណា សញ្ញីតិ នំ បញ្ញបេន្តិ ។ អរូបី អត្តា ហោតិ អរោគោ បរំ មរណា សញ្ញីតិ នំ បញ្ញបេន្តិ ។ រូបី ច អរូបី ច អត្តា ហោតិ ។ បេ ។ នេវរូបី នារូបី អត្តា ហោតិ ។ អន្តវា អត្តា ហោតិ ។ អនន្តវា អត្តា ហោតិ ។ អន្តវា ច អនន្តវា ច អត្តា ហោតិ ។ នេវន្តវា នានន្តវា អត្តា ហោតិ ។ ឯកត្តសញ្ញី អត្តា

១ ម. ឧទ្ធមាឃាតនិកា សញ្ញីវាទា ឧទ្ធមាឃាតនំ សញ្ញឹ អត្តានំ ។ ខ. សញ្ញឹ អត្តានំ ។

ដ៏ចំរើន ជាអ្នកប្រកបដោយអបរន្តកប្បទិដ្ឋិ ជាអ្នកមានសេចក្ដីយល់ឃើញរឿយ ៗ នូវខន្ធជាចំណែកខាងមុខ ប្រារព្ធខន្ធជាចំណែកខាងមុខ ហើយសំដែងនូវចំណែក នៃទិដ្ឋិច្រើនប្រការ ដោយហេតុ៤៤ តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។

(៤៦) ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយឧទ្ធមាឃតនទិដ្ឋិ ជាសញ្ញីវាទ(ប្រកាន់នូវខ្លួនថាកាលស្លាប់ទៅមានសញ្ញា) បញ្ញត្តនូវខ្លួនថា មានសញ្ញាខាងមុខអំពីសេចក្ដីស្លាប់ ដោយហេតុ១៦យ៉ាង ។ ចុះពួកសមណព្រាហ្មណ៍ដ៏ចំរើននោះ ជាអ្នកប្រកបដោយឧទ្ធមាឃតនទិដ្ឋិ ជាសញ្ញីវាទ បញ្ញត្តនូវខ្លួនថាមានសញ្ញាខាងមុខអំពីសេចក្ដីស្លាប់ ដោយហេតុ១៦ យ៉ាង តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ សមណព្រាហ្មណ៍ពួកនោះ បញ្ញត្តនូវខ្លួននោះថា ខ្លួនមានរូប តែមិនមានរោគ គឺទៀង មានសញ្ញាខាងមុខអំពីសេចក្ដីស្លាប់ ។ បញ្ញត្តនូវខ្លួននោះថា ខ្លួនមិនមានរូប ទាំងមិនមានរោគ មានសញ្ញាខាងមុខអំពីសេចក្ដីស្លាប់ ។ បញ្ញត្តនូវខ្លួននោះថា ខ្លួនមានរូបខ្លះ មិនមានរូបខ្លះក៏មាន ។ បេ ។ ខ្លួនមានរូបក៏មិនមែន មិនមានរូបក៏មិនមែនក៏មាន ។ ខ្លួនមានទីបំផុតក៏មាន ។ ខ្លួនមិនមានទីបំផុតក៏មាន ។ ខ្លួនមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះក៏មាន ។ ខ្លួនមានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែនក៏មាន ។ ខ្លួនមានសញ្ញា

ហោតិ ។ នានត្តសញ្ញី អត្តា ហោតិ ។ បរិត្តសញ្ញី អត្តា ហោតិ ។ អប្បមាណសញ្ញី អត្តា ហោតិ ។ ឯកន្តសុខី អត្តា ហោតិ ។ ឯកន្តទុក្ខី អត្តា ហោតិ ។ សុខទុក្ខី អត្តា ហោតិ ។ អទុក្ខមសុខី អត្តា ហោតិ អរោគោ បរំ មរណា សញ្ញីតិ នំ បញ្ញបេន្តិ ។ ឥមេហិ ខោ តេ ភិក្ខវេ សមណព្រាហ្មណា ឧទ្ធមាឃាតនិកា សញ្ញីវាទា ឧទ្ធមាឃាតនំ សញ្ញិមត្តានំ បញ្ញបេន្តិ សោឡសហិ វត្ថូហិ ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឧទ្ធមាឃាតនិកា សញ្ញីវាទា ឧទ្ធមាឃាតនំ សញ្ញិមត្តានំ បញ្ញបេន្តិ សព្វេ តេ ឥមេហេវ សោឡសហិ វត្ថូហិ ឯតេសំ វា អញ្ញតរេន នត្ថិ ឥតោ ពហិទ្ធា ។ បេ ។ យេហិ តថាគតស្ស យថាភុច្ចំ វណ្ណំ សម្មា វទមានា វទេយ្យុំ ។

(៤៧) សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា ឧទ្ធមាឃាតនិកា អសញ្ញីវាទា ឧទ្ធមាឃាតនំ អសញ្ញិមត្តានំ បញ្ញបេន្តិ អដ្ឋហិ វត្ថូហិ ។ តេ ច ភោន្តោ

ដូចគ្នាក៏មាន ។ ខ្លួនមានសញ្ញាផ្សេងគ្នាក៏មាន ។ ខ្លួនមានសញ្ញាយ៉ាងតិចក៏មាន ។ ខ្លួនមានសញ្ញាដ៏ប្រមាណមិនបានក៏មាន ។ ខ្លួនមានសេចក្ដីសុខតែម្យ៉ាងក៏មាន ។ ខ្លួនមានទុក្ខតែម្យ៉ាងក៏មាន ។ ខ្លួនមានសុខនិងទុក្ខប្រែប្រួលគ្នាក៏មាន ។ ខ្លួនមិនមានទុក្ខមិនមានសុខទាំងមិនមានរោគ មានសញ្ញា ខាងមុខអំពីសេចក្ដីស្លាប់ក៏មាន ។ ម្នាលភិក្ខុទាំងឡាយ សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកប្រកបដោយឧទ្ធមាឃាតនទិដ្ឋិ ជាសញ្ញីវាទ បញ្ញត្តនូវខ្លួនថា មានសញ្ញា ខាងមុខអំពីសេចក្ដីស្លាប់ ដោយហេតុ១៦ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ ជាអ្នកប្រកបដោយឧទ្ធមាឃាតនទិដ្ឋិ ជាសញ្ញីវាទ បញ្ញត្តនូវខ្លួនថា មានសញ្ញា ខាងមុខអំពីសេចក្ដីស្លាប់ សមណព្រាហ្មណ៍ទាំងអស់នោះ តែងបញ្ញត្ត ដោយហេតុ ១៦ យ៉ាងនេះឯង ឬក៏បណ្ដាហេតុ ១៦ នោះ ដោយហេតុណាមួយ មិនមានហេតុដទៃក្រៅពីនេះឡើយ ។ បេ ។ ពួកជនកាលនិយាយសរសើរគុណ របស់ព្រះតថាគតតាមសេចក្ដីពិត ដោយធម៌ទាំងឡាយណា ។

(៤៧) ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយឧទ្ធមាឃាតនទិដ្ឋិ ជាអសញ្ញីវាទ បញ្ញត្តនូវខ្លួនថាមិនមានសញ្ញា ខាងមុខអំពីសេចក្ដីស្លាប់ ដោយហេតុ ៨ យ៉ាង ។ ចុះពួកសមណ-

សមណព្រាហ្មណា កិមាគម្ម កិមារព្ភ ឧទ្ធមាឃ-
តនិកា អសញ្ញីវាទា ឧទ្ធមាឃតនំ អសញ្ញិមត្តានំ
បញ្ញបេន្តិ អដ្ឋហិ វត្ថូហិ ។ រូបី អត្តា ហោតិ អរោគោ
បរំ មរណា អសញ្ញីតិ នំ បញ្ញបេន្តិ ។ អរូបី អត្តា ហោតិ
អរោគោ បរំ មរណា អសញ្ញីតិ នំ បញ្ញបេន្តិ ។ រូបី ច អរូបី
ច អត្តា ហោតិ ។ បេ ។ នេវរូបី នារូបី អត្តា ហោតិ ។
អន្តវា អត្តា ហោតិ ។ អនន្តវា អត្តា ហោតិ ។
អន្តវា ច អនន្តវា ច អត្តា ហោតិ ។ នេវន្តវា នានន្តវា
អត្តា ហោតិ អរោគោ បរំ មរណា អសញ្ញីតិ នំ
បញ្ញបេន្តិ ។ ឥមេហិ ខោ តេ ភិក្ខវេ សមណព្រាហ្ម-
ណា ឧទ្ធមាឃតនិកា អសញ្ញីវាទា ឧទ្ធមាឃតនំ
អសញ្ញិមត្តានំ បញ្ញបេន្តិ អដ្ឋហិ វត្ថូហិ ។ យេ ហិ
កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឧទ្ធមាឃ-
តនិកា អសញ្ញីវាទា ឧទ្ធមាឃតនំ អសញ្ញិមត្តានំ
បញ្ញបេន្តិ សព្វេ តេ ឥមេហេវ អដ្ឋហិ វត្ថូហិ ឯតេសំ

ព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកប្រកបដោយឧទ្ធមាឃតនទិដ្ឋិ ជាអសញ្ញីវាទ បញ្ញត្តនូវខ្លួនថា មិនមានសញ្ញាខាងមុខអំពីសេចក្ដីស្លាប់ ដោយហេតុ ៨ យ៉ាង តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ សមណព្រាហ្មណ៍ទាំងនោះ បញ្ញត្តនូវខ្លួននោះថា ខ្លួនមានរូប តែមិនមានរោគ មិនមានសញ្ញាខាងមុខអំពីសេចក្ដីស្លាប់ ។ បញ្ញត្តនូវខ្លួននោះថា ខ្លួនមិនមានរូប ទាំងមិនមានរោគ មិនមានសញ្ញាខាងមុខអំពីសេចក្ដីស្លាប់ ។ បញ្ញត្តនូវខ្លួននោះថា ខ្លួនមានរូបខ្លះ មិនមានរូបខ្លះក៏មាន ។ បេ ។ ខ្លួនមានរូបក៏មិនមែន មិនមានរូបក៏មិនមែនក៏មាន ។ ខ្លួនមានទីបំផុតក៏មាន ។ ខ្លួនមិនមានទីបំផុតក៏មាន ។ ខ្លួនមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះក៏មាន ។ ខ្លួនមានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែន តែមិនមានរោគ មិនមានសញ្ញាខាងមុខអំពីសេចក្ដីស្លាប់ ។ ម្នាលភិក្ខុទាំងឡាយ ពួសមណព្រាហ្មណ៍ទាំងនោះ ជាអ្នកប្រកបដោយឧទ្ធមាឃតនទិដ្ឋិ ជាអសញ្ញីវាទ បញ្ញត្តនូវខ្លួនថា មិនមានសញ្ញាខាងមុខអំពីសេចក្ដីស្លាប់ ដោយហេតុ ៨ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ ជាអ្នកប្រកបដោយឧទ្ធមាឃតនទិដ្ឋិ ជាអសញ្ញីវាទ បញ្ញត្តនូវខ្លួនថា មិនមានសញ្ញាខាងមុខអំពីសេចក្ដីស្លាប់ ពួកសមណព្រាហ្មណ៍ទាំងអស់នោះ រមែងបញ្ញត្តដោយហេតុ ៨ យ៉ាងនេះឯង ឬក៏បណ្ដាហេតុ ៨ យ៉ាងនុ៎ះ

វា អញ្ញតរេន នត្ថិ ឥតោ ពហិទ្ធា ។ បេ ។ យេហិ តថាគតស្ស យថាភុច្ចំ វណ្ណំ សម្មា វទមានា វទេយ្យុំ ។

(៤៨) សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា ឧទ្ធមាឃតនិកា នេវសញ្ញីនាសញ្ញីវាទា ឧទ្ធមាឃតនា នេវសញ្ញីនាសញ្ញិមត្តានំ(១) បញ្ញបេន្តិ អដ្ឋហិ វត្ថូហិ ។ តេ ច ភោន្តោ សមណព្រាហ្មណា កិមាគម្ម កិមារព្ភ ឧទ្ធមាឃតនិកា នេវសញ្ញីនាសញ្ញីវាទា ឧទ្ធមាឃតនា នេវសញ្ញីនាសញ្ញិមត្តានំ បញ្ញបេន្តិ អដ្ឋហិ វត្ថូហិ ។ រូបី អត្តា ហោតិ អរោគោ បរំ មរណា នេវសញ្ញីនាសញ្ញីតិ នំ បញ្ញបេន្តិ ។ អរូបី អត្តា ហោតិ ។ បេ ។ រូបី ច អរូបី ច អត្តា ហោតិ ។ នេវរូបី នារូបី អត្តា ហោតិ ។ អន្តវា អត្តា ហោតិ ។ អនន្តវា អត្តា ហោតិ ។ អន្តវា ច អនន្តវា ច អត្តា ហោតិ ។

---

១ ឱ. នេវសញ្ញី នាសញ្ញី អត្តានំ ។ ម. នេវសញ្ញីនាសញ្ញី អត្តានំ ។

ដោយហេតុណាមួយ មិនមានហេតុដទៃ ក្រៅពីនេះឡើយ ។ បេ ។ ពួកជនកាលនិយាយសរសើរគុណ របស់ព្រះតថាគត តាមសេចក្តីពិត ដោយធម៌ទាំងឡាយណា ។

(៤៨) ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ ជាអ្នកប្រកបដោយឧទ្ធមាឃតនទិដ្ឋិ ជានេវសញ្ញីនាសញ្ញីវាទ បញ្ញត្តនូវខ្លួនថាមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន (មានសញ្ញាដូចជាគ្មានសញ្ញាក៏មានសញ្ញាដ៏ល្អិត) ខាងមុខអំពីសេចក្តីស្លាប់ ដោយហេតុ ៨ យ៉ាង ។ ចុះពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកប្រកបដោយឧទ្ធមាឃតនទិដ្ឋិ ជានេវសញ្ញីនាសញ្ញីវាទ បញ្ញត្តនូវខ្លួនថា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែនខាងមុខអំពីសេចក្តីស្លាប់ ដោយហេតុ ៨ យ៉ាង តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ សមណព្រាហ្មណ៍ពួកនោះ បញ្ញត្តនូវខ្លួននោះថា ខ្លួនមានរូប តែមិនមានរោគ មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ខាងមុខអំពីសេចក្តីស្លាប់ ។ បញ្ញត្តនូវខ្លួននោះថា ខ្លួនមិនមានរូបក៏មាន ។ បេ ។ ខ្លួនមានរូបខ្លះ មិនមានរូបខ្លះក៏មាន ។ ខ្លួនមានរូបក៏មិនមែន មិនមានរូបក៏មិនមែនក៏មាន ។ ខ្លួនមានទីបំផុតក៏មាន ។ ខ្លួនមិនមានទីបំផុតក៏មាន ។ ខ្លួនមានទីបំផុតខ្លះ មិនមានទីបំផុតខ្លះក៏មាន ។

នេវន្តវា នានន្តវា អត្តា ហោតិ អរោគោ បរម្មរណា នេវសញ្ញីនាសញ្ញីតិ នំ បញ្ញបេន្តិ ។ ឥមេហិ ខោ តេ ភិក្ខវេ សមណព្រាហ្មណា ឧទ្ធមាឃតនិកា នេវសញ្ញីនាសញ្ញីវាទា ឧទ្ធមាឃតនំ នេវសញ្ញីនាសញ្ញឹ អត្តានំ បញ្ញបេន្តិ អដ្ឋហិ វត្ថូហិ ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឧទ្ធមាឃតនិកា នេវសញ្ញីនាសញ្ញីវាទា ឧទ្ធមាឃតនំ នេវសញ្ញីនាសញ្ញឹ អត្តានំ បញ្ញបេន្តិ សព្វេ តេ ឥមេហេវ អដ្ឋហិ វត្ថូហិ ឯតេសំ វា អញ្ញតរេន នត្ថិ ឥតោ ពហិទ្ធា ។ បេ ។ យេហិ តថាគតស្ស យថាភុច្ចំ វណ្ណំ សម្មា វទមានា វទេយ្យុំ ។

(៨៩) សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា ឧច្ឆេទវាទា សតោ[១] សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញបេន្តិ សត្តហិ វត្ថូហិ ។ តេ ច ភោន្តោ សមណព្រាហ្មណា កិមាគម្ម កិមារព្ភ ឧច្ឆេទវាទា សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញបេន្តិ សត្តហិ

---

១ ឱ. សតោតិ ន ទិស្សតិ ។

ខ្លួនមានទីបំផុតក៏មិនមែន មិនមានទីបំផុតក៏មិនមែន តែមិនមានរោគ មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ខាងមុខអំពីសេចក្តីស្លាប់ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍ទាំងនោះ ជាអ្នកប្រកបដោយឧទ្ធមាឃាតនទិដ្ឋិ ជានេវសញ្ញីនាសញ្ញីវាទ បញ្ញត្តនូវខ្លួនថា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ខាងមុខអំពីសេចក្តីស្លាប់ ដោយហេតុ៨យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ ជាអ្នកប្រកបដោយឧទ្ធមាឃាតនទិដ្ឋិ ជានេវសញ្ញីនាសញ្ញីវាទ បញ្ញត្តនូវខ្លួនថា មានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ខាងមុខអំពីសេចក្តីស្លាប់ សមណៈឬព្រាហ្មណ៍ទាំងអស់នោះ រមែងបញ្ញត្តដោយហេតុ ៨ យ៉ាងនេះឯង ឬក៏បណ្តាហេតុ ៨ យ៉ាងនុ៎ះ ដោយហេតុណាមួយ មិនមានហេតុដទៃក្រៅពីនេះឡើយ ។ បេ ។ ពួកជនកាលនិយាយសរសើរគុណ របស់ព្រះតថាគតតាមសេចក្តីពិត ដោយធម៌ទាំងឡាយណា ។

(៨៩) ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ ជាឧច្ឆេទវាទ (អ្នកពោលថាដាច់សូន្យ) បញ្ញត្តនូវការដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀត នៃសត្វដែលមាននៅ ដោយហេតុ៧យ៉ាង ។ ចុះពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះជាឧច្ឆេទវាទ បញ្ញត្តនូវការដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀត នៃសត្វដែលមាននៅដោយហេតុ៧

វទន្តិ ។ ឥធ ភិក្ខវេ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា ឯវំវាទី ហោតិ ឯវំទិដ្ឋិ យតោ ខោ ភោ អយំ អត្តា រូបី ចាតុម្មហាភូតិកោ មាតាបេត្តិក-សម្ភវោ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណា ឯត្តាវតា ខោ ភោ អយំ អត្តា សម្មា សមុច្ឆិន្នោ ហោតីតិ ។ ឥត្ថេកេ សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញាបេន្តិ ។ តមញ្ញោ[១] ឯវមាហ អត្ថិ ខោ ភោ ឯសោ អត្តា យំ ត្វំ វទេសិ នេសោ នត្ថីតិ វទាមិ នោ ច ខោ ភោ អយំ អត្តា ឯត្តាវតា សម្មា សមុច្ឆិន្នោ ហោតិ អត្ថិ ខោ ភោ អញ្ញោ អត្តា ទិព្វោ រូបី កាមាវចរោ កពឡីង្ការាហារភក្ខោ[២] តំ ត្វំ ន ជានាសិ ន បស្សសិ តមហំ ជានាមិ បស្សាមិ សោ ខោ ភោ អត្តា យតោ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ

១ ឱ. តំ អញ្ញោ ។ ២ ឱ. កពឡិង្ការាហារភក្ខោ ។ ម. កពឡីការាហារភក្ខោ ។

យ៉ាង តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយ ក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍ ជាអ្នកមានពាក្យយ៉ាងនេះ មានសេចក្តីយល់ឃើញយ៉ាងនេះថា នែអ្នកដ៏ចំរើន ខ្លួននេះមានរូបប្រកបដោយមហាភូតរូប៤ កើតអំពីមាតាបិតា លុះកាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាស ខាងមុខអំពីសេចក្តីស្លាប់ទៅ រមែងមិនមាន នែអ្នកដ៏ចំរើន ព្រោះហេតុមានប្រមាណប៉ុណ្ណេះ ទើបខ្លួននោះឯងឈ្មោះថាដាច់សូន្យដោយប្រាកដ ។ សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវការដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀត នៃសត្វដែលមាននៅ ដោយប្រការដូច្នេះឯង ។ មានបុគ្គលដទៃក្រៅអំពីបុគ្គលពួកនោះនិយាយយ៉ាងនេះថា នែអ្នកដ៏ចំរើន អ្នកនិយាយថាខ្លួនមាននុ៎ះ ក៏មានមែនឯខ្ញុំមិននិយាយថា ខ្លួននុ៎ះមិនមានទេ នែអ្នកដ៏ចំរើន តែថាខ្លួននេះមិនមែនជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណេះឡើយនែអ្នកដ៏ចំរើន មានខ្លួនដទៃទៀត មានរូបជាទិព្វ ជាកាមាវចរទេវតា (ត្រាច់ទៅក្នុងកាមភព) មានកវឡិង្ការាហារជាចំណី អ្នកមិនដឹងមិនឃើញនូវខ្លួននោះឡើយ ឯខ្ញុំទើបដឹងទើបឃើញនូវខ្លួននោះ នែអ្នកដ៏ចំរើន ខ្លួននោះឯងលុះមានកាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាសខាងមុខ

ច ហោតិ បរំ មរណា ឯត្តាវតា ខោ ភោ អយំ អត្តា សម្មា សមុច្ឆិន្នោ ហោតីតិ ។ ឥត្ថេកេ សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញបេន្តិ ។ តមញ្ញោ ឯវមាហ អត្ថិ ខោ ភោ ឯសោ អត្តា យំ ត្វំ វទេសិ នេសោ នត្ថីតិ វទាមិ នេសោ ខោ ភោ អយំ អត្តា ឯត្តាវតា សម្មា សមុច្ឆិន្នោ ហោតិ អត្ថិ ខោ ភោ អញ្ញោ អត្តា ទិព្វោ រូបី មនោមយោ សព្វង្គបច្ចង្គី អហីនិន្ទ្រិយោ តំ ត្វំ ន ជានាសិ ន បស្សសិ តមហំ ជានាមិ បស្សាមិ សោ ខោ ភោ អត្តា យតោ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណា ឯត្តាវតា ខោ ភោ អយំ អត្តា សម្មា សមុច្ឆិន្នោ ហោតីតិ ។ ឥត្ថេកេ សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញបេន្តិ ។ តមញ្ញោ ឯវមាហ អត្ថិ ខោ ភោ ឯសោ អត្តា យំ ត្វំ វទេសិ នេសោ នត្ថីតិ

អំពីសេចក្ដីស្លាប់ទៅ មិនកើតទៀតទេ នែអ្នកដ៏ចំរើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះ ទើបខ្លួននេះឈ្មោះថាជាសភាវៈដាច់សូន្យដោយពិត ៗ សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវការដាច់សូន្យ នូវសេចក្ដីវិនាស នូវសេចក្ដីមិនកើតទៀត នៃសត្វដែលមាននៅ ដោយប្រការដូច្នេះឯង ៗ មានបុគ្គលដទៃក្រៅអំពីបុគ្គលពួកនោះនិយាយយ៉ាងនេះថា នែអ្នកដ៏ចំរើន អ្នកនិយាយថាខ្លួនមាននុ៎ះ ក៏មានមែន ឯខ្ញុំមិននិយាយថាខ្លួននុ៎ះមិនមានទេ នែអ្នកដ៏ចំរើន តែថាខ្លួននេះមិនមែនជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណោះឡើយ នែអ្នកដ៏ចំរើន មានខ្លួនដទៃទៀត មានរូបជាទិព្វ សម្រេចដោយឈានចិត្ត មានអវយវៈធំតូចគ្រប់សព្វ មានឥន្ទ្រិយមិនថោកទាប គឺមានឥន្ទ្រិយពេញលេញ អ្នកមិនដឹង មិនឃើញនូវខ្លួននោះឡើយ ឯខ្ញុំទើបដឹង ទើបឃើញនូវខ្លួននោះ នែអ្នកដ៏ចំរើន ខ្លួននោះឯង លុះកាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាស ខាងមុខអំពីសេចក្ដីស្លាប់ទៅ មិនកើតទៀតទេ នែអ្នកដ៏ចំរើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះ ទើបខ្លួននេះឈ្មោះថាជាសភាវៈដាច់សូន្យដោយពិត ៗ សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវការដាច់សូន្យ នូវសេចក្ដីវិនាស នូវសេចក្ដីមិនកើតទៀត នៃសត្វដែលមាននៅ ដោយប្រការដូច្នេះឯង ៗ មានបុគ្គលដទៃក្រៅអំពីបុគ្គលពួកនោះនិយាយយ៉ាងនេះថា នែអ្នកដ៏ចំរើន អ្នកនិយាយថា

វទាមិ នោ ច ខោ ភោ អយំ អត្តា ឯត្តាវតា សម្មា សមុច្ឆិន្នោ ហោតិ អត្ថិ ខោ ភោ អញ្ញោ អត្តា សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ(១) អាកាសានញ្ចាយតនូបគោ យំ(២) ត្វំ ន ជានាសិ ន បស្សសិ តមហំ ជានាមិ បស្សាមិ សោ ខោ ភោ អត្តា យតោ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណា ឯត្តាវតា ខោ ភោ អយំ អត្តា សម្មា សមុច្ឆិន្នោ ហោតីតិ ។ ឥត្ថេកេ សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញបេន្តិ ។ តមញ្ញោ ឯវមាហ អត្ថិ ខោ ភោ ឯសោ អត្តា យំ ត្វំ វទេសិ នេសោ នត្ថីតិ វទាមិ នោ ច ខោ ភោ អយំ អត្តា ឯត្តាវតា សម្មា សមុច្ឆិន្នោ ហោតិ អត្ថិ

១ ឱ. ឧកាសោតិ ។ ២ ឱ. ម. តំ ។

ខ្លួនមាននុ៎ះក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួននុ៎ះមិនមានទេ នែអ្នកដ៏ចំរើន តែថា ខ្លួននេះមិនមែនជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណោះឡើយ នែអ្នកដ៏ចំរើន មានខ្លួនដទៃដែលចូលទៅកាន់អាកាសានញ្ចាយតនភព មានអារម្មណ៍ថាអាកាសមិនមានទីបំផុតដូច្នេះ ព្រោះកន្លងនូវរូបសញ្ញា គឺសេចក្តីសំគាល់ក្នុងរូប ព្រោះអស់ទៅនៃបដិឃសញ្ញា គឺសេចក្តីសំគាល់ ក្នុងអារម្មណ៍ដែលជាទីខ្ទាំងខ្ទប់ចិត្ត ព្រោះមិនធ្វើទុកក្នុងចិត្តដល់នានត្តសញ្ញា គឺសេចក្តីសំគាល់ក្នុងអារម្មណ៍ផ្សេង ៗ ដោយសព្វគ្រប់ អ្នកមិនដឹង មិនឃើញនូវខ្លួនណា ខ្ញុំទើបដឹង ទើបឃើញនូវខ្លួននោះ នែអ្នកដ៏ចំរើន ខ្លួននោះឯង លុះកាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាស ខាងមុខអំពីសេចក្តីស្លាប់ទៅ មិនកើតទៀតទេ នែអ្នកដ៏ចំរើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះ ទើបខ្លួននេះឈ្មោះថាជាសភាវៈដាច់សូន្យដោយពិត ៗ សមណព្រាហ្មណ៍ ពួកមួយបញ្ញត្តនូវការដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀត នៃសត្វដែលមាននៅ ដោយប្រការដូច្នេះឯង ៗ មានបុគ្គលដទៃក្រៅអំពីបុគ្គលពួកនោះនិយាយយ៉ាងនេះថា នែអ្នកដ៏ចំរើន អ្នកនិយាយថាខ្លួនមាននុ៎ះ ក៏មានមែន ឯខ្ញុំមិននិយាយថាខ្លួននុ៎ះមិនមានទេ នែអ្នកដ៏ចំរើន តែថាខ្លួននេះ មិនមែនជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណោះឡើយ

ខោ ភោ អញ្ញោ អត្តា សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនូបគោ យំ ត្វំ ន ជានាសិ ន បស្សសិ តមហំ ជានាមិ បស្សាមិ សោ ខោ ភោ អត្តា យតោ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ ន ហោតិ បរម្មរណា ឯត្តាវតា ខោ ភោ អយំ អត្តា សម្មា សមុច្ឆិន្នោ ហោតីតិ ។ ឥត្ថេកេ សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញាបេន្តិ ។ តមញ្ញោ ឯវមាហ អត្ថិ ខោ ភោ ឯសោ អត្តា យំ ត្វំ វទេសិ នេសោ នត្ថីតិ វទាមិ នោ ច ខោ ភោ អយំ អត្តា ឯត្តាវតា សម្មា សមុច្ឆិន្នោ ហោតិ អត្ថិ ខោ ភោ អញ្ញោ អត្តា សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនូបគោ យំ ត្វំ ន ជានាសិ ន បស្សសិ តមហំ ជានាមិ បស្សាមិ សោ ខោ ភោ អត្តា យតោ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិនស្សតិ

នែអ្នកដ៏ចំរើន មានខ្លួនដទៃ ដែលកន្លងបង់នូវអាកាសានញ្ចាយតនជ្ឈាន ដោយសព្វគ្រប់ ហើយចូលទៅកាន់វិញ្ញាណញ្ចាយតនភព មានអារម្មណ៍ថា វិញ្ញាណមិនមានទីបំផុតដូច្នេះ អ្នកមិនដឹង មិនឃើញនូវខ្លួនណា ខ្ញុំទើបដឹង ទើបឃើញនូវខ្លួននោះ នែអ្នកដ៏ចំរើន ខ្លួននោះឯង លុះកាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាស ខាងមុខអំពីសេចក្តីស្លាប់ទៅ មិនកើតទៀតឡើយ នែអ្នកដ៏ចំរើន ព្រោះហេតុមានប្រមាណប៉ុណ្ណេះ ទើបខ្លួននេះឈ្មោះថាជាសភាវៈដាច់សូន្យដោយពិត ៗ សមណព្រាហ្មណ៍ពួកមួយ បញ្ញត្ត នូវការដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀតនៃសត្វដែលមានទៅ ដោយប្រការដូច្នេះឯង ៗ មានបុគ្គលដទៃក្រៅអំពីបុគ្គលពួកនោះ និយាយយ៉ាងនេះថា នែអ្នកដ៏ចំរើន អ្នកនិយាយថា ខ្លួនមាននុ៎ះក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួននុ៎ះមិនមានទេ នែអ្នកដ៏ចំរើន តែថា ខ្លួននេះមិនមែន ជាសភាវៈដាច់សូន្យ ព្រោះហេតុមានប្រមាណប៉ុណ្ណោះឡើយ នែអ្នកដ៏ចំរើន មានខ្លួនដទៃដែលកន្លងបង់នូវវិញ្ញាណញ្ចាយតនៈដោយសព្វគ្រប់ ហើយចូលទៅកាន់អាកិញ្ចញ្ញាយតនភព មានអារម្មណ៍ថា អ្វីតិចតួចក៏មិនមានដូច្នេះ អ្នកមិនដឹង មិនឃើញនូវខ្លួនណា ឯខ្ញុំទើបដឹង ទើបឃើញនូវខ្លួននោះ នែអ្នកដ៏ចំរើន ខ្លួននោះឯង លុះកាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាស

ន ហោតិ បរម្មរណា ឯត្តាវតា ខោ ភោ អយំ អត្តា សម្មា
សមុច្ឆិន្នោ ហោតីតិ ។ ឥត្ថេកេ សតោ សត្តស្ស ឧច្ឆេទំ
វិនាសំ វិភវំ បញ្ញាបេន្តិ ។ តមញ្ញោ ឯវមាហ អត្ថិ ខោ
ភោ ឯសោ អត្តា យំ ត្វំ វទេសិ នេសោ នត្ថីតិ វទាមិ
នោ ច ខោ ភោ អយំ អត្តា ឯត្តាវតា សម្មា សមុច្ឆិ-
ន្នោ ហោតិ អត្ថិ ខោ ភោ អញ្ញោ អត្តា សព្វសោ អា-
កិញ្ចញ្ញាយតនំ សមតិក្កម្ម សន្តមេតំ បណីតមេតន្តិ
នេវសញ្ញានាសញ្ញាយតនូបគោ យំ ត្វំ ន ជានាសិ ន
បស្សសិ តមហំ ជានាមិ បស្សាមិ សោ ខោ ភោ
អយំ(១) អត្តា យតោ កាយស្ស ភេទា ឧច្ឆិជ្ជតិ វិន-
ស្សតិ ន ហោតិ បរម្មរណា ឯត្តាវតា ខោ ភោ អយំ
អត្តា សម្មា សមុច្ឆិន្នោ ហោតីតិ ។ ឥត្ថេកេ ស-
តោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញាបេន្តិ ។

---

១ ម. អយន្តិ បាឋោ ន ទិស្សតិ ។

ខាងមុខអំពីសេចក្ដីស្លាប់ទៅ មិនកើតទៀតឡើយ នែអ្នកដ៏ចំរើន ខ្លួននេះ ឈ្មោះថាជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណេះ ឯង ៗ សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវការដាច់សូន្យ នូវសេចក្ដីវិនាស នូវសេចក្ដីមិនកើតទៀត នៃសត្វដែលមាននៅ ដោយប្រការដូច្នេះឯង ៗ មានបុគ្គលដទៃ ក្រៅអំពីបុគ្គលពួកនោះ និយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចំរើន អ្នកនិយាយថា ខ្លួនមាននុះក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួននុះមិនមានទេ ម្នាលអ្នកដ៏ចំរើន តែថា ខ្លួននេះមិនមែន ជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណេះឡើយ ម្នាលអ្នកដ៏ចំរើន មានខ្លួនដទៃ ដែលកន្លងបង់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយសព្វគ្រប់ ហើយចូលទៅកាន់នេវសញ្ញានាសញ្ញាយតនគត មានអារម្មណ៍ថា នេះជាធម្មជាត ស្ងប់ នេះជាធម្មជាត ឧត្តម អ្នកមិនដឹង មិនឃើញនូវខ្លួនណា ឯខ្ញុំទើបដឹង ទើបឃើញនូវខ្លួននោះ នែអ្នកដ៏ចំរើន ខ្លួននេះឯង លុះកាយបែកធ្លាយទៅកាលណា រមែងដាច់សូន្យ រមែងវិនាស ខាងមុខអំពីសេចក្ដីស្លាប់ មិនកើតទៀតឡើយ នែអ្នកដ៏ចំរើន ខ្លួននេះឈ្មោះថាជាសភាវៈដាច់សូន្យដោយពិត ព្រោះហេតុមានប្រមាណប៉ុណ្ណេះឯង ៗ សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវការដាច់សូន្យ នូវសេចក្ដីវិនាស នូវសេចក្ដីមិនកើតទៀតនៃសត្វដែលមាននៅ ដោយប្រការដូច្នេះឯង ៗ

ឥមេហិ ខោ តេ ភិក្ខវេ សមណព្រាហ្មណា ឧច្ឆេទវាទា សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញាបេន្តិ សត្តហិ វត្ថូហិ ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ឧច្ឆេទវាទា សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញាបេន្តិ សព្វេ តេ ឥមេហេវ សត្តហិ វត្ថូហិ ។ បេ ។ យេហិ តថាគតស្ស យថាភុច្ចំ វណ្ណំ សម្មា វទមានា វទេយ្យុំ ។

(៨០) សន្តិ ភិក្ខវេ ឯកេ សមណព្រាហ្មណា ទិដ្ឋធម្មនិព្វានវាទា សតោ សត្តស្ស បរមទិដ្ឋធម្មនិព្វានំ បញ្ញាបេន្តិ បញ្ចហិ វត្ថូហិ ។ តេ ច ភោន្តោ សមណព្រាហ្មណា កិមាគម្ម កិមារព្ភ ទិដ្ឋធម្មនិព្វានវាទា សតោ សត្តស្ស បរមទិដ្ឋធម្មនិព្វានំ បញ្ញាបេន្តិ បញ្ចហិ វត្ថូហិ ។ ឥធ ភិក្ខវេ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា ឯវំវាទី ហោតិ ឯវំទិដ្ឋិ យតោ ខោ

ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍ទាំងនោះ ជាឧច្ឆេទវាទ រមែងបញ្ញត្តនូវការដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀតនៃសត្វដែលមាននៅ ដោយហេតុ ៧ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ ជាឧច្ឆេទវាទ បញ្ញត្តនូវការដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀត នៃសត្វដែលមាននៅ ពួកសមណព្រាហ្មណ៍ទាំងអស់នោះ រមែងបញ្ញត្តដោយហេតុ ៧ យ៉ាងនេះឯង ។ បេ ។ ពួកជន កាលនិយាយសរសើរគុណ របស់ព្រះតថាគត តាមសេចក្តីពិត ដោយធម៌ទាំងឡាយណា ។

(៩០) ម្នាលភិក្ខុទាំងឡាយ មានសមណព្រាហ្មណ៍ពួកមួយ ជាទិដ្ឋធម្មនិព្វានវាទ (អ្នកពោលនូវនិព្វានគឺសេចក្តីរលត់ទុក្ខក្នុងបច្ចុប្បន្ន) បញ្ញត្តព្រះនិព្វាន ក្នុងបច្ចុប្បន្នថាជាគុណជាត យ៉ាងក្រៃលែងរបស់សត្វ ដែលមាននៅដោយហេតុ ៥ យ៉ាង ។ ចុះពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាទិដ្ឋធម្មនិព្វានវាទ បញ្ញត្តព្រះនិព្វានក្នុងបច្ចុប្បន្នថាជាគុណ យ៉ាងក្រៃលែងរបស់សត្វដែលមាននៅ ដោយហេតុ ៥ យ៉ាង តើព្រោះអាស្រ័យអ្វី ព្រោះប្រារព្ធអ្វី ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកមួយក្នុងលោកនេះ ជាសមណៈឬព្រាហ្មណ៍មានពាក្យយ៉ាងនេះ មានសេចក្តីយល់ឃើញយ៉ាងនេះថា

កោ អយំ អត្តា បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គីភូតោ បរិចារេតិ ឯត្តាវតា ខោ ភោ អយំ អត្តា បរមទិដ្ឋធម្មនិព្វានប្បត្តោ[១] ហោតីតិ ។ ឥត្ថេកេ សតោ សត្តស្ស បរមទិដ្ឋធម្មនិព្វានំ បញ្ញបេន្តិ ។ តមញ្ញោ ឯវមាហ អត្ថិ ខោ ភោ ឯសោ អត្តា យំ ត្វំ វទេសិ នេសោ នត្ថីតិ វទាមិ នោ ច ខោ ភោ អយំ អត្តា ឯត្តាវតា បរមទិដ្ឋធម្មនិព្វានប្បត្តោ ហោតិ តំ កិស្ស ហេតុ កាមា ហិ ភោ អនិច្ចា ទុក្ខា វិបរិណាមធម្មា តេសំ វិបរិណាមញ្ញថាភាវា ឧប្បជ្ជន្តិ សោកបរិទេវទុក្ខទោមនស្សុបាយាសា យតោ ខោ ភោ អយំ អត្តា វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ឯត្តាវតា ខោ ភោ

១ បរមទិដ្ឋធម្មនិព្វានំ បត្តោតិបិ បាឋោ ។

នែអ្នកដ៏ចំរើន កាលណាបើខ្លួននេះឆ្អែតស្កប់ស្កល់ ឲ្យគេបម្រើដោយកាមគុណ ៥ ម្នាលអ្នកដ៏ចំរើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះឯង ទើបខ្លួននេះឈ្មោះថាជាអត្តភាពដល់នូវព្រះនិព្វាន ក្នុងបច្ចុប្បន្នថាជាគុណជាតយ៉ាងក្រៃលែង។ សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវព្រះនិព្វានក្នុងបច្ចុប្បន្នថាជាគុណជាតយ៉ាងក្រៃលែង របស់សត្វដែលមាននៅ ដោយប្រការដូច្នេះឯង ។ មានបុគ្គលដទៃក្រៅអំពីបុគ្គលពួកនោះនិយាយយ៉ាងនេះថា នែអ្នកដ៏ចំរើន អ្នកនិយាយថាខ្លួនមាននុ៎ះ ក៏មានមែន ឯខ្ញុំមិននិយាយថាខ្លួននុ៎ះមិនមានទេ នែអ្នកដ៏ចំរើន តែថាខ្លួននេះមិនមែនដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្នថាជាគុណជាត យ៉ាងក្រៃលែង ព្រោះហេតុមានប្រមាណប៉ុណ្ណោះទេ ពាក្យដែលខ្ញុំថាដូច្នោះតើព្រោះហេតុអ្វី ម្នាលអ្នកដ៏ចំរើន ព្រោះហេតុថា កាមទាំងឡាយមិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា បានសេចក្តីស្តាយស្រណោះសេចក្តីខ្សឹកខ្សួល សេចក្តីលំបាកកាយ សេចក្តីលំបាកចិត្ត សេចក្តីចង្អៀតចង្អល់ចិត្ត រមែងកើតឡើង ព្រោះកាមទាំងនោះ ប្រែប្រួលទៅប្រព្រឹត្តទៅដោយប្រការដទៃ នែអ្នកដ៏ចំរើន ខ្លួននេះឯង កាលណាបានស្ងប់ស្ងាត់ចាកកាមទាំងឡាយហើយ បានស្ងប់ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយ បានដល់បឋមជ្ឈានប្រកបដោយវិតក្កៈវិចារៈមានបីតិនិងសុខៈកើតអំពីសេចក្តីស្ងាត់ ម្នាលអ្នកដ៏ចំរើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះ

អយំ អត្តា បរមទិដ្ឋធម្មនិព្វានប្បត្តោ ហោតីតិ ។ ឥត្ថេកេ សតោ សត្តស្ស បរមទិដ្ឋធម្មនិព្វានំ បញ្ញបេន្តិ ។ តមញ្ញោ ឯវមាហ អត្ថិ ខោ ភោ ឯសោ អត្តា យំ ត្វំ វទេសិ នេសោ នត្ថីតិ វទាមិ នោ ច ខោ ភោ អយំ អត្តា ឯត្តាវតា បរមទិដ្ឋធម្មនិព្វានប្បត្តោ ហោតិ តំ កិស្ស ហេតុ យទេវ តត្ថ វិតក្កិតំ វិចារិតំ ឯតេន ឯតំ ឱឡារិកំ អក្ខាយតិ យតោ ខោ ភោ អយំ អត្តា វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយំ ឈានំ ឧបសម្បជ្ជ វិហរតិ ឯត្តាវតា ខោ ភោ អយំ អត្តា បរមទិដ្ឋធម្មនិព្វានប្បត្តោ ហោតីតិ ។

ទើបខ្លួននេះឈ្មោះថា បានដល់នូវព្រះនិព្វាន ក្នុងបច្ចុប្បន្នថាជាគុណ-ជាតយ៉ាងក្រៃលែង ។ សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវព្រះនិព្វាន ក្នុងបច្ចុប្បន្នថាជាគុណជាតយ៉ាងក្រៃលែង របស់សត្វដែលមាននៅ ដោយប្រការដូច្នេះឯង ។ មានបុគ្គលដទៃក្រៅអំពីបុគ្គលពួកនោះ និយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចំរើន អ្នកនិយាយថា ខ្លួនមាននុ៎ះ ក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួននុ៎ះមិនមានទេ ម្នាលអ្នកដ៏ចំរើន តែថា ខ្លួននេះមិនមែនដល់នូវព្រះនិព្វាន ក្នុងបច្ចុប្បន្នថាជាគុណជាត យ៉ាងក្រៃលែង ព្រោះហេតុមានប្រមាណប៉ុណ្ណេះឡើយ ពាក្យដែលថាដូច្នោះ តើព្រោះហេតុអ្វី ព្រោះហេតុថា ចិត្តដែលប្រកបដោយវិតក្កៈនិងវិចារៈមាននៅក្នុងបឋមជ្ឈាននោះ បឋមជ្ឈាននុ៎ះនៅប្រាកដ ជាឈានគ្រោតគ្រាត ព្រោះមានវិតក្កៈនិងវិចារៈនុ៎ះនៅឡើយ ម្នាលអ្នកដ៏ចំរើន កាលណាបើខ្លួននេះបានរម្ងាប់វិតក្កៈនិងវិចារៈអស់ហើយ ក៏បានដល់នូវទុតិយជ្ឈាន ជាធម្មជាតច្បាស់ប្រាកដក្នុងខ្លួន មានសេចក្តីជ្រះថ្លាគឺសទ្ធា ជាសភាពនៃចិត្តដ៏ខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខៈកើតអំពីសមាធិ គឺបឋមជ្ឈាន ម្នាលអ្នកដ៏ចំរើន ព្រោះហេតុមានប្រមាណប៉ុណ្ណេះ ទើបខ្លួននេះឈ្មោះថាបានដល់នូវព្រះនិព្វាន ក្នុងបច្ចុប្បន្នថាជាគុណជាត យ៉ាងក្រៃលែង ។

ឥត្ថេកេ សតោ សត្តស្ស បរមទិដ្ឋធម្មនិព្វានំ បញ្ញា-
បេន្តិ ។ តមញ្ញោ ឯវមាហ អត្ថិ ខោ ភោ ឯសោ
អត្តា យំ ត្វំ វទេសិ នេសោ នត្ថីតិ វទាមិ នោ ច
ខោ ភោ អយំ អត្តា ឯត្តាវតា បរមទិដ្ឋធម្មនិព្វានប្បត្តោ
ហោតិ តំ កិស្ស ហេតុ យទេវ តត្ថ បីតិគតំ
ចេតសោ ឧព្ពិលាវិតត្តំ(១) ឯតេនេតំ ឱឡារិកំ អក្ខាយតិ
យតោ ខោ ភោ អយំ អត្តា បីតិយា ច វិរាគា
ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច
កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧ-
បេក្ខកោ សតិមា សុខវិហារីតិ តតិយំ ឈានំ ឧប-
សម្បជ្ជ វិហរតិ ឯត្តាវតា ខោ ភោ អយំ អត្តា
បរមទិដ្ឋធម្មនិព្វានប្បត្តោ ហោតីតិ ។ ឥត្ថេកេ សតោ
សត្តស្ស បរមទិដ្ឋធម្មនិព្វានំ បញ្ញាបេន្តិ ។ តមញ្ញោ

---

១ ម. ឧប្បិលាវិតត្តំ ។ ឱ. ឧព្ភិលាវិតត្តំ ។

សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវព្រះនិព្វាន ក្នុងបច្ចុប្បន្នថាជាគុណ-ជាតយ៉ាងក្រៃលែង របស់សត្វដែលមាននៅ ដោយប្រការដូច្នេះឯង ។ មានបុគ្គលដទៃក្រៅអំពីបុគ្គលពួកនោះ និយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចំរើន អ្នកនិយាយថា ខ្លួនមាននុ៎ះ ក៏មានមែន ខ្ញុំមិននិយាយថា ខ្លួននុ៎ះមិនមានទេ ម្នាលអ្នកដ៏ចំរើន តែថា ខ្លួននេះមិនមែន បានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្នថាជាគុណជាត យ៉ាងក្រៃលែង ព្រោះហេតុមានប្រមាណប៉ុណ្ណោះឡើយ ពាក្យដែលខ្ញុំថាយ៉ាងនោះ តើព្រោះហេតុអ្វី ព្រោះហេតុថា បីតិជាទីកើតឡើងនៃចិត្តមានក្នុងទុតិយជ្ឈាននុ៎ះ នៅប្រាកដជាឈានគ្រោតគ្រាត ព្រោះមានបីតិនុ៎ះនៅឡើយ ម្នាលអ្នកដ៏ចំរើន កាលណាបើខ្លួននេះប្រកបដោយឧបេក្ខាផង មានស្មារតីដឹងខ្លួនផង រមែងបានទទួលសុខដោយនាមកាយផង ព្រោះអស់ទៅនៃបីតិ ក៏បានដល់នូវតតិយជ្ឈានដែលព្រះអរិយៈទាំងឡាយប្រាប់ថា លោកអ្នកបានតតិយជ្ឈាននោះប្រកបដោយឧបេក្ខា មានស្មារតីនៅជាសុខដូច្នេះ ម្នាលអ្នកដ៏ចំរើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះ ទើបខ្លួននេះឈ្មោះថា បានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្នថាជាគុណជាត យ៉ាងក្រៃលែង ។ សមណព្រាហ្មណ៍ពួកមួយ បញ្ញត្តនូវព្រះនិព្វាន ក្នុងបច្ចុប្បន្នថាជាគុណជាត យ៉ាងក្រៃលែងរបស់សត្វដែលមាននៅ ដោយប្រការដូច្នេះឯង ។ មានបុគ្គលដទៃ

ឯវមាហ អត្ថិ ខោ ភោ ឯសោ អត្តា យំ ត្វំ វទេសិ នេសោ នត្ថីតិ វទាមិ នោ ច ខោ ភោ អយំ អត្តា ឯត្តាវតា បរមទិដ្ឋធម្មនិព្វានប្បត្តោ ហោតិ តំ កិស្ស ហេតុ យទេវ តត្ថ សុខមិតិ ចេតសោ អាភោគោ ឯតេនេតំ ឱឡារិកំ អក្ខាយតិ យតោ ខោ ភោ អយំ អត្តា សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ឯត្តាវតា ខោ ភោ អយំ អត្តា បរមទិដ្ឋធម្មនិព្វានប្បត្តោ ហោតីតិ ។ ឥត្ថេកេ សតោ សត្តស្ស បរមទិដ្ឋធម្មនិព្វានំ បញ្ញបេន្តិ ។ ឥមេហិ ខោ តេ ភិក្ខវេ សមណព្រាហ្មណា ទិដ្ឋធម្មនិព្វានវាទា សតោ សត្តស្ស បរមទិដ្ឋធម្មនិព្វានំ បញ្ញបេន្តិ បញ្ចហិ វត្ថូហិ ។

ក្រៅអំពីបុគ្គលពួកនោះនិយាយយ៉ាងនេះថា ម្នាលអ្នកដ៏ចំរើន អ្នកនិយាយថា ខ្លួនមាននុ៎ះ ក៏មានមែន ឯខ្ញុំមិននិយាយថា ខ្លួននុ៎ះមិនមានទេ ម្នាលអ្នកដ៏ចំរើន តែថា ខ្លួននេះមិនមែនបានដល់នូវព្រះនិព្វាន ក្នុងបច្ចុប្បន្នថាជាគុណជាតយ៉ាងក្រៃលែង ព្រោះហេតុមានប្រមាណប៉ុណ្ណោះឡើយ ពាក្យដែលខ្ញុំថា យ៉ាងនោះ តើព្រោះហេតុអ្វី ព្រោះហេតុថា សេចក្តីអើពើ ឬសេចក្តីកួចការនៃចិត្តថាសុខដូច្នេះ រមែងមានក្នុងតតិយជ្ឈាននោះ តតិយជ្ឈាននុ៎ះនៅប្រាកដ ជាឈានគ្រោតគ្រាត ព្រោះមានសុខនៅឡើយ ម្នាលអ្នកដ៏ចំរើន កាលណាបើខ្លួននេះបានលះបង់សុខផង លះបង់ទុក្ខផង មានសោមនស្សនឹងទោមនស្សអស់ហើយក្នុងកាលមុន ហើយបានដល់នូវចតុត្ថជ្ឈាន មានអារម្មណ៍មិនមែនជាទុក្ខ មិនមែនជាសុខ គឺជាឧបេក្ខា មានសតិដ៏បរិសុទ្ធកើតអំពីឧបេក្ខាវេទនា ម្នាលអ្នកដ៏ចំរើន ព្រោះហេតុមានប្រមាណប៉ុណ្ណោះឯង ទើបខ្លួននេះឈ្មោះថា បានដល់នូវព្រះនិព្វានក្នុងបច្ចុប្បន្នថាជាគុណជាតយ៉ាងក្រៃលែង ។ សមណព្រាហ្មណ៍ពួកមួយបញ្ញត្តនូវព្រះនិព្វាន ក្នុងបច្ចុប្បន្នថាជាគុណជាត យ៉ាងក្រៃលែងរបស់សត្វដែលមាននៅ ដោយប្រការដូច្នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍នោះ ជាទិដ្ឋធម្មនិព្វានវាទ បញ្ញត្តនូវព្រះនិព្វាន ក្នុងបច្ចុប្បន្នថាជាគុណជាតយ៉ាងក្រៃលែង របស់សត្វដែលមាននៅ ដោយហេតុ ៥ យ៉ាងនេះឯង ។

យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា ទិដ្ឋធម្មនិព្វានវាទា សន្តោ សត្តស្ស បរមទិដ្ឋធម្មនិព្វានំ បញ្ញបេន្តិ សព្វេ តេ ឥមេហេវ បញ្ចហិ វត្ថូហិ ។ បេ ។ យេហិ តថាគតស្ស យថាភុច្ចំ វណ្ណំ សម្មា វទមានា វទេយ្យុំ ។ ឥមេហិ ខោ តេ ភិក្ខវេ សមណព្រាហ្មណា អបរន្តកប្បិកា អបរន្តានុទិដ្ឋិនោ អបរន្តំ អារព្ភ អនេកវិហិតានិ អធិមុត្តិបទានិ អភិវទន្តិ ចតុចត្តាឡីសាយ វត្ថូហិ ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា អបរន្តកប្បិកា អបរន្តានុទិដ្ឋិនោ អបរន្តំ អារព្ភ អនេកវិហិតានិ អធិមុត្តិបទានិ អភិវទន្តិ សព្វេ តេ ឥមេហេវ ចតុចត្តាឡីសាយ វត្ថូហិ ។ បេ ។ យេហិ តថាគតស្ស យថាភុច្ចំ វណ្ណំ សម្មា វទមានា វទេយ្យុំ ។ ឥមេហិ ខោ តេ ភិក្ខវេ សមណព្រាហ្មណា បុព្វន្តកប្បិកា ច អបរន្តកប្បិកា ច បុព្វន្តាបរន្តកប្បិកា ច

ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ ជាទិដ្ឋធម្មនិព្វានវាទ បញ្ញត្តនូវព្រះនិព្វាន ក្នុងបច្ចុប្បន្នថាជាគុណជាតយ៉ាងក្រៃលែង របស់សត្វដែលមាននៅ ពួកសមណព្រាហ្មណ៍ទាំងអស់នោះ រមែងបញ្ញត្ត ដោយហេតុ៥យ៉ាងនេះឯង ។ បេ ។ ពួកជនកាលនិយាយសរសើរគុណ របស់ព្រះតថាគត តាមសេចក្តីពិត ដោយធម៌ទាំងឡាយណា ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍នោះ ជាអ្នកប្រកបដោយអបរន្តកប្បទិដ្ឋិ ជាអ្នកមានសេចក្តីយល់ឃើញរឿយ ៗ នូវខន្ធជាចំណែកខាងមុខ ប្រារព្ធខន្ធជាចំណែកខាងមុខ តែងសំដែងនូវចំណែកនៃទិដ្ឋិ ច្រើនប្រការ ដោយហេតុទាំង៤៤នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ ជាអ្នកប្រកបដោយអបរន្តកប្បទិដ្ឋិ ជាអ្នកមានសេចក្តីយល់ឃើញនូវខន្ធជាចំណែកខាងមុខ ប្រារព្ធខន្ធជាចំណែកខាងមុខ សំដែងនូវចំណែកនៃទិដ្ឋិច្រើនប្រការ សមណព្រាហ្មណ៍ទាំងអស់នោះ រមែងបញ្ញត្តដោយហេតុទាំង ៤៤ នេះឯង ។ បេ ។ ពួកជនកាលនិយាយសរសើរគុណរបស់ព្រះតថាគត តាមសេចក្តីពិត ដោយធម៌ទាំងឡាយណា ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍នោះ ជាអ្នកប្រកបដោយបុព្វន្តកប្បទិដ្ឋិក្តី ប្រកបដោយអបរន្តកប្បទិដ្ឋិក្តី ប្រកបដោយបុព្វន្តាបរន្តកប្បទិដ្ឋិក្តី

បុព្វន្តាបរន្តានុទិដ្ឋិនោ បុព្វន្តាបរន្តំ អារព្ភ អនេកវិហិតានិ អធិមុត្តិបទានិ អភិវទន្តិ ទ្វាសដ្ឋិយា វត្ថូហិ ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា បុព្វន្តកប្បិកា វា អបរន្តកប្បិកា វា បុព្វន្តាបរន្ត-កប្បិកា វា បុព្វន្តាបរន្តានុទិដ្ឋិនោ បុព្វន្តាបរន្តំ អារព្ភ អនេកវិហិតានិ អធិមុត្តិបទានិ អភិវទន្តិ សព្វេ តេ ឥមេហេវ ទ្វាសដ្ឋិយា វត្ថូហិ ឯតេសំ វា អញ្ញតរេន នត្ថិ ឥតោ ពហិទ្ធា ។ តយិទំ ភិក្ខវេ តថាគតោ បជានាតិ ឥមេ ទិដ្ឋិដ្ឋានា ឯវំគហិតា ឯវំបរាមដ្ឋា ឯវំគតិកា ភវន្តិ ឯវំ អភិសម្បរាយាតិ ។ តញ្ច តថាគតោ បជានាតិ តតោ ច ឧត្តរិតរំ បជានាតិ តញ្ច បជាននំ ន បរាមសតិ

ជាអ្នកមានសេចក្ដីយល់ឃើញរឿយ ៗ នូវខន្ធជាចំណែកខាងដើម នឹងខន្ធជាចំណែកខាងមុខ ព្រោះខន្ធជាចំណែកខាងដើម នឹងខន្ធជាចំណែកខាងមុខ ហើយសំដែងនូវចំណែក នៃសេចក្ដីយល់ឃើញ ច្រើនប្រការដោយហេតុទាំង៦២នេះឯង។ម្នាលភិក្ខុទាំងឡាយ ពួកសមណៈព្រាហ្មណ៍ឯណានីមួយ ជាអ្នកប្រកបដោយបុព្វន្តកប្បទិដ្ឋិ ប្រកបដោយអបរន្តកប្ប-ទិដ្ឋិ ប្រកបដោយបុព្វន្តាបរន្តកប្បទិដ្ឋិ ជាអ្នកមានសេចក្ដីយល់ឃើញរឿយៗនូវខន្ធជាចំណែកខាងដើម នឹងខន្ធជាចំណែកខាងមុខ ព្រោះខន្ធជាចំណែកខាងដើម នឹងខន្ធជាចំណែកខាងមុខ សំដែងនូវចំណែកនៃសេចក្ដីយល់ឃើញ ច្រើនប្រការ ពួកសមណព្រាហ្មណ៍ទាំងអស់នោះ រមែងសំដែងដោយហេតុទាំង ៦២ នេះឯង ឬក៏បណ្ដាហេតុទាំង ៦២ នុ៎ះ ដោយហេតុណាមួយ មិនមានហេតុដទៃក្រៅពីនេះឡើយ ។ ម្នាលភិក្ខុទាំងឡាយព្រះតថាគតដឹងច្បាស់នូវហេតុនៃទិដ្ឋិនោះដូច្នេះថា ហេតុនៃទិដ្ឋិទាំងឡាយនេះ ដែលបុគ្គលកាន់យកយ៉ាងនេះ ប្រកាន់ខុសយ៉ាងនេះ មានគតិយ៉ាងនេះ មានការប្រព្រឹត្តទៅក្នុងខាងមុខ យ៉ាងនេះ ។ ព្រះតថាគតដឹងច្បាស់នូវហេតុនៃទិដ្ឋិនោះផង ដឹងច្បាស់ (នូវសីល សមាធិ នឹងសព្វញ្ញុតញ្ញាណ) ដែលជាគុណជាតលើសលុបក្រៃលែង ជាងនោះទៅទៀតផង កាលបើដឹងច្បាស់នូវគុណវិសេសនោះហើយ ក៏មិនបានប្រកាន់ខុសឡើយ មួយ

អបរាមសតោ ចស្ស បច្ចត្តញ្ញេវ(១) និព្វុតិ វិទិតា វេទនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ វិទិត្វា ។ អនុបាទា វិមុត្តោ ភិក្ខវេ តថាគតោ ។ ឥមេ ខោ តេ ភិក្ខវេ ធម្មា គម្ភីរា ទុទ្ទសា ទុរនុពោធា សន្តា បណីតា អតក្កាវចរា និបុណា បណ្ឌិតវេទនីយា យេ តថាគតោ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ យេហិ តថាគតស្ស យថាភុច្ចំ វណ្ណំ សម្មា វទមានា វទេយ្យុំ ។

(៥១) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា សស្សតវាទា សស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ

១ ខ. បច្ចត្តំយេវ ។

ទៀត កាលបើព្រះតថាគតមិនបានប្រកាន់ខុសហើយ ក៏ដឹងនូវព្រះនិព្វាន ជាគ្រឿងរលត់ទៅ (នៃបពមាសក្កិលេស) ដោយខ្លួនឯង ទាំងដឹងច្បាស់ នូវហេតុដែលនាំឲ្យកើតឡើងនៃវេទនាផង នូវសេចក្តីអស់ទៅនៃវេទនាផង នូវសេចក្តីឆ្ងាញ់ពិសារបស់វេទនាផង នូវទោសរបស់វេទនាផង នូវកិរិយារលាស់ចោលនូវវេទនាផង ដោយគួរតាមពិត ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ផុតស្រឡះហើយ (ចាកកិលេស) ព្រោះមិនបានប្រកាន់ (នូវធម៌ណាមួយមានខន្ធជាដើម) ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាដ៏ឧត្តមដោយខ្លួនឯង ហើយអាចសំដែងនូវធម៌ទាំងឡាយបាន ពួកជន កាលពោលសរសើរគុណ របស់ព្រះតថាគត តាមសេចក្តីពិត ដោយធម៌ទាំងឡាយណា ធម៌ទាំងនេះឯង ជាធម៌ដ៏ជ្រាលជ្រៅ ដែលបុគ្គលកម្រឃើញបាន ត្រាស់ដឹងបានដោយកម្រ ជាធម៌ស្ងប់រម្ងាប់ ជាធម៌ថ្លៃថ្លា មិនជាទីស្ទង់ប្រមើលដោយសេចក្តីត្រិះរិះបាន ជាធម៌ដ៏ល្អិត មានតែអ្នកប្រាជ្ញ ទើបអាចដឹងបាន ។

(៥១) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាសស្សតវាទ បញ្ញត្តខ្លួននឹងលោក

ចតូហិ វត្ថូហិ តទបិ តេសំ ភវតំ សមណព្រាហ្មណានំ អជានតំ អបស្សតំ វេទយិតំ តណ្ហាគតានំ បរិត្តស្សិតំ វិប្ផន្ទិតមេវ[១] ។

(៤២) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា ឯកច្ចសស្សតិកា ឯកច្ចអសស្សតិកា ឯកច្ចំ សស្សតំ ឯកច្ចំ អសស្សតំ អត្តានញ្ច លោកញ្ច បញ្ញាបេន្តិ ចតូហិ វត្ថូហិ តទបិ តេសំ ភវតំ សមណព្រាហ្មណានំ អជានតំ អបស្សតំ វេទយិតំ តណ្ហាគតានំ បរិត្តស្សិតំ វិប្ផន្ទិតមេវ ។

(៤៣) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា អន្តានន្តិកា អន្តានន្តំ លោកស្ស បញ្ញាបេន្តិ ចតូហិ វត្ថូហិ តទបិ តេសំ ភវតំ សមណព្រាហ្មណានំ អជានតំ អបស្សតំ វេទយិតំ តណ្ហាគតានំ បរិត្តស្សិតំ វិប្ផន្ទិតមេវ ។

---

១ ខ. ម. បរិត្តស្សិតវិប្ផន្ទិតមេវ ។

ថា ទៀងដោយវត្ថុ ៤ យ៉ាង ឯអារម្មណ៍ (ក្នុងទិដ្ឋិ) នោះ ដែលពួកសមណ-ព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ (តាមសភាវធម៌ដែលពិត) ទទួលដឹងហើយ ពួកសមណព្រាហ្មណ៍ដែលលុះក្នុងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្លុត អន្ទះអន្ទែងវិញ ។

(៩២) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកប ដោយឯកច្ចសស្សតឯកច្ចអស-ស្សតទិដ្ឋិ បញ្ញត្តខន្ធនិងលោកថា ទៀងខ្លះ មិនទៀងខ្លះ ដោយវត្ថុ ៤ យ៉ាង ឯអារម្មណ៍ (ក្នុងទិដ្ឋិ) នោះ ដែលពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ (តាមសភាវធម៌ដែលពិត) ទទួលដឹងហើយ ពួកសមណព្រាហ្មណ៍ដែលលុះក្នុងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្លុត អន្ទះអន្ទែងវិញ ។

(៩៣) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកប ដោយអន្តានន្តទិដ្ឋិ បញ្ញត្តលោកថា មានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ដោយវត្ថុ ៤ យ៉ាង ឯអារម្មណ៍ (ក្នុងទិដ្ឋិ) នោះ ដែលពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ (តាមសភាវធម៌ដែលពិត) ទទួលដឹងហើយ ពួកសមណព្រាហ្មណ៍ដែលលុះក្នុងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្លុត អន្ទះអន្ទែងវិញ ។

(៨៤) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា អមរាវិក្ខេបិកា តត្ថ តត្ថ បញ្ហំ បុដ្ឋា សមានា វាចា-វិក្ខេបំ អាបជ្ជន្តិ អមរាវិក្ខេបំ ចតូហិ វត្ថូហិ តទបិ តេសំ ភវតំ សមណព្រាហ្មណានំ អជានតំ អបស្សតំ វេទយិតំ តណ្ហាគតានំ បរិតស្សិតំ វិប្ផន្ទិតមេវ ។

(៨៥) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា អធិច្ចសមុប្បន្និកា អធិច្ចសមុប្បន្នំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ទ្វីហិ វត្ថូហិ តទបិ តេសំ ភវតំ សមណ-ព្រាហ្មណានំ អជានតំ អបស្សតំ វេទយិតំ តណ្ហាគតានំ បរិតស្សិតំ វិប្ផន្ទិតមេវ ។

ព្រហ្មជាលសូត្រ ប្រកបដោយអមរាវិក្ខេបទិដ្ឋិជាដើម

(៩៤) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកប ដោយអមរាវិក្ខេបទិដ្ឋិ កាលបើមានអ្នកផង សាកសួរប្រស្នា ក្នុងកុសលនិងអកុសលនោះៗ ហើយ ក៏ដល់នូវការបោះវាចា បោះសំដី មិនឲ្យស្លាប់ពាក្យ ដោយវត្ថុ ៤ យ៉ាង ឯអារម្មណ៍ (ក្នុងទិដ្ឋិ) នោះ ដែលពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ (តាមសភាវធម៌ដែលពិត) ទទួលដឹងហើយ ពួកសមណព្រាហ្មណ៍ដែលលុះក្នុងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្លុត អន្ទះអន្ទែងវិញ ។

(៩៥) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយអធិច្ចសមុប្បន្នទិដ្ឋិ បញ្ញត្តខ្លួននិងលោកថា កើតឡើងដោយឥតហេតុ ដោយវត្ថុ៤យ៉ាង ឯអារម្មណ៍ (ក្នុងទិដ្ឋិ) នោះដែលពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ (តាមសភាវធម៌ដែលពិត) ទទួលដឹងហើយ ពួកសមណព្រាហ្មណ៍ ដែលលុះក្នុងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្លុត អន្ទះអន្ទែងវិញ ។

(៨៦) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា បុព្វន្តកប្បិកា បុព្វន្តានុទិដ្ឋិនោ បុព្វន្តំ អារព្ភ អនេកវិហិតានិ អធិមុត្តិបទានិ(១) អភិវទន្តិ អដ្ឋារសហិ វត្ថូហិ តទបិ តេសំ ភវតំ សមណព្រាហ្មណានំ អជានតំ អបស្សតំ វេទយិតំ តណ្ហាគតានំ បរិតស្សិតំ វិប្ផន្ទិតមេវ ។

(៨៧) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា ឧទ្ធមាឃតនិកា សញ្ញីវាទា ឧទ្ធមាឃតនំ សញ្ញិមត្តានំ បញ្ញបេន្តិ សោឡសហិ វត្ថូហិ តទបិ តេសំ ភវតំ សមណព្រាហ្មណានំ អជានតំ អបស្សតំ វេទយិតំ តណ្ហាគតានំ បរិតស្សិតំ វិប្ផន្ទិតមេវ ។

---

១ ម. អធិវុត្តិបទានិ ។

(៩៦) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយបុព្វន្តកប្បទិដ្ឋិ ជាអ្នកមានសេចក្ដីយល់ឃើញរឿយ ៗ នូវខន្ធជាចំណែកខាងដើម ប្រារព្ធនូវខន្ធជាចំណែកខាងដើម សំដែងនូវចំណែកនៃសេចក្ដីយល់ឃើញ ច្រើនប្រការ ដោយវត្ថុ ១៧ យ៉ាង ឯអារម្មណ៍ (ក្នុងទិដ្ឋិ) នោះ ដែលពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ (តាមសភាវធម៌ដែលពិត) ទទួលដឹងហើយ ពួកសមណព្រាហ្មណ៍ដែលលុះក្នុងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្លុត អន្ទះអន្ទែងវិញ ៗ

(៩៧) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកប ដោយឧទ្ធមាឃតនទិដ្ឋិ ជាសញ្ញីវាទ បញ្ញត្តខ្លួនថា មានសញ្ញា ខាងមុខអំពីសេចក្ដីស្លាប់ ដោយវត្ថុ ១៦ យ៉ាង ឯអារម្មណ៍ (ក្នុងទិដ្ឋិ) នោះ ដែលពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ (តាមសភាវធម៌ដែលពិត) ទទួលដឹងហើយ ពួកសមណព្រាហ្មណ៍ដែលលុះក្នុងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្លុត អន្ទះអន្ទែងវិញ ៗ

(៥៨) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា ឧទ្ធមាឃតនិកា អសញ្ញីវាទា ឧទ្ធមាឃតនំ អសញ្ញិមត្តានំ បញ្ញបេន្តិ អដ្ឋហិ វត្ថូហិ តទបិ តេសំ ភវតំ សមណព្រាហ្មណានំ អជានតំ អបស្សតំ វេទយិតំ តណ្ហាគតានំ បរិតស្សិតំ វិប្ផន្ទិតមេវ ។

(៥៩) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា ឧទ្ធមាឃតនិកា នេវសញ្ញីនាសញ្ញីវាទា ឧទ្ធមាឃតនំ នេវសញ្ញីនាសញ្ញិមត្តានំ បញ្ញបេន្តិ អដ្ឋហិ វត្ថូហិ តទបិ តេសំ ភវតំ សមណព្រាហ្មណានំ អជានតំ អបស្សតំ វេទយិតំ តណ្ហាគតានំ បរិតស្សិតំ វិប្ផន្ទិតមេវ ។

(៦០) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា ឧច្ឆេទវាទា សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ

ព្រហ្មជាលសូត្រ ប្រកបដោយឧទ្ធមាឃាតនទិដ្ឋិជាដើម

(៥៨) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកប ដោយឧទ្ធមាឃាតនទិដ្ឋិ ជាអសញ្ញីវាទ បញ្ញត្តខ្លួនថា មិនមានសញ្ញា ខាងមុខអំពីសេចក្តីស្លាប់ ដោយវត្ថុ ៨ យ៉ាង ឯអារម្មណ៍ (គន្លងទិដ្ឋិ) នោះ ដែលពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ ( តាមសភាវធម៌ដែលពិត ) ទទួលដឹងហើយ ពួកសមណព្រាហ្មណ៍ដែលលុះ គន្លងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្លុត អន្ទះអន្ទែងវិញ ។

(៥៩) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកប ដោយឧទ្ធមាឃាតនទិដ្ឋិ ជានេវសញ្ញីនាសញ្ញីវាទ បញ្ញត្តខ្លួនថាមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ខាងមុខអំពីសេចក្តីស្លាប់ ដោយវត្ថុ ៨ យ៉ាង ឯអារម្មណ៍ (គន្លងទិដ្ឋិ) នោះ ដែលពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ (តាមសភាវធម៌ដែលពិត) ទទួលដឹងហើយ ពួកសមណព្រាហ្មណ៍ដែលលុះគន្លងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្លុត អន្ទះអន្ទែងវិញ ។

( ៦០ ) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាឧច្ឆេទវាទ បញ្ញត្តនូវការដាច់សូន្យ នូវសេចក្តីវិនាស នូវសេចក្តីមិនកើតទៀត នៃសត្វដែលមាននៅ

បញ្ញបេន្តិ សត្តហិ វត្ថូហិ តទបិ តេសំ ភវតំ សមណ-
ព្រាហ្មណានំ អជានតំ អបស្សតំ វេទយិតំ តណ្ហា-
គតានំ បរិតស្សិតំ វិប្ផន្ទិតមេវ ។

(៦១) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា ទិដ្ឋធម្មនិព្វានវាទា សតោ សត្តស្ស បរមទិដ្ឋធម្មនិព្វានំ បញ្ញបេន្តិ បញ្ចហិ វត្ថូហិ តទបិ តេសំ ភវតំ សមណ-ព្រាហ្មណានំ អជានតំ អបស្សតំ វេទយិតំ តណ្ហាគតានំ បរិតស្សិតំ វិប្ផន្ទិតមេវ ។

(៦២) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា អបរន្តកប្បិកា អបរន្តានុទិដ្ឋិនោ អបរន្តំ អារព្ភ អនេ-កវិហិតានិ អធិមុត្តិបទានិ អភិវទន្តិ ចតុចត្តាឡីសា-យ វត្ថូហិ តទបិ តេសំ ភវតំ សមណព្រាហ្មណានំ

ដោយវត្ថុ ៧ យ៉ាង ឯអារម្មណ៍(គន្លងទិដ្ឋិ)នោះ ដែលពួកសមណព្រាហ្មណ៍ ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ ( តាមសភាវធម៌ដែលពិត ) ទទួលដឹងហើយ ពួកសមណព្រាហ្មណ៍ដែលជាអ្នកលុះក្នុងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្លុត អន្ទះអន្ទែងវិញ ។

(៦១) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាទិដ្ឋធម្មនិព្វានវាទ បញ្ញត្តនូវព្រះនិព្វាន ក្នុងបច្ចុប្បន្ន ថាជាគុណជាតយ៉ាងក្រៃលែង របស់សត្វដែលមានទៅ ដោយវត្ថុ ៥ យ៉ាង ឯអារម្មណ៍ (គន្លងទិដ្ឋិ)នោះ ដែលពួកសមណព្រាហ្មណ៍ ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ (តាមសភាវធម៌ដែលពិត) ទទួលដឹងហើយ ពួកសមណព្រាហ្មណ៍ដែលជាអ្នកលុះក្នុងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្លុត អន្ទះអន្ទែងវិញ ។

(៦២) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកប ដោយអបរន្តកប្បទិដ្ឋិ មាន សេចក្តីយល់ឃើញរឿយ ៗ នូវខន្ធជាចំណែកខាងមុខ ប្រារព្ធនូវខន្ធជា ចំណែកខាងមុខ សំដែងនូវចំណែកនៃសេចក្តីយល់ឃើញ ច្រើនប្រការ ដោយវត្ថុ៤៤យ៉ាង ឯអារម្មណ៍ (គន្លងទិដ្ឋិ )នោះដែលពួកសមណព្រាហ្មណ៍

អជានតំ អបស្សតំ វេទយិតំ តណ្ហាគតានំ បរិតស្សិតំ វិប្ផន្ទិតមេវ ។

(៦៣) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា បុព្វន្តកប្បិកា ច អបរន្តកប្បិកា ច បុព្វន្តាបរន្តកប្បិកា ច បុព្វន្តាបរន្តានុទិដ្ឋិនោ បុព្វន្តាបរន្តំ អារព្ភ អនេកវិហិតានិ អធិមុត្តិបទានិ អភិវទន្តិ ទ្វាសដ្ឋិយា វត្ថូហិ តទបិ តេសំ ភវតំ សមណព្រាហ្មណានំ អជានតំ អបស្សតំ វេទយិតំ តណ្ហាគតានំ បរិតស្សិតំ វិប្ផន្ទិតមេវ ។

(៦៤) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា សស្សតវាទា សស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ចតូហិ វត្ថូហិ តទបិ ផស្សបច្ចយា ។

ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ (តាមសភាវធម៌ដែលពិត) ទទួលដឹងហើយ ពួកសមណព្រាហ្មណ៍ដែលជាអ្នកលុះក្នុងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្លុត អន្ទះអន្ទែងវិញ ។

(៦៣) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកប ដោយបុព្វន្តកប្បទិដ្ឋិ ផង ប្រកបដោយអបរន្តកប្បទិដ្ឋិផង ប្រកបដោយបុព្វន្តាបរន្តកប្បទិដ្ឋិផង មានសេចក្តីយល់ឃើញរឿយៗ នូវខន្ធជាចំណែកខាងដើម នឹងខន្ធជាចំណែកខាងមុខ ប្រារព្ធខន្ធជាចំណែកខាងដើម នឹងខន្ធជាចំណែកខាងមុខ សំ-ដែងនូវចំណែកនៃសេចក្តីយល់ឃើញច្រើនប្រការ ដោយវត្ថុ ៦២ យ៉ាង ឯអារម្មណ៍ (ក្នុងទិដ្ឋិ)នោះ ដែលពួកសមណព្រាហ្មណ៍ដ៏ចំរើនទាំងនោះ ជាអ្នកមិនដឹង មិនឃើញ (តាមសភាវធម៌ដែលពិត) ទទួលដឹងហើយ ពួកសមណព្រាហ្មណ៍ដែលជាអ្នកលុះក្នុងអំណាចតណ្ហា ក៏ត្រឡប់ទៅជាតក់ស្លុត អន្ទះអន្ទែងវិញ ។

(៦៤) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ដែលជាសស្សតវាទ បញ្ញត្តខ្លួននឹងលោកថា ទៀង ដោយវត្ថុ ៤ យ៉ាង ឯអារម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(៦៥) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា ឯកច្ចសស្សតិកា ឯកច្ចអសស្សតិកា ឯកច្ចំ សស្សតំ ឯកច្ចំ អសស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ចតូហិ វត្ថូហិ តទបិ ផស្សបច្ចយា ។

(៦៦) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា អន្តានន្តិកា អន្តានន្តំ លោកស្ស បញ្ញបេន្តិ ចតូហិ វត្ថូហិ តទបិ ផស្សបច្ចយា ។

(៦៧) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា អមរាវិក្ខេបិកា តត្ថ តត្ថ បញ្ហំ បុដ្ឋា សមានា វាចាវិក្ខេបំ អាបជ្ជន្តិ អមរាវិក្ខេបំ ចតូហិ វត្ថូហិ តទបិ ផស្សបច្ចយា ។

(៦៨) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា អធិច្ចសមុប្បន្និកា អធិច្ចសមុប្បន្នំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ទ្វីហិ វត្ថូហិ តទបិ ផស្សបច្ចយា ។

(៦៥) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដែលជាអ្នកប្រកប ដោយឯកច្ចសស្សតឯកច្ចអសស្សតទិដ្ឋិ បញ្ញត្តខ្លួននិងលោកថា ទៀងខ្លះ មិនទៀងខ្លះ ដោយវត្ថុ ៤ យ៉ាង ឯការម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(៦៦) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដែលជាអ្នកប្រកបដោយអន្តានន្តទិដ្ឋិ បញ្ញត្តលោកថា មានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ដោយវត្ថុ ៤ យ៉ាង ឯការម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(៦៧) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដែលជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិ កាលបើមានអ្នកផង សាកសួរប្រស្នាក្នុងកុសលនិងអកុសលនោះៗ ហើយ ក៏ដល់នូវការបោះវាចា បោះសំដីមិនឲ្យស្ងាប់ពាក្យ ដោយវត្ថុ ៤ យ៉ាង ឯការម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(៦៨) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដែលជាអ្នកប្រកបដោយអធិច្ចសមុប្បន្នទិដ្ឋិ បញ្ញត្តខ្លួននិងលោកថា កើតឡើងដោយឥតហេតុ ដោយវត្ថុ ២ យ៉ាង ឯការម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(៦៩) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា
បុព្វន្តកប្បិកា បុព្វន្តានុទិដ្ឋិនោ បុព្វន្តំ អារព្ភ អនេក-
វិហិតានិ អធិមុត្តិបទានិ អភិវទន្តិ អដ្ឋារសហិ វត្ថូហិ
តទបិ ផស្សបច្ចយា ។

(៧០) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា
ឧទ្ធមាឃតនិកា សញ្ញីវាទា ឧទ្ធមាឃតនំ សញ្ញឹមត្តានំ
បញ្ញបេន្តិ សោឡសហិ វត្ថូហិ តទបិ ផស្សបច្ចយា ។

(៧១) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា
ឧទ្ធមាឃតនិកា អសញ្ញីវាទា ឧទ្ធមាឃតនំ អសញ្ញឹ-
មត្តានំ បញ្ញបេន្តិ អដ្ឋហិ វត្ថូហិ តទបិ ផស្សបច្ចយា ។

(៧២) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា
ឧទ្ធមាឃតនិកា នេវសញ្ញីនាសញ្ញីវាទា ឧទ្ធមាឃតនំ

## ព្រហ្មជាលសូត្រ ប្រកបដោយបុព្វន្តកប្បទិដ្ឋិជាដើម

(៦៩) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដែលជាអ្នកប្រកបដោយបុព្វន្តកប្បទិដ្ឋិ មានសេចក្តីយល់ឃើញរឿយ ៗ នូវខន្ធជាចំណែកខាងដើម ប្រារព្ធនូវខន្ធ ជាចំណែកខាងដើម ហើយសំដែងនូវចំណែកនៃសេចក្តីយល់ឃើញ ជាច្រើនប្រការដោយវត្ថុ ១៨ យ៉ាង ឯអារម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(៧០) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដែលជាអ្នកប្រកបដោយឧទ្ធមាឃតនទិដ្ឋិ ជាសញ្ញីវាទ បញ្ញត្តខ្លួនថា មានសញ្ញា ខាងមុខអំពីសេចក្តីស្លាប់ ដោយវត្ថុ ១៦ យ៉ាង ឯអារម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(៧១) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដែលជាអ្នកប្រកបដោយឧទ្ធមាឃតនទិដ្ឋិ ជាអសញ្ញីវាទ បញ្ញត្តខ្លួនថា មិនមានសញ្ញា ខាងមុខអំពីសេចក្តីស្លាប់ ដោយវត្ថុ ៨ យ៉ាង ឯអារម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(៧២) ម្នាលភិក្ខុទាំងឡាយ បណ្តាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដែលជាអ្នកប្រកបដោយឧទ្ធមាឃតនទិដ្ឋិ ជា នេវសញ្ញីនាសញ្ញីវាទ បញ្ញត្តខ្លួនថា មានសញ្ញា ក៏មិនមែន មិនមាន

នេវសញ្ញីនាសញ្ញិមត្តានំ បញ្ញបេន្តិ អដ្ឋហិ វត្ថូហិ តទបិ ផស្សបច្ចយា ។

(៧៣) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា ឧច្ឆេទវាទា សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញបេន្តិ សត្តហិ វត្ថូហិ តទបិ ផស្សបច្ចយា ។

(៧៤) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា ទិដ្ឋធម្មនិព្វានវាទា សតោ សត្តស្ស បរមទិដ្ឋធម្មនិព្វានំ បញ្ញបេន្តិ បញ្ចហិ វត្ថូហិ តទបិ ផស្សបច្ចយា ។

(៧៥) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា អបរន្តកប្បិកា អបរន្តានុទិដ្ឋិនោ អបរន្តំ អារព្ភ អនេកវិហិតានិ អធិមុត្តិបទានិ អភិវទន្តិ ចតុចត្តារីសាយ វត្ថូហិ តទបិ ផស្សបច្ចយា ។

សញ្ញាក៏មិនមែន ខាងមុខអំពីសេចក្ដីស្លាប់ ដោយវត្ថុ ៨ យ៉ាង ឯអារម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(៧៣) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដែលជាឧច្ឆេទវាទ បញ្ញត្តនូវការដាច់សូន្យ នូវសេចក្ដីវិនាស នូវសេចក្ដីមិនកើតទៀត នៃសត្វដែលមាននៅ ដោយវត្ថុ ៧ យ៉ាង ឯអារម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(៧៤) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដែលជាទិដ្ឋធម្មនិព្វានវាទ បញ្ញត្តព្រះនិព្វានក្នុងបច្ចុប្បន្នថាជាគុណជាតយ៉ាងក្រៃលែង របស់សត្វដែលមាននៅ ដោយវត្ថុ ៥ យ៉ាង ឯអារម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(៧៥) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដែលជាអ្នកប្រកបដោយអបរន្តកប្បទិដ្ឋិ មានសេចក្ដីយល់ឃើញរឿយ ៗ នូវខន្ធជាចំណែកខាងមុខ ប្រារព្ធនូវខន្ធជាចំណែកខាងមុខ សំដែងនូវចំណែកនៃសេចក្ដីយល់ឃើញ ជាច្រើនប្រការ ដោយវត្ថុ ៤៤ យ៉ាង ឯអារម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(៧៦) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា បុព្វន្តកប្បិកា ច អបរន្តកប្បិកា ច បុព្វន្តាបរន្តកប្បិកា ច បុព្វន្តាបរន្តានុទិដ្ឋិនោ បុព្វន្តាបរន្តំ អារព្ភ អនេកវិហិតានិ អធិមុត្តិបទានិ អភិវទន្តិ ទ្វាសដ្ឋិយា វត្ថូហិ តទបិ ផស្សបច្ចយា ។

(៧៧) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា សស្សតវាទា សស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ចតូហិ វត្ថូហិ តេ វត អញ្ញត្រ ផស្សា បដិសំវេទិស្សន្តីតិ នេតំ ឋានំ វិជ្ជតិ ។

(៧៨) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា ឯកច្ចសស្សតិកា ឯកច្ចអសស្សតិកា ឯកច្ចំ សស្សតំ ឯកច្ចំ អសស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ចតូហិ វត្ថូហិ តេ វត អញ្ញត្រ ផស្សា បដិសំវេទិស្សន្តីតិ នេតំ ឋានំ វិជ្ជតិ ។

(៧៦) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ ដែលជាអ្នកប្រកបដោយបុព្វន្តកប្បទិដ្ឋិផង ប្រកបដោយអបរន្តកប្បទិដ្ឋិផង ប្រកបដោយបុព្វន្តាបរន្តកប្បទិដ្ឋិផង មានសេចក្ដីយល់ឃើញរឿយ ៗ នូវខន្ធជាចំណែកខាងដើម ប្រារព្ធនូវខន្ធ ជាចំណែកខាងដើម និងខន្ធជាចំណែកខាងមុខ សំដែងនូវចំណែកនៃសេចក្ដីយល់ឃើញច្រើនប្រការ ដោយវត្ថុ ៦២ យ៉ាង ឯអារម្មណ៍នៃទិដ្ឋិនោះ ព្រោះមានផស្សៈជាបច្ច័យ ។

(៧៧) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាសស្សតវាទ បញ្ញត្តខ្លួននិងលោកថា ទៀងដោយវត្ថុ ៤ យ៉ាង ឯពួកសមណព្រាហ្មណ៍នោះឯង វៀរចាកផស្សៈចេញហើយ នឹងទទួលដឹង (នូវអារម្មណ៍បាន) ពាក្យនុ៎ះ មិនសមហេតុទេ គឺថាបើវៀរចាកផស្សៈ មិនអាចទទួលអារម្មណ៍បានឡើយ ។

(៧៨) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយឯកច្ចសស្សត-ឯកច្ចអសស្សតទិដ្ឋិ បញ្ញត្តខ្លួននិងលោកថា ទៀងខ្លះ មិនទៀងខ្លះ ដោយវត្ថុ ៤ យ៉ាង ពួកសមណព្រាហ្មណ៍នោះឯង វៀរចាកផស្សៈចេញហើយ នឹងទទួលដឹង (នូវអារម្មណ៍បាន) ពាក្យនុ៎ះ មិនសមហេតុទេ ។

(៧៩) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា អន្តានន្តិកា អន្តានន្តំ លោកស្ស បញ្ញបេន្តិ ចតូហិ វត្ថូហិ តេ វត អញ្ញត្រ ផស្សា បដិសំវេទិស្សន្តីតិ នេតំ ឋានំ វិជ្ជតិ ។

(៨០) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា អមរាវិក្ខេបិកា តត្ថ តត្ថ បញ្ហំ បុដ្ឋា សមានា វាចាវិក្ខេបំ អាបជ្ជន្តិ អមរាវិក្ខេបំ ចតូហិ វត្ថូហិ តេ វត អញ្ញត្រ ផស្សា បដិសំវេទិស្សន្តីតិ នេតំ ឋានំ វិជ្ជតិ ។

(៨១) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា អធិច្ចសមុប្បន្និកា អធិច្ចសមុប្បន្នំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ទ្វីហិ វត្ថូហិ តេ វត អញ្ញត្រ ផស្សា បដិសំវេទិស្សន្តីតិ នេតំ ឋានំ វិជ្ជតិ ។

(៧៩) ម្នាលភិក្ខុទាំងឡាយ បណ្ដាសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ដែលជាអ្នកប្រកបដោយអន្តានន្តទិដ្ឋិ បញ្ញត្តលោកថា មានទីបំផុតខ្លះ មិនមានទីបំផុតខ្លះ ដោយវត្ថុ ៤ យ៉ាង ពួកសមណព្រាហ្មណ៍នោះឯង វៀរចាកផស្សៈចេញហើយ នឹងទទួលដឹង (នូវអារម្មណ៍បាន) ពាក្យដូច្នេះ មិនសមហេតុទេ ។

(៨០) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិ កាលបើមានអ្នកផង សាកសួរប្រស្នាក្នុងកុសលនិងអកុសលនោះៗ ហើយ ក៏ដល់នូវការបោះពាក្យបោះសំដីមិនឲ្យស្ទាប់ពាក្យ ដោយវត្ថុ ៤ យ៉ាង ពួកសមណព្រាហ្មណ៍នោះឯង វៀរចាកផស្សៈចេញហើយ នឹងទទួលដឹង (នូវអារម្មណ៍បាន) ពាក្យដូច្នេះ មិនសមហេតុទេ ។

(៨១) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយអធិច្ចសមុប្បន្នទិដ្ឋិ បញ្ញត្តខ្លួននិងលោកថា កើតឡើងដោយឥតហេតុ ដោយវត្ថុ ២ យ៉ាង ពួកសមណព្រាហ្មណ៍នោះឯង វៀរចាកផស្សៈចេញហើយ នឹងទទួលដឹង (នូវអារម្មណ៍បាន) ពាក្យដូច្នេះ មិនសមហេតុទេ ។

(៨២) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា បុព្វន្តកប្បិកា បុព្វន្តានុទិដ្ឋិនោ បុព្វន្តំ អារព្ភ អនេក-វិហិតានិ អធិមុត្តិបទានិ អភិវទន្តិ អដ្ឋារសហិ វត្ថូហិ តេ វត អញ្ញត្រ ផស្សា បដិសំវេទិស្សន្តីតិ នេតំ ឋានំ វិជ្ជតិ ។

(៨៣) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា ឧទ្ធមាឃតនិកា សញ្ញីវាទា ឧទ្ធមាឃតនំ សញ្ញឹម-ត្តានំ បញ្ញបេន្តិ សោឡសហិ វត្ថូហិ តេ វត អញ្ញត្រ ផស្សា បដិសំវេទិស្សន្តីតិ នេតំ ឋានំ វិជ្ជតិ ។

(៨៤) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា ឧទ្ធមាឃតនិកា អសញ្ញីវាទា ឧទ្ធមាឃតនំ អសញ្ញឹ-មត្តានំ បញ្ញបេន្តិ អដ្ឋហិ វត្ថូហិ តេ វត អញ្ញត្រ ផស្សា បដិសំវេទិស្សន្តីតិ នេតំ ឋានំ វិជ្ជតិ ។

(៨២) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយបុព្វន្តកប្បិកទិដ្ឋិ មានសេចក្ដីយល់ឃើញរឿយ ៗ នូវខន្ធជាចំណែកខាងដើម ប្រារព្ធនូវខន្ធជាចំណែកខាងដើម សំដែងនូវចំណែកនៃសេចក្ដីយល់ឃើញ ច្រើនប្រការ ដោយវត្ថុ ១៨ យ៉ាង ពួកសមណព្រាហ្មណ៍នោះ វៀរចាកផស្សៈចេញហើយ នឹងទទួលដឹង (នូវអារម្មណ៍បាន) ពាក្យដូច្នេះ មិនសមហេតុទេ ។

(៨៣) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយឧទ្ធមាឃតនិកទិដ្ឋិ ជាសញ្ញីវាទ បញ្ញត្តខ្លួនថា មានសញ្ញាខាងមុខអំពីសេចក្ដីស្លាប់ ដោយវត្ថុ ៦ យ៉ាងពួកសមណព្រាហ្មណ៍នោះឯង វៀរចាកផស្សៈចេញហើយ នឹងទទួលដឹង (នូវអារម្មណ៍បាន) ពាក្យដូច្នេះ មិនសមហេតុទេ ។

(៨៤) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយឧទ្ធមាឃតនិកទិដ្ឋិ ជាអសញ្ញីវាទ បញ្ញត្តខ្លួនថាមិនមានសញ្ញា ខាងមុខអំពីសេចក្ដីស្លាប់ ដោយវត្ថុ ៨ យ៉ាង ពួកសមណព្រាហ្មណ៍នោះ វៀរចាកផស្សៈចេញហើយ នឹងទទួលដឹង (នូវអារម្មណ៍បាន) ពាក្យដូច្នេះ មិនសមហេតុទេ ។

(៨៥) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា ឧទ្ធមាឃាតនិកា នេវសញ្ញីនាសញ្ញីវាទា ឧទ្ធមាឃាតនា នេវសញ្ញីនាសញ្ញឹមត្តានំ បញ្ញបេន្តិ អដ្ឋហិ វត្ថូហិ តេ វត អញ្ញត្រ ផស្សា បដិសំវេទិស្សន្តីតិ នេតំ ឋានំ វិជ្ជតិ ។

(៨៦) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា ឧច្ឆេទវាទា សតោ សត្តស្ស ឧច្ឆេទំ វិនាសំ វិភវំ បញ្ញបេន្តិ សត្តហិ វត្ថូហិ តេ វត អញ្ញត្រ ផស្សា បដិសំវេទិស្សន្តីតិ នេតំ ឋានំ វិជ្ជតិ ។

(៨៧) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា ទិដ្ឋធម្មនិព្វានវាទា សតោ សត្តស្ស បរមទិដ្ឋធម្មនិព្វានំ បញ្ញបេន្តិ បញ្ចហិ វត្ថូហិ តេ វត អញ្ញត្រ ផស្សា បដិសំវេទិស្សន្តីតិ នេតំ ឋានំ វិជ្ជតិ ។

(៨៥) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយឧទ្ធមាឃតនទិដ្ឋិ ជានេវសញ្ញីនាសញ្ញីវាទ បញ្ញត្តខ្លួនថា មានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន ខាងមុខអំពីសេចក្ដីស្លាប់ ដោយវត្ថុ ៨ យ៉ាង ពួកសមណព្រាហ្មណ៍នោះ វៀរចាកផស្សៈចេញហើយ នឹងទទួលដឹង ( នូវអារម្មណ៍បាន ) ពាក្យដូច្នេះ មិនសមហេតុទេ ។

(៨៦) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាឧច្ឆេទវាទ បញ្ញត្តនូវការដាច់សូន្យ នូវសេចក្ដីវិនាស នូវសេចក្ដីមិនកើតទៀត នៃសត្វដែលមាននៅ ដោយវត្ថុ ៧ យ៉ាង ពួកសមណព្រាហ្មណ៍នោះឯង វៀរចាកផស្សៈចេញហើយ នឹងទទួលដឹង ( នូវអារម្មណ៍បាន ) ពាក្យដូច្នេះ មិនសមហេតុទេ ។

(៨៧) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាទិដ្ឋធម្មនិព្វានវាទ បញ្ញត្តនិព្វានក្នុងបច្ចុប្បន្ន ថាជាគុណជាតយ៉ាងក្រៃលែង នៃសត្វដែលមាននៅ ដោយវត្ថុ ៥ យ៉ាង ពួកសមណព្រាហ្មណ៍នោះឯង វៀរចាកផស្សៈចេញហើយ នឹងទទួលដឹង (នូវអារម្មណ៍បាន) ពាក្យដូច្នេះ មិនសមហេតុទេ ។

(៨៨) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា អបរន្តកប្បិកា អបរន្តានុទិដ្ឋិនោ អបរន្តំ អារព្ភ អនេកវិហិតានិ អធិមុត្តិបទានិ អភិវទន្តិ ចតុចត្តាឡីសាយ វត្ថូហិ តេ វត អញ្ញត្រ ផស្សា បដិសំវេទិស្សន្តីតិ នេតំ ឋានំ វិជ្ជតិ ។

(៨៩) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា បុព្វន្តកប្បិកា ច អបរន្តកប្បិកា ច បុព្វន្តាបរន្តកប្បិកា ច បុព្វន្តាបរន្តានុទិដ្ឋិនោ បុព្វន្តាបរន្តំ អារព្ភ អនេកវិហិតានិ អធិមុត្តិបទានិ អភិវទន្តិ ទ្វាសដ្ឋិយា វត្ថូហិ តេ វត អញ្ញត្រ ផស្សា បដិសំវេទិស្សន្តីតិ នេតំ ឋានំ វិជ្ជតិ ។

(៨៨) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយអបរន្តកប្បទិដ្ឋិ ជាអ្នកមានសេចក្ដីយល់ឃើញរឿយ ៗ នូវខន្ធជាចំណែកខាងមុខ ប្រារព្ធនូវខន្ធជាចំណែកខាងមុខ សំដែងនូវចំណែក នៃសេចក្ដីយល់ឃើញ ច្រើនប្រការ ដោយវត្ថុ ៤៤ យ៉ាង ពួកសមណព្រាហ្មណ៍នោះឯង វៀរចាកផស្សៈចេញហើយ នឹងទទួលដឹង ( នូវអារម្មណ៍បាន ) ពាក្យដូច្នេះ មិនសមហេតុទេ ។

(៨៩) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយបុព្វន្តកប្បទិដ្ឋិ ប្រកបដោយអបរន្តកប្បទិដ្ឋិ ទាំងប្រកបដោយបុព្វន្តាបរន្តកប្បទិដ្ឋិ ជាអ្នកមានសេចក្ដីយល់ឃើញរឿយ ៗ នូវខន្ធជាចំណែកខាងដើម នឹងខន្ធជាចំណែកខាងមុខ ប្រារព្ធនូវខន្ធជាចំណែកខាងដើម នឹងខន្ធជាចំណែកខាងមុខ សំដែងនូវចំណែកនៃសេចក្ដីយល់ឃើញ ច្រើនប្រការ ដោយវត្ថុ ៦២ យ៉ាង ពួកសមណព្រាហ្មណ៍នោះឯង វៀរចាកផស្សៈចេញហើយ នឹងទទួលដឹង ( នូវអារម្មណ៍បាន ) ពាក្យដូច្នេះ មិនសមហេតុទេ ។

(៩០) តត្រ ភិក្ខវេ យេ តេ សមណព្រាហ្មណា សស្សតវាទា សស្សតំ អត្តានញ្ច លោកញ្ច បញ្ញបេន្តិ ចតូហិ វត្ថូហិ យេបិ តេ សមណព្រាហ្មណា ឯកច្ចសស្សតិកា ឯកច្ចអសស្សតិកា យេបិ តេ សមណព្រាហ្មណា អន្តានន្តិកា យេបិ តេ សមណព្រាហ្មណា អមរាវិក្ខេបិកា យេបិ តេ សមណព្រាហ្មណា អធិច្ចសមុប្បន្និកា យេបិ តេ សមណព្រាហ្មណា បុព្វន្តកប្បិកា យេបិ តេ សមណព្រាហ្មណា ឧទ្ធមាឃតនិកា សញ្ញីវាទា យេបិ តេ សមណព្រាហ្មណា ឧទ្ធមាឃតនិកា អសញ្ញីវាទា យេបិ តេ សមណព្រាហ្មណា ឧទ្ធមាឃតនិកា នេវសញ្ញីនាសញ្ញីវាទា យេបិ តេ សមណព្រាហ្មណា ឧច្ឆេទវាទា យេបិ តេ សមណព្រាហ្មណា ទិដ្ឋធម្មនិព្វានវាទា យេបិ តេ សមណព្រាហ្មណា អបរន្តកប្បិកា[១] យេបិ តេ សមណព្រាហ្មណា បុព្វន្តកប្បិកា ច អបរន្តកប្បិកា

---

១ ឱ. យេបិ តេ សមណព្រាហ្មណា បុព្វន្តកប្បិកា យេបិ តេ សមណព្រាហ្មណា អបរន្តកប្បិកាតិ ទិស្សន្តិ ។

(៩០) ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកសមណព្រាហ្មណ៍ទាំងនោះ ពួកសមណព្រាហ្មណ៍ណា ជាសស្សតវាទ បញ្ញត្តខ្លួននិងលោកថា ទៀង ដោយវត្ថុ ៤ យ៉ាងក្តី ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយឯកច្ចសស្សតឯកច្ចអសស្សតទិដ្ឋិក្តី ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយអន្តានន្តទិដ្ឋិក្តី ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយអមរាវិក្ខេបទិដ្ឋិក្តី ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយអធិច្ចសមុប្បន្នទិដ្ឋិក្តី ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយបុព្វន្តកប្បទិដ្ឋិក្តី ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយឧទ្ធមាឃតនទិដ្ឋិ ជាសញ្ញីវាទក្តី ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយឧទ្ធមាឃតនទិដ្ឋិ ជាអសញ្ញីវាទក្តី ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយឧទ្ធមាឃតនទិដ្ឋិ ជានេវសញ្ញីនាសញ្ញីវាទក្តី ពួកសមណព្រាហ្មណ៍ណា ជាឧច្ឆេទវាទក្តី ពួកសមណព្រាហ្មណ៍ណា ជាទិដ្ឋធម្មនិព្វានវាទក្តី ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយអបរន្តកប្បទិដ្ឋិក្តី ពួកសមណព្រាហ្មណ៍ណា ជាអ្នកប្រកបដោយបុព្វន្តកប្បទិដ្ឋិ ប្រកប

ឌ បុព្វន្តាបរន្តកប្បិកា ច(១) បុព្វន្តាបរន្តានុទិដ្ឋិនោ បុព្វន្តាបរន្តំ អារព្ភ អនេកវិហិតានិ អធិមុត្តិបទានិ អភិវទន្តិ ទ្វាសដ្ឋិយា វត្ថូហិ សព្វេ តេ ឆហិ ផស្សាយតនេហិ ផុស្សា ផុស្សា(២) បដិសំវេទេន្តិ ។ តេសំ វេទនាបច្ចយា តណ្ហា តណ្ហាបច្ចយា ឧបាទានំ ឧបាទានបច្ចយា ភវោ ភវបច្ចយា ជាតិ ជាតិបច្ចយា ជរាមរណំ សោកបរិទេវទុក្ខទោមនស្សុបាយាសា សម្ភវន្តិ ។ យតោ ខោ ភិក្ខវេ ភិក្ខុ ឆន្នំ ផស្សាយតនានំ សមុទយញ្ច អត្ថង្គមញ្ច អស្សាទញ្ច អាទីនវញ្ច និស្សរណញ្ច យថាភូតំ បជានាតិ ។ អយំ ឥមេហិ សព្វេហេវ ឧត្តរិតរំ បជានាតិ ។ យេ ហិ កេចិ ភិក្ខវេ សមណា វា ព្រាហ្មណា វា បុព្វន្តកប្បិកា វា

---

១ ឱ. ជាតិ ន ទិស្សតិ ។ ២ ឱ. ម. ផុស្ស ផុស្ស ។ កត្ថចិ អម្ហាកំ បោត្ថកេសុបិ ត្លៀទំសោយេវ ។

ដោយអបរន្តកប្បទិដ្ឋិ ទាំងប្រកបដោយបុព្វន្តាបរន្តកប្បទិដ្ឋិ ជាអ្នកមានសេចក្តីយល់ឃើញរឿយ ៗ នូវខន្ធជាចំណែកខាងដើម នឹងខន្ធជាចំណែកខាងមុខ ប្រារព្ធនូវខន្ធជាចំណែកខាងដើម នឹងខន្ធជាចំណែកខាងមុខ សំដែងនូវចំណែក នៃសេចក្តីយល់ឃើញច្រើនប្រការ ដោយវត្ថុ ៦២ ក្តី ពួកសមណព្រាហ្មណ៍ទាំងអស់នោះ ទទួលដឹង ( នូវអារម្មណ៍ ) ព្រោះប៉ះពាល់ត្រូវដោយអាយតនៈ ជាទីកើតនៃផស្សៈ៦ យ៉ាង ៗ តណ្ហារបស់សមណព្រាហ្មណ៍ទាំងនោះ កើតមាន ព្រោះវេទនាជាបច្ច័យ ឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ ភពកើតមាន ព្រោះឧបាទានជាបច្ច័យ ជាតិកើតមាន ព្រោះភពជាបច្ច័យ ជរាមរណៈកើតមាន ព្រោះជាតិជាបច្ច័យ សេចក្តីសោកស្រណោះ សេចក្តីខ្សឹកខ្សួល សេចក្តីមិនស្រួលកាយ សេចក្តីតូចចិត្ត សេចក្តីចង្អៀតចិត្ត ក៏កើតមាន ព្រោះជាតិជាបច្ច័យដែរ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដឹងច្បាស់នូវហេតុដែលនាំឲ្យកើតឡើង នឹងសេចក្តីវិនាស នឹងសេចក្តីត្រេកអរ នឹងទោសនឹងឧបាយជាគ្រឿងរលាស់ចេញនូវអាយតនៈ ជាទីកើតនៃផស្សៈទាំង ៦ តាមសេចក្តីពិតប្រាកដ ក្នុងកាលណា ៗ ភិក្ខុនេះរមែងដឹងច្បាស់នូវធម៌លើសលុបជាងទិដ្ឋិទាំងឡាយទាំងពួងនេះ ( ក្នុងកាលនោះឯង ) ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ណាមួយ ជាអ្នកប្រកបដោយបុព្វន្តកប្ប-

អបរន្តកប្បិកា វា បុព្វន្តាបរន្តកប្បិកា វា បុព្វន្តាប-
រន្តានុទិដ្ឋិនោ បុព្វន្តាបរន្តំ អារព្ភ អនេកវិហិតានិ អធិ-
មុត្តិបទានិ អភិវទន្តិ សព្វេ តេ ឥមេហេវ ទ្វាសដ្ឋិយា
វត្ថូហិ អន្តោជាលីកតា ឯត្ថ សិតា វ ឧម្មុជ្ជមានា
ឧម្មុជ្ជន្តិ ឯត្ថ បរិយាបន្នា អន្តោជាលីកតា វ ឧម្មុជ្ជមានា
ឧម្មុជ្ជន្តិ សេយ្យថាបិ ភិក្ខវេ ទក្ខោ កេវដ្ដោ វា កេវដ្ដន្តេ-
វាសី វា សុខុមច្ឆិកេន ជាលេន បរិត្តំ ឧទកទហំ(១)
ឱត្ថរេយ្យ តស្ស ឯវមស្ស យេ ខោ កេចិ ឥមស្មឹ ឧទ-
កទហេ ឱឡារិកា បាណា សព្វេបេតេ(២) អន្តោជាលី-
កតា ឯត្ថ សិតា វ ឧម្មុជ្ជមានា ឧម្មុជ្ជន្តិ ឯត្ថ បរិយាបន្នា
អន្តោជាលីកតា វ ឧម្មុជ្ជមានា ឧម្មុជ្ជន្តិ ឯវមេវ ខោ
ភិក្ខវេ យេ ហិ កេចិ សមណា វា ព្រាហ្មណា វា

---

១ ឱ ម. ឧទករហំ ។ ២ ឱ. ម. សព្វេតេ ។

ទិដ្ឋិ ប្រកបដោយអបរន្តកប្បទិដ្ឋិ ប្រកបដោយបុព្វន្តាបរន្តកប្បទិដ្ឋិ ជាអ្នកមានសេចក្តីយល់ឃើញរឿយៗ នូវខន្ធជាចំណែកខាងដើម និងខន្ធជាចំណែកខាងមុខ ប្រារព្ធនូវខន្ធជាចំណែកខាងដើមនិងខន្ធជាចំណែកខាងមុខ សំដែងនូវចំណែកនៃសេចក្តីយល់ឃើញច្រើនប្រការ ពួកសមណព្រាហ្មណ៍ទាំងអស់នោះ ដែលតែ ៦២ នេះឯង (គ្របសង្កត់) ធ្វើឲ្យដូចជានៅខាងក្នុងសំណាញ់ គឺធម្មទេសនារបស់ព្រះតថាគត អាស្រ័យនៅក្នុងសំណាញ់នេះ កាលងើបឡើង ក៏ងើបឡើង (ក្នុងសំណាញ់នេះ) ជាប់នៅក្នុងសំណាញ់នេះ ធ្វើឲ្យដូចជានៅខាងក្នុងសំណាញ់ គឺធម្មទេសនារបស់ព្រះតថាគត កាលងើបឡើង ក៏ងើបឡើង (ក្នុងសំណាញ់នេះ) ម្នាលភិក្ខុទាំងឡាយ នាយនេសាទមច្ឆជាតិក្តី កម្មកររបស់នាយនេសាទមច្ឆជាតិក្តី ដែលប៉ិនប្រសប់បង់សំណាញ់ មានក្រឡាដ៏ញឹកទៅក្នុងអន្លង់ទឹកតូចនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកសត្វធំតូចណាមួយ នៅក្នុងអន្លង់ទឹកនេះ ពួកសត្វធំតូចទាំងនោះ អញធ្វើឲ្យនៅខាងក្នុងសំណាញ់ អាស្រ័យនៅក្នុងសំណាញ់នេះ កាលបើងើបឡើង ក៏ងើបឡើង (ក្នុងសំណាញ់នេះ) ជាប់ចំពាក់នៅក្នុងសំណាញ់នេះ អញធ្វើឲ្យនៅខាងក្នុងសំណាញ់ កាលបើងើបឡើង ក៏ងើបឡើង (ក្នុងសំណាញ់) សេចក្តីនេះមានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ពួកសមណៈឬព្រាហ្មណ៍ណាមួយ

បុព្វន្តកប្បិកា ច អបរន្តកប្បិកា ច បុព្វន្តាបរន្តកប្បិកា ច បុព្វន្តាបរន្តានុទិដ្ឋិនោ បុព្វន្តាបរន្តំ អារព្ភ អនេកវិហិតានិ អធិមុត្តិបទានិ អភិវទន្តិ សព្វេ តេ ឥមេហេវ ទ្វាសដ្ឋិយា វត្ថូហិ អន្តោជាលីកតា ឯត្ថ សិតាវ ឧម្មុជ្ជមានា ឧម្មុជ្ជន្តិ ឯត្ថ បរិយាបន្នា អន្តោជាលីកតាវ ឧម្មុជ្ជមានា ឧម្មុជ្ជន្តិ ។ ឧច្ឆិន្នភវនេត្តិកោ ភិក្ខវេ តថាគតស្ស កាយោ តិដ្ឋតិ យាវស្ស កាយោ ឋស្សតិ តាវ នំ ទក្ខន្តិ(1) ទេវមនុស្សា កាយស្ស ភេទា ឧទ្ធំ ជីវិតបរិយាទានា ន នំ(2) ទក្ខន្តិ ទេវមនុស្សា សេយ្យថាបិ ភិក្ខវេ អម្ពបិណ្ឌិយា វណ្ដច្ឆិន្នាយ យានិ កានិចិ អម្ពានិ វណ្ដបដិពន្ធានិ(3) សព្វានិ តានិ

---

១ ឱ. ទក្ខិន្តិ ។ ២ ឱ. នត្ថិ ន ទិស្សតិ ។ ៣ ឱ. វណ្ដូបនិពន្ធនានិ ។

ជាអ្នកប្រកបដោយបុព្វន្តកប្បវិកប្បិ ប្រកបដោយអបរន្តកប្បវិកប្បិ ប្រកបដោយបុព្វន្តាបរន្តកប្បវិកប្បិ ជាអ្នកឃើញរឿយ ៗ នូវខន្ធជាចំណែកខាងដើមនិងខន្ធជាចំណែកខាងមុខ ប្រារព្ធនូវខន្ធជាចំណែកខាងដើម និងខន្ធជាចំណែកខាងមុខ សំដែងនូវចំណែកនៃសេចក្តីយល់ឃើញ ច្រើនប្រការ ពួកសមណព្រាហ្មណ៍ទាំងអស់នោះ ដែលវត្ថុ ៦២ នេះឯង (គ្រប់សង្កត់) ធ្វើឲ្យដូចជានៅខាងក្នុងនៃសំណាញ់ គឺធម្មទេសនារបស់តថាគត អាស្រ័យនៅក្នុងសំណាញ់នេះ កាលងើបឡើងក៏ងើបឡើង (ក្នុងសំណាញ់នេះ) ជាប់នៅក្នុងសំណាញ់នេះ ធ្វើឲ្យដូចជានៅក្នុងសំណាញ់ គឺធម្មទេសនារបស់ព្រះតថាគត កាលបើងើបឡើងក៏ងើបឡើង (ក្នុងសំណាញ់នេះ) មានឧបមេយ្យដូច្នោះឯង ។ ម្នាលភិក្ខុទាំងឡាយ កាយរបស់ព្រះតថាគតមានតណ្ហានាំទៅកាន់ភពថ្មីទៀត ដាច់អស់ហើយ តែកាយឋិតនៅ (កាយរបស់ព្រះតថាគតនេះ) ឋិតនៅ ត្រឹមណា ទេវតានិងមនុស្សទាំងឡាយក៏នឹងឃើញកាយនោះត្រឹមណោះ លុះទំលាយខន្ធខាងមុខអំពីកិរិយាអស់ទៅនៃជីវិត ទើបពួកទេវតានិងមនុស្ស លែងឃើញកាយនោះ ម្នាលភិក្ខុទាំងឡាយ កាលបើចង្កោមផ្លែស្វាយ ដែលមានទងដាច់ហើយ ផ្លែស្វាយណាមួយដែលជាប់នៅក្នុងទង (ជាមួយគ្នា) ផ្លែស្វាយទាំងអស់នោះ

តទន្វយានិ ភវន្តិ ឯវមេវ ខោ ភិក្ខវេ ឧច្ឆិន្នភវនេត្តិកោ តថាគតស្ស កាយោ តិដ្ឋតិ យាវស្ស កាយោ ឋស្សតិ តាវ នំ ទក្ខិន្តិ ទេវមនុស្សា កាយស្ស ភេទា ឧទ្ធំ ជីវិតបរិយាទានា ន នំ ទក្ខិន្តិ ទេវមនុស្សាតិ ។ ឯវំ វុត្តេ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ កោនាមោ អយំ ភន្តេ ធម្មបរិយាយោតិ ។ តស្មាតិហ ត្វំ អានន្ទ ឥមំ ធម្មបរិយាយំ អត្ថជាលន្តិបិ នំ ធារេហិ ធម្មជាលន្តិបិ នំ ធារេហិ ព្រហ្មជាលន្តិបិ នំ ធារេហិ ទិដ្ឋិជាលន្តិបិ នំ ធារេហិ

រមែង(ដាច់ជ្រុះ)ទៅតាមគ្នាដែរ សេចក្តីនេះមានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ កាយរបស់ព្រះតថាគត មានតណ្ហាដែលនាំទៅកាន់ភពថ្មីទៀតដាច់អស់ហើយ (តែកាយនេះ) ឋិតនៅ កាយរបស់ព្រះតថាគតនេះឋិតនៅ ត្រឹមណា ទេវតានិងមនុស្សទាំងឡាយ នឹងឃើញកាយនោះ ត្រឹមណោះ លុះកាយបែកធ្លាយទៅ ខាងមុខអំពីកិរិយាអស់ទៅនៃជីវិត ទើបពួកទេវតានិងមនុស្សលែងបានឃើញកាយ របស់ព្រះតថាគតនោះ ក៏មានឧបមេយ្យដូច្នោះឯង ។ កាលដែលព្រះមានព្រះភាគ ត្រាស់សំដែងយ៉ាងនេះហើយ ព្រះអានន្ទមានអាយុ ក៏ក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចំរើន សេចក្តីនេះជាអស្ចារ្យ បពិត្រព្រះអង្គដ៏ចំរើន សេចក្តីនេះមិនធ្លាប់មានមកទេ បពិត្រព្រះអង្គដ៏ចំរើន ធម្មបរិយាយនេះឈ្មោះដូចម្តេច ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលអានន្ទ ហេតុនោះ អ្នកចូរចាំទុកនូវធម្មបរិយាយនេះ ក្នុងសាសនានេះថា អត្ថជាលៈ (មានអត្ថដូចជាបណ្តាញ) ដូច្នេះក៏បាន ចូរចាំទុកនូវធម្មបរិយាយនោះថា ធម្មជាលៈ (មានធម៌ដូចជាបណ្តាញ) ដូច្នេះក៏បាន ចូរចាំទុកនូវធម្មបរិយាយនោះថា ព្រហ្មជាលៈ (មានធម៌ដ៏ប្រសើរដូចជាបណ្តាញ) ដូច្នេះក៏បាន ចូរចាំទុកនូវធម្មបរិយាយនោះថា ទិដ្ឋិជាលៈ (មានទិដ្ឋិ ៦២ ដូចជាបណ្តាញ) ដូច្នេះក៏បាន

អនុត្តរោ សង្គាមវិជយោតិបិ នំ ធារេហីតិ ។ ឥទមវោច ភគវា ។ អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុំ ។ ឥមស្មឹ ច បន វេយ្យាករណស្មឹ ភញ្ញមានេ ទសសហស្សី លោកធាតុ អកម្បិត្ថាតិ ។

ព្រហ្មជាលសុត្តំ បឋមំ និដ្ឋិតំ ។

ចូរចាំទុកនូវធម្មបរិយាយនោះថា សង្គាមវិជយៈ(មានជ័យជំនះក្នុងសង្គ្រាម) ដ៏ប្រសើរដូច្នេះក៏បាន ។ លុះព្រះមានព្រះភាគ ទ្រង់ត្រាស់សំដែងព្រះសូត្រនេះហើយ ។ ភិក្ខុទាំងនោះ មានចិត្តត្រេកអរ រីករាយ ចំពោះភាសិតរបស់ព្រះមានព្រះភាគ ។ កាលដែលព្រះមានព្រះភាគ បានត្រាស់សំដែងព្រះសូត្រនេះ ជាពាក្យវេយ្យាករណ៍(ចប់)ហើយ លោក-ធាតុទាំងមួយម៉ឺន ក៏កម្រើកញាប់ញ័រ ។

ចប់ ព្រហ្មជាលសូត្រ ទី ១ ។

# សាមញ្ញផលសុត្តំ ទុតិយំ

(៩១) ឯវំ មេ សុតំ ។ ឯកំ សមយំ ភគវា រាជ-
គហេ វិហរតិ ជីវកស្ស កោមារភច្ចស្ស អម្ពវនេ មហតា
ភិក្ខុសង្ឃេន សទ្ធឹ អឌ្ឍតេឡសេហិ ភិក្ខុសតេហិ ។
តេន ខោ បន សមយេន រាជា មាគធោ អជាតសត្តុ
វេទេហិបុត្តោ តទហុបោសថេ បណ្ណរសេ កោមុទិយា
ចាតុម្មាសិនិយា បុណ្ណាយ បុណ្ណមាយ រត្តិយា រាជា-
មច្ចបរិវុតោ ឧបរិបាសាទវរគតោ និសិន្នោ ហោតិ ។
អថខោ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ
ឧទានំ ឧទានេសិ រមណីយា វត ភោ ទោសិនា រត្តិ
អភិរូបា វត ភោ ទោសិនា រត្តិ ទស្សនីយា វត ភោ
ទោសិនា រត្តិ បាសាទិកា វត ភោ ទោសិនា រត្តិ
លក្ខញ្ញា វត ភោ ទោសិនា រត្តិ កំ នុ ខ្វជ្ជ សម-
ណំ វា ព្រាហ្មណំ វា បយិរុបាសេយ្យាម យន្នោ

# សាមញ្ញផលសូត្រ ទី ២

[៩១] ខ្ញុំបានស្ដាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តអម្ពវ័ន (ព្រៃស្វាយ) ជារបស់ជីវកកោមារភត្យ ទៀបក្រុងរាជគ្រឹះ មួយអន្លើនឹងភិក្ខុសង្ឃច្រើន ចំនួនមួយពាន់ពីររយហាសិបរូប ។ សម័យនោះឯង ព្រះបាទអជាតសត្តុវេទេហិបុត្ត (ជាព្រះរាជបុត្ររបស់ព្រះរាជទេវី ទ្រង់ព្រះនាមវេទេហិ) ជាធំក្នុងដែនមគធៈ មានរាជ-អាមាត្យចោមរោម ទ្រង់គង់ប្រថាប់លើប្រាសាទដ៏ប្រសើរ ក្នុងរាត្រីមានព្រះចន្ទពេញវង់ ជារាត្រីមានរដូវភ្លៀង គ្រប់គ្រាន់ហើយ ជាទីបំផុតនៃខែ ៤ ជាកាលមានផ្កាកុមុទរីក ជាថ្ងៃឧបោសថទី ១៥ គឺពេញបូណ៌មីខែកត្តិក ។ គ្រានោះឯង ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាធំក្នុងដែនមគធៈ ទ្រង់បន្លឺឧទានវាចាថា រាត្រីប្រាសចាកទោស (ស្វាងរុងរឿង) គួរជាទីត្រេកអរ អ្ហីម្ល៉េះហ្ន៎ រាត្រីប្រាសចាកទោស មានភាពល្អ អ្ហីម្ល៉េះហ្ន៎ រាត្រីប្រាសចាកទោស គួរជាទីរមិលមើល អ្ហីម្ល៉េះហ្ន៎ រាត្រីប្រាសចាកទោស ជាទីនាំមកនូវសេចក្ដីជ្រះថ្លា អ្ហីម្ល៉េះហ្ន៎ រាត្រីប្រាសចាកទោស គួរជាទីកំណត់ដឹង អ្ហីម្ល៉េះហ្ន៎ ក្នុងថ្ងៃនេះ តើយើងគប្បីចូលទៅរកសមណៈឬព្រាហ្មណ៍ ណាហ្ន៎ យើងចូលទៅ

បយិរុបាសតោ ចិត្តំ បសីទេយ្យាតិ ។ ឯវំ វុត្តេ អញ្ញ-
តរោ រាជាមច្ចោ រាជានំ មាគធំ អជាតសត្តុំ វេទេហិ-
បុត្តំ ឯតទវោច អយំ ទេវ បូរណោ កស្សបោ សង្ឃី-
ចេវ គណី ច គណាចរិយោ ច ញាតោ យសស្សី
តិត្ថករោ សាធុសម្មតោ ពហុជនស្ស រត្តញ្ញូ ចិរបព្វ-
ជិតោ អទ្ធគតោ វយោអនុប្បត្តោ តំ ទេវោ បូរណំ
កស្សបំ បយិរុបាសតុ អប្បេវនាម ទេវស្ស បូរណំ
កស្សបំ បយិរុបាសតោ ចិត្តំ បសីទេយ្យាតិ ។ ឯវំ
វុត្តេ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ តុណ្ហី
អហោសិ ។ អញ្ញតរោបិ ខោ រាជាមច្ចោ រាជានំ
មាគធំ អជាតសត្តុំ វេទេហិបុត្តំ ឯតទវោច អយំ ទេវ
មក្ខលិ គោសាលោ សង្ឃីចេវ គណី ច គណាចរិយោ
ច ញាតោ យសស្សី តិត្ថករោ សាធុសម្មតោ
ពហុជនស្ស រត្តញ្ញូ ចិរបព្វជិតោ អទ្ធគតោ

អង្គុយជិតបុគ្គលណា ទើបទ្រង់មានចិត្តជ្រះថ្លាបាន ។ កាលបើព្រះរាជាមានព្រះបន្ទូលយ៉ាងនេះហើយ មានរាជអាមាត្យម្នាក់ ក្រាបបង្គំទូលព្រះបាទអជាតសត្រូវវេទេហិបុត្រ ជាធំក្នុងដែនមគធៈដូច្នេះថា បពិត្រព្រះសម្មតិទេព គ្រូឈ្មោះបូរណកស្សបនេះជាអ្នកមានពួកមានគណៈ(ច្រើន)ផងជាអាចារ្យរបស់គណៈផង ជាអ្នកមានកេរ្តិ៍ឈ្មោះ ជាអ្នកមានយស ជាអ្នកធ្វើនូវលទ្ធិ មហាជនសន្មតថាជាសប្បុរស ជាអ្នកដឹងរាត្រីយូរ បួសយូរជាងជនច្រើន តាំងនៅជាយូរអង្វែង (អស់ពីរបីរាជ្យមកហើយ) ដល់ហើយនូវបច្ឆិមវ័យ សូមព្រះសម្មតិទេពស្តេចចូលទៅរកគ្រូឈ្មោះបូរណកស្សបនោះចុះ កាលបើព្រះសម្មតិទេព ស្តេចចូលទៅរកគ្រូឈ្មោះបូរណកស្សបហើយ មុខជាទ្រង់មានព្រះរាជហឫទ័យជ្រះថ្លាមិនខាន ។ កាលបើរាជអាមាត្យនោះ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះបាទអជាតសត្រូវវេទេហិបុត្រ ជាធំក្នុងដែនមគធៈទ្រង់ព្រះតុណ្ហីភាព ។ មានរាជអាមាត្យម្នាក់ទៀត ក្រាបបង្គំទូលព្រះបាទអជាតសត្រូវវេទេហិបុត្រ ជាធំក្នុងដែនមគធៈដូច្នេះថា បពិត្រព្រះសម្មតិ-ទេព គ្រូឈ្មោះមក្ខលិគោសាលនេះ ជាអ្នកមានពួកមានគណៈ(ច្រើន) ផងជាអាចារ្យរបស់គណៈផង ជាអ្នកមានកេរ្តិ៍ឈ្មោះ ជាអ្នកមានយស ជាអ្នកធ្វើនូវលទ្ធិ មហាជនសន្មតថាជាសប្បុរស ជាអ្នកដឹងរាត្រីយូរ បួសយូរជាងជនច្រើន តាំងនៅជាយូរអង្វែង (អស់ពីរបីរាជ្យមកហើយ) ដល់ហើយ

វយោអនុប្បត្តោ តំ ទេវោ មក្ខលិំ គោសាលំ បយិរុបា-
សតុ អប្បេវនាម ទេវស្ស មក្ខលិំ គោសាលំ បយិរុបា-
សតោ ចិត្តំ បសីទេយ្យាតិ ។ ឯវំ វុត្តេ រាជា មាគធោ
អជាតសត្តុ វេទេហិបុត្តោ តុណ្ហី អហោសិ ។ អញ្ញតរោបិ
ខោ រាជាមច្ចោ រាជានំ មាគធំ អជាតសត្តុំ វេទេហិបុត្តំ
ឯតទវោច អយំ ទេវ អជិតោ កេសកម្ពលោ សង្ឃី ចេវ
គណី ច គណាចរិយោ ច ញាតោ យសស្សី តិត្ថករោ
សាធុសម្មតោ ពហុជនស្ស រត្តញ្ញូ ចិរបព្វជិតោ អទ្ធគ-
តោ វយោអនុប្បត្តោ តំ ទេវោ អជិតំ កេសកម្ពលំ
បយិរុបាសតុ អប្បេវនាម ទេវស្ស អជិតំ កេសកម្ពលំ
បយិរុបាសតោ ចិត្តំ បសីទេយ្យាតិ ។ ឯវំ វុត្តេ រាជា
មាគធោ អជាតសត្តុ វេទេហិបុត្តោ តុណ្ហី អហោសិ ។
អញ្ញតរោបិ ខោ រាជាមច្ចោ រាជានំ មាគធំ អជាត-
សត្តុំ វេទេហិបុត្តំ ឯតទវោច អយំ ទេវ បកុធោ

នូវបច្ចិមវ័យ សូមព្រះសម្មតិទេព ស្តេចចូលទៅគង់ជិតគ្រូឈ្មោះមក្ខលិគោសាលនោះចុះ កាលបើ ព្រះសម្មតិទេព ស្តេចចូលទៅរកគ្រូឈ្មោះមក្ខលិគោសាលហើយ មុខជានឹងមានព្រះរាជហឫទ័យជ្រះថ្លាមិនខាន ។ កាលបើរាជអាមាត្យនោះ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាធំក្នុងដែនមគធៈ ក៏ទ្រង់ព្រះតុណ្ហីភាព ។ មានរាជអាមាត្យម្នាក់ទៀត ក្រាបបង្គំទូលព្រះបាទអជាតសត្តុវេទេហិបុត្ត ជាធំក្នុងដែនមគធៈ ដូច្នេះថា បពិត្រព្រះសម្មតិទេព គ្រូឈ្មោះអជិតកេសកម្ពលនេះ ជាអ្នកមានពួកមានគណៈ(ច្រើន)ផង ជាអាចារ្យរបស់គណៈផង ជាអ្នកមានកេរ្តិ៍ឈ្មោះ ជាអ្នកមានយស ជាអ្នកធ្វើនូវលទ្ធិ មហាជនសន្មតថាជាសប្បុរស ជាអ្នកដឹងរាត្រីយូរ បួសយូរជាងជនជាច្រើន តាំងនៅជាយូរអង្វែង (អស់ពីរបីរាជ្យមកហើយ) ដល់ហើយនូវបច្ចិមវ័យ សូមព្រះសម្មតិទេព ស្តេចចូលទៅរកគ្រូឈ្មោះអជិតកេសកម្ពលនោះចុះ កាលបើ ព្រះសម្មតិទេព ស្តេចចូលទៅរកគ្រូឈ្មោះអជិតកេសកម្ពលហើយ មុខជានឹងមានព្រះរាជហឫទ័យជ្រះថ្លាមិនខានៗ កាលបើរាជអាមាត្យនោះ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាធំក្នុងដែនមគធៈ ទ្រង់ព្រះតុណ្ហីភាព ។ មានរាជអាមាត្យម្នាក់ទៀត ក្រាបបង្គំទូលព្រះបាទអជាតសត្តុវេទេហិបុត្ត ជាធំក្នុងដែនមគធៈដូច្នេះថា បពិត្រព្រះសម្មតិទេព គ្រូឈ្មោះបកុធ

កច្ចាយនោ សង្ឃី ចេវ គណី ច គណាចរិយោ ច ញាតោ យសស្សី តិត្ថករោ សាធុសម្មតោ ពហុជនស្ស រត្តញ្ញូ ចិរបព្វជិតោ អទ្ធគតោ វយោអនុប្បត្តោ. តំ ទេវោ បកុធំ កច្ចាយនំ បយិរុបាសតុ អប្បេវនាម ទេវស្ស បកុធំ កច្ចាយនំ បយិរុបាសតោ ចិត្តំ បសីទេយ្យាតិ ។ ឯវំ វុត្តេ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ តុណ្ហី អហោសិ ។ អញ្ញតរោបិ ខោ រាជាមច្ចោ រាជានំ មាគធំ អជាតសត្តុំ វេទេហិបុត្តំ ឯតទវោច អយំ ទេវ សញ្ជយោ វេលដ្ឋបុត្តោ សង្ឃី ចេវ គណី ច គណាចរិយោ ច ញាតោ យសស្សី តិត្ថករោ សាធុសម្មតោ ពហុជនស្ស រត្តញ្ញូ ចិរបព្វជិតោ អទ្ធគតោ វយោអនុប្បត្តោ តំ ទេវោ សញ្ជយំ វេលដ្ឋបុត្តំ បយិរុបាសតុ អប្បេវនាម ទេវស្ស សញ្ជយំ វេលដ្ឋបុត្តំ បយិរុបាសតោ

## សាមញ្ញផលសូត្រ រឿងព្រះបាទអជាតសត្តុ

កច្ចាយនៈនេះ ជាអ្នកមានពួកមានគណៈ ( ច្រើន ) ផង ជាអាចារ្យរបស់គណៈផង ជាអ្នកមានកេរ្តិ៍ឈ្មោះ ជាអ្នកមានយស ជាអ្នកធ្វើនូវលទ្ធិ មហាជនសន្មត ថាជាសប្បុរស ជាអ្នកដឹងរាត្រីយូរ បួសយូរជាងជនជាច្រើន តាំងនៅជាយូរអង្វែង (អស់ពីរបីរាជ្យមកហើយ) ដល់ហើយ នូវបច្ឆិមវ័យ សូមព្រះសម្មតិទេព ស្ដេចចូលទៅរកគ្រូឈ្មោះបកុធកច្ចាយនៈនោះចុះ កាលបើ ព្រះសម្មតិទេព ស្ដេចចូលទៅរកគ្រូឈ្មោះបកុធកច្ចាយនៈហើយ មុខជានឹងមានព្រះរាជហឫទ័យជ្រះថ្លាមិនខាន ។ កាលបើរាជអាមាត្យនោះ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាធំក្នុងដែនមគធៈ ទ្រង់ព្រះតុណ្ហីភាព ។ មានរាជអាមាត្យម្នាក់ទៀត ក្រាបបង្គំទូលព្រះបាទអជាតសត្តុវេទេហិបុត្ត ជាធំក្នុងដែនមគធៈ ដូច្នេះថា បពិត្រព្រះសម្មតិទេព គ្រូឈ្មោះសញ្ជយវេលដ្ឋបុត្តនេះ ជាអ្នកមានពួកមានគណៈ ( ច្រើន ) ផង ជាអាចារ្យរបស់គណៈផង ជាអ្នកមានកេរ្តិ៍ឈ្មោះ ជាអ្នកមានយស ជាអ្នកធ្វើនូវលទ្ធិ មហាជនសន្មតថាជាសប្បុរស ជាអ្នកដឹងរាត្រីយូរ បួសយូរជាងជនជាច្រើន តាំងនៅ ជាយូរអង្វែង ( អស់ពីរបីរាជ្យមកហើយ ) ដល់ហើយនូវបច្ឆិមវ័យ ព្រះសម្មតិទេព ស្ដេចចូលទៅរកគ្រូឈ្មោះសញ្ជយវេលដ្ឋបុត្តនោះចុះ កាលបើព្រះសម្មតិទេព ស្ដេចចូលទៅរកគ្រូឈ្មោះសញ្ជយវេលដ្ឋបុត្តហើយ មុខជានឹងមាន

ចិត្តំ បសីទេយ្យាតិ ។ ឯវំ វុត្តេ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ តុណ្ហី អហោសិ ។ អញ្ញតរោបិ ខោ រាជាមច្ចោ រាជានំ មាគធំ អជាតសត្តុំ វេទេហិបុត្តំ ឯតទវោច អយំ ទេវ និគណ្ឋោ នាដបុត្តោ[១] សង្ឃី ចេវ គណី ច គណាចរិយោ ច ញាតោ យសស្សី តិត្ថករោ សាធុសម្មតោ ពហុជនស្ស រត្តញ្ញូ ចិរបព្វជិតោ អទ្ធគតោ វយោអនុប្បត្តោ តំ ទេវោ និគណ្ឋំ នាដបុត្តំ បយិរុបាសតុ អប្បេវនាម ទេវស្ស និគណ្ឋំ នាដបុត្តំ បយិរុបាសតោ ចិត្តំ បសីទេយ្យាតិ ។ ឯវំ វុត្តេ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ តុណ្ហី អហោសិ ។

(៩២) តេន ខោ បន សមយេន ជីវកោ កោមារភច្ចោ រញ្ញោ មាគធស្ស អជាតសត្តុស្ស វេទេហិបុត្តស្ស អវិទូរេ តុណ្ហីភូតោ និសិន្នោ ហោតិ ។ អថ ខោ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ ជីវកំ កោមារភច្ចំ ឯតទវោច ត្វំ បន សម្ម ជីវក កឹ តុណ្ហីតិ ។

---

១ ឧ. នាតបុត្តោ ។

ព្រះរាជហឫទ័យជ្រះថ្លាមិនខាន ។ កាលបើរាជអាមាត្យនោះ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាធំក្នុងដែនមគធៈ ទ្រង់ព្រះតុណ្ហីភាព ។ មានរាជអាមាត្យម្នាក់ទៀត ក្រាបបង្គំទូលព្រះបាទអជាតសត្តុវេទេហិបុត្ត ជាធំក្នុងដែនមគធៈដូច្នេះថា បពិត្រព្រះសម្មតិទេព គ្រូឈ្មោះនិគណ្ឋនាដបុត្តនេះ ជាអ្នកមានពួកមានគណៈ(ច្រើន)ផង ជាអាចារ្យរបស់គណៈផង ជាអ្នកមានកេរ្តិ៍ឈ្មោះ ជាអ្នកមានយស ជាអ្នកធ្វើទីលទ្ធិ មហាជនសន្មតថាជាសប្បុរស ជាអ្នកដឹងរាត្រីយូរ បួសយូរជាងជនជាច្រើន តាំងនៅជាយូរអង្វែង (អស់ពីរបីរាជ្យមកហើយ) ដល់ហើយ នូវបច្ឆិមវ័យ សូមព្រះសម្មតិទេព ស្តេចចូលទៅរកគ្រូឈ្មោះនិគណ្ឋនាដបុត្តនោះចុះ កាលបើព្រះសម្មតិទេព ស្តេចចូលទៅរកគ្រូឈ្មោះនិគណ្ឋនាដបុត្តហើយ មុខជាទ្រង់មានព្រះរាជហឫទ័យជ្រះថ្លាមិនខាន ។ កាលបើរាជអាមាត្យនោះ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាធំក្នុងដែនមគធៈ ទ្រង់ព្រះតុណ្ហីភាព ។

(៩២) សម័យនោះឯង ជីវកកោមារភត្យអង្គុយស្ងៀម ជិតព្រះបាទអជាតសត្តុវេទេហិបុត្ត ជាធំក្នុងដែនមគធៈ ។ គ្រានោះ ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាធំក្នុងដែនមគធៈ ទ្រង់មានព្រះរាជឱង្ការនឹងជីវកកោមារភត្យដូច្នេះថា នែជីវកៈជាសំឡាញ់ ចុះហេតុអ្វីបានជាអ្នកស្ងៀម ។

អយំ ទេវ ភគវា អរហំ សម្មាសម្ពុទ្ធោ អម្ហាកំ អម្ពវនេ វិហរតិ មហតា ភិក្ខុសង្ឃេន សទ្ធឹ អឌ្ឍតេឡសេហិ ភិក្ខុសតេហិ តំ ខោ បន ភគវន្តំ[១] ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ តំ ទេវោ ភគវន្តំ បយិរុបាសតុ អប្បេវនាម ទេវស្ស ភគវន្តំ បយិរុបាសតោ ចិត្តំ បសីទេយ្យាតិ ។ តេនហិ សម្ម ជីវក ហត្ថិយានានិ កប្បាបេហីតិ ។ ឯវំ ទេវាតិ ខោ ជីវកោ កោមារភច្ចោ រញ្ញោ មាគធស្ស អជាតសត្តុស្ស វេទេហិបុត្តស្ស បដិស្សុណិត្វា

១ ឱ. ម. ភគវន្តំ គោតមំ ។

ជីវកកោមារភច្ច ក្រាបបង្គំទូលថា បពិត្រព្រះសម្មតិទេព ព្រះមានព្រះភាគនេះ ជាអរហន្តសម្មាសម្ពុទ្ធ ឥឡូវនេះព្រះអង្គគង់នៅ ក្នុងវត្តអម្ពវ័នរបស់ខ្ញុំព្រះអង្គ មួយអន្លើនឹងភិក្ខុសង្ឃច្រើន ចំនួន ១២៥០ រូប ឯកិត្តិស័ព្ទដ៏ពីរោះរបស់ព្រះមានព្រះភាគអង្គនោះ ឮខ្ចរខ្ចាយសុសសាយទៅយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាងហើយ ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ចំពោះព្រះអង្គដោយប្រពៃ ព្រះអង្គបរិបូណ៌ដោយវិជ្ជានឹងចរណៈ គឺសេចក្តីចេះដឹងនឹងក្រិត្យដែលបុគ្គលគប្បីប្រព្រឹត្ត ព្រះអង្គមានដំណើរល្អ ទៅកាន់ព្រះនិព្វាន ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណមិនមានបុគ្គលណាមួយស្មើ ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតានឹងមនុស្សទាំងឡាយ ព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលត្រឡប់មកកាន់ភពថ្មីទៀត សូមព្រះសម្មតិទេព ស្តេចចូលទៅរកព្រះមានព្រះភាគនោះចុះ កាលបើព្រះសម្មតិទេព ស្តេចចូលទៅរកព្រះមានព្រះភាគហើយ មុខជានឹងមានព្រះរាជហឫទ័យជ្រះថ្លាមិនខាន ។ ព្រះរាជាទ្រង់មានព្រះរាជបញ្ជាថា នែជីវកៈជាសំឡាញ់ បើដូច្នោះ ចូរអ្នកឲ្យរៀបចំយានដំរីទាំងឡាយចុះ ។ ជីវកកោមារភច្ច ទទួលព្រះរាជបញ្ជានៃព្រះបាទអជាតសត្រូវវេទេហិបុត្ត

បញ្ចមត្តានិ ហត្ថិនិយាសតានិ(១) កប្បាបេត្វា រញ្ញោ ច អារោហណីយំ នាគំ រញ្ញោ មាគធស្ស អជាតសត្តុស្ស វេទេហីបុត្តស្ស បដិវេទេសិ កប្បិតានិ ខោ តេ ទេវ ហត្ថិយានានិ យស្សទានិ កាលំ មញ្ញសីតិ ។ អថខោ រាជា មាគធោ អជាតសត្តុ វេទេហីបុត្តោ បញ្ចសុ ហត្ថិនិយាសតេសុ(២) បច្ចេកា ឥត្ថិយោ អារោបេត្វា អារោហណីយំ នាគំ អភិរុហិត្វា ឧក្កាសុ ធារិយមានាសុ រាជគហម្ហា និយ្យាសិ មហច្ចរាជានុភាវេន យេន ជីវកស្ស កោមារភច្ចស្ស អម្ពវនំ តេន បាយាសិ ។ អថខោ រញ្ញោ មាគធស្ស អជាតសត្តុស្ស វេទេហីបុត្តស្ស អវិទូរេ អម្ពវនស្ស អហុទេវ ភយំ អហុ ឆម្ភិតត្តំ អហុ លោមហំសោ ។ អថខោ រាជា មាគធោ អជាតសត្តុ វេទេហីបុត្តោ ភីតោ សំវិគ្គោ លោមហដ្ឋជាតោ(៣) ជីវកំ កោមារភច្ចំ ឯតទវោច កច្ចិ មំ សម្ម ជីវក ន វញ្ចេសិ កច្ចិ មំ សម្ម ជីវក ន បលម្ភេសិ កច្ចិ មំ សម្ម ជីវក ន បច្ចត្ថិកានំ ទេសិ

---

១ ឱ. ហត្ថិនិកាសតានិ ។ ២ ហត្ថិនិកាសតេសូតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ៣ លោមហំសជាតោតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

ជាធំក្នុងដែនមគធៈ ដោយពាក្យថា ព្រះករុណាថ្លៃវិសេស ហើយក៏ឲ្យរៀបចំដំរីញីទាំងឡាយចំនួន ៥០០ ផង ឲ្យរៀបចំដំរីឈ្មោលជាព្រះទីនាំងរបស់ព្រះរាជាផង រួចហើយក៏ចូលទៅក្រាបបង្គំទូលព្រះបាទអជាតសត្តុវេទេហិបុត្ត ជាធំក្នុងដែនមគធៈថា បពិត្រព្រះសម្មតិទេព យានដំរីទាំងឡាយខ្ញុំព្រះអង្គបានឲ្យរៀបចំ សម្រាប់ព្រះអង្គជាស្រេចហើយ ឥឡូវនេះ សូមព្រះអង្គកំណត់កាលដ៏គួរនឹងព្រះរាជដំណើរចុះ ៗ លំដាប់នោះ ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាធំក្នុងដែនមគធៈ ឲ្យពួកស្រីឡើងជិះដំរីញី ១ នាក់គ្រប់ទាំង ៥០០ ហើយទ្រង់ឡើងគង់លើដំរីឈ្មោលជាព្រះទីនាំង មានពួករាជបុរសកាន់គប់ភ្លើង ហែចេញអំពីក្រុងរាជគ្រឹះ ដោយរាជានុភាពដ៏ប្រសើរ ស្ដេចសំដៅទៅត្រង់ទីវត្តអម្ពវ័ន របស់ជីវកកោមារភច្ច ៗ ក្នុងកាលដែលព្រះបាទអជាតសត្តុវេទេហិបុត្ត ជាធំក្នុងដែនមគធៈ ទ្រង់ស្ដេចទៅដល់ទីជិតនៃវត្តអម្ពវ័ន ក៏មានសេចក្ដីខ្លាច មានសេចក្ដីតក់ស្លុត មានសេចក្ដីព្រឺរោមកើតឡើង ៗ លុះព្រះបាទអជាតសត្តុវេទេហិបុត្ត ជាធំក្នុងដែនមគធៈ កើតមានសេចក្ដីខ្លាច សេចក្ដីតក់ស្លុត ព្រឺរោមកើតឡើងហើយ ទើបទ្រង់មានព្រះបន្ទូលនឹងជីវកកោមារភច្ចដូច្នេះថា នែជីវកៈ ជាសំឡាញ់ អ្នកមិនបញ្ឆោតខ្ញុំទេឬ នែជីវកៈជាសំឡាញ់ អ្នកមិនល្បួងខ្ញុំទេឬ នែជីវកៈ ជាសំឡាញ់ អ្នកមិននាំខ្ញុំ (យកមក) ឲ្យដល់ពួកសត្រូវទេឬ ព្រោះថាភិក្ខុ

កថំ ហិ នាម តាវមហតោ ភិក្ខុសង្ឃស្ស អឌ្ឍតេ-ឡសានំ ភិក្ខុសតានំ នេវ ខិបិតសទ្ទោ ភវិស្សតិ ន ឧក្កាសិតសទ្ទោ ន និគ្ឃោសោតិ ។ មា ភាយិ មហារាជ មា ភាយិ មហារាជ ន តំ ទេវ វញ្ចេមិ ន តំ ទេវ បលម្ភាមិ ន តំ ទេវ បច្ចត្ថិកានំ ទេមិ អភិក្កម មហារាជ អភិក្កម មហារាជ ឯតេ មណ្ឌលមាឡេ បទីបា[១] ឈាយន្តីតិ ។ អថខោ រាជា មាគធោ អជាតសត្តុ វេទេហីបុត្តោ យាវតិកា នាគស្ស ភូមិ នាគេន គន្ត្វា នាគា បច្ចោរោហិត្វា បត្តិកោវ[២] យេន មណ្ឌលមាឡស្ស ទ្វារំ តេនុ-បសង្កមិ ឧបសង្កមិត្វា ជីវកំ កោមារភច្ចំ ឯតទ-វោច កហំ បន សម្ម ជីវក ភគវាតិ ។ ឯសោ មហារាជ ភគវា មជ្ឈិមំ ថម្ភំ និស្សាយ បុរត្ថា-ភិមុខោ និសិន្នោ បុរក្ខតោ ភិក្ខុសង្ឃស្សាតិ ។ អថខោ រាជា មាគធោ អជាតសត្តុ វេទេហីបុត្តោ

---

១ ឱ. ម. ទីបា ។ ២ ឱ. ម. បត្តិកោ វ ។

សង្ឃជាច្រើនដល់ម្ល៉ោះ ចំនួន ១២៥០ រូប ហេតុអ្វីក៏គ្មានសម្លេងកណ្តាស សម្លេងក្អក សម្លេងគឹកកង់សោះ ៗ ជីវកកោមារភច្ច ក្រាបបង្គំទូលថា បពិត្រមហារាជ សូមព្រះអង្គកុំខ្លាចឡើយ បពិត្រមហារាជ សូមព្រះអង្គ កុំខ្លាចឡើយ បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គមិនបញ្ឆោតព្រះអង្គទេ បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គមិនល្បួងព្រះអង្គទេ បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គមិន(នាំយកព្រះអង្គមក)ឲ្យដល់ពួកសត្រូវទេ បពិត្រមហារាជ សូមព្រះអង្គស្តេចចូលទៅ បពិត្រមហារាជ សូមព្រះអង្គស្តេចចូលទៅ នុ៎ះន៏ប្រទីបទាំងឡាយ ដែលគេអុជតាំងនៅក្នុងរោងមានសណ្ឋានមូល(១) ៗ លំដាប់នោះ ព្រះបាទអជាតសត្តុវេទេហីបុត្តជាធំក្នុងដែនមគធៈ ទ្រង់ស្តេចទៅដោយដំរីកំណត់ត្រឹមទីដែលល្មមបរដំរីទៅបាន ហើយក៏ទ្រង់ចុះពីដំរី ទ្រង់ស្តេចទៅដោយព្រះបាទ ចូលសំដៅទៅត្រង់ទ្វាររោងមានសណ្ឋានមូល លុះស្តេចចូលទៅដល់ហើយ ទ្រង់មានព្រះបន្ទូលដូច្នេះទៅនឹងជីវកកោមារភច្ចថា នែជីវកៈជាសំឡាញ់ ចុះព្រះមានព្រះភាគ ទ្រង់គង់ក្នុងទីណា ៗ ជីវកកោមារភច្ច ក្រាបបង្គំទូលថា បពិត្រមហារាជ នុ៎ះន៏ព្រះមានព្រះភាគ ទ្រង់គង់ផ្អែកនឹងសសរកណ្តាល ឆ្ពោះព្រះភក្ត្រទៅទិសខាងកើត ខាងមុខភិក្ខុសង្ឃ ៗ គ្រានោះ ព្រះបាទអជាតសត្តុវេទេហីបុត្ត ជាធំក្នុងដែនមគធៈ

---

១ សាលាសម្រាប់អង្គុយ ( អដ្ឋកថា ត្រង់ព្រហ្មជាលសូត្រ ) ។

យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ តុណ្ហីភូតំ តុណ្ហីភូតំ ភិក្ខុសង្ឃំ អនុវិលោកេត្វា រហទមិវ វិប្បសន្នំ ឧទានំ ឧទានេសិ ឥមិនា មេ ឧបសមេន ឧទយភទ្ទោ(១) កុមារោ សមន្នាគតោ ហោតុ យេនេតរហិ ឧបសមេន ភិក្ខុសង្ឃោ សមន្នាគតោតិ ។ អាគមា ខោ ត្វំ មហារាជ យថាបេមន្តិ ។ បិយោ មេ ភន្តេ ឧទយភទ្ទោ កុមារោ ឥមិនា មេ ភន្តេ ឧបសមេន ឧទយភទ្ទោ កុមារោ សមន្នាគតោ ហោតុ យេនេតរហិ ឧបសមេន ភិក្ខុសង្ឃោ សមន្នាគតោតិ ។

(៩៣) អថខោ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ ភគវន្តំ អភិវាទេត្វា ភិក្ខុសង្ឃស្ស អញ្ជលឹ ឧបនាមេត្វា(២) ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ ភគវន្តំ

---

១ ឱ. ឧទាយិភទ្ទោ ។ ២ ឱ. ម. បណាមេត្វា ។

ទ្រង់ស្តេចចូលទៅរកព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ទ្រង់ឋិតនៅក្នុងទីសមគួរ ។ លុះព្រះបាទអជាតសត្តុវេទេហិបុត្ត ជាធំក្នុងដែនមគធៈ ទ្រង់ឋិតនៅក្នុងទីសមគួរហើយ ទើបទ្រង់ឆ្មៀងព្រះនេត្រក្រឡេកទតទៅភិក្ខុសង្ឃ ដែលអង្គុយនៅស្ងៀមទាំងអស់ ក៏ទ្រង់បន្លឺនូវឧទានក្រោយដ៏ថាស្អាត ដូចជាអន្លង់ទឹកថា ឥឡូវនេះ ភិក្ខុសង្ឃប្រកបដោយសេចក្តីស្ងប់រម្ងាប់ណា សូមឲ្យឧទយភទ្ទកុមារ ជាកូនរបស់អញប្រកបដោយសេចក្តីស្ងប់រម្ងាប់នេះ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បពិត្រមហាបពិត្រ ព្រះអង្គស្តេចមកដោយជាប់ចំពាក់ នឹងសេចក្តីស្រឡាញ់ផង ។ ព្រះបាទអជាតសត្តុ ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ឧទយភទ្ទកុមារជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គ បពិត្រព្រះអង្គដ៏ចំរើន ឥឡូវនេះ ភិក្ខុសង្ឃ ប្រកបដោយសេចក្តីស្ងប់រម្ងាប់ណា សូមឲ្យឧទយភទ្ទកុមារជាកូនរបស់ខ្ញុំព្រះអង្គ ប្រកបដោយសេចក្តីស្ងប់រម្ងាប់នេះផង ។

(៩៣) លំដាប់នោះ ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាធំក្នុងដែនមគធៈ ថ្វាយបង្គំព្រះមានព្រះភាគ ហើយប្រណម្យអញ្ជលី ចំពោះភិក្ខុសង្ឃរួចហើយក៏គង់ក្នុងទីសមគួរ ។ លុះព្រះបាទអជាតសត្តុវេទេហិបុត្តជាធំក្នុងដែនមគធៈគង់ក្នុងទីសមគួរហើយ ទ្រង់ក្រាបបង្គំទូលព្រះមានព្រះភាគ

ឯតទវោច បុច្ឆេយ្យាមហំ ភន្តេ ភគវន្តំ កញ្ចិទេវ ទេសំ លេសមត្តំ សចេ មេ ភគវា ឱកាសំ ករោតិ បញ្ហស្ស វេយ្យាករណាយាតិ ។ បុច្ឆ មហារាជ យទាកង្ខសីតិ ។ យថា នុ ខោ ឥមានិ ភន្តេ បុថុសិប្បាយតនានិ សេយ្យថីទំ ហត្ថារោហា អស្សារោហា រថិកា ធនុគ្គហា ចេលកា ចលកា បិណ្ឌទាយិកា ឧគ្គា រាជបុត្តា បក្ខន្ទិនោ មហានាគា សូរា ចម្មយោធិនោ ទាសកបុត្តា អាឡារិកា កប្បកា នហាបកា(១) សូទា មាលាការា រជកា បេសការា នឡការា កុម្ភការា គណកា មុទ្ទិកា យានិ វា បនញ្ញានិបិ ឯវំគតានិ បុថុសិប្បាយតនានិ តេ ទិដ្ឋេវ ធម្មេ សន្ទិដ្ឋិកំ សិប្ប-

---

១ នហាបិកាតិបិ ទិស្សតិ ។

ដូច្នេះថា សូមទ្រង់ព្រះមេត្តាប្រោស បើព្រះមានព្រះភាគ ទ្រង់ធ្វើឱកាស ដើម្បីព្យាករណ៍ (ដោះ) ប្រស្នារបស់ខ្ញុំព្រះអង្គបាន ខ្ញុំព្រះអង្គនឹងគប្បីទូលសួរនូវហេតុទីមួយ គ្រាន់តែជាលេសគ្រឿងអាងនឹងព្រះមានព្រះភាគ ។ ព្រះអង្គទ្រង់ត្រាស់ថា បពិត្រមហារាជ បើទ្រង់ប្រាថ្នានឹងសួរនូវប្រស្នាណា សូមទ្រង់សួរមកចុះ ។ ព្រះរាជាទ្រង់សួរថា សូមទ្រង់ព្រះមេត្តាប្រោស ដូចជាសិល្បៈសម្រាប់បង្កើតផល មានប្រមាណច្រើនទាំងនេះ បានដល់សិល្បៈរបស់បុគ្គលនោះ ៗ គឺសិល្បៈរបស់ពួកបុគ្គលអ្នកកាន់ការខាងដំរី អ្នកកាន់ការខាងសេះ អ្នកកាន់ការខាងរថ ពួកខ្មាន់ធ្នូ ពួកអ្នកកាន់ទង់ជ័យ (មុខ) ពួកអ្នកចាត់ទ័ព ពួកអ្នកបញ្ជូនស្បៀង ពួកព្រះរាជបុត្រអ្នកពុះពារ (ចូលសង្គ្រាម) ពួកអ្នកស្ទុះចូលទៅ ក្នុងសង្គ្រាម (អ្នកយកអាសា) ពួកយោធាអ្នកអង់អាច ពួកសេនាអ្នកក្លៀវក្លា ពួកយោធាអ្នកពាក់អាវក្រោះ ពួកកូននៃជនជាទាសៈ (ជាទីស្រឡាញ់របស់ចៅហ្វាយនាយ) ពួកអ្នកធ្វើនំ ពួកជាងអ្នកកោរកាត់ ពួកអ្នកផ្ងូតទឹក ពួកអ្នកធ្វើអាហារ ពួកជាងក្រងផ្កា ពួកជាងជ្រលក់ ពួកជាងតម្បាញ ពួកជាងត្បាញផែង ពួកជាងស្មូនឆ្នាំង ពួកអ្នកចេះលេខនព្វន្ត ពួកអ្នកចេះរាប់ដោយម្រាមដៃទទេ ពុំនោះសោត សិល្បៈសម្រាប់បង្កើតផល មានប្រមាណច្រើនណាមួយដទៃទៀត ដែលមានបែបយ៉ាងនេះក្តី បុគ្គលទាំងនោះ រមែងចិញ្ចឹមជីវិតអាស្រ័យនូវផល

ផលំ ឧបជីវន្តិ តេ តេន អត្តានំ សុខេន្តិ បីណេន្តិ មាតាបិតរោ សុខេន្តិ បីណេន្តិ បុត្តទារំ សុខេន្តិ បីណេន្តិ មិត្តាមច្ចេ សុខេន្តិ បីណេន្តិ សមណព្រាហ្មណេសុ ឧទ្ធគ្គិកំ ទក្ខិណំ បតិដ្ឋបេន្តិ សោវគ្គិកំ សុខវិបាកំ សគ្គសំវត្តនិកំ សក្កា នុ ខោ ភន្តេ ឯវមេវ(១) ទិដ្ឋេវ ធម្មេ សន្ទិដ្ឋិកំ សាមញ្ញផលំ បញ្ញបេតុន្តិ ។ អភិជានាសិ នោ ត្វំ មហារាជ ឥមំ បញ្ហំ អញ្ញេ សមណព្រាហ្មណេ បុច្ឆិតាតិ ។ អភិជានាមហំ ភន្តេ ឥមំ បញ្ហំ អញ្ញេ សមណព្រាហ្មណេ បុច្ឆិតាតិ ។ យថា កថំ បន តេ

១ ឱ. ឯវមេវំ ។

របស់សិល្បៈ ដែលឃើញច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្ន បុគ្គលទាំងនោះ រមែងធ្វើខ្លួន ឲ្យដល់នូវសេចក្តីសុខ ឲ្យពេញលេញ ( ដោយកម្លាំងកាយ កម្លាំងប្រាជ្ញា ) រមែងធ្វើមាតាបិតា ឲ្យដល់នូវសេចក្តីសុខ ឲ្យពេញលេញ រមែងធ្វើបុត្រភរិយា ឲ្យដល់នូវសេចក្តីសុខ ឲ្យពេញលេញ រមែងធ្វើមិត្តអាមាត្យ ឲ្យដល់នូវសេចក្តីសុខ ឲ្យពេញលេញ រមែងញុំាងទក្ខិណា. ទាន ដែលមានផលខ្ពស់ ជាទានគួរដល់នូវកិរិយាកើតក្នុងឋានសួគ៌ ជាទានមានផលនាំមកនូវសេចក្តីសុខ ជាទានញុំាងធម៌[១]ទាំង ១០ ដ៏ប្រសើរ ឲ្យប្រព្រឹត្តទៅដោយល្អ ឲ្យតម្កល់ចំពោះសមណៈនិងព្រាហ្មណ៍ទាំងឡាយ ដោយសិល្បៈនោះ បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គអាចនឹងបញ្ញត្តនូវផល នៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ដូចយ៉ាងផលសិល្បៈនោះបានដែរឬទេ ។ ព្រះអង្គទ្រង់ត្រាស់ថា បពិត្រមហារាជ ក្រែងមហារាជ បានសួរប្រស្នានេះ នឹងសមណព្រាហ្មណ៍ទាំងឡាយដទៃ ជ្រាបច្បាស់ហើយឬ ។ ព្រះរាជាក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ខ្ញុំព្រះអង្គបានសួរប្រស្នានេះនឹងសមណព្រាហ្មណ៍ទាំងឡាយដទៃ ដឹងច្បាស់ហើយ ។ ព្រះអង្គទ្រង់ត្រាស់ថា បពិត្រមហារាជ ចុះសមណៈនឹងព្រាហ្មណ៍ទាំងឡាយនោះ ដោះស្រាយដោយប្រការ ដូចម្តេចខ្លះ បើ

---

១ ធម៌ទាំង ១០ ជាទិព្វ គឺ រូប សម្លេង ក្លិន រស ផ្សព្វ អាយុ វណ្ណៈ សុខ យស អធិបតី ។

មហារាជ ព្យាករឹសុ សចេ តេ អគរុ ភាសស្សូតិ ។ ន ខោ មេ ភន្តេ គរុ យត្ថស្ស ភគវា និសិន្នោ ភគវន្តរូបោ វាតិ ។ តេនហិ មហារាជ ភាសស្សូតិ ។

(៩៤) ឯកមិទាហំ ភន្តេ សមយំ យេន បូរណោ កស្សបោ តេនុបសង្កមឹ ឧបសង្កមិត្វា បូរណេន កស្ស-បេន សទ្ធឹ សម្មោទឹ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹ ឯកមន្តំ និសិន្នោ ខោ អហំ ភន្តេ បូរណំ កស្សបំ ឯតទវោចំ យថា នុ ខោ ឥមានិ ភោ កស្សប បុថុសិប្បាយតនានិ សេយ្យថីទំ ហត្ថារោហា អស្សារោហា រថិកា ធនុគ្គហា ចេលកា ចលកា បិណ្ឌទាយិកា ឧគ្គា រាជបុត្តា បក្ខន្ទិនោ

មហារាជ មិនទើសទាល់ទេ សូមមហារាជផ្ទៀងមក ។ ព្រះរាជាក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស ព្រះមានព្រះភាគ ឬបុគ្គលដែលមានសភាពដូចជាព្រះមានព្រះភាគ គង់នៅក្នុងទីណា ទីនោះខ្ញុំព្រះអង្គមិនមានសេចក្តីទើសទាល់ទេ ។ ព្រះអង្គត្រាស់ថា បពិត្រមហារាជ បើដូច្នោះ សូមមហារាជ ទ្រង់មានព្រះរាជឧក្ការមកចុះ ។

(៩៤) ព្រះរាជាក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ក្នុងក្រុងរាជគ្រឹះនេះ សម័យមួយ ខ្ញុំព្រះអង្គបានចូលទៅរកគ្រូឈ្មោះបូរណកស្សប លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាល ជាមួយនឹងគ្រូឈ្មោះបូរណកស្សប លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹក ល្មមឲ្យកើតសេចក្តីស្និទ្ធស្នាលហើយ ក៏បានអង្គុយក្នុងទីសមគួរ បពិត្រព្រះអង្គដ៏ចំរើន លុះខ្ញុំព្រះអង្គអង្គុយក្នុងទីសមគួរហើយ ក៏ផ្តើមពាក្យសួរដូច្នេះ ទៅនឹងគ្រូឈ្មោះបូរណកស្សបថា បពិត្រលោកកស្សបដ៏ចំរើន ដូចជាសិល្បៈសម្រាប់បង្កើតផលមានប្រមាណច្រើនទាំងនេះ គឺសិល្បៈរបស់ពួកបុគ្គលអ្នកជិះដំរី(១) អ្នកជិះសេះ(២) អ្នកកាន់ការខាងរថ ពួកខ្មាន់ធ្នូ ពួកអ្នកកាន់ទង់ជ័យ (មុខ) ពួកអ្នកចាត់ទ័ព ពួកអ្នកបញ្ជូនស្បៀង ពួកព្រះរាជបុត្តអ្នកពុះពារ (លុកចូលក្នុងសង្គ្រាម) ពួកអ្នកស្ទុះ

---

១–២ អដ្ឋកថា ថា អ្នកថែរក្សាដំរីសេះ ក៏រាប់បញ្ចូលក្នុងជនពួកនេះទាំងអស់ ។

មហានាគា សូរា ចម្មយោធិនោ ទាសកបុត្តា អាឡារិ-
កា កប្បកា នហាបកា សូទា មាលាការា រជកា
បេសការា នឡការា កុម្ភការា គណកា មុទ្ទិកា
យានិ វា បនញ្ញានិបិ ឯវំគតានិ បុថុសិប្បាយតនានិ តេ
ទិដ្ឋេវ ធម្មេ សន្ទិដ្ឋិកំ សិប្បផលំ ឧបជីវន្តិ តេ តេន
អត្តានំ សុខេន្តិ បីណេន្តិ មាតាបិតរោ សុខេន្តិ បីណេន្តិ
បុត្តទារំ សុខេន្តិ បីណេន្តិ មិត្តាមច្ចេ សុខេន្តិ បីណេន្តិ
សមណព្រាហ្មណេសុ ឧទ្ធគ្គិកំ ទក្ខិណំ បតិដ្ឋបេន្តិ
សោវគ្គិកំ សុខវិបាកំ សគ្គសំវត្តនិកំ សក្កា នុ ខោ
ភោ កស្សប ឯវមេវ ទិដ្ឋេវ ធម្មេ សន្ទិដ្ឋិកំ សាមញ្ញ-

ចូលសម្រុកក្នុងសង្គ្រាម ពួកយោធាអ្នកអង់អាច ពួកសេនាអ្នកក្លៀវក្លា ពួកយោធាអ្នកពាក់គ្រឿងក្រោះ ពួកកូននៃជនជាទាសៈ (ជាទីស្រឡាញ់របស់ចៅហ្វាយនាយ) ពួកអ្នកធ្វើនំ ពួកជាងអ្នកកោរកាត់ ពួកអ្នកផ្ងូតទឹក ពួកអ្នកធ្វើអាហារ ពួកជាងក្រងផ្កា ពួកជាងជ្រលក់ ពួកជាងតម្បាញ ពួកជាងត្បាញផែង ពួកស្មូនឆ្នាំង ពួកអ្នកចេះលេខនព្វន្ធ ពួកអ្នកចេះគិតដោយម្រាមដៃទទេ ពុំនោះសោត សិល្បៈសម្រាប់បង្កើតផលមានប្រមាណច្រើនឯណានីមួយដទៃទៀត ដែលមានបែបយ៉ាងនេះ បុគ្គលទាំងនោះ រមែងចិញ្ចឹមជីវិតអាស្រ័យនូវផលរបស់សិល្បៈ ដែលឃើញច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្ន បុគ្គលទាំងនោះ រមែងធ្វើខ្លួនឲ្យដល់នូវសេចក្ដីសុខឲ្យពេញលេញ រមែងធ្វើមាតាបិតា ឲ្យដល់នូវសេចក្ដីសុខ ឲ្យពេញលេញ រមែងធ្វើបុត្រភរិយាឲ្យដល់នូវសេចក្ដីសុខ ឲ្យពេញលេញ រមែងធ្វើមិត្តអាមាត្យឲ្យដល់នូវសេចក្ដីសុខ ឲ្យពេញលេញ រមែងញុំាងទក្ខិណាទានដែលមានផលខ្ពស់ ជាទានគួរដល់កិរិយាកើតក្នុងឋានសួគ៌ ជាទានមានផលនាំមកនូវសេចក្ដីសុខ ជាទានញុំាងធម៌ទាំង ១០ ដ៏ប្រសើរ ឲ្យប្រព្រឹត្តទៅដោយល្អ ឲ្យតម្កល់នៅក្នុងសមណៈនិងព្រាហ្មណ៍ទាំងឡាយ ដោយសិល្បៈនោះ បពិត្រលោកកស្សបដ៏ចំរើន លោកអាចនឹងបញ្ញត្តនូវផលនៃសាមញ្ញប្បដិបត្តិ(១) ដែលឃើញច្បាស់ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ដូចយ៉ាងផលសិល្បៈ

---

១ សាមញ្ញផល គឺផលផ្លែឬជាអានិសង្សនៃអ្នកបួសក្នុងសាសនា ។

ផលំ បញ្ញាបេតុន្តិ ឯវំ វុត្តេ ភន្តេ បូរណោ កស្សបោ មំ ឯតទវោច ករោតោ(១) ខោ មហារាជ ការយតោ ឆិន្ទតោ ឆេទាបយតោ បចតោ បាចាបយតោ សោចយតោ សោចាបយតោ កិលមយតោ កិលមាបយតោ ផន្ទតោ ផន្ទាបយតោ បាណមតិបាតាបយតោ(២) អទិន្នំ អាទិយតោ សន្ធឹ ឆិន្ទតោ និល្លោបំ ហរតោ ឯកាគារិកំ ករោតោ បរិបន្ថេ តិដ្ឋតោ បរទារំ គច្ឆតោ មុសា ភណតោ ករោតោ ន ករីយតិ បាបំ ខុរបរិយន្តេន ចេបិ ចក្កេន យោ ឥមិស្សា បឋវិយា បាណេ ឯកំ មំសខលំ ឯកំ មំសបុញ្ជំ ករេយ្យ នត្ថិ តតោនិទានំ បាបំ នត្ថិ បាបស្ស អាគមោ ទក្ខិណញ្ចេបិ គង្គាយ តីរំ គច្ឆេយ្យ ហនន្តោ

---

១ ឧ. ករតោ ។ ២ ឧ. បាចយតោ សោចយតោ កិលមយតោ ផន្ទតោ ផន្ទាបយតោ បាណំ អតិមាបយតោ ។ ម. បាណមតិបាតាបយតោ ។

នោះបានដែរឬ បពិត្រព្រះអង្គដ៏ចំរើន កាលដែលខ្ញុំព្រះអង្គសួរយ៉ាងនេះហើយ គ្រូឈ្មោះបូរណកស្សប ឆ្លើយដូច្នេះនឹងខ្ញុំព្រះអង្គថា បពិត្រមហារាជ បុគ្គលធ្វើបាបដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យធ្វើ កាត់(នូវអវយវៈមានដៃជាដើម) របស់អ្នកដទៃដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យកាត់ បៀតបៀនគេដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យបៀតបៀន ធ្វើអ្នកដទៃឲ្យសោកសៅដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យធ្វើឲ្យគេសោកសៅ ធ្វើអ្នកដទៃឲ្យលំបាកដោយខ្លួនឯងឬប្រើអ្នកដទៃឲ្យធ្វើឲ្យគេលំបាក អន្ទះអន្ទែងដោយខ្លួនឯង ឬធ្វើគេឲ្យអន្ទះអន្ទែង សម្លាប់សត្វដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យសម្លាប់ កាន់យកនូវទ្រព្យដែលគេមិនបានឲ្យ កាត់នូវទីត(នៃផ្ទះ)ប្លន់នូវពួកអ្នកស្រុក ប្លន់យកទ្រព្យតែផ្ទះ ១ ឈរចាំក្បែរផ្លូវ (ដើម្បីដណ្ដើមយកទ្រព្យ) លួចប្រពន្ធនៃបុគ្គលដទៃ ពោលពាក្យកុហក ឈ្មោះថា មិនបានធ្វើបាបទេ មួយទៀតបើបុគ្គលណា ធ្វើនូវសត្វទាំងឡាយលើផែនដីនេះ ឲ្យមានគំនរសាច់តែមួយ ឲ្យមានពំនូកនៃសាច់តែមួយ ដោយគ្រឿងចក្រមានខ្នងកង់ដ៏មុតដូចជាកាំបិតកោរ បាបដែលមានអំពើនោះជាហេតុមិនមាន (ដល់បុគ្គលអ្នកធ្វើនោះ) ទេ អំពើបាបក៏មិនឲ្យផល (ដល់បុគ្គលនោះឡើយ) ទោះបីបុគ្គលឆ្លងទៅកាន់ត្រើយខាងស្ដាំនៃទន្លេគង្គា ហើយគប្បីសម្លាប់សត្វដោយខ្លួនឯង ឬប្រើអ្នក

ឃាតេន្តោ ឆិន្ទន្តោ ឆេទាបេន្តោ បចន្តោ បចាបេន្តោ(១) នត្ថិ តតោនិទានំ បាបំ នត្ថិ បាបស្ស អាគមោ ទក្ខិណញ្ចេបិ គង្គាយ តីរំ គច្ឆេយ្យ ទទន្តោ ទទាបេន្តោ(២) យជន្តោ យជាបេន្តោ នត្ថិ តតោនិទានំ បុញ្ញំ នត្ថិ បុញ្ញស្ស អាគមោ ទានេន ទមេន សំយមេន សច្ចវាចេន(៣) នត្ថិ តតោនិទានំ បុញ្ញំ នត្ថិ បុញ្ញស្ស អាគមោតិ ឥត្ថំ ខោ មេ ភន្តេ បូរណោ កស្សបោ សន្ទិដ្ឋិកំ សាមញ្ញផលំ បុដ្ឋោ សមានោ អកិរិយំ ព្យាកាសិ សេយ្យថាបិ ភន្តេ អម្ពំ វា បុដ្ឋោ លពុជំ ព្យាករេយ្យ លពុជំ វា បុដ្ឋោ អម្ពំ ព្យាករេយ្យ ឯវមេវ ខោ មេ ភន្តេ បូរណោ កស្សបោ សន្ទិដ្ឋិកំ សាមញ្ញផលំ បុដ្ឋោ សមានោ អកិរិយំ

១ ឱ. ឃាបេន្តោ ។ ២ ឱ. ម. ទាបេន្តោ ។ ៣ ឱ. ម. សច្ចវជ្ជេន ។

ដទៃឲ្យសម្លាប់ កាត់ (នូវអវយវៈមានដៃជាដើម) ដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យកាត់ បៀតបៀនគេ ដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យបៀតបៀន បាបដែលមានអំពើនោះជាហេតុ មិនមាន (ដល់បុគ្គលអ្នកធ្វើនោះ) ទេ អំពើបាបក៏មិនឲ្យផល (ដល់បុគ្គលនោះឡើយ) ទោះបីបុគ្គលធ្វើទៅកាន់ត្រើយខាងជើងនៃទន្លេគង្គា ហើយឲ្យទានដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យឲ្យ បូជាដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យបូជា បុណ្យដែលមានអំពើនោះជាហេតុ មិនមាន (ដល់បុគ្គលអ្នកធ្វើនោះ) ទេ អំពើបុណ្យមិនឲ្យផល (ដល់បុគ្គលនោះឡើយ) បុគ្គលធ្វើកុសលដោយឲ្យទាន ដោយទូន្មានឥន្ទ្រិយ ដោយសង្រួមកាយវាចា ដោយពោលពាក្យសច្ចៈ បុណ្យដែលមានអំពើនោះជាហេតុ មិនមាន (ដល់បុគ្គលអ្នកធ្វើនោះ) ទេ អំពើបុណ្យមិនឲ្យផល (ដល់បុគ្គលនោះឡើយ) បពិត្រព្រះអង្គដ៏ចំរើន គ្រូឈ្មោះបូរណកស្សប កាលដែលខ្ញុំព្រះអង្គ សួរនូវផលសមណប្បដិបត្តិដែលឃើញច្បាស់ ដោយខ្លួនឯង ដោយប្រការដូច្នេះហើយ ក៏បែរជាដោះស្រាយ ដោយអកិរិយវាទ (ពោលឃាត់អំពើបុណ្យបាប) បពិត្រព្រះអង្គដ៏ចំរើន ប្រៀបដូចបុគ្គលដែលគេសួរពីដើមស្វាយ បែរជាប្រាប់នូវដើមខ្នុរវិញ ឬគេសួរពីដើមខ្នុរ បែរជាប្រាប់នូវដើមស្វាយវិញ បពិត្រព្រះអង្គដ៏ចំរើន គ្រូឈ្មោះបូរណកស្សប កាលខ្ញុំព្រះអង្គសួរនូវផលនៃសមណប្បដិបត្តិដែល

ព្យាកាសិ តស្ស មយ្ហំ ភន្តេ ឯតទហោសិ កថំ ហិ នាម មាទិសោ សមណំ វា ព្រាហ្មណំ វា វិជិតេ វសន្តំ អបសាទេតព្វំ មញ្ញេយ្យាតិ សោ ខោ អហំ ភន្តេ បូរណស្ស កស្សបស្ស ភាសិតំ នេវ អភិនន្ទឹ នប្បដិក្កោសឹ អនភិនន្ទិត្វា អប្បដិក្កោសិត្វា អនត្តមនោ អនត្តមនវាចំ អនិច្ឆារេត្វា តមេវ វាចំ អនុគ្គណ្ហន្តោ អនិក្កុជ្ជេន្តោ ឧដ្ឋាយាសនា បក្កាមឹ ។

(៩៨) ឯកមិទាហំ ភន្តេ សមយំ យេន មក្ខលិ គោសាលោ តេនុបសង្កមឹ ឧបសង្កមិត្វា មក្ខលិនា គោសាលេន(១) សទ្ធឹ សម្មោទឹ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹ ឯកមន្តំ និសិន្នោ ខោ អហំ ភន្តេ មក្ខលឹ គោសាលំ ឯតទវោចំ យថា នុ ខោ ឥមានិ ភោ គោសាល បុថុសិប្បាយតនានិ ។ បេ ។ សក្កា នុ ខោ គោសាល ឯវមេវ ទិដ្ឋេ វ

---

១ ឱ មក្ខលិគោសាលេន ។

ឃើញច្បាស់ដោយខ្លួនឯងហើយ បែរជាដោះស្រាយ ដោយអកិរិយវាទទៅវិញ ក៏ដូច្នោះដែរ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្តីរិះគិតដូច្នេះថា បុគ្គលប្រហែលដូចជាអញ មិនសមបើទៅរាប់អានសមណៈព្រាហ្មណ៍ អ្នកនៅអាស្រ័យក្នុងដែន ដែលជាបុគ្គលគួរបៀតបៀនសោះ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនបានត្រេកអរ មិនបានឃាត់ហាម នូវភាសិតរបស់គ្រូឈ្មោះបូរណកស្សបឡើយ លុះខ្ញុំព្រះអង្គមិនបានត្រេកអរ មិនបានឃាត់ហាម មានសេចក្តីតូចចិត្ត តែមិនបានបញ្ចេញវាចាសំដែងនូវសេចក្តីតូចចិត្ត មិនបានកាន់តាម មិនបានយកចិត្តទុកដាក់នឹងវាចានោះទេ ហើយក៏ក្រោកចាកអាសនៈចៀសចេញទៅ ។

(៩៥) បពិត្រព្រះអង្គដ៏ចំរើន ក្នុងក្រុងរាជគ្រឹះនេះ សម័យមួយ ខ្ញុំព្រះអង្គចូលទៅរកគ្រូឈ្មោះមក្ខលិគោសាល លុះចូលទៅដល់ហើយក៏ពោលពាក្យពក់ទាក់សំណេះសំណាល ជាមួយនឹងគ្រូឈ្មោះមក្ខលិគោសាល លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹក ល្មមឲ្យកើតសេចក្តីស្និទ្ធស្នាលហើយ ក៏បានអង្គុយក្នុងទីសមគួរ បពិត្រព្រះអង្គដ៏ចំរើន លុះខ្ញុំព្រះអង្គអង្គុយក្នុងទីដ៏សមគួរហើយ ក៏ផ្តើមពាក្យសួរដូច្នេះទៅនឹងគ្រូឈ្មោះមក្ខលិគោសាលថា បពិត្រលោកគោសាលដ៏ចំរើន ដូចជាសិល្បៈសម្រាប់បង្កើតផលមានប្រមាណច្រើនទាំងនេះ ។ បេ ។ បពិត្រលោកគោសាល

ធម្មេ សន្ទិដ្ឋិកំ សាមញ្ញផលំ បញ្ញបេតុន្តិ ឯវំ វុត្តេ ភន្តេ
មក្ខលិ គោសាលោ មំ ឯតទវោច នត្ថិ មហារាជ ហេតុ
នត្ថិ បច្ចយោ សត្តានំ សំកិលេសាយ អហេតូ អប្បច្ច-
យា សត្តា សំកិលិស្សន្តិ នត្ថិ ហេតុ នត្ថិ បច្ចយោ
សត្តានំ វិសុទ្ធិយា អហេតូ អប្បច្ចយា សត្តា វិសុជ្ឈន្តិ
នត្ថិ អត្តការេ នត្ថិ បរការេ នត្ថិ បុរិសការេ នត្ថិ ពលំ
នត្ថិ វីរិយំ នត្ថិ បុរិសថាមោ នត្ថិ បុរិសបរក្កមោ សព្វេ

ដ៏ចំរើន លោកអាចនឹងបញ្ញត្តនូវផលនៃសាមញ្ញ្យដ៏ប្រាកដ ដែលឃើញច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ដូចយ៉ាងផលសិល្បៈនោះបានដែរឬ បពិត្រព្រះអង្គដ៏ចំរើន កាលដែលខ្ញុំព្រះអង្គសួរយ៉ាងនេះហើយ គ្រូឈ្មោះមក្ខលិគោសាល បានពោលពាក្យដូច្នេះមកនឹងខ្ញុំព្រះអង្គថា បពិត្រមហារាជ ហេតុបច្ច័យនាំឲ្យសៅហ្មង ដល់សត្វទាំងឡាយមិនមានទេ សត្វទាំងឡាយរមែងសៅហ្មងដោយឥតហេតុ ឥតបច្ច័យ ហេតុបច្ច័យនាំឲ្យបរិសុទ្ធដល់សត្វទាំងឡាយមិនមានឡើយ សត្វទាំងឡាយ រមែងបរិសុទ្ធដោយឥតហេតុ ឥតបច្ច័យ អំពើរបស់ខ្លួន(១)ក៏មិនមាន អំពើរបស់អ្នកដទៃ(២) ក៏មិនមាន អំពើរបស់បុរស(៣)ក៏មិនមាន កម្លាំងក៏មិនមាន ព្យាយាមក៏មិនមាន កម្លាំងរបស់បុរសក៏មិនមាន សេចក្តីសង្វាតរបស់បុរស(៤)ក៏មិនមាន

---

១ អដ្ឋកថា ថា សត្វទាំងឡាយបានអត្តភាពជាទេវតាក្តី ជាមារក្តី ជាព្រហ្មក្តី ជាសាវកពោធិក្តី ជាបច្ចេកពោធិក្តី ជាសព្វញ្ញុតញ្ញាណក្តី ដោយកុសលកម្មដែលខ្លួនបានធ្វើ ព្រោះថា អំពើរបស់ខ្លួន ។ ២ សត្វទាំងឡាយបាននូវគុណធម៌មានរូបល្អក្នុងអត្តភាពជាមនុស្សរហូតដល់ព្រះអរហត្តជាទីបំផុត ក៏ព្រោះអាស្រ័យនឹងពាក្យទូន្មានប្រៀនប្រដៅរបស់អ្នកដទៃព្រោះថា អំពើរបស់អ្នកដទៃ ។ ៣ សត្វទាំងឡាយបានសម្បត្តិដ៏ប្រសើរ ដោយអំពើនឹងព្យាយាមរបស់បុរស ឈ្មោះថា អំពើរបស់បុរស ។ ៤ ពាក្យទាំង ៤ នេះ ជាពាក្យផ្លាស់ប្តូរគ្នា មានសេចក្តីដូចគ្នាតែម្យ៉ាង។

សត្តា សព្វេ បាណា សព្វេ ភូតា សព្វេ ជីវា អវសា អពលា អវីរិយា និយតិសង្គតិភាវបរិណតា ឆស្វេវា-ភិជាតីសុ សុខញ្ច ទុក្ខញ្ច[1] បដិសំវេទេន្តិ ចុទ្ទស ខោ បនិមានិ មហាកប្បេ[2] យោនិប្បមុខសតស-ហស្សានិ សដ្ឋី ច សតានិ ឆ សតានិ[3] បញ្ច-ច កម្មុនោ សតានិ បញ្ច ច កម្មានិ តីណិ ច កម្មានិ កម្មេ ច ឧបឌ្ឍកម្មេ[4] ច ទ្វដ្ឋិបដិបទា

១ ឱ. ឆស្វេវាភិជាតីសុ សុខទុក្ខំ ។ ២ ម. ប. មហាកប្បានិ បាឋោ ន ទិស្សតិ ។
៣ ឱ. សដ្ឋិញ្ច សតានិ ឆ ច សតានិ ។ ៤ ម. អឌ្ឍកម្មេ ។

សត្វទាំងអស់ (មានសត្វឧដ្ឋ គោ លា ជាដើម) បាណៈទាំងអស់(១) ភូតទាំងអស់ (មានសត្វកើតក្នុងស្រោមស៊ុតជាដើម) ជីវៈគឺធញ្ញជាតិទាំងអស់ ឥតមានអំណាច ឥតមានកម្លាំង ឥតមានព្យាយាម(ក្នុងការធ្វើឲ្យសៅហ្មងឬបរិសុទ្ធ) មានសេចក្តីប្រែប្រួលដោយនិយតិនិងសង្គតិ និងសភាវៈ(២) តាំងនៅក្នុងអភិជាតិទាំង ៦ ហើយរមែងទទួលសុខនិងទុក្ខ បពិត្រមហារាជ ឯកំណើតដែលជាប្រធាន(៣) មានចំនួន ១ លាន ៤ សែន ៦ ពាន់ ៦ រយ ទាំងនេះក្តី កម្មទាំង ៥០០ ក្តី កម្មទាំង ៥ ក្តី កម្មទាំង ៣ ក្តី កម្មគឺកាយកម្មនិងវចីកម្មក្តី កម្មពាក់កណ្តាល គឺមនោកម្មក្តី បដិបទាទាំង ៦២ ក្តី

---

១ សត្វដែលមានឥន្ទ្រិយ ១ គឺរូបជីវិតិន្ទ្រិយ បានដល់អសញ្ញីសត្វ សត្វដែលមានឥន្ទ្រិយ ២ គឺចក្ខុន្ទ្រិយ ១ សោតិន្ទ្រិយ ១ បានដល់រូបព្រហ្ម ១៤ ជាន់ វៀរលែងអសញ្ញីព្រហ្មចេញ ។ ២ សេចក្តីជិតស្និទ្ធមិនបែកគ្នាយ ប្រៀបដូចចុងកែវមណី ដែលមិនប្រេះឆារព្រោះជា និយតិ ។ ការត្រាច់រង្គាត់ទៅក្នុងអភិជាតិទាំង ៦ ឈ្មោះថា សង្គតិ ។ ធម្មតាដែលកើតឡើងដូច ៗ គ្នា ឈ្មោះថា សភាវៈ ប្រៀបដូចបន្លាដែលស្រួចឯង ផ្លែក្រូចមានសណ្ឋានមូលដោយខ្លួនឯង សត្វម្រឹគបក្សីទាំងពួងមានរូបរាងវិចិត្រផ្សេង ៗ ដោយធម្មតាឯង យ៉ាងណាមិញ លោកទាំងអស់មានសេចក្តីប្រែប្រួលទៅជាភ្នក្នោះ ៗ មិនបាច់អាស្រ័យហេតុបច្ច័យឡើយ ប្រៀបដូចបន្លាជាដើម យ៉ាងនោះឯង ឈ្មោះថា សភាវៈ ។ ៣ មានកំណើត មនុស្ស តិរច្ឆាន ក្សត្រិយ៍ និងព្រាហ្មណ៍ ជាដើម ។

ទ្វដ្ឋន្តរកប្បា ឆឡាភិជាតិយោ អដ្ឋបុរិសភូមិយោ ឯកូន-

បញ្ញាស អាជីវកសតេ ឯកូនបញ្ញាស បរិព្វាជកសតេ

ឯកូនបញ្ញាស នាគវាសសតេ(១) វីសេ ឥន្ទ្រិយសតេ តឹ-

សេ និរយសតេ ឆត្តឹសរជោធាតុយោ សត្តសញ្ញីគព្ភា ស-

ត្តអសញ្ញីគព្ភា សត្តនិគណ្ឋិគព្ភា សត្តទេវា សត្តមនុស្សា

សត្តបិសាចា(២) សត្តសរា សត្តបវុដា សត្តបវុដសតានិ

---

១ ឱ ម. នាគាវាសសតេ ។ ២ ឱ. សត្តបេសាចា ។

អន្តរកប្ប[១]ទាំង៦២ក្តី អភិជាតិ[២]ទាំង ៦ បុរិសភូមិ[៣]ទាំង ៨ ពួកអាជីវកៈទាំង ១៤៩ ពួកបរិព្វាជកទាំង ១៤៩ លំនៅនៃនាគទាំង ១៤៩ ឥន្ទ្រិយទាំង ១២០ នរកទាំង១៣០ ធាតុដែលប្រកបដោយធុលី (មានខ្នងដៃខ្នងជើងជាដើម) ទាំង៣៦ពួក គភ៌នៃសត្វដែលមានសញ្ញា[៤]ទាំង៧ ពួកគភ៌ (នៃធញ្ញជាតិ) ដែលគ្មានសញ្ញា[៥]ទាំង៧ ពួកគភ៌នៃជាតិដែលដុះអំពីថ្នាំង (មានអំពៅជាដើម) ទាំង៧ ពួកទេវតាទាំង៧ ពួកមនុស្សទាំង៧ ពួកបិសាចទាំង ៧ ស្រះទាំង៧ រអាង្គទាំង៧ រអាង្គទាំង៧០០

---

១ អដ្ឋកថា ថា ក្នុងមហាកប្ប ១ មានអន្តរកប្ប ៦៤ តែគ្រូឈ្មោះមក្ខលិគោសាលមិនដឹងក្នុងហ្នឹងទេ បានជាពោលថា៖ ២ ។ ២ ឯអភិជាតិទាំង ៦ នោះ គឺកណ្ហាភិជាតិ (ជាតិខ្មៅ) បានដល់ព្រានម្រឹគព្រានបក្សីជាដើម១ នីលាភិជាតិ (ជាតិខៀវ) បានដល់ភិក្ខុដែលបួសក្នុងព្រះពុទ្ធសាសនា ១ លោហិតាភិជាតិ (ជាតិក្រហម) បានដល់ពួកនិគ្រន្ថ ១ ហលិទ្ទាភិជាតិ (ជាតិលឿងខ្ចីរមៀត) បានដល់ពួកអចេលកសាវ័ក ១ សុក្កាភិជាតិ (ជាតិស) បានដល់ពួកអាជីវក ១ បរមសុក្កាភិជាតិ (ជាតិសណាស់) បានដល់ជននានន្ទគោត្រ និងវច្ឆគោត្រជាដើម ១ ។ ៣ ឯបុរិសភូមិទាំង ៨ នោះ គឺមន្ទភូមិ (កាលដែលនៅល្ងង់ខ្លៅ) បានដល់ទារកដែលទើបប្រសូតមកបាន ៧ ថ្ងៃនៅល្ងង់វង្វេង ១ ខិឌ្ឌាភូមិ (កាលដែលមានល្បែង)បានដល់ទារកដែលមកអំពីទុគ្គតិយំស្រែកច្រើន ឬទារកដែលមកពីសុគតិ រលឹកឃើញសុគតិហើយសើចរីករាយសប្បាយច្រើន ១ បទវីមំសភូមិ (កាលទើបរៀនដើរ) បានដល់ទារកដែលទើបបេះកាន់ដៃមាតាបិតារៀនដើរ ១ ឧជុគតភូមិ (កាលដែលដើរត្រង់បាន) បានដល់ទារកដែលបេះដើររឹងប៉ឹងហើយ ១ សេក្ខភូមិ (កាលដែលសិក្សាសិល្បៈ) ១ សមណភូមិ (កាលដែលចេញបួស)១ ជិនភូមិ (កាលដែលរៀនសិល្បៈអំពីសំណាក់អាចារ្យចេះដឹងស្រេចហើយ)១ បន្នភូមិ (កាលបួសហើយត្រាច់ទៅបិណ្ឌបាត ឬប្រតិបត្តិធម៌ ឬកាស់គ្រាំគ្រា) ១ ។ ៤ សត្វដែលមានសញ្ញា ៧ នោះ គឺឧដ្ឋ ១ គោ ១ លា ១ ពពែ ១ សត្វចិញ្ចឹម ១ ម្រឹគ ១ ក្របី ១ ។ ៥ ធញ្ញជាតិ ៧ នោះ គឺស្រូវសាលី១ ស្រូវខ្សាយ១ ស្រូវដំណើប ១ ស្រងៃ ១ កន្ទុយដំរី ១ ស្លូយ ១ គែលលក ១ ។

សាមញ្ញផលសុត្តេ មក្ខលិវាទោ

សត្តបបាតា សត្តបបាតសតានិ សត្តសុបិនា សត្តសុបិ-នសតានិ ចុល្លាសីតិមហាកប្បិនោ(១) សតសហស្សានិ យានិ ពាលេ ច បណ្ឌិតេ ច សន្ធាវិត្វា សំសរិត្វា ទុក្ខស្សន្តំ ករិស្សន្តិ តត្ថ នត្ថិ ឥមិនាហំ សីលេន វា វត្តេន វា តបេន វា ព្រហ្មចរិយេន វា អបរិបក្កំ វា កម្មំ បរិបាចេស្សាមិ បរិបក្កំ វា កម្មំ ផុស្សា ផុស្សា(២) ព្យន្តិករិស្សាមីតិ ហេវំ នត្ថិ ទោណមិតេ សុខទុក្ខេ បរិយន្តកតេ សំសារេ នត្ថិ ហានវឌ្ឍនេ(៣) នត្ថិ ឧក្កំសាវក្កំសេ សេយ្យថាបិ នាម សុត្តគុឡេ ខិត្តេ និព្វេឋិយមានមេវ បលេតិ ឯវមេវ ពាលេ ច បណ្ឌិ-តេ ច សន្ធាវិត្វា សំសរិត្វា ទុក្ខស្សន្តំ ករិស្សន្តីតិ ឥត្ថំ

---

១ ឱ. ចុល្លាសីតិមហាកប្បុនោ ។ ២ ឱ. ម. ផុស្ស ផុស្ស ។ ៣ ឱ. ម. ហាយនវឌ្ឍនេ ។

ជ្រោះធំទាំង ៧ ជ្រោះតូចទាំង ៧០០ សុបិនធំទាំង ៧ សុបិនតូចទាំង ៧០០ ជនពាលក្តី ជនជាបណ្ឌិតក្តី អន្ទោលទៅ ត្រាច់រង្គាត់ទៅ (ក្នុងវដ្ត-សំសារ) អស់កាលចំនួន ៨ លានចុល្លមហាកប្បហើយនឹងធ្វើនូវទីបំផុតនៃទុក្ខបាន បុគ្គលកំណត់ទុកថា អាត្មាអញនឹងញ៉ាំងកម្មដែលមិនទាន់ចាស់ឲ្យចាស់ផង អាត្មាអញបានពាល់ត្រូវរឿយ ៗ នូវកម្មដែលចាស់ស្រាប់ហើយ ៗ ធ្វើឲ្យអស់ទៅផង ដោយសីលនេះក្តី ដោយវត្តនេះក្តី ដោយតបៈនេះក្តី ដោយព្រហ្មចរិយៈនេះក្តី ក្នុងកប្បទាំងឡាយនោះ មិនមានឡើយ សេចក្តីសុខទុក្ខដែលធ្វើឲ្យមានទីបំផុត ដូចគេវាល់របស់ (ឲ្យអស់ទៅ) ដោយទោណៈ មិនមានក្នុងសំសារវដ្ត ដោយប្រការយ៉ាងនេះឡើយ សេចក្តីសាបសូន្យ (នៃសំសាររបស់ជនជាបណ្ឌិត) នឹងសេចក្តីចំរើន (នៃសំសាររបស់ជនពាល) មិនមានឡើយ សេចក្តីល្អូតលាស់ឡើងនឹងសេចក្តីរេចរិល មិនមានឡើយ ប្រៀបដូចរមូរនៃអម្បោះ ដែលគេបោះចោលទៅ រសាយអស់ (ត្រឹមតែកំណត់អម្បោះប៉ុណ្ណោះ) យ៉ាងណាមិញ ជនពាលក្តី ជនជាបណ្ឌិតក្តី ដែលអន្ទោលទៅ ត្រាច់រង្គាត់ទៅ (ក្នុងសំសារ) (អស់កំណត់នេះហើយ) នឹងធ្វើនូវទីបំផុតនៃទុក្ខបានដូច្នោះឯង បពិត្រ

យោ មេ ភន្តេ មក្ខលិ គោសាលោ សន្ទិដ្ឋិកំ សាមញ្ញផលំ បុដ្ឋោ សមានោ សំសារសុទ្ធឹ ព្យាកាសិ សេយ្យថាបិ ភន្តេ អម្ពំ វា បុដ្ឋោ លពុជំ ព្យាករេយ្យ លពុជំ វា បុដ្ឋោ អម្ពំ ព្យាករេយ្យ ឯវមេវ ខោ មេ(១) ភន្តេ មក្ខលិ គោសាលោ សន្ទិដ្ឋិកំ សាមញ្ញផលំ បុដ្ឋោ សមានោ សំសារសុទ្ធឹ ព្យាកាសិ តស្ស មយ្ហំ ភន្តេ ឯតទហោសិ កថំ ហិ នាម មាទិសោ សមណំ វា ព្រាហ្មណំ វា វិជិតេ វសន្តំ អបសាទេតព្វំ មញ្ញេយ្យាតិ សោ ខោ អហំ ភន្តេ មក្ខលិស្ស គោសាលស្ស ភាសិតំ នេវ អភិនន្ទឹ នប្បដិក្កោសឹ អនភិនន្ទិត្វា អប្បដិក្កោសិត្វា អនត្តមនោ អនត្តមនវាចំ អនិច្ឆារេត្វា តមេវ វាចំ អនុគ្គណ្ហន្តោ អនិក្កុជ្ជេន្តោ(២) ឧដ្ឋាយាសនា បក្កាមឹ ។

---

១ ឱ. មេតិ បទំ ន ទិស្សតិ ។ ២ ឱ. អនិក្កុជ្ជន្តោ ។ ម. អនិក្កុជេន្តោ ។

ព្រះអង្គដ៏ចំរើន គ្រូឈ្មោះមក្ខលិគោសាល កាលខ្ញុំព្រះអង្គសួររកផលនៃសមណប្បដិបត្តិដែលឃើញច្បាស់ដោយខ្លួនឯង ដោយប្រការដូច្នេះហើយ ក៏បែរជាដោះស្រាយ នូវសេចក្តីបរិសុទ្ធិនៃសំសារទៅវិញ បពិត្រព្រះអង្គដ៏ចំរើន ប្រៀបដូចបុគ្គលដែលគេសួរពីដើមស្វាយ ក៏បែរជាប្រាប់នូវដើមខ្នុរសម្លវិញ ឬគេសួរពីដើមខ្នុរសម្ល បែរជាប្រាប់នូវដើមស្វាយវិញ បពិត្រព្រះអង្គដ៏ចំរើន គ្រូឈ្មោះមក្ខលិគោសាល កាលដែលខ្ញុំព្រះអង្គសួររកផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ហើយបែរជាដោះស្រាយនូវសេចក្តីបរិសុទ្ធិ នៃសំសារទៅវិញ ដូច្នោះឯង បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្តីរិះគិត ដូច្នេះថា បុគ្គលប្រហែលអញ មិនសមបើទៅគប់អានសមណៈឬព្រាហ្មណ៍ អ្នកនៅអាស្រ័យក្នុងដែន ដែលជាបុគ្គលគួរបៀតបៀនសោះ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនបានត្រេកអរ មិនបានឃាត់ហាមនូវភាសិត របស់គ្រូឈ្មោះមក្ខលិ-គោសាលឡើយ លុះខ្ញុំព្រះអង្គមិនបានត្រេកអរ មិនបានឃាត់ហាម ក៏មានសេចក្តីតូចចិត្ត តែមិនបានបញ្ចេញវាចា សំដែងនូវសេចក្តីតូចចិត្ត មិនបានកាន់តាម មិនបានយកចិត្តទុកដាក់នឹងវាចានោះទេ ហើយក៏ក្រោកចាកអាសនៈ ចៀសចេញទៅ ។

(៩៦) ឯកមិទាហំ ភន្តេ សមយំ យេន អជិតោ កេសកម្ពលោ[១] តេនុបសង្កមឹ ឧបសង្កមិត្វា អជិតេន កេសកម្ពលេន[២] សទ្ធឹ សម្មោទឹ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹ ឯកមន្តំ និសិន្នោ ខោ អហំ ភន្តេ អជិតំ កេសកម្ពលំ ឯតទវោចំ យថា នុ ខោ ឥមានិ ភោ អជិត បុថុសិប្បាយតនានិ ។ បេ ។ សក្កា នុ ខោ ភោ អជិត ឯវមេវ ទិដ្ឋេវ ធម្មេ សន្ទិដ្ឋិកំ សាមញ្ញផលំ បញ្ញបេតុន្តិ ឯវំ វុត្តេ ភន្តេ អជិតោ កេសកម្ពលោ មំ ឯតទវោច នត្ថិ មហារាជ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ

---

១ ឱ. កេសកម្ពលី ។ ២ ឱ. កេសកម្ពលិនា ។

## សាមញ្ញផលសូត្រ វាទៈរបស់គ្រូឈ្មោះអជិត

[៩៦] បពិត្រព្រះអង្គដ៏ចំរើន ក្នុងក្រុងរាជគ្រឹះនេះ សម័យមួយ ខ្ញុំព្រះអង្គចូលទៅរកគ្រូឈ្មោះអជិតកេសកម្ពល លុះចូលទៅដល់ហើយ ក៏ពោលពាក្យពក់ទាក់សំណេះសំណាល ជាមួយនឹងគ្រូឈ្មោះអជិតកេសកម្ពល លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹកល្ហុមឲ្យកើតសេចក្តីស្និទ្ធស្នាលហើយ ក៏បានអង្គុយក្នុងទីដ៏សមគួរ បពិត្រព្រះអង្គដ៏ចំរើន លុះខ្ញុំព្រះអង្គអង្គុយក្នុងទីដ៏សមគួរហើយ ក៏ផ្តើមពាក្យសួរដូច្នេះទៅនឹងគ្រូឈ្មោះអជិតកេសកម្ពលថា បពិត្រលោកអជិតដ៏ចំរើន ដូចជាសិល្បៈសម្រាប់បង្កើតផលមានប្រមាណច្រើនទាំងនេះ ។ បេ ។ បពិត្រលោកអជិតដ៏ចំរើន លោកម្ចាស់អាចនឹងបញ្ញត្តនូវផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ដូចយ៉ាងផលសិល្បៈនោះបានដែរឬ បពិត្រព្រះអង្គដ៏ចំរើ កាលដែលខ្ញុំព្រះអង្គសួរយ៉ាងនេះហើយ គ្រូឈ្មោះអជិត-កេសកម្ពល ក៏បានពោលពាក្យដូច្នេះ នឹងខ្ញុំព្រះអង្គថា បពិត្រមហារាជ ទានដែលបុគ្គលឲ្យហើយ មិនមានផល ការបូជាធំ មិនមានផល ការបូជាតូច(១) មិនមានផល ផលនឹងវិបាក(២)នៃកម្មដែលបុគ្គលធ្វើល្អនឹងធ្វើ

១ អដ្ឋកថា ថា គ្រឿងសក្ការៈដែលគេធ្វើដល់ភ្ញៀវ ។ ២ ផលដែលក្លាយមកលើសលុបហៅថា ផល ផលដែលប្រហែលនឹងកម្ម ដែលបុគ្គលធ្វើហើយ ហៅថា វិបាក ។

នត្ថិ អយំ លោកោ នត្ថិ បរលោកោ[១] នត្ថិ មាតា នត្ថិ បិតា នត្ថិ សត្តា ឱបបាតិកា នត្ថិ លោកេ សមណព្រាហ្មណា សមគ្គតា[២] សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តិ ចាតុម្មហាភូតិកោ អយំ បុរិសោ យទា កាលំ ករោតិ បឋវី បឋវីកាយំ អនុបេតិ អនុបគច្ឆតិ អាបោ អាបោកាយំ អនុបេតិ អនុបគច្ឆតិ តេជោ តេជោកាយំ អនុបេតិ អនុបគច្ឆតិ វាយោ វាយោកាយំ អនុបេតិ អនុបគច្ឆតិ អាកាសំ ឥន្ទ្រិយានិ សង្កមន្តិ អាសន្ទិបញ្ចមា បុរិសា តំ[៣] អាទាយ គច្ឆន្តិ យាវ អាឡាហនា បទានិ បញ្ញាយន្តិ[៤] កាបោតកានិ អដ្ឋីនិ ភវន្តិ ភស្សន្តា អាហុតិយោ

---

១ ឱ. បរោ លោកោ ។ ២ ឱ. សមគ្គតា សម្មគ្គតាតិបិ ទ្វេ បាឋា ទិស្សន្តិ ។ ៣ ឱ. ម. មតំ ។ ៤ ឱ. អាឡាហនា បទានិ បញ្ញាបេន្តិ ។

អាក្រក់ មិនមានឡើយ លោកនេះ(១)មិនមាន លោកខាងមុខ(២)មិនមាន ប្រតិបត្តិខុសឬត្រូវក្នុងមាតា មិនមានផល (បុណ្យបាប) ការប្រតិបត្តិខុសឬត្រូវក្នុងបិតា មិនមានផល (បុណ្យបាប) សត្វជាឧបបាតិកៈកំណើត មិនមាន សមណៈនិងព្រាហ្មណ៍ទាំងឡាយ ដែលមានសេចក្តីព្រមព្រៀងគ្នា ប្រតិបត្តិដោយប្រពៃ ធ្វើឲ្យជាក់ច្បាស់ ព្រោះត្រាស់ដឹងដោយខ្លួនឯង ហើយសំដែងនូវលោកនេះនិងលោកខាងមុខ ក៏មិនមានក្នុងលោកឡើយ បុរសនេះប្រកបដោយមហាភូតរូប ៤ លុះទទួលមរណកាលក្នុងវេលាណា បឋវីធាតុខាងក្នុង ក៏ទៅជាបឋវីធាតុខាងក្រៅ អាបោធាតុខាងក្នុង ក៏ទៅជាអាបោធាតុខាងក្រៅ តេជោធាតុខាងក្នុង ក៏ទៅជាតេជោធាតុខាងក្រៅ វាយោធាតុខាងក្នុង ក៏ទៅជាវាយោធាតុខាងក្រៅ ឥន្ទ្រិយ (ទាំង៦)ក៏រសាត់អណ្តែតទៅកាន់អាកាស ពួកបុរស ( ទាំង ៤នាក់ ) មានគ្រែជាគំរប់ ៥ សែងយកបុរសដែលស្លាប់ទៅនោះ ស្នាមជើង គឺគុណនិងទោសក៏ប្រាកដនៅកំណត់ត្រឹមឈាបនដ្ឋានប៉ុណ្ណោះ សល់នៅតែឆ្អឹង មានសម្បុរ (ប្រផេះ) ដូចស្លាបនៃសត្វព្រាប ឯគ្រឿងសក្ការបូជាមានផេះជាទីបំផុត ទាននេះពួក

---

១-២ អដ្ឋកថា ថា លោកនេះមិនមានផលសត្វដែលឋិតនៅក្នុងលោកខាងមុខ លោកខាងមុខមិនមានដល់សត្វដែលឋិតនៅក្នុងលោកនេះ សត្វទាំងឡាយកើតនៅក្នុងទីណា លុះច្យុតហើយក៏សូន្យទៅក្នុងទីនោះ មិនកើតទៀតឡើយ ។

ទត្តុបញ្ញត្តមិទំ ទានំ តេសំ តុច្ឆំ មុសា វិលាបោ យេ កេចិ អត្ថិកវាទំ វទន្តិ ពាលេ ច បណ្ឌិតេ ច កាយស្ស ភេទា ឧច្ឆិជ្ជន្តិ វិនស្សន្តិ ន ហោន្តិ បរំ មរណាតិ ឥត្ថំ ខោ មេ ភន្តេ អជិតោ កេសកម្ពលោ សន្ទិដ្ឋិកំ សាមញ្ញផលំ បុដ្ឋោ សមានោ ឧច្ឆេទំ ព្យាកាសិ[១] សេយ្យថាបិ ភន្តេ អម្ពំ វា បុដ្ឋោ លពុជំ ព្យាករេយ្យ លពុជំ វា បុដ្ឋោ អម្ពំ ព្យាករេយ្យ ឯវមេវ ខោ មេ ភន្តេ អជិតោ កេសកម្ពលោ សន្ទិដ្ឋិកំ សាមញ្ញផលំ បុដ្ឋោ សមានោ ឧច្ឆេទំ ព្យាកាសិ តស្ស មយ្ហំ ភន្តេ ឯតទហោសិ កថំ ហិ នាម មាទិសោ សមណំ វា ព្រាហ្មណំ វា វិជិតេ វសន្តំ អបសាទេតព្វំ មញ្ញេយ្យាតិ សោ ខោ អហំ ភន្តេ

១ ឱ. ឧច្ឆេទវាទំ វ្យាកាសិ ។

មនុស្សពាលក៏ទៅបានបញ្ញត្តទុកមកហើយ ជនទាំងឡាយណា ពោលពាក្យថា អំពើមានទានជាដើម មានផល ពាក្យរបស់ជនទាំងនោះ ជាពាក្យកុហកទទេ ជនពាលក្តី ជនជាបណ្ឌិតក្តី លុះបែកធ្លាយរាងកាយទៅរមែងដាច់សូន្យ បាត់ទៅ មិនកើតទៀត ខាងមុខអំពីសេចក្តីស្លាប់ឡើយ បពិត្រព្រះអង្គដ៏ចំរើន គ្រូឈ្មោះអជិតកេសកម្ពល កាលបើខ្ញុំព្រះអង្គសួររកផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ដោយប្រការដូច្នេះហើយ ក៏បែរជាដោះស្រាយដោយឧច្ឆេទវាទ ( ពោលថាសត្វស្លាប់ទៅសូន្យ ឥតមានកើតទៀត ) ទៅវិញ បពិត្រព្រះអង្គដ៏ចំរើន ប្រៀបដូចបុគ្គលដែលគេសួរពីដើមស្វាយ ក៏បែរជាប្រាប់នូវដើមខ្នុរសម្លវិញ ឬគេសួរពីដើមខ្នុរសម្ល ក៏បែរជាប្រាប់នូវដើមស្វាយវិញ បពិត្រព្រះអង្គដ៏ចំរើន គ្រូឈ្មោះអជិតកេសកម្ពល កាលដែលខ្ញុំព្រះអង្គសួររកផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ដោយប្រការដូច្នេះហើយ ក៏បែរជាដោះស្រាយដោយឧច្ឆេទវាទទៅវិញ ដូច្នោះឯង បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្តីរិះគិតយ៉ាងនេះថា បុគ្គលប្រហែលអញ មិនសមបើទៅគប់អានសមណៈឬព្រាហ្មណ៍ អ្នកនៅអាស្រ័យក្នុងដែន ដែលជាបុគ្គលគួរបៀតបៀនសោះ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំ

អជិតស្ស កេសកម្ពលស្ស ភាសិតំ នេវ អភិនន្ទឹ នប្បដិក្កោសឹ អនភិនន្ទិត្វា អប្បដិក្កោសិត្វា អនត្តមនោ អនត្តមនវាចំ អនិច្ឆារេត្វា តមេវ វាចំ អនុគ្គណ្ហន្តោ អនិក្កុជ្ជន្តោ ឧដ្ឋាយាសនា បក្កាមឹ ។

(៩៧) ឯកមិទាហំ ភន្តេ សមយំ យេន បកុធោ កច្ចាយនោ តេនុបសង្កមឹ ឧបសង្កមិត្វា បកុធេន កច្ចាយនេន សទ្ធឹ សម្មោទឹ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹ ឯកមន្តំ និសិន្នោ ខោ អហំ ភន្តេ បកុធំ កច្ចាយនំ ឯតទវោចំ យថា នុ ខោ ឥមានិ ភោ កច្ចាយន បុថុសិប្បាយតនានិ ។បេ។ សក្កា នុ ខោ ភោ កច្ចាយន ឯវមេវ ទិដ្ឋេវ ធម្មេ សន្ទិដ្ឋិកំ សាមញ្ញផលំ បញ្ញាបេតុន្តិ ឯវំ វុត្តេ ភន្តេ បកុធោ កច្ចាយនោ មំ ឯតទវោច សត្តិមេ មហារាជ

ព្រះអង្គមិនបានក្រេកអរ មិនបានឃាត់ហាមនូវភាសិតរបស់គ្រូឈ្មោះអ-ជិតកេសកម្ពលឡើយ លុះខ្ញុំព្រះអង្គមិនបានក្រេកអរ មិនបានឃាត់ហាម ក៏មានសេចក្តីតូចចិត្ត តែមិនបានបញ្ចេញវាចា សំដែងនូវសេចក្តីតូចចិត្ត មិនបានកាន់តាម មិនបានយកចិត្តទុកដាក់នឹងវាចានោះទេ ក៏ក្រោកចាកអាសនៈ ចៀសចេញទៅ ។

(៩៧) បពិត្រព្រះអង្គដ៏ចំរើន ក្នុងក្រុងរាជគ្រឹះនេះ សម័យមួយ ខ្ញុំព្រះអង្គចូលទៅរកគ្រូឈ្មោះបកុធកច្ចាយនៈ លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់ សំណេះសំណាលជាមួយនឹងគ្រូឈ្មោះបកុធកច្ចាយនៈ លុះបញ្ចប់នូវពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹកលម្មឲ្យកើតសេចក្តីស្និទ្ធស្នាលហើយ ក៏អង្គុយក្នុងទីដ៏សមគួរ បពិត្រព្រះអង្គដ៏ចំរើន លុះខ្ញុំព្រះអង្គអង្គុយទីដ៏សមគួរហើយ ក៏ផ្តើមពាក្យសួរដូច្នេះ ទៅនឹងគ្រូឈ្មោះបកុធកច្ចាយនៈថា បពិត្រលោកកច្ចាយនៈដ៏ចំរើន ដូចជាសិល្បៈសម្រាប់បង្កើតផលមានប្រមាណច្រើនទាំងនេះ ។បេ។ បពិត្រលោកកច្ចាយនៈដ៏ចំ-រើន លោកអាចនឹងបញ្ញត្តនូវផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ដូចយ៉ាងសិល្បៈនោះបានដែរឬ បពិត្រព្រះអង្គដ៏ចំរើន កាលបើខ្ញុំព្រះអង្គ សួរយ៉ាងនេះហើយ គ្រូឈ្មោះបកុធកច្ចាយនៈបានឆ្លើយពាក្យដូច្នេះ មកនឹងខ្ញុំព្រះអង្គថា បពិត្រមហារាជ កាយ គឺពួក

កាយា អកដា អកដវិធា អនិម្មិតា អនិម្មាតា វញ្ឈា កូ-ដដ្ឋា ឯសិកដ្ឋាយិដ្ឋិតា(១) តេ ន ឥញ្ជន្តិ ន វិបរិណាមន្តិ ន អញ្ញមញ្ញំ ព្យាពាធេន្តិ នាលំ អញ្ញមញ្ញស្ស សុខាយ វា ទុក្ខាយ វា សុខទុក្ខាយ វា កតមេ សត្ត បឋវិកា-យោ អាបោកាយោ តេជោកាយោ វាយោកាយោ សុខេ ទុក្ខេ ជីវេ សត្តមេ(២) ឥមេ សត្តកាយា អកដា អ-កដវិធា អនិម្មិតា អនិម្មាតា វញ្ឈា កូដដ្ឋា ឯសិ-កដ្ឋាយិដ្ឋិតា តេ ន ឥញ្ជន្តិ ន វិបរិណាមន្តិ ន អញ្ញមញ្ញំ ព្យាពាធេន្តិ នាលំ អញ្ញមញ្ញស្ស សុខាយ វា ទុក្ខាយ វា សុខទុក្ខាយ វា តត្ថ នត្ថិ ហន្តា វា ឃាតេតា វា សោតា វា សាវេតា វា វិញ្ញាតា វា វិញ្ញាបេតា វា ។ សោ-ហិ(៣) តិណ្ហេន សត្ថេន សីសំ ឆិន្ទតិ ន កោចិ កញ្ចិ ជីវិតា វោរោបេតិ សត្តន្នំយេវ កាយានំ អន្តរេន សត្ថ-មនុបតតីតិ(៤) ឥត្ថំ ខោ មេ ភន្តេ បកុធោ កច្ចាយនោ

១ ឯសិកដ្ឋាយិដ្ឋិកាតិបិ បាឋោ ។ ២ ឧ. ជីវសត្តមេ ។ ៣ ឧ, ម. សោ បិ ។
៤ ម. សត្តន្នំ ត្វេវ កាយានមន្តរេន សត្ថំ វិវរមនុបតតីតិ ។ ឧ. សត្ថវិវរំ អនុបតតីតិ ។

## សាមញ្ញផលសូត្រ វាទៈរបស់គ្រូឈ្មោះបកុធៈ

ទាំង ៧ នេះ គ្មាននរណាធ្វើកើត គ្មានវិធីធ្វើកើត គ្មាននរណានិម្មិតដោយឫទ្ធិបាន គ្មាននរណាសាងកើត ជាសភាវៈអា (គ្មានពូជតទៅទៀត) តាំងនៅដូចជាកំពូលភ្នំ ឋិតនៅមាំដូចជាសសរគោល កាយទាំងនោះមិនញាប់ញ័រ មិនប្រែប្រួល មិនបៀតបៀននូវគ្នានឹងគ្នា មិនអាចធ្វើគ្នានឹងគ្នាឲ្យបានសុខ ឬឲ្យបានទុក្ខ ឬទាំងសុខទាំងទុក្ខទេ ឯកាយ គឺពួកទាំង ៧ ដូចម្តេចខ្លះ គឺពួកធាតុដី ១ ពួកធាតុទឹក ១ ពួកធាតុភ្លើង ១ ពួកធាតុខ្យល់ ១ សេចក្តីសុខ ១ សេចក្តីទុក្ខ ១ ជីវិត ១ ជាគំរប់ ៧ កាយ គឺពួកទាំង ៧ នេះ គ្មាននរណាធ្វើកើត គ្មានវិធីធ្វើកើត គ្មាននរណានិម្មិតដោយឫទ្ធិបាន គ្មាននរណាសាងកើត ជាសភាវៈអា តាំងនៅដូចជាកំពូលភ្នំ ឋិតនៅមាំដូចជាសសរគោល កាយទាំងនោះមិនញាប់ញ័រ មិនប្រែប្រួល មិនបៀតបៀននូវគ្នានឹងគ្នា មិនអាចធ្វើគ្នានឹងគ្នាឲ្យបានសុខ ឬឲ្យបានទុក្ខ ឬទាំងសុខទាំងទុក្ខទេ បុគ្គលសម្លាប់ដោយខ្លួនឯងក្តី ប្រើគេឲ្យសម្លាប់ក្តី ស្លាប់ខ្លួនឯងក្តី ញុំាងគេឲ្យស្លាប់ក្តី ដឹងច្បាស់ខ្លួនឯងក្តី ញុំាងអ្នកដទៃឲ្យដឹងច្បាស់ក្តី មិនមានក្នុងកាយទាំងនោះឡើយ ទុកជាបុគ្គលនោះកាត់សីសៈដោយសស្ត្រាដ៏មុត ក៏ឈ្មោះថាគ្មានអ្នកណាផ្តាច់ផ្តិលអ្នកណាចាកជីវិតបាន ឯសស្ត្រាគ្រាន់តែចូលទៅតាមចន្លោះនៃកាយទាំង ៧ ប៉ុណ្ណោះឯង បពិត្រព្រះអង្គដ៏ចំរើន គ្រូឈ្មោះបកុធកច្ចាយនៈ

សន្ទិដ្ឋិកំ សាមញ្ញផលំ បុដ្ឋោ សមានោ អញ្ញេន អញ្ញំ ព្យាកាសិ សេយ្យថាបិ ភន្តេ អម្ពំ វា បុដ្ឋោ លពុជំ ព្យាករេយ្យ លពុជំ វា បុដ្ឋោ អម្ពំ ព្យាករេយ្យ ឯវមេវ ខោ មេ ភន្តេ បកុធោ កច្ចាយនោ សន្ទិដ្ឋិកំ សាមញ្ញផលំ បុដ្ឋោ សមានោ អញ្ញេន អញ្ញំ ព្យាកាសិ តស្ស មយ្ហំ ភន្តេ ឯតទហោសិ កថំ ហិ នាម មាទិសោ សមណំ វា ព្រាហ្មណំ វា វិជិតេ វសន្តំ អបសាទេតព្វំ មញ្ញេយ្យាតិ សោ ខោ អហំ ភន្តេ បកុធស្ស កច្ចាយនស្ស ភាសិតំ នេវ អភិនន្ទឹ នប្បដិក្កោសឹ អនភិនន្ទិត្វា អប្បដិក្កោសិត្វា អនត្តមនោ អនត្តមនវាចំ អនិច្ឆារេត្វា តមេវ វាចំ អនុគ្គណ្ហន្តោ អនិក្កុជ្ជន្តោ ឧដ្ឋាយាសនា បក្កាមឹ ។

(៩៨) ឯកមិទាហំ ភន្តេ សមយំ យេន និគណ្ឋោ នាដបុត្តោ តេនុបសង្កមឹ ឧបសង្កមិត្វា និគណ្ឋេន

កាលបើខ្ញុំព្រះអង្គសួរកេផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ដោយប្រការដូច្នេះហើយ ក៏បែរជាដោះស្រាយដោយរឿងដទៃផ្សេងទៅវិញ បពិត្រព្រះអង្គដ៏ចំរើន ប្រៀបដូចបុគ្គលដែលគេសួរពីដើមស្វាយ បែរជាប្រាប់នូវដើមខ្នុរសម្លវិញ ឬគេសួរពីដើមខ្នុរសម្ល បែរជាប្រាប់នូវដើមស្វាយវិញ បពិត្រព្រះអង្គដ៏ចំរើន គ្រូឈ្មោះបកុធកច្ចាយនៈ កាលដែលខ្ញុំព្រះអង្គសួរកេផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯងហើយ ក៏បែរជាដោះស្រាយដោយរឿងដទៃផ្សេងទៅវិញ ដូច្នោះឯង បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្ដីរិះគិតយ៉ាងនេះថា បុគ្គលប្រហែលអញ មិនសមបើទៅពប់អានសមណៈឬព្រាហ្មណ៍ អ្នកនៅអាស្រ័យក្នុងដែន ដែលជាបុគ្គលគួរបៀតបៀនសោះ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនបានត្រេកអរ មិនបានឃាត់ហាមនូវភាសិតរបស់គ្រូឈ្មោះបកុធកច្ចាយនៈឡើយ លុះខ្ញុំព្រះអង្គមិនបានត្រេកអរ មិនបានឃាត់ហាម ក៏មានសេចក្ដីតូចចិត្តដែរ តែមិនបានបញ្ចេញវាចាសំដែងនូវសេចក្ដីតូចចិត្ត មិនបានកាន់តាម មិនបានយកចិត្តទុកដាក់នឹងវាចានោះទេ ហើយក្រោកចាកអាសនៈ ចៀសចេញទៅ ។

(៩៨) បពិត្រព្រះអង្គដ៏ចំរើន ក្នុងក្រុងរាជគ្រឹះនេះ សម័យមួយ ខ្ញុំព្រះអង្គចូលទៅរកគ្រូឈ្មោះនិគណ្ឋនាដបុត្ត លុះចូលទៅដល់ហើយ ក៏ពោល

## សាមញ្ញផលសុត្តំ និគណ្ឋវាទោ

នាដបុត្តេន សទ្ធឹ សម្មោទឹ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹ ឯកមន្តំ និសិន្នោ ខោ អហំ ភន្តេ និគណ្ឋំ នាដបុត្តំ ឯតទវោចំ យថា នុ ខោ ឥមានិ ភោ អគ្គិវេស្សន បុថុសិប្បាយតនានិ ។បេ។ សក្កា នុ ខោ ភោ អគ្គិវេស្សន ឯវមេវ ទិដ្ឋេវ ធម្មេ សន្ទិដ្ឋិកំ សាមញ្ញផលំ បញ្ញបេតុន្តិ ឯវំ វុត្តេ ភន្តេ និគណ្ឋោ នាដបុត្តោ មំ ឯតទវោច ឥធ មហារាជ និគណ្ឋោ ចាតុយាមសំវរសំវុតោ ហោតិ កថញ្ច ខោ(១) មហារាជ និគណ្ឋោ ចាតុយាមសំវរសំវុតោ ហោតិ ឥធ មហារាជ និគណ្ឋោ សព្វវារិវារិតោ ច ហោតិ សព្វវារិយុត្តោ ច សព្វវារិធុតោ ច សព្វវារិផុដោ ច ឯវំ ខោ មហារាជ និគណ្ឋោ ចាតុយាមសំ-

---

១ ឱ. ម. ខោតិ ន ទិស្សតិ ។

ពាក្យពក់ទាក់សំណេះសំណាល ជាមួយនឹងគ្រូឈ្មោះនិគណ្ឋនាដបុត្ត លុះបញ្ចប់ពាក្យដែលគួររីករាយនឹងពាក្យដែលគួររលឹក ល្មមឲ្យកើតសេចក្ដីស្និទ្ធស្នាលហើយ ក៏អង្គុយក្នុងទីដ៏សមគួរ បពិត្រព្រះអង្គដ៏ចំរើន លុះខ្ញុំព្រះអង្គអង្គុយក្នុងទីដ៏សមគួរហើយបានផ្ដើមពាក្យសួរដូច្នេះនឹងគ្រូឈ្មោះនិគណ្ឋនាដបុត្តថា បពិត្រលោកអគ្គិវេស្សនៈដ៏ចំរើន ដូចជាសិល្បៈសម្រាប់បង្កើតផលមានប្រមាណច្រើនទាំងនេះ ៗបេៗ បពិត្រលោកអគ្គិវេស្សនៈដ៏ចំរើនលោកម្ចាស់អាចនឹងបញ្ញត្តនូវផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ដូចយ៉ាងផលសិល្បៈនេះបានដែរឬ បពិត្រព្រះអង្គដ៏ចំរើន កាលបើខ្ញុំព្រះអង្គសួរយ៉ាងនេះហើយ គ្រូឈ្មោះនិគណ្ឋនាដបុត្តឆ្លើយពាក្យដូច្នេះ មកនឹងខ្ញុំព្រះអង្គថា បពិត្រមហារាជ ក្នុងលោកនេះនិគ្រណ្ឋបានសង្រួមដោយការសង្រួម មាន ៤ ចំណែក បពិត្រមហារាជនិគ្រណ្ឋដែលបានសង្រួមដោយការសង្រួម មាន ៤ ចំណែក (នោះ) តើដូចម្ដេចខ្លះ បពិត្រមហារាជ និគ្រណ្ឋក្នុងលោកនេះ ឃាត់ហាមទឹកទាំងពួង(១) ១ ប្រកបដោយទឹកទាំងពួង(២) ១ កំចាត់បាបដោយទឹកទាំងពួង(៣) ១ ប្រោះព្រំដោយទឹកទាំងពួង(៤) ១ បពិត្រមហារាជ និគ្រណ្ឋ

---

១ អដ្ឋកថា ថា ហាមឃាត់ទឹកត្រជាក់គ្រប់មុខដោយសំគាល់ថា ក្នុងទឹកត្រជាក់មានសត្វ មិនគួរប្រើប្រាស់ឡើយ ។ ២ ប្រកបដោយការរាំងផ្លូវបាបទាំងពួង ។ ដីកាថា ប្រកបដោយការសង្រួមគ្រប់ប្រការ ។ ៣ កំចាត់បាប ដោយការរាំងផ្លូវបាបទាំងពួង ។ ៤ ប្រោះព្រំដោយការរាំងផ្លូវបាបទាំងពួង ( តាមន័យនៃអដ្ឋកថានិងដីកា ត្រង់ពាក្យថាទឹក ៗ ក្នុងខ ទី ២-៣-៤-នោះ ជាឈ្មោះនៃការរាំងផ្លូវបាប ។

វរសំវុតោ ហោតិ យតោ ខោ មហារាជ និគណ្ឋោ ឯវំ ចាតុយាមសំវរសំវុតោ ហោតិ អយំ វុច្ចតិ មហារាជ និគណ្ឋោ គតត្តោ ច យតត្តោ ច ឋិតត្តោ ចាតិ ឥត្ថំ ខោ មេ ភន្តេ និគណ្ឋោ នាដបុត្តោ សន្ទិដ្ឋិកំ សាមញ្ញផលំ បុដ្ឋោ សមានោ ចាតុយាមសំវរំ ព្យាកាសិ ។ សេយ្យថាបិ ភន្តេ អម្ពំ វា បុដ្ឋោ លពុជំ ព្យាករេយ្យ លពុជំ វា បុដ្ឋោ អម្ពំ ព្យាករេយ្យ ឯវមេវ ខោ មេ ភន្តេ និគណ្ឋោ នាដបុត្តោ សន្ទិដ្ឋិកំ សាមញ្ញផលំ បុដ្ឋោ សមានោ ចាតុយាមសំវរំ ព្យាកាសិ ។ តស្ស មយ្ហំ ភន្តេ ឯតទហោសិ កថំ ហិ នាម មាទិសោ សមណំ វា ព្រាហ្មណំ វា វិជិតេ វសន្តំ អបសាទេតព្វំ មញ្ញេយ្យាតិ ។ សោ ខោ អហំ ភន្តេ និគណ្ឋស្ស នាដបុត្តស្ស ភាសិតំ នេវ អភិនន្ទឹ នប្ប-

បានសង្រួម ដោយការសង្រួម មាន ៤ ចំណែកយ៉ាងនេះឯង បពិត្រមហារាជ កាលណា និគ្រណ្ឋបានសង្រួម ដោយការសង្រួម ៤ ចំណែកយ៉ាងនេះ បពិត្រមហារាជ និគ្រណ្ឋនេះ គេហៅថា អ្នកមានខ្លួនដល់នូវទីបំផុតផង មានខ្លួនសង្រួមហើយផង មានខ្លួននៅដោយល្អផង បពិត្រព្រះអង្គដ៏ចំរើន ឯគ្រូឈ្មោះនិគណ្ឋនាដបុត្ត កាលដែលខ្ញុំព្រះអង្គសួររកផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ ដោយខ្លួនឯង ដោយប្រការដូច្នេះហើយ ក៏បែរជាដោះស្រាយទៅរកការសង្រួមមាន ៤ ចំណែកទៅវិញ បពិត្រព្រះអង្គដ៏ចំរើន ប្រៀបដូចបុគ្គលដែលគេសួរពីដើមស្វាយ បែរជាប្រាប់នូវដើមខ្នុរសម្ងវិញ ឬគេសួរពីដើមខ្នុរសម្ង បែរជាប្រាប់នូវដើមស្វាយវិញ បពិត្រព្រះអង្គដ៏ចំរើន គ្រូឈ្មោះនិគណ្ឋនាដបុត្ត កាលដែលខ្ញុំព្រះអង្គសួររកផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ក៏បែរជាដោះស្រាយទៅរកការសង្រួមមាន ៤ ចំណែកទៅវិញ ដូច្នោះឯង បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្តីរិះគិតដូច្នេះថា បុគ្គលប្រហែលអញ មិនសមបើទៅកប់អានសមណៈ ឬព្រាហ្មណ៍ អ្នកនៅអាស្រ័យក្នុងដែន ដែលជាបុគ្គលគួរបៀតបៀនសោះ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនបានត្រេកអរ មិនបានឃាត់ហាមនូវភាសិតរបស់គ្រូឈ្មោះនិគណ្ឋនាដបុត្តឡើយ លុះខ្ញុំព្រះអង្គមិនបាន

ដិក្កោសឹ អនភិនន្ទិត្វា អប្បដិក្កោសិត្វា អនត្តមនោ អនត្តមនវាចំ អនិច្ឆារេត្វា តមេវ វាចំ អនុគ្គណ្ហន្តោ អនិក្កុជ្ជេន្តោ ឧដ្ឋាយាសនា បក្កាមឹ ។

(៩៨) ឯកមិទាហំ ភន្តេ សមយំ យេន សញ្ជយោ បេលដ្ឋបុត្តោ តេនុបសង្កមឹ ឧបសង្កមិត្វា សញ្ជយេន បេលដ្ឋបុត្តេន សទ្ធឹ សម្មោទឹ សម្មោទនីយំ កថំ សារា-ណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹ ឯកមន្តំ និសិន្នោ ខោ អហំ ភន្តេ សញ្ជយំ បេលដ្ឋបុត្តំ ឯតទវោចំ យ-ថា នុ ខោ ឥមានិ ភោ សញ្ជយ បុថុសិប្បាយតនា-និ ។ បេ ។ សក្កា នុ ខោ ភោ សញ្ជយ ឯវមេវ ទិដ្ឋេវ ធម្មេ សន្ទិដ្ឋិកំ សាមញ្ញផលំ បញ្ញបេតុន្តិ ឯវំ វុត្តេ ភន្តេ សញ្ជយោ បេលដ្ឋបុត្តោ មំ ឯតទវោច អត្ថិ បរោ លោកោតិ ឥតិ ចេ មំ បុច្ឆសិ អត្ថិ បរោ លោកោតិ ឥតិ ចេ មេ អស្ស អត្ថិ បរោ លោកោតិ ឥតិ តេ

ត្រេកអរ មិនបានឃាត់ហាម ក៏មានសេចក្តីតូចចិត្តដែរ តែមិនបានបញ្ចេញវាចា សំដែងនូវសេចក្តីតូចចិត្ត មិនបានកាន់តាម មិនបានយកចិត្តទុកដាក់នឹងវាចានោះទេ ហើយក្រោកចាកអាសនៈ ចៀសចេញទៅ ។

(៩៩) បពិត្រព្រះអង្គដ៏ចំរើន ក្នុងក្រុងរាជគ្រឹះនេះ សម័យមួយ ខ្ញុំព្រះអង្គចូលទៅរកគ្រូឈ្មោះសញ្ជ័យវេលដ្ឋបុត្ត លុះចូលទៅដល់ហើយ ក៏ពោលពាក្យរាក់ទាក់សំណេះសំណាល នឹងគ្រូឈ្មោះសញ្ជ័យវេលដ្ឋបុត្ត លុះបញ្ចប់នូវពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹក ល្មមឲ្យកើតសេចក្តីសិទ្ធស្នាលហើយ ក៏អង្គុយក្នុងទីដ៏សមគួរ បពិត្រព្រះអង្គដ៏ចំរើន លុះខ្ញុំព្រះអង្គអង្គុយក្នុងទីដ៏សមគួរហើយ បានផ្តើមពាក្យសួរដូច្នេះទៅនឹងគ្រូឈ្មោះសញ្ជ័យវេលដ្ឋបុត្តថា បពិត្រលោកសញ្ជ័យដ៏ចំរើន ដូចជាសិល្បៈសម្រាប់បង្កើតផលមានប្រមាណច្រើនទាំងនេះ ។បេ។ បពិត្រលោកសញ្ជ័យដ៏ចំរើន លោកអាចនឹងបញ្ញត្តផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្ន ដូចយ៉ាងផលសិល្បៈនោះបានដែរឬ បពិត្រព្រះអង្គដ៏ចំរើន កាលបើខ្ញុំព្រះអង្គសួរយ៉ាងនេះហើយ គ្រូឈ្មោះសញ្ជ័យវេលដ្ឋបុត្ត ឆ្លើយពាក្យដូច្នេះមកនឹងខ្ញុំព្រះអង្គថា បើមហាបពិត្រសួរអាត្មាថា លោកខាងមុខមានដែរឬ បើសេចក្តីយល់ឃើញរបស់អាត្មាថា លោកខាងមុខមាន អាត្មាគប្បីដោះស្រាយនូវហេតុនោះដល់ព្រះអង្គថា លោកខាងមុខមាន

នំ(១) ព្យាករេយ្យ ឯវន្តិបិ(២) មេ នោ តថាតិបិ មេ នោ អញ្ញថាតិបិ មេ នោ នោតិបិ មេ នោ នោ នោតិបិ មេ នោ នត្ថិ បរោ លោកោ អត្ថិ ច នត្ថិ ច បរោ លោកោ នេវ អត្ថិ ន នត្ថិ បរោ លោកោ អត្ថិ សត្តា ឱបបា-តិកា នត្ថិ សត្តា ឱបបាតិកា អត្ថិ ច នត្ថិ ច សត្តា ឱបបាតិកា នេវ អត្ថិ ន នត្ថិ សត្តា ឱបបាតិកា អត្ថិ សុកដទុក្កដានំ កម្មានំ ផលំ វិបាកោ ឥតិ ចេ មំ បុច្ឆសិ អត្ថិ សុកដទុក្កដានំ កម្មានំ ផលំ វិបាកោ ឥតិ ចេ មេ អស្ស អត្ថិ សុកដទុក្កដានំ កម្មានំ ផលំ វិបាកោ ឥតិ តេ នំ ព្យាករេយ្យំ នត្ថិ សុ-កដទុក្កដានំ កម្មានំ ផលំ វិបាកោ អត្ថិ ច នត្ថិ ច សុកដទុក្កដានំ កម្មានំ ផលំ វិបាកោ

---

១ គេនាតិបិ ទិស្សតិ ។ ២ ឱ. ឯវម្បិ ។

ឯសេចក្តីយល់ឃើញរបស់អាត្មាថា យ៉ាងនេះក៏មិនមែន(១) សេចក្តីយល់ឃើញរបស់អាត្មាថា យ៉ាងនោះក៏មិនមែន(២) សេចក្តីយល់ឃើញរបស់អាត្មាថា យ៉ាងដទៃក៏មិនមែន(៣) សេចក្តីយល់ឃើញរបស់អាត្មាថាមិនមែនក៏ទេ(៤) សេចក្តីយល់ឃើញរបស់អាត្មាថា មិនមែនទេ ក៏មិនមែនដែរ(៥) (សេចក្តីយល់ឃើញរបស់អាត្មាថា) លោកខាងមុខមិនមាន លោកខាងមុខមានខ្លះ មិនមានខ្លះ លោកខាងមុខមានក៏មិនមែន មិនមានក៏មិនមែន ពួកសត្វជាឧបបាតិកៈមាន ពួកសត្វជាឧបបាតិកៈមិនមាន ពួកសត្វជាឧបបាតិកៈមានខ្លះមិនមានខ្លះ ពួកសត្វជាឧបបាតិកៈមានក៏មិនមែន មិនមានក៏មិនមែន បើមហារាជសួរអាត្មាថា ផលវិបាកនៃកម្ម ដែលបុគ្គលធ្វើល្អនិងធ្វើអាក្រក់ មានដែរឬ បើសេចក្តីយល់ឃើញរបស់អាត្មាថា ផលវិបាកនៃកម្ម ដែលបុគ្គលធ្វើល្អនិងធ្វើអាក្រក់មាន អាត្មាគប្បីដោះស្រាយនូវហេតុនោះ ដល់ព្រះអង្គថា ផលវិបាកនៃកម្ម ដែលបុគ្គលធ្វើល្អនិងធ្វើអាក្រក់មាន ផលវិបាកនៃកម្ម ដែលបុគ្គលធ្វើល្អនិងធ្វើអាក្រក់ មិនមាន ផលវិបាកនៃកម្ម

---

១ អដ្ឋកថា ថា ពាក្យថាយ៉ាងនេះក៏មិនមែន ជាពាក្យឃាត់អាការណា ៗ ដែលមិនមានទីកំណត់ ។ ២ ពាក្យថាយ៉ាងនោះក៏មិនមែន ជាពាក្យឃាត់សស្សតវាទ គឺពាក្យថា លោកទៀង ។ ៣ ពាក្យថាយ៉ាងដទៃក៏មិនមែន ជាពាក្យឃាត់ឯកច្ចសស្សតឯកច្ចអសស្សតវាទ គឺពាក្យថាលោកទៀងខ្លះមិនទៀងខ្លះ ។ ៤ ពាក្យថាមិនមែនក៏ទេ ជាពាក្យឃាត់ឧច្ឆេទវាទ គឺពាក្យថាសត្វស្លាប់ទៅសូន្យមិនកើតទៀត ។ ៥ ពាក្យថាមិនមានក៏ទេក៏មិនមែនដែរ ជាពាក្យឃាត់តក្កីវាទ គឺពាក្យថា សត្វស្លាប់ទៅមិនមែនជាមានមិនមែនជាគ្មាន ។

នេវ អត្ថិ ន នត្ថិ សុកដទុក្កដានំ កម្មានំ ផលំ វិបាកោ ហោតិ តថាគតោ បរម្មរណា ន ហោតិ តថាគតោ បរម្មរណា ហោតិ ច ន ច ហោតិ[១] តថាគតោ បរម្មរណា នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ ឥតិ ចេ មំ បុច្ឆសិ នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ ឥតិ ចេ មេ អស្ស នេវ ហោតិ ន ន ហោតិ តថាគតោ បរម្មរណាតិ ឥតិ តេ នំ ព្យាករេយ្យំ ឯវម្បិ មេ នោ តថាតិបិ មេ នោ អញ្ញថាតិបិ មេ នោ នោតិបិ មេ នោ នោ នោតិបិ មេ នោតិ ឥត្ថំ ខោ មេ ភន្តេ សញ្ជយោ ពេលដ្ឋបុត្តោ សន្ទិដ្ឋិកំ សាមញ្ញផលំ បុដ្ឋោ សមានោ វិក្ខេបំ ព្យាកាសិ សេយ្យថាបិ ភន្តេ អម្ពំ វា បុដ្ឋោ លពុជំ ព្យាករេយ្យ លពុជំ វា បុដ្ឋោ

---

១ ឱ. ម. ន ហោតិ ច ។

សាមញ្ញផលសូត្រ វាទៈរបស់គ្រូឈ្មោះសញ្ជ័យ

ដែលបុគ្គលធ្វើល្អនឹងធ្វើអាក្រក់មានខ្លះមិនមានខ្លះ ផលវិបាកនៃកម្ម ដែលបុគ្គលធ្វើល្អនឹងធ្វើអាក្រក់ មានក៏មិនមែន មិនមានក៏មិនមែន បើមហារាជសួរអាត្មាថា ខាងមុខអំពីសេចក្តីស្លាប់ សត្វកើតទៀត ខាងមុខអំពីសេចក្តីស្លាប់ សត្វមិនកើតទៀត ខាងមុខអំពីសេចក្តីស្លាប់ សត្វកើតទៀតខ្លះមិនកើតទៀតខ្លះ ខាងមុខអំពីសេចក្តីស្លាប់ សត្វកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែនដូច្នេះឬ បើសេចក្តីយល់ឃើញរបស់អាត្មាថា ខាងមុខអំពីសេចក្តីស្លាប់ សត្វកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន អាត្មាគប្បីដោះស្រាយនូវហេតុនោះ ដល់ព្រះអង្គថា ខាងមុខអំពីសេចក្តីស្លាប់ សត្វកើតទៀតក៏មិនមែន មិនកើតទៀតក៏មិនមែន សេចក្តីយល់ឃើញរបស់អាត្មាថាយ៉ាងនេះ ក៏មិនមែន សេចក្តីយល់ឃើញរបស់អាត្មាថា យ៉ាងនោះក៏មិនមែន សេចក្តីយល់ឃើញរបស់អាត្មាថាយ៉ាងដទៃក៏មិនមែន សេចក្តីយល់ឃើញរបស់អាត្មាថា មិនមែនក៏ទេ សេចក្តីយល់ឃើញរបស់អាត្មាថា មិនមែនទេ ក៏មិនមែនដែរ បពិត្រព្រះអង្គដ៏ចំរើន គ្រូឈ្មោះសញ្ជយវេលដ្ឋបុត្ត កាលបើខ្ញុំព្រះអង្គសួររកផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ដោយប្រការដូច្នេះហើយ ក៏បែរជាដោះស្រាយបន្លែបន្លប់ទៅវិញ បពិត្រព្រះអង្គដ៏ចំរើន ប្រៀបដូចបុគ្គលដែលគេសួរពីដើមស្វាយ បែរជាប្រាប់នូវដើមខ្នុរសម្លវិញ ឬគេសួរពីដើមខ្នុរសម្ល

អម្ពំ ព្យាករេយ្យ ឯវមេវ ខោ មេ ភន្តេ សញ្ចយោ ពេលដ្ឋបុត្តោ សន្ទិដ្ឋិកំ សាមញ្ញផលំ បុដ្ឋោ សមានោ វិក្ខេបំ ព្យាកាសិ តស្ស មយ្ហំ ភន្តេ ឯតទហោសិ អយញ្ច ឥមេសំ សមណព្រាហ្មណានំ សព្ពពាលោ សព្ពមូឡ្ហោ កថំ ហិ នាម សន្ទិដ្ឋិកំ សាមញ្ញផលំ បុដ្ឋោ សមានោ វិក្ខេបំ ព្យាករិស្សតីតិ តស្ស មយ្ហំ ភន្តេ ឯតទហោសិ កថញ្ហិ នាម មាទិសោ សមណំ វា ព្រាហ្មណំ វា វិជិតេ វសន្តំ អបសាទេតព្ពំ មញ្ញេយ្យាតិ សោ ខោ អហំ ភន្តេ សញ្ចយស្ស ពេលដ្ឋបុត្តស្ស ភាសិតំ នេវ អភិនន្ទឹ នប្បដិក្កោសឹ អនភិនន្ទិត្វា អប្បដិក្កោសិត្វា អនត្តមនោ អនត្តមនវាចំ អនិច្ឆារេត្វា តមេវ វាចំ អនុគ្គណ្ហន្តោ អនិក្កុជ្ជេន្តោ ឧដ្ឋាយាសនា បក្កាមឹ ។

បែរជាប្រាប់នូវដើមស្វាយវិញ បពិត្រព្រះអង្គដ៏ចំរើន គ្រូឈ្មោះសញ្ជយ-វេលដ្ឋបុត្ត កាលដែលខ្ញុំព្រះអង្គសួររកផល នៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ក៏បែរជាដោះស្រាយបន្ទែបន្ទប់ទៅវិញ ដូច្នោះឯង បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្ដីត្រិះរិះដូច្នេះថា គ្រូឈ្មោះសញ្ជយវេលដ្ឋបុត្តនេះឯង ល្ងង់ជ្រុល វង្វេងជ្រុល ជាងសមណៈនឹងព្រាហ្មណ៍ទាំងឡាយពួកនេះ កាលបើអញសួរត្រង់ផល នៃសមណប្ប-ដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯងហើយ មិនសមបើទៅដោះស្រាយបន្ទែបន្ទប់សោះ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមានសេចក្ដីត្រិះរិះដូច្នេះថា បុគ្គលប្រហែលអញ មិនសមបើទៅកប់អានសមណៈឬព្រាហ្មណ៍អ្នកនៅអាស្រ័យក្នុងដែន ដែលជាបុគ្គលគួរបៀតបៀនសោះ បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គមិនបានត្រេកអរ មិនបានឃាត់ហាមនូវភាសិតរបស់គ្រូឈ្មោះសញ្ជយវេលដ្ឋបុត្តឡើយ លុះខ្ញុំព្រះអង្គមិនបានត្រេកអរ មិនបានឃាត់ហាម ក៏មានសេចក្ដីតូចចិត្តដែរ តែមិនបានបញ្ចេញវាចាសំដែងនូវសេចក្ដីតូចចិត្ត មិនបានកាន់តាម មិនបានយកចិត្តទុកដាក់នឹងវាចានោះទេ ហើយក្រោកចាកអាសនៈ ចៀសចេញទៅ ។

(១០០) សោហំ ភន្តេ ភគវន្តំ បុច្ឆាមិ យថា នុ ខោ ឥមានិ ភន្តេ បុថុសិប្បាយតនានិ សេយ្យថីទំ ហត្ថារោហា អស្សារោហា រថិកា ធនុគ្គហា ចេលកា ចលកា បិណ្ឌទាយិកា ឧគ្គា រាជបុត្តា បក្ខន្ទិនោ មហានាគា សូរា ចម្មយោធិនោ ទាសកបុត្តា អាឡារិកា កប្បកា ន្ហាបកា សូទា មាលាការា រជកា បេសការា នឡការា កុម្ភការា គណកា មុទ្ទិកា យានិ វា បនញ្ញានិបិ ឯវំគតានិ បុថុសិប្បាយតនានិ តេ ទិដ្ឋេវ ធម្មេ សន្ទិដ្ឋិកំ សិប្បផលំ ឧបជីវន្តិ តេ តេន អត្តានំ សុខេន្តិ បីណេន្តិ មាតាបិតរោ សុខេន្តិ បីណេន្តិ បុត្តទារំ

## សាមញ្ញផលសូត្រ ការសួរអំពីផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង

(១០០) បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គសូមសួរចំពោះព្រះមានព្រះភាគ សូមទ្រង់ព្រះមេត្តាប្រោស ដូចជាសិល្បៈសម្រាប់បង្កើតផលមានប្រមាណច្រើនទាំងនេះ បានដល់សិល្បៈរបស់បុគ្គលនោះៗ គឺសិល្បៈរបស់បុគ្គលអ្នកកាន់ការខាងដំរី អ្នកកាន់ការខាងសេះ អ្នកកាន់ការខាងរថ ពួកខាន់ធ្នូ ពួកអ្នកកាន់ទង់ជ័យ (មុខ) ពួកអ្នកចាត់ទ័ព ពួកអ្នកបញ្ជូនស្បៀង ពួកព្រះរាជបុត្តអ្នកពុះពារ ( លុកចូលក្នុងសង្គ្រាម ) ពួកអ្នកស្ទុះចូលទៅក្នុងសង្គ្រាម (អ្នកយកអាសា) ពួកយោធាអ្នកអង់អាច ពួកសេនាអ្នកក្លៀវក្លា ពួកយោធាអ្នកពាក់អាវក្រោះ ពួកកូននៃជនជាទាសៈ ( ដែលជាទីស្រឡាញ់នៃចៅហ្វាយនាយ) ពួកអ្នកធ្វើនំ ពួកជាងកោរកាត់ ពួកអ្នកផ្ងូតទឹក ពួកអ្នកធ្វើអាហារ ពួកជាងក្រងផ្កា ពួកជាងជ្រលក់ ពួកជាងតម្បាញ ពួកជាងត្បាញផែង ពួកស្មូនឆ្នាំង ពួកអ្នកចេះលេខនព្វន្ធ ពួកអ្នកចេះរាប់ដោយម្រាមដៃទទេ ពុំនោះសោត សិល្បៈសម្រាប់បង្កើតផលមានប្រមាណច្រើនឯណានីមួយដទៃទៀត ដែលមានបែបយ៉ាងនេះក្តី បុគ្គលទាំងនោះ រមែងចិញ្ចឹមជីវិតអាស្រ័យនូវផលរបស់សិល្បៈ ដែលឃើញច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្ន បុគ្គលទាំងនោះ រមែងធ្វើនូវខ្លួនឲ្យដល់នូវសេចក្តីសុខឲ្យពេញលេញ (ដោយកម្លាំងកាយកម្លាំងប្រាជ្ញា) រមែងធ្វើមាតាបិតាឲ្យដល់នូវសេចក្តីសុខ ឲ្យពេញលេញ រមែងធ្វើនូវកូននិងប្រពន្ធឲ្យដល់

សុខេន្តិ បិណេន្តិ មិត្តាមច្ចេ សុខេន្តិ បិណេន្តិ សមណ-
ព្រាហ្មណេសុ ឧទ្ធគ្គិកំ ទក្ខិណំ បតិដ្ឋាបេន្តិ សោវគ្គិកំ
សុខវិបាកំ សគ្គសំវត្តនិកំ សក្កា នុ ខោ ភន្តេ ឯវ-
មេវ ទិដ្ឋេវ ធម្មេ សន្ទិដ្ឋិកំ សាមញ្ញផលំ បញ្ញាបេតុន្តិ ។
សក្កា(១) មហារាជ តេនហិ មហារាជ តញ្ញេវេត្ថ បដិ-
បុច្ឆិស្សាមិ យថា តេ ខមេយ្យ តថា នំ(២) ព្យាករេយ្យាសិ
តំ កឹ មញ្ញសិ មហារាជ ឥធ តេ អស្ស បុរិសោ ទាសោ
កម្មការោ បុព្វុដ្ឋាយី បច្ឆានិបាតី កឹការបដិស្សាវី
មនាបចារី បិយវាទី មុខុល្លោកិកោ តស្ស ឯវមស្ស

---
១ ឱ. សក្កា នុ ខោ ។ ២ ឱ. នំ ។

នូវសេចក្ដីសុខឲ្យពេញលេញ រមែងធ្វើមិត្តអាមាត្យឲ្យដល់នូវសេចក្ដីសុខឲ្យពេញលេញ រមែងញុំាងទក្ខិណាទាន ដែលមានផលដ៏ខ្ពស់ ជាទានគួរដល់កិរិយាកើតក្នុងឋានសួគ៌ ជាទានមានផលនាំមកនូវសេចក្ដីសុខ ជាទានញុំាងផលទាំង ១០ ដ៏ប្រសើរ ឲ្យប្រព្រឹត្តទៅដោយល្អ ឲ្យតម្កល់នៅក្នុងសមណៈនិងព្រាហ្មណ៍ទាំងឡាយ ដោយសិល្បៈនោះ បពិត្រព្រះអង្គដ៏ចំរើន ព្រះអង្គអាចនឹងបញ្ញត្ត នូវផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ដូចយ៉ាងផលសិល្បៈនោះបានដែរឬ ។ ព្រះអង្គទ្រង់ត្រាស់ថា បពិត្រមហារាជ តថាគតអាច (បញ្ញត្តបាន) បពិត្រមហារាជ បើដូច្នោះ តថាគតសូមសួរមហារាជ ក្នុងហេតុនោះវិញ មហារាជគាប់ព្រះរាជហឫទ័យយ៉ាងណា គប្បីដោះស្រាយនូវប្រស្នានោះយ៉ាងនោះចុះ ។ បពិត្រមហារាជ ចុះព្រះអង្គសំគាល់នូវហេតុនោះដូចម្ដេច ក្នុងលោកនេះ (បើ) មហារាជមានបុរសជាខ្ញុំបម្រើ អ្នកធ្វើរាជការ ជាអ្នកក្រោកឡើងមុន(១)និងដេកក្រោយ ជាអ្នកទទួលស្ដាប់ក្នុងកិច្ចការឯណានីមួយ ជាអ្នកប្រព្រឹត្តធ្វើនូវអំពើជាទីគាប់ចិត្ត ជាអ្នកពោលនូវពាក្យជាទីស្រឡាញ់ ជាអ្នកបង្ហាញមុខ (ម្ចាស់) បុរសនោះមានសេចក្ដីត្រិះរិះយ៉ាងនេះ

---

១ អដ្ឋកថា ថា បុរសជាខ្ញុំបម្រើបានឃើញម្ចាស់ មកអំពីចម្ងាយរមែងក្រោកឡើងមុន ដើម្បីទទួលដំណើរហើយក្រាលអាសនៈតាំងធ្វើនូវកិច្ច ដែលគួរធ្វើមានទឹកសម្រាប់លាងជើងជាដើមរួចទើបដេកក្រោយ ។

សាមញ្ញផលសូត្រ ការទ្រង់សំដែងផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង

ថា អើហ្ន៎ ហេតុអស្ចារ្យពេកណាស់ អើហ្ន៎ ហេតុចម្លែកពេកណាស់ នេះជាគតិរបស់បុណ្យ នេះជាវិបាករបស់បុណ្យ ព្រោះថាព្រះបាទអជាតសត្តុវេទេហិបុត្តជាធំក្នុងដែនមគធៈនេះ ក៏ជាមនុស្ស ឯអាត្មាអញសោតក៏ជាមនុស្សដែរ ប៉ុន្តែព្រះបាទអជាតសត្តុវេទេហិបុត្ត ជាធំក្នុងដែនមគធៈនេះ ទ្រង់ឆ្អែតស្កប់ស្កល់ដោយកាមគុណទាំង ៥ មានគេបម្រើហាក់ដូចជាទេវតា ឯអាត្មាអញជាខ្ញុំបម្រើ អ្នកធ្វើពលការ ជាអ្នកក្រោកឡើងមុន ដេកក្រោយ ជាអ្នកទទួលស្តាប់ ក្នុងកិច្ចការនីមួយ ជាអ្នកប្រព្រឹត្តនូវអំពើជាទីគាប់ចិត្ត ជាអ្នកពោលនូវពាក្យជាទីស្រឡាញ់ ជាអ្នកបង្ហាញមុខ (ម្ចាស់) អាត្មាអញគួរធ្វើបុណ្យ ដូចជាបុណ្យព្រះរាជានោះ បើដូច្នេះ មានតែអាត្មាអញកោរសក់ និងពុកមាត់ពុកចង្កាចេញ ហើយស្លៀកដណ្តប់សំពត់កាសាយៈទាំងឡាយ ចេញចាកផ្ទះហើយចូលទៅកាន់ផ្នួស ។ សម័យខាងក្រោយមក បុរសនោះក៏កោរសក់និងពុកមាត់ពុកចង្កាចេញ ហើយស្លៀកដណ្តប់សំពត់កាសាយៈទាំងឡាយចេញចាកផ្ទះហើយចូលទៅកាន់ផ្នួស ។ លុះបុរសនោះ បានបួសយ៉ាងនេះហើយ ក៏សង្រួមកាយ សង្រួមវាចា សង្រួមចិត្តគ្រប់ឥរិយាបថ សន្តោសដោយគ្រឿងបរិភោគនិងគ្រឿងស្លៀកដណ្តប់ដ៏ឧត្តម ត្រេកអរចំពោះទីស្ងាត់ ៗ មានបុរស ១ ពួកទៀត ក្រាបទូល

## សាមញ្ញផលសុត្តេ សន្ទិដ្ឋិកសាមញ្ញផលទេសនា

អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ បុញ្ញានំ គតិ បុញ្ញានំ វិបាកោ អយំ ហិ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ មនុស្សោ អហំបិ មនុស្សោ អយំ ហិ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គិភូតោ បរិចារេតិ ទេវោ មញ្ញេ អហំ បនម្ហិស្ស[១] ទាសោ កម្មករោ បុព្វុដ្ឋាយី បច្ឆានិបាតី កឹការបដិស្សាវី មនាបចារី បិយវាទី មុខុល្លោកិកោ[២] សោ វតស្សាហំ បុញ្ញានិ ករេយ្យំ យន្នូនាហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យន្តិ ។ សោ អបរេន សមយេន កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យ ។ សោ ឯវំ បព្វជិតោ សមានោ កាយេន សំវុតោ វិហរេយ្យ វាចាយ សំវុតោ វិហរេយ្យ មនសា សំវុតោ វិហរេយ្យ ឃាសច្ឆាទនបរមតាយ សន្តុដ្ឋោ អភិរតោ បវិវេកេ ។ តញ្ចេតេ[៣] បុរិសា ឯវមារោចេយ្យុំ

---

១ អហំ បនម្ហស្សាតិបិ បាឋោ ។ ២ ឱ មុខុល្លោកកោ ។ ៣ ឱ ម. តំ ចេ តេ ។

យគ្ឃេ ទេវ ជានេយ្យាសិ យោ តេ សោ(១) បុរិសោ ទាសោ កម្មករោ បុព្វុដ្ឋាយី បច្ឆានិបាតី កិំការប្បដិស្សាវី មនាបចារី បិយវាទី មុខុល្លោកិកោ សោ ទេវ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតោ សោ ឯវំ បព្វជិតោ សមានោ កាយេន សំវុតោ វិហរតិ វាចាយ សំវុតោ វិហរតិ មនសា សំវុតោ វិហរតិ ឃាសច្ឆាទនបរមតាយ សន្តុដ្ឋោ អភិរតោ បវិវេកេតិ ។ អបិ នុ ត្វំ ឯវំ ជានេយ្យាសិ ឯតុ មេ ភោ សោ បុរិសោ បុនទេវ ហោតុ ទាសោ កម្មករោ បុព្វុដ្ឋាយី បច្ឆានិបាតី កិំការប្បដិស្សាវី មនាបចារី បិយវាទី មុខុល្លោកិកោតិ ។ នោ ហេតំ ភន្តេ អថខោ នំ មយមេវ អភិវាទេយ្យាមបិ បច្ចុដ្ឋេ-

១ ម. ម. សោតិ បាឋោ ន ទិស្សតិ ។

មហារាជយ៉ាងនេះថា សូមព្រះរាជតេជះតម្កល់លើត្បូង បពិត្រព្រះសម្មតិទេព សូមព្រះអង្គជ្រាប បុរសដែលជាខ្ញុំបម្រើ អ្នកធ្វើរាជការរបស់ព្រះអង្គ ជាអ្នកក្រោកឡើងមុន ដេកក្រោយ ជាអ្នកទទួលស្តាប់ពាក្យ ក្នុងកិច្ចការនីមួយ ជាអ្នកប្រព្រឹត្តធ្វើនូវអំពើជាទីគាប់ចិត្ត ជាអ្នកពោលនូវពាក្យជាទីស្រឡាញ់ ជាអ្នកបញ្ហាញមុខ (ម្ចាស់) បពិត្រព្រះសម្មតិទេព បុរសនោះកោរសក់និងពុកមាត់ ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈទាំងឡាយ ចេញចាកផ្ទះហើយចូលទៅកាន់ផ្នួស លុះបុរសនោះ បានបួសយ៉ាងនេះ ហើយក៏សង្រួមកាយ សង្រួមវាចា សង្រួមចិត្ត គ្រប់ឥរិយាបថ សន្តោសដោយគ្រឿងបរិភោគ និងគ្រឿងស្លៀកពាក់ដ៏ឧត្តម ត្រេកអរចំពោះទីស្ងាត់ ៗ ចុះមហារាជគួរពោលយ៉ាងនេះថា អើ បុរសនោះត្រូវចូលមក (នៅក្នុងសំណាក់) អញវិញ ត្រូវមកធ្វើជាខ្ញុំបម្រើអញ អ្នកធ្វើរាជការ ជាអ្នកក្រោកមុន ដេកក្រោយ ជាអ្នកទទួលស្តាប់ពាក្យ ក្នុងកិច្ចការនីមួយ ជាអ្នកប្រព្រឹត្តធ្វើនូវអំពើជាទីគាប់ចិត្ត ជាអ្នកពោលនូវពាក្យ ជាទីស្រឡាញ់ ជាអ្នកបញ្ហាញមុខ (ម្ចាស់) ដូច្នេះដែរឬ ៗ ព្រះរាជាក្រាបបង្គំទូលថា 'បពិត្រព្រះអង្គដ៏ចំរើន ហេតុនោះមិនមែនដូច្នោះទេ តាមពិត យើងខ្ញុំទាំងឡាយគួរតែថ្វាយបង្គំបុគ្គលនោះផង គួរតែក្រោកទទួលបុគ្គលនោះផង គួរតែនិមន្ត

យ្យាមបិ អាសនេនបិ និមន្តេយ្យាម អភិនិមន្តេយ្យាម-
បិ នំ ចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជ-
បរិក្ខារេហិ ធម្មិកំបិស្ស រក្ខាវរណគុត្តឹ សំវិទហេយ្យា-
មាតិ ។ តំ កឹ មញ្ញសិ មហារាជ យទិ ឯវំ សន្តេ
ហោតិ វា សន្ទិដ្ឋិកំ សាមញ្ញផលំ នោ វាតិ ។ អទ្ធា
ខោ ភន្តេ ឯវំ សន្តេ ហោតិ សន្ទិដ្ឋិកំ សាមញ្ញផលន្តិ ។
ឥទំ ខោ តេ មហារាជ មយា បឋមំ ទិដ្ឋេវ ធម្មេ
សន្ទិដ្ឋិកំ សាមញ្ញផលំ បញ្ញត្តន្តិ ។

(១០១) សក្កា បន ភន្តេ អញ្ញំបិ ឯវមេវ ទិដ្ឋេវ
ធម្មេ សន្ទិដ្ឋិកំ សាមញ្ញផលំ បញ្ញាបេតុន្តិ ។ សក្កា
មហារាជ តេនហិ មហារាជ តញ្ញេវេត្ថ បដិបុច្ឆិស្សាមិ
យថា តេ ខមេយ្យ តថា នំ ព្យាករេយ្យាសិ ។

សាមញ្ញផលសូត្រ ការប្រុងសំដែងផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ដោយអាសនៈផង គួរតែនិមន្តបុគ្គលនោះដោយចីវរបិណ្ឌបាតសេនាសនៈ និងគ្រឿងបរិក្ខារគឺថ្នាំជាបច្ច័យដល់អ្នកមានជម្ងឺផង គួរតែចាត់ចែងនូវការរក្សាការពារគ្រប់គ្រង ដែលប្រកបដោយធម៌ ដល់បុគ្គលនោះផង ។ ព្រះអង្គទ្រង់ត្រាស់ថា បពិត្រមហារាជ ចុះមហារាជសំគាល់ហេតុនោះដូចម្តេច កាលបើហេតុយ៉ាងនោះមានហើយ ផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ឈ្មោះថាមានដែរ ឬមិនមានទេ ។ ព្រះរាជាក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន កាលបើហេតុយ៉ាងនេះ មានហើយ ផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ឈ្មោះថាមានដោយពិត ។ ព្រះអង្គទ្រង់ត្រាស់ថា បពិត្រមហារាជ នេះឯងជាផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ជាបឋម ដែលតថាគត អាចបញ្ញត្តដល់មហារាជបាន ។

(១០១) ព្រះរាជាទូលសួរទៀតថា បពិត្រព្រះអង្គដ៏ចំរើន ចុះព្រះអង្គអាចបញ្ញត្តនូវផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ក្នុងបច្ចុប្បន្នដទៃទៀត យ៉ាងដូច្នោះ បានដែរឬ ។ ព្រះអង្គទ្រង់ត្រាស់ថា បពិត្រមហារាជ តថាគត (អាចបញ្ញត្តបាន) បពិត្រមហារាជ បើដូច្នេះ តថាគតសូមសួរមហារាជ ចំពោះប្រស្នានុ៎ះវិញ មហារាជគាប់ព្រះរាជហឫទ័យយ៉ាងណា គប្បីដោះស្រាយនូវប្រស្នានោះយ៉ាងនោះចុះ ។

តំ កឹ មញ្ញសិ មហារាជ ឥធ តេ អស្ស បុរិសោ ក-
ស្សកោ គហបតិកោ ការការកោ រាសិវឌ្ឍកោ ។
តស្ស ឯវមស្ស អច្ឆរិយំ វត ភោ អព្ភុតំ វត ភោ
បុញ្ញានំ គតិ បុញ្ញានំ វិបាកោ(១) អយំ ហិ រាជា
មាគធោ អជាតសត្តុ វេទេហិបុត្តោ មនុស្សោ អហម្បិ
មនុស្សោ អយំ ហិ រាជា មាគធោ អជាតសត្តុ វេទេ-
ហិបុត្តោ បញ្ចហិ កាមគុណេហិ សមប្បិតោ សមង្គី-
ភូតោ បរិចារេតិ ទេវោ មញ្ញេ អហំ បនម្ហិស្ស កស្ស-
កោ គហបតិកោ ការការកោ រាសិវឌ្ឍកោ សោ
វតស្សាហំ បុញ្ញានិ ករេយ្យំ យន្នូនាហំ កេសមស្សុំ
ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា
អនគារិយំ បព្វជេយ្យន្តិ ។ សោ អបរេន សមយេន
អប្បំ វា ភោគក្ខន្ធំ បហាយ មហន្តំ វា ភោគក្ខន្ធំ
បហាយ អប្បំ វា ញាតិបរិវដ្ដំ បហាយ មហន្តំ វា
ញាតិបរិវដ្ដំ បហាយ កេសមស្សុំ ឱហារេត្វា កាសា-
យានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វ-
ជេយ្យ ។ សោ ឯវំ បព្វជិតោ សមានោ កាយេន

---

១ ឱ. បុញ្ញានំ គតិ បុញ្ញានំ វិបាកោតិ ឥទំ ន ទិស្សតិ ។

បពិត្រមហារាជ ចុះព្រះអង្គសំគាល់នូវហេតុនោះដូចម្ដេច ក្នុងលោកនេះ (បើ) ព្រះអង្គមានបុរសជាអ្នកភ្ជួររាស់ ជាគហបតិ ជាអ្នកធ្វើគ្រឿងពលិការ ជាអ្នកធ្វើគំនរស្រូវឲ្យចំរើន ៗ បុរសនោះ ក៏មានសេចក្ដីត្រិះរិះយ៉ាងនេះថា អើហ្ន៎ ហេតុអស្ចារ្យពេកណាស់ អើហ្ន៎ ហេតុចម្លែកពេកណាស់ នេះជាគតិរបស់បុណ្យ នេះជាវិបាករបស់បុណ្យ ព្រោះថាព្រះបាទអជាតសត្តុវេទេហិបុត្រ ជាធំក្នុងដែនមគធៈនេះ ក៏ជាមនុស្ស អាត្មាអញសោតក៏ជាមនុស្សដែរ ប៉ុន្តែព្រះបាទអជាតសត្តុវេទេហិបុត្រ ជាធំក្នុងដែនមគធៈនេះ ទ្រង់ឆ្អែតស្កប់ស្កល់ដោយកាមគុណទាំង ៥ មានគេបម្រើហាក់ដូចជាទេវតា ឯអាត្មាអញជាអ្នកភ្ជួររាស់ ជាគហបតិ ជាអ្នកធ្វើគ្រឿងពលិការ ជាអ្នកធ្វើគំនរស្រូវឲ្យចំរើនដល់ព្រះរាជានោះទៅវិញ អាត្មាអញគួរតែធ្វើបុណ្យឲ្យបានដូចជាបុណ្យព្រះរាជានោះ បើដូច្នោះ មានតែអាត្មាអញ កោរសក់និងពុកមាត់ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈទាំងឡាយ ចេញចាកផ្ទះ ហើយចូលទៅកាន់ផ្នួស ៗ សម័យខាងក្រោយមក បុរសនោះ ក៏លះបង់នូវគំនរនៃភោគៈតិចក្ដី លះបង់នូវគំនរនៃភោគៈច្រើនក្ដី លះបង់ញាតិវង្សតិចក្ដី លះបង់ញាតិវង្សច្រើនក្ដី ចោលចេញ ហើយក៏កោរសក់និងពុកមាត់ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈទាំងឡាយ ចេញចាកផ្ទះ ហើយចូលទៅកាន់ផ្នួស ៗ លុះបុរសនោះបានបួសយ៉ាងនេះហើយ

សំវុតោ វិហរេយ្យ វាចាយ សំវុតោ វិហរេយ្យ មនសា សំវុតោ វិហរេយ្យ ឃាសច្ឆាទនបរមតាយ សន្តុដ្ឋោ អភិរតោ បវិវេកេ ។ តញ្ចេ តេ បុរិសា ឯវមារោចេយ្យុំ យគ្ឃេ ទេវ ជានេយ្យាសិ យោ តេ សោ បុរិសោ កស្សកោ គហបតិកោ ការការកោ រាសិវឌ្ឍកោ សោ ទេវ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតោ សោ ឯវំ បព្វជិតោ សមានោ កាយេន សំវុតោ វិហរតិ វាចាយ សំវុតោ វិហរតិ មនសា សំវុតោ វិហរតិ ឃាសច្ឆាទន-បរមតាយ សន្តុដ្ឋោ អភិរតោ បវិវេកេតិ ។ អបិ នុ ត្វំ ឯវំ វទេយ្យាសិ ឯតុ មេ ភោ សោ បុរិសោ បុនទេវ ហោតុ កស្សកោ គហបតិកោ ការការកោ រាសិវឌ្ឍកោតិ ។ នោ ហេតំ ភន្តេ អថខោ នំ មយ-មេវ អភិវាទេយ្យាមបិ បច្ចុដ្ឋេយ្យាមបិ អាសនេនបិ និមន្តេយ្យាម អភិនិមន្តេយ្យាមបិ នំ ចីវរបិណ្ឌបាតសេ-នាសនគិលានបច្ចយភេសជ្ជបរិក្ខារេហិ ធម្មិកំបិស្ស

ក៏សង្រួមកាយ សង្រួមវាចា សង្រួមចិត្ត គ្រប់ឥរិយាបថ សន្តោសដោយគ្រឿងបរិភោគនិងគ្រឿងស្លៀកដណ្តប់ដ៏ឧត្តម ត្រេកអរចំពោះទីស្ងាត់ ៗ មានបុរស ១ ពួកទៀតក្រាបទូលមហារាជយ៉ាងនេះថា សូមព្រះរាជតេជះតម្កល់លើត្បូង បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់ជ្រាប បុរសណា ដែលជាអ្នកភ្ជួររាស់ ជាគហបតិ ជាអ្នកធ្វើនូវគ្រឿងពលិការ ជាអ្នកធ្វើគំនរស្រូវឲ្យចំរើន (ដល់ព្រះអង្គ) បពិត្រព្រះសម្មតិទេព បុរសនោះ កោរសក់និងពុកមាត់ពុកចង្កា ស្លៀកដណ្តប់សំពត់កាសាយៈទាំងឡាយ ចេញចាកផ្ទះ ហើយចូលទៅកាន់ផ្នួស លុះបុរសនោះបានបួសយ៉ាងនេះហើយ ក៏សង្រួមកាយ សង្រួមវាចា សង្រួមចិត្ត គ្រប់ឥរិយាបថ សន្តោសដោយគ្រឿងបរិភោគ និងគ្រឿងស្លៀកដណ្តប់ដ៏ឧត្តម ត្រេកអរចំពោះទីស្ងាត់ ៗ បុះមហារាជត្រាស់ពោលយ៉ាងនេះថា អើ បុរសនោះត្រូវចូលមកវិញ ត្រូវធ្វើជាអ្នកភ្ជួររាស់ស្រែ ជាគហបតិ ជាអ្នកធ្វើនូវគ្រឿងពលិការ ជាអ្នកធ្វើគំនរស្រូវឲ្យចំរើន ដល់អញវិញ ដូច្នេះដែរឬ ៗ ព្រះរាជាក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន ហេតុនោះ មិនមែនដូច្នោះទេ តាមពិត យើងខ្ញុំទាំងឡាយ គួរតែថ្វាយបង្គំបុរសនោះផង គួរតែក្រោកទទួលបុរសនោះផង គួរតែនិមន្តដោយអាសនៈផង គួរតែនិមន្តបុរសនោះដោយចីវរ បិណ្ឌបាត សេនាសនៈនិងគ្រឿងបរិក្ខារ គឺថ្នាំជាបច្ច័យដល់អ្នកជម្ងឺផង

រក្ខាវរណគុត្តឹ សំវិទហេយ្យាមាតិ ។ តំ កឹ មញ្ញសិ មហារាជ យទិ ឯវំ សន្តេ ហោតិ វា សន្ទិដ្ឋិកំ សាមញ្ញផលំ នោ វាតិ ។ អទ្ធា ខោ ភន្តេ ឯវំ សន្តេ ហោតិ សន្ទិដ្ឋិកំ សាមញ្ញផលន្តិ ។ ឥទំ ខោ តេ មហារាជ មយា ទុតិយំ ទិដ្ឋេ វ ធម្មេ សន្ទិដ្ឋិកំ សាមញ្ញផលំ បញ្ញត្តន្តិ ។

(១០២) សក្កា បន ភន្តេ អញ្ញំបិ ទិដ្ឋេ វ ធម្មេ សន្ទិដ្ឋិកំ សាមញ្ញផលំ បញ្ញាបេតុំ ឥមេហិ សន្ទិដ្ឋិកេហិ សាមញ្ញផលេហិ អភិក្កន្តតរញ្ច បណីតតរញ្ចាតិ ។ សក្កា មហារាជ តេនហិ មហារាជ សុណាហិ(១) សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ ភគវតោ

១ ឱ. ម សុណោហិ ។

គួរតែចាត់ចែងការរក្សា ការពារគ្រប់គ្រងដ៏ប្រកបដោយធម៌ ដល់បុរស
នោះផង ។ ព្រះអង្គទ្រង់ត្រាស់ថា បពិត្រមហារាជ ព្រះអង្គសំគាល់នូវ
ហេតុនោះដូចម្ដេច កាលបើហេតុយ៉ាងនេះមានហើយ ផលនៃសមណ-
ប្បដិបត្តិដែលឃើញច្បាស់ដោយខ្លួនឯង ឈ្មោះថាមានដែរ ឬមិនមានទេ ។
ព្រះរាជា ក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចំរើន កាលបើហេតុយ៉ាង
នេះមានហើយ ផលនៃសមណប្បដិបត្តិដែលឃើញច្បាស់ ដោយខ្លួនឯង
ឈ្មោះថាមានដោយពិត ។ ព្រះអង្គទ្រង់ត្រាស់ថា បពិត្រមហារាជ នេះ
ឯងជាផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯងក្នុងបច្ចុប្បន្ន
ជាគំរប់ ២ ដែលតថាគត អាចបញ្ញត្តដល់មហារាជបាន ។

(១០២) ព្រះរាជាទូលសួរថា បពិត្រព្រះអង្គដ៏ចំរើន ចុះព្រះអង្គ
អាចនឹងបញ្ញត្តនូវផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង
ក្នុងបច្ចុប្បន្នដទៃទៀត ដែលរុងរឿងដោយវិសេសផង ដែលថ្លៃថ្លាដោយ
វិសេសផង ជាងផលនៃសមណប្បដិបត្តិដែលឃើញច្បាស់ ដោយខ្លួនឯង
ទាំងអម្បាលនេះបានដែរឬ ។ ព្រះអង្គទ្រង់ត្រាស់ថា បពិត្រមហារាជ
តថាគតអាចបញ្ញត្តបាន បពិត្រមហារាជ បើដូច្នោះ សូមមហារាជ ទ្រង់
ព្រះសណ្ដាប់ ធ្វើទុកក្នុងព្រះទ័យឲ្យប្រពៃចុះ តថាគតនឹងពោល ។
ឯព្រះបាទអជាតសត្តុវេទេហិបុត្រ ជាធំក្នុងដែនមគធៈ ក៏ទទួលព្រះពុទ្ធដីកា

## សាមញ្ញផលសុត្តេ ពុទ្ធគុណកថា

បច្ចស្សោសិ ។ ភគវា ឯតទវោច ឥធ មហារាជ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ(១) សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ ។ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ ។ តំ ធម្មំ សុណាតិ គហបតិ វា គហបតិបុត្តោ វា អញ្ញតរស្មឹ វា កុលេ បច្ចាជាតោ ។ សោ តំ ធម្មំ សុត្វា តថា-

---

១ ឱ. ម. តិសទ្ទោ ន ទិស្សតិ ។

នៃព្រះមានព្រះភាគដោយពាក្យថា ព្រះករុណាព្រះអង្គ ៗ ទើបព្រះមានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកាដូច្នេះថា បពិត្រមហារាជ ព្រះតថាគតកើតឡើង ក្នុងលោកនេះ ជាបុគ្គលឆ្ងាយចាកសេចក្ដីសៅហ្មងគ្រប់យ៉ាងត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ បរិបូណ៌ដោយវិជ្ជានិងចរណៈ គឺសេចក្ដីចេះដឹងនិងក្រឹត្យ ដែលបុគ្គលគប្បីប្រព្រឹត្តមានដំណើរល្អ ជ្រាបច្បាស់នូវត្រៃលោក ប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ជាអ្នកទូន្មាននូវបុរស ដែលគួរទូន្មានបានជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ត្រាស់ដឹងនូវអរិយសច្ចធម៌ លែងវិលត្រឡប់មកកាន់ភពថ្មីទៀត ព្រះតថាគតនោះបានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់ដោយព្រះអង្គឯង ហើយញុំាងលោកនេះ ព្រមទាំងទេវលោកមារលោក ព្រហ្មលោក ពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេពនិងមនុស្សដ៏សេសឲ្យត្រាស់ដឹងផង ៗ ព្រះអង្គទ្រង់សំដែងធម៌មានលំអបទដើម លំអបទកណ្ដាលនិងលំអបទចុង ជាធម៌បរិបូណ៌ដោយអត្ថនិងព្យញ្ជនៈ ទ្រង់ប្រកាសនូវព្រហ្មចរិយធម៌ ដ៏បរិសុទ្ធបរិបូណ៌គ្រប់គ្រាន់ទាំងអស់ ៗ បុគ្គលជាគហបតិក្ដី ជាបុត្តនៃគហបតិក្ដី បុគ្គលដែលមកកើតខាងក្រោយក្នុងត្រកូលឯណានីមួយក្ដី រមែងស្ដាប់នូវធម៌នោះ ៗ លុះបុគ្គលនោះ បានស្ដាប់នូវធម៌នោះហើយ រមែងបានចំពោះនូវជំនឿក្នុង

គតេ សទ្ធំ បដិលភតិ ។ សោ តេន សទ្ធាបដិលាភេន សមន្នាគតោ ឥតិ បដិសញ្ចិក្ខតិ សម្ពាធោ ឃរាវាសោ រជាបថោ អព្ភោកាសោ បព្វជ្ជា នយិទំ សុករំ អគារំ អជ្ឈាវសតា ឯកន្តបរិបុណ្ណំ ឯកន្តបរិសុទ្ធំ សំខលិខិតំ ព្រហ្មចរិយំ ចរិតុំ យន្នូនាហំ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជេយ្យន្តិ ។ សោ អបរេន សមយេន អប្បំ វា ភោគក្ខន្ធំ បហាយ មហន្តំ វា ភោគក្ខន្ធំ បហាយ អប្បំ វា ញាតិបរិវដ្ដំ បហាយ មហន្តំ វា ញាតិបរិវដ្ដំ បហាយ កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជតិ ។ សោ[១] ឯវំ បព្វជិតោ សមានោ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ កាយកម្មវចីកម្មេន សមន្នាគតោ កុសលេន បរិសុទ្ធាជីវោ សីលសម្បន្នោ ឥន្ទ្រិយេសុ គុត្តទ្វារោ សតិសម្បជញ្ញេន សមន្នាគតោ សន្តុដ្ឋោ ។

១ ម. សោតិ ន ទិស្សតិ ។

ព្រះតថាគត ។ លុះបុគ្គលនោះ ប្រកបដោយកិរិយាបានចំពោះនូវជំនឿដូច្នោះហើយ រមែងពិចារណាថា ការនៅគ្រប់គ្រងផ្ទះ ចង្អៀត (ពេកណាស់) ជាផ្លូវនៃធូលីគឺរាគាទិក្កិលេស (មានតែ) បព្វជ្ជា ទើបមានពេលទំនេរច្រើន ព្រហ្មចរិយធម៌នេះ បុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តឲ្យបរិបូណ៌គ្រប់គ្រាន់ ឲ្យបរិសុទ្ធស្អាតដូចជាស័ង្ខ ដែលគេខាត់ហើយទេ បើដូច្នោះមានតែអាត្មាអញ កោរសក់នឹងពុកមាត់ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះ ហើយចូលទៅកាន់ផ្នួស ។ សម័យខាងក្រោយមក បុគ្គលនោះក៏លះបង់នូវគំនរភោគៈតិចក្ដី លះបង់នូវគំនរភោគៈច្រើនក្ដី លះបង់នូវញាតិវង្សតិចក្ដី លះបង់នូវញាតិវង្សច្រើនក្ដី ហើយកោរសក់នឹងពុកមាត់ពុកចង្កា ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាកផ្ទះ ហើយចូលទៅកាន់ផ្នួស ។ លុះបុគ្គលនោះបានបួសយ៉ាងនេះហើយ ក៏សង្រួមតាមបាតិមោក្ខសំវរៈគ្រប់ឥរិយាបថ បរិបូណ៌ដោយអាចារៈនឹងគោចរៈ ជាអ្នកឃើញភ័យក្នុងទោសទាំងឡាយត្រឹមតែបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ប្រកបដោយកាយកម្មនឹងវចីកម្មជាកុសល មានអាជីវៈដ៏បរិសុទ្ធ ជាអ្នកបរិបូណ៌ដោយសីល រក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយ ប្រកបដោយសតិនឹងសម្បជញ្ញៈ ជាអ្នកសន្ដោស ។

(១០៣) កថញ្ច មហារាជ ភិក្ខុ សីលសម្បន្នោ ហោតិ ឥធ មហារាជ ភិក្ខុ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ និហិតទណ្ឌោ និហិតសត្ថោ លជ្ជី ទយាបន្នោ សព្វបាណភូតហិតានុកម្បី វិហរតិ ។ ឥទម្បិស្ស ហោតិ សីលស្មឹ ។ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតោ ហោតិ ទិន្នាទាយី ទិន្នបាដិកង្ខី អថេនេន សុចិភូតេន អត្តនា វិហរតិ ។ ឥទម្បិស្ស ហោតិ សីលស្មឹ ។ អព្រហ្មចរិយំ បហាយ ព្រហ្មចារី ហោតិ អារាចារី វិរតោ មេថុនា គាមធម្មា ។ ឥទម្បិស្ស ហោតិ សីលស្មឹ ។ មុសាវាទំ បហាយ មុសាវាទា បដិវិរតោ ហោតិ សច្ចវាទី សច្ចសន្ធោ ថេតោ បច្ចយិកោ អវិសំវាទកោ លោកស្ស ។ ឥទម្បិស្ស ហោតិ សីលស្មឹ ។ បិសុណំ វាចំ បហាយ បិសុណាយ វាចាយ បដិវិរតោ ហោតិ ឥតោ សុត្វា ន អមុត្រ អក្ខាតា ឥមេសំ ភេទាយ អមុត្រ វា សុត្វា ន ឥមេសំ អក្ខាតា អមូសំ ភេទាយ ឥតិ ភិន្នានំ វា សន្ធាតា

សាមញ្ញផលសូត្រ សីលក្ខន្ធកថា ចូឡសីល

(១០៣) បពិត្រមហារាជ ភិក្ខុជាអ្នកបរិបូណ៌ដោយសីល (នោះ) ដូចម្តេចខ្លះ បពិត្រមហារាជ ភិក្ខុក្នុងសាសនានេះ លះបង់បាណាតិបាត ជាអ្នកវៀរស្រឡះចាកបាណាតិបាត មានដំបងដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាស់បាប បរិបូណ៌ដោយសេចក្តីអាណិត ជាអ្នកអនុគ្រោះដោយប្រយោជន៍ ដល់សត្វមានជីវិតទាំងពួង ។ នេះជាសីលរបស់ភិក្ខុនោះ ។ ភិក្ខុលះបង់អទិន្នាទាន ជាអ្នកវៀរស្រឡះចាកអទិន្នាទាន កាន់យកតែវត្ថុដែលគេឲ្យ ចង់បានតែវត្ថុដែលគេឲ្យ មានខ្លួនជាស្អាត មិនមែនជាមនុស្សលួច ។ នេះជាសីលរបស់ភិក្ខុនោះ ។ ភិក្ខុលះបង់អព្រហ្មចរិយៈ ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ជាអ្នកប្រព្រឹត្តឆ្ងាយ ជាអ្នកវៀរចាកមេថុនធម្ម ដែលជាធម៌របស់អ្នកស្រុក ។ នេះជាសីលរបស់ភិក្ខុនោះ ។ ភិក្ខុលះបង់មុសាវាទ ជាអ្នកវៀរស្រឡះចាកមុសាវាទ ពោលតែពាក្យពិត តនូវពាក្យពិត ដោយពាក្យពិត ជាអ្នកមានសំដីទឹង មានពាក្យដែលគេគួរជឿ មិនបានពោលបំភាន់សត្វលោក ។ នេះជាសីលរបស់ភិក្ខុនោះ។ ភិក្ខុលះបង់បិសុណាវាចា ជាអ្នកវៀរស្រឡះចាកបិសុណាវាចា ឮអំពីទីនេះ មិនបានយកទៅប្រាប់ក្នុងទីឯណោះ ដើម្បីបំបែកនូវជនទាំងឡាយនេះ ឬឮក្នុងទីឯណោះ មិនបានយកមកប្រាប់ដល់ជនទាំងឡាយនេះ ដើម្បីបំបែកនូវជនទាំងឡាយឯណោះ ជាអ្នកផ្សះផ្សានូវជនទាំងឡាយ

សហិតានំ វា អនុប្បទាតា សមគ្គារាមោ សមគ្គរតោ សមគ្គនន្ទី សមគ្គករណឹ វាចំ ភាសិតា ហោតិ ។ ឥទំបិស្ស ហោតិ សីលស្មឹ ។ ផរុសំ វាចំ បហាយ ផរុសាយ វាចាយ បដិវិរតោ ហោតិ យា សា វាចា នេលា កណ្ណសុខា បេមនីយា ហទយង្គមា បោរី ពហុជនកន្តា ពហុជនមនាបា តថារូបឹ វាចំ ភាសិតា ហោតិ ។ ឥទំបិស្ស ហោតិ សីលស្មឹ ។ សម្ផប្បលាបំ បហាយ សម្ផប្បលាបា បដិវិរតោ ហោតិ កាលវាទី ភូតវាទី អត្ថវាទី ធម្មវាទី វិនយវាទី និធានវតឹ វាចំ ភាសិតា ហោតិ កាលេន សាបទេសំ បរិយន្តវតឹ អត្ថសញ្ហិតំ ។ ឥទំបិស្ស ហោតិ សីលស្មឹ ។ ពីជគាមភូតគាមសមារម្ភា បដិវិរតោ ហោតិ ។ ឯកភត្តិកោ ហោតិ រត្តូបរតោ វិរតោ វិកាលភោជនា ។ នច្ចគីតវាទិតវិសូកទស្សនា បដិវិរតោ

ដែលបែកគ្នាហើយ ឬឲ្យកម្លាំងថែមដល់ពួកជន ដែលជានឹងគ្នាហើយ មានសេចក្តីព្រមព្រៀងគ្នាជាទីត្រេកអរ ត្រេកអរតែក្នុងសេចក្តីព្រមព្រៀងគ្នា រីករាយតែក្នុងសេចក្តីព្រមព្រៀងគ្នា ជាអ្នកនិយាយតែវាចាដែលជាគ្រឿងធ្វើនូវសេចក្តីព្រមព្រៀងគ្នា ។ នេះជាសីលរបស់ភិក្ខុនោះ ។ ភិក្ខុលះបង់ផរុសវាចា ជាអ្នកវៀរស្រឡះចាកផរុសវាចា ក៏វាចាណាដែលមិនមានទោស នាំមកនូវសេចក្តីសុខដល់ត្រចៀក (អ្នកដទៃ) ជាពាក្យគួរឲ្យកើតសេចក្តីស្រឡាញ់ ជាពាក្យគួរតម្កល់ទុកក្នុងហឫទ័យ ជាសំដីរបស់អ្នកក្រុង ជាពាក្យជាទីត្រេកអរនៃជនច្រើនគ្នា ជាទីគាប់ចិត្តនៃជនច្រើនគ្នា តែងពោលនូវវាចាមានសភាពដូច្នោះ ។ នេះជាសីលរបស់ភិក្ខុនោះ ។ ភិក្ខុលះបង់សម្ផប្បលាបៈ ជាអ្នកវៀរស្រឡះចាកសម្ផប្បលាបៈ ជាអ្នកពោលនូវពាក្យក្នុងកាលគួរ ពោលនូវពាក្យពិត ពោលនូវអត្ថ ពោលនូវធម៌ ពោលនូវវិន័យ ពោលនូវពាក្យគួរតម្កល់ទុកក្នុងហឫទ័យ ជាពាក្យប្រកបដោយគ្រឿងអាង ជាពាក្យមានកំណត់ ជាពាក្យប្រកបដោយប្រយោជន៍តាមកាលដ៏គួរ ។ នេះជាសីលរបស់ភិក្ខុនោះ ។ ភិក្ខុវៀរស្រឡះចាកការធ្វើពីជគាមនិងភូតគាម[1]ឲ្យវិនាស ៖ ជាអ្នកបរិភោគភត្តតែ ១ ពេល វៀរបរិភោគក្នុងរាត្រី វៀរបរិភោគក្នុងកាលខុស ។ វៀរចាកការ

---

១ វត្ថុដែលមានពូជដុះឡើងបាន តែមិនដុះជាប់នឹងផែនដីមានគ្រាប់ឈើជាដើម ហៅថា ពីជគាម, ឈើ ស្មៅជាដើម ដែលដុះជាប់នឹងផែនដី ហៅថា ភូតគាម ។

ហោតិ ។ មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា
បដិវិរតោ ហោតិ ។ ឧច្ចាសយនមហាសយនា បដិវិរតោ
ហោតិ ។ ជាតរូបរជតបដិគ្គហណា បដិវិរតោ ហោតិ ។
អាមកធញ្ញបដិគ្គហណា បដិវិរតោ ហោតិ ។ អាមក-
មំសបដិគ្គហណា បដិវិរតោ ហោតិ ។ ឥត្ថីកុមារិ-
កបដិគ្គហណា បដិវិរតោ ហោតិ ។ ទាសីទាសប-
ដិគ្គហណា បដិវិរតោ ហោតិ ។ អជេឡកបដិគ្គ-
ហណា បដិវិរតោ ហោតិ ។ កុក្កុដសូករបដិគ្គហ-
ណា បដិវិរតោ ហោតិ ។ ហត្ថិគវស្សវឡវបដិគ្គហ-
ណា បដិវិរតោ ហោតិ ។ ខេត្តវត្ថុបដិគ្គហណា ប-
ដិវិរតោ ហោតិ ។ ទូតេយ្យបហិណគមនានុយោគា
បដិវិរតោ ហោតិ ។ កយវិក្កយា បដិវិរតោ ហោតិ ។
តុលាកូដកំសកូដមានកូដា បដិវិរតោ ហោតិ ។
ឧក្កោដនវញ្ចននិកតិសាចិយោគា បដិវិរតោ ហោតិ ។

មើលនូវរបាំ នឹងស្ដាប់នូវចម្រៀង នឹងភ្លេងប្រគំ ដែលជាសត្រូវដល់កុសលធម៌ ។ វៀរចាកការទ្រទ្រង់នឹងការប្រដាប់ស្អិតស្អាងកងកាយ ដោយផ្កាកម្រង គ្រឿងក្រអូប នឹងគ្រឿងលាបផ្សេងៗ ។ វៀរចាកទីដេកទីអង្គុយដ៏ខ្ពស់នឹងទីដេកទីអង្គុយដ៏ប្រសើរ ។ វៀរចាកការទទួលនូវមាសនឹងប្រាក់ ។ វៀរចាកការទទួលនូវធញ្ញជាតិឆៅ ។ វៀរចាកការទទួលនូវសាច់ឆៅ ។ វៀរចាកការទទួលនូវស្រីនឹងកុមារី ។ វៀរចាកការទទួលខ្ញុំស្រី នឹងខ្ញុំប្រុស ។ វៀរចាកការទទួល នូវពពែនឹងចៀម ។ វៀរចាកការទទួលនូវមាន់នឹងជ្រូក ។ វៀរចាកការទទួលនូវដំរី គោ សេះឈ្មោលញី ។ វៀរចាកការទទួលនូវស្រែនឹងចម្ការ ។ វៀរចាកការប្រកបនូវទូតកម្ម គឺនាំសំបុត្រ ឬពាក្យបណ្ដាំរបស់គ្រហស្ថ នឹងទៅដោយគេប្រើអំពីផ្ទះមួយទៅផ្ទះមួយ ។ វៀរចាកការទិញនឹងលក់ ។ វៀរចាកការបញ្ឆោតឬបន្លំដោយជញ្ជីង នឹងបញ្ឆោតដោយភាជន៍កាខ្លែមាស (ជាដើម) នឹងបញ្ឆោតដោយរង្វាល់រង្វាស់ ។ វៀរចាកការប្រកប នូវអំពើវៀច គឺបន្ខុសបំភាន់(១)នឹងបញ្ឆោតបោកប្រាស នឹងបន្លំដោយរបស់ក្លែង ។

---

១ បានខាងចៅក្រមស៊ីសំណូកគេ ហើយកាត់ក្ដីវៀច ធ្វើអ្នកចាញ់ឲ្យទៅជាឈ្នះ អ្នកឈ្នះឲ្យទៅជាចាញ់វិញ ។

ឆេទនវធពន្ធនវិបរាមោសអាលោបសហសាការា បដិវិរតោ ហោតិ ។ ឥទំបិស្ស ហោតិ សីលស្មឹ ។

ចូឡសីលំ និដ្ឋិតំ ។

(១០៦) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ ពីជគាមភូតគាមសមារម្ភំ អនុយុត្តា វិហរន្តិ ។ សេយ្យថីទំ ។ មូលពីជំ ខន្ធពីជំ ផលុពីជំ អគ្គពីជំ ពីជពីជមេវ បញ្ចមំ ឥតិ វា ។ ឥតិ ឯវរូបា ពីជគាមភូតគាមសមារម្ភា បដិវិរតោ ហោតិ ។ ឥទំបិស្ស ហោតិ សីលស្មឹ ។

(១០៧) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ សន្និធិការបរិភោគំ អនុយុត្តា វិហរន្តិ ។ សេយ្យថីទំ ។

វៀរចាកការកាត់ (នូវអវយវៈមានដៃជាដើម) ការសម្លាប់ ការចង ការលាក់ខ្លួនពួនចាំធ្វើអំពើអាក្រក់ និងការប្លន់ការកំហែងយកទ្រព្យ ។ នេះជាសីលរបស់ភិក្ខុនោះ ។

ចប់ ចូឡសីល ។

(១០៤) មួយវិញទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ដ៏ចំរើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ រមែងប្រកបរឿយ ៗ នូវការធ្វើពីជគាមនិងភូតគាមឲ្យវិនាស មានសភាពដូច្នេះ ។ ពីជគាមនិងភូតគាមនោះ តើដូចម្តេចខ្លះ ។ គឺមើម ឬឫសជាពូជ ១ ដើមជាពូជ ១ ថ្នាំងជាពូជ ១ ចុង ឬត្រួយជាពូជ ១ គ្រាប់ជាពូជ ១ ជាគំរប់ ៥ ។ ភិក្ខុជាអ្នកវៀរចាកការធ្វើពីជគាមនិងភូតគាមឲ្យវិនាស មានសភាពដូច្នេះឯង ។ នេះជាសីលរបស់ភិក្ខុនោះ ។

(១០៥) ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ រមែងប្រកបរឿយ ៗ នូវការបរិភោគវត្ថុដែលសន្សំទុក មានសភាពដូច្នេះ ។ ការសន្សំទុក នោះតើដូចម្តេច ។

អន្នសន្និធឹ(១) បានសន្និធឹ វត្ថសន្និធឹ យានសន្និធឹ សយនសន្និធឹ គន្ធសន្និធឹ អាមិសសន្និធឹ ឥតិ វា ។ ឥតិ ឯវរូបា សន្និធិការបរិភោគា បដិវិរតោ ហោតិ ។ ឥទំបិស្ស ហោតិ សីលស្មឹ ។

(១០៦) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ វិសូកទស្សនំ អនុយុត្តា វិហរន្តិ ។ សេយ្យថីទំ ។ នច្ចំ គីតំ វាទិតំ បេក្ខំ អក្ខានំ បាណិស្សរំ វេតាឡំ កុម្ភថូនំ សោភនករកំ ចណ្ឌាលំ វំសំ ធោវនំ ហត្ថិយុទ្ធំ អស្សយុទ្ធំ មហិំសយុទ្ធំ(២) ឧសភយុទ្ធំ អជយុទ្ធំ មេណ្ឌយុទ្ធំ(៣) កុក្កុដយុទ្ធំ វដ្ដកយុទ្ធំ ទណ្ឌយុទ្ធំ មុដ្ឋិយុទ្ធំ និព្វុទ្ធំ ឧយ្យោធិកំ ពលគ្គំ សេនាព្យូហំ អនីកទស្សនំ ឥតិ វា ។ ឥតិ ឯវរូបា វិសូកទស្សនា បដិវិរតោ ហោតិ ។ ឥទំបិស្ស ហោតិ សីលស្មឹ ។

---

១ អន្នសន្និធិន្តិបិ អន្នសន្និធីតិបិ បាឋោ ទិស្សតិ ។ ឯវំ សព្វត្ថ ។ ២ ម. មហិសយុទ្ធំ ។ ៣ ឱ. ម. មេណ្ឌកយុទ្ធំ ។

គឺសន្សំបាយទុក ១ សន្សំទឹកទុក ១ សន្សំសំពត់ទុក ១ សន្សំយានទុក ១ សន្សំទីដេកទុក ១ សន្សំគ្រឿងក្រអូបទុក ១ សន្សំគ្រឿងអាមិសៈទុក ១ ។ ភិក្ខុជាអ្នកវៀរចាកការបរិភោគវត្ថុដែលសន្សំទុក មានសភាពដូច្នេះឯង ។ នេះជាសីលរបស់ភិក្ខុនោះ ។

(១០៦)ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ រមែងប្រកបរឿយ ៗ នូវការមើលការស្ដាប់នូវល្បែង ដែលជាសត្រូវដល់កុសលធម៌មានសភាពដូច្នេះ ។ ល្បែងជាសត្រូវដល់កុសលធម៌នោះតើដូចម្ដេច ។ គឺល្បែងរាំខ្លះ ច្រៀងខ្លះ ប្រគំខ្លះ មហោស្រពខ្លះ ចម្រៀងមហាភារតៈនឹងរាមកេរ្តិ៍ជាដើមខ្លះ គងខ្លះ រគាំងខ្លះ ស្គរមានជ្រុងបួនខ្លះ គូរគំនូររូបរបាំខ្លះ ល្បែងដុំដែកខ្លះ ល្បែងកាំខ្លះ ល្បែងលាងឆ្អឹងខ្លះ ដំរីជល់គ្នាខ្លះ សេះប្រខាំគ្នាខ្លះ ក្របីជល់គ្នាខ្លះ គោជល់គ្នាខ្លះ ពពែជល់គ្នាខ្លះ កែះជល់គ្នាខ្លះ មាន់ជល់គ្នាខ្លះ ចាបជល់គ្នាខ្លះ ល្បែងគុណដំបងខ្លះ ប្រដាល់ខ្លះ ចម្បាប់ខ្លះ ចម្បាំងខ្លះ ទីគេកប់ពលខ្លះ ទីលំនៅកងទ័ពខ្លះ ទីមើលពួកសេនាដែលប្រកបដោយអង្គ ៤ ខ្លះ ។ ភិក្ខុជាអ្នកវៀរចាកការមើលការស្ដាប់នូវល្បែង ដែលជាសត្រូវដល់កុសលធម៌មានសភាពដូច្នេះឯង ។ នេះជាសីលរបស់ភិក្ខុនោះ ។

(១០៧) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ ជូតប្បមាទដ្ឋានានុយោគមនុយុត្តា[១] វិហរន្តិ ។ សេយ្យថីទំ ។ អដ្ឋបទំ ទសបទំ អាកាសំ បរិហារបថំ សន្តិកំ ខលិកំ ឃដិកំ សលាកហត្ថំ អក្ខំ បង្គចីរំ[២] វង្កកំ មោក្ខចិកំ ចិង្គុលកំ[៣] បត្តាឡ្ហកំ រថកំ ធនុកំ អក្ខរិកំ មនេសិកំ[៤] យថាវជ្ជំ ឥតិ វា ។ ឥតិ ឯវរូបា ជូតប្បមាទដ្ឋានានុយោគា បដិវិរតោ ហោតិ ។ ឥទំបិស្ស ហោតិ សីលស្មឹ ។

---

១ ឱ. ម. ជូតប្បមាទដ្ឋានានុយោគំ អនុយុត្តា ។ ២ ឱ. ម. បង្គចីរំ ។ ៣ ឱ. ម. ចិង្គុលិកំ ។ ៤ មនេសិកន្តិបិ បាឋោ ។

(១០៧) ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើន ពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ រមែងប្រកបរឿយ ៗ នូវល្បែងបាស្កា ដែលជាហេតុជាទីតាំងនៃសេចក្តីប្រមាទ មានសភាពដូច្នេះ ៗ ល្បែងបាស្កានោះតើដូចម្តេចខ្លះ ៗ គឺបាស្កាមានក្រឡាប្រាំបី(១) ខ្លះ បាស្កាមានក្រឡាដប់(២)ខ្លះ បាស្កាដែលលេងឮដ៏អាកាស(៣)ខ្លះ ល្បែងវេងផ្លូវដែលគូរពង(៤) ខ្លះ ល្បែងផ្ទាត់គ្រាប់មានគ្រាប់ក្រួសជាដើមខ្លះ លេងបាស្កាក្នុងទីលានសម្រាប់លេងខ្លះ ល្បែងហ៊ុំបុកកូនគោលខ្លះ ល្បែងរលាស់ទឹកលាក់ឲ្យទាយរូបខ្លះ ល្បែងអង្គុញខ្លះ ល្បែងផ្លុំបីស្លឹកខ្លះ ល្បែងនង្គ័លតូចខ្លះ ល្បែងដាំដូងខ្លះ ល្បែងកង្ហារខ្លះ ល្បែងកស់ដីខ្សាច់ ( បាយឡុកបាយឡ ) ខ្លះ ល្បែងរថតូចខ្លះ ល្បែងធ្នូតូចខ្លះ ល្បែងសរសេរអក្សរខ្យល់ឲ្យទាយខ្លះ ល្បែងទាយចិត្ត ( ស្តេចចង់ ) ខ្លះ ល្បែងកំប្លែងត្រាប់គេខ្លះ ៗ ឯភិក្ខុជាអ្នកវៀរចាកល្បែងបាស្កា ដែលជាហេតុជាទីតាំង នៃសេចក្តីប្រមាទ មានសភាពដូច្នេះឯង ៗ នេះជាសីលរបស់ភិក្ខុនោះដែរ ៗ

---

១ ចត្រង្គមានក្រឡា ៨ ។ ២ ចត្រង្គមានក្រឡា ១០ ន័យខ្លះថាបាយយុំ ។ ៣ ចត្រង្គឥតក្តារលេងតែមាត់ទទេ ។ ៤ ប្រហែលជាបិទមុខបិទពួន ។

(១០៨) យថា វា បនេកេ ភោន្តោ សមណព្រាហ្ម-ណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ ឧច្ចាសយនមហាសយនំ អនុយុត្តា វិហរន្តិ ។ សេយ្យ-ថីទំ ។ អាសន្ទឹ បល្លង្កំ គោណកំ ចិត្តកំ បដិកំ បដលិកំ តូលិកំ[១] វិកតិកំ ឧទ្ធលោមឹ ឯកន្តលោមឹ កដ្ឋិស្សំ កោសេយ្យំ កុត្តកំ ហត្ថត្ថរំ អស្សត្ថរំ

---

១ ម. តុលិកំ ។

(១០៨) មួយវិញទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ដ៏ចំរើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធា ហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយ ៗ នូវឧច្ចាសយនមហាសយនៈ (ទីដេកទីអង្គុយដ៏ខ្ពស់ទាំងទីដេកទីអង្គុយដ៏ប្រសើរ) មានសភាពដូច្នេះ ៗ ឧច្ចាសយនមហាសយនៈនោះ តើដូចម្តេចខ្លះ ៗ គឺអាសនៈដែលខ្ពស់ហួសប្រមាណខ្លះ គ្រែដែលមានជើងវិចិត្រ ដោយរូបសត្វសាហាវខ្លះ ព្រំដែលមានរោមវែងជាង ៤ ធ្នាប់ខ្លះ កម្រាលដែលធ្វើដោយរោម វិចិត្រដោយរូបសត្វសាហាវខ្លះ កម្រាលមានពណ៌សដែលធ្វើដោយរោមសត្វខ្លះ កម្រាលដែលធ្វើដោយរោមសត្វមានផ្កាដេរដាសខ្លះ កម្រាលដែលញាត់ដោយសំឡីជាប្រក្រតីខ្លះ កម្រាលដែលធ្វើដោយរោមសត្វ វិចិត្រដោយរូបសត្វសាហាវ មានសីហៈនិងខ្លាធំជាដើមខ្លះ កម្រាលដែលធ្វើដោយរោមសត្វ មានរោមប្រាងឡើងតែម្ខាងខ្លះ កម្រាលដែលធ្វើដោយរោមសត្វ មានរោមប្រាងឡើងទាំងសងខាងខ្លះ កម្រាលដែលធ្វើដោយឌិនខ្សែរសយមាសនិងសូត្រ ចាក់ស្រែះដោយរតនវត្ថុ មានមាសជាដើមខ្លះ កម្រាលដែលធ្វើដោយសរសៃសូត្រ ចាក់ស្រែះដោយរតនវត្ថុខ្លះ កម្រាលដែលធ្វើដោយរោមសត្វ ល្មមចុះពួកស្រីរបាំ ១៦ នាក់ ឈររាំបានខ្លះ កម្រាលសម្រាប់ក្រាលលើខ្នងដំរីខ្លះ កម្រាលសម្រាប់ក្រាលលើខ្នងសេះខ្លះ

រថត្ថរំ អជិនប្បវេណឹ កទលិមិគបវរបច្ចត្ថរណំ ស-
ឧត្តរច្ឆទំ ឧភតោលោហិតកូបធានំ ឥតិ វា ឥតិ
ឯវរូបា ឧច្ចាសយនមហាសយនា បដិវិរតោ ហោតិ ។
ឥទំបិស្ស ហោតិ សីលស្មឹ ។

(១០៩) យថា វា បនេកេ ភោន្តោ សមណព្រាហ្ម-
ណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ
មណ្ឌនវិភូសនដ្ឋានានុយោគំ អនុយុត្តា វិហរន្តិ ។
សេយ្យថីទំ ។ ឧច្ឆាទនំ បរិមទ្ទនំ នហាបនំ សម្ពាហនំ
អាទាសំ អញ្ជនំ មាលាគន្ធវិលេបនំ មុខចុណ្ណំ មុខាលេ-
បនំ ហត្ថពន្ធំ សិខាពន្ធំ ទណ្ឌំ នាលិកំ អសឹ ឆត្តំ
ចិត្រុបាហនំ ឧណ្ហីសំ មណឹ វាលពីជនឹ ឱទាតានិ
វត្ថានិ ទីឃទសានិ ឥតិ វា ឥតិ ឯវរូបា មណ្ឌនវិភូ-

កម្រាលសម្រាប់ក្រាលលើរថខ្លះ កម្រាលដែលធ្វើដោយស្បែកខ្លាខ្លះ កម្រាលដ៏ឧត្តមដែលធ្វើដោយស្បែកសត្វឈ្លូសខ្លះ ខ្នើយមានពណ៌ក្រហមទាំង ២ ខាង គឺខ្នើយក្បាលនឹងខ្នើយជើង ព្រមទាំងពិតានមានពណ៌ក្រហមខ្លះ ។ ភិក្ខុជាអ្នកវៀរចាកឧច្ចាសយនមហាសយនៈ មានសភាពដូច្នោះឯង ។ នេះជាសីលរបស់ភិក្ខុនោះ ។

(១០៩) ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើន ពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយ ៗ នូវតែជាទីតាំងនៃការប្រដាប់ស្អិតស្អាងកងកាយ មានសភាពដូច្នេះ ។ តែជាទីតាំងនៃការប្រដាប់ស្អិតស្អាងកងកាយនោះ តើដូចម្តេចខ្លះ ។ គឺការដុសខាត់បំបាត់ក្លិនអាក្រក់(គ្រឿងអប់)ខ្លះ ការច្របាច់តែខ្លះ ការផ្ងូតទឹកខ្លះ ការគក់ច្របាច់ខ្លះ កញ្ចក់ខ្លះ តែសម្រាប់លាបគ្រឿងប្រដាប់ខ្លះ ផ្កាកម្រងគ្រឿងក្រអូបនឹងគ្រឿងលាបខ្លះ គ្រឿងលំអិតសម្រាប់ព្រោះមុខខ្លះ តែសម្រាប់លាបមុខខ្លះ គ្រឿងប្រដាប់ដៃខ្លះ ចំណងផ្នួងសក់ខ្លះ ដំបងខ្លះ បំពង់ថ្នាំខ្លះ ដាវខ្លះ ព្រះខានខ្លះ ឆត្រខ្លះ ស្បែកជើងដ៏វិចិត្រខ្លះ មកុដ ឬក្បាំងមុខ (ស្នៀតសក់)ខ្លះ កែវមណីខ្លះ ផ្ចិតធ្វើដោយរោមកន្ទុយសត្វខ្លះ សំពត់សខ្លះ សំពត់មានជាយវែងខ្លះ ។ ភិក្ខុជាអ្នកវៀរចាកការប្រកប

សន្ទិដ្ឋានុយោគា បដិវិរតោ ហោតិ ។ ឥទំបិស្ស ហោតិ សីលស្មឹ ។

(១១០) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ តិរច្ឆានកថំ អនុយុត្តា វិហរន្តិ ។ សេយ្យថីទំ ។ រាជកថំ ចោរកថំ មហាមត្តកថំ សេនាកថំ ភយកថំ យុទ្ធកថំ អន្នកថំ បានកថំ វត្ថកថំ សយនកថំ មាលាកថំ គន្ធកថំ ញាតិកថំ យានកថំ គាមកថំ និគមកថំ នគរកថំ ជនបទកថំ ឥត្ថីកថំ បុរិសកថំ សូរកថំ(១) វិសិខាកថំ កុម្ភដ្ឋានកថំ បុព្វបេតកថំ

១ សុរាកថន្តិ កត្ថចិ បោត្ថកេ ទិស្សតិ ។

រឿយ ៗ នូវវត្ថុជាទីតាំងនៃការប្រដាប់ស្អិតស្អាងកាយ មានសភាពដូច្នេះឯង ៗ នេះជាសីលរបស់ភិក្ខុនោះ ៗ

(១១០) មួយទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយ ៗ នូវតិរច្ឆានកថា (ពាក្យនិយាយទទឹងផ្លូវសួគ៌និងផ្លូវព្រះនិព្វាន) មានសភាពដូច្នេះ ៗ តិរច្ឆានកថានោះ តើដូចម្តេចខ្លះ ៗ គឺការនិយាយអំពីស្តេចខ្លះ និយាយអំពីចោរខ្លះ និយាយអំពីអាមាត្យធំខ្លះ និយាយអំពីសេនាទាហានខ្លះ និយាយអំពីភ័យខ្លះ និយាយអំពីចម្បាំងខ្លះ និយាយអំពីបាយម្ហូបចំណីខ្លះ និយាយអំពីទឹកផឹកខ្លះ និយាយអំពីសំពត់ខ្លះ និយាយអំពីទីដេកខ្លះ និយាយអំពីផ្កាកម្រងខ្លះ និយាយអំពីគ្រឿងក្រអូបខ្លះ និយាយអំពីញាតិខ្លះ និយាយអំពីយានខ្លះ និយាយអំពីស្រុកខ្លះ និយាយអំពីនិគមខ្លះ និយាយអំពីនគរខ្លះ និយាយអំពីជនបទខ្លះ និយាយអំពីស្រីខ្លះ និយាយអំពីបុរសខ្លះ និយាយអំពីយោធាដែលក្លៀវក្លាខ្លះ និយាយអំពីច្រកផ្លូវខ្លះ និយាយអំពីកំពង់ទឹកខ្លះ និយាយអំពីញាតិ (ដែលទៅកាន់បរលោកហើយ) ខ្លះ

នានត្តកថំ លោកក្ខាយិកំ សមុទ្ទក្ខាយិកំ ឥតិ ភវាភវកថំ ឥតិ វា ឥតិ ឯវរូបាយ តិរច្ឆានកថាយ បដិវិរតោ ហោតិ ។ ឥទំបិស្ស ហោតិ សីលស្មឹ ។

(១១១) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ វិគ្គាហិកកថំ អនុយុត្តា វិហរន្តិ ។ សេយ្យថីទំ ។ ន ត្វំ ឥមំ ធម្មវិនយំ អាជានាសិ អហំ ឥមំ ធម្មវិនយំ អាជានាមិ កឹ ត្វំ ឥមំ ធម្មវិនយំ អាជានិស្សសិ មិច្ឆាបដិបន្នោ ត្វមសិ អហមស្មិ សម្មាបដិបន្នោ សហិតំ មេ អសហិតន្តេ បុរេ វចនីយំ បច្ឆា អវច

និយាយអំពីពាក្យឥតប្រយោជន៍ មានសភាពផ្សេង ៗ ខ្លះ និយាយអំពីលោកខ្លះ និយាយអំពីសមុទ្រខ្លះ និយាយអំពីសេចក្តីចំរើននិងមិនចំរើនខ្លះ ៗ ភិក្ខុជាអ្នកវៀរចាកតិរច្ឆានកថា មានសភាពដូច្នេះឯង ៗ នេះជាសីលរបស់ភិក្ខុនោះ ៗ

(១១១) មួយទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើន ពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ តែងប្រកបរឿយ ៗ នូវពាក្យប្រណាំងប្រ-ដែង មានសភាពដូច្នេះ ៗ ពាក្យប្រណាំងប្រដែងនោះ តើដូចម្តេចខ្លះ ៗ គឺពាក្យថា អ្នកមិនមែនចេះដឹងនូវធម៌និងវិន័យនេះទេ ខ្ញុំទើបដឹងនូវធម៌និងវិន័យនេះ អ្នកនឹងបានឈ្មោះថាចេះដឹង នូវធម៌និងវិន័យនេះដូចម្តេចបាន អ្នកជាអ្នកប្រតិបត្តិខុស ខ្ញុំទើបជាអ្នកប្រតិបត្តិត្រូវល្អ ពាក្យរបស់ខ្ញុំទើបប្រកបដោយប្រយោជន៍ ពាក្យរបស់អ្នកមិនប្រកបដោយប្រយោជន៍ទេ សំដីដែលគេត្រូវនិយាយមុន អ្នកត្រឡប់ជានិយាយក្រោយវិញ សំដីដែលគេត្រូវ

បច្ឆា វចនីយំ បុរេ អវច អធិចិណ្ណន្តេ វិបរាវត្តំ អារោបិ-
តោ តេ វាទោ និគ្គហិតោសិ ចរ វាទប្បមោក្ខាយ
និព្ពេឋេហិ វា សចេ បហោសីតិ ឥតិ វា ឥតិ
ឯវរូបាយ វិគ្គាហិកកថាយ បដិវិរតោ ហោតិ ។
ឥទំបិស្ស ហោតិ សីលស្មឹ ។

(១១២) យថា វា បនេកេ ភោន្តោ សមណព្រាហ្ម-
ណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបំ
ទូតេយ្យបហិណគមនានុយោគមនុយុត្តា វិហរន្តិ ។
សេយ្យថីទំ ។ រញ្ញំ រាជមហាមត្តានំ ខត្តិយានំ ព្រាហ្ម-
ណានំ គហបតិកានំ កុមារានំ ឥធ គច្ឆ អមុត្រ[១]
គច្ឆ ឥទំ ហរ អមុត្រ ឥទំ អាហរាតិ ឥតិ វា ឥតិ
ឯវរូបា ទូតេយ្យបហិណគមនានុយោគា បដិវិរតោ
ហោតិ ។ ឥទំបិស្ស ហោតិ សីលស្មឹ ។

---

១ ឱ. ម. អមុត្រា ។

និយាយក្រោយ អ្នកត្រឡប់ជានិយាយមុនវិញ ពាក្យផ្ទុយអ្នកប្រព្រឹត្តមក ជាយូរអង្វែងហើយ ទោសគឺសំដីរបស់អ្នក ខ្ញុំបានលើកឡើងហើយ អ្នកជាមនុស្សត្រូវខ្ញុំសង្កត់សង្កិនបាន អ្នកចូរទៅសិក្សាដើម្បីដោះស្រាយ នូវទោសគឺសំដី ឬបើអ្នកអាច ចូរអ្នកដោះស្រាយឲ្យរួចទោសចុះ ។ ភិក្ខុជាអ្នកវៀរចាកពាក្យប្រណាំងប្រជែង មានសភាពដូច្នេះឯង ។ នេះ ជាសីលរបស់ភិក្ខុនោះ ។

(១១២) ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើន ពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះតែងប្រកបរឿយៗ នូវទូតកម្មគឺការនាំសំបុត្រ ឬពាក្យបណ្តាំរបស់គ្រហស្ថ ទឹងការទៅដោយគេបញ្ជូនអំពីផ្ទះមួយទៅផ្ទះ មួយ មានសភាពដូច្នេះ ។ ទូតកម្មជាដើមនោះ តើដូចម្តេចខ្លះ ។ គឺពាក្យដែល ស្តេច មហាមាត្យរបស់ស្តេច ក្សត្រ ព្រាហ្មណ៍ គហបតិ ឬកុមារក្តី បញ្ជូន ទៅថា លោកចូរទៅកន្លែងនេះដូច្នេះក្តី លោកចូរទៅកន្លែងឯណោះដូច្នេះក្តី លោកចូរនាំយករបស់នេះទៅដូច្នេះក្តី លោកចូរនាំយករបស់នេះមកអំពីទី ឯណោះមកដូច្នេះក្តី ។ ភិក្ខុជាអ្នកវៀរចាកការប្រកបរឿយៗ នូវទូតកម្ម គឺការនាំសំបុត្រឬពាក្យបណ្តាំរបស់គ្រហស្ថ ទឹងការទៅដោយគេបញ្ជូនអំពី ផ្ទះមួយទៅផ្ទះមួយ មានសភាពដូច្នេះឯង ។ នេះជាសីលរបស់ភិក្ខុនោះ ។

(១១៣) យថា វា បនេកេ ភោន្តោ សមណ-ព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ កុហកា ច ហោន្តិ លបកា ច នេមិត្តិកា ច និប្បេសិកា ច លាភេន ច លាភំ និជ្ជិគីសិតារោ ឥតិ វា ។ ឥតិ ឯវរូបា កុហនលបនា បដិវិរតោ ហោតិ ។ ឥទំបិស្ស ហោតិ សីលស្មិំ ។

មជ្ឈិមសីលំ និដ្ឋិតំ ។

(១១៤) យថា វា បនេកេ ភោន្តោ សមណ-ព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិកំ កប្បេន្តិ ។ សេយ្យថីទំ ។ អង្គំ និមិត្តំ ឧប្បាតំ សុបិនំ

(១៦៧) ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើន ពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ ជាអ្នកកុហកគឺញុំាងសត្វលោកឲ្យកោត ឲ្យស្ញើច (ឲ្យជ្រះថ្លាដោយការប្រើប្រាស់បច្ច័យជាដើម) ខ្លះ ជាអ្នកនិ-យាយរកទាក់ (នឹងគ្រហស្ថ) ខ្លះ ជាអ្នកធ្វើនិមិត្តគឺពោលបញ្ចិតបញ្ចៀង ខ្លះ ជាអ្នកដេរប្រទេចខ្លះ ជាអ្នកស្វែងរកនូវលាភដោយលាភខ្លះ ។ ភិក្ខុ ជាអ្នកវៀរចាកការកុហក នឹងការនិយាយរកទាក់ មានសភាពដូច្នេះ ឯង ។ នេះជាសីលរបស់ភិក្ខុនោះ ។

ចប់ មជ្ឈិមសីល ។

(១៦៨) ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើន ពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ គឺចិញ្ចឹមជីវិតខុស ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះៗ តិរច្ឆានវិជ្ជានោះ តើដូចម្តេចខ្លះៗ គឺសាស្ត្រា (ក្បួន) និយាយអំពីអវយវៈខ្លះ ទាយនិមិត្តគឺហេតុខ្លះ ឧត្បាត គឺការធ្លាក់ចុះនៃហេតុធំ ៗ មានរន្ទះបាញ់ជាដើមខ្លះ ទាយយល់សប្តិខ្លះ

លក្ខណំ មូសិកច្ឆិន្នំ អគ្គិហោមំ ទព្វិហោមំ ថុសហោមំ

កណហោមំ តណ្ឌុលហោមំ សប្បិហោមំ តេលហោមំ

មុខហោមំ លោហិតហោមំ អង្គវិជ្ជា វត្ថុវិជ្ជា ខេត្តវិជ្ជា

សិវវិជ្ជា ភូតវិជ្ជា ភូរិវិជ្ជា អហិវិជ្ជា វិសវិជ្ជា វិច្ឆិកវិជ្ជា

មូសិកវិជ្ជា សកុណវិជ្ជា វាយសវិជ្ជា បក្កជ្ឈានំ

សរបរិត្តាណំ មិគចក្កំ(១) ឥតិ វា ឥតិ ឯវរូបាយ

តិរច្ឆានវិជ្ជាយ មិច្ឆាជីវា បដិវិរតោ ហោតិ ។ ឥទម្បិស្ស

ហោតិ សីលស្មឹ ។

---

១ ឱ. ម. មិគបក្កំ ។

ទាយលក្ខណៈខ្លះ ទាយវត្ថុដែលកណ្ដុរកាត់ (សំពត់ជាដើម) ខ្លះ និយាយអំពីការបូជាដោយភ្លើងខ្លះ និយាយអំពីការបូជាដោយវែកខ្លះ និយាយអំពីការបូជាដោយអង្កាមខ្លះ និយាយអំពីការបូជាដោយកុណ្ឌកខ្លះ និយាយអំពីការបូជាដោយអង្ករខ្លះ និយាយអំពីការបូជាដោយទឹកដោះរាវខ្លះ និយាយអំពីការបូជាដោយប្រេងខ្លះ និយាយអំពីការបូជាដោយមាត់(១)ខ្លះ និយាយអំពីការបូជាដោយឈាមខ្លះ វិជ្ជាសម្រាប់ទាយនូវអវយវៈខ្លះ វិជ្ជាសម្រាប់ទាយភូមិឋានខ្លះ វិជ្ជាសម្រាប់ទាយទីស្រែចំការខ្លះ វិជ្ជាស្គាល់ព្រៃខ្មោចខ្លះ វិជ្ជាចាប់ខ្មោចខ្លះ វិជ្ជាសម្រាប់ការពាររក្សាភូមិផ្ទះខ្លះ វិជ្ជាស្ដោះពស់(២)ខ្លះ វិជ្ជារក្សាពិសខ្លះ វិជ្ជាស្ដោះខ្ទួយទិចខ្លះ វិជ្ជាស្ដោះកណ្ដុរខាំខ្លះ វិជ្ជាសម្រាប់ទាយសម្រែកសត្វស្លាបខ្លះ វិជ្ជាសម្រាប់ទាយសម្រែកក្អែកខ្លះ វិជ្ជាសម្រាប់ទាយអាយុខ្លះ វិជ្ជាសម្រាប់ពកាំងនូវសរខ្លះ វិជ្ជាសម្រាប់មើល នូវស្នាមជើងម្រឹគគឺសត្វជើង ៤ ទាំងអស់ខ្លះ ។ ភិក្ខុជាអ្នកវៀរចាកការចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ។ នេះជាសីលរបស់ភិក្ខុនោះ ។

---

១ អដ្ឋកថា ថា យកមាត់ខាំវត្ថុមានគ្រាប់ស្ពៃជាដើម យកទៅដាក់ក្នុងភ្លើង ឬសូត្ររបៀនបូជាដោយមាត់ ។ ២ វិជ្ជាមើលសត្វ ដែលពស់ខាំ ឬហៅពស់ ។

(១១៨) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិកំ កប្បេន្តិ ។ សេយ្យថីទំ ។ មណិលក្ខណំ វត្ថលក្ខណំ ទណ្ឌលក្ខណំ សត្ថលក្ខណំ អសិលក្ខណំ(១) ឧសុលក្ខណំ ធនុលក្ខណំ អាវុធលក្ខណំ ឥត្ថីលក្ខណំ បុរិសលក្ខណំ កុមារលក្ខណំ កុមារីលក្ខណំ ទាសលក្ខណំ ទាសីលក្ខណំ ហត្ថិលក្ខណំ អស្សលក្ខណំ មហិសលក្ខណំ ឧសភលក្ខណំ គោលក្ខណំ អជលក្ខណំ មេណ្ឌលក្ខណំ កុក្កុដលក្ខណំ វដ្ដកលក្ខណំ គោធាលក្ខណំ កណ្ណិកលក្ខណំ កច្ឆបលក្ខណំ មិគលក្ខណំ ឥតិ វា ។ ឥតិ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវា បដិវិរតោ ហោតិ ។ ឥទំបិស្ស ហោតិ សីលស្មឹ ។

---

១ ឱ. មណិលក្ខណំ ទណ្ឌលក្ខណំ វត្ថលក្ខណំ អសិលក្ខណំ ។ ម. មណិលក្ខណំ ទណ្ឌលក្ខណំ សត្ថលក្ខណំ អសិលក្ខណំ ។

(១១៤) ម្យ៉ាងទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះ ៗ តិរច្ឆានវិជ្ជានោះ តើដូចម្តេចខ្លះ ៗ គឺការទាយលក្ខណៈកែវមណីខ្លះ ទាយលក្ខណៈសំពត់ខ្លះ ទាយលក្ខណៈដម្បងឬឈើច្រត់ខ្លះ ទាយលក្ខណៈគ្រឿងសស្ត្រាខ្លះ ទាយលក្ខណៈដាវខ្លះ ទាយលក្ខណៈសរខ្លះ ទាយលក្ខណៈធ្នូខ្លះ ទាយលក្ខណៈអាវុធខ្លះ ទាយលក្ខណៈស្រីខ្លះ ទាយលក្ខណៈបុរសខ្លះ ទាយលក្ខណៈក្មេងប្រុសខ្លះ ទាយលក្ខណៈក្មេងស្រីខ្លះ ទាយលក្ខណៈខ្ញុំប្រុសខ្លះ ទាយលក្ខណៈខ្ញុំស្រីខ្លះ ទាយលក្ខណៈដំរីខ្លះ ទាយលក្ខណៈសេះខ្លះ ទាយលក្ខណៈក្របីខ្លះ ទាយលក្ខណៈគោឧសភខ្លះ ទាយលក្ខណៈគោខ្លះ ទាយលក្ខណៈពពែខ្លះ ទាយលក្ខណៈកែះខ្លះ ទាយលក្ខណៈមាន់ខ្លះ ទាយលក្ខណៈចាបឬក្រួចខ្លះ ទាយលក្ខណៈរូបគំនូរឬគ្រឿងប្រដាប់ធ្វើដោយរូបទន្សងខ្លះ ទាយលក្ខណៈគ្រឿងប្រដាប់ឬកំពូលផ្ទះខ្លះ ទាយលក្ខណៈរូបគំនូរឬគ្រឿងប្រដាប់ធ្វើដោយរូបអណ្តើកខ្លះ ទាយលក្ខណៈម្រឹគ គឺសត្វជើង ៤ ទាំងអស់ខ្លះ ៗ ភិក្ខុជាអ្នកវៀរចាកមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ៗ នេះជាសីលរបស់ភិក្ខុនោះ ៗ

(១១៦) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិកំ កប្បេន្តិ ។ សេយ្យថីទំ ។ រញ្ញំ និយ្យានំ ភវិស្សតិ រញ្ញំ អនិយ្យានំ ភវិស្សតិ អព្ភន្តរានំ រញ្ញំ ឧបយានំ ភវិស្សតិ ពាហិរានំ រញ្ញំ អបយានំ ភវិស្សតិ ពាហិរានំ រញ្ញំ ឧបយានំ ភវិស្សតិ អព្ភន្តរានំ រញ្ញំ អបយានំ ភវិស្សតិ អព្ភន្តរានំ រញ្ញំ ជយោ ភវិស្សតិ ពាហិរានំ រញ្ញំ បរាជយោ ភវិស្សតិ ពាហិរានំ រញ្ញំ ជយោ ភវិស្សតិ អព្ភន្តរានំ រញ្ញំ បរាជយោ ភវិស្សតិ ឥតិ ឥមស្ស ជយោ ភវិស្សតិ ឥមស្ស បរាជយោ ភវិស្សតិ ឥតិ វា ឥតិ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវា បដិវិរតោ ហោតិ ។ ឥទម្បិស្ស ហោតិ សីលស្មឹ ។

(១១៧) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិកំ កប្បេន្តិ ។ សេយ្យថីទំ ។ ចន្ទគ្គាហោ ភវិស្សតិ សុរិយគ្គាហោ

## សាមញ្ញផលសូត្រ សីលក្ខន្ធកថា មហាសីល

(១៦១) ម្យ៉ាងទៀត ដូចជា សមណព្រាហ្មណ៍ទាំងឡាយដ៏ចំរើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះ ៗ តិរច្ឆានវិជ្ជានោះ តើដូចម្តេចខ្លះ ៗ គឺការទាយអំពីការលើកទ័ពថា ព្រះរាជាគួរស្តេចចេញទៅ (ក្នុងថ្ងៃនោះ) ព្រះរាជាគួរស្តេចត្រឡប់មកវិញ (ក្នុងថ្ងៃនោះ) ព្រះរាជាខាងក្នុងនឹងរុករានចូលទៅ ព្រះរាជាខាងក្រៅនឹងថយចេញទៅ ព្រះរាជាខាងក្រៅនឹងរុករានចូលមក ព្រះរាជាខាងក្នុងនឹងថយចេញទៅ ព្រះរាជាខាងក្នុងនឹងមានជ័យជំនះ ព្រះរាជាខាងក្រៅនឹងបរាជ័យ ព្រះរាជាខាងក្រៅនឹងមានជ័យជំនះ ព្រះរាជាខាងក្នុងនឹងបរាជ័យ ព្រះរាជាអង្គនេះនឹងមានជ័យជំនះ ព្រះរាជាអង្គនេះនឹងបរាជ័យ ៗ ភិក្ខុជាអ្នកវៀរចាកមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ៗ នេះជាសីលរបស់ភិក្ខុនោះ ៗ

(១១៧) មួយវិញទៀត ដូចជាសមណព្រាហ្មណ៍ទាំងឡាយ ដ៏ចំរើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះ ៗ តិរច្ឆានវិជ្ជានោះ តើដូចម្តេចខ្លះ ៗ គឺការទាយថា (ក្នុងថ្ងៃឯណោះ) នឹងមានចន្ទគ្រាះ នឹងមានសូរ្យគ្រាះ នឹង

ភវិស្សតិ នក្ខត្តគ្គាហោ ភវិស្សតិ ចន្ទិមសុរិយានំ បថគមនំ ភវិស្សតិ ចន្ទិមសុរិយានំ ឧប្បថគមនំ ភវិស្សតិ នក្ខត្តានំ បថគមនំ ភវិស្សតិ នក្ខត្តានំ ឧប្បថគមនំ ភវិស្សតិ ឧក្កាបាតោ ភវិស្សតិ ទិសាឌាហោ ភវិស្សតិ ភូមិចាលោ ភវិស្សតិ ទេវទុន្ទុភិ ភវិស្សតិ ចន្ទិមសុរិយនក្ខត្តានំ ឧគ្គមនំ ឱគ្គមនំ សង្កិលេសំ វោទានំ ភវិស្សតិ ឯវំវិបាកោ ចន្ទគ្គាហោ ភវិស្សតិ ឯវំវិបាកោ សុរិយគ្គាហោ ភវិស្សតិ ឯវំវិបាកោ នក្ខត្តគ្គាហោ ភវិស្សតិ ឯវំវិបាកំ ចន្ទិមសុរិយានំ បថគមនំ ភវិស្សតិ ឯវំវិបាកំ ចន្ទិមសុរិយានំ ឧប្បថគមនំ ភវិស្សតិ ឯវំវិបាកំ នក្ខត្តានំ បថគមនំ ភវិស្សតិ ឯវំវិបាកំ នក្ខត្តានំ ឧប្បថគមនំ ភវិស្សតិ ឯវំវិបាកោ ឧក្កាបាតោ ភវិស្សតិ ឯវំវិបាកោ ទិសាឌាហោ ភវិស្សតិ ឯវំវិបាកោ ភូមិចាលោ ភវិស្សតិ

មាននក្សត្រគ្រោះ គឺផ្កាយព្រះគ្រោះដើរមូលគ្នា ឬដើររំលងព្រះអាទិត្យ ព្រះចន្ទ ឬផ្កាយណាមួយ ព្រះចន្ទព្រះអាទិត្យនឹងដើរតាមផ្លូវត្រូវគ្នា ព្រះចន្ទព្រះអាទិត្យ នឹងដើរខុសផ្លូវគ្នា ផ្កាយតាំងឡាយនឹងដើរតាមផ្លូវត្រូវគ្នា ផ្កាយតាំងឡាយនឹងដើរខុសផ្លូវគ្នា នឹងមានឧក្កាបាត[1]នឹងកើតមានកំដៅក្តៅទិស នឹងមានកម្រើកផែនដី នឹងមានផ្គរលាន់ (ឥតមានភ្លៀង) ព្រះចន្ទព្រះអាទិត្យផ្កាយនឹងរះឡើង ឬលិចទៅវិញនឹងសៅហ្មងឬផូរផង់ ចន្ទគ្រាះនឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ សូរ្យគ្រាះនឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ នក្សត្រគ្រាះនឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ ព្រះចន្ទនឹងព្រះអាទិត្យដើរតាមផ្លូវត្រូវគ្នា នឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ ព្រះចន្ទនឹងព្រះអាទិត្យ ដើរខុសផ្លូវគ្នា នឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ ពួកផ្កាយដើរតាមផ្លូវត្រូវគ្នា នឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ ពួកផ្កាយដើរខុសផ្លូវគ្នា នឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ ឧក្កាបាតនឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ កំដៅក្តៅទិសនឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ ការកម្រើកផែនដីនឹងបណ្ដាលឲ្យមានសុខទុក្ខយ៉ាងនេះ

---

១ ក្នុងសីលន្តប្បកាសនាដីកាថា កាលបើអាកាសមានខ្យល់ទង្គិចគ្នាខ្លាំង ក៏កើតមានពន្លឺរស្មី ដូចជាពន្លឺប្រទីបធ្លាក់ចុះមកអំពីអាកាស ហៅថា ឧក្កាបាត ។

ឯវំវិបាកោ ទេវទុន្ទុភិ ភវិស្សតិ ឯវំវិបាកំ ចន្ទិមសុរិយនក្ខត្តានំ ឧគ្គមនំ ឱគ្គមនំ សង្កិលេសំ វោទានំ ភវិស្សតិ ឥតិ វា ឥតិ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវា បដិវិរតោ ហោតិ ។ ឥទំបិស្ស ហោតិ សីលស្មឹ ។

(១១៨) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិកំ កប្បេន្តិ ។ សេយ្យថីទំ ។ សុវុដ្ឋិកា ភវិស្សតិ ទុព្វុដ្ឋិកា ភវិស្សតិ សុភិក្ខំ ភវិស្សតិ ទុព្ភិក្ខំ ភវិស្សតិ ខេមំ ភវិស្សតិ ភយំ ភវិស្សតិ រោគោ ភវិស្សតិ អារោគ្យំ ភវិស្សតិ មុទ្ទា គណនា សង្ខានំ កាវេយ្យំ លោកាយតំ(១) ឥតិ វា ឥតិ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវា បដិវិរតោ ហោតិ ។ ឥទំបិស្ស ហោតិ សីលស្មឹ ។

---

១ លោកាយតន្តិ កត្ថចិ បោត្ថកេ ទិស្សតិ ។

ផ្គរលាន់ (ឥតមានភ្លៀង) នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ព្រះចន្ទ ព្រះអាទិត្យនឹងផ្កាយរះឡើងឬលិចទៅវិញ សៅហ្មងឬផូរផង់នឹងបណ្តាលឲ្យមានសុខទុក្ខយ៉ាងនេះ ៗ ភិក្ខុជាអ្នកវៀរចាកមិច្ឆាជីវៈព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ៗ នេះជាសីលរបស់ភិក្ខុនោះដែរ ៗ

(១១៨) មួយវិញទៀត ដូចជា សមណព្រាហ្មណ៍ទាំងឡាយ ដ៏ចំរើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធា ហើយ តែសមណព្រាហ្មណ៍ទាំងនោះ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះ ៗ តិរច្ឆានវិជ្ជានោះ តើដូចម្តេចខ្លះ ៗ គឺការទាយថា (ក្នុងឆ្នាំនោះ) នឹងមានភ្លៀងធ្លាក់ស្រួល នឹងមានភ្លៀងធ្លាក់ មិនស្រួល នឹងមានបាយសម្បូណ៌ នឹងមានបាយក្រ នឹងមានសេចក្តីក្សេមក្សាន្ត នឹងមានភ័យ នឹងមានរោគ នឹងមិនមានរោគ ការរាប់ដោយដៃទទេ ការរាប់ដោយវិធីទន្ត រាប់បូក(១) កាព្យឃ្លោង គម្ពីរលោកាយតៈ ៗ ភិក្ខុជាអ្នកវៀរចាកមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ៗ នេះជាសីលរបស់ភិក្ខុនោះដែរ ៗ

---

១ អដ្ឋកថា ថា ការរាប់នេះបើស្គាល់ដល់បុគ្គលណា បុគ្គលនោះកាលបើឃើញដើមឈើ ក៏អាចនឹងដឹងថា ឈើនេះមានស្លឹកប៉ុណ្ណេះ ៗ បាន ។

(១១៩) យថា វា បនេកេ ភោន្តោ សមណព្រាហ្មណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិកំ កប្បេន្តិ ។ សេយ្យថីទំ ។ អាវាហនំ វិវាហនំ សំវទនំ វិវទនំ សង្កិរណំ វិកិរណំ សុភគករណំ ទុព្ភគករណំ វិរុទ្ធគព្ភករណំ ជិវ្ហានិពន្ធនំ(១) ហនុសំហននំ ហត្ថាភិជប្បនំ(២) កណ្ណជប្បនំ អាទាសបញ្ហំ កុមារីបញ្ហំ ទេវបញ្ហំ អាទិច្ចុបដ្ឋានំ មហតុបដ្ឋានំ អព្ភុជ្ជលនំ សិរិវ្ហាយនំ ឥតិ វា ។ ឥតិ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវា បដិវិរតោ ហោតិ ។ ឥទម្បិស្ស ហោតិ សីលស្មឹ ។

---

១ ឱ. ជិវ្ហានិពទ្ធំ ។ ២ ម. ឯត្ថន្តរេ ហនុជប្បនន្តិ បាឋោ ទិស្សតិ ។

(១១៩) មួយវិញទៀត ដូចជា សមណព្រាហ្មណ៍ទាំងឡាយ ដ៏ចំរើនពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលគេឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះ ៗ តិរច្ឆានវិជ្ជានោះ តើដូចម្តេចខ្លះ ៗ គឺវិធីរៀបអាពាហមង្គលខ្លះ វិធីរៀបវិវាហមង្គលខ្លះ វិធីធ្វើឲ្យព្រមព្រៀងគ្នា (ស្នេហ៍) ខ្លះ វិធីធ្វើឲ្យព្រាត់ប្រាសគ្នា (បង់ចំណែង) ខ្លះ វិធីប្រមូលទ្រព្យខ្លះ វិធីប្រកបជំនួញខ្លះ វិធីធ្វើឲ្យចូលចិត្តស្រឡាញ់គ្នា ឬធ្វើឲ្យមានសិរីខ្លះ វិធីធ្វើឲ្យស្អប់គ្នាខ្លះ វិធីធ្វើគភ៌ដែលបំរុងនឹងវិនាសមិនឲ្យវិនាសខ្លះ វិធីចងអណ្តាតឲ្យរឹងដោយមន្តខ្លះ វិធីចងចង្កាឲ្យរឹងខ្លះ វិធីសូត្ររបៀនដើម្បីផ្លាស់ប្តូរដៃខ្លះ វិធីសូត្ររបៀនដើម្បីមិនឲ្យឮសម្លេងដោយត្រចៀកខ្លះ ប្រស្នាកញ្ចក់ គឺមន្តខាបយកទេវតាឲ្យមកនៅនឹងកញ្ចក់ ហើយសួរប្រស្នាខ្លះ ប្រស្នាកុមារី គឺមន្តបញ្ចូលទេវតាក្នុងសរីរៈនៃកុមារី ហើយសួរប្រស្នាខ្លះ ប្រស្នាទេវតា គឺមន្តបញ្ចូលទេវតាក្នុងសរីរៈនៃទាសី ហើយសួរប្រស្នាខ្លះ វិធីបម្រើព្រះអាទិត្យខ្លះ វិធីបម្រើមហាព្រហ្មខ្លះ វិធីបញ្ចេញភ្លើងអំពីមាត់ដោយមន្តខ្លះ វិធីហៅសិរីឲ្យឋិតក្នុងសរីរៈខ្លះ ៗ ភិក្ខុជាអ្នកវៀរចាកមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ៗ នេះជាសីលរបស់ភិក្ខុនោះដែរ ៗ

(១៦០) យថា វា បនេកេ ភោន្តោ សមណព្រាហ្ម-ណា សទ្ធាទេយ្យានិ ភោជនានិ ភុញ្ជិត្វា តេ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវេន ជីវិកំ កប្បេន្តិ ។ សេយ្យថីទំ ។ សន្តិកម្មំ បណិធិកម្មំ ភូតកម្មំ ភូរិកម្មំ(១) វស្សកម្មំ វោស្សកម្មំ វត្ថុកម្មំ វត្ថុបរិកិរណំ(២) អាចមនំ នហាបនំ ជុហនំ វមនំ វិរេចនំ ឧទ្ធំវិរេចនំ អធោវិរេចនំ សីសវិរេចនំ កណ្ណតេលំ នេត្តប្បានំ(៣) នត្ថុកម្មំ អញ្ជនំ បច្ចញ្ជនំ សាលាកិយំ សល្លកត្តិយំ ទារកតិកិច្ឆំ(៤) មូលភេ-សជ្ជានំ អនុប្បទានំ ឱសធីនំ បដិមោក្ខោ ឥតិ វា ។ ឥតិ ឯវរូបាយ តិរច្ឆានវិជ្ជាយ មិច្ឆាជីវា បដិវិរតោ ហោតិ ។ ឥទម្បិស្ស ហោតិ សីលស្មឹ ។

---

១ ឱ. ភូរិកម្មំ ភូតិកម្មំ ។ ម. ភូតកម្មំ ភូរិកម្មំ ។ ២ ម. វត្ថុបរិកម្មំ ។ ឱ. វត្ថុបដិកិរណំ ។ ៣ ឱ. នេត្តតប្បនំ ។ ម. នេត្តបានំ ។ ៤ ឱ. ម. ទារកតិកិច្ឆា ។

(១៦០) ម្យ៉ាងទៀត ដូចជា សមណព្រាហ្មណ៍ទាំងឡាយ ដ៏ចំរើន ពួកមួយ បរិភោគនូវភោជនទាំងឡាយ ដែលទាយកឲ្យដោយសទ្ធាហើយ តែសមណព្រាហ្មណ៍ទាំងនោះ ចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជាមានសភាពដូច្នេះ ៗ តិរច្ឆានវិជ្ជានោះ តើដូចម្តេចខ្លះ ៗ គឺការបន់ស្រន់ខ្លះ ការលាបំណន់ខ្លះ ធ្វើមន្តសម្រាប់ការពារបិសាចខ្លះ ធ្វើមន្តសម្រាប់ការពារផ្ទះខ្លះ ធ្វើខ្ទើយឲ្យដូចជាបុរសខ្លះ ធ្វើបុរសឲ្យដូចជាខ្ទើយខ្លះ ធ្វើពិធីសង់ផ្ទះលើទីដីដែលមិនធ្លាប់បានធ្វើខ្លះ ធ្វើពលិកម្មនៅទីដីដែលសង់ផ្ទះខ្លះ ជំរះមុខឲ្យស្អាតដោយទឹកឲ្យគេខ្លះ បង្កក់ប្រសិទ្ធឲ្យគេខ្លះ បូជាភ្លើងឲ្យគេខ្លះ ធ្វើថ្នាំសម្រាប់ឲ្យក្អួតខ្លះ ធ្វើថ្នាំបញ្ចុះខ្លះ ធ្វើថ្នាំកំចាត់បង់នូវទោសខាងលើខ្លះ ធ្វើថ្នាំកំចាត់បង់នូវទោសខាងក្រោមខ្លះ ធ្វើថ្នាំកំចាត់បង់ នូវទោស ក្នុងក្បាលខ្លះ ស្លប្រេងសម្រាប់បន្តក់ត្រចៀកខ្លះ ធ្វើថ្នាំសម្រាប់ស្អំភ្នែកខ្លះ ធ្វើថ្នាំសម្រាប់ហិតខ្លះ ធ្វើថ្នាំសម្រាប់លាបបង្អាត់ខ្លះ ធ្វើថ្នាំត្រជាក់សម្រាប់ស្រលាបខ្លះ ធ្វើវេជ្ជកម្មរក្សាភ្នែកខ្លះ ធ្វើពេទ្យវះខ្លះ ធ្វើពេទ្យរក្សាក្មេងខ្លះ ដាក់ថ្នាំក្រោយឲ្យជួយកម្លាំងថ្នាំមុនខ្លះ លាងថ្នាំដើមចេញខ្លះ(១) ៗ ភិក្ខុជាអ្នកវៀរចាកមិច្ឆាជីវៈ ព្រោះតិរច្ឆានវិជ្ជា មានសភាពដូច្នេះឯង ៗ នេះជាសីលរបស់ភិក្ខុនោះដែរ ៗ

---

១ អដ្ឋកថា ថា កាលបើមានជម្ងឺដាក់ថ្នាំ មានថ្នាំផ្សំជាដើមក្នុងជម្ងឺនោះ កាលបើជម្ងឺស្រួលសមគួរហើយ ក៏នាំយកថ្នាំនោះចេញ ។

(១២១) ស(១) ខោ សោ មហារាជ ភិក្ខុ ឯវំ សីលសម្បន្នោ ន កុតោចិ ភយំ សមនុបស្សតិ យទិទំ សីលសំវរតោ ។ សេយ្យថាបិ មហារាជ ខត្តិយោ មុទ្ធាវសិត្តោ និហតបច្ចាមិត្តោ ន កុតោចិ ភយំ សមនុបស្សតិ យទិទំ បច្ចត្ថិកតោ ឯវមេវ ខោ មហារាជ ភិក្ខុ ឯវំ សីលសម្បន្នោ ន កុតោចិ ភយំ សមនុបស្សតិ យទិទំ សីលសំវរតោ ។ សោ ឥមិនា អរិយេន សីលក្ខន្ធេន សមន្នាគតោ អជ្ឈត្តំ អនវជ្ជសុខំ បដិសំវេទេតិ ។ ឯវំ ខោ មហារាជ ភិក្ខុ សីលសម្បន្នោ ហោតិ ។

មហាសីលំ និដ្ឋិតំ ។

---

១ សោតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

[១៦១] បពិត្រមហាបពិត្រ ភ័យណាដែលគប្បីកើតឡើង ព្រោះសេចក្ដីសង្រួមក្នុងសីល ភិក្ខុនោះឯងបរិបូណ៌ដោយសីល យ៉ាងនេះហើយ រមែងមិនបានឃើញនូវភ័យនោះ អំពីទីណាមួយឡើយ ។ បពិត្រមហាបពិត្រ ប្រៀបដូចជាភ័យណា ដែលគប្បីកើតឡើងអំពីសត្រូវ ក្សត្រិយ៍ដែលបានមុទ្ធាភិសេក(១) ហើយកំចាត់បង់នូវពួកសត្រូវអស់ហើយ រមែងមិនបានឃើញភ័យនោះ អំពីទីណាមួយឡើយ ដូចម្ដេចមិញ បពិត្រមហាបពិត្រ ភ័យណា ដែលគប្បីកើតឡើង ព្រោះសេចក្ដីសង្រួម ក្នុងសីល ភិក្ខុអ្នកបរិបូណ៌ដោយសីល យ៉ាងនេះហើយ រមែងមិនបានឃើញ នូវភ័យនោះ អំពីទីណាមួយឡើយ ដូច្នោះឯង ។ ភិក្ខុនោះ បើបានប្រកបដោយសីលក្ខន្ធជារបស់ព្រះអរិយៈនេះហើយ រមែងទទួលនូវសេចក្ដីសុខ ដែលមិនមានទោសក្នុងសន្ដានចិត្តនៃខ្លួន ។ បពិត្រមហាបពិត្រ ភិក្ខុជាអ្នកបរិបូណ៌ដោយសីល យ៉ាងនេះឯង ។

ចប់ មហាសីល ។

---

១ ព្រះរាជាដែលគេបានអភិសេកស្រោចទឹកលើព្រះសិរ្ស, ឡើងសោយរាជ្យរួចហើយ ។

(១៦៦) កថញ្ច មហារាជ ភិក្ខុ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោតិ ។ ឥធ មហារាជ ភិក្ខុ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ចក្ខុន្ទ្រិយំ ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ ។ សោតេន សទ្ទំ សុត្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ សោតិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ សោតិន្ទ្រិយំ សោតិន្ទ្រិយេ សំវរំ អាបជ្ជតិ ។ ឃានេន គន្ធំ ឃាយិត្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ ឃានិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ ឃានិន្ទ្រិយំ

## សាមញ្ញផលសូត្រ សេចក្តីសង្រួមក្នុងឥន្ទ្រិយ

(១៦២) បពិត្រមហារាជ ភិក្ខុដែលជាអ្នករក្សា នូវទ្វារក្នុងឥន្ទ្រិយទាំងឡាយ តើដូចម្តេចខ្លះ ។ បពិត្រមហារាជ ភិក្ខុក្នុងសាសនានេះ បានឃើញរូបដោយចក្ខុហើយ តែមិនកាន់យកនូវនិមិត្ត មិនកាន់យក នូវអនុព្យញ្ជនៈ ឯអភិជ្ឈានឹងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមក តែងតែគ្របសង្កត់នូវបុគ្គល ដែលមិនបានសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួមនូវចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវចក្ខុន្ទ្រិយនោះ រក្សា នូវចក្ខុន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងចក្ខុន្ទ្រិយ ។ ឮសម្លេងដោយត្រចៀកហើយ តែមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ ឯអភិជ្ឈានឹងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមក តែងតែគ្របសង្កត់នូវបុគ្គលដែលមិនសង្រួមនូវសោតិន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួម នូវសោតិន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវសោតិន្ទ្រិយនោះ រក្សានូវសោតិន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងសោតិន្ទ្រិយ ។ បានធុំក្លិនដោយច្រមុះហើយ តែមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ ឯអភិជ្ឈានឹងទោ-មនស្ស ដែលជាអកុសលធម៌ដ៏លាមក តែងតែគ្របសង្កត់នូវបុគ្គលដែលមិនបានសង្រួមនូវឃានិន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួមនូវឃានិន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវឃានិន្ទ្រិយនោះ រក្សានូវឃានិន្ទ្រិយ ដល់នូវ

ឃានិន្ទ្រិយេ សំវរំ អាបជ្ជតិ ។ ជិវ្ហាយ រសំ សាយិត្វា
ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណ-
មេនំ ជិវ្ហិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា
អកុសលា ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ
រក្ខតិ ជិវ្ហិន្ទ្រិយំ ជិវ្ហិន្ទ្រិយេ សំវរំ អាបជ្ជតិ ។ កាយេន
ផោដ្ឋព្វំ ផុសិត្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី
យត្វាធិករណមេនំ កាយិន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈា-
ទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ
តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ កាយិន្ទ្រិយំ កាយិន្ទ្រិយេ
សំវរំ អាបជ្ជតិ ។ មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី
ហោតិ នានុព្យញ្ជនគ្គាហី យត្វាធិករណមេនំ មនិន្ទ្រិយំ
អសំវុតំ វិហរន្តំ អភិជ្ឈាទោមនស្សា បាបកា អកុសលា
ធម្មា អន្វាស្សវេយ្យុំ តស្ស សំវរាយ បដិបជ្ជតិ រក្ខតិ មនិ-
ន្ទ្រិយំ មនិន្ទ្រិយេ សំវរំ អាបជ្ជតិ ។ សោ ឥមិនា អរិយេន

សេចក្តីសង្រួមក្នុងឃានិន្ទ្រិយ ។ បានជញ្ជក់ជញ្ជាបនូវរសដោយអណ្តាតហើយ តែមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ ឯអភិជ្ឈានិងទោមនស្សដែលជាអកុសលធម៌ដ៏លាមក តែងតែគ្របសង្កត់នូវបុគ្គលដែលមិនបានសង្រួមនូវជិវ្ហិន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួមនូវជិវ្ហិន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវជិវ្ហិន្ទ្រិយនោះ រក្សានូវជិវ្ហិន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងជិវ្ហិន្ទ្រិយ ។ បានពាល់ត្រូវនូវសម្ផស្សដោយកាយហើយ តែមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ ឯអភិជ្ឈានិងទោមនស្សដែលជាអកុសលធម៌ដ៏លាមក តែងតែគ្របសង្កត់នូវបុគ្គលដែលមិនបានសង្រួមនូវកាយិន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួម នូវកាយិន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួម នូវកាយិន្ទ្រិយនោះ រក្សានូវកាយិន្ទ្រិយ ដល់នូវសេចក្តីសង្រួមក្នុងកាយិន្ទ្រិយ ។ បានដឹងច្បាស់នូវធម្មារម្មណ៍ដោយចិត្តហើយ តែមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ ឯអភិជ្ឈានិងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមក តែងតែគ្របសង្កត់នូវបុគ្គល ដែលមិនបានសង្រួម នូវមនិន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួមនូវមនិន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសង្រួមនូវមនិន្ទ្រិយនោះ រក្សានូវមនិន្ទ្រិយ ដល់នូវសេចក្តីសង្រួម ក្នុងមនិន្ទ្រិយ ។ ភិក្ខុនោះ

ឥន្ទ្រិយសំវរេន សមន្នាគតោ អជ្ឈត្តំ អព្យាសេកសុខំ បដិសំវេទេតិ ។ ឯវំ ខោ មហារាជ ភិក្ខុ ឥន្ទ្រិយេសុ គុត្តទ្វារោ ហោតិ ។

(១២៣) កថញ្ច មហារាជ ភិក្ខុ សតិសម្បជញ្ញេន សមន្នាគតោ ហោតិ ។ ឥធ មហារាជ ភិក្ខុ អភិក្កន្តេ បដិក្កន្តេ សម្បជានការី ហោតិ អាលោកិតេ វិលោកិតេ សម្បជានការី ហោតិ សមិញ្ជិតេ បសារិតេ សម្បជានការី ហោតិ សង្ឃាដិបត្តចីវរធារណេ សម្បជានការី ហោតិ អសិតេ បីតេ ខាយិតេ សាយិតេ សម្បជានការី ហោតិ ឧច្ចារបស្សាវកម្មេ សម្បជានការី ហោតិ គតេ ឋិតេ និសិន្នេ សុត្តេ ជាគរិតេ ភាសិតេ តុណ្ហីភាវេ សម្បជានការី ហោតិ ។ ឯវំ ខោ មហារាជ ភិក្ខុ សតិសម្បជញ្ញេន សមន្នាគតោ ហោតិ ។

(១២៤) កថញ្ច មហារាជ ភិក្ខុ សន្តុដ្ឋោ ហោតិ ។ ឥធ មហារាជ ភិក្ខុ សន្តុដ្ឋោ ហោតិ កាយបរិហារិកេន ចីវរេន កុច្ឆិបរិហារិកេន បិណ្ឌបាតេន សោ យេន

បានប្រកបព្រមដោយឥន្ទ្រិយសំវរៈ ជារបស់អរិយៈនេះហើយ រមែងទទួលចំពោះនូវសុខ ដែលមិនប្រឡូកប្រឡំដោយកិលេសជាខាងក្នុង ។ បពិត្រមហារាជ ភិក្ខុជាអ្នករក្សានូវទ្វារក្នុងឥន្ទ្រិយទាំងឡាយ យ៉ាងនេះឯង ។

(១៦៣) បពិត្រមហារាជ ឯភិក្ខុជាអ្នកប្រកបដោយសតិនឹងសម្បជញ្ញៈនោះ តើដូចម្តេចខ្លះ ។ បពិត្រមហារាជ ភិក្ខុក្នុងសាសនានេះ កាលឈានដើរទៅមុខ ឈានថយក្រោយ ក៏មានសេចក្តីដឹងខ្លួន កាលក្រឡេកមើលទៅមុខ ក្រឡេកមើលទៅទិសផ្សេង ៗ ក៏មានសេចក្តីដឹងខ្លួន កាលបត់លា (ដៃជើង) ក៏មានសេចក្តីដឹងខ្លួន កាលទ្រទ្រង់នូវសង្ឃាដិ បាត្រ ចីវរ ក៏មានសេចក្តីដឹងខ្លួន កាលបរិភោគផឹក ទំពា ជញ្ជក់ជញ្ជាប ក៏មានសេចក្តីដឹងខ្លួន កាលបន្ទោឧច្ចារៈបស្សាវៈ ក៏មានសេចក្តីដឹងខ្លួន កាលដើរ ឈរ អង្គុយ ដេកលក់ ភ្ញាក់ពីដេក និយាយឬស្ងៀម ក៏មានសេចក្តីដឹងខ្លួន ។ បពិត្រមហារាជ ភិក្ខុជាអ្នកប្រកប ដោយសតិនឹងសម្បជញ្ញៈ ដោយប្រការដូច្នេះឯង ។

(១៦៤) បពិត្រមហារាជ ឯភិក្ខុជាអ្នកសន្តោស (ត្រេកអរចំពោះបច្ច័យតាមមានតាមបាន) តើដូចម្តេចខ្លះ ។ បពិត្រមហារាជ ភិក្ខុក្នុងសាសនានេះ ជាអ្នកសន្តោសដោយចីវរ ដែលជាគ្រឿងរក្សានូវកាយ ដោយចង្ហាន់បិណ្ឌបាត ដែលជាគ្រឿងរក្សានូវផ្ទៃ ភិក្ខុនោះកាលបើចៀស

យេនេវ បក្កមតិ សមាទាយេវ បក្កមតិ ។ សេយ្យថាបិ មហារាជ បក្ខី សកុណោ យេន យេនេវ ឌេតិ សបត្តភារោវ ឌេតិ ឯវមេវ ខោ មហារាជ ភិក្ខុ សន្តុដ្ឋោ ហោតិ កាយបរិហារិកេន ចីវរេន កុច្ឆិបរិហារិកេន បិណ្ឌបាតេន សោ យេន យេនេវ បក្កមតិ សមាទាយេវ បក្កមតិ ។ ឯវំ ខោ មហារាជ ភិក្ខុ សន្តុដ្ឋោ ហោតិ ។

(១២៨) សោ ឥមិនា ច អរិយេន សីលក្ខន្ធេន សមន្នាគតោ ឥមិនា ច អរិយេន ឥន្ទ្រិយសំវរេន សមន្នាគតោ ឥមិនា ច អរិយេន សតិសម្បជញ្ញេន សមន្នាគតោ ឥមាយ ច អរិយាយ សន្តុដ្ឋិយា សមន្នាគតោ វិវិត្តំ សេនាសនំ ភជតិ អរញ្ញំ រុក្ខមូលំ បព្វតំ កន្ទរំ គិរិគុហំ សុសានំ វនបត្ថំ(១) អព្ភោកាសំ បលាលបុញ្ជំ ។ សោ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ និសីទតិ បល្លង្កំ អាភុជិត្វា ឧជុំ កាយំ បណិធាយ បរិមុខំ សតឹ ឧបដ្ឋបេត្វា ។ សោ អភិជ្ឈំ លោកេ បហាយ វិគតាភិជ្ឈេន ចេតសា វិហរតិ អភិជ្ឈាយ ចិត្តំ បរិសោធេតិ

---

១ វនសណ្ឌន្តិ កត្ថចិ បោត្ថកេ ទិស្សតិ ។

ចេញទៅក្នុងទិសណា ៗ តែងកាន់យក (នូវបរិក្ខារ) ប៉ុណ្ណោះ ហើយចៀសចេញទៅ (ក្នុងទិសនោះៗ) ។ បពិត្រមហារាជ ប្រៀបដូចសត្វសកុណ-ជាតិ មានស្លាប ទោះហើរទៅក្នុងទិសណា ៗ រមែងមានស្លាបរបស់ខ្លួនជាភារៈប៉ុណ្ណោះ ហើរទៅ ដូចម្តេចមិញ បពិត្រមហារាជ ភិក្ខុជាអ្នកសន្តោស ដោយចីវរ ដែលជាគ្រឿងរក្សានូវកាយ ដោយចង្ហាន់បិណ្ឌបាត ដែលជាគ្រឿងរក្សានូវផ្ទៃ ភិក្ខុនោះ ទោះបីចៀសចេញទៅ ក្នុងទិសណា ៗ តែងកាន់យក (នូវគ្រឿងបរិក្ខារ) ប៉ុណ្ណោះ ហើយចៀសចេញទៅ (ក្នុងទិសនោះ ៗ) ដូច្នោះឯង ។ បពិត្រមហារាជ ភិក្ខុជាអ្នកសន្តោស ដោយប្រការដូច្នេះឯង ។

(១២៨) ភិក្ខុនោះប្រកបដោយសីលក្ខន្ធ ជារបស់ព្រះអរិយៈនេះផង ប្រកបដោយឥន្ទ្រិយសំវរៈ ជារបស់ព្រះអរិយៈនេះផង ប្រកបដោយសតិនឹងសម្បជញ្ញៈ ជារបស់ព្រះអរិយៈនេះផង ប្រកបដោយសេចក្តីសន្តោសជារបស់ព្រះអរិយៈនេះផង ត្រូវការទីសេនាសនៈស្ងាត់ គឺព្រៃ ម្លប់ឈើ ភ្នំ ជ្រោះភ្នំ គុហាភ្នំ ព្រៃស្មសាន ព្រៃស្បាត ទីវាល ទីគំនរចំបើង ។ លុះភិក្ខុនោះត្រឡប់មកអំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្ត ក៏ពត់ភ្នែនតម្រង់កាយឲ្យត្រង់ ប្រុងស្មារតីឲ្យមានមុខឆ្ពោះ(ទៅរកកម្មដ្ឋាន)។ ភិក្ខុនោះរមែងលះបង់នូវអភិជ្ឈាក្នុងលោកនៅដោយចិត្តគ្មានអភិជ្ឈា ជំរះចិត្តឲ្យស្អាត ចាកអភិជ្ឈា

ព្យាបាទបទោសំ បហាយ អព្យាបន្នចិត្តោ វិហរតិ សព្វបាណភូតហិតានុកម្បី ព្យាបាទបទោសា ចិត្តំ បរិសោធេតិ ថីនមិទ្ធំ បហាយ វិគតថីនមិទ្ធោ វិហរតិ អាលោកសញ្ញី សតោ សម្បជានោ ថីនមិទ្ធា ចិត្តំ បរិសោធេតិ ឧទ្ធច្ចកុក្កុច្ចំ បហាយ អនុទ្ធតោ វិហរតិ អជ្ឈត្តំ វូបសន្តចិត្តោ ឧទ្ធច្ចកុក្កុច្ចា ចិត្តំ បរិសោធេតិ វិចិកិច្ឆំ បហាយ តិណ្ណវិចិកិច្ឆោ វិហរតិ អកថង្កថី កុសលេសុ ធម្មេសុ វិចិកិច្ឆាយ ចិត្តំ បរិសោធេតិ ។

(១៦៦) សេយ្យថាបិ មហារាជ បុរិសោ ឥណំ អាទាយ កម្មន្តេ បយោជេយ្យ តស្ស តេ កម្មន្តា សមិជ្ឈេយ្យុំ សោ យានិ ច បោរាណានិ ឥណមូលានិ តានិ ច ព្យន្តីករេយ្យ[១] សិយា ចស្ស ឧត្តរឹ អវសិដ្ឋំ ទារភរណាយ[២] តស្ស ឯវមស្ស អហំ ខោ បុព្វេ ឥណមាទាយ កម្មន្តេ បយោជេសឹ តស្ស មេ តេ កម្មន្តា សមិជ្ឈឹសុ សោហំ យានិ ច បោរាណានិ ឥណមូលានិ តានិ ច ព្យន្តីអកាសឹ

---

១ ម. ព្យន្តិ ករេយ្យ ។ ២ ឱ. ទាភរណាយ ។

រមែងលះបង់នូវព្យាបាទនឹងសេចក្តីប្រទូស្ត នៅដោយចិត្តមិនមានព្យាបាទ ជាអ្នកមានសេចក្តីអនុគ្រោះដោយប្រយោជន៍ ដល់សត្វមានជីវិតទាំងពួង ជំរះចិត្តឲ្យស្អាតចាកអកុសលធម៌ ជាគ្រឿងប្រទូស្តគឺព្យាបាទ រមែងលះបង់នូវថីនមិទ្ធៈ គឺសេចក្តីងងុយងោកងក់ នៅដោយចិត្តប្រាសចាកថីនមិទ្ធៈ ជាអ្នកមានសេចក្តីសំគាល់នូវពន្លឺ មានស្មារតី នឹងសេចក្តីដឹងខ្លួន ជំរះចិត្តឲ្យស្អាតចាកថីនមិទ្ធៈ រមែងលះបង់ នូវឧទ្ធច្ចកុក្កុច្ចៈ គឺសេចក្តីរាយមាយសោយចិត្ត នៅដោយចិត្តមិនរាយមាយ ជាអ្នកមានចិត្តស្ងប់រម្ងាប់ខាងក្នុង ជំរះចិត្តឲ្យស្អាតចាកឧទ្ធច្ចកុក្កុច្ចៈ រមែងលះបង់នូវវិចិកិច្ឆា គឺសេចក្តីងឿងឆ្ងល់ នៅដោយចិត្តឆ្លងផុតវិចិកិច្ឆា ជាអ្នកមិនមានសេចក្តីសង្ស័យ ក្នុងកុសលធម៌ ជំរះចិត្តឲ្យស្អាតចាកវិចិកិច្ឆា ។

(១២៦) បពិត្រមហារាជ ប្រៀបដូចបុរស ដែលយកទ្រព្យជាបំណុលគេទៅប្រកបការងារទាំងឡាយ ការងារទាំងនោះរបស់បុរសនោះក៏សម្រេច បុរសនោះក៏ចាត់ចែងសងនូវទ្រព្យចាស់ ជាបំណុលអស់ទៅ ទ្រព្យចំណេញរបស់បុរសនោះ ក៏មានសល់នៅច្រើន ល្មមនឹងចិញ្ចឹមនូវភរិយាបាន បុរសនោះក៏មានសេចក្តីត្រិះរិះ យ៉ាងនេះថា អាត្មាអញកាលពីដើម យកទ្រព្យជាបំណុលគេទៅប្រកបការងារ ៗ ទាំងអម្បាលនោះ របស់អាត្មាអញ ក៏បានសម្រេចហើយ អាត្មាអញ បានចាត់ចែងសងនូវទ្រព្យចាស់ ជាបំណុលដើមរួចអស់ហើយ ទ្រព្យចំណេញរបស់

អត្ថិ ច មេ ឧត្តរឹ អវសិដ្ឋំ នាគរណាយត្តន្តិ ។ សោ តតោ និទានំ លភេថ បាមោជ្ជំ អធិគច្ឆេយ្យ[1] សោមនស្សំ ។ សេយ្យថាបិ មហារាជ បុរិសោ អាពាធិកោ អស្ស ទុក្ខិតោ ពាឡ្ហគិលានោ ភត្តញ្ចស្ស នច្ឆាទេយ្យ ន ចស្ស កាយេ ពលមត្តា ។ សោ អបរេន សមយេន តម្ហា អាពាធា មុច្ចេយ្យ ភត្តញ្ចស្ស ឆាទេយ្យ សិយា ចស្ស កាយេ ពលមត្តា តស្ស ឯវមស្ស អហំ ខោ បុព្វេ អាពាធិកោ អហោសឹ ទុក្ខិតោ ពាឡ្ហគិលានោ ភត្តញ្ច មេ ន ឆាទេសិ ន ច មេ អាសិ កាយេ ពលមត្តា សោហម្ហិ ឯតរហិ តម្ហា អាពាធា មុត្តោ ភត្តញ្ច មេ ឆាទេតិ អត្ថិ ច មេ កាយេ ពលមត្តាតិ ។ សោ តតោ និទានំ លភេថ បាមោជ្ជំ អធិគច្ឆេយ្យ សោមនស្សំ ។ សេយ្យថាបិ មហារាជ បុរិសោ ពន្ធនាគារេ ពទ្ធោ អស្ស សោ អបរេន សមយេន តម្ហា ពន្ធនា មុច្ចេយ្យ សោត្ថិនា អព្ភយេន ន ចស្ស កិញ្ចិ

---

១ អធិគច្ឆតិបិ ឍាហេ ។

អាត្មាអញក៏មានសល់នៅជាច្រើន ល្មមនឹងចិញ្ចឹមភរិយាបានដែរ ។ បុរសនោះគប្បីបាននូវបាមោជ្ជៈ (សេចក្តីរីករាយ) គប្បីបាននូវសេចក្តីសោមនស្ស ដែលមានទ្រព្យបំណេញនោះជាហេតុ ។ បពិត្រមហារាជ មួយទៀត ប្រៀបដូចបុរស មានអាពាធ ដល់នូវសេចក្តីទុក្ខ ឈឺធ្ងន់ ហើយបុរសនោះបរិភោគបាយមិនឆ្ងាញ់ផង កម្លាំងក្នុងកាយរបស់បុរសនោះ ក៏មិនមានផង ៗ សម័យខាងក្រោយមក បុរសនោះក៏សះស្បើយ អំពីអាពាធនោះ បុរសនោះ បានបរិភោគបាយឆ្ងាញ់ផង កម្លាំងក្នុងកាយរបស់បុរសនោះ ក៏មានផង ទើបបុរសនោះមានសេចក្តីត្រិះរិះ យ៉ាងនេះថា អាត្មាអញកាលអំពីដើម មានអាពាធ ដល់នូវសេចក្តីទុក្ខ ឈឺធ្ងន់ អាត្មាអញបរិភោគបាយមិនឆ្ងាញ់ផង កម្លាំងក្នុងកាយរបស់អាត្មាអញ ក៏មិនមានផង ឥឡូវនេះ អាត្មាអញបានសះស្បើយអំពីអាពាធនោះហើយ អាត្មាអញបានបរិភោគបាយឆ្ងាញ់ផង កម្លាំងក្នុងកាយរបស់អាត្មាអញក៏មានផង ៗ បុរសនោះ ក៏បាននូវបាមោជ្ជៈ បាននូវសេចក្តីសោមនស្ស ដែលមានការសះស្បើយអំពីអាពាធនោះជាហេតុ ។ បពិត្រមហារាជ មួយទៀត ប្រៀបដូចបុរសដែលជាប់នៅ ក្នុងផ្ទះឃុំខាំង សម័យខាងក្រោយមក បុរសនោះក៏រួចអំពីការឃុំខាំងនោះ ដោយស្រួល មិនមានភ័យ ឯសេចក្តីបង់ខាតនៃភោគៈទាំងឡាយ របស់បុរសនោះ សូម្បីបន្តិចបន្តួច ក៏មិនមាន

ភោគានំ វយោ តស្ស ឯវមស្ស អហំ ខោ បុព្វេ ពន្ធនាគារេ ពទ្ធោ អហោសឹ សោម្ហិ ឯតរហិ តម្ហា ពន្ធនា មុត្តោ សោត្ថិនា អព្ភយេន នត្ថិ ច មេ កិញ្ចិ ភោគានំ វយោតិ ។ សោ តតោនិទានំ លភេថ បាមោជ្ជំ អធិគច្ឆេយ្យ សោមនស្សំ ។ សេយ្យថាបិ មហារាជ បុរិសោ ទាសោ អស្ស អនត្តាធីនោ បរាធីនោ ន យេនកាមង្គមោ សោ អបរេន សមយេន តម្ហា ទាសព្យា មុច្ចេយ្យ អត្តាធីនោ អបរាធីនោ ភុជិស្សោ យេនកាមង្គមោ តស្ស ឯវមស្ស អហំ ខោ បុព្វេ ទាសោ អហោសឹ អនត្តាធីនោ បរាធីនោ ន យេនកាមង្គមោ សោម្ហិ ឯតរហិ តម្ហា ទាសព្យា មុត្តោ អត្តាធីនោ អបរាធីនោ ភុជិស្សោ

ទើបបុរសនោះ មានសេចក្ដីត្រិះរិះ យ៉ាងនេះថា អាត្មាអញ កាលពីដើម បានជាប់នៅក្នុងផ្ទះឃុំខាំង ឥឡូវនេះអាត្មាអញបានរួចអំពីការឃុំខាំងនោះ ដោយស្រួល មិនមានភ័យហើយ ឯសេចក្ដីបង់ខាតនៃភោគៈទាំងឡាយ របស់អាត្មាអញ សូម្បីបន្តិចបន្តួច ក៏មិនមានឡើយ ។ បុរសនោះ ក៏បាននូវមោជ្ជៈ បាននូវសេចក្ដីសោមនស្ស ដែលមានការរួច អំពីផ្ទះឃុំខាំងនោះជាហេតុ ។ បពិត្រមហារាជ មួយទៀត ប្រៀបដូចបុរសដែលជាទាសៈគេ រមែងមិនបានធ្វើកិច្ចការនីមួយតាមអំពើចិត្តខ្លួន រមែងធ្វើទៅតាមសេចក្ដីគាប់ចិត្តរបស់បុគ្គលដទៃ ទៅកាន់ទីណា តាមបំណងរបស់ខ្លួនមិនបានឡើយ លុះសម័យខាងក្រោយមក បុរសនោះ ក៏បានរួចអំពីភាវៈជាទាសៈនោះ ជាអ្នកបានធ្វើនូវអំពើ តាមគាប់ចិត្តរបស់ខ្លួន មិនបានធ្វើទៅតាមសេចក្ដីគាប់ចិត្ត របស់បុគ្គលដទៃ បានរួចជាអ្នកជាទៅកាន់ទីណាតាមបំណងរបស់ខ្លួនបាន ទើបបុរសនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា អាត្មាអញកាលអំពីដើម ជាទាសៈគេ មិនបានធ្វើកិច្ចការនីមួយតាមអំពើចិត្តរបស់ខ្លួន តែងធ្វើទៅតាមសេចក្ដីគាប់ចិត្ត របស់បុគ្គលដទៃ ទៅកាន់ទីណាតាមបំណង របស់ខ្លួនមិនបានឡើយ ឥឡូវនេះអាត្មាអញ បានរួចពីភាវៈជាទាស គេនោះហើយ ជាអ្នកបានធ្វើកិច្ចការនីមួយតាមអំពើចិត្តរបស់ខ្លួន មិនបានធ្វើទៅតាមសេចក្ដីគាប់ចិត្តរបស់បុគ្គលដទៃ

យេនកាមង្គមោតិ ។ សោ តតោនិទានំ លភេថ បា-
មោជ្ជំ អធិគច្ឆេយ្យ សោមនស្សំ ។ សេយ្យថាបិ មហា-
រាជ បុរិសោ សធនោ សភោគោ កន្តារំ អទ្ធានមគ្គំ
បដិបជ្ជេយ្យ ទុព្ភិក្ខំ សប្បដិភយំ សោ អបរេន សម-
យេន តំ កន្តារំ និត្ថរេយ្យ សោត្ថិនា គាមន្តំ អនុបា-
បុណេយ្យ ខេមំ អប្បដិភយំ តស្ស ឯវមស្ស អហំ ខោ
បុព្វេ សធនោ សភោគោ កន្តារំ អទ្ធានមគ្គំ បដិបជ្ជឹ
ទុព្ភិក្ខំ សប្បដិភយំ សោម្ហិ ឯតរហិ តំ កន្តារំ និត្ថិណ្ណោ
សោត្ថិនា គាមន្តំ អនុប្បត្តោ ខេមំ អប្បដិភយន្តិ ។
សោ តតោនិទានំ លភេថ បាមោជ្ជំ អធិគច្ឆេយ្យ
សោមនស្សំ ។ ឯវមេវ ខោ មហារាជ ភិក្ខុ យថា ឥណំ
យថា រោគំ យថា ពន្ធនាគារំ យថា ទាសព្យំ យថា-
កន្តារទ្ធានមគ្គំ ឯវំ ឥមេ បញ្ច នីវរណេ អប្បហីនេ
អត្តនិ សមនុបស្សតិ ។ សេយ្យថាបិ មហារាជ

បានរួចជាអ្នកជា ទៅកាន់ទីណាតាមចំណង់របស់ខ្លួនបាន ។ បុរសនោះ ក៏បាននូវបាមោជ្ជៈ បាននូវសេចក្តីសោមនស្ស ដែលមានការរួចអំពីភាវៈជាទាសៈគេនោះជាហេតុ ។ បពិត្រមហារាជ មួយទៀត ប្រៀបដូចបុរសមានទ្រព្យ មានភោគៈ ដើរទៅកាន់ផ្លូវឆ្ងាយដាច់ស្រយាល ជាផ្លូវរកបាយបានដោយក្រ ប្រកបដោយភ័យចំពោះមុខ សម័យខាងក្រោយមក បុរសនោះ ក៏បានឆ្លងផុត អំពីផ្លូវឆ្ងាយដាច់ស្រយាលនោះ បានដល់ស្រុកភូមិដោយស្រួល ជាទីក្សេម មិនមានភ័យ ទើបបុរសនោះមានសេចក្តីត្រិះរិះ យ៉ាងនេះថា អាត្មាអញកាលអំពីដើម ជាអ្នកមានទ្រព្យ មានភោគៈ ដើរទៅកាន់ផ្លូវឆ្ងាយដាច់ស្រយាល ជាផ្លូវរកបាយបានដោយក្រ ប្រកបដោយភ័យចំពោះមុខ ឥឡូវនេះ អាត្មាអញបានឆ្លងផុតផ្លូវឆ្ងាយដាច់ស្រយាលនោះហើយ បានដល់ស្រុកភូមិដោយស្រួល ជាទីក្សេម មិនមានភ័យ ។ បុរសនោះ ក៏បាននូវបាមោជ្ជៈ បាននូវសេចក្តីសោមនស្ស ដែលមានការបានដល់នូវស្រុកភូមិជាទីក្សេមនោះជាហេតុ ។ បពិត្រមហារាជ ភិក្ខុពិចារណាឃើញនូវនីវរណៈ ៥ នេះក្នុងខ្លួន ដែលមិនទាន់លះបង់ យ៉ាងនេះថាដូចជាបំណុល ដូចជារោគ ដូចជាផ្ទះសម្រាប់ឃុំខាំង ដូចជាភាវៈជាទាសៈ ឬថាដូចជាផ្លូវឆ្ងាយដាច់ស្រយាល យ៉ាងនោះឯង ។ បពិត្រមហារាជ ដូចបុគ្គលពិចារណាឃើញ នូវការមិនជំពាក់បំណុលគេយ៉ាងណា នូវការ

យថា អាណណ្យំ យថា អារោគ្យំ យថា ពន្ធនាមោក្ខំ យថា ភុជិស្សំ យថា ខេមន្តភូមឹ ឯវមេវ ខោ មហារាជ ភិក្ខុ ឥមេ បញ្ច នីវរណេ បហីនេ អត្តនិ សមនុបស្សតិ ។

(១២៧) តស្សិមេ បញ្ច នីវរណេ បហីនេ អត្តនិ សមនុបស្សតោ បាមោជ្ជំ ជាយតិ បមុទិតស្ស បីតិ ជាយតិ បីតិមនស្ស កាយោ បស្សម្ភតិ បស្សទ្ធកាយោ សុខំ បដិសំវេទេតិ(១) សុខិនោ ចិត្តំ សមាធិយតិ ។ សោ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥមមេវ កាយំ វិវេកជេន បីតិសុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស វិវេកជេន បីតិសុខេន អប្ផុដំ(២) ហោតិ ។ សេយ្យថាបិ មហារាជ

១ ឱ, ម. វេទេតិ ។ ២ ឱ. អប្ផុតំ ។

មិនមានរោគ យ៉ាងណា នូវការរួចអំពីផ្ទះសម្រាប់ឃុំខាំង យ៉ាងណា នូវភាពជាអ្នកជា យ៉ាងណា នូវទីដីក្សេមក្សាន្ត យ៉ាងណា បពិត្រមហារាជ ភិក្ខុពិចារណាឃើញនូវនីវរណៈ ៥ នេះក្នុងខ្លួន ដែលបានលះបង់ហើយ ក៏យ៉ាងនោះឯង ។

(១២៧) កាលបើភិក្ខុនោះ បានពិចារណាឃើញច្បាស់នូវនីវរណៈ ទាំង ៥ នេះក្នុងខ្លួន ដែលបានលះបង់ហើយ បាមោជ្ជៈ (សេចក្តីរីករាយ) ក៏កើតឡើង កាលបើ ចិត្តរីករាយហើយ បីតិក៏កើត កាលបើ ចិត្តប្រកបដោយបីតិហើយ នាមកាយ រមែងស្ងប់ស្ងាត់ ភិក្ខុដែលមាននាមកាយ ស្ងប់ស្ងាត់ហើយ រមែងទទួលនូវសុខ ចិត្តរបស់ភិក្ខុ ដែលប្រកបដោយសុខ តែងតម្កល់មាំបាន ។ ភិក្ខុនោះ លុះស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយហើយ ក៏បានដល់នូវបឋមជ្ឈានប្រកបដោយវិតក្កៈ ប្រកបដោយវិចារៈ មានបីតិនិងសុខៈដែលកើតអំពីវិវេក ក៏សម្រេចសម្រាន្តនៅ (ដោយឥរិយាបថទាំង ៤) ។ ភិក្ខុនោះ រមែងញុំាងកាយនេះឲ្យជ្រួតជ្រាប ឲ្យឆ្អែតស្កប់ស្កល់ បរិបូណ៌ ផ្សព្វផ្សាយ ដោយបីតិនិងសុខៈដែលកើតអំពីវិវេក សរីរដ្ឋានបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថាមិនបានផ្សព្វផ្សាយ ដោយបីតិនិងសុខៈ ដែលកើតអំពីវិវេក មិនមានឡើយ ។ បពិត្រមហារាជ ប្រៀបដូចជា

ទក្ខោ ន្ហាបកោ វា ន្ហាបកន្តេវាសី វា កំសថា-
លេ ន្ហានីយចុណ្ណានិ អាកិរិត្វា ឧទកេន បរិប្ផោសកំ
សន្នេយ្យ សាយំ ន្ហានីយបិណ្ឌិ ស្នេហានុគតា ស្នេ-
ហបរេតា សន្តរពាហិរា ផុដា[១] ស្នេហេន ន ច
បគ្ឃរិណី ឯវមេវ ខោ មហារាជ ភិក្ខុ ឥមមេវ កាយំ
វិវេកជេន បីតិសុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ
បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស វិវេកជេន
បីតិសុខេន អប្ផុដំ ហោតិ ។ ឥទម្បិ ខោ មហារាជ
សន្ទិដ្ឋិកំ សាមញ្ញផលំ បុរិមេហិ សន្ទិដ្ឋិកេហិ សា-
មញ្ញផលេហិ អភិក្កន្តតរញ្ច បណីតតរញ្ច ។

(១២៨) បុន ចបរំ មហារាជ ភិក្ខុ វិតក្កវិចារានំ
វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ
អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយជ្ឈានំ ឧប-
សម្បជ្ជ វិហរតិ ។ សោ ឥមមេវ កាយំ សមាធិជេន

---

១ ផុដ្ឋាតិបិ បាឋោ ។

អ្នកផ្ងូតទឹកក្តី បុគ្គលអ្នកជំនួយការនៃជនអ្នកផ្ងូតទឹកក្តី ដែលឈ្លាសរោយនូវលំអិតសម្រាប់ងូតទាំងឡាយ ក្នុងភាជន៍សំរិទ្ធិ ប្រោះព្រំដោយទឹក ហើយសូនជាដុំ លុះដល់វេលាល្ងាច ដុំលំអិតសម្រាប់(លាប)ងូត(នោះ) ក៏ស្អិតជាប់ចូលគ្នា ស្អិតល្អួតទាំងខាងក្នុងទាំងខាងក្រៅ មិនបានកក់កាយខ្ចាយចេញឡើយ យ៉ាងណាមិញ បពិត្រមហារាជ ភិក្ខុដែលញុំាងកាយនេះ ឲ្យជ្រួតជ្រាប ឆ្អែតស្កប់ស្កល់ បរិបូណ៌ ផ្សព្វផ្សាយ ដោយបីតិនិងសុខ ដែលកើតអំពីវិវេក សរីរដ្ឋានបន្តិចបន្តួច នៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថា មិនបានផ្សព្វផ្សាយដោយបីតិនិងសុខៈ ដែលកើតអំពីវិវេក មិនមានឡើយ យ៉ាងនោះឯង ។ បពិត្រមហារាជ នេះឯង ជាផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ដ៏រុងរឿងដោយវិសេសផង ថ្លៃថ្លាដោយវិសេសផង ជាងផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ដូចបានពោលមកខាងដើម ។

(១២៨) បពិត្រមហារាជ ប្រការមួយទៀត ភិក្ខុបានចូលដល់ទុតិយជ្ឈាន ជាធម្មជាតកើតមានក្នុងសន្តានចិត្ត ប្រកបដោយសេចក្តីជ្រះថ្លា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខៈដែលកើតអំពីសមាធិ ព្រោះរម្ងាប់នូវវិតក្ក និងវិចារៈ ក៏សម្រេចសម្រាន្តនៅ ។ ភិក្ខុនោះ រមែងញុំាងកាយនេះ ឲ្យជ្រួតជ្រាប ឆ្អែតស្កប់

សាមញ្ញផលសុត្តេ ទុតិយជ្ឈានំ ឧទករហទោបមា

បីតិសុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស សមាធិជេន បីតិសុខេន អប្ផុដំ ហោតិ ។ សេយ្យថាបិ មហារាជ ឧទករហទោ គម្ភីរោ ឧព្ភិទោទកោ(១) តស្ស នេវស្ស បុរត្ថិមាយ ទិសាយ ឧទកស្ស អាយមុខំ ន ទក្ខិណាយ ទិសាយ ឧទកស្ស អាយមុខំ ន បច្ឆិមាយ ទិសាយ ឧទកស្ស អាយមុខំ ន ឧត្តរាយ ទិសាយ ឧទកស្ស អាយមុខំ ទេវោ ច(២) ន កាលេន កាលំ សម្មាធារំ អនុប្បវេច្ឆេយ្យ អថខោ តម្ហា ច(៣) ឧទករហទា សីតា វារិធារា(៤) ឧព្ភិជ្ជិត្វា តមេវ ឧទករហទំ សីតេន វារិនា អភិសន្ទេយ្យ បរិសន្ទេយ្យ បរិបូរេយ្យ បរិប្ផរេយ្យ នាស្ស កិញ្ចិ សព្វាវតោ ឧទករហទស្ស សីតេន វារិនា អប្ផុដំ អស្ស ឯវមេវ ខោ មហារាជ ភិក្ខុ ឥមមេវ កាយំ សមាធិជេន បីតិសុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូ-រេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស ស-មាធិជេន បីតិសុខេន អប្ផុដំ ហោតិ ។ ឥទំបិ ខោ

---

១ ឧ. ឧព្ភិទោទកោ ។ ២ ឧ. ម. ច ។ ៣ ឧ. ចសទ្ទោ ន ទិស្សតិ ។ ម. ច ។ ៤ ឧ. សីតវារិធារា ។

## សាមញ្ញផលសូត្រ ទុតិយជ្ឈាន សេចក្តីប្រៀបដោយអន្លង់ទឹក

ស្កល់បរិបូណ៌ ផ្សព្វផ្សាយ ដោយបីតិនិងសុខៈដែលកើតអំពីសមាធិ សរីរដ្ឋានបន្តិចបន្តួច នៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថាមិនបានផ្សព្វផ្សាយដោយបីតិនិងសុខៈ ដែលកើតអំពីសមាធិ មិនមានឡើយ ។ បពិត្រមហារាជ ប្រៀបដូចជាអន្លង់ទឹកដ៏ជ្រៅ មានទឹកជោរឡើង ប្រឡាយជាទីហូរមកនៃទឹកក្នុងទិសខាងកើត នៃអន្លង់ទឹកនោះមិនមាន ប្រឡាយជាទីហូរមកនៃទឹកក្នុងទិសខាងត្បូងមិនមាន ប្រឡាយជាទីហូរមកនៃទឹកក្នុងទិសខាងលិចមិនមាន ប្រឡាយជាទីហូរមកនៃទឹកក្នុងទិសខាងជើង ក៏មិនមាន ទាំងភ្លៀងក៏មិនបានបង្អុរចុះនូវធារទឹកដោយស្រួល ក្នុងអន្លង់ទឹកនោះតាមកាលវេលាឡើយ ឯធារទឹកដ៏ត្រជាក់ ក៏ស្រាប់តែជោរឡើងអំពីអន្លង់ទឹកនោះប៉ុណ្ណោះ ហើយញុំាងអន្លង់ទឹកនោះ ឲ្យជ្រួតជ្រាបខ្អួតដ៏បរិបូណ៌ផ្សព្វផ្សាយដោយទឹកត្រជាក់ ទីប្រទេសបន្តិចបន្តួចនៃអន្លង់ទឹក ទាំងអស់នោះឈ្មោះថាមិនបានផ្សព្វផ្សាយដោយទឹកត្រជាក់ មិនមានឡើយ យ៉ាងណាមិញ បពិត្រមហារាជ ភិក្ខុញុំាងកាយនេះឲ្យជ្រួតជ្រាប ខ្អួតស្កប់ស្កល់ បរិបូណ៌ ផ្សព្វផ្សាយ ដោយបីតិនិងសុខៈដែលកើតអំពីសមាធិ សរីរដ្ឋានបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថាមិនបានផ្សព្វផ្សាយដោយបីតិនិងសុខៈ ដែលកើតអំពីសមាធិ មិនមានឡើយ យ៉ាងនោះឯង ។ បពិត្រ

មហារាជ សន្ទិដ្ឋិកំ សាមញ្ញផលំ បុរិមេហិ សន្ទិដ្ឋិកេហិ សាមញ្ញផលេហិ អភិក្កន្តតរញ្ច បណីតតរញ្ច ។

(១៨៩) បុន ចបរំ មហារាជ ភិក្ខុ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរតិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេតិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយជ្ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥមមេវ កាយំ និប្បីតិកេន សុខេន អភិសន្ទេតិ បរិសន្ទេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស និប្បីតិកេន សុខេន អប្ផុដំ ហោតិ ។ សេយ្យថាបិ មហារាជ ឧប្បលិនិយំ វា(១) បទុមិនិយំ វា(២) បុណ្ឌរីកិនិយំ វា(៣) អប្បេកច្ចានិ ឧប្បលានិ វា បទុមានិ វា បុណ្ឌរីកានិ វា ឧទកេ ជាតានិ ឧទកេ សំវឌ្ឍានិ ឧទកានុគ្គតានិ អន្តោនិមុគ្គបោសីនិ(៤) តានិ យាវ ច អគ្គា យាវ ច មូលា សីតេន វារិនា អភិសន្នានិ បរិសន្នានិ បរិបូរានិ បរិប្ផុដានិ(៥)

---

១.២.៣ ឱ. វាសទ្ទោ ន ទិស្សតិ ។ ៤ ឱ. អន្តោនិមុគ្គបោសីនិ ។ ៥ ឱ. បរិប្ផុដ្ឋានិ ។ ម. បរិប្ផុតានិ ។

មហារាជ នេះឯងជាផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ដ៏ប្រសើរដោយវិសេសផង ថ្លៃថ្លាដោយវិសេសផង ជាផលនៃសមណប្បដិបត្តិដែលឃើញច្បាស់ដោយខ្លួនឯង ដូចពោលមកខាងដើម ៗ

(១២៩) បពិត្រមហារាជ ប្រការមួយទៀត ភិក្ខុមានចិត្តនឿយណាយចាកបីតិហើយ ប្រកបដោយឧបេក្ខាមានស្មារតីដឹងខ្លួន បានទទួលនូវសុខ ដោយនាមកាយ ព្រោះអរិយៈទាំងឡាយ តែងសរសើរនូវបុគ្គលដែលបាននូវតតិយជ្ឈានទោះថា បុគ្គលអ្នកបានតតិយជ្ឈាន មានចិត្តប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខ ដូច្នេះ ព្រោះតតិយជ្ឈានណា ក៏បានដល់នូវតតិយជ្ឈាន (នោះ) ហើយសម្រេចសម្រាន្តនៅ ៗ ភិក្ខុនោះ រមែងញ៉ាំងកាយនេះឲ្យជ្រួតជ្រាប ឆ្អែតស្កប់ស្កល់បរិបូណ៌ ផ្សព្វផ្សាយដោយសុខៈ ដែលមិនមានបីតិ សរីរដ្ឋានបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថាមិនបានផ្សព្វផ្សាយដោយសុខៈ ដែលគ្មានបីតិ មិនមានឡើយ ៗ បពិត្រមហារាជ ប្រៀបដូចទីដែលដុះព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី មានព្រលិត ឬឈូកក្រហម ឬឈូកសពួកខ្លះ ដែលដុះក្នុងទឹក ចំរើនក្នុងទឹក មិនទាន់លូតឡើងផុតអំពីទឹក លិចនៅក្នុងទឹក សំនៅអាស្រ័យនឹងទឹក បទុមជាតិ(១)ទាំងនោះ រមែងជ្រួតជ្រាបឆ្អែតស្កប់ស្កល់បរិបូណ៌ផ្សព្វផ្សាយដោយទឹកត្រជាក់ តាំងអំពីឫសមើមរហូតដល់ចុង

---

១ ពួកឈូកព្រលិតផ្សេង ៗ ហៅថា បទុមជាតិ ឬឧប្បលជាតិក៏បាន ។

នាស្ស កិញ្ចិ សព្វាវតំ ឧប្បលានំ វា បទុមានំ វា បុណ្ឌរីកានំ វា សីតេន វារិនា អប្ផុដំ អស្ស ។ ឯវមេវ ខោ មហារាជ ភិក្ខុ ឥមមេវ កាយំ និប្បីតិកេន សុខេន អភិសន្នេតិ បរិសន្នេតិ បរិបូរេតិ បរិប្ផរតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស និប្បីតិកេន សុខេន អប្ផុដំ ហោតិ ។ ឥទំបិ ខោ មហារាជ សន្ទិដ្ឋិកំ សាមញ្ញផលំ បុរិមេហិ សន្ទិដ្ឋិកេហិ សាមញ្ញផលេហិ អភិក្កន្តតរញ្ច បណីតតរញ្ច ។

(១៣០) បុន ចបរំ មហារាជ ភិក្ខុ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហរតិ ។ សោ ឥមមេវ កាយំ បរិសុទ្ធេន ចេតសា បរិយោទាតេន ផរិត្វា និសិន្នោ ហោតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស បរិសុទ្ធេន ចេតសា បរិយោទាតេន អប្ផុដំ ហោតិ ។

ទីប្រទេសបន្តិចបន្តួច នៃកាយជាតិទាំងអស់ ទោះជាព្រលិតក្តី ឈូកក្រហមក្តី ឈូកសក្តី ដែលឈ្មោះថា មិនបានផ្សព្វផ្សាយ ដោយទឹកដ៏ត្រជាក់មិនមានឡើយ យ៉ាងណាមិញ បពិត្រមហាពជ ភិក្ខុដែលញុំាងកាយនេះ ឲ្យជ្រួតជ្រាបខ្ពួតស្អប់ស្អល់បរិបូណ៌ផ្សព្វផ្សាយ ដោយសុខៈដែលមិនមានបីតិ សរីរដ្ឋានបន្តិចបន្តួចនៃកាយទាំងអស់ របស់ភិក្ខុនោះឈ្មោះថា មិនបានផ្សព្វផ្សាយដោយសុខៈ ដែលគ្មានបីតិ មិនមានឡើយ យ៉ាងនោះឯង ។ បពិត្រមហាពជ នេះឯងជាផលនៃសមណបដិបត្តិដែលឃើញច្បាស់ដោយខ្លួនឯង ដ៏វិសេសជាងផលវិសេសផង ថ្លៃថ្លាដោយវិសេសផង ជាងផលនៃសមណបដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯងដូចបានពោលមកខាងដើម ។

(១៣០) បពិត្រមហាពជ ប្រការមួយទៀត ភិក្ខុលះបង់នូវសុខផង លះបង់នូវទុក្ខផង មានសោមនស្សនឹងទោមនស្ស អស់ហើយក្នុងកាលមុន ក៏បាននូវចតុត្ថជ្ឈានដែលមិនមានទុក្ខ មិនមានសុខ មានតែសតិដ៏បរិសុទ្ធដែលកើតអំពីឧបេក្ខា ហើយសម្រេចសម្រាន្តនៅ ។ ភិក្ខុនោះ រមែងញុំាងកាយនេះ ឲ្យផ្សព្វផ្សាយ ដោយចិត្តដ៏បរិសុទ្ធ ផូរផង់អង្គុយនៅ ឯសរីរដ្ឋានបន្តិចបន្តួចនៃកាយទាំងអស់ របស់ភិក្ខុនោះឈ្មោះថា មិនបានផ្សព្វផ្សាយ ដោយចិត្តដ៏បរិសុទ្ធ ផូរផង់ មិនមានឡើយ ។

សេយ្យថាបិ មហារាជ បុរិសោ ឱទាតេន វត្ថេន សសីសំ បារុបិត្វា និសិន្នោ អស្ស នាស្ស កិញ្ចិ សព្វាវតោ កាយស្ស ឱទាតេន វត្ថេន អប្ផុដំ អស្ស ឯវមេវ ខោ មហារាជ ភិក្ខុ ឥមមេវ កាយំ បរិសុទ្ធេន ចេតសា បរិយោទាតេន ផរិត្វា និសិន្នោ ហោតិ នាស្ស កិញ្ចិ សព្វាវតោ កាយស្ស បរិសុទ្ធេន ចេតសា បរិយោទាតេន អប្ផុដំ ហោតិ ។ ឥទំបិ ខោ មហារាជ សន្ទិដ្ឋិកំ សាមញ្ញផលំ បុរិមេហិ សន្ទិដ្ឋិកេហិ សាមញ្ញផលេហិ អភិក្កន្តតរញ្ច បណីតតរញ្ច ។

(១៣១) សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ[១] កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ[២] ញាណទស្សនាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ សោ ឯវំ បជានាតិ អយំ ខោ មេ កាយោ រូបី ចាតុម្មហាភូតិកោ មាតាបេត្តិកសម្ភវោ ឱទនកុម្មាសុបចយោ អនិច្ចុច្ឆាទនប-

១ ឱ. មុទ្ទុភូតេ ។ ២ ឱ. អនេញ្ជប្បត្តេ ។

បពិត្រមហារាជ ប្រៀបដូចបុរសដែលយកសំពត់សស្អាត ទៅដណ្ដប់កាយព្រមទាំងក្បាល ហើយអង្គុយនៅ ឯសរីរដ្ឋានបន្តិចបន្តួចនៃកាយទាំងអស់ របស់បុរសនោះ ឈ្មោះថា មិនបានផ្សព្វផ្សាយដោយសំពត់សស្អាតមិនមានឡើយ យ៉ាងណាមិញ បពិត្រមហារាជ ភិក្ខុដែលញុំាងកាយនេះ ឲ្យផ្សព្វផ្សាយដោយចិត្តដ៏បរិសុទ្ធផូរផង់ អង្គុយនៅ ឯសរីរដ្ឋានបន្តិចបន្តួចនៃកាយទាំងអស់របស់ភិក្ខុនោះ ឈ្មោះថា មិនបានផ្សព្វផ្សាយដោយចិត្តដ៏បរិសុទ្ធផូរផង់មិនមានឡើយ យ៉ាងនោះឯង ។ បពិត្រមហារាជ នេះឯងជាផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ដ៏រុងរឿងដោយវិសេសផង ថ្លៃថ្លាដោយវិសេសផង ជាងផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ដូចបានពោលមកខាងដើម ។

(១៣១) ភិក្ខុនោះ កាលបើចិត្តតាំងមាំបរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម ដល់នូវសេចក្តីមិនញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ រមែងទាញនាំបង្អោនចិត្តទៅ ដើម្បីញាណទស្សនៈ គឺបញ្ញាសម្រាប់ដឹង សម្រាប់ឃើញ ។ ភិក្ខុនោះក៏ដឹងច្បាស់ យ៉ាងនេះថា កាយរបស់អាត្មាអញនេះ មានរូបប្រកបដោយមហាភូតរូប ៤ កើតអំពីមាតានឹងបិតា មានសេចក្តីចំរើនដោយជាតិបាយនឹងនំ ជាសភាវៈមិនទៀង (ទោះបី) មានការលាប

រិមទ្ទនភេទនវិទ្ធំសនធម្មោ ឥទញ្ច បន មេ វិញ្ញាណំ ឯត្ថ និស្សិតំ(១) ឯត្ថ បដិពទ្ធន្តិ ។ សេយ្យថាបិ មហារាជ មណិវេឡុរិយោ សុភោ ជាតិមា អដ្ឋំសោ សុបរិកម្មកតោ អច្ឆោ វិប្បសន្នោ សព្វាការសម្បន្នោ តត្រស្ស សុត្តំ អាវុតំ(២) នីលំ វា បីតំ វា លោហិតំ វា ឱទាតំ វា បណ្ឌុសុត្តំ(៣) វា តមេនំ ចក្ខុមា បុរិសោ ហត្ថេ ករិត្វា បច្ចវេក្ខេយ្យ អយំ ខោ មណិវេឡុរិយោ សុភោ ជាតិមា អដ្ឋំសោ សុបរិកម្មកតោ អច្ឆោ វិប្បសន្នោ សព្វាការសម្បន្នោ តត្រិទំ សុត្តំ អាវុតំ នីលំ វា បីតំ វា លោហិតំ វា(៤) ឱទាតំ វា បណ្ឌុសុត្តំ វាតិ ឯវមេវ ខោ មហារាជ ភិក្ខុ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនីយេ ឋិតេ អានេញ្ជប្បត្តេ ញាណទស្សនាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ

---

១ ឱ. ម. សិតំ ។ ២ អាវុធិត្តំបិ បាឋោ ។ ៣ ឱ. ម. បណ្ឌុសុត្តំ ។ ៤ ម. បីតកំ វា លោហិតកំ វា ។

ដុសខាត់បំបាត់ក្លិនទទឹងគក់ច្របាច់ ក៏គង់មានសេចក្តីបែកធ្លាយ ខ្ចាត់ខ្ចាយទៅជាធម្មតា ក៏ឯវិញ្ញាណរបស់អាត្មាអញនេះសោត អាស្រ័យនៅក្នុងកាយនេះ ជាប់នៅក្នុងកាយនេះ ៗ បពិត្រមហារាជ ប្រៀបដូចកែវមណីនឹងកែវពិទូរ្យដ៏ល្អមានជាតិបរិសុទ្ធ មានជ្រុង ៨ ដែលជាងបានធ្វើល្អហើយ មានសម្បុរភ្លឺថ្លាថ្លុះ បរិបូណ៌ដោយអាការទាំងពួង (មានដុសលាងជាដើម) ប្រសិនបើមានបេស គេដោតទៅនឹងកែវនោះ ជាបេសមានពណ៌ខៀវក្តី លឿងក្តី ក្រហមក្តី សក្តី ជាបេសស៊ីនួនក្តី បុរសដែលមានភ្នែក (ភ្លឺ) គប្បីយកកែវនោះមកដាក់លើដៃ ហើយពិចារណាមើលថា នេះជាកែវមណីនឹងកែវពិទូរ្យដ៏ល្អ មានជាតិបរិសុទ្ធ មានជ្រុង ៨ ដែលជាងបានធ្វើល្អហើយ មានសម្បុរភ្លឺថ្លាថ្លុះ បរិបូណ៌ដោយអាការទាំងពួង នេះជាបេសដែលគេដោតទៅក្នុងកែវនោះ ជាបេសមានពណ៌ខៀវក្តី លឿងក្តី ក្រហមក្តី សក្តី ជាបេសស៊ីនួន់ក្តី (ពិតមែន) យ៉ាងណាមិញ បពិត្រមហារាជ ភិក្ខុកាលបើចិត្តតាំងមាំបរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាវៈជាចិត្តទន់ គួរដល់ភាវនាកម្ម ដល់នូវសេចក្តីមិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏ទាញនាំបង្អោនចិត្តទៅ ដើម្បីញាណទស្សនៈ

សោ ឯវំ បជានាតិ អយំ ខោ មេ កាយោ រូបី ចាតុម្មហាភូតិកោ មាតាបេត្តិកសម្ភវោ ឱទនកុម្មា-សូបចយោ អនិច្ចុច្ឆាទនបរិមទ្ទនភេទនវិទ្ធំសនធម្មោ ឥទញ្ច បន មេ វិញ្ញាណំ ឯត្ថ សិតំ ឯត្ថ បដិព-ទ្ធន្តិ ។ ឥទំបិ ខោ មហារាជ សន្ទិដ្ឋិកំ សាមញ្ញផលំ បុរិមេហិ សន្ទិដ្ឋិកេហិ សាមញ្ញផលេហិ អភិក្កន្តត-រញ្ច បណីតតរញ្ច ។

(១៣២) សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ មនោមយំ អភិនិម្មា-នាយ(១) ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ សោ ឥមម្ហា កាយា អញ្ញំ កាយំ អភិនិម្មិនាតិ រូបឹ មនោ-មយំ សព្វង្គបច្ចង្គឹ អហីនិន្ទ្រិយំ ។ សេយ្យថាបិ មហារាជ បុរិសោ មុញ្ជម្ហា ឦសិកំ(២) បព្វាហេយ្យ(៣) តស្ស

១ ខ. ម. មនោមយំ កាយំ អភិនិម្មិនាយ ។ ២ ខ. ឦសិកំ ។ ឦសិកន្តិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ៣ ខ. បវាហេយ្យ ។

គឺបញ្ញាសម្រាប់ដឹងសម្រាប់ឃើញ ភិក្ខុនោះក៏ដឹងច្បាស់យ៉ាងនេះថា កាយរបស់អាត្មាអញនេះឯង មានរូបប្រកបដោយមហាភូតរូប ៤ កើតអំពីមាតានឹងបិតា មានសេចក្ដីចំរើនដោយជាតិបាយនឹងនំ ជាសភាវៈមិនទៀង (នោះបី)មានការលាបផ្សំខាត់បំបាត់ក្លិននឹងគក់ច្របាច់ ក៏គង់មានសេចក្ដីបែកធ្លាយខ្ចាត់ខ្ចាយជាធម្មតា ក៏ឯវិញ្ញាណ របស់អាត្មាអញនេះសោតអាស្រ័យនៅក្នុងកាយនេះ ជាប់នៅក្នុងកាយនេះ យ៉ាងនោះឯង ។ បពិត្រមហារាជ នេះឯងជាផលនៃសមណបដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ដ៏រុងរឿងដោយវិសេសផង ថ្លៃថ្លាដោយវិសេសផង ជាងផលនៃសមណបដិបត្តិទាំងឡាយ ដែលឃើញច្បាស់ដោយខ្លួនឯង ដូចបានពោលមកខាងដើម ។

(១៣៦) ភិក្ខុនោះកាលបើចិត្តតាំងមាំបរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការនាកម្ម ដល់នូវសេចក្ដីមិនញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ រមែងទាញនាំបង្អោនចិត្តទៅ ដើម្បីនិម្មិតនូវកាយ ដែលសម្រេចអំពីចិត្ត ។ ភិក្ខុនោះ ក៏និម្មិតនូវកាយផ្សេងចេញអំពីកាយនេះ មានរូបដែលសម្រេចអំពីចិត្ត មានអវយវៈធំនឹងអវយវៈតូចសព្វគ្រប់ មានឥន្ទ្រិយមិនថោកថយ បពិត្រមហារាជ ប្រៀបដូចបុរសទាក់ថេ្ចញនូវបណ្ដូល អំពីស្មៅយាប្លង

ឯវមស្ស អយំ មុញ្ជោ អយំ ឦសិកា អញ្ញោ មុញ្ជោ អញ្ញា ឦសិកា មុញ្ជម្ហា ត្វេវ ឦសិកា បព្វូឡ្ហាតិ សេយ្យថា វា(១) បន មហារាជ បុរិសោ អសឹ កោសិយា បវាហេយ្យ តស្ស ឯវមស្ស អយំ អសិ អយំ កោសិ អញ្ញោ អសិ អញ្ញា កោសិ កោសិយា ត្វេវ អសិ បព្វូឡ្ហាតិ សេយ្យថា វា(២) បន មហារាជ បុរិសោ អហឹ ករណ្ឌា ឧទ្ធរេយ្យ តស្ស ឯវមស្ស អយំ អហិ អយំ ករណ្ឌោ អញ្ញោ អហិ អញ្ញោ ករណ្ឌោ ករណ្ឌា ត្វេវ អហិ ឧទ្ធរិតោតិ ឯវមេវ ខោ មហារាជ ភិក្ខុ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ មនោមយំ អភិនិម្មានាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ សោ ឥមម្ហា កាយា អញ្ញំ កាយំ អភិនិម្មិនាតិ រូបឹ មនោមយំ សព្វង្គបច្ចង្គឹ អហីនិន្ទ្រិយំ ។ ឥទំបិ ខោ មហារាជ

១ ២ ម. បុភឡ្ហាតិ សេយ្យថាបិ ។

បុរសនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា នេះជាស្នោយាបូង នេះជាបណ្តូល ស្នោយាបូងដោយឡែក បណ្តូលដោយឡែក តែជាបណ្តូលដែលអាត្មាអញ តាក់បញ្ចេញមកអំពីស្នោយាបូងហ្នឹងឯង យ៉ាងណាមិញ បពិត្រមហាពជ មួយទៀត ប្រៀបដូចបុរស ហូតដាវចេញអំពីស្រោម បុរសនោះមានសេចក្តីត្រិះរិះ យ៉ាងនេះថា នេះជាដាវ នេះជាស្រោម ដាវផ្សេង ស្រោមផ្សេង តែជាដាវដែលអាត្មាអញ ហូតចេញមកអំពីស្រោមហ្នឹងឯង យ៉ាងណាមិញ បពិត្រមហាពជ មួយទៀត ប្រៀបដូចបុរស ទាញយកសត្វពស់ចេញអំពីស្រោម បុរសនោះមានសេចក្តីត្រិះរិះ យ៉ាងនេះថា នេះជាពស់ នេះជាស្រោម សត្វពស់ផ្សេង ស្រោមផ្សេង តែជាពស់ដែលអាត្មាអញ ទាញចេញមកអំពីស្រោមហ្នឹងឯង យ៉ាងណាមិញ បពិត្រមហាពជ ភិក្ខុកាលបើចិត្តតាំងមាំបរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់នូវការនាកម្ម ដល់នូវសេចក្តីមិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ រមែងទាញនាំបង្អោនចិត្តទៅ ដើម្បីនិម្មិតនូវកាយ ដែលសម្រេចអំពីចិត្តបាន យ៉ាងនោះឯង ។ ភិក្ខុនោះ រមែងនិម្មិតនូវកាយផ្សេង ចេញអំពីកាយនេះ មានរូបដែលសម្រេចអំពីចិត្ត មានអវយវៈធំទឹងអវយវៈតូចសព្វគ្រប់ មានឥន្ទ្រិយមិនថោកថយ ។ បពិត្រមហាពជ នេះឯងជាផល

សន្ទិដ្ឋិកំ សាមញ្ញផលំ បុរិមេហិ សន្ទិដ្ឋិកេហិ សា-
មញ្ញផលេហិ អភិក្កន្តតរញ្ច បណីតតរញ្ច ។

(១៣៣) សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ ឥទ្ធិវិធាយ ចិត្តំ អភិនី-
ហរតិ អភិនិន្នាមេតិ សោ អនេកវិហិតំ ឥទ្ធិវិធំ បច្ចនុ-
ភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ពហុធាបិ ហុត្វា ឯកោ ហោតិ អាវិភាវំ តិរោភាវំ តិរោកុឌ្ឌំ តិរោបាការំ តិរោបព្វតំ អសជ្ជមានោ គច្ឆតិ សេយ្យថាបិ អាកាសេ បឋវិយាបិ ឧម្មុជ្ជនិម្មុជ្ជំ ករោតិ សេយ្យថាបិ ឧទកេ ឧទកេបិ អភិជ្ជមានេ គច្ឆតិ សេយ្យថាបិ បឋវិយំ អាកាសេបិ បល្លង្កេន កមតិ សេយ្យថាបិ បក្ខី សកុ-
ណោ ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ

នៃសមណាប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ដ៏ប្រសើរដោយវិសេសផង ថ្លៃថ្លាដោយវិសេសផង ជាងផលនៃសមណប្បដិបត្តិទាំងឡាយ ដែលឃើញច្បាស់ដោយខ្លួនឯង ដូចបានពោលមកខាងដើម ។

(១៣៣) ភិក្ខុនោះ កាលបើចិត្តតាំងមាំ បរិសុទ្ធ ផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការ-នាកម្ម ដល់នូវសេចក្តីមិនញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ ភិក្ខុនោះ រមែងទាញនាំបង្អោនចិត្តទៅ ដើម្បីតាក់តែងឫទ្ធិ ភិក្ខុនោះទទួលនូវការតាក់តែងឫទ្ធិជាច្រើនប្រការបាន គឺជាមនុស្សម្នាក់ធ្វើឲ្យទៅជាច្រើននាក់ក៏បាន មនុស្សច្រើននាក់ធ្វើឲ្យទៅជាម្នាក់ក៏បាន ធ្វើទីកំបាំងឲ្យទៅជាទីវាលក៏បាន ធ្វើទីវាលឲ្យទៅជាទីកំបាំងក៏បាន ដើរ ( ទំលុះ ) ទៅក្រៅជញ្ជាំង ក្រៅកំពែង ក្រៅភ្នំ មិនទើសទាក់ ដូចដើរទៅក្នុងទីវាលក៏បាន ធ្វើនូវការមុជចុះនឹងងើបឡើងក្នុងផែនដី ដូចមុជងើបក្នុងទឹកក៏បាន ដើរទៅលើទឹក មិនបែកធ្លាយទឹក ដូចជាដើរលើផែនដីក៏បាន អណ្តែតទៅឯអាកាសទាំងភ្នែន ដូចជាសត្វស្លាបក៏បាន ចាប់ស្ទាបអង្អែលព្រះចន្ទនឹងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនោះ មានអានុភាពច្រើនយ៉ាងនោះ

បាណិនា បរិមសតិ[១] បរិមជ្ជតិ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ សេយ្យថាបិ មហារាជ ទក្ខោ កុម្ភការោ វា កុម្ភការន្តេវាសី វា សុបរិកម្មកតាយ មត្តិកាយ យំ យទេវ ភាជនវិកតឹ អាកង្ខេយ្យ តន្តទេវ[២] ករេយ្យ អភិនិប្ផាទេយ្យ សេយ្យថា វា បន មហារាជ ទក្ខោ ទន្តការោ វា ទន្តការន្តេវាសី វា សុបរិកម្មកតស្មឹ ទន្តស្មឹ យំ យទេវ ទន្តវិកតឹ អាកង្ខេយ្យ តន្តទេវ ករេយ្យ អភិនិប្ផាទេយ្យ សេយ្យថា វា បន មហារាជ ទក្ខោ សុវណ្ណការោ វា សុវណ្ណការន្តេវាសី វា សុបរិកម្មកតស្មឹ សុវណ្ណស្មឹ យំ យទេវ សុវណ្ណវិកតឹ អាកង្ខេយ្យ តន្តទេវ ករេយ្យ អភិនិប្ផាទេយ្យ ឯវមេវ ខោ មហារាជ ភិក្ខុ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ ឥទ្ធិវិធាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ សោ អនេកវិហិតំ ឥទ្ធិវិធំ

---

១ ម. បរាមសតិ ។ ២ ឱ. ម. តំ តទេវ ។

ដោយដៃក៏បាន ញុំាងអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោកក៏បាន បពិត្រមហារាជ ប្រៀបដូចជាស្មូនឆ្នាំងក្តី អន្តេវាសិកនៃស្មូនឆ្នាំងក្តី ដែលឈ្លាសវៃ កាលបើដីស្អិតដែលគេច្របាច់ល្អហើយ បើចង់ធ្វើនូវភាជន៍ដ៏ប្លែកណា ៗ ក៏គប្បីធ្វើឲ្យសម្រេចទៅជាភាជន៍នោះ ៗ បាន យ៉ាងណាមិញ បពិត្រមហារាជ មួយវិញទៀត ជាងភ្លុកក្តី អន្តេវាសិករបស់ជាងភ្លុកក្តី ដែលឈ្លាសវៃ កាលបើភ្លុកដែលគេធ្វើបរិកម្មល្អហើយ បើចង់ធ្វើនូវគ្រឿងប្រើប្រាស់ ជាវិការៈនៃភ្លុកដ៏ប្លែកណា ៗ ក៏គប្បីធ្វើឲ្យសម្រេចនូវគ្រឿងប្រើប្រាស់ ជាវិការៈនៃភ្លុកដ៏ប្លែកនោះៗ បាន យ៉ាងណាមិញ បពិត្រមហារាជ មួយវិញទៀត ជាងមាសក្តី អន្តេវាសិករបស់ជាងមាសក្តី ដែលឈ្លាសវៃ កាលបើមាសដែលគេធ្វើបរិកម្មល្អហើយ បើចង់ធ្វើនូវគ្រឿងប្រើប្រាស់ ជាវិការៈនៃមាសដ៏ប្លែកណា ៗ ក៏គប្បីធ្វើឲ្យសម្រេចនូវគ្រឿងប្រើប្រាស់ ជាវិការៈនៃមាសដ៏ប្លែកនោះៗបាន យ៉ាងណាមិញ បពិត្រមហារាជ ភិក្ខុកាលបើចិត្តតាំងមាំបរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការភាវនា ដល់នូវសេចក្តីមិនញាប់ញ័រ ទៅតាមអារម្មណ៍យ៉ាងនេះហើយ ក៏រមែងទាញនាំបង្អោនចិត្តទៅ ដើម្បីតាក់តែងនូវឫទ្ធិបានយ៉ាងនោះឯង ។ ភិក្ខុនោះ រមែងទទួលចំពោះនូវការតាក់តែងឫទ្ធិ មានប្រការជាច្រើនបាន

បច្ចនុភោតិ ឯកោបិ ហុត្វា ពហុធា ហោតិ ពហុធាបិ ហុត្វា ឯកោ ហោតិ អាវិភាវំ តិរោភាវំ តិរោកុឌ្ឌំ តិរោបាការំ តិរោបព្វតំ អសជ្ជមានោ គច្ឆតិ សេយ្យថាបិ អាកាសេ បថវិយាបិ ឧម្មុជ្ជនិមុជ្ជំ ករោតិ សេយ្យថាបិ ឧទកេ ឧទកេបិ អភិជ្ជមានេ គច្ឆតិ សេយ្យថាបិ បថវិយំ អាកាសេបិ បល្លង្កេន កមតិ សេយ្យថាបិ បក្ខី សកុណោ ឥមេបិ ចន្ទិមសុរិយេ ឯវំមហិទ្ធិកេ ឯវំមហានុភាវេ បាណិនា បរិមសតិ បរិមជ្ជតិ យាវ ព្រហ្មលោកាបិ កាយេន វសំ វត្តេតិ ។ ឥទំបិ ខោ មហារាជ សន្ទិដ្ឋិកំ សាមញ្ញផលំ បុរិមេហិ សន្ទិដ្ឋិកេហិ សាមញ្ញផលេហិ អភិក្កន្តតរញ្ច បណីតតរញ្ច ។

(១៣៦) សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ ទិព្វាយ សោតធាតុយា ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ សោ ទិព្វាយ សោ-

គឺមនុស្សម្នាក់ ធ្វើឲ្យទៅជាច្រើននាក់ក៏បាន មនុស្សច្រើននាក់ ធ្វើឲ្យទៅជាម្នាក់វិញក៏បាន ធ្វើទីកំបាំងឲ្យទៅជាទីវាលក៏បាន ធ្វើទីវាលឲ្យទៅជាទីកំបាំងក៏បាន ដើរ (ទំលុះ) ទៅក្រៅជញ្ជាំង ក្រៅកំពែង ក្រៅភ្នំ មិនទើសទាក់ ដូចជាដើរទៅក្នុងទីវាលក៏បាន ធ្វើនូវការមុជចុះនិងការងើបឡើងក្នុងផែនដី ដូចជាមុជងើបក្នុងទឹកក៏បាន ដើរទៅលើទឹកមិនបែកធ្លាយទឹក ដូចជាដើរទៅលើផែនដីក៏បាន អណ្ដែតទៅឯអាកាសទាំងភ្នែន ដូចជាសត្វស្លាបក៏បាន ចាប់ស្ទាបអង្អែលព្រះចន្ទនិងព្រះអាទិត្យទាំងនេះ ដែលមានឫទ្ធិច្រើនយ៉ាងនេះ មានអានុភាពច្រើនយ៉ាងនេះ ដោយដៃក៏បាន ញុំាងអំណាចឲ្យប្រព្រឹត្តទៅដោយកាយ ដរាបដល់ព្រហ្មលោកក៏បាន ។ បពិត្រមហារាជ នេះឯងជាផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ដ៏រុងរឿងដោយវិសេសផង ថ្លៃថ្លាដោយវិសេសផង ជាងផលនៃសមណប្បដិបត្តិទាំងឡាយ ដែលឃើញច្បាស់ដោយខ្លួនឯង ដូចបានពោលមកខាងដើម ។

(១៣៤) ភិក្ខុនោះ កាលបើចិត្តតាំងមាំបរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការភាវនា ដល់នូវសេចក្ដីមិនញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ រមែងទាញនាំបង្អោនចិត្តទៅក្នុងសោតធាតុជាទិព្វ ។ ភិក្ខុនោះ កាលបើមាន

ធាតុយា វិសុទ្ធាយ អតិក្កន្តមានុសិកាយ ឧភោ សទ្ទេ សុណាតិ ទិព្វេ ច មានុសេ ច យេ ទូរេ សន្តិកេ ច សេយ្យថាបិ មហារាជ បុរិសោ អទ្ធានមគ្គប្បដិបន្នោ សោ សុណេយ្យ ភេរិសទ្ទំបិ មុទិង្គសទ្ទំបិ សង្ខសទ្ទំបិ បណវសទ្ទំបិ ទេណ្ឌិមសទ្ទំបិ(១) តស្ស ឯវមស្ស ភេរិសទ្ទោ ឥតិបិ មុទិង្គសទ្ទោ ឥតិបិ សង្ខសទ្ទោ ឥតិបិ បណវសទ្ទោ ឥតិបិ ទេណ្ឌិមសទ្ទោ ឥតិបិ(២) ឯវមេវ ខោ មហារាជ ភិក្ខុ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ ទិព្វាយ សោតធាតុយា ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ សោ ទិព្វាយ សោតធាតុយា វិសុទ្ធាយ អតិក្កន្តមានុសិកាយ ឧភោ សទ្ទេ សុណាតិ ទិព្វេ ច មានុសេ ច យេ ទូរេ សន្តិកេ ច ។ ឥទំបិ ខោ មហារាជ សន្ទិដ្ឋិកំ សាមញ្ញផលំ បុរិមេហិ សន្ទិដ្ឋិកេហិ សាមញ្ញផលេហិ អភិក្កន្តតរញ្ច បណីតតរញ្ច ។

---

១ ខ.ម. សង្ខបណវទេណ្ឌិមសទ្ទំបិ ។ ២ ខ. មុទិង្គសទ្ទោ ឥតិបិ សង្ខបណវទេណ្ឌិមសទ្ទោ ឥតិបិ ។

សោតធាតុជាទិព្វបរិសុទ្ធស្អាត កន្លងបង់នូវសោតធាតុជារបស់មនុស្សធម្មតាហើយ រមែងឮនូវសម្លេងទាំងពីរ គឺសម្លេងទិព្វ ១ សម្លេងមនុស្ស ១ ដែលនៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តីបាន បពិត្រមហារាជ ប្រៀបដូចបុរសដែលដើរទៅកាន់ផ្លូវឆ្ងាយ បុរសនោះឮសម្លេងស្គរធំក្តី សម្លេងសំភោរក្តី សម្លេងស័ង្ខក្តី សម្លេងស្គរដ័យក្តី សម្លេងស្គរតូចក្តី បុរសនោះ ក៏មានសេចក្តីត្រិះរិះ យ៉ាងនេះថា នេះជាសម្លេងស្គរធំ នេះជាសម្លេងសំភោរ នេះជាសម្លេងស័ង្ខ នេះជាសម្លេងស្គរដ័យ នេះជាសម្លេងស្គរតូច យ៉ាងណាមិញ បពិត្រមហារាជ ភិក្ខុកាលបើចិត្តតាំងមាំបរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការភាវនា ដល់នូវសេចក្តីមិនញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ រមែងទាញនាំបង្អោនចិត្តទៅក្នុងសោតធាតុជាទិព្វ ភិក្ខុនោះ កាលបើមានសោតធាតុជាទិព្វបរិសុទ្ធស្អាត កន្លងបង់នូវសោតធាតុជារបស់មនុស្សធម្មតាហើយ រមែងឮសម្លេងទាំងពីរ គឺសម្លេងទិព្វ ១ សម្លេងមនុស្ស ១ ដែលនៅក្នុងទីឆ្ងាយក្តី ក្នុងទីជិតក្តី យ៉ាងនោះឯង ៗ បពិត្រមហារាជ នេះឯងជាផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ដ៏រុងរឿងដោយវិសេសផង ថ្លៃថ្លាដោយវិសេសផង ជាងផលនៃសមណប្បដិបត្តិទាំងឡាយ ដែលឃើញច្បាស់ដោយខ្លួនឯង ដូចបានពោលមកខាងដើម ៗ

(១៣៨) សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ ចេតោបរិយញាណាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ សោ បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច បជានាតិ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានាតិ វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ បជានាតិ សទោសំ វា ចិត្តំ សទោសំ ចិត្តន្តិ បជានាតិ វីតទោសំ វា ចិត្តំ វីតទោសំ ចិត្តន្តិ បជានាតិ សមោហំ វា ចិត្តំ សមោហំ ចិត្តន្តិ បជានាតិ វីតមោហំ វា ចិត្តំ វីតមោហំ ចិត្តន្តិ បជានាតិ សង្ខិត្តំ វា ចិត្តំ សង្ខិត្តំ ចិត្តន្តិ បជានាតិ វិក្ខិត្តំ វា ចិត្តំ វិក្ខិត្តំ ចិត្តន្តិ បជានាតិ មហគ្គតំ វា ចិត្តំ

(១៣៥) ភិក្ខុនោះ កាលបើចិត្តតាំងមាំបរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការភាវនា ដល់នូវសេចក្តីមិនញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ រមែងទាញនាំបង្អោននូវចិត្តទៅ ដើម្បីចេតោបរិយញ្ញាណ (ប្រាជ្ញាជាគ្រឿងកំណត់ដឹងនូវចិត្តសត្វដទៃ) ។ ភិក្ខុនោះ ក៏កំណត់ដឹងច្បាស់នូវចិត្តនៃសត្វទាំងឡាយដទៃ នឹងចិត្តនៃបុគ្គលទាំងឡាយដទៃ ដោយចិត្តរបស់ខ្លួនបាន ចិត្តដែលប្រកបដោយរាគៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ចិត្តដែលប្រាសចាករាគៈហើយក្តី ក៏ដឹងច្បាស់ថាចិត្តប្រាសចាករាគៈហើយ ចិត្តដែលប្រកបដោយទោសៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ ចិត្តដែលប្រាសចាកទោសៈហើយក្តី ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈហើយ ចិត្តដែលប្រកបដោយមោហៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ចិត្តដែលប្រាសចាកមោហៈហើយក្តី ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈហើយ ចិត្តដែលរួញថយ[១]ក្តី ក៏ដឹងច្បាស់ថា ចិត្តរួញថយ ចិត្តដែលរាយមាយ[២]ក្តី ក៏ដឹងច្បាស់ថា ចិត្តរាយមាយ ចិត្តដែលជាមហគ្គតៈ គឺចិត្តដល់នូវភាវៈជាធំ (បានដល់រូបាវចរនឹងអរូបាវចរ) ក្តី ក៏ដឹងច្បាស់

---

១ អដ្ឋកថា ថា ចិត្តដែលត្រូវថីនមិទ្ធគ្របសង្កត់ ។ ២ ចិត្តដែលប្រកបដោយឧទ្ធច្ចៈ ។

មហគ្គតំ ចិត្តន្តិ បជានាតិ អមហគ្គតំ វា ចិត្តំ អមហគ្គតំ ចិត្តន្តិ បជានាតិ សឧត្តរំ វា ចិត្តំ សឧត្តរំ ចិត្តន្តិ បជានាតិ អនុត្តរំ វា ចិត្តំ អនុត្តរំ ចិត្តន្តិ បជានាតិ សមាហិតំ វា ចិត្តំ សមាហិតំ ចិត្តន្តិ បជានាតិ អសមាហិតំ វា ចិត្តំ អសមាហិតំ ចិត្តន្តិ បជានាតិ វិមុត្តំ វា ចិត្តំ វិមុត្តំ ចិត្តន្តិ បជានាតិ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានាតិ ។ សេយ្យថាបិ មហារាជ ឥត្ថី វា បុរិសោ វា ទហរោ វា យុវា មណ្ឌនក-ជាតិកោ[១] អាទាសេ វា បរិសុទ្ធេ បរិយោទាតេ អច្ឆេ វា ឧទកបត្តេ សកំ មុខនិមិត្តំ បច្ចវេក្ខ-មានោ សកណិកំ វា សកណិកន្តិ ជានេយ្យ អកណិកំ វា អកណិកន្តិ ជានេយ្យ ឯវមេវ ខោ មហារាជ ភិក្ខុ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ

---

១ ឱ. ម. មណ្ឌនជាតិកោ ។

ថាចិត្តជាមហគ្គតៈ ចិត្តដែលមិនមែនជាមហគ្គតៈ គឺជាកាមាវចរក្តី ក៏ដឹងច្បាស់ថា ចិត្តមិនមែនជាមហគ្គតៈ ចិត្តដែលមានចិត្តដទៃក្រៃលែងជាង គឺជាកាមាវចរក្តី ក៏ដឹងច្បាស់ថា ចិត្តមានចិត្តដទៃក្រៃលែងជាង ចិត្តដែលមិនមានចិត្តដទៃក្រៃលែងជាង គឺរូបាវចរនឹងអរូបាវចរក្តី ក៏ដឹងច្បាស់ថា ចិត្តមិនមានចិត្តដទៃក្រៃលែងជាង ចិត្តដែលតាំងមាំហើយក្តី ក៏ដឹងច្បាស់ថា ចិត្តតាំងមាំហើយ(១) ចិត្តដែលមិនបានតាំងមាំក្តី ក៏ដឹងច្បាស់ថា ចិត្តមិនបានតាំងមាំ ចិត្តដែលរួចស្រឡះ(២)ហើយក្តី ក៏ដឹងច្បាស់ថា ចិត្តរួចស្រឡះហើយ ចិត្តដែលមិនទាន់រួចស្រឡះក្តី ក៏ដឹងច្បាស់ថា ចិត្តមិនទាន់រួចស្រឡះ ។ បពិត្រមហារាជ ប្រៀបដូចស្ត្រីក្តី បុរសក្តី ដែលនៅក្មេង ជាក្រមុំ កំលោះ ដែលនៅកំពុងតែចូលចិត្តនឹងប្រដាប់តាក់តែងរាងកាយ កាលឆ្លុះមើលនូវស្រមោលនៃមុខរបស់ខ្លួនក្នុងកញ្ចក់ដ៏បរិសុទ្ធស្អាតក្តី ក្នុងភាជន៍ដ៏ពេញដោយទឹកថ្លាក្តី បើស្រមោលនៃមុខប្រកបដោយទោស មានមុនជាដើម ក៏ដឹងថាមុខប្រកបដោយទោស បើស្រមោលនៃមុខមិនប្រកបដោយទោសក្តី ក៏ដឹងថាមុខមិនប្រកបដោយទោស យ៉ាងណាមិញ បពិត្រមហារាជ ភិក្ខុកាលបើចិត្តតាំងមាំ បរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាស

---

១ ចិត្តជាអប្បនាសមាធិ ឬឧបចារសមាធិ ។ ២ ចិត្តដែលរួចដោយតទង្គវិមុត្តិនឹងវិក្ខម្ភនវិមុត្តិ ។

កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ ចេតោបរិយញាណាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ សោ បរសត្តានំ បរបុគ្គលានំ ចេតសា ចេតោ បរិច្ច បជានាតិ សរាគំ វា ចិត្តំ សរាគំ ចិត្តន្តិ បជានាតិ វីតរាគំ វា ចិត្តំ វីតរាគំ ចិត្តន្តិ បជានាតិ សទោសំ វា ចិត្តំ សទោសំ ចិត្តន្តិ បជានាតិ វីតទោសំ វា ចិត្តំ វីតទោសំ ចិត្តន្តិ បជានាតិ សមោហំ វា ចិត្តំ សមោហំ ចិត្តន្តិ បជានាតិ វីតមោហំ វា ចិត្តំ វីតមោហំ ចិត្តន្តិ បជានាតិ សង្ខិត្តំ វា ចិត្តំ សង្ខិត្តំ ចិត្តន្តិ បជានាតិ វិក្ខិត្តំ វា ចិត្តំ វិក្ខិត្តំ ចិត្តន្តិ បជានាតិ មហគ្គតំ វា ចិត្តំ មហគ្គតំ ចិត្តន្តិ បជានាតិ អមហគ្គតំ វា ចិត្តំ អមហគ្គតំ ចិត្តន្តិ បជានាតិ សឧត្តរំ វា ចិត្តំ សឧត្តរំ ចិត្តន្តិ បជានាតិ អនុត្តរំ វា ចិត្តំ អនុត្តរំ ចិត្តន្តិ បជានាតិ សមាហិតំ វា ចិត្តំ សមាហិតំ ចិត្តន្តិ បជានាតិ

ចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការការងារ ដល់នូវសេចក្តីមិនញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ រមែងទាញនាំបង្អោនចិត្តទៅដើម្បីចេតោបរិយញ្ញាណ ភិក្ខុនោះ រមែងកំណត់ដឹងច្បាស់ នូវចិត្តនៃសត្វទាំងឡាយដទៃ នឹងចិត្តនៃបុគ្គលទាំងឡាយដទៃ ដោយចិត្តរបស់ខ្លួនបាន ចិត្តដែលប្រកបដោយរាគៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយរាគៈ ចិត្តដែលប្រាសចាករាគៈហើយក្តី ក៏ដឹងច្បាស់ថា ចិត្តប្រាសចាករាគៈហើយ ចិត្តដែលប្រកបដោយទោសៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយទោសៈ ចិត្តដែលប្រាសចាកទោសៈហើយក្តី ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកទោសៈហើយ ចិត្តដែលប្រកបដោយមោហៈក្តី ក៏ដឹងច្បាស់ថា ចិត្តប្រកបដោយមោហៈ ចិត្តដែលប្រាសចាកមោហៈហើយក្តី ក៏ដឹងច្បាស់ថា ចិត្តប្រាសចាកមោហៈហើយ ចិត្តដែលរួញថយក្តី ក៏ដឹងច្បាស់ថា ចិត្តរួញថយ ចិត្តដែលរាយមាយក្តី ក៏ដឹងច្បាស់ថា ចិត្តរាយមាយ ចិត្តដែលជាមហគ្គតៈក្តី ក៏ដឹងច្បាស់ថា ចិត្តជាមហគ្គតៈ ចិត្តដែលមិនមែនជាមហគ្គតៈក្តី ក៏ដឹងច្បាស់ថា ចិត្តមិនមែនជាមហគ្គតៈ ចិត្តដែលមានចិត្តដទៃក្រៃលែងជាងក្តី ក៏ដឹងច្បាស់ថា ចិត្តមានចិត្តដទៃក្រៃលែងជាង ចិត្តដែលមិនមានចិត្តដទៃក្រៃលែងជាងក្តី ក៏ដឹងច្បាស់ថា ចិត្តមិនមានចិត្តដទៃក្រៃលែងជាង ចិត្តដែលតាំងមាំហើយក្តី ក៏ដឹងច្បាស់ថា ចិត្តតាំង

អសមាហិតំ វា ចិត្តំ អសមាហិតំ ចិត្តន្តិ បជានាតិ វិមុត្តំ វា ចិត្តំ វិមុត្តំ ចិត្តន្តិ បជានាតិ អវិមុត្តំ វា ចិត្តំ អវិមុត្តំ ចិត្តន្តិ បជានាតិ ។ ឥទំបិ ខោ មហារាជ សន្ទិដ្ឋិកំ សាមញ្ញផលំ បុរិមេហិ សន្ទិដ្ឋេហិ សាមញ្ញផលេហិ អភិក្កន្តតរញ្ច បណីតតរញ្ច ។

(១៣៦) សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ បុព្វេនិវាសានុស្សតិញ្ញាណាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ សោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកំបិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសំបិ ជាតិយោ តឹសំបិ ជាតិយោ ចត្តាឡីសំបិ(១) ជាតិយោ បញ្ញាសំបិ ជាតិយោ សតំបិ

១ ឱ. ចត្តារីសម្បិ ។

មាំហើយ ចិត្តដែលមិនតាំងមាំក្តី ក៏ដឹងច្បាស់ថា ចិត្តមិនតាំងមាំ ចិត្តដែលរួចស្រឡះហើយក្តី ក៏ដឹងច្បាស់ថា ចិត្តរួចស្រឡះហើយ ចិត្តដែលមិនទាន់រួចស្រឡះក្តី ក៏ដឹងច្បាស់ថា ចិត្តមិនទាន់រួចស្រឡះ យ៉ាងនោះឯង ៗ បពិត្រមហាបពិត្រ នេះឯងជាផលនៃសាមញ្ញបដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ដ៏វិសេសឧត្តមជាងផល ថ្លៃថ្លាដោយវិសេសផង ជាងផលនៃសាមញ្ញបដិបត្តិទាំងឡាយ ដែលឃើញច្បាស់ដោយខ្លួនឯង ដូចបានពោលមកខាងដើម ៗ

(១៣៦) ភិក្ខុនោះ កាលបើចិត្តតាំងមាំបរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការភាវនា ដល់នូវសេចក្តីមិនញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ រមែងទាញនាំបង្អោនចិត្តទៅ ដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ (ប្រាជ្ញាជាគ្រឿងរលឹកតាមនូវខន្ធ ដែលសត្វធ្លាប់អាស្រ័យនៅ ក្នុងកាលមុន) ៗ ភិក្ខុនោះ រមែងរលឹកតាមនូវបុព្វេនិវាស គឺខន្ធដែលសត្វ ធ្លាប់អាស្រ័យនៅហើយក្នុងកាលមុនជាច្រើនប្រការ ការរលឹកបាននោះ តើដូចម្តេច គឺរលឹកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១០០ ជា-

ជាតិយោ សហស្សំបិ ជាតិយោ សតសហស្សំបិ ជាតិយោ អនេកេបិ សំវដ្តកប្បេ អនេកេបិ វិវដ្តកប្បេ អនេកេបិ សំវដ្តវិវដ្តកប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ សេយ្យថាបិ មហារាជ បុរិសោ សកម្ហា គាមា អញ្ញំ គាមំ គច្ឆេយ្យ តម្ហាបិ គាមា អញ្ញំបិ គាមំ គច្ឆេយ្យ សោ តម្ហា គាមា សកំយេវ គាមំ បច្ចាគច្ឆេយ្យ

ខ្លះ ១ ពាន់ជាតិខ្លះ ១ សែនជាតិខ្លះ អនេកសំវដ្តកប្ប គឺកប្បដែលវិនាសជាច្រើនខ្លះ អនេកវិវដ្តកប្ប គឺកប្បដែលចម្រើនជាច្រើនខ្លះ អនេកសំវដ្ត-វិវដ្តកប្បខ្លះ(១)ថា អាត្មាអញ បានកើតក្នុងភពឯណោះ មានឈ្មោះ យ៉ាងនេះ មានគោត្រ យ៉ាងនេះ មានសម្បុរ យ៉ាងនេះ មានអាហារ យ៉ាងនេះ បានទទួលសុខនិងទុក្ខ យ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះអាត្មាអញច្យុតចាកភពនោះហើយ បានទៅកើតក្នុងភពឯណោះ ដែលអាត្មាអញបានកើតក្នុងភពនោះ មានឈ្មោះ យ៉ាងនេះ មានគោត្រ យ៉ាងនេះ មានសម្បុរ យ៉ាងនេះ មានអាហារ យ៉ាងនេះ បានទទួលសុខនិងទុក្ខ យ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះអាត្មាអញ ច្យុតចាកភពនោះហើយ ក៏បានមកកើតក្នុងភពនេះ ៗ ភិក្ខុនោះ រលឹកតាមនូវបុព្វេ-និវាសជាច្រើនប្រការ ព្រមទាំងអាការ គឺសម្បុរនិងអាហារជាដើម ព្រមទាំងឧទ្ទេស គឺឈ្មោះនិងគោត្រត្រកូល ដោយប្រការដូច្នេះឯង ៗ បពិត្រមហារាជ ប្រៀបដូចបុរសដែលចេញអំពីស្រុករបស់ខ្លួន ទៅកាន់ស្រុកដទៃ រួចចេញអំពីស្រុកនោះ ហើយទៅកាន់ស្រុកដទៃទៀត បុរសនោះចេញអំពីស្រុកនោះហើយ ទើបត្រឡប់មកកាន់ស្រុករបស់ខ្លួនដដែលវិញ

១ កប្បមាន ៤ គឺ គិតតាំងពីថ្ងៃដែលកប្បវិនាស ទៅទល់គ្នានឹងភ្លើងឆេះអស់រលីង ហៅថា សំវដ្តកប្ប ១ តាំងអំពីភ្លើងឆេះអស់ នៅសល់តែអាកាសសូន្យទទេ ហៅថាសំវដ្តដ្ឋាយិកប្ប ១ តាំងអំពីកកើតដីឡើងជាថ្មី ទៅទល់នឹងកាល ដែលកើតមានព្រះអាទិត្យព្រះចន្ទ ហៅថា វិវដ្តកប្ប ១ តាំងអំពីព្រះអាទិត្យព្រះចន្ទ កើតឡើងទៅទល់នឹងវិនាសវិញ ហៅថា វិវដ្តដ្ឋាយិ-កប្ប ១ រួមកប្បទាំង ៤ នេះចូលជាមួយគ្នា ហៅថា សំវិវដ្តកប្ប ឬហៅថា មហាកប្ប សំវិវដ្ត-កប្បដែលច្រើន ហៅថា អនេកសំវដ្តវិវដ្តកប្ប ។

តស្ស ឯវមស្ស អហំ ខោ សកម្ហា គាមា អមុំ គាមំ អគញ្ឆឹ តត្រាហំ(១) ឯវំ អដ្ឋាសឹ ឯវំ និសីទឹ ឯវំ អភាសឹ ឯវំ តុណ្ហី អហោសឹ តម្ហាបិ គាមា អមុំ គាមំ អគញ្ឆឹ តត្រាបាហំ(២) ឯវំ អដ្ឋាសឹ ឯវំ និសីទឹ ឯវំ អភាសឹ ឯវំ តុណ្ហី អហោសឹ សោម្ហិ តម្ហា គាមា សកំយេវ គាមំ បច្ចាគតោតិ ឯវមេវ ខោ មហារាជ ភិក្ខុ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ បុព្វេនិវាសានុស្សតិញ្ញាណាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ សោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសំបិ ជាតិយោ តឹសំបិ ជាតិយោ ចត្តាឡីសំបិ ជាតិយោ បញ្ញាសំបិ ជាតិយោ សតម្បិ ជាតិយោ សហស្សំបិ ជាតិយោ សតសហស្សំបិ ជាតិយោ អនេកេបិ សំវដ្ដកប្បេ អនេកេបិ វិវដ្ដកប្បេ អនេកេបិ សំវដ្ដវិវដ្ដកប្បេ អមុត្រាសឹ

១ ឱ. តត្រ ។ ម. តត្រាបិ ។ ២ ឱ. ម. តត្រាបិ ។

បុរសនោះគប្បីមានសេចក្តីត្រិះរិះ យ៉ាងនេះថា អាត្មាអញ បានចេញអំពីស្រុករបស់ខ្លួន ទៅកាន់ស្រុកឯណោះ ក្នុងស្រុកនោះ អាត្មាអញ បានឈរយ៉ាងនេះ បានអង្គុយយ៉ាងនេះ បាននិយាយយ៉ាងនេះ បានស្ងៀមយ៉ាងនេះ លុះអាត្មាអញ ចេញអំពីស្រុកនោះហើយ បានទៅកាន់ស្រុកឯណោះទៀត ក៏ក្នុងស្រុកនោះឯង អាត្មាអញ បានឈរយ៉ាងនេះ បានអង្គុយយ៉ាងនេះ បាននិយាយយ៉ាងនេះ បានស្ងៀមយ៉ាងនេះ អាត្មាអញចេញអំពីស្រុកនោះហើយ ក៏បានត្រឡប់មកកាន់ស្រុក របស់ខ្លួនដដែលវិញ យ៉ាងណាមិញ បពិត្រមហារាជ ភិក្ខុកាលបើចិត្តតាំងមាំបរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការភាវនា ដល់នូវសេចក្តីមិនញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ រមែងទាញនាំបង្អោនចិត្តទៅ ដើម្បីបុព្វេនិវាសានុស្សតិញ្ញាណ ភិក្ខុនោះ រមែងរលឹកតាមនូវបុព្វេនិវាសជាច្រើនប្រការ ការរលឹកបាននោះតើដូចម្តេច គឺរលឹកបាន ១ ជាតិខ្លះ ២ ជាតិខ្លះ ៣ ជាតិខ្លះ ៤ ជាតិខ្លះ ៥ ជាតិខ្លះ ១០ ជាតិខ្លះ ២០ ជាតិខ្លះ ៣០ ជាតិខ្លះ ៤០ ជាតិខ្លះ ៥០ ជាតិខ្លះ ១ រយជាតិខ្លះ ១ ពាន់ជាតិខ្លះ ១ សែនជាតិខ្លះ អនេកសំវដ្តកប្បខ្លះ អនេកវិវដ្តកប្បខ្លះ អនេកសំវដ្តវិវដ្តកប្បខ្លះថា អាត្មាអញបាន

ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ។ ឥទំបិ ខោ មហារាជ សន្ទិដ្ឋិកំ សាមញ្ញផលំ បុរិមេហិ សន្ទិដ្ឋិកេហិ សាមញ្ញផលេហិ អភិក្កន្តតរញ្ច បណីតតរញ្ច ។

(១៣៧) សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ សត្តានំ ចុតូ-

កើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះអាត្មាអញច្យុតចាកភពនោះហើយ បានទៅកើតក្នុងភពឯណោះ ដែលអាត្មាអញបានកើតក្នុងភពនោះ មានឈ្មោះយ៉ាងនេះ មានគោត្រយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានទទួលសុខទុក្ខយ៉ាងនេះ មានកំណត់អាយុត្រឹមប៉ុណ្ណេះ លុះអាត្មាអញ ច្យុតចាកភពនោះហើយ ក៏បានមកកើតក្នុងភពនេះ ភិក្ខុនោះរមែងរលឹកតាមនូវបុព្វេនិវាស ជាច្រើនប្រការ ព្រមទាំងអាការ ព្រមទាំងឧទ្ទេស ដោយប្រការដូច្នេះ យ៉ាងនោះឯង ។ បពិត្រមហារាជ នេះឯងជាផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ដ៏រុងរឿងដោយវិសេសផង ថ្លៃថ្លាដោយវិសេសផង ជាងផលនៃសមណប្បដិបត្តិទាំងឡាយ ដែលឃើញច្បាស់ដោយខ្លួនឯង ដូចបានពោលមកខាងដើម ។

(១៣៧) ភិក្ខុនោះកាលបើចិត្តតាំងមាំបរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការការងារ ដល់នូវសេចក្តីមិនញាប់ញ័រ ទៅតាមអារម្មណ៍ យ៉ាងនេះហើយ

## សាមញ្ញផលសុត្តំ ចុតូបបាតញាណំ

បាតញាណាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ សោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ

រមែងទាញនាំបង្អោនចិត្តទៅ ដើម្បីចុតូបបាតញ្ញាណ (ប្រាជ្ញាជាគ្រឿងដឹងនូវចុតិនិងបដិសន្ធិ) នៃពួកសត្វ គឺទិព្វចក្ខុញាណ ។ ភិក្ខុនោះ មានចក្ខុដូចជាទិព្វបរិសុទ្ធស្អាត កន្លងបង់នូវចក្ខុជារបស់មនុស្សធម្មតា បានឃើញនូវសត្វទាំងឡាយ ដែលច្យុត ដែលកើតឡើង ថោកទាបនិងឧត្តម មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ រមែងដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួនថា អើហ្ន៎ សត្វពួកនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត ជាអ្នកតិះដៀលនូវព្រះអរិយៈទាំងឡាយ ជាមិច្ឆាទិដ្ឋិ កាន់យកនូវអំពើជាមិច្ឆាទិដ្ឋិ សត្វពួកនោះ លុះទំលាយកាយខាងនាយអំពីសេចក្តីស្លាប់ រមែងទៅកើតក្នុងតិរច្ឆាន ប្រេត អសុរកាយ នរក អើហ្ន៎ ចំណែកឯសត្វពួកនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត ជាអ្នកមិនតិះដៀលនូវព្រះអរិយៈទាំងឡាយ ជាសម្មាទិដ្ឋិ កាន់យកនូវអំពើជាសម្មាទិដ្ឋិ សត្វពួកនោះ លុះទំលាយកាយខាងនាយ អំពីសេចក្តីស្លាប់ រមែងចូលទៅកាន់លោក គឺមនុស្ស សុគតិនិងឋានសួគ៌ ភិក្ខុនោះមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធ កន្លងបង់នូវចក្ខុជារបស់មនុស្សធម្មតា បានឃើញនូវសត្វទាំងឡាយ ដែលច្យុត ដែលកើតឡើង ជាសត្វថោកថយនិងឧត្តម

សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ។ សេយ្យថាបិ មហារាជ មជ្ឈេ សិង្ឃាដកេ បាសាទោ តត្រ ចក្ខុមា បុរិសោ ឋិតោ បស្សេយ្យ មនុស្សេ គេហំ បវិសន្តេបិ និក្ខមន្តេបិ រថិយាយ វីថី សញ្ចរន្តេបិ មជ្ឈេ សិង្ឃាដកេ និសិន្នេបិ តស្ស ឯវមស្ស ឯតេ មនុស្សា គេហំ បវិសន្តិ ឯតេ និក្ខមន្តិ ឯតេ រថិយាយ វីថី សញ្ចរន្តិ ឯតេ មជ្ឈេ សិង្ឃាដកេ និសិន្នាតិ ឯវមេវ ខោ មហារាជ ភិក្ខុ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ សត្តានំ ចុតូបបាតញាណាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ សោ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧប.

មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ រមែងដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន ដោយប្រការដូច្នេះ ។ បពិត្រមហារាជ ប្រៀបដូចជាប្រាសាទ ដែលតាំងនៅត្រង់ផ្លូវបែកជា ៣[1] នាកណ្ដាលក្រុង បុរសដែលមានភ្នែក (ភ្លឺ) ឈរនៅលើប្រាសាទនោះ ក៏គប្បីឃើញនូវមនុស្សទាំងឡាយ ដែលចូលទៅកាន់ផ្ទះក្ដី ចេញអំពីផ្ទះក្ដី ត្រាច់ទៅមកអំពីច្រកផ្លូវទៅកាន់ថ្នល់ក្ដី អង្គុយនៅក្នុងផ្លូវបែកជា ៣ នាកណ្ដាលក្រុងក្ដី បុរសនោះគប្បីមានសេចក្ដីត្រិះរិះយ៉ាងនេះថា មនុស្សទាំងនុ៎ះចូលទៅកាន់ផ្ទះ មនុស្សទាំងនុ៎ះចេញអំពីផ្ទះ មនុស្សទាំងនុ៎ះដើរទៅមកអំពីច្រកផ្លូវទៅកាន់ថ្នល់ មនុស្សទាំងនុ៎ះអង្គុយនៅក្នុងផ្លូវបែកជា ៣ នាកណ្ដាលក្រុង យ៉ាងណាមិញ បពិត្រមហារាជ ភិក្ខុកាលបើចិត្តតាំងមាំបរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ការភាវនា ដល់នូវសេចក្ដីមិនញាប់ញ័រទៅតាមអារម្មណ៍យ៉ាងនេះហើយ រមែងទាញនាំបង្អោនចិត្តទៅ ដើម្បីបញ្ញាជាគ្រឿងដឹងនូវចុតិនិងបដិសន្ធិនៃពួកសត្វ ភិក្ខុនោះមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធកន្លងបង់នូវចក្ខុជារបស់នៃមនុស្សធម្មតា រមែងឃើញនូវសត្វទាំងឡាយដែលច្យុត

---

១ សព្ទនេះ ប្រែថា ផ្លូវបែកជា ៤ ក៏បាន ។

បជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ឥមេ វត ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នាគតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុបវាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ កាយស្ស ភេទា បរំ មរណា សុគតឹ សគ្គំ លោកំ ឧបបន្នាតិ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន សត្តេ បស្សតិ ចវមានេ ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាតិ ។ ឥទំបិ

ដែលកើតឡើង ជាសត្វថោកថយ ទីងខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ រមែងដឹងច្បាស់ នូវពួកសត្វ ដែលប្រព្រឹត្តទៅ តាមកម្មរបស់ខ្លួនថា អើហ្ន៎ សត្វពួកនេះ ប្រកបដោយកាយទុច្ចរិត ប្រកបដោយវចីទុច្ចរិត ប្រកបដោយមនោទុច្ចរិត តិះដៀលនូវព្រះអរិយៈទាំងឡាយ ជាមិច្ឆាទិដ្ឋិ កាន់យកនូវអំពើជាមិច្ឆាទិដ្ឋិ សត្វពួកនោះ លុះទំលាយកាយទៅខាងនាយអំពីសេចក្តីស្លាប់ រមែងចូលទៅកើតក្នុងកំណើតនៃតិរច្ឆាន ប្រេត អសុរកាយ នរក អើហ្ន៎ ចំណែកឯសត្វពួកនេះ ប្រកបដោយកាយសុចរិត ប្រកបដោយវចីសុចរិត ប្រកបដោយមនោសុចរិត មិនបានតិះដៀលនូវព្រះអរិយៈទាំងឡាយ ជាសម្មា-ទិដ្ឋិ កាន់យកនូវអំពើជាសម្មាទិដ្ឋិ សត្វពួកនោះ លុះទំលាយកាយទៅខាងនាយអំពីសេចក្តីស្លាប់ រមែងចូលទៅកាន់លោក គឺមនុស្សសុគតិនឹងឋានសួគ៌ ភិក្ខុនោះមានចក្ខុដូចជាទិព្វដ៏បរិសុទ្ធផុតផង់ កន្លងបង់នូវចក្ខុជារបស់នៃមនុស្សធម្មតា រមែងឃើញនូវសត្វទាំងឡាយ ដែលច្យុត ដែលកើតឡើងជាសត្វថោកថយទីងខ្ពង់ខ្ពស់ មានសម្បុរល្អ មានសម្បុរអាក្រក់ មានគតិល្អ មានគតិអាក្រក់ រមែងដឹងច្បាស់នូវពួកសត្វដែលប្រព្រឹត្តទៅតាមកម្មរបស់ខ្លួន យ៉ាងនោះឯង ៗ បពិត្រមហារាជ នេះឯងជាផល

ខោ មហារាជ សន្ទិដ្ឋិកំ សាមញ្ញផលំ បុរិមេហិ សន្ទិដ្ឋិកេហិ សាមញ្ញផលេហិ អភិក្កន្តតរញ្ច បណីតតរញ្ច ។

[១៣៨] សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ អាសវានំ ខយញ្ញាណាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ សោ ឥទំ ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឥមេ អាសវាតិ យថាភូតំ បជានាតិ អយំ អាសវសមុទយោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ តស្ស ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចតិ

នៃសមណប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង ដ៏ប្រសើរដោយវិសេសផង ថ្លៃថ្លាដោយវិសេសផង ជាងផលនៃសមណប្បដិបត្តិទាំងឡាយ ដែលឃើញច្បាស់ដោយខ្លួនឯង ដូចបានពោលមកខាងដើម ។

(១៣៨) ភិក្ខុនោះ កាលបើចិត្តតាំងមាំ បរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម ដល់នូវសេចក្តីមិនញាប់ញ័រទៅតាមអារម្មណ៍ យ៉ាងនេះហើយ រមែងទាញនាំបង្អោនចិត្តទៅ ដើម្បីអាសវក្ខយញ្ញាណ (ប្រាជ្ញាដឹងនូវធម៌ជាគ្រឿងអស់ទៅនៃអាសវៈ) ។ ភិក្ខុនោះ រមែងដឹងតាមពិតថា នេះជាទុក្ខ ដឹងតាមពិតថា នេះជាទីប្រជុំកើតឡើងនៃទុក្ខ ដឹងតាមពិតថា នេះជាព្រះនិព្វានជាគ្រឿងរលត់ទុក្ខ ដឹងតាមពិតថា នេះជាផ្លូវប្រតិបត្តិដំណើរទៅកាន់ព្រះនិព្វានជាគ្រឿងរលត់ទុក្ខ ដឹងតាមពិតថា នេះជាអាសវៈ ដឹងតាមពិតថា ធម៌[1]នេះជាទីប្រជុំកើតឡើងនៃអាសវៈ ដឹងតាមពិតថា ធម៌នេះជាគ្រឿងរលត់នៃអាសវៈ ដឹងតាមពិតថា ធម៌នេះជាផ្លូវប្រតិបត្តិដំណើរទៅកាន់ព្រះនិព្វាន ជាគ្រឿងរលត់នៃអាសវៈ ។ កាលបើភិក្ខុនោះដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តក៏ផុតស្រឡះចាកកាមាសវៈ[2] ផង

---

១ សេចក្តីកើតនៃអវិជ្ជាជាហេតុនាំឲ្យកើតអាសវៈ ។ ២ សេចក្តីត្រេកត្រអាលត្រាំនៅក្នុងកាម ហៅថា កាមាសវៈ ។

ភវាសវាបិ ចិត្តំ វិមុច្ចតិ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ សេយ្យថាបិ មហារាជ បព្វតសង្ខេបេ ឧទករហទោ អច្ឆោ វិប្បសន្នោ អនាវិលោ តត្ថ ចក្ខុមា បុរិសោ តីរេ ឋិតោ បស្សេយ្យ សិប្បិកសម្ពុកំបិ[១] សក្ខរកឋលំបិ មច្ឆគុម្ពំបិ ចរន្តំបិ តិដ្ឋន្តំបិ តស្ស ឯវមស្ស អយំ ខោ ឧទករហទោ អច្ឆោ វិប្បសន្នោ អនាវិលោ តត្រិមេ[២] សិប្បិកសម្ពុកាបិ សក្ខរកឋលាបិ[៣] មច្ឆគុម្ពាបិ ចរន្តិបិ តិដ្ឋន្តិបីតិ[៤] ឯវមេវ ខោ មហារាជ ភិក្ខុ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ

---

១ ឱ សិប្បិសម្ពុកម្បិ ។ ២ ឱ. ម. តត្រីមេ ។ ៣ ឱ សក្ខរកឋលាបិ ។ ម. សក្ខរកថលាបិ ។ ៤ ម. ចរន្តាបិ តិដ្ឋន្តាបីតិ ។

## សាមញ្ញផលសូត្រ  អាសវក្ខយញាណ

ចិត្តក៏ផុតស្រឡះចាកភវាសវៈ[១] ផង ចិត្តក៏ផុតស្រឡះចាកអវិជ្ជាសវៈ[២] ផង ។ កាលបើចិត្តភិក្ខុនោះ បានផុតស្រឡះហើយ សេចក្តីដឹងក៏កើតឡើងដល់ភិក្ខុនោះថា ចិត្តរបស់អាត្មាអញផុតស្រឡះហើយ ។ ភិក្ខុនោះដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញ ក៏បានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ បពិត្រមហារាជ ប្រៀបដូចជារអាងទឹក លើកំពូលភ្នំជាទឹកដ៏ថ្លាស្អាត មិនល្អក់ បុរសដែលមានភ្នែក (ភ្លឺ) ឈរនៅមាត់នៃរអាងទឹកនោះ ក៏គប្បីឃើញនូវខ្យងនិងខ្ចៅផង នូវក្រួសនិងដុំថ្មផង នូវហ្វូងនៃត្រីផង កំពុងត្រាច់ទៅក្តី ឈប់នៅក្តី ក្នុងរអាងនោះ បុរសនោះ គប្បីមានសេចក្តីត្រិះរិះយ៉ាងនេះថា រអាងទឹកនេះឯង ថ្លាស្អាតមិនល្អក់ ខ្យងនិងខ្ចៅទាំងឡាយក្តី ក្រួសនិងដុំថ្មក្តី ហ្វូងនៃត្រីទាំងនេះក្តី ត្រាច់ទៅខ្លះ ឈប់នៅខ្លះ ក្នុងរអាងនោះ យ៉ាងណាមិញ បពិត្រមហារាជ ភិក្ខុកាលបើ ចិត្តតាំងមាំបរិសុទ្ធផូរផង់ មិនមានទីទួលគឺកិលេស ប្រាសចាកឧបក្កិលេស មានសភាពជាចិត្តទន់ គួរដល់ភាវនាកម្ម ដល់នូវសេចក្តីមិនញាប់ញ័រទៅតាមអារម្មណ៍

---

១ សេចក្តីត្រេកត្រអាលត្រាំទៅក្នុងភពទាំង ៣ ហៅថា ភវាសវៈ ។ ២ សេចក្តីមិនដឹងក្នុងសច្ចៈទាំង ៤ ទាំងមិនដឹងនូវចំណែកនៃខន្ធខាងដើម ខាងចុង ទាំងខាងដើម ខាងចុងនិងបដិច្ចសមុប្បាទធម៌ហៅថា អវិជ្ជាសវៈ ។

អាសវានំ ខយញាណាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ សោ ឥទំ(១) ទុក្ខន្តិ យថាភូតំ បជានាតិ អយំ ទុក្ខសមុទយោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធោតិ យថាភូតំ បជានាតិ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ឥមេ អាសវាតិ យថាភូតំ បជានាតិ អយំ អាសវសមុទយោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធោតិ យថាភូតំ បជានាតិ អយំ អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ បជានាតិ ។ តស្ស ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចតិ ភវាសវាបិ ចិត្តំ វិមុច្ចតិ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចតិ ។ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ ហោតិ ។ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ ឥទំបិ ខោ មហារាជ សន្ទិដ្ឋិកំ សាមញ្ញផលំ

---

១ ម. ឥមំ ។

យ៉ាងនេះហើយ រមែងទាញនាំបង្អោនចិត្តទៅ ដើម្បីអាសវក្ខយញ្ញាណ ភិក្ខុនោះឯង រមែងដឹងតាមពិតថា នេះជាទុក្ខ ដឹងតាមពិតថា នេះជាទីប្រជុំកើតឡើងនៃទុក្ខ ដឹងតាមពិតថា នេះជាព្រះនិព្វានជាគ្រឿងរលត់ទុក្ខ ដឹងតាមពិតថា នេះជាផ្លូវប្រតិបត្តិដំណើរទៅកាន់ព្រះនិព្វានជាគ្រឿងរលត់ទុក្ខ ដឹងតាមពិតថា នេះជាអាសវៈ ដឹងតាមពិតថា ធម៌នេះជាទីប្រជុំកើតឡើងនៃអាសវៈ ដឹងតាមពិតថា ធម៌នេះជាគ្រឿងរលត់នៃអាសវៈ ដឹងតាមពិតថា នេះជាផ្លូវប្រតិបត្តិដំណើរទៅ កាន់ព្រះនិព្វានជាគ្រឿងរលត់នៃអាសវៈ យ៉ាងនោះឯង ។ កាលបើភិក្ខុនោះ ដឹងយ៉ាងនេះ ឃើញយ៉ាងនេះហើយ ចិត្តក៏ផុតស្រឡះចាកកាមាសវៈផង ចិត្តក៏ផុតស្រឡះចាកភវាសវៈផង ចិត្តក៏ផុតស្រឡះចាកអវិជ្ជាសវៈផង ។ កាលបើចិត្តនៃភិក្ខុនោះបានផុតស្រឡះហើយសេចក្តីដឹង ក៏កើតឡើងដល់ភិក្ខុនោះថា ចិត្តរបស់អាត្មាអញផុតស្រឡះហើយ ។ ភិក្ខុនោះ ក៏ដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ មគ្គព្រហ្មចរិយៈ អាត្មាអញ បានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញ ក៏បានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀត មិនមានឡើយ ។ បពិត្រមហា-រាជ នេះឯងជាផលនៃសណាប្បដិបត្តិ ដែលឃើញច្បាស់ដោយខ្លួនឯង

បុរិមេហិ សន្ទិដ្ឋិកេហិ សាមញ្ញផលេហិ អភិក្កន្តតរញ្ច បណីតតរញ្ច ។ ឥមស្មា ច បន(១) មហារាជ សន្ទិដ្ឋិកា សាមញ្ញផលា(២) អញ្ញំ សន្ទិដ្ឋិកំ សាមញ្ញផលំ ឧត្តរិតរំ វា បណីតតរំ វា នត្ថីតិ ។

(១៣៩) ឯវំ វុត្តេ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភន្តេ អភិក្កន្តំ ភន្តេ សេយ្យថាបិ ភន្តេ និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ(៣) ភគវតា អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ(៤)

---

១ ឱ. ឥមម្ហា ។ ២ ឱ. សន្ទិដ្ឋិកេហិ សាមញ្ញផលេហិ ។ ៣ ម. ឯវមេវ ភន្តេ ។
៤ ឱ. សោហំ ។

ដ៏រុងរឿងដោយវិសេសផង ថ្លៃថ្លាដោយវិសេសផង ជាងផលនៃសាមណប្បដិបត្តិទាំងឡាយ ដែលឃើញច្បាស់ដោយខ្លួនឯង ដូចបានពោលមកខាងដើម ៗ បពិត្រមហារាជ មួយវិញទៀត ផលនៃសាមណប្បដិបត្តិដែលឃើញច្បាស់ដោយខ្លួនឯងដទៃទៀត ដ៏លើសលុបដោយវិសេសក្តី ថ្លៃថ្លាដោយវិសេសក្តី ជាងផលនៃសាមណប្បដិបត្តិដែលឃើញច្បាស់ដោយខ្លួនឯងនេះទៅទៀត មិនមានឡើយ ៗ

(១៣៩) កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ព្រះធម៌ទេសនាយ៉ាងនេះចប់ហើយ ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាធំក្នុងដែនមគធៈ ក៏ក្រាបបង្គំទូលចំពោះព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ពីរោះពេកណាស់ បពិត្រព្រះអង្គដ៏ចំរើន ពីរោះពេកណាស់ បពិត្រព្រះអង្គដ៏ចំរើន ប្រៀបដូចជាបុគ្គល ផ្ងារឡើងនូវវត្ថុដែលផ្កាប់ ឬបើកនូវវត្ថុដែលគេបិទបាំង ឬក៏ប្រាប់ផ្លូវ ដល់មនុស្សអ្នកវង្វេងផ្លូវ ពុំនោះសោត ដូចគេទ្រោលបំភ្លឺនូវប្រទីបក្នុងទីងងឹត ដោយគិតថា បុរសអ្នកមានភ្នែក (ភ្លឺ) នឹងបានឃើញនូវរូបទាំងឡាយបាន យ៉ាងណាមិញ ធម៌ដែលព្រះមានព្រះភាគ ទ្រង់សំដែងហើយ ដោយបរិយាយជាច្រើន ក៏យ៉ាងនោះឯង បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គនេះ សូមដល់នូវ

ភន្តេ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតំ អច្ចយោ មំ ភន្តេ អច្ចគមា យថាពាលំ យថាមូឡ្ហំ យថាអកុសលំ យោហំ ភន្តេ បិតរំ ធម្មិកំ ធម្មរាជានំ ឥស្សរិយស្ស ការណា ជីវិតា វោរោបេសឹ តស្ស មេ ភន្តេ ភគវា អច្ចយំ អច្ចយតោ បដិគ្គណ្ហាតុ អាយតឹ សំវរាយាតិ ។ តគ្ឃ ត្វំ មហារាជ អច្ចយោ អច្ចគមា យថាពាលំ យថាមូឡ្ហំ យថាអកុសលំ យោ ត្វំ បិតរំ ធម្មិកំ ធម្មរាជានំ ឥស្សរិយស្ស ការណា ជីវិតា វោរោបេសិ យតោ ច ខោ ត្វំ មហារាជ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោសិ តន្តេ មយំ បដិគ្គណ្ហាម

ព្រះមានព្រះភាគព្រមទាំងព្រះធម៌ទាំងព្រះសង្ឃ ជាសរណៈ សូមព្រះមានព្រះភាគចាំទុកនូវខ្ញុំព្រះអង្គថា ជាឧបាសកអ្នកដល់នូវសរណគមន៍ ស្មើដោយជីវិត ក្នុងកាលមានថ្ងៃនេះជាដើមរៀងទៅ បពិត្រព្រះអង្គដ៏ចំរើន ទោសកំហុស ប្រព្រឹត្តកន្លង នូវខ្ញុំព្រះអង្គ ដែលជាមនុស្សល្ងង់យ៉ាងណា ជាមនុស្សវង្វេងយ៉ាងណា ជាមនុស្សមិនឈ្លាសវៃ យ៉ាងណា បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំព្រះអង្គណា បានផ្តាច់បង់ព្រះជន្មាយុ នៃព្រះបិតាដែលជាព្រះធម្មរាជ ប្រកបដោយធម៌ ព្រោះហេតុតែឥស្សរិយយស បពិត្រព្រះអង្គដ៏ចំរើន សូមព្រះមានព្រះភាគ អត់នូវទោសកំហុស តាមទោសកំហុសរបស់ខ្ញុំព្រះអង្គនោះ ដើម្បីនឹងសង្រួមតទៅ ។ ព្រះមានព្រះភាគត្រាស់ថា បពិត្រមហារាជ អើទោសកំហុសប្រព្រឹត្តកន្លងនូវមហារាជហើយ ដែលជាមនុស្សល្ងង់យ៉ាងណា ជាមនុស្សវង្វេងយ៉ាងណា ជាមនុស្សមិនឈ្លាសវៃយ៉ាងណា មហារាជដែលបានផ្តាច់បង់ព្រះជន្មាយុនៃព្រះបិតា ដែលជាធម្មរាជ ប្រកបដោយធម៌ ព្រោះហេតុតែឥស្សរិយយស បពិត្រមហារាជ មួយវិញទៀត មហារាជ បានឃើញនូវទោសកំហុសតាមទោសកំហុសពិត ហើយសំដែងទោសតាមធម៌ ដោយហេតុណា ( ហេតុនោះ ) តថាគត អត់នូវទោសកំហុសនោះ ចំពោះមហារាជ

វុឌ្ឍិ ហេសា មហារាជ អរិយស្ស វិនយេ យោ អច្ចយំ អច្ចយតោ ទិស្វា យថាធម្មំ បដិករោតិ អាយតឹ សំវរំ អាបជ្ជតីតិ ។

(៨៤០) ឯវំ វុត្តេ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ ភគវន្តំ ឯតទវោច ហន្ទ ចទានិ មយំ ភន្តេ គច្ឆាម ពហុកិច្ចា មយំ ពហុករណីយាតិ ។ យស្សទានិ ត្វំ មហារាជ កាលំ មញ្ញសីតិ ។ អថខោ រាជា មាគធោ អជាតសត្តុ វេទេហិបុត្តោ ភគវតោ ភាសិតំ អភិនន្ទិត្វា អនុមោទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ភគវា អចិរបក្កន្តស្ស រញ្ញោ មាគធស្ស អជាតសត្តុស្ស វេទេហិបុត្តស្ស ភិក្ខូ អាមន្តេសិ ខតាយំ ភិក្ខវេ រាជា

បពិត្រមហារាជ បុគ្គលណាឃើញទោសកំហុស តាមទោសកំហុសពិត ហើយសំដែងទោសតាមធម៌ ដល់នូវសេចក្តីសង្រួមតទៅ នេះជាសេចក្តីចំរើន (របស់បុគ្គលនោះ) ក្នុងអរិយវិន័យ ។

(១៤០) កាលបើព្រះមានព្រះភាគ ទ្រង់មានបន្ទូលយ៉ាងនេះហើយ ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាធំក្នុងដែនមគធៈ ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចំរើន ក៏ឥឡូវនេះ យើងខ្ញុំព្រះអង្គ សូមក្រាបថ្វាយបង្គំលា (ដ្បិត) យើងខ្ញុំព្រះអង្គមានកិច្ចច្រើន មានការងារច្រើន ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា បពិត្រមហារាជ សូមមហារាជទ្រង់ជ្រាបនូវកាលដ៏គួរនឹងស្តេចទៅ ក្នុងកាលឥឡូវនេះចុះ ។ លំដាប់នោះ ព្រះបាទអជាតសត្តុវេទេហិបុត្ត ជាធំក្នុងដែនមគធៈ ទ្រង់ត្រេកអរអនុមោទនានឹងភាសិត របស់ព្រះមានព្រះភាគហើយ ទើបក្រោកចាកអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយក៏ស្តេចចេញទៅ ។ លំដាប់នោះ ព្រះមានព្រះភាគ កាលដែលព្រះបាទអជាតសត្តុវេទេហិបុត្ត ជាធំក្នុងដែនមគធៈ ស្តេចចេញទៅមិនយូរប៉ុន្មាន ក៏ទ្រង់ត្រាស់ចំពោះភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ព្រះរាជាអង្គនេះជីករំលើងគុណធម៌របស់ខ្លួនចេញអស់ហើយ ម្នាលភិក្ខុទាំងឡាយ ព្រះរាជា

ឧបហតាយំ ភិក្ខវេ រាជា សចាយំ ភិក្ខវេ រាជា បិតរំ ធម្មិកំ ធម្មរាជានំ ជីវិតា ន វោរោបេស្សថ ឥមស្មិំយេវស្ស អាសនេ វិរជំ វីតមលំ ធម្មចក្ខុំ ឧប្បជ្ជិស្សថាតិ ។ ឥទមវោច ភគវា ។ អត្តមនា តេ ភិក្ខូ ភគវតោ ភាសិតំ អភិនន្ទុន្តិ ។

សាមញ្ញផលសុត្តំ និដ្ឋិតំ ទុតិយំ ។

អគ្គិនេះ ផ្តាច់បង់គុណធម៌របស់ខ្លួនចេញអស់ហើយ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើព្រះរាជាអង្គនេះ មិនបានផ្តាច់បង់ព្រះជន្មាយុនៃព្រះបិតា ដែលជាព្រះធម្មរាជ ប្រកបដោយធម៌ទេ ធម្មចក្ខុគឺសោតាបត្តិមគ្គ ដែលប្រាសចាកធុលី ប្រាសចាកមន្ទិល នឹងកើតឡើង ដល់ព្រះរាជាអង្គនោះ លើអាសនៈនេះ មិនខាន ឡើយ ។ លុះព្រះមានព្រះភាគ ទ្រង់មានព្រះបន្ទូលដូច្នេះហើយ ។ ភិក្ខុទាំងឡាយនោះ ក៏មានសេចក្តីត្រេកអរ រីករាយនឹងភាសិតរបស់ព្រះមានព្រះភាគ ។

ចប់ សាមញ្ញផលសូត្រ ទី ២ ។

---

# អម្ពដ្ឋសុត្តំ តតិយំ

(១៦១) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា កោសលេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ យេន ឥច្ឆានង្គល-ន្នាម កោសលានំ ព្រាហ្មណគាមោ តទវសរិ ។ តត្រ សុទំ ភគវា ឥច្ឆានង្គលេ វិហរតិ ឥច្ឆានង្គល-វនសណ្ឌេ ។

(១៦២) តេន ខោ បន សមយេន ព្រាហ្ម-ណោ បោក្ខរសាតិ(១) ឧក្កដ្ឋំ អជ្ឈាវសតិ សត្តុ-ស្សទំ សតិណកដ្ឋោទកំ សធញ្ញំ រាជភោគ្គំ រញ្ញា បសេនទិកោសលេន ទិន្នំ រាជទាយំ ព្រហ្មទេយ្យំ ។ អស្សោសិ ខោ ព្រាហ្មណោ បោក្ខរសាតិ សម-ណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យ-កុលា បព្វជិតោ កោសលេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ

---

១ ម. បោក្ខរសាទិ ។

# អម្ពដ្ឋសូត្រ ទី ៣

(១៤១) (សូត្រនេះ) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិក(១) ក្នុងកោសលជនបទ ព្រមដោយភិក្ខុសង្ឃច្រើន ចំនួន៥០០រូប បានស្តេចទៅដល់ស្រុកព្រាហ្មណ៍ឈ្មោះឥច្ឆានង្គលៈ របស់ដែនកោសល ។ ព្រះមានព្រះភាគគង់នៅក្នុងដងព្រៃឈ្មោះឥច្ឆានង្គលៈ ទៀបស្រុកឥច្ឆានង្គលៈនោះ ។

(១៤២) សម័យនោះឯង ព្រាហ្មណ៍ឈ្មោះពោក្ខរសាតិ នៅគ្រប់គ្រងឧក្កដ្ឋនគរ ដែលជាក្រុងកុះករដោយសត្វ (ទាំងមនុស្ស) បរិបូណ៌ដោយស្មៅ ឧស ទឹក បរិបូណ៌ដោយស្រូវអង្ករ ជាព្រះរាជទ្រព្យដែលព្រះបាទបសេនទិកោសល ទ្រង់ព្រះរាជទាន ជាព្រះរាជអំណោយ ជារង្វាន់ដ៏ប្រសើរ គឺទ្រង់ប្រទានដោយដាច់ខាត ។ ព្រាហ្មណ៍ឈ្មោះពោក្ខរសាតិ បានឮថា ព្រះសមណគោតមដ៏ចំរើន ជាសក្យបុត្រ ចេញចាកសក្យត្រកូល ទៅទ្រង់ព្រះផ្នួស ឥឡូវ ទ្រង់ពុទ្ធដំណើរមកកាន់ចារិកក្នុងកោសលជនបទ ព្រមដោយភិក្ខុសង្ឃច្រើន ចំនួន៥០០រូប មកដល់

១ អដ្ឋកថា ថា ចារិកក្នុងទីនេះ សំដៅយកផ្លូវឆ្ងាយ ។

ឥច្ឆានង្គលំ អនុប្បត្តោ ឥច្ឆានង្គលេ វិហរតិ ឥច្ឆានង្គលវនសណ្ឌេ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ(1) សោ ឥមំ លោកំ សទេវកំ សមារកំ សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ។

---

១ ម. យ. ឥតិសទ្ទោ ន ទិស្សតិ ។

ស្រុកឈ្មោះឥច្ឆានង្គលៈ គង់នៅក្នុងដងព្រៃឈ្មោះឥច្ឆានង្គលៈ ទៀបស្រុកឈ្មោះឥច្ឆានង្គលៈ កិត្តិសព្ទសំឡេងសរសើរនៃព្រះសមណគោតមដ៏ចំរើននោះពីរោះខ្ចរខ្ចាយ សុសសាយមកយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាកសេចក្ដីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ គឺសេចក្ដីចេះដឹង និងក្រឹត្យ ដែលបុគ្គលគប្បីប្រព្រឹត្ត ព្រះអង្គមានដំណើរល្អ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀត ព្រះអង្គបានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់ចំពោះព្រះអង្គ ហើយញុំាងលោកនេះព្រមទាំងទេវលោក មារលោក ព្រហ្មលោក និងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស ឲ្យបានត្រាស់ដឹងផង ទ្រង់សំដែងធម៌មានលំអបទដើម បទកណ្ដាល និងបទចុង ទ្រង់ប្រកាសព្រហ្មចរិយធម៌ ព្រមទាំងអត្ថនិងព្យញ្ជនៈដ៏ពេញបរិបូណ៌ បរិសុទ្ធទាំងអស់ ក៏ការដែលបានឃើញ បានជួបនឹងព្រះអរហន្តទាំងឡាយ មានសភាពដូច្នោះ ជាការប្រពៃណាស់ ។

(១៦៣) តេន ខោ បន សមយេន ព្រាហ្មណស្ស បោក្ខរសាតិស្ស អម្ពដ្ឋោ នាម មាណវោ អន្តេវាសី ហោតិ អជ្ឈាយកោ មន្តធរោ តិណ្ណំ វេទានំ បារគូ សនិឃណ្ឌុកេដុភានំ សាក្ខរប្បភេទានំ ឥតិហាសបញ្ចមានំ បទកោ វេយ្យាករណោ លោកាយតមហាបុរិសលក្ខណេសុ អនវយោ អនុញ្ញាតបដិញ្ញាតោ សកេ អាចរិយកេ តេវិជ្ជកេ បាវចនេ យមហំ ជានាមិ តំ ត្វំ ជានាសិ យំ ត្វំ ជានាសិ តមហំ ជានាមីតិ ។ អថខោ ព្រាហ្មណោ បោក្ខរសាតិ អម្ពដ្ឋំ មាណវំ អាមន្តេសិ អយំ តាត អម្ពដ្ឋ សមណោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ កោសលេសុ ចារិកំ ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ ឥច្ឆានង្គលំ អនុប្បត្តោ

### អម្ពដ្ឋសូត្រ និទាន រឿងអម្ពដ្ឋមាណព

(១៤៣) សម័យនោះឯង មាណពឈ្មោះអម្ពដ្ឋ ជាសិស្សរបស់ព្រាហ្មណ៍បោក្ខរសាតិ ជាអ្នកកយមន្ត ចេះចាំនូវមន្ត ជាអ្នកដល់នូវត្រើយនៃត្រៃវេទ(១) ព្រមទាំងគម្ពីរនិឃណ្ឌុ(២) គម្ពីរកេដុភៈ(៣) ព្រមទាំងអក្ខរប្បភេទ គឺសិក្ខានិងនិរុត្តិ ដែលមានគម្ពីរឥតិហាសៈ(៤) ជាគំរប់ ៥ ជាអ្នករៀនយកនូវបទនិងវេយ្យាករណ៍ ជាអ្នកមិនខុនថយគឺស្ទាត់ជំនាញ ក្នុងលោកាយតសាស្ត្រ និងមហាបុរិសលក្ខណព្យាករណសាស្ត្រ ជាអ្នកដែលអាចារ្យបានអនុញ្ញាតហើយ ទាំងខ្លួនក៏បានប្តេជ្ញាហើយថា ខ្ញុំចេះអ្វី អ្នកក៏ចេះនោះដែរ អ្នកចេះអ្វី ខ្ញុំក៏ចេះនោះដែរ ក្នុងបាវចនៈ (ពាក្យជាប្រធានគឺលទ្ធិសាសនា) ដែលប្រកបដោយត្រៃវិជ្ជា ក្នុងសំណាក់អាចារ្យរបស់ខ្លួន ៗ គ្រានោះ បោក្ខរសាតិព្រាហ្មណ៍ ហៅអម្ពដ្ឋមាណពមកប្រាប់ថា នែអម្ពដ្ឋ ព្រះសមណគោតមជាសក្យបុត្រនេះចេញចាកសក្យត្រកូលទៅទ្រង់ផ្នួសហើយ ត្រាច់មកកាន់ចារិកក្នុងកោសលជនបទ ឥឡូវទ្រង់ពុទ្ធដំណើរព្រមដោយភិក្ខុសង្ឃច្រើន ចំនួន ៥០០ រូប មកដល់ស្រុកឥច្ឆានង្គលៈ គង់ក្នុងដងព្រៃ

---

១ អដ្ឋកថា ថា ត្រៃវេទនោះបានដល់វេទ ៣ គឺ ឥរុវេទ ១ យជុវេទ ១ សាមវេទ ១ ។
២ ដីកាថា គម្ពីរដែលសំដែងអំពីសព្ទនឹងវិធីចែកសព្ទ តាមលំដាប់ពាក្យ (អក្ខរាភិធានសព្ទ ឬសព្ទវចនាធិប្បាយ) ។ ៣ ដីកាថា គម្ពីរដែលនិយាយអំពីកំណត់កិរិយាសព្ទ មានវិកប្បច្រើនយ៉ាង ដែលចែកចេញទៅជាវណ្ណៈ បទ សម្ពន្ធ នឹងអត្ថនៃបទ ជាដើម ដែលហៅថា មូលកិរិយាកប្បសាស្ត្រ ។ ៤ អដ្ឋកថា ថា គម្ពីរដែលនិយាយពីរឿងព្រេង ប្រកបដោយពាក្យថា ឥតិហអាសៈឥតិហអាសៈ ។

ឥច្ឆានង្គលេ វិហរតិ ឥច្ឆានង្គលវនសណ្ឌេ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា-តិ សោ ឥមំ លោកំ សទេវកំ សមារកំ ស-ព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេតិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិ-យោសានកល្យាណំ សាត្ថំ សព្យញ្ជនំ កេវលប-រិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ បកាសេតិ សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ឯវំ ខោ តាត អម្ពដ្ឋ មាណវ យេន សមណោ គោតមោ តេនុបសង្កម ឧបសង្កមិត្វា សមណំ

ឥច្ឆានង្គលៈ ទៀបស្រុកឥច្ឆានង្គលៈ កិត្តិសព្ទសំឡេងសរសើរព្រះសមណ-គោតមដ៏ចំរើននោះ ពីរោះឮខ្ចរខ្ចាយសុសសាយមកយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គប្រ-កបដោយវិជ្ជានិងចរណៈ គឺសេចក្តីចេះដឹងនិងក្រឹត្យដែលបុគ្គលគប្បីប្រព្រឹត្ត ព្រះអង្គមានដំណើរល្អ ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គទូន្មាននូវបុគ្គលដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គបានត្រាស់ដឹងនូវចតុរារិយសច្ច ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀត ព្រះអង្គបានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់ដោយព្រះអង្គឯង ហើយញ៉ាំងលោកនេះ ព្រមទាំងទេវលោក មារលោក ព្រហ្មលោក និងពពួកសត្វព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសឲ្យបានត្រាស់ដឹងផង ទ្រង់សំដែងធម៌មានលំអបទដើម បទកណ្តាលនិងបទចុង ទ្រង់ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថនិងព្យញ្ជនៈ ដ៏ពេញបរិ-បូណ៌ បរិសុទ្ធទាំងអស់ ក៏ការដែលបានឃើញបានជួបនឹងព្រះអរហន្តទាំងឡាយ មានសភាពយ៉ាងនោះជាការប្រពៃណាស់ នៃអម្ពដ្ឋមាណព អ្នកចូរមកណេះ ចូរចូលទៅរកព្រះសមណគោតម លុះចូលទៅដល់ហើយ

គោតមំ ជានាហិ យទិ វា តំ ភវន្តំ គោតមំ តថា សន្តំយេវ សទ្ទោ អព្ភុគ្គតោ យទិ វា នោ តថា យទិ វា សោ ភវំ គោតមោ តាទិសោ យទិ វា ន តាទិសោ តថា មយំ ភវន្តំ គោតមំ វេទិស្សាមាតិ ។ យថា កថំ បនាហំ ភោ តំ ភវន្តំ គោតមំ ជានិស្សាមិ យទិ វា តំ ភវន្តំ គោតមំ តថា សន្តំយេវ សទ្ទោ អព្ភុគ្គតោ យទិ វា នោ តថា យទិ វា សោ ភវំ គោតមោ តាទិសោ យទិ វា ន តាទិសោតិ ។

អាគតានិ ខោ តាត អម្ពដ្ឋ អម្ហាកំ មន្តេសុ ទ្វត្តឹសមហាបុរិសលក្ខណានិ យេហិ សមន្នាគតស្ស មហាបុរិសស្ស ទ្វេវ[១] គតិយោ ភវន្តិ អនញ្ញា សចេ អគារំ អជ្ឈាវសតិ រាជា ហោតិ ចក្កវត្តិ ធម្មិកោ ធម្មរាជា ចាតុរន្តោ វិជិតាវី ជនបទត្ថាវរិយប្បត្តោ សត្តរតនសមន្នាគតោ តស្សិមានិ សត្តរតនានិ ភវន្តិ សេយ្យថីទំ ចក្ករតនំ ហត្ថិរតនំ អស្សរតនំ មណិរតនំ

## អម្ពដ្ឋសូត្រ និទាន រឿងអម្ពដ្ឋមាណព

ចូរពិនិត្យ នូវព្រះសមណគោតមមើល ទោះបីកិត្តិសព្ទសំឡេងសរសើរព្រះសមណគោតមដ៏ចំរើននោះ ឮខ្ចរខ្ចាយទៅពិតដូច្នោះមែន ឬមិនមែនដូច្នោះទេ ទោះបីព្រះសមណគោតមដ៏ចំរើននោះ ប្រាកដដូច្នោះក្តី មិនប្រាកដដូច្នោះក្តី យើងនឹងដឹង នូវព្រះសមណគោតមដ៏ចំរើននោះដោយពិត ៗ ម្នាលគ្នាយើងដ៏ចំរើន ទោះបីកិត្តិសព្ទសំឡេងសរសើរព្រះសមណគោតមដ៏ចំរើននោះ ឮខ្ចរខ្ចាយសុសសាយពិតដូច្នោះក្តី មិនពិតដូច្នោះក្តី ទោះបីព្រះសមណគោតមដ៏ចំរើននោះ ប្រាកដដូច្នោះក្តី មិនប្រាកដដូច្នោះក្តី យើងនឹងដឹង នូវព្រះសមណគោតមដ៏ចំរើននោះដោយប្រការឯណានីមួយ មិនខានឡើយ ៗ ម្នាលអម្ពដ្ឋ មហាបុរិសលក្ខណៈទាំងឡាយ ៣២ ប្រការ មានប្រាកដមកក្នុងមន្តទាំងឡាយរបស់យើងហើយ កាលបើមហាបុរស ប្រកបដោយមហាបុរិសលក្ខណៈណាហើយ គង់មានគតិជាពីរយ៉ាង មិនខុសអំពីគតិទាំងពីរយ៉ាងនេះទេ គឺបើមហាបុរសនៅគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្កពត្តិឋិតនៅក្នុងធម៌ ជាស្តេចប្រកបដោយធម៌ មានជ័យជំនះផ្សាយរាជអំណាចរហូតដល់ផែនដី ដែលមានសមុទ្រទាំង ៤ ព័ទ្ធជុំវិញ ព្រះអង្គដល់នូវភាវៈជាអ្នកមាំមួនក្នុងជនបទ ប្រកបដោយរតនៈ ៧ ប្រការ រតនៈ ៧ ប្រការរបស់ព្រះអង្គនោះ គឺ ចក្ករ័តន៍ ១ ដំរីរ័តន៍ ១ សេះរ័តន៍ ១ មណិរ័តន៍ ១

ឥត្ថីរតនំ គហបតិរតនំ បរិណាយករតនមេវ សត្តមំ បរោសហស្សំ ខោ បនស្ស បុត្តា ភវន្តិ សូរា វីរង្គរូបា បរសេនប្បមទ្ទនា សោ ឥមំ បឋវឹ សាគរបរិយន្តំ អទណ្ឌេន អសត្ថេន ធម្មេន អភិវិជិយ អជ្ឈាវសតិ សចេ បន អគារស្មា អនគារិយំ បព្វជតិ អរហំ ហោតិ សម្មាសម្ពុទ្ធោ លោកេ វិវដ្ដច្ឆទោ អហំ ខោ បន តាត អម្ពដ្ឋ មន្តានំ ទាតា ត្វំ មន្តានំ បដិគ្គហេតា(១) ។ ឯវំ ភោតិ ខោ អម្ពដ្ឋោ មាណវោ ព្រាហ្មណស្ស បោក្ខរសាតិស្ស បដិស្សុត្វា ឧដ្ឋាយាសនា ព្រាហ្មណំ បោក្ខរសាតឹ អភិវាទេត្វា បទក្ខិណំ កត្វា វឡវារថមារុយ្ហ សម្ពហុលេហិ មាណវេហិ សទ្ធឹ យេន ឥច្ឆានង្គលវនសណ្ឌោ តេន បាយាសិ យាវតិកា យានស្ស ភូមិ យានេន គន្ត្វា យានា បច្ចោរោហិត្វា បត្តិកោវ អារាមំ បាវិសិ ។

---

១ ឧ. ម. បដិគ្គហេតាតិ ។

ស្រីរ័តន៍១ គហបតិរ័តន៍ (អ្នកជាប្រធានត្រួតត្រាការរ៉ាក្សព្រះរាជកំង) ១ នឹងបរិណាយករ័តន៍ គឺអគ្គមហាសេនាធិបតីមួយទៀត ជាគំរប់៧ ចំណែកព្រះរាជឱរសរបស់ទ្រង់ ក៏មានចំនួនច្រើនពាន់ សុទ្ធតែជាអ្នកក្លៀវក្លា មានរូបសណ្ឋានជាអ្នកអង់អាច អាចញាំញីនូវសេនារបស់ស្តេចឯទៀតបាន ព្រះអង្គទ្រង់ប្រាបប្រាម គ្រប់គ្រងនូវផែនដីនេះ ដែលមានសាគរជាទីបំផុត ដោយធម៌ គឺសីល ៥ មិនបាច់ប្រើរាជអាជ្ញា មិនបាច់ប្រើសស្ត្រាវុធឡើយ បើព្រះអង្គចេញពីព្រះរាជដំណាក់ទៅទ្រង់ព្រះផ្នួស នឹងបានត្រាស់ជាព្រះអរហន្តសម្មាសម្ពុទ្ធក្នុងលោក ជាអ្នកមានកិលេសជាគ្រឿងបិទបាំងបើកហើយ ម្នាលអម្ពដ្ឋ អញឯងជាអ្នកឲ្យនូវមន្តទាំងឡាយ(ដល់អ្នក)អ្នកក៏បានទទួលរៀននូវមន្តទាំងឡាយហើយ ។ អម្ពដ្ឋមាណពបានទទួលពាក្យរបស់បោក្ខរសាតិព្រាហ្មណ៍ថា បពិត្រលោកដ៏ចំរើន យ៉ាងនេះឯង ហើយក៏ក្រោកចាកអាសនៈថ្វាយបង្គំបោក្ខរសាតិព្រាហ្មណ៍ ធ្វើប្រទក្សិណហើយឡើងជិះរថដែលទឹមដោយសេះ ទៅជាមួយនឹងមាណពមានចំនួនច្រើននាក់ សំដៅទៅរកដងព្រៃឥច្ឆានង្គលៈ បរយានទៅទល់ត្រឹមទី ដែលយានល្មមឈប់បាន ហើយក៏ចុះពីយានដើរទៅដោយជើងទទេ ឆ្ពោះទៅកាន់អារាម ។

អម្ពដ្ឋសុត្តេ និទានំ អម្ពដ្ឋមាណវវត្ថុ

(១៤៤) តេន ខោ បន សមយេន សម្ពហុលា ភិក្ខូ អព្ភោកាសេ ចង្កមន្តិ ។ អថខោ អម្ពដ្ឋោ មាណវោ យេន តេ ភិក្ខូ តេនុបសង្កមិ ឧបសង្កមិត្វា តេ ភិក្ខូ ឯតទវោច កហំ នុ ខោ ភោ ឯតរហិ សោ ភវំ គោតមោ វិហរតិ តំ ហិ មយំ ភវន្តំ គោតមំ ទស្សនាយ ឥធូបសង្កន្តាតិ ។ អថខោ តេសំ ភិក្ខូនំ ឯតទហោសិ អយំ ខោ អម្ពដ្ឋោ មាណវោ អភិញ្ញាតកោលញ្ញោ ចេវ អភិញ្ញាតស្ស ច ព្រាហ្មណស្ស បោក្ខរសាតិស្ស អន្តេវាសី អគរុ ខោ បន ភគវតោ ឯវរូបេហិ កុលបុត្តេហិ សទ្ធឹ កថាសល្លាបោ ហោតីតិ ។ តេ អម្ពដ្ឋំ មាណវំ ឯតទវោចុំ ឯសោ អម្ពដ្ឋ វិហារោ សំវុតទ្វារោ តេន អប្បសទ្ទោ ឧបសង្កមិត្វា អតរមានោ អាឡិន្ទំ បវិសិត្វា ឧក្កាសិត្វា អគ្គឡំ អាកោដេហិ វិវរិស្សតិ តេ ភគវា ទ្វារន្តិ ។ អថខោ អម្ពដ្ឋោ មាណវោ យេន សោ វិហារោ សំវុតទ្វារោ តេន អប្បសទ្ទោ ឧបសង្កមិត្វា អតរមានោ អាឡិន្ទំ បវិសិត្វា ឧក្កាសិត្វា

## អម្ពដ្ឋសូត្រ និទាន រឿងអម្ពដ្ឋមាណព

(១៤៤) សម័យនោះឯង ភិក្ខុទាំងឡាយច្រើនរូប កំពុងចង្ក្រមនៅកន្លែងវាល ៗ គ្រានោះ អម្ពដ្ឋមាណពចូលទៅរកភិក្ខុទាំងនោះ លុះចូលទៅដល់ហើយ បានពោលពាក្យនេះ នឹងភិក្ខុទាំងឡាយនោះថា បពិត្រលោកទាំងឡាយដ៏ចំរើន ឥឡូវនេះ ព្រះគោតមដ៏ចំរើន ព្រះអង្គគង់នៅកន្លែងណា ដ្បិតយើងខ្ញុំទាំងឡាយ ចូលមកកន្លែងនេះ ដើម្បីនឹងគាល់ព្រះគោតមដ៏ចំរើននោះ ៗ គ្រានោះឯង ភិក្ខុទាំងនោះ មានសេចក្ដីត្រិះរិះដូច្នេះថា អម្ពដ្ឋមាណពនេះ ជាមនុស្សកើតក្នុងត្រកូល ល្បីល្បាញផង ត្រូវជាសិស្សរបស់បោក្ខរសាតិព្រាហ្មណ៍ ដែលល្បីល្បាញ (ដោយរូបជាតិ មន្ត ត្រកូល នឹងប្រទេស) ផង ការសំណេះសំណាលជាមួយនឹងកុលបុត្រ មានសភាពយ៉ាងនេះ ជាការមិនធ្ងន់ដល់ព្រះមានព្រះភាគប៉ុន្មានទេ ៗ ភិក្ខុទាំងឡាយនោះ ក៏និយាយពាក្យនុ៎ះទៅនឹងអម្ពដ្ឋមាណពថា ម្នាលអម្ពដ្ឋ វិហារ (គន្ធកុដិ) នុ៎ះ បិទទ្វារហើយ ព្រោះហេតុនោះ ចូរអ្នកស្ងៀមស្ងប់សំឡេង ដើរចូលទៅកុំរលះរលាំង លុះចូលទៅដល់របៀងហើយក្អកគ្រហែម គោះសន្ទះទ្វារ ព្រះមានព្រះភាគ គង់នឹងបើកទ្វារឲ្យអ្នក ៗ គ្រានោះ អម្ពដ្ឋមាណពស្ងៀមស្ងប់សំឡេង ដើរចូលទៅរកវិហារដែលមានទ្វារបិទ មិនរលះរលាំង ចូលដល់ទៅរបៀងហើយក្អកគ្រហែម

អគ្គឡំ អាកោដេសិ ។ វិវរិ ភគវា ទ្វារំ ។ បាវិសិ អម្ពដ្ឋោ មាណវោ ។ មាណវកាបិ ខោ(១) បវិសិត្វា ភគវតា សទ្ធឹ សម្មោទឹសុ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទឹសុ ។

(១៤៨) អម្ពដ្ឋោ បន មាណវោ ចង្កមន្តោបិ និសិន្នេ ភគវតា កញ្ចិ កញ្ចិ(២) កថំ សារណីយំ វីតិសារេតិ ឋិតោបិ និសិន្នេ ភគវតា កញ្ចិ កញ្ចិ កថំ សារណីយំ វីតិសារេតិ ។ អថខោ ភគវា អម្ពដ្ឋំ មាណវំ ឯតទវោច ឯវំ នុ(៣) តេ អម្ពដ្ឋ ព្រាហ្មណេហិ វុឌ្ឍេហិ មហល្លកេហិ អាចរិយបាចរិយេហិ សទ្ធឹ កថាសល្លាបោ ហោតិ យថយិទំ ចរំ តិដ្ឋំ និសិន្នេន មយា កញ្ចិ កញ្ចិ កថំ សារណីយំ វីតិសារេសីតិ ។ នោ ហិទំ ភោ គោតម គច្ឆន្តោ វា ហិ ភោ គោតម គច្ឆន្តេន ព្រាហ្មណោ ព្រាហ្មណេន សទ្ធឹ សល្លបិតុមរហតិ ឋិតោ វា ហិ

---

១ ឱ ម ខោសទ្ទោ ន បញ្ញាយតិ ។ ២ ម. កិញ្ចិ កិញ្ចិ ។ ៣ ឱ. នុ ខោ ។

គោះសន្ទះទ្វារ ៗ ព្រះមានព្រះភាគក៏បើកទ្វារឲ្យ ៗ អម្ពដ្ឋមាណពក៏ចូលទៅ ៗ ចំណែកខាងពួកមាណព ចូលទៅដល់ហើយ បានពោលពាក្យសំណេះសំណាលនឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួរសំណេះសំណាល នឹងពាក្យគួររលឹកហើយ ទើបអង្គុយក្នុងទីសមគួរ ៗ

(១៤៥) ឯអម្ពដ្ឋមាណព សូម្បីកំពុងដើរ ក៏ហ៊ានចរចានូវពាក្យដែលគួររលឹកណាមួយ ជាមួយព្រះមានព្រះភាគ ដែលទ្រង់កំពុងគង់ សូម្បីឈរក៏ហ៊ានចរចានូវពាក្យដែលគួររលឹកណាមួយ ជាមួយព្រះមានព្រះភាគ ដែលទ្រង់កំពុងគង់ ៗ គ្រានោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះទៅនឹងអម្ពដ្ឋមាណពថា ម្នាលអម្ពដ្ឋ អ្នកធ្លាប់តែចរចាជាមួយនឹងពួកព្រាហ្មណ៍ចាស់ៗ មានអាយុច្រើន ជាអាចារ្យតូចអាចារ្យធំ (របស់អ្នក) ដូចអ្នកកំពុងដើរ កំពុងឈរ ហើយចរចានូវពាក្យ ដែលគួររលឹកណាមួយ ជាមួយនឹងតថាគតដែលកំពុងអង្គុយយ៉ាងហ្នឹងឬ ៗ អម្ពដ្ឋមាណពក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចំរើន ហេតុនេះមិនមែនដូច្នោះទេ បពិត្រព្រះគោតមដ៏ចំរើន ព្រោះថា ព្រាហ្មណ៍កំពុងដើរ គួរនិយាយជាមួយនឹងព្រាហ្មណ៍កំពុងដើរ បពិត្រព្រះគោតមដ៏ចំរើន ព្រាហ្មណ៍កំពុងឈរ គួរ

ភោ គោតម ឋិតេន ព្រាហ្មណោ ព្រាហ្មណេន សទ្ធឹ សល្លបិតុមរហតិ និសិន្នោ វា ហិ ភោ គោតម និសិន្នេន ព្រាហ្មណោ ព្រាហ្មណេន សទ្ធឹ សល្លបិតុមរហតិ សយានោ វា ហិ ភោ គោតម សយានេន ព្រាហ្មណោ ព្រាហ្មណេន សទ្ធឹ សល្លបិតុមរហតិ យេ ច ខោ ភោ គោតម មុណ្ឌកា សមណកា ឥព្ភា កណ្ហា ពន្ធុបាទាបច្ចា(១) តេបិ មេ សទ្ធឹ ឯវំ កថាសល្លាបោ ហោតិ យថរិវ ភោតា គោតមេនាតិ ។ អត្ថិកវតោ ខោ បន តេ អម្ពដ្ឋ ឥធាគមនំ អហោសិ យាយេវ ខោ បនត្ថាយ អាគច្ឆេយ្យាថ តមេវ អត្ថំ សាធុកំ មនសិករេយ្យាថ អវុសិតវាយេវ ខោ បន អម្ពដ្ឋោ មាណវោ វុសិតមានី កិមញ្ញត្រ អវុសិតត្តាតិ ។ អថខោ អម្ពដ្ឋោ មាណវោ ភគវតា អវុសិតវាទេន វុច្ចមានោ កុបិតោ អនត្តមនោ ភគវន្តំយេវ ខុំសេន្តោ ភគវន្តំយេវ វម្ភេន្តោ ភគវន្តំយេវ វទមានោ(២) សមណោ ច មេ ភោ គោតមោ បាបិតោ ភវិស្សតីតិ ភគវន្តំ ឯតទវោច

១ ពន្ធុបាទាបច្ចាតិបិ ញាណោ ។ ២ ឱ. ម. ឧបវទមានោ ។

និយាយ ជាមួយនឹងព្រាហ្មណ៍កំពុងឈរ បពិត្រព្រះគោតមដ៏ចំរើន ព្រាហ្មណ៍កំពុងអង្គុយ គួរនិយាយជាមួយនឹងព្រាហ្មណ៍កំពុងអង្គុយ បពិត្រព្រះគោតមដ៏ចំរើន ព្រាហ្មណ៍កំពុងដេក គួរនិយាយជាមួយនឹងព្រាហ្មណ៍កំពុងដេកដូចគ្នា បពិត្រព្រះគោតមដ៏ចំរើន តែការនិយាយចរចា របស់ខ្ញុំជាមួយព្រះគោតមដ៏ចំរើន ដូចគ្នានឹងការនិយាយចរចា របស់ខ្ញុំជាមួយនឹងពួកសមណៈត្រងោល ដែលជាគោត្រកូលគហបតិ ជាកណ្ហគោត្រ កើតអំពីព្រះបាទរបស់មហាព្រហ្មដូច្នោះដែរ ៗ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអម្ពដ្ឋ ចំណែកអ្នកមានសេចក្តីត្រូវការហើយ ទើបបានមកក្នុងទីនេះ បើអ្នកទាំងឡាយមក ដើម្បីប្រយោជន៍ណា គួរធ្វើទុកក្នុងចិត្តនូវប្រយោជន៍នោះឯង ឲ្យសម្រេចទៅចុះ តែអម្ពដ្ឋមាណព ជាអ្នកមិនធ្លាប់បានសិក្សាទេ ប្រកាន់ថា ខ្ញុំធ្លាប់បានសិក្សាមកហើយ ការប្រកាន់ដូច្នោះម្តេចបាន ព្រោះអ្នកមិនបានសិក្សាក្នុងត្រកូលនៃអាចារ្យដទៃសោះ ៗ លំដាប់នោះ អម្ពដ្ឋមាណពកាលត្រូវព្រះមានព្រះភាគត្រាស់ដោយវាទៈថា ខ្ញុំមិនបានសិក្សា(ដូច្នោះ)ហើយ ក៏ខឹងអាក់អន់ចិត្ត កាលនឹងពោលទ្រគោះទៅរកព្រះមានបុណ្យ កាលនឹងពោលសង្កត់ព្រះមានបុណ្យ កាលនឹងពោលផ្ចាញ់ព្រះមានបុណ្យ ក៏គិតថា ព្រះសមណគោតមដ៏ចំរើន មុខជានឹងធ្វើអញឲ្យអាក្រក់ ហើយបានពោលពាក្យនេះនឹងព្រះ

ចណ្ឌា ភោ គោតម សក្យជាតិ ផរុសា ភោ គោតម សក្យជាតិ លហុសា ភោ គោតម សក្យជាតិ រភសា ភោ គោតម សក្យជាតិ ឥព្ភា សន្តា ឥព្ភា សមានា ន ព្រាហ្មណេ សក្ការោន្តិ ន ព្រាហ្មណេ គរុករោន្តិ ន ព្រាហ្មណេ មានេន្តិ ន ព្រាហ្មណេ បូជេន្តិ ន ព្រាហ្មណេ អបចាយន្តិ តយិទំ ភោ គោតម នច្ឆន្នំ តយិទំ នប្បតិរូបំ យទិមេ សក្យា ឥព្ភា សន្តា ឥព្ភា សមានា ន ព្រាហ្មណេ សក្ការោន្តិ ន ព្រាហ្មណេ គរុករោន្តិ ន ព្រាហ្មណេ មានេន្តិ ន ព្រាហ្មណេ បូជេន្តិ ន ព្រាហ្មណេ អបចាយន្តីតិ ។ ឥតិហ អម្ពដ្ឋោ មាណវោ ឥទំ បឋមំ សក្យេសុ ឥព្ភវាទំ និបាតេសិ ។

(១៤៦) កឹ បន តេ អម្ពដ្ឋ សក្យា អបរទ្ធុន្តិ ។ ឯកមិទាហំ ភោ គោតម សមយំ អាចរិយស្ស ព្រាហ្មណស្ស បោក្ខរសាតិស្ស កេនចិទេវ ករណីយេន កបិលវត្ថុំ អគមាសឹ យេន សក្យានំ សន្ធា-

មានព្រះភាគថា នៃព្រះគោតមដ៏ចំរើន ជាតិសក្យៈកាចណាស់ នៃព្រះគោតមដ៏ចំរើន ជាតិសក្យៈអាក្រក់ណាស់ នៃព្រះគោតមដ៏ចំរើន ជាតិសក្យៈមានចិត្តស្រាលណាស់ នៃព្រះគោតមដ៏ចំរើន ជាតិសក្យៈជាពួកគហបតិ មានសំដីច្រើនណាស់ ជាពួកគហបតិ ឥតធ្វើសក្ការៈពួកព្រាហ្មណ៍ ឥតធ្វើសេចក្តីគោរពពួកព្រាហ្មណ៍ ឥតរាប់អានពួកព្រាហ្មណ៍ ឥតបូជាពួកព្រាហ្មណ៍ ឥតកោតក្រែងពួកព្រាហ្មណ៍ឡើយ នៃព្រះគោតមដ៏ចំរើន ត្រង់ដែលពួកសក្យៈនេះ ជាពួកគហបតិ ពួកគហបតិ ឥតធ្វើសក្ការៈពួកព្រាហ្មណ៍ ឥតធ្វើសេចក្តីគោរពពួកព្រាហ្មណ៍ ឥតរាប់អានពួកព្រាហ្មណ៍ ឥតបូជាពួកព្រាហ្មណ៍ ឥតកោតក្រែងពួកព្រាហ្មណ៍ នេះឯងជាអំពើមិនត្រូវទំនងទេ នេះឯងជាអំពើមិនសមគួរទេ ។ អម្ពដ្ឋមាណពបាននិយាយបន្ទុះបន្ទាប់ពួកសក្យៈ ថាជាពួកគហបតិ នេះជាពាក្យដំបូង ដោយប្រការដូច្នេះ ។

(១៤៦) ព្រះអង្គទ្រង់ត្រាស់សួរថា ម្នាលអម្ពដ្ឋ ចុះពួកសក្យៈបានប្រទូស្តនឹងអ្នកដូចម្តេច ។ អម្ពដ្ឋមាណពឆ្លើយថា បពិត្រព្រះគោតមដ៏ចំរើន សម័យមួយ ខ្ញុំបានទៅកាន់នគរកបិលពស្តុ ដោយកិច្ចនីមួយរបស់បោក្ខរសាតិព្រាហ្មណ៍ ជាអាចារ្យ (របស់ខ្ញុំ) ហើយបានចូលទៅកាន់សណ្ឋាគារ គឺសាលាបង្រៀនចំណេះវិជ្ជា សម្រាប់គ្រង់ពជសម្បត្តិរបស់

គារំ តេនុបសង្កមឹ តេន ខោ បន សមយេន សម្ពហុលា សក្យា ចេវ សក្យកុមារា ច សណ្ឋាគារេ ឧច្ចេសុ អាសនេសុ និសិន្នា ហោន្តិ អញ្ញមញ្ញំ អង្គុលិប្បតោទកេហិ(១) សញ្ជគ្ឃន្តា សង្កីឡន្តា អញ្ញទត្ថុ មមញ្ញេវ(២) មញ្ញេ អនុជគ្ឃន្តា(៣) ន មំ កោចិ អាសនេនបិ និមន្តេសិ តយិទំ ភោ គោតម ន ឆន្នំ តយិទំ នប្បតិរូបំ យទិមេ សក្យា ឥព្ភា សន្តា ឥព្ភា សមានា ន ព្រាហ្មណេ សក្ករោន្តិ ន ព្រាហ្មណេ គរុករោន្តិ ន ព្រាហ្មណេ មានេន្តិ ន ព្រាហ្មណេ បូជេន្តិ ន ព្រាហ្មណេ អបចាយន្តីតិ ។ ឥតិហ អម្ពដ្ឋោ មាណវោ ឥទំ ទុតិយំ សក្យេសុ ឥព្ភវាទំ និបាតេសិ ។

(១៤៧) លដុកិកាបិ(៤) ខោ អម្ពដ្ឋ សកុណិកា សកេ កុលាវកេ កាមលាបិនី ហោតិ សកំ ខោ បនេតំ អម្ពដ្ឋ សក្យានំ យទិទំ កបិលវត្ថុ ន អរហតា(៥) យស្មា អម្ពដ្ឋោ ឥមាយ អប្បមត្តាយ អភិសជ្ជិតុន្តិ ។ ចត្តារោមេ ខោ គោតម វណ្ណា

១ ម. អង្គុលិបតោទកេន ។ ២ ខ. អញ្ញទត្ថុ មមំយេវ ។ ម. អញ្ញទត្ថុមមញ្ញេវ ។
៣ ខ. អនោជគ្ឃន្តា ។ ៤ ម. លដុកិកាបិ ។ ៥ ខ. ន អរហតិ ។ ម. នារហតា ។

ពួកសក្យៈ សម័យនោះឯង ពួកសក្យៈនឹងពួកកុមារនៃសក្យៈជាច្រើនកំពុងអង្គុយនៅលើអាសនៈដ៏ខ្ពស់ក្នុងសណ្ឋាគារ កំពុងតែសើចលេង ប្រឡែងគ្នា ចាក់ក្រឡេកគ្នាទៅវិញទៅមក ទំនងជាសើចចំអកមករកខ្ញុំដោយពិត ឥតមានអ្នកណាមួយអញ្ជើញខ្ញុំ ដោយអាសនៈសោះ នៃព្រះគោតមដ៏ចំរើន ការនេះមិនទំនងទេ ការនេះមិនសមគួរទេ ត្រង់ដែលពួកសក្យៈនេះជាពូជគហបតិ ពួកគហបតិ ឥតធ្វើសក្ការៈពួកព្រាហ្មណ៍ ឥតធ្វើសេចក្តីគោរពពួកព្រាហ្មណ៍ ឥតគប់អានពួកព្រាហ្មណ៍ ឥតបូជាពួកព្រាហ្មណ៍ ឥតកោតក្រែងពួកព្រាហ្មណ៍ ។ អម្ពដ្ឋមាណព បាននិយាយបន្តុះបង្អាប់ពួកសក្យៈថាជាពូជគហបតិ នេះជាពាក្យគំរប់ពីរ ដោយប្រការដូច្នេះ ។

(១៤៧) ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអម្ពដ្ឋ ប៉ុនអម្បាលសត្វបក្សីចៀបកប្បាស នៅក្នុងសំបុករបស់ខ្លួន ក៏និយាយទៅតាមចំណង់បាន ម្នាលអម្ពដ្ឋ ឯនគរកបិលពស្តុនេះ ជារបស់សក្យៈទាំងឡាយផងគេ ព្រោះហេតុនោះ អម្ពដ្ឋមិនគួរខឹងសំបារក្នុងការសើចតិចតួចនេះទេ ។ អម្ពដ្ឋមាណពពោលពាក្យតបថា ព្រះគោតមដ៏ចំរើន វណ្ណៈ(ត្រកូល)ទាំងឡាយ

ខត្តិយា ព្រាហ្មណា វេស្សា សុទ្ទា តេសំ ហិ ភោ គោតម ចតុន្នំ វណ្ណានំ តយោ វណ្ណា ខត្តិយា ច វេស្សា ច សុទ្ទា ច អញ្ញទត្ថុ ព្រាហ្មណស្សេវ បរិចារកា សម្បជ្ជន្តិ តយិទំ ភោ គោតម ន ឆន្នំ តយិទំ នប្បតិរូបំ យទិមេ សក្យា ឥព្ភា សន្តា ឥព្ភា សមានា ន ព្រាហ្មណេ សក្ករោន្តិ ន ព្រាហ្មណេ គរុករោន្តិ ន ព្រាហ្មណេ មានេន្តិ ន ព្រាហ្មណេ បូជេន្តិ ន ព្រាហ្មណេ អបចាយន្តីតិ ។ ឥតិហ អម្ពដ្ឋោ មា-ណវោ ឥទំ ទុតិយំ សក្យេសុ ឥព្ភវាទំ និបាតេសិ ។

(១៤៨) អថខោ ភគវតោ ឯតទហោសិ អតិពាឡ្ហំ ខោ អយំ អម្ពដ្ឋោ មាណវោ សក្យេសុ ឥព្ភវាទេន និម្មាទេតិ យន្នូនាហំ គោត្តំ បុច្ឆេយ្យន្តិ ។ អថខោ ភគវា អម្ពដ្ឋំ មាណវំ ឯតទវោច កថំ គោត្តោសិ អម្ពដ្ឋាតិ ។ កណ្ហាយនោហមស្មិ ភោ គោតមាតិ ។ បោរាណំ ខោ បន តេ អម្ពដ្ឋ មាតាបេត្តិកំ នាមគោត្តំ អនុស្សរតោ អយ្យបុត្តា សក្យា ភវន្តិ

៤ នេះ គឺ ខត្តិយៈ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ បពិត្រព្រះគោតមដ៏ចំរើន តាមពិត បណ្តាវណ្ណៈទាំងឡាយ ៤ នេះ វណ្ណៈទាំង ៣ គឺខត្តិយៈ ១ វេស្សៈ ១ សុទ្ទៈ ១ ត្រូវតែបំរើប្រតិបត្តិពួកព្រាហ្មណ៍ នៃព្រះគោតមដ៏ចំរើន ការនេះមិនទំនងទេ ការនេះមិនសមគួរទេ ត្រង់ដែលសក្យៈទាំងឡាយនេះ ជាពួជគហបតិ ពួកគហបតិឥតធ្វើសក្ការៈពួកព្រាហ្មណ៍ ឥតធ្វើសេចក្តីគោរពពួកព្រាហ្មណ៍ ឥតកប់អានពួកព្រាហ្មណ៍ ឥតបូជាពួកព្រាហ្មណ៍ ឥតកោតក្រែងពួកព្រាហ្មណ៍ ។ អម្ពដ្ឋមាណព បាននិយាយបន្ទះបន្ទាប់ពួកសក្យៈ ថាជាពួជគហបតិ នេះជាពាក្យគំរប់ ៣ ដោយប្រការដូច្នេះ ។

(១៤៨) លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់មានសេចក្តីត្រិះរិះដូច្នេះថា អម្ពដ្ឋមាណពនេះ ខ្លាំងណាស់តើ ហ៊ានញុំាញីពួកសក្យៈដោយវាទៈថា ជាពួជគហបតិ បើដូច្នោះ ត្រូវតែថាគតសួរគោត្រមើល ។ ទើបព្រះមានព្រះភាគត្រាស់ពាក្យនេះនឹងអម្ពដ្ឋមាណពថា ម្នាលអម្ពដ្ឋ អ្នកជាគោត្រអ្វី ។ អម្ពដ្ឋមាណពឆ្លើយតបថា នៃព្រះគោតមដ៏ចំរើន ខ្ញុំជាកណ្ហាយនគោត្រ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអម្ពដ្ឋ អ្នកកាលបើនឹកទៅរកនាមនឹងគោត្ររបស់មាតាបិតា អំពីបុរាណ (នឹងដឹងថា) មានព្រះអង្គម្ចាស់

ជាពួកសក្យៈ ឯខ្លួនអ្នកជាកូននៃទាសីរបស់ពួកសក្យៈ (នោះ) ម្នាលអម្ពដ្ឋ ពួកសក្យៈតែងអាងព្រះរាជាទ្រង់ព្រះនាម ឧក្កាកៈ ថាជាបុព្វបុរស ។

(១៤៩) ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលអម្ពដ្ឋ ក្នុងកាលពីដើម មានព្រះរាជាទ្រង់ព្រះនាម ឧក្កាកៈ មានព្រះមហេសីជាទីស្រឡាញ់ជាទីពេញព្រះហឫទ័យ ទ្រង់មានបំណងនឹងបង្វែររាជសម្បត្តិ ឲ្យរាជបុត្ររបស់ព្រះមហេសីនោះ ហើយក៏បណ្ដេញពួកព្រះរាជកុមារជាច្បង (៤ព្រះអង្គ) គឺព្រះរាជកុមារនាម ឧក្កាមុខ ១ ករកណ្ឌុ ១ ហត្ថិនិកៈ ១ សិនិបុរៈ ១ ឲ្យចេញអំពីដែន ។ ព្រះរាជបុត្រទាំងនោះ លុះព្រះបិតាបណ្ដេញចេញអំពីដែនហើយ ក៏នាំគ្នាទៅអាស្រ័យនៅក្នុងដងព្រៃឈ្មោះមហាសាក ទៀបឆ្នេរស្រះបោក្ខរណី ជិតខាងហិមវន្តប្រទេស ។ ព្រះរាជបុត្រទាំងនោះ បានសម្រេចការរួមនៅជាមួយនឹងពួកព្រះភគិនីរបស់ខ្លួន ព្រោះការខ្លាចក្រែងក្លាយខូចជាតិ ។ ម្នាលអម្ពដ្ឋ គ្រានោះ ព្រះបាទឧក្កាករាជ បានត្រាស់ហៅពួកអាមាត្យដែលជារាជបរិវារមកថា ម្នាលអ្នកទាំងឡាយដ៏ចំរើន ឥឡូវនេះកុមារទាំងឡាយទៅនៅក្នុងទីណា ។ ពួករាជអាមាត្យក្រាបទូលថា បពិត្រព្រះសម្មតិទេព មានដងព្រៃឈ្មោះមហាសាក នៅទៀបឆ្នេរនៃស្រះបោក្ខរណី ជិតខាងហិមវន្តប្រទេស ឥឡូវនេះពួកព្រះរាជកុមារទៅនៅក្នុង

ទាសីបុត្តោ ត្វមសិ សក្យានំ សក្យា ខោ បន អម្ពដ្ឋ រាជានំ ឱក្កាកំ(១) បិតាមហំ ទហន្តិ ។

(១៤៩) ភូតបុព្វំ អម្ពដ្ឋ រាជា ឱក្កាកោ យា សា មហេសី បិយា មនាបា តស្សា បុត្តស្ស រជ្ជំ បរិណាមេតុកាមោ ជេដ្ឋកុមារេ រដ្ឋស្មា បព្វាជេសិ ឱក្កាមុខំ ករកណ្ឌុំ ហត្ថិនិកំ សិនិបុរំ(២) ។ តេ រដ្ឋស្មា បព្វាជិតា(៣) ហិមវន្តបស្សេ បោក្ខរណិយា តីរេ មហាសាកវនសណ្ឌោ(៤) តត្ថ វាសំ កប្បេសុំ ។ តេ ជាតិសម្ភេទភយា សកាហិ ភគិនីហិ សទ្ធឹ សំវាសំ កប្បេសុំ ។ អថខោ អម្ពដ្ឋ រាជា ឱក្កាកោ អមច្ចេ បារិសជ្ជេ អាមន្តេសិ កហំ នុ ខោ ភោ ឯតរហិ កុមារា សម្មន្តីតិ ។ អត្ថិ ទេវ ហិមវន្តបស្សេ បោក្ខរណិយា តីរេ មហាសាកវនសណ្ឌោ តត្ថេតរហិ កុ-

១ ខ ឱក្កាកំ ។ ២ ខ. ករណ្ឌុំ ហត្ថិនីយំ សីនិបុរំ ។ ម. ករកណ្ឌុំ ហត្ថិនិកំ សិនិសូរំ ។
៣ ខ ឯត្ថន្តរេ យត្ថាតិ បាឋោ ទិស្សតិ ។ ៤ ខ. ម. មហាសាកសណ្ឌោ ។

មារា សម្មន្តិ តេ ជាតិសម្ភេទភយា សកាហិ ភគិនិហិ សទ្ធឹ សំវាសំ កប្បេន្តិ ។ អថខោ អម្ពដ្ឋ រាជា ឱក្កាកោ ឧទានំ ឧទានេសិ សក្យា វត ភោ កុមារា បរមសក្យា វត ភោ កុមារាតិ ។ តទគ្គេ ខោ បន អម្ពដ្ឋ សក្យា បញ្ញាយន្តិ ។ សោ ច សក្យានំ(១) បុព្វបុរិសោ ។ រញ្ញោ ខោ បន អម្ពដ្ឋ ឱក្កាកស្ស ទិសា នាម ទាសី អហោសិ សា កណ្ហំ នាម ជនេសិ ។ ជាតោ កណ្ហោ បព្យាហាសិ ធោវថ មំ អម្ម នហាបេថ មំ អម្ម ឥមស្មា មំ អម្ម អសុចិស្មា បរិមោចេថ អត្ថាយ វោ(២) ភវិស្សាមីតិ ។ យថា ខោ បន អម្ពដ្ឋ ឯតរហិ មនុស្សា បិសាចេ បិសាចាតិ សញ្ជានន្តិ ឯវមេវ ខោ អម្ពដ្ឋ តេន ខោ បន សម-យេន មនុស្សា បិសាចេ កណ្ហាតិ សញ្ជានន្តិ ។ តេ ឯវមាហំសុ អយំ ជាតោ បព្យាហាសិ កណ្ហោ ជាតោ បិសាចោ ជាតោតិ ។ តទគ្គេ ខោ បន អម្ពដ្ឋ កណ្ហាយនា បញ្ញាយន្តិ ។ សោ ច

១ ម. តេសំ ។ ២ រោតិប្រែ ណាហេ ។

ដងព្រៃនោះ ព្រះរាជកុមារទាំងនោះ សម្រេចការនៅរួមជាមួយនឹងពួកព្រះភគិនីរបស់ខ្លួន ដោយការខ្លាចក្រែងក្លាយខូចជាតិ ។ ម្នាលអម្ពដ្ឋ គ្រានោះ ព្រះបាទឱក្កាករាជ ក៏បន្លឺនូវព្រះឧទានវាចាថា អើហ្ន៎ កុមារទាំងឡាយពេញជាអង់អាច អើហ្ន៎ កុមារទាំងឡាយពេញជាមោះមុតមែន ។ ម្នាលអម្ពដ្ឋ ចាប់ដើមអំពីកាលនោះមក ពួកសក្យវង្សក៏កើតប្រាកដឡើង ។ ព្រះបាទឱក្កាករាជនោះហើយ ជាបុព្វបុរសរបស់ពួកសក្យៈ ។ ម្នាលអម្ពដ្ឋ ព្រះបាទឱក្កាករាជ មានទាសីម្នាក់ឈ្មោះនាងទិសា នាងនោះបានបង្កើតកូនប្រុសម្នាក់ឈ្មោះកណ្ហៈ ។ លុះកណ្ហកុមារប្រសូតមក ក៏ស្រែកយំថា ម៉ែ ចូរលាងខ្ញុំ ម៉ែ ចូរផ្តួតទឹកខ្ញុំ ម៉ែ ចូរនាំខ្ញុំអំពីទីស្មោកគ្រោកនេះចេញ ខ្លួនខ្ញុំមុខជានឹងមានប្រយោជន៍ដល់ម៉ែ ។ ម្នាលអម្ពដ្ឋ ក្នុងកាលឥឡូវនេះ មនុស្សទាំងឡាយស្គាល់ពួកបិសាចថា ជាបិសាច យ៉ាងណា ម្នាលអម្ពដ្ឋ ក្នុងសម័យនោះឯង មនុស្សទាំងឡាយ ក៏ស្គាល់នូវពួកបិសាចថាដូចជាកណ្ហកុមារ យ៉ាងនោះដែរ ។ មនុស្សទាំងនោះនាំគ្នាពោលពាក្យយ៉ាងនេះថា កុមារនេះកើតមកហើយស្រែកយំថា កុមារខ្មៅកើតហើយ បិសាចកើតហើយ ។ ម្នាលអម្ពដ្ឋ ចាប់ដើមពីកាលនោះមក មានពួកជនជាកណ្ហាយនគោត្រ ក៏កើតប្រាកដឡើង ។ កណ្ហកុមារនោះឯងហើយ

កណ្ហាយនានំ បុព្វបុរិសោ ។ ឥតិ ខោ តេ អម្ពដ្ឋ បោរាណំ មាតាបេត្តិកំ នាមគោត្តំ អនុស្សរតោ អយ្យបុត្តា សក្យា ភវន្តិ ទាសីបុត្តោ ត្វមសិ សក្យានន្តិ ។

(១៨០) ឯវំ វុត្តេ តេ មាណវកា ភគវន្តំ ឯតទវោចុំ មា ភវំ គោតមោ អម្ពដ្ឋំ មាណវំ អតិពាឡ្ហំ ទាសីបុត្តវាទេន និម្មាទេសិ សុជាតោ ច ភោ គោតម អម្ពដ្ឋោ មាណវោ កុលបុត្តោ ច អម្ពដ្ឋោ មាណវោ ពហុស្សុតោ ច អម្ពដ្ឋោ មាណវោ កល្យាណវាក្ករណោ ច អម្ពដ្ឋោ មាណវោ បណ្ឌិតោ ច អម្ពដ្ឋោ មាណវោ បហោតិ ច អម្ពដ្ឋោ មាណវោ ភោតា គោតមេន សទ្ធឹ អស្មឹ វចនេ បដិមន្តេតុន្តិ ។ អថ ខោ ភគវា តេ មាណវកេ ឯតទវោច សចេ ខោ តុម្ហាកំ មាណវកានំ[១] ឯវំ ហោតិ ទុជ្ជាតោ ច អម្ពដ្ឋោ មាណវោ អកុលបុត្តោ ច អម្ពដ្ឋោ មាណវោ អប្បស្សុតោ ច អម្ពដ្ឋោ មាណវោ អកល្យាណវាក្ករណោ ច អម្ពដ្ឋោ មាណវោ ទុប្បញ្ញោ ច អម្ពដ្ឋោ មាណវោ ន ច បហោតិ អម្ពដ្ឋោ មាណវោ

---

១ ឱ. មាណវកា ។

ជាបុព្វបុរសរបស់ពួកកណ្ហាយនគោត្រ ។ ម្នាលអម្ពដ្ឋ កាលបើអ្នកនឹកទៅរកនាមនិងគោត្រ ជារបស់មាតាបិតាអំពីដើម (នឹងដឹងថា) មានព្រះអង្គម្ចាស់ជាពួកសក្យៈ ឯខ្លួនអ្នកជាកូននៃទាសី របស់ពួកសក្យៈ (នោះ) ដោយប្រការដូច្នេះឯង ។

[១៩០] កាលដែលព្រះមានព្រះភាគ ទ្រង់មានពុទ្ធតម្រាស់យ៉ាងនេះហើយ ពួកមាណពទាំងនោះ ក៏ពោលពាក្យនេះនឹងព្រះមានព្រះភាគថា ព្រះគោតមដ៏ចំរើន កុំញាំញីខ្លាំងពេកនូវអម្ពដ្ឋមាណព ដោយពាក្យថាកូនទាសី បពិត្រព្រះគោតមដ៏ចំរើន អម្ពដ្ឋមាណពជាអ្នកមានកំណើតល្អផង អម្ពដ្ឋមាណពជាកូននៃអ្នកមានត្រកូលផង អម្ពដ្ឋមាណពជាអ្នកចេះដឹងច្រើនផង អម្ពដ្ឋមាណពជាអ្នកមានវាចាពីរោះផង អម្ពដ្ឋមាណពជាបណ្ឌិតផង អម្ពដ្ឋមាណពជាអ្នកសមនឹងប្រឹក្សាឆ្លើយឆ្លងគ្នា ក្នុងពាក្យនោះជាមួយនឹងព្រះគោតមដ៏ចំរើនផង ។ គ្រានោះ ព្រះមានព្រះភាគ បានត្រាស់ពាក្យនេះនឹងពួកមាណពទាំងនោះថា ប្រសិនបើអ្នកទាំងឡាយ ជាមាណព មានសេចក្តីត្រិះរិះយ៉ាងនេះថា អម្ពដ្ឋមាណពមានកំណើតមិនល្អផង អម្ពដ្ឋមាណពមិនមែនជាកូននៃអ្នកមានត្រកូលផង អម្ពដ្ឋមាណពចេះដឹងតិចផង អម្ពដ្ឋមាណពមានវាចាមិនពីរោះផង អម្ពដ្ឋមាណពជាមនុស្សឥតបញ្ញាផង អម្ពដ្ឋមាណពមិនសមនឹងប្រឹក្សាឆ្លើយឆ្លងគ្នាក្នុងពាក្យនេះ

សមណេន គោតមេន សទ្ធឹ អស្មឹ វចនេ បដិមន្តេតុំ តិដ្ឋតុ អម្ពដ្ឋោ មាណវកោ តុម្ហេ មយា សទ្ធឹ មន្តវ្ហោ អស្មឹ វចនេ សចេ បន តុម្ហាកំ មាណវកានំ ឯវំ ហោតិ សុជាតោ ច អម្ពដ្ឋោ មាណវកោ កុលបុត្តោ ច អម្ពដ្ឋោ មាណវកោ ពហុស្សុតោ ច អម្ពដ្ឋោ មាណវកោ កល្យា·ណវាក្ករណោ ច អម្ពដ្ឋោ មាណវកោ បណ្ឌិតោ ច អម្ពដ្ឋោ មាណវកោ បហោតិ ច អម្ពដ្ឋោ មាណវកោ សមណេន គោតមេន សទ្ធឹ អស្មឹ វចនេ បដិមន្តេតុំ តិដ្ឋថ តុម្ហេ អម្ពដ្ឋោ មាណវកោ មយា សទ្ធឹ អស្មឹ វចនេ បដិមន្តេតូតិ ។ សុជាតោ ច ភោ គោតម អម្ពដ្ឋោ មាណវកោ កុលបុត្តោ ច អម្ពដ្ឋោ មាណវកោ ពហុ·ស្សុតោ ច អម្ពដ្ឋោ មាណវកោ កល្យាណវាក្ករណោ ច អម្ពដ្ឋោ មាណវកោ បណ្ឌិតោ ច អម្ពដ្ឋោ មាណវកោ បហោតិ ច អម្ពដ្ឋោ មាណវកោ ភោតា គោតមេន សទ្ធឹ អស្មឹ វចនេ បដិមន្តេតុំ តុណ្ហី មយំ ភវិស្សាម អម្ពដ្ឋោ មាណវកោ ភោតា គោតមេន សទ្ធឹ អស្មឹ វចនេ បដិមន្តេតូតិ ។

ជាមួយនឹងព្រះសមណគោតមបានផង ដូច្នេះ ចូរឲ្យអម្ពដ្ឋមាណពឈប់ចុះ ចូរអ្នកទាំងឡាយប្រឹក្សាក្នុងពាក្យនោះជាមួយនឹងតថាគតវិញ តែបើអ្នកទាំងឡាយ ជាមាណព មានសេចក្តីត្រិះរិះយ៉ាងនេះថា អម្ពដ្ឋមាណពមានកំណើតល្អផង អម្ពដ្ឋមាណពជាកូននៃអ្នកមានត្រកូលផង អម្ពដ្ឋមាណពជាអ្នកចេះដឹងច្រើនផង អម្ពដ្ឋមាណពមានវាចាពីរោះផង អម្ពដ្ឋមាណពជាបណ្ឌិតផង អម្ពដ្ឋមាណពសមនឹងប្រឹក្សាឆ្លើយឆ្លងគ្នា ក្នុងពាក្យនោះ ជាមួយនឹងព្រះសមណគោតមបានផង ដូច្នេះ ចូរអ្នកទាំងឡាយឈប់ចុះ ចូរឲ្យអម្ពដ្ឋមាណពប្រឹក្សាឆ្លើយឆ្លងគ្នា ក្នុងពាក្យនោះជាមួយនឹងតថាគត ។ ពួកមាណពក៏ពោលថា បពិត្រព្រះគោតមដ៏ចំរើន អម្ពដ្ឋមាណពជាអ្នកមានកំណើតល្អផង អម្ពដ្ឋមាណពជាកូននៃអ្នកមានត្រកូលផង អម្ពដ្ឋមាណពជាអ្នកចេះដឹងច្រើនផង អម្ពដ្ឋមាណពជាអ្នកមានវាចាពីរោះផង អម្ពដ្ឋមាណពជាបណ្ឌិតផង អម្ពដ្ឋមាណពសមនឹងប្រឹក្សាឆ្លើយឆ្លងគ្នា ក្នុងពាក្យនោះជាមួយនឹងព្រះគោតមដ៏ចំរើនបានផង យើងទាំងឡាយ នឹងនៅស្ងៀម ឲ្យតែអម្ពដ្ឋមាណពប្រឹក្សាឆ្លើយឆ្លងគ្នា ក្នុងពាក្យនោះជាមួយនឹងព្រះគោតមដ៏ចំរើនចុះ ។

[១៥១] អថខោ ភគវា អម្ពដ្ឋំ មាណវំ ឯតទវោច អយំ ខោ បន តេ អម្ពដ្ឋ សហធម្មិកោ បញ្ហោ អាគច្ឆតិ អកាមា ព្យាកាតព្វោ សចេ ត្វំ ន ព្យាករិស្សសិ អញ្ញេន វា អញ្ញំ បដិចរិស្សសិ តុណ្ហី វា ភវិស្សសិ បក្កមិស្សសិ វា ឯត្ថេវ តេ សត្តធា មុទ្ធា ផលិស្សតិ តំ កឹ មញ្ញសិ អម្ពដ្ឋ កិន្តិ តេ សុតំ ព្រាហ្មណានំ វុឌ្ឍានំ មហល្លកានំ អាចរិយបាចរិយានំ ភាសមានានំ កុតោបភុតិកា កណ្ហាយនា កោ ច កណ្ហាយនានំ បុព្វបុរិសោតិ ។ ឯវំ វុត្តេ អម្ពដ្ឋោ មាណវោ តុណ្ហី អហោសិ ។ ទុតិយម្បិ ខោ ភគវា អម្ពដ្ឋំ មាណវំ ឯតទវោច តំ កឹ មញ្ញសិ អម្ពដ្ឋ កិន្តិ តេ សុតំ ព្រាហ្មណានំ វុឌ្ឍានំ មហល្លកានំ អាចរិយបាចរិយានំ ភាសមានានំ កុតោបភុតិកា កណ្ហាយនា កោ ច កណ្ហាយនានំ បុព្វបុរិសោតិ ។ ទុតិយម្បិ ខោ អម្ពដ្ឋោ មាណវោ តុណ្ហី អហោសិ ។ អថខោ

[១៩១] លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះនឹងអម្ពដ្ឋមាណពថា ម្នាលអម្ពដ្ឋ ប្រស្នាប្រកបដោយហេតុនេះឯង មកដល់អ្នកហើយ ទោះបីអ្នកមិនប្រាថ្នានឹងឆ្លើយ ក៏ត្រូវតែឆ្លើយ បើអ្នកនឹងមិនឆ្លើយក្តី នឹងនិយាយក់សាងទៅរកហេតុដទៃ ដោយរឿងដទៃក្តី អ្នកនឹងនៅស្ងៀមក្តី នឹងដើរចេញទៅក្តី ក្បាលអ្នកនឹងបែកជា ៧ ភាគ ក្នុងទីនេះមិនខាន ម្នាលអម្ពដ្ឋ អ្នកសំគាល់ហេតុនោះដូចម្តេច អ្នកធ្លាប់បានឮឬទេ ពាក្យរបស់ពួកព្រាហ្មណ៍ចាស់ៗ មានអាយុច្រើនជាអាចារ្យតូចនឹងអាចារ្យធំ និយាយថា ពួកកណ្ហាយនគោត្រ កើតអំពីណា អ្នកណា ជាបុព្វបុរសរបស់ពួកកណ្ហាយនគោត្រ ។ កាលបើព្រះសាស្តាទ្រង់ត្រាស់សួរយ៉ាងនេះហើយ អម្ពដ្ឋមាណពក៏នៅស្ងៀម ។ ព្រះមានព្រះភាគបានត្រាស់ពាក្យនេះនឹងអម្ពដ្ឋមាណព អស់វារៈពីរដងទៀតថា ម្នាលអម្ពដ្ឋ អ្នកសំគាល់ហេតុនោះដូចម្តេច អ្នកធ្លាប់បានឮឬទេ ពាក្យរបស់ពួកព្រាហ្មណ៍ចាស់ៗ មានអាយុច្រើនជាអាចារ្យតូចនឹងអាចារ្យធំនិយាយថា ពួកកណ្ហាយនគោត្រ កើតមកពីណា អ្នកណាជាបុព្វបុរស របស់ពួកកណ្ហាយនគោត្រ ។ អម្ពដ្ឋមាណពក៏នៅស្ងៀមអស់វារៈពីរដង ។ គ្រានោះ

ភគវា អម្ពដ្ឋំ មាណវំ ឯតទវោច ព្យាករោហីទានិ(១) អម្ពដ្ឋ ន ទានិ តេ តុណ្ហីភាវស្ស កាលោ យោ ខោ អម្ពដ្ឋ តថាគតេន យាវតតិយកំ សហធម្មិកំ បញ្ហំ បុដ្ឋោ ន ព្យាករោតិ ឯត្ថេវស្ស សត្តធា មុទ្ធា ផលិស្សតីតិ ។

(១៥២) តេន ខោ បន សមយេន វជិរបាណិ(២) យក្ខោ មហន្តំ អយោកូដំ អាទាយ អាទិត្តំ សម្បជ្ជ-លិតំ សជោតិភូតំ អម្ពដ្ឋស្ស មាណវស្ស ឧបរិវេហាសំ ឋិតោ ហោតិ សចាយំ អម្ពដ្ឋោ មាណវោ ភគវតា យាវតតិយកំ សហធម្មិកំ បញ្ហំ បុដ្ឋោ ន ព្យាក-រិស្សតិ ឯត្ថេវស្ស សត្តធា មុទ្ធំ ផាលេស្សាមីតិ ។ តំ ខោ បន វជិរបាណឹ យក្ខំ ភគវា ចេវ បស្សតិ អម្ពដ្ឋោ ច មាណវោ ។ អថខោ អម្ពដ្ឋោ មាណវោ ភីតោ សំវិគ្គោ លោមហដ្ឋជាតោ ភគវន្តំយេវ តាណំ គវេសិ(៣) ភគវន្តំយេវ លេណំ គវេសិ ភគវន្តំយេវ សរណំ គវេសិ ឧបនិសីទិត្វា ភគវន្តំ ឯតទវោច កិមេតំ

១ ឱ. ព្យាករោហិ ឥទានិ ។ ២ ឱ. ម. វជិរបាណី ។ ៣ ឱ. ម. គវេសី ។

ព្រះមានព្រះភាគ បានត្រាស់ពាក្យនេះនឹងអម្ពដ្ឋមាណពថា ម្នាលអម្ពដ្ឋ អ្នកចូរឆ្លើយឥឡូវនេះមក ឥឡូវនេះមិនមែនជាកាលត្រូវអ្នកនៅស្ងៀមទេ ម្នាលអម្ពដ្ឋ បុគ្គលណាដែលតថាគតសួរប្រស្នា ប្រកបដោយហេតុ អស់វារៈ ៣ ដងហើយ មិនឆ្លើយ ក្បាលរបស់បុគ្គលនោះនឹងបែកជា ៧ ភាគ ក្នុងទីនេះ មិនខាន ។

(១៩២) សម័យនោះឯង មានយក្ស[១]ឈ្មោះវជិរបាណិ (យក្សមានកែវវជិរក្នុងដៃ) កាន់ដំបងដែកយ៉ាងធំ ដែលភ្លើងកំពុងឆេះព្រោលឆ្នោលសន្ធោសន្ធៅ មកឈរឯអាកាស ពីខាងលើអម្ពដ្ឋមាណព ដោយគិតថា បើអម្ពដ្ឋមាណពនេះ ព្រះមានព្រះភាគសួរប្រស្នាប្រកបដោយហេតុ អស់វារៈ ៣ ដងហើយ នឹងមិនឆ្លើយទេ អញនឹងសំពងក្បាលមាណពនេះ ឲ្យបែកជា ៧ ភាគ ក្នុងទីនេះឯង ។ ព្រះមានព្រះភាគនឹងអម្ពដ្ឋមាណព ក៏ឃើញនូវយក្សឈ្មោះវជិរបាណិនោះដែរ ។ គ្រានោះ អម្ពដ្ឋមាណពភ័យតក់ស្លុត ព្រឺរោមខ្ញាកឡើង ក៏ស្ទុះទៅរកព្រះមានព្រះភាគ យកជាទីពឹងពំនាក់ ស្ទុះទៅរកព្រះមានព្រះភាគ យកជាទីជ្រកកោន ស្ទុះទៅរកព្រះមានព្រះភាគយកជាសរណៈ ហើយចូលទៅអង្គុយជិត ទើបក្រាបបង្គំទូល

១ អដ្ឋកថា ថា យក្សក្នុងទីនេះ គឺព្រះឥន្ទ្រាធិរាជ ។

ភវំ គោតមោ អាហ បុន ភវំ គោតមោ ព្រូតុតិ(១) ។ តំ កឹ មញ្ញសិ អម្ពដ្ឋ កិន្តិ តេ សុតំ ព្រាហ្មណានំ វុឌ្ឍានំ មហល្លកានំ អាចរិយបាចរិយានំ ភាសមានានំ កុតោបភុតិកា កណ្ហាយនា កោ ច កណ្ហាយនានំ បុព្វបុរិសោតិ ។ ឯវមេវ ភោ(២) គោតម សុតំ យថេវ(៣) ភវំ គោតមោ អាហ តតោបភុតិកា កណ្ហាយនា សោ ច កណ្ហាយនានំ បុព្វបុរិសោតិ ។

(១៤៣) ឯវំ វុត្តេ តេ(៤) មាណវកា ឧន្នាទិនោ ឧច្ចាសទ្ទា មហាសទ្ទា អហេសុំ ទុជ្ជាតោ កិរ ភោ អម្ពដ្ឋោ មាណវោ អកុលបុត្តោ កិរ ភោ អម្ពដ្ឋោ មាណវោ ទាសិបុត្តោ កិរ ភោ អម្ពដ្ឋោ មាណវោ សក្យានំ អយ្យបុត្តា កិរ ភោ អម្ពដ្ឋស្ស មាណវស្ស សក្យា ភវន្តិ ធម្មវាទឹយេវ(៥) កិរ មយំ សមណំ គោតមំ អបសាទេតព្វំ អមញ្ញាម្ហាតិ ។

---

១ ឱ. ព្រូមេតុតំ ។ ម. ព្រវិតូតិ ។ ២ ឱ. ម. ឯវមេវ អេ ភោ ។ ៣ ឱ. ម. យថេវ ។ ៤ ឱ. តេសទ្ទោ ន ទិស្សតិ ។ ៥ ឱ ម. ធម្មវាទិញ្ញេវ ។

ពាក្យនេះនឹងព្រះមានព្រះភាគថា ព្រះគោតមដ៏ចំរើន ត្រាស់ហើយនូវពាក្យនុ៎ះដូចម្តេច សូមព្រះគោតមដ៏ចំរើន ត្រាស់ម្តងទៀត ។ ព្រះមានព្រះភាគទ្រង់ត្រាស់សួរថា ម្នាលអម្ពដ្ឋ អ្នកសំគាល់ហេតុនោះដូចម្តេច អ្នកធ្លាប់បានឮឬទេ ពាក្យរបស់ពួកព្រាហ្មណ៍ ចាស់ ៗ មានអាយុច្រើនជាអាចារ្យតូចនឹងអាចារ្យធំ និយាយថា ពួកកណ្ហាយនគោត្រ កើតមកពីណា អ្នកណា ជាបុព្វបុរសរបស់ពួកកណ្ហាយនគោត្រ ។ អម្ពដ្ឋមាណពក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចំរើន ពាក្យដែលខ្ញុំធ្លាប់បានឮមក ដូចព្រះគោតមដ៏ចំរើន បានត្រាស់ហើយថា កណ្ហាយនគោត្រទាំងឡាយកើតមកអំពីត្រកូលនោះ កណ្ហកុមារនោះហើយ ដែលជាបុព្វបុរសរបស់ពួកកណ្ហាយនគោត្រ ដូច្នោះដែរ ។

(១៨៣) កាលបើអម្ពដ្ឋមាណពពោលយ៉ាងនេះហើយ មាណពទាំងនោះ ក៏បន្លឺសំឡេងកឹកកងរំពងថា ម្នាលគ្នាយើង អម្ពដ្ឋមាណពជាមនុស្សមានជាតិទន់ទាបទេតើ ម្នាលគ្នាយើង អម្ពដ្ឋមាណពមិនមែនជាកូននៃអ្នកមានត្រកូលទេតើ ម្នាលគ្នាយើង អម្ពដ្ឋមាណព ជាកូននៃទាសីរបស់ពួកសក្យៈទេតើ ម្នាលគ្នាយើង ពួកសក្យៈជាម្ចាស់នៃអម្ពដ្ឋមាណពទេតើ ព្រះសមណគោតមជាអ្នកពោលត្រឹមត្រូវពិត យើងទាំងឡាយបែរជាស្មានថាព្រះសមណគោតម ជាបុគ្គលដែលយើងគប្បីរុករានទៅវិញ ។

អថខោ ភគវតោ ឯតទហោសិ អតិពាឡ្ហំ ខោ ឥមេ មាណវកា អម្ពដ្ឋំ មាណវំ ទាសីបុត្តវាទេន និម្មាទេន្តិ យន្នូនាហំ បរិមោចេយ្យន្តិ ។ អថខោ ភគវា តេ មាណវកេ ឯតទវោច មា ខោ តុម្ហេ មាណវកា អម្ពដ្ឋំ មាណវកំ អតិពាឡ្ហំ ទាសីបុត្តវាទេន និម្មាទេថ ឧឡារោ ច(១) សោ កណ្ហោ ឥសិ អហោសិ សោ ទក្ខិណំ ជនបទំ គន្ត្វា ព្រហ្មមន្តេ អធិយិត្វា រាជានំ ឧក្កាកំ ឧបសង្កមិត្វា មទ្ទរូបឹ ធីតរំ យាចិ ។ តស្ស រាជា ឧក្កាកោ នេវរេ មយ្ហំ ទាសីបុត្តោ សមានោ មទ្ទរូបឹ ធីតរំ យាចតីតិ កុបិតោ អនត្តមនោ ខុរប្បំ សន្នយ្ហិ ។ សោ តំ ខុរប្បំ នេវ អសក្ខិ មុញ្ចិតុំ នោ បដិសំហរិតុំ ។

(១៥៦) អថខោ មាណវកា អមច្ចា បារិសជ្ជា កណ្ហំ ឥសឹ ឧបសង្កមិត្វា ឯតទវោចុំ សោត្ថិ ភទន្តេ ហោតុ រញ្ញោ សោត្ថិ ភទន្តេ ហោតុ

---

១ ឱ. ម បសត្ថោ ឥ ទិស្សតិ ។

គ្រានោះ ព្រះមានព្រះភាគទ្រង់ត្រិះរិះដូច្នេះថា មាណពទាំងនេះមើលងាយខ្លាំងណាស់ នូវអម្ពដ្ឋមាណព ដោយពាក្យពោលថាជាកូននៃទាសីបើដូច្នោះ គួរតែតថាគតជួយដោះស្រាយចេញ ។ លំដាប់នោះ ព្រះមានព្រះភាគបានត្រាស់ពាក្យនេះ នឹងពួកមាណពទាំងនោះថា ម្នាលមាណពទាំងឡាយ អ្នកទាំងឡាយកុំមើលងាយខ្លាំងពេកនូវអម្ពដ្ឋមាណព ដោយពាក្យពោលថាជាកូននៃទាសីឡើយ (កាលពីដើម) គាត់ជាកណ្ហឥសីជាអ្នកថ្កើងថ្កាន គាត់ទៅកាន់ទក្ខិណជនបទ (នៅជាខាងស្តាំនៃទន្លេគង្គា) បានរៀននូវព្រហ្មមន្តទាំងឡាយ ហើយចូលទៅគាល់ព្រះបាទឧក្កាករាជ ហើយទូលសូមព្រះរាជធីតាទ្រង់ព្រះនាមមទ្ទរូបី ។ ព្រះបាទឧក្កាករាជ ក៏ទ្រង់ក្រោធពិរោធភាក់អន់ព្រះហឫទ័យនឹងឥសីនោះថា មនុស្សចង្រៃ ជាកូននៃទាសី មិនគួរនឹងហ៊ានមកសូមនាងមទ្ទរូបី ជាធីតារបស់អញសោះ ទើបទ្រង់ផ្គង់សរឡើង ។ ព្រះបាទឧក្កាករាជនោះ មិនអាចនឹងថ្លែង មិនអាចនឹងដាក់ចុះ នូវសរនោះចេញបាន (ដោយអានុភាពនៃមន្តរបស់ឥសីនោះ) ។

(១៩៤) គ្រានោះ ពួកមាណពជាអាមាត្យ រាជបរិស័ទចូលទៅរកកណ្ហឥសី ហើយបានពោលពាក្យនេះថា បពិត្រលោកដ៏ចំរើន សូមសួស្តីមានដល់ព្រះរាជា បពិត្រលោកដ៏ចំរើន សូមសួស្តីមានដល់ព្រះ

រញ្ញោតិ ។ សោត្ថិ ភវិស្សតិ រញ្ញោ អបិច រាជា យទិ អធោ ខុរប្បំ មុញ្ចិស្សតិ យាវតា រញ្ញោ វិជិតំ ឯត្តាវតា បថវី ឧន្ទ្រិយិស្សតីតិ(១) ។ សោត្ថិ ភទន្តេ ហោតុ រញ្ញោ សោត្ថិ ជនបទស្សាតិ ។ សោត្ថិ ភវិស្សតិ រញ្ញោ សោត្ថិ ជនបទស្ស អបិច រាជា យទិ ឧទ្ធំ ខុរប្បំ មុញ្ចិស្សតិ យាវតា រញ្ញោ វិជិតំ ឯត្តាវតា សត្ត វស្សានិ ទេវោ ន វស្សិស្សតីតិ ។ សោត្ថិ ភទន្តេ ហោតុ រញ្ញោ សោត្ថិ ជនបទស្ស ទេវោ ច វស្សតូតិ(២) ។ សោត្ថិ ភវិស្សតិ រញ្ញោ សោត្ថិ ជនបទស្ស ទេវោ ច វស្សិស្សតិ(៣) អបិច រាជា ជេដ្ឋកុមារេ ខុរប្បំ បតិដ្ឋាបេតុ សោត្ថិកុមារោ បល្លោមោ ភវិស្សតីតិ ។ អថខោ មាណវកា រាជា ឱក្កាកោ ជេដ្ឋកុមារេ ខុរប្បំ បតិដ្ឋាបេសិ សោត្ថិកុមារោ បល្លោមោ ភវិស្សតីតិ(៤) ។ អថខោ មាណវកា(៥)

---

១ ឧទ្រិយិស្សតីតិ កត្ថចិ បោត្ថកេ ទិស្សតិ ។ ២ ឱ. ម. ទេវោ ច វស្សតូតិ ។ ៣ ឱ. ម. ទេវោ ច វស្សិស្សតិ ។ ៤ ឱ. ម. អថខោ មាណវកា អមច្ចា ឱក្កាកស្ស អារោចេសុំ ។ ឱក្កាកោ ជេដ្ឋកុមារេ ខុរប្បំ បតិដ្ឋាបេតុ សោត្ថិកុមារោ បល្លោមោ ភវិស្សតីតិ ។ ៥ ឱ. ម. មាណវកាតិ ន ទិស្សតិ ។

រាជា ៗ កណ្ហឥសីតបថា សួស្តីគង់នឹងមានដល់ព្រះរាជា ប៉ុន្តែបើព្រះរាជានឹងថ្លែងសរទៅខាងក្រោម ផែនដីក៏នឹងស្រុតរហូតទាំងព្រះរាជាណាខេត្ត ៗ ពួករាជអាមាត្យពោលថា បពិត្រលោកដ៏ចំរើន សូមសួស្តីមានដល់ព្រះរាជា សូមសួស្តីមានដល់ជនបទ ៗ កណ្ហឥសីតបវិញថា សួស្តីគង់នឹងមានដល់ព្រះរាជា សួស្តីគង់នឹងមានដល់ជនបទ ប៉ុន្តែបើព្រះរាជានឹងថ្លែងសរទៅខាងលើ ភ្លៀងនឹងមិនធ្លាក់អស់ ៧ ឆ្នាំ ពេញទាំងព្រះរាជាណាខេត្ត ៗ ពួករាជអាមាត្យពោលអង្វរថា បពិត្រលោកដ៏ចំរើន សូមសួស្តីមានដល់ព្រះរាជា សូមសួស្តីមានដល់ជនបទ សូមឱ្យភ្លៀងបង្អុរមក ៗ កណ្ហឥសីតបវិញថា សួស្តីគង់នឹងមានដល់ព្រះរាជា សួស្តីគង់នឹងមានដល់ជនបទ ភ្លៀងគង់នឹងបង្អុរមក ប៉ុន្តែបើព្រះរាជាទ្រង់ប្រគល់សរទុកលើព្រះរាជកុមារច្បង ព្រះរាជកុមារនឹងជាអ្នកមានសួស្តី នឹងមានរោមសម្បុះ គឺមិនកិតក័យ ៗ លំដាប់នោះ ពួកមាណពនឹង

រាជា ឧក្កាកោ ជេដ្ឋកុមារេ ខុរប្បំ បតិដ្ឋាបេសិ ។ សោត្ថិកុមារោ បល្លោមោ សម្ភវិ ។ [១] តស្ស រាជា ឧក្កាកោ ភីតោ ព្រហ្មទណ្ឌេន តជ្ជិតោ មទ្ទរូបឹ[២] ធីតរំ អទាសិ ។ មា ខោ តុម្ហេ មាណវកា អម្ពដ្ឋំ មាណវំ អតិពាឡ្ហំ ទាសីបុត្តវាទេន វម្ភេថ ឧឡារោ សោ កណ្ហោ ឥសិ អហោសីតិ ។

(១៥៥) អថខោ ភគវា អម្ពដ្ឋំ មាណវំ អាមន្តេសិ តំ កឹ មញ្ញសិ អម្ពដ្ឋ ឥធ ខត្តិយកុមារោ ព្រាហ្មណ-កញ្ញាយ សទ្ធឹ សំវាសំ កប្បេយ្យ តេសំ សំវាស-មន្វាយ បុត្តោ ជាយេថ យោ សោ ខត្តិយកុមារេន ព្រាហ្មណកញ្ញាយ បុត្តោ ឧប្បន្នោ អបិនុ សោ លភេថ ព្រាហ្មណេសុ អាសនំ វា ឧទកំ វាតិ ។ លភេថ ភោ គោតម ។ អបិនុ នំ ព្រាហ្មណា ភោ-ជេយ្យុំ សទ្ធេ វា ថាលិបាកេ វា យញ្ញេ វា បាហុនេ វាតិ ។ ភោជេយ្យុំ ភោ គោតម ។ អបិនុ នំ ព្រាហ្ម-ណា មន្តេ វាចេយ្យុំ វា នោ វាតិ ។ វាចេយ្យុំ ភោ

---

១ ឱ. ម. ឯត្ថន្តរេ អថខោតិ ទិស្សតិ ។ ២ ឱ. ទុទ្ទរូបឹ ។

ព្រះបាទឱក្កាករាជ ទ្រង់ប្រគល់សរទៅលើព្រះរាជកុមារច្បង ។ ព្រះរាជកុមារ ដែលមានសួស្តី ក៏មានកេមសម្ងបចុះ ។ ព្រះបាទឱក្កាករាជ ត្រូវព្រហ្មទណ្ឌគម្រាម ក៏ខ្លបខ្លាច ទើបទ្រង់ព្រះរាជទានព្រះរាជធីតា ទ្រង់ព្រះនាមមទ្ទរូបី ដល់កណ្ហឥសីនោះ ។ ម្នាលពួកមាណព អ្នកទាំងឡាយ កុំមើលងាយអម្ពដ្ឋមាណព ដោយវាទៈថាជាកូននៃទាសី ខ្លាំងពេកឡើយ កណ្ហឥសីនោះ ជាមនុស្សថ្កើងថ្កានដែរ ។

(១៨៤) លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងអម្ពដ្ឋមាណពថា ម្នាលអម្ពដ្ឋ អ្នកសំគាល់សេចក្តីនោះដូចម្តេច ខត្តិយកុមារ ក្នុងលោកនេះ នៅរួមសំវាស ជាមួយនឹងព្រាហ្មណកញ្ញា ក៏កើតបុត្រឡើង ព្រោះអាស្រ័យការនៅរួម នៃជនទាំងពីរនោះ កូនណាដែលកើតអំពីខត្តិយកុមារនឹងព្រាហ្មណកញ្ញា កូននោះគួរបានអាសនៈឬទឹក ក្នុងពួកព្រាហ្មណ៍ ដែរឬទេ ។ អម្ពដ្ឋមាណព ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចំរើន កូននោះគួរបាន ។ ចុះពួកព្រាហ្មណ៍ គួរអញ្ជើញកូននោះឲ្យបរិភោគ ក្នុងកាលដែលធ្វើភត្ត ឧទ្ទិសឲ្យមនុស្សស្លាប់ក្តី ក្នុងការជាមង្គលក្តី ក្នុងពិធីបូជាក្តី ក្នុងការទទួលភ្ញៀវក្តី បានដែរឬ ។ បពិត្រព្រះគោតមដ៏ចំរើន ពួកព្រាហ្មណ៍ គួរអញ្ជើញកូននោះឲ្យបរិភោគបាន ។ ចុះពួកព្រាហ្មណ៍គួរបង្រៀនមន្តកូននោះបាន ឬមិនបានទេ ។ បពិត្រព្រះ

គោតម ។ អបិនុស្ស ឥត្ថីសុ អាវដំ វា អស្ស អនាវដំ វាតិ ។ អនាវដំ ហិស្ស ភោ គោតម ។ អបិនុ ខត្តិយាភិសេកេន(១) អភិសិញ្ចេយ្យុន្តិ ។ នោ ហិទំ(២) ភោ គោតម ។ តំ កិស្ស ហេតុ ។ មាតិតោ ហិ ភោ គោតម អនុប្បន្នោតិ ។

(១៩៦) តំ កិំ មញ្ញសិ អម្ពដ្ឋ ឥធ ព្រាហ្មណកុមារោ ខត្តិយកញ្ញាយ សទ្ធឹ សំវាសំ កប្បេយ្យ តេសំ សំវាសមន្វាយ បុត្តោ ជាយេថ យោ សោ ព្រាហ្មណកុមារេន ខត្តិយកញ្ញាយ បុត្តោ ឧប្បន្នោ អបិនុ សោ លភេថ ព្រាហ្មណេសុ អាសនំ វា ឧទកំ វាតិ ។ លភេថ ភោ គោតម ។ អបិនុ នំ ព្រាហ្មណា ភោជេយ្យុំ សទ្ធេ វា ថាលិបាកេ វា យញ្ញេ វា បាហុនេ វាតិ ។ ភោជេយ្យុំ ភោ គោតម ។ អបិនុ នំ ព្រាហ្មណា មន្តេ វាចេយ្យុំ វា នោ វាតិ ។

---

១ ឱ. ម. អបិនុ នំ ខត្តិយាខត្តិយាភិសេកេន ។ ២ ឱ. នោ ហេតំ ។

គោតមដ៏ចំរើន គួរបង្រៀនមន្តកូននោះបាន ។ ចុះគួរហាមមិនឲ្យខត្តិយកុមារនោះបានពួកស្រី (ដែលជាព្រាហ្មណកញ្ញា) ឬមិនគួរហាមទេ ។ បពិត្រព្រះគោតមដ៏ចំរើន មិនគួរហាមទេ ។ ចុះជនទាំងឡាយគួរអភិសេកកូននោះឲ្យជាក្សត្រិយ៍បានដែរឬទេ ។ បពិត្រព្រះគោតមដ៏ចំរើន ហេតុនេះមិនគួរទេ ។ ពាក្យដែលខ្ញុំពោលនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះគោតមដ៏ចំរើន ព្រោះហេតុថា កូននោះមិនបានកើតមក អំពីមាតា (ជាខត្តិយកញ្ញា) ។

[១៩៦] ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអម្ពដ្ឋ អ្នកសំគាល់ហេតុនោះដូចម្តេច ព្រាហ្មណកុមារក្នុងលោកនេះ នៅរួមសំរាសជាមួយនឹងខត្តិយកញ្ញា ក៏កើតបុត្រឡើង ព្រោះអាស្រ័យការនៅរួម នៃជនទាំងពីរនាក់នោះ កូនណាដែលកើតអំពីព្រាហ្មណកុមារនឹងខត្តិយកញ្ញា កូននោះ គួរបានអាសនៈឬទឹក ក្នុងពួកព្រាហ្មណ៍ដែរឬទេ ។ អម្ពដ្ឋមាណព ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចំរើន កូននោះគួរបាន ។ ចុះពួកព្រាហ្មណ៍គួរអញ្ជើញកូននោះឲ្យបរិភោគ ក្នុងកាលធ្វើភត្តុទ្ទិសឲ្យមនុស្សស្លាប់ក្តី ក្នុងការដាំមង្គលក្តី ក្នុងពិធីបូជាក្តី ក្នុងការទទួលភ្ញៀវក្តី បានដែរឬទេ ។ បពិត្រព្រះគោតមដ៏ចំរើន ពួកព្រាហ្មណ៍ គួរអញ្ជើញកូននោះឲ្យបរិភោគបាន ។ ចុះពួកព្រាហ្មណ៍ គួរបង្រៀនមន្តកូននោះបាន ឬមិនបានទេ ។

វាចេយ្យុំ ភោ គោតម ។ អបិនុស្ស ឥត្ថីសុ អាវដំ វា អស្ស អនាវដំ វាតិ ។ អនាវដំ ហិស្ស ភោ គោតម ។ អបិនុ នំ ខត្តិយាភិសេកេន អភិសិញ្ចេយ្យុន្តិ ។ នោ ហិទំ ភោ គោតម ។ តំ កិស្ស ហេតុ ។ បិតិតោ ហិ ភោ គោតម អនុបបន្នោតិ ។

(១៤៧) ឥតិ ខោ អម្ពដ្ឋ ឥត្ថិយា វា ឥត្ថឹ ករិត្វា បុរិសេន វា បុរិសំ ករិត្វា ខត្តិយាវ សេដ្ឋា ហីនា ព្រាហ្មណា ។ តំ កឹ មញ្ញសិ អម្ពដ្ឋ ឥធ ព្រាហ្មណា ព្រាហ្មណំ កិស្មិញ្ចិទេវ[១] បករណេ ខុរមុណ្ឌំ ករិត្វា ភស្សបុដេន វធិត្វា រដ្ឋា វា នគរា វា បព្វាជេយ្យុំ អបិនុ សោ លភេថ ព្រាហ្មណេសុ អាសនំ វា ឧទកំ វាតិ ។ នោ ហិទំ ភោ គោតម ។ អបិនុ នំ ព្រាហ្មណា ភោជេយ្យុំ សទ្ធេ វា ថាលិបាកេ វា យញ្ញេ វា បាហុនេ វាតិ ។ នោ ហិទំ ភោ គោតម ។ អបិនុ

១ ម. កិស្មិំចិទេវ ។

បពិត្រព្រះគោតមដ៏ចំរើន គួរបង្រៀនមន្តកូននោះបាន ។ ចុះគួរហាមមិនឲ្យព្រាហ្មណកុមារនោះបានពួកស្រ្តី (ដែលជាខត្តិយកញ្ញា) ឬមិនគួរហាមទេ ។ បពិត្រព្រះគោតមដ៏ចំរើន មិនគួរហាមទេ ។ ចុះជនទាំងឡាយគួរអភិសេកកូននោះឲ្យជាក្សត្រិយ៍បានដែរឬទេ ។ បពិត្រព្រះគោតមដ៏ចំរើន ហេតុនេះមិនគួរទេ ។ ពាក្យដែលចំពោះនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះគោតមដ៏ចំរើន ព្រោះកូននោះមិនបានកើតមកអំពីបិតាជាក្សត្រិយ៍ ។

(១៨៧) ព្រះមានព្រះភាគ ត្រាស់សួរថា ម្នាលអម្ពដ្ឋ ប្រៀបផ្ទឹមស្រីនឹងស្រីក្តី ប្រៀបផ្ទឹមប្រុសនឹងប្រុសក្តី ( ឃើញថា ) ពួកក្សត្រិយ៍ជាត្រកូលប្រសើរជាង ពួកព្រាហ្មណ៍ជាត្រកូលទាបដូច្នេះឯង ។ ម្នាលអម្ពដ្ឋ អ្នកសំគាល់ហេតុនោះដូចម្តេច ពួកព្រាហ្មណ៍ក្នុងលោកនេះ កោរក្បាលព្រាហ្មណ៍ ព្រោះទោសណាមួយ ហើយរោយផេះមួយក្តាប់ ដាក់ (លើក្បាល) រួចបណ្តេញចេញចាកដែនក្តី ចាកនគរក្តី ក៏ព្រាហ្មណ៍នោះគួរបានអាសនៈឬទឹក ក្នុងពួកព្រាហ្មណ៍ដែរឬទេ ។ អម្ពដ្ឋមាណពក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចំរើន នេះមិនគួរបានទេ ។ ចុះពួកព្រាហ្មណ៍ គួរអញ្ជើញព្រាហ្មណ៍ ឲ្យបរិភោគក្នុងកាលធ្វើភត្ត ឧទ្ទិសដល់មនុស្សស្លាប់ក្តី ក្នុងការជាមង្គលក្តី ក្នុងពិធីបូជាក្តី ក្នុងការទទួលភ្ញៀវក្តី បានដែរឬទេ ។ បពិត្រព្រះគោតមដ៏ចំរើន នេះមិនគួរបានទេ ។ ចុះ

នំ ព្រាហ្មណា មន្តេ វាចេយ្យុំ វា នោ វាតិ ។ នោ ហិទំ ភោ គោតម ។ អបិ នុស្ស ឥត្ថីសុ អាវដំ វា អស្ស អនាវដំ វាតិ ។ អាវដំ ហិស្ស ភោ គោតម ។

(១៤៨) តំ កឹ មញ្ញសិ អម្ពដ្ឋ ឥធ ខត្តិយា ខត្តិយំ កិស្មិញ្ចិទេវ បករណេ ខុរមុណ្ឌំ ករិត្វា ភស្សបុដេន វធិត្វា រដ្ឋា វា នគរា វា បព្វាជេយ្យុំ អបិ នុ សោ លភេថ ព្រាហ្មណេសុ អាសនំ វា ឧទកំ វាតិ ។ លភេថ ភោ គោតម ។ អបិ នុ នំ ព្រាហ្មណា ភោជេយ្យុំ សទ្ធេ វា ថាលិបាកេ វា យញ្ញេ វា បាហុនេ វាតិ ។ ភោជេយ្យុំ ភោ គោតម ។ អបិ នុ នំ ព្រាហ្មណា មន្តេ វាចេយ្យុំ វា នោ វាតិ ។ វាចេយ្យុំ ភោ គោតម ។ អបិ នុស្ស ឥត្ថីសុ អាវដំ វា អស្ស អនាវដំ វាតិ ។ អនាវដញ្ហិស្ស[១] ភោ គោតម ។ ឯត្តាវតា ខោ អម្ពដ្ឋ ខត្តិយោ បរមនិហីនតប្បត្តោ[២] ហោតិ យទិទំ

---

១ ឱ. អនាវដំ ហិស្ស ។ ២ ឱ. ម. បរមនិហីនតំ បត្តោ ។

ពួកព្រាហ្មណ៍គួរបង្រៀនមន្តព្រាហ្មណ៍នោះបាន ឬមិនបានទេ ។ បពិត្រព្រះគោតមដ៏ចំរើន នេះមិនគួរបង្រៀនទេ ។ ចុះគេគួរហាមមិនឲ្យព្រាហ្មណ៍នោះបានពួកស្ត្រី ( ដែលជាព្រាហ្មណកញ្ញា ) ឬមិនគួរហាមទេ ។ បពិត្រព្រះគោតមដ៏ចំរើន គួរហាម ។

(១៥៨) ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលអម្ពដ្ឋ អ្នកសំគាល់ហេតុនោះដូចម្តេច ពួកក្សត្រិយ៍ក្នុងលោកនេះ កោរក្បាលក្សត្រិយ៍ ព្រោះទោសណាមួយ ហើយរោយផេះមួយក្តាប់ ដាក់ (លើក្បាល) រួចបណ្តេញចាកដែនក្តី ចាកនគរក្តី ចុះក្សត្រិយ៍នោះ គួរបានអាសនៈឬទឹកក្នុងពួកព្រាហ្មណ៍ដែរឬទេ ។ អម្ពដ្ឋមាណពក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចំរើន គួរបាន ។ ចុះពួកព្រាហ្មណ៍ គួរអញ្ជើញក្សត្រិយ៍នោះឲ្យបរិភោគ ក្នុងកាលធ្វើភត្ត ឧទ្ទិសឲ្យមនុស្សស្លាប់ក្តី ក្នុងការជាមង្គលក្តី ក្នុងពិធីបូជាក្តី ក្នុងការទទួលភ្ញៀវក្តី បានដែរឬទេ ។ បពិត្រព្រះគោតមដ៏ចំរើន គួរអញ្ជើញឲ្យបរិភោគបាន ។ ចុះពួកព្រាហ្មណ៍គួរបង្រៀនមន្តក្សត្រិយ៍នោះបាន ឬមិនបានទេ ។ បពិត្រព្រះគោតមដ៏ចំរើន គួរបង្រៀនបាន ។ ចុះគេគួរហាមមិនឲ្យក្សត្រិយ៍នោះបានពួកស្រី (ដែលជាព្រាហ្មណកញ្ញា ) ឬមិនគួរហាមទេ ។ បពិត្រព្រះគោតមដ៏ចំរើន មិនគួរហាមទេ ។ ម្នាលអម្ពដ្ឋ ក្សត្រិយ៍ជាមនុស្សថោកទាបយ៉ាងក្រៃលែង ព្រោះពួក

ខត្តិយា ខុរមុណ្ឌំ ករិត្វា ភស្សបុដេន វធិត្វា រដ្ឋា វា នគរា វា បព្វាជេន្តិ ។ ឥតិ ខោ អម្ពដ្ឋ យទាបិ ខត្តិយោ បរមនិហីនតប្បត្តោ ហោតិ តទាបិ ខត្តិយាវ សេដ្ឋា ហីនា ព្រាហ្មណា ។ ព្រហ្មុនា បេសា អម្ពដ្ឋ សនង្កុមារេន គាថា ភាសិតា

(១៨៩) ខត្តិយោ សេដ្ឋោ[១] ជនេតស្មឹ
យេ គោត្តបដិសារិនោ
វិជ្ជាចរណសម្បន្នោ
សោ សេដ្ឋោ[២] ទេវមានុសេតិ ។

(១៩០) សា ខោ បនេសា អម្ពដ្ឋ ព្រហ្មុនា សនង្កុមារេន គាថា សុគីតា ន ទុគ្គីតា សុភាសិតា ន ទុព្ភាសិតា អត្ថសញ្ហិតា នោ អនត្ថសញ្ហិតា អនុមតា មយា អហំបិ អម្ពដ្ឋ ឯវំ វទាមិ

(១៩១) ខត្តិយោ សេដ្ឋោ ជនេតស្មឹ
យេ គោត្តបដិសារិនោ
វិជ្ជាចរណសម្បន្នោ
សោ សេដ្ឋោ ទេវមានុសេតិ ។

ភាណវារំ បឋមំ ។

---

១-២. សេដ្ឋោតិ កត្ថចិ បោត្ថកេ ទិស្សតិ ។

ក្សត្រិយ៍ផងគ្នា កោរក្បាលហើយរោយផេះមួយក្តាប់ដាក់ (លើក្បាល) រួចបណ្តេញចេញចាកដែនក្តី ចាកនគរក្តី ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។ ម្នាលអម្ពដ្ឋ ក្នុងវេលាណាក្សត្រិយ៍ទោះដល់នូវភាវៈជាអ្នកថោកទាបយ៉ាងក្រៃលែងដូច្នេះ វេលានោះ ពួកក្សត្រិយ៍គង់នៅប្រសើរជាង ឯពួកព្រាហ្មណ៍ជាមនុស្សថោកទាប ។ ម្នាលអម្ពដ្ឋ សមដូចជាព្រហ្មឈ្មោះសនង្កុមារ បានពោលគាថា ថា

(១៥៩) ក្សត្រិយ៍ជាមនុស្សប្រសើរបំផុត ក្នុងប្រជុំជន ដែល
ពោលអាងគោត្រ បុគ្គលដែលបរិបូណ៌ ដោយវិជ្ជានិងចរណៈ
ជាមនុស្សប្រសើរបំផុត ក្នុងពួកទេវតានិងមនុស្ស ។

(១៦០) ម្នាលអម្ពដ្ឋ គាថានោះ ព្រហ្មឈ្មោះសនង្កុមារបានច្រៀងត្រូវហើយ មិនមែនច្រៀងខុសទេ ជាសុភាសិត មិនមែនជាទុព្ភាសិតទេ ប្រកបដោយប្រយោជន៍ មិនមែនមិនប្រកបដោយប្រយោជន៍ទេ តថាគតក៏យល់ឃើញតាម ម្នាលអម្ពដ្ឋ សូម្បីតថាគត ក៏តែងពោលយ៉ាងនេះថា

(១៦១) ក្សត្រិយ៍ជាមនុស្សប្រសើរបំផុត ក្នុងប្រជុំជន ដែល
ពោលអាងគោត្រ បុគ្គលដែលបរិបូណ៌ ដោយវិជ្ជានិងចរណៈ
ជាមនុស្សប្រសើរបំផុត ក្នុងពួកទេវតានិងមនុស្ស ។

ចប់ ភាណវារៈទី ១ ។

(១៦៤) កតមំ បន តំ ភោ គោតម ចរណំ កតមា សា វិជ្ជាតិ ។ ន ខោ អម្ពដ្ឋ អនុត្តរាយ វិជ្ជាចរណសម្បទាយ ជាតិវាទោ វា វុច្ចតិ គោត្តវាទោ វា វុច្ចតិ មានវាទោ វា វុច្ចតិ អរហសិ វា មំ ត្វំ ន វា មំ ត្វំ អរហសីតិ ។ យត្ថ ខោ អម្ពដ្ឋ អាវាហោ វា ហោតិ វិវាហោ វា ហោតិ អាវាហវិវាហោ វា ហោតិ ឯត្ថេតំ វុច្ចតិ ជាតិវាទោ វា[១] ឥតិបិ គោត្តវាទោ វា[២] ឥតិបិ មានវាទោ វា[៣] ឥតិបិ អរហសិ វា មំ ត្វំ ន វា មំ ត្វំ អរហសីតិ ។ យេ ហិ កេចិ អម្ពដ្ឋ ជាតិវាទវិនិពទ្ធា[៤] វា គោត្តវាទវិនិពទ្ធា វា មានវាទវិនិពទ្ធា វា អាវាហវិវាហវិនិពទ្ធា វា អារកា តេ អនុត្តរាយ វិជ្ជាចរណសម្បទាយ ។ បហាយ ខោ អម្ពដ្ឋ

---

១-២.៣ ម. ភាសេត្តេន វិសុត្តិ ។ ៤ ម. ជាតិវាទវិនិពទ្ធា ។

(១៦២) អម្ពដ្ឋមាណព ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចំរើន ចរណៈនោះតើដូចម្តេច វិជ្ជានោះតើដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអម្ពដ្ឋ ការពោលប្រកាន់ជាតិក្តី ការពោលប្រកាន់គោត្រក្តី ការពោលប្រកាន់មានះថា អ្នកគួរដល់យើង ឬមិនគួរដល់យើងដូច្នេះក្តី ព្រោះបរិបូណ៌ ដោយវិជ្ជានិងចរណៈ ដែលមិនមានគុណជាតិដទៃក្រៃលែងជាង តថាគតមិនបានពោលទេ ម្នាលអម្ពដ្ឋ លុះតែក្នុងទីណា ដែលមានអាវាហៈក្តី វិវាហៈក្តី អាវាហៈនិងវិវាហៈក្តី ទីនោះទើបតថាគតពោលអំពីការពោលប្រកាន់ជាតិដូច្នេះខ្លះ ការពោលប្រកាន់គោត្រដូច្នេះខ្លះ ការពោលប្រកាន់មានះថា អ្នកគួរដល់យើង ឬមិនគួរដល់យើងដូច្នេះខ្លះ ម្នាលអម្ពដ្ឋ បើពួកជនណាមួយ ដែលនៅជាប់ចំពាក់ ដោយការពោលប្រកាន់ជាតិក្តី ជាប់ចំពាក់ ដោយការពោលប្រកាន់គោត្រក្តី ជាប់ចំពាក់ដោយការពោលប្រកាន់មានះក្តី ជាប់ចំពាក់ ដោយអាវាហៈវិវាហៈក្តី ពួកជននោះឈ្មោះថាជាអ្នកឆ្ងាយចាកគុណសម្បត្តិ គឺវិជ្ជានិងចរណៈ ដែលមិនមានគុណជាតិដទៃក្រៃលែងជាង ម្នាលអម្ពដ្ឋ ការដែលធ្វើឲ្យជាក់ច្បាស់នូវគុណសម្បត្តិ គឺវិជ្ជានិងចរណៈ ដែលមិនមានគុណជាតិដទៃលើសលុបជាង រមែងមាន

ជាតិវាទវិនិពន្ធញ្ច គោត្តវាទវិនិពន្ធញ្ច មានវាទវិនិពន្ធញ្ច អាវាហវិវាហវិនិពន្ធញ្ច អនុត្តរាយ វិជ្ជាចរណសម្បទាយ សច្ឆិកិរិយា ហោតីតិ ។

(១៦៣) កតមំ បន តំ ភោ គោតម ចរណំ កតមា សា វិជ្ជាតិ ។ ឥធ អម្ពដ្ឋ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ ។ បេ ។ (យថា សាមញ្ញផលេ(១) ឯវំ វិត្ថារេតព្វំ) ។ បេ ។ ឯវំ ខោ អម្ពដ្ឋ ភិក្ខុ សីលសម្បន្នោ ហោតិ ។ បេ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ឥទម្បិស្ស ហោតិ ចរណស្មឹ ។ បេ ។ វិតក្កវិចារានំ វូបសមា ទុតិយំ ឈានំ តតិយំ ឈានំ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ឥទម្បិស្ស ហោតិ ចរណស្មឹ ។ ឥទម្បិ ខោ តំ អម្ពដ្ឋ ចរណំ ។ ញាណទស្សនាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ បេ ។ ឥទម្បិស្ស ហោតិ វិជ្ជាយ ។ បេ ។ នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ ឥទម្បិស្ស ហោតិ វិជ្ជាយ ។ អយំ ខោ សា អម្ពដ្ឋ វិជ្ជា ។ អយំ វុច្ចតិ

១ ឱ. សាមញ្ញផលំ ។

ព្រោះបានលះបង់នូវការជាប់ជំពាក់ ដោយការពោលប្រកាន់ជាតិផង លះបង់នូវការជាប់ជំពាក់ ដោយការពោលប្រកាន់គោត្រផង លះបង់នូវការជាប់ជំពាក់ ដោយការពោលប្រកាន់មានះផង លះបង់នូវការជាប់ជំពាក់ ដោយអាវាហវិវាហៈផង ។

(១៦៣) អម្ពដ្ឋមាណព ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចំរើន ចរណៈនោះតើដូចម្តេច វិជ្ជានោះតើដូចម្តេច ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអម្ពដ្ឋ ព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ កើតឡើង ក្នុងលោកនេះ ។ បេ ។ (បណ្ឌិតគប្បីសំដែងឲ្យពិស្តារដូចក្នុងសាមញ្ញផលសូត្រ) ។ បេ ។ ម្នាលអម្ពដ្ឋ ភិក្ខុជាអ្នកបរិបូណ៌ដោយសីលយ៉ាងនេះ ។ បេ ។ ចូលកាន់បឋមជ្ឈាន នេះជាចរណៈរបស់ភិក្ខុនោះ ។បេ។ ព្រោះការរម្ងាប់វិតក្កវិចារៈហើយ ក៏ចូលកាន់ទុតិយជ្ឈាន តតិយជ្ឈាន ចតុត្ថជ្ឈាន ។ នេះជាចរណៈរបស់ភិក្ខុនោះ ។ ម្នាលអម្ពដ្ឋ នេះឯងហៅថា ចរណៈ ។ ភិក្ខុរមែងទាញនាំបង្អោនចិត្តទៅដើម្បីញាណទស្សនៈ ។ បេ ។ នេះជាវិជ្ជារបស់ភិក្ខុនោះ ។ បេ ។ (ភិក្ខុ) ដឹងច្បាស់ថា កិច្ចដទៃក្រៅ អំពីសោឡសកិច្ចនេះទៅទៀតមិនមាន ។ នេះជាវិជ្ជារបស់ភិក្ខុនោះ ។ ម្នាលអម្ពដ្ឋ នេះឯងហៅថា វិជ្ជា ។ ម្នាលអម្ពដ្ឋ ភិក្ខុនេះតថាគតពោលថា ជាអ្នកបរិបូណ៌

អម្ពដ្ឋ វិជ្ជាសម្បន្នោ ឥតិបិ ចរណសម្បន្នោ ឥតិបិ វិជ្ជាចរណសម្បន្នោ ឥតិបិ ។ ឥមាយ ច អម្ពដ្ឋ វិជ្ជាសម្បទាយ ចរណសម្បទាយ អញ្ញា វិជ្ជាសម្បទា ចរណសម្បទា ឧត្តរិតរា វា បណីតតរា វា នត្ថិ ។ ឥមាយ ខោ អម្ពដ្ឋ អនុត្តរាយ វិជ្ជាចរណសម្បទាយ ចត្តារិ អបាយមុខានិ ភវន្តិ ។ កតមានិ ចត្តារិ ។ ឥធ អម្ពដ្ឋ ឯកច្ចោ សមណោ វា ព្រាហ្មណោ វា ឥមំយេវ អនុត្តរំ វិជ្ជាចរណសម្បទំ អនភិសម្ភុណមានោ ខារិវិធមាទាយ អរញ្ញវនមជ្ឈោគាហតិ បវត្តផលភោជនោ ភវិស្សាមីតិ ។ សោ អញ្ញទត្ថុ វិជ្ជាចរណសម្បន្នស្សេវ បរិចារកោ សម្បជ្ជតិ ។ ឥមាយ ខោ អម្ពដ្ឋ អនុត្តរាយ វិជ្ជាចរណសម្បទាយ ឥទំ បឋមំ អបាយមុខំ ភវតិ ។

(១២៤) បុន ចបរំ អម្ពដ្ឋ ឥធេកច្ចោ សមណោ វា ព្រាហ្មណោ វា ឥមញ្ចេវ(១) អនុត្តរំ វិជ្ជាចរណសម្បទំ អនភិសម្ភុណមានោ បវត្តផលភោជនត្តញ្ច អនភិសម្ភុណមានោ កុទ្ទាលបិដកំ អាទាយ អរញ្ញ-

១ ឱ. ឥមញ្ច ។

ដោយវិជ្ជាខ្លះ បរិបូណ៌ដោយចរណៈខ្លះ បរិបូណ៌ដោយវិជ្ជានឹងចរណៈខ្លះៗ ម្នាលអម្ពដ្ឋ ការបរិបូណ៌ដោយវិជ្ជា ការបរិបូណ៌ដោយចរណៈដទៃដ៏លើសលុប ឬថ្លៃថ្លាជាងគុណសម្បទាគឺវិជ្ជា ជាងគុណសម្បទាគឺចរណៈនេះ មិនមានឡើយ ។ ម្នាលអម្ពដ្ឋ ប្រធាននៃសេចក្តីសាបសូន្យ នៃគុណសម្បទាគឺវិជ្ជានឹងចរណៈដែលរកគុណជាតិដទៃលើសលុបជាងគ្មាន នេះមាន ៤ យ៉ាង ។ ប្រធាននៃសេចក្តីសាបសូន្យ ៤ យ៉ាងនោះតើអ្វីខ្លះ ។ ម្នាលអម្ពដ្ឋ សមណៈក្តី ព្រាហ្មណ៍ក្តីពួកខ្លះក្នុងលោកនេះ កាលដែលមិនបានសម្រេចនូវគុណសម្បទាគឺវិជ្ជានឹងចរណៈ ដ៏ប្រសើរនេះឯង ហើយរែកនូវអម្រែកដ៏ពេញដោយបរិក្ខារទៅកាន់ព្រៃ ដោយគិតថា អាត្មាអញនឹងបរិភោគផ្លែឈើដែលជ្រុះឯង ។ សមណៈនឹងព្រាហ្មណ៍នោះឈ្មោះថា គ្រាន់តែជាអ្នកបំរើរបស់បុគ្គលអ្នកបរិបូណ៌ដោយវិជ្ជានឹងចរណៈដោយពិត ។ ម្នាលអម្ពដ្ឋ នេះជាប្រធាននៃសេចក្តីសាបសូន្យទី ១ នៃគុណសម្បទាគឺវិជ្ជានឹងចរណៈ ដែលមិនមានគុណជាតិដទៃ លើសលុបជាងនេះឯង ។

[១៦៤] ម្នាលអម្ពដ្ឋ ម្យ៉ាងទៀតថា សមណៈឬព្រាហ្មណ៍ពួកមួយក្នុងលោកនេះ មិនបានសម្រេចនូវគុណសម្បទា គឺវិជ្ជានឹងចរណៈ មិនមានគុណជាតិដទៃក្រៃលែងជាងនេះឯង មិនសម្រេចនូវការបរិភោគនូវផ្លែឈើដែលជ្រុះឯង ហើយក៏កាន់នូវចបនឹងល្អី ដើរចូលទៅកាន់ព្រៃ

វនមជ្ឈោគាហតិ(១) កន្ទមូលផលភោជនោ ភវិស្សា-
មីតិ ។ សោ អញ្ញទត្ថុ វិជ្ជាចរណសម្បន្នស្សេវ បរិចារ-
កោ សម្បជ្ជតិ ។ ឥមាយ ខោ អម្ពដ្ឋ អនុត្តរាយ
វិជ្ជាចរណសម្បទាយ ឥទំ ទុតិយំ អបាយមុខំ ហោតិ ។

(១៦៨) បុន ចបរំ អម្ពដ្ឋ ឥធេកច្ចោ សមណោ វា ព្រាហ្មណោ វា ឥមញ្ចេវ អនុត្តរំ វិជ្ជាចរណសម្បទំ អនភិសម្ភុណមានោ បវត្តផលភោជនតញ្ច អនភិសម្ភុណមានោ កន្ទមូលផលភោជនតញ្ច អនភិសម្ភុណមានោ គាមសាមន្តំ វា និគមសាមន្តំ វា អគ្យាគារំ ករិត្វា អគ្គឹ បរិចរន្តោ អច្ឆតិ ។ សោ អញ្ញទត្ថុ វិជ្ជាចរណសម្បន្នស្សេវ បរិចារកោ សម្បជ្ជតិ ។ ឥមាយ ខោ អម្ពដ្ឋ អនុត្តរាយ វិជ្ជាចរណសម្បទាយ ឥទំ តតិយំ អបាយមុខំ ហោតិ ។

---

១ ឱ. អរញ្ញ វនំ អជ្ឈោគាហតិ ។

ដោយគិតថា អាត្មាអញនឹងយកមើមដំឡូងនឹងផ្លែឈើជាអាហារ ។ សមណព្រាហ្មណ៍នោះឈ្មោះថា គ្រាន់តែជាអ្នកបំរើ របស់បុគ្គលអ្នកបរិបូណ៌ ដោយវិជ្ជានឹងចរណៈដោយពិត ។ ម្នាលអម្ពដ្ឋ នេះជាប្រធាននៃសេចក្តីសាបសូន្យទី ២ នៃគុណសម្បទា គឺវិជ្ជានឹងចរណៈដ៏ប្រសើរនេះឯង ។

(១៦៩) ម្នាលអម្ពដ្ឋ ម្យ៉ាងទៀត សមណៈឬព្រាហ្មណ៍ពួកខ្លះ ក្នុងលោកនេះ មិនសម្រេចនូវគុណសម្បទា គឺវិជ្ជានឹងចរណៈដ៏ប្រសើរនេះឯងផង មិនសម្រេចនូវការបរិភោគផ្លែឈើដែលជ្រុះឯងផង មិនសម្រេចនូវការបរិភោគមើមដំឡូងនឹងផ្លែឈើផង តែធ្វើរោងភ្លើងទុកជិតស្រុកឬជិតនិគម ហើយនៅបំរើភ្លើង ។ សមណព្រាហ្មណ៍នោះឈ្មោះថា គ្រាន់តែជាអ្នកបំរើ របស់បុគ្គលអ្នកបរិបូណ៌ ដោយវិជ្ជានឹងចរណៈដោយពិត ។ ម្នាលអម្ពដ្ឋ នេះជាប្រធាននៃសេចក្តីសាបសូន្យទី ៣ នៃគុណសម្បទា គឺវិជ្ជានឹងចរណៈដ៏ប្រសើរនេះឯង ។

(១៦៦) បុន ចបរំ អម្ពដ្ឋ ឥធេកច្ចោ សមណោ វា ព្រាហ្មណោ វា ឥមញ្ចេវ អនុត្តរំ វិជ្ជាចរណសម្បទំ អនភិសម្ភុណមានោ បវត្តផលភោជនតញ្ច អនភិសម្ភុណមានោ កន្ទមូលផលភោជនតញ្ច អនភិសម្ភុណមានោ អគ្គិបារិចរិយញ្ច អនភិសម្ភុណមានោ ចាតុម្មហាបថេ ចតុទ្វារំ អគារំ ករិត្វា អច្ឆតិ យោ ឥមាហិ ចតូហិ ទិសាហិ អាគមិស្សតិ សមណោ វា ព្រាហ្មណោ វា តមហំ[1] យថាសត្តិ យថាពលំ បដិបូជិស្សាមីតិ ។ សោ អញ្ញទត្ថុ វិជ្ជាចរណសម្បន្នស្សេវ បរិចារកោ សម្បជ្ជតិ ។ ឥមាយ ខោ អម្ពដ្ឋ អនុត្តរាយ វិជ្ជាចរណសម្បទាយ ឥទំ ចតុត្ថំ អបាយមុខំ ហោតិ ។ ឥមាយ ខោ អម្ពដ្ឋ អនុត្តរាយ វិជ្ជាចរណសម្បទាយ ឥមានិ ចត្តារិ អបាយមុខានិ ភវន្តិ ។

(១៦៧) តំ កឹ មញ្ញសិ អម្ពដ្ឋ អបិនុ ត្វំ ឥមាយ អនុត្តរាយ វិជ្ជាចរណសម្បទាយ សន្ទិស្សសិ សាចរិយកោតិ ។ នោ ហិទំ ភោ គោតម កោ ចាហំ

---

១ ឱ. តំ អហំ ។

(១៦៦) ម្នាលអម្ពដ្ឋ ម្យ៉ាងទៀត សមណៈឬព្រាហ្មណ៍ពួកខ្លះក្នុងលោកនេះ មិនសម្រេច នូវគុណសម្បទា គឺវិជ្ជានិងចរណៈដ៏ប្រសើរនេះឯងផង មិនសម្រេចនូវការបរិភោគផ្លែឈើដែលជ្រុះឯងផង មិនសម្រេចនូវការបរិភោគមើមដំឡូងនិងផ្លែឈើផង មិនសម្រេចនូវការបំរើភ្លើងផង តែធ្វើរោងមានទ្វារ ៤ នៅក្បែរផ្លូវធំ ៤ ហើយគិតថា អ្នកណាមកអំពីទិសទាំង ៤ នេះ ទោះសមណៈក្តី ព្រាហ្មណ៍ក្តី អាត្មាអញនឹងបូជានូវសមណព្រាហ្មណ៍នោះ តាមអំណាច តាមកម្លាំង ៗ សមណព្រាហ្មណ៍នោះឈ្មោះថា គ្រាន់តែជាអ្នកបំរើ របស់បុគ្គលអ្នកបរិបូណ៌ដោយវិជ្ជានិងចរណៈដោយពិត ៗ ម្នាលអម្ពដ្ឋ នេះជាប្រធាននៃសេចក្តីសាបសូន្យទី ៤ នៃគុណសម្បទា គឺវិជ្ជានិងចរណៈដ៏ប្រសើរនេះឯង ៗ ម្នាលអម្ពដ្ឋ ប្រធាននៃសេចក្តីសាបសូន្យនៃគុណសម្បទា គឺវិជ្ជានិងចរណៈដ៏ប្រសើរមាន ៤ យ៉ាងនេះឯង ៗ

(១៦៧) ម្នាលអម្ពដ្ឋ អ្នកសំគាល់សេចក្តីនោះដូចម្តេច ខ្លួនអ្នកព្រមទាំងអាចារ្យ យល់ច្បាស់ក្នុងគុណសម្បទា គឺវិជ្ជានិងចរណៈដ៏ប្រសើរនេះខ្លះដែរឬ ៗ បពិត្រព្រះគោតមដ៏ចំរើន ហេតុនេះមិនមានទេ បពិត្រព្រះ

ភោ គោតម សាចរិយកោ កា ច អនុត្តរា វិជ្ជាចរ-
ណសម្បទា អារកាហំ(១) ភោ គោតម ឥមាយ អ-
នុត្តរាយ វិជ្ជាចរណសម្បទាយ សាចរិយកោតិ ។ តំ
កឹ មញ្ញសិ អម្ពដ្ឋ អបិនុ ត្វំ ឥមំយេវ អនុត្តរំ វិជ្ជា-
ចរណសម្បទំ អនភិសម្ភុណមានោ ខារិវិធមាទាយ
អរញ្ញវនមជ្ឈោគាហសិ សាចរិយកោ បវត្តផលភោជ-
នោ(២) ភវិស្សាមីតិ ។ នោ ហិទំ ភោ គោតម ។ តំ
កឹ មញ្ញសិ អម្ពដ្ឋ អបិនុ ត្វំ ឥមញ្ចេវ អនុត្តរំ វិជ្ជាចរ-
ណសម្បទំ អនភិសម្ភុណមានោ បវត្តផលភោជនត្តញ្ច
អនភិសម្ភុណមានោ កុទ្ទាលបិដកំ អាទាយ អរញ្ញ-
វនមជ្ឈោគាហសិ សាចរិយកោ កន្ទមូលផលភោ-
ជនោ ភវិស្សាមីតិ ។ នោ ហិទំ ភោ គោតម ។ តំ
កឹ មញ្ញសិ អម្ពដ្ឋ អបិនុ ត្វំ ឥមញ្ចេវ អនុត្តរំ
វិជ្ជាចរណសម្បទំ អនភិសម្ភុណមានោ បវត្តផល-
ភោជនត្តញ្ច អនភិសម្ភុណមានោ កន្ទមូលផល-
ភោជនត្តញ្ច អនភិសម្ភុណមានោ គាមសាមន្តំ វា

---

១ ឱ. អារកោហំ ។ ២ ឱ. ម. បវត្តផលភោជិនោ ។

គោតមដ៏ចំរើន ខ្ញុំព្រះអង្គព្រមទាំងអាចារ្យដោយខ្សែកផ្សេង គុណសម្បទា គឺវិជ្ជានឹងចរណៈដ៏ប្រសើរដោយខ្សែកផ្សេង បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គព្រមទាំងអាចារ្យ ជាមនុស្សឆ្ងាយចាកគុណសម្បទា គឺវិជ្ជានឹងចរណៈដ៏ប្រសើរនេះ ។ ម្នាលអម្ពដ្ឋ អ្នកសំគាល់ហេតុនោះដូចម្តេច ខ្លួនអ្នកព្រមទាំងអាចារ្យ កាលបើមិនទាន់បានសម្រេចនូវគុណសម្បទា គឺវិជ្ជានឹងចរណៈដ៏ប្រសើរនេះទេ ហើយនាំយកនូវអំរែកដ៏ពេញ ដោយគ្រឿងបរិក្ខារតត្រុកចូលទៅកាន់ព្រៃដោយគិតថា យើងនឹងយកផ្លែឈើដែលជ្រុះឯងជាអាហារដូច្នេះឬ ។ បពិត្រព្រះគោតមដ៏ចំរើន ហេតុនេះមិនមែនទេ ។ ម្នាលអម្ពដ្ឋ អ្នកសំគាល់ហេតុនោះដូចម្តេច ខ្លួនអ្នកព្រមទាំងអាចារ្យ កាលមិនសម្រេចនូវគុណសម្បទា គឺវិជ្ជានឹងចរណៈដ៏ប្រសើរនេះផង ជាអ្នកមិនសម្រេចនូវការបរិភោគផ្លែឈើដែលជ្រុះឯងផង កាន់ចបនឹងល្អី តត្រុកចូលទៅកាន់ព្រៃ ដោយគិតថា យើងនឹងយកនូវមើមដំឡូងនឹងផ្លែឈើជាអាហារដូច្នេះដែរឬ ។ បពិត្រព្រះគោតមដ៏ចំរើន ហេតុនេះមិនមែនដូច្នោះទេ ។ ម្នាលអម្ពដ្ឋ អ្នកសំគាល់ហេតុនោះដូចម្តេច ខ្លួនអ្នកព្រមទាំងអាចារ្យ កាលមិនបានត្រាស់ដឹងនូវគុណសម្បទា គឺវិជ្ជានឹងចរណៈដ៏ប្រសើរនេះផង ជាអ្នកមិនសម្រេចនូវការបរិភោគនូវផ្លែឈើដែលជ្រុះឯងផង ជាអ្នកមិនសម្រេចនូវការបរិភោគនូវមើមដំឡូងនឹងផ្លែឈើផង តែធ្វើរោងភ្លើងជិតស្រុកក្តី

និគមសាមន្តំ វា អគ្យាគារំ ករិត្វា អគ្គឹ បរិចរន្តោ អច្ឆសិ សាចរិយកោតិ ។ នោ ហិទំ ភោ គោតម ។ តំ កឹ មញ្ញសិ អម្ពដ្ឋ អបិន្នុ ត្វំ ឥមញ្ចេវ អនុត្តរំ វិជ្ជាចរណសម្បទំ អនភិសម្ភុណមានោ បវត្តផលភោជនតញ្ច អនភិសម្ភុណមានោ កន្ទមូលផលភោជនតញ្ច អនភិសម្ភុណមានោ អគ្គិបារិចរិយញ្ច អនភិសម្ភុណមានោ ចាតុម្មហាបថេ ចតុទ្វារំ អគារំ ករិត្វា អច្ឆសិ សាចរិយកោ យោ ឥមាហិ ចតូហិ ទិសាហិ អាគមិស្សតិ សមណោ វា ព្រាហ្មណោ វា តមហំ យថាសត្តិ យថាពលំ បដិបូជិស្សាមីតិ(១) ។ នោ ហិទំ ភោ គោតម ។ ឥតិ ខោ អម្ពដ្ឋ ឥមាយ ចេវ ត្វំ អនុត្តរាយ វិជ្ជាចរណសម្បទាយ បរិហីនោ សាចរិយកោ យេ ហិ កោចិមេ(២) អនុត្តរាយ វិជ្ជាចរណសម្បទាយ ចត្តារិ អបាយមុខានិ ភវន្តិ តតោ ច(៣) បរិហីនោ សាចរិយកោ ។

---

១ ឱ. ម. បដិបូជេស្សាមាតិ ។ ២ ឱ. ម. យេបិមេ ។ ៣ ឱ. បសិ ។ ម. បិ ត្វំ ។

ជិតនិគមក្តី ហើយនៅចាំបំរើភ្លើងដូច្នេះដែរឬ ។ បពិត្រព្រះគោតមដ៏ចំរើន ហេតុនេះមិនមែនដូច្នោះទេ ។ ម្នាលអម្ពដ្ឋ អ្នកសំគាល់ហេតុនោះដូចម្តេច ខ្លួនអ្នកព្រមទាំងអាចារ្យ កាលមិនសម្រេចនូវគុណសម្បទា គឺវិជ្ជានិងចរណៈដ៏ប្រសើរនេះឯងផង មិនសម្រេចនូវការបរិភោគនូវផ្លែឈើដែលជ្រុះឯងផង មិនសម្រេចនូវការបរិភោគនូវមើមដំឡូងនិងផ្លែឈើផង មិនសម្រេចនូវការបំរើភ្លើងទេ តែធ្វើរោងមានទ្វារ ៤ ក្បែរផ្លូវធំ ៤ ហើយនៅដោយគិតថា អ្នកណាមកអំពីទិសទាំង ៤នេះ ទោះសមណៈក្តី ព្រាហ្មណ៍ក្តី អាត្មាអញនឹងបូជានូវសមណព្រាហ្មណ៍នោះ តាមអំណាច តាមកំឡាំង ដូច្នេះដែរឬ ។ បពិត្រព្រះគោតមដ៏ចំរើន ហេតុនេះមិនមែនដូច្នោះទេ ។ ម្នាលអម្ពដ្ឋ ខ្លួនអ្នកព្រមទាំងអាចារ្យ ជាអ្នកសាបសូន្យហើយ ចាកគុណសម្បទា គឺវិជ្ជានិងចរណៈដ៏ប្រសើរនេះផង ខ្លួនអ្នកព្រមទាំងអាចារ្យ ជាអ្នកសាបសូន្យចាកប្រធាន នៃសេចក្តីសាបសូន្យនៃគុណសម្បទា គឺវិជ្ជានិងចរណៈដ៏ប្រសើរមាន ៤ យ៉ាងនោះផង ។

(១៦៨) ភាសិតា ខោ បន តេ ឯសា អម្ពដ្ឋ អាចរិយេន ព្រាហ្មណេន បោក្ខរសាតិនា វាចា កេ ច[1] មុណ្ឌកា សមណកា ឥព្ភា កណ្ហា ពន្ធុបាទបច្ចា[2] កា ច តេវិជ្ជានំ ព្រាហ្មណានំ សាកច្ឆាតិ ។ អត្តនា អាបាយិកោបិ អបរិបូរមានោ ។ បស្ស អម្ពដ្ឋ យាវ អបរទ្ធញ្ច តេ ឥទំ អាចរិយស្ស ព្រាហ្មណស្ស បោក្ខរសាតិស្ស ។ ព្រាហ្មណោ ខោ បន អម្ពដ្ឋ បោក្ខរសាតិ រញ្ញោ បសេនទិកោសលស្ស ទត្តិកំ ភុញ្ជតិ តស្ស រាជា បសេនទិកោសលោ សម្មុខីភាវំបិ ន ទទាតិ យទាបិ តេន មន្តេតិ តិរោទុស្សេន មន្តេតិ ។ យស្ស ខោ បន អម្ពដ្ឋ ធម្មិកំ បយាតំ[3] ភិក្ខំ បដិគ្គណ្ហេយ្យ កថំ តស្ស រាជា បសេនទិកោសលោ សម្មុខីភាវំបិ ន ទទេយ្យ ។ បស្ស អម្ពដ្ឋ យាវ អបរទ្ធញ្ច តេ ឥទំ អាចរិយស្ស ព្រាហ្មណស្ស បោក្ខរសាតិស្ស ។

---

១ ឱ, ម. កេចិ ។ ២ ឱ. ពន្ធុបទាបច្ចា ។ ម ពន្ធុបាទាបច្ចា ។ ៣ ឱ. បយតំ ។

[១៦៨] ម្នាលអម្ពដ្ឋ បោក្ខរសាតិព្រាហ្មណ៍ ជាអាចារ្យរបស់អ្នក បានពោលពាក្យនេះថា ពួកសមណៈត្រងោលណាមួយ ឆ្នាប់ជាត្រកូលគហបតី ជាកណ្ហគោត្រ កើតអំពីព្រះបាទនៃមហាព្រហ្ម ពួកព្រាហ្មណ៍ដែលបានត្រៃវិជ្ជានឹងសាកច្ឆាជាមួយដូចម្តេចបាន ។ ខ្លួនឯងសូម្បីតែនឹងបំពេញវត្តដែលជាផ្លូវសាបសូន្យតាក (វិជ្ជា) ក៏នៅមិនទាន់គ្រប់គ្រាន់ ។ ម្នាលអម្ពដ្ឋ អ្នកចូរមើលកំហុសប៉ុណ្ណោះ របស់បោក្ខរសាតិព្រាហ្មណ៍ជាអាចារ្យនៃអ្នកចុះ ។ ម្នាលអម្ពដ្ឋ បោក្ខរសាតិព្រាហ្មណ៍បានបរិភោគនូវវត្ថុដែលទ្រង់ប្រោសព្រះរាជទាននៃព្រះបាទបសេនទិកោសល តែព្រះបាទបសេនទិកោសល ទ្រង់មិនបានព្រះរាជទានដល់ព្រាហ្មណ៍នោះចំពោះព្រះភក្ត្រទេ សូម្បីតែកន្លងវេលា ដែលទ្រង់ប្រឹក្សាជាមួយនឹងព្រាហ្មណ៍នោះ តែងប្រឹក្សាពីខាងក្រៅព្រះសាណី (វាំងនន) ។ ម្នាលអម្ពដ្ឋ ព្រាហ្មណ៍ណាដែលគួរទទួលនូវភិក្ខាដែលគេនាំមកថ្វាយ ប្រកបដោយធម៌ហើយ ចុះហេតុដូចម្តេច បានជាព្រះបាទបសេនទិកោសល ទ្រង់មិនព្រះរាជទានដល់ព្រាហ្មណ៍នោះចំពោះព្រះភក្ត្រខ្លះ ។ ម្នាលអម្ពដ្ឋ អ្នកចូរមើលកំហុសប៉ុណ្ណោះ របស់បោក្ខរសាតិព្រាហ្មណ៍ជាអាចារ្យរបស់អ្នកចុះ ។

(១៦៩) តំ កឹ មញ្ញសិ អម្ពដ្ឋ ឥធ រាជា បសេនទិ កោសលោ ហត្ថិគីវាយំ វា និសិន្នោ(១) រថូ-បត្ថរេ វា ឋិតោ ឧគ្គេហិ វា រាជញ្ញេហិ វា(២) កិញ្ចិទេវ មន្តនំ មន្តេយ្យ ។ សោ តម្ហា បទេសា អបក្កម្ម ឯកមន្តំ(៣) តិដ្ឋេយ្យ អថ អាគច្ឆេយ្យ សុទ្ទោ វា សុទ្ទទាសោ វា សោ តស្មិំ បទេសេ ឋិតោ(៤) មន្តនំ មន្តេយ្យ ឯវំបិ រាជា បសេនទិ កោសលោ អាហ ឯវំបិ រាជា បសេនទិ កោសលោ អាហាតិ ។ អបិ នុ សោ រាជភណិតំ វា ភណតិ រាជមន្តំ វា មន្តេតិ តាវតា សោ អស្ស រាជា វា រាជមហាមត្តោ វាតិ(៥) ។ នោ ហិទំ ភោ គោតម ។ ឯវមេវ ខោ ត្វំ អម្ពដ្ឋ យេ តេ(៦) អហេសុំ ព្រាហ្មណានំ បុព្វកា ឥសយោ

១ ឱ. ម. ឯត្ថន្តរេ អស្សបិដ្ឋេ វា និសិន្នោតិ ទិស្សតិ ។ ២ ឱ. រាជវេយ្យេហិ វា ។ ៣ ឱ. ឯកមន្តេ ។ ៤ ឱ. ម. ឯត្ថន្តរេ តទេវាតិ ទិស្សតិ ។ ៥ ឱ. ឯវំបិ រាជា បសេនទិកោសលោ អភាសិ ។ អបិនុ សោ រាជាភណិតំ វា ភណតិ រាជាមន្តំ វា មន្តេតិ តាវតា សោ អស្ស រាជា វា រាជមត្តោ វាតិ ។ ៦ ឱ. ម. តេ ។

(១៦៩) ម្នាលអម្ពដ្ឋ អ្នកសំគាល់ហេតុនោះដូចម្ដេច ព្រះបាទបសេនទិកោសលក្នុងជនបទនេះ គង់នៅលើ កដំរីក្តី ឋិតនៅលើកជាសនៈក្នុងរថក្តី ទ្រង់ប្រឹក្សារឿងអ្វី ៗ ជាមួយនឹងពួករាជអាមាត្យ ឬជាមួយនឹងព្រះរាជវង្សានុវង្ស ។ ព្រះអង្គបានស្ដេចចេញពីប្រទេសនោះ ទៅទ្រង់ឋិតនៅក្នុងទីដ៏សមគួរ ក៏ស្រាប់តែមានបុរសជាតិសូទ្រៈ ឬទាសៈរបស់បុរសជាតិសូទ្រៈនោះ មកឈរក្នុងប្រទេសនោះនិយាយថា ព្រះរាជាបសេនទិកោសលទ្រង់មានព្រះរាជឱង្ការយ៉ាងនេះខ្លះ ព្រះរាជាបសេនទិកោសលទ្រង់មានព្រះរាជឱង្ការយ៉ាងនេះខ្លះ ៗ បុរសនោះបើគ្រាន់តែនិយាយតាមទំនងដែលស្ដេចទ្រង់មានព្រះរាជឱង្ការក្តី ប្រឹក្សាទូវការដែលស្ដេចទ្រង់ប្រឹក្សាក្តី ដោយហេតុមានប្រមាណប៉ុណ្ណោះ តើទឹងហៅថាស្ដេច ឬហៅថាអាមាត្រធំរបស់ស្ដេច បានដែរឬទេ ។ បពិត្រព្រះគោតមដ៏ចំរើន សេចក្តីនេះមិនមែនដូច្នោះទេ ។ ម្នាលអម្ពដ្ឋ ខ្លួនអ្នកក៏ដូច្នោះដែរ ម្យ៉ាងទៀត ឥសីទាំងឡាយណា ដែលជាបុព្វបុរស របស់ព្រាហ្មណ៍ទាំងឡាយ

មន្តានំ កត្តារោ មន្តានំ បវត្តារោ យេសមិទំ ឯតរហិ ព្រាហ្មណា បោរាណំ មន្តបទំ គីតំ បវុត្តំ សមិហិតំ តទនុគាយន្តិ តទនុភាសន្តិ ភាសិតមនុភាសន្តិ វាចិតមនុវាចេន្តិ សេយ្យថីទំ អដ្ឋកោ វាមកោ វាមទេវោ វេស្សាមិត្តោ យមតគ្គិ(១) អង្គីរសោ ភារទ្វាជោ វាសេដ្ឋោ កស្សបោ ភគុ ត្យាហំ មន្តេ អធិយាមិ សាចរិយកោ តាវតា ត្វំ ការិស្សសិ ឥសិ វា ឥសិត្តាយ វា បដិបន្នោតិ នេតំ ឋានំ វិជ្ជតិ ។ តំ កឹ មញ្ញសិ អម្ពដ្ឋ កិន្តិ តេ សុតំ ព្រាហ្មណានំ វុឌ្ឍានំ មហល្លកានំ អាចរិយបាចរិយានំ ភាសមានានំ យេ តេ អហេសុំ ព្រាហ្មណានំ បុព្វកា ឥសយោ មន្តានំ កត្តារោ មន្តានំ បវត្តារោ យេសមិទំ ឯតរហិ ព្រាហ្មណា បោរាណមន្តបទំ(២) គីតំ បវុត្តំ សមិហិតំ តទនុគាយន្តិ តទនុភាសន្តិ ភាសិតមនុ-

១ យមតគ្គី ឥតិបិ បាឋោ ។ ២ ឱ. ម. បោរាណំ មន្តបទំ ។

ជាអ្នកកសាងមន្ត ជាអ្នកកាយមន្ត លំអាននៃមន្តបុរាណនេះ ដែលពួកឥសីណាបាន ( ស្វាធ្យាយ ) មកហើយ បានសូត្រមកហើយ បានសន្សំមកច្រើនហើយ ឥឡូវនេះព្រាហ្មណ៍ទាំងនោះ តែងច្រៀង (ស្វាធ្យាយ) តាមលំអាននៃមន្តនោះ តែងសូត្រតាមលំអាននៃមន្តនោះ តែងពោលតាមលំអាននៃមន្តដែលពួកឥសីបានពោលមក តែងបង្រៀនតាមលំអាននៃមន្តដែលពួកឥសីបានបង្រៀនមក ឥសីទាំងនោះគឺឥសីណាខ្លះ គឺឥសីឈ្មោះ អដ្ឋកៈ ១ វាមកៈ ១ វាមទេវៈ ១ វេស្សាមិត្តៈ ១ យមតគ្គិ ១ អង្គីរសៈ ១ ភារទ្វាជៈ ១ វាសេដ្ឋៈ ១ កស្សបៈ ១ ភគុ ១ តថាគតក៏ធ្លាប់បានរៀនមន្តទាំងនោះដែរ ឯខ្លួនអ្នកព្រមទាំងអាចារ្យនឹងបានឈ្មោះថាជាឥសីឬជាអ្នកប្រព្រឹត្ត ដើម្បីភាវៈជាឥសីដោយការរៀនមន្តប៉ុណ្ណោះ ហេតុនេះមិនមែនដូច្នោះទេ ។ ម្នាលអម្ពដ្ឋ អ្នកសំគាល់ហេតុនោះដូចម្តេច អ្នកធ្លាប់បានឮពួកព្រាហ្មណ៍ចាស់ ៗ មានអាយុច្រើន ជាអាចារ្យតូចធំ ធ្លាប់និយាយមកដូចម្តេច ឥសីទាំងឡាយណាដែលជាបុព្វបុរស របស់ព្រាហ្មណ៍ទាំងឡាយដែលជាអ្នកកសាងមន្ត ជាអ្នកកាយមន្ត លំអាននៃមន្តបុរាណនេះ ដែលពួកឥសីណាបានច្រៀង (ស្វាធ្យាយ) មកហើយ បានសូត្រមកហើយ បានសន្សំមកច្រើនហើយ ឥឡូវនេះព្រាហ្មណ៍ទាំងឡាយ តែងស្វាធ្យាយតាមលំអាននៃមន្តនោះ តែងសូត្រតាមលំអាននៃមន្តនោះ តែងពោលតាម

ភាសន្តិ វាចិតមនុវាចេន្តិ សេយ្យថីទំ អដ្ឋកោ វា-
មកោ វាមទេវោ វេស្សាមិត្តោ យមតគ្គិ អង្គីរសោ
ភារទ្វាជោ វាសេដ្ឋោ កស្សបោ ភគុ យំ សុ តេ
សុន្ហាតា សុវិលិត្តា កប្បិតកេសមស្សូ អាមុត្ត-
មាលាភរណា[1] ឱទាតវត្ថវសនា បញ្ចហិ កាមគុ-
ណេហិ សមប្បិតា សមង្គិភូតា បរិចារេន្តិ សេយ្យ-
ថាបិ ត្វំ ឯតរហិ សាចរិយកោតិ ។ នោ ហិទំ
ភោ គោតម ។ បេ ។ យំ សុ តេ សាលីនំ
ឱទនំ វិចិត្តកាឡកំ អនេកសូបំ អនេកព្យញ្ជនំ
បរិភុញ្ជន្តិ សេយ្យថាបិ ត្វំ ឯតរហិ សាចរិយកោតិ ។
នោ ហិទំ ភោ គោតម ។ បេ ។ យំ សុ តេ វេឋកន-
តបស្សាហិ[2] នារីហិ បរិចារេន្តិ សេយ្យថាបិ ត្វំ ឯតរហិ
សាចរិយកោតិ ។ នោ ហិទំ ភោ គោតម ។ បេ ។

---

១ ម. អាមុត្តមណិកុណ្ឌលាភរណា ។ ២ ម. វេដ្ឋកនតបស្សាហិ ។

លំអាននៃមន្តដែលពួកឥសី បានពោលមក តែងបង្រៀនតាមលំអាននៃមន្តដែលពួកឥសីបានបង្រៀនមក ឥសីទាំងនោះគឺឥសីណាខ្លះ គឺឥសីឈ្មោះអដ្ឋកៈ ១ វាមកៈ ១ វាមទេវៈ ១ វេស្សាមិត្តៈ ១ យមតគ្គិ ១ អង្គីរសៈ ១ ភារទ្វាជៈ ១ វាសេដ្ឋៈ ១ កស្សបៈ ១ ភគុ ១ ដូច្នេះឬ ឥសីទាំងនោះបានងូតទឹកដ៏ស្អាត លាបស្រឡាបដោយគ្រឿងក្រអូបសាយល្អ មានសក់នឹងពុកមាត់កាត់ស្រេចហើយ ពាក់កម្រងផ្កានឹងគ្រឿងប្រដាប់ ស្លៀកសំពត់ស ជាអ្នកឆ្អែតស្កប់ស្កល់ មានគេផ្គាប់ផ្គុនបម្រើដោយកាមគុណ ៥ ដូចជាខ្លួនអ្នកព្រមទាំងអាចារ្យ ក្នុងកាលឥឡូវនេះយ៉ាងនេះដែរឬ ។ បពិត្រព្រះគោតមដ៏ចំរើន សេចក្តីនេះមិនមែនដូច្នោះទេ ។ បេ ។ ឥសីទាំងនោះបរិភោគបាយនៃស្រូវសាលី ប្រាសចាកមន្ទិលមានសម្លច្រើនមុខ នឹងម្ហូបគ្រៀមច្រើនមុខ ដូចជាខ្លួនអ្នកព្រមទាំងអាចារ្យ ក្នុងកាលឥឡូវនេះយ៉ាងនេះដែរឬ ។ បពិត្រព្រះគោតមដ៏ចំរើន សេចក្តីនេះមិនមែនដូច្នោះទេ ។ បេ ។ ឥសីទាំងនោះត្រេកត្រអាលដោយពួកស្ត្រីមានចង្កេះរៀវ ដោយសំពត់ព័ទ្ធព័ន្ធ ដូចជាខ្លួនអ្នកព្រមទាំងអាចារ្យ ក្នុងកាលឥឡូវនេះយ៉ាងនេះដែរឬ ។ បពិត្រព្រះគោតមដ៏ចំរើន សេចក្តីនេះមិនមែនដូច្នោះទេ ។ បេ ។

យំ សុ តេ កុត្តវាលេហិ វឡវារថេហិ ទីឃាហិ បតោទលដ្ឋីហិ វាហនេ វិតុទន្តា វិបរិយាយន្តិ សេយ្យ-ថាបិ ត្វំ សាចរិយកោតិ ។ នោ ហិទំ ភោ គោតម ។ បេ ។ យំ សុ តេ ឧក្កិណ្ណបរិក្ខាសុ ឱក្ខិត្តបលិឃាសុ[១] នគរូបការិកាសុ ទីឃាសិតាវុធេ-ហិ[២] បុរិសេហិ រក្ខាបេន្តិ សេយ្យថាបិ ត្វំ សាចរិយកោតិ ។ នោ ហិទំ ភោ គោតម ។ បេ ។ ឥតិ ខោ អម្ពដ្ឋ នេវ ត្វំ ឥសិ ន បន[៣] ឥសិត្តាយ បដិបន្នោ សាចរិយកោ យស្ស ខោ បន អម្ពដ្ឋ មយិ កង្ខា វា វិមតិ វា សោ មំ បញ្ហេន អហំ វេយ្យាករណេន សោធិស្សាមីតិ ។

(១៧០) អថ ខោ ភគវា វិហារា និក្ខម្ម ចង្កមំ អព្ភុដ្ឋាសិ ។ អម្ពដ្ឋោបិ មាណវោ វិហារា និក្ខម្ម ចង្កមំ អព្ភុដ្ឋាសិ ។ អថ ខោ អម្ពដ្ឋោ មាណវោ ភគវន្តំ ចង្កមន្តំ អនុចង្កមមានោ ភគវតោ កាយេ ទ្វត្តឹសម-ហាបុរិសលក្ខណានិ សមន្នេសិ ។ អទ្ទសា ខោ អម្ពដ្ឋោ មាណវោ ភគវតោ កាយេ ទ្វត្តឹសមហាបុរិស-

១ ឱ. ម. ឱក្ខិត្តបលិឃាសុ ។ ២ ម. ទីឃាសិវុធេហិ ។ ៣ ម. បនសទ្ទោ ន បញ្ញាយតិ ។

ឥសីទាំងនោះ គ្រាប់ទៅដោយរថ ដែលទឹមដោយសេះកាត់កេមកន្ទុយ ពាក់ពាហនៈ ដោយដងចន្ទុញដ៏វែង ដូចជាអ្នកព្រមទាំងអាចារ្យ ក្នុងកាលឥឡូវនេះ យ៉ាងនេះដែរឬ ។ បពិត្រព្រះគោតមដ៏ចំរើន សេចក្តីនេះមិនមែនដូច្នោះទេ ។បេ។ ឥសីទាំងនោះ ប្រើបុរសដែលសៀតដាវវែង ឲ្យកេក្រាទៀបជើងកំពែងនគរ មានស្នាមក្បោះព័ទ្ធជុំវិញ ទាំងសឹកគន្ទឹះខ្ជាប់ ដូចជាខ្លួនអ្នកព្រមទាំងអាចារ្យ ក្នុងកាលឥឡូវនេះ យ៉ាងនេះដែរឬ ។ បពិត្រព្រះគោតមដ៏ចំរើន សេចក្តីនេះមិនមែនដូច្នោះទេ ។បេ។ ម្នាលអម្ពដ្ឋ ខ្លួនអ្នកព្រមទាំងអាចារ្យ មិនមែនជាឥសី មិនមែនជាអ្នកប្រតិបត្តិ ដើម្បីភាវៈជាឥសីទេ ដោយប្រការដូច្នេះឯង ម្នាលអម្ពដ្ឋ មួយវិញទៀត អ្នកណា មានសេចក្តីសង្ស័យ ឬងឿងឆ្ងល់ចំពោះតថាគត ឲ្យអ្នកនោះមកសួរប្រស្នាចំពោះតថាគតចុះ តថាគតនឹងដោះស្រាយឲ្យ ។

(១៧០) លំដាប់នោះ ព្រះមានព្រះភាគ ស្តេចចេញអំពីវិហារ ហើយទ្រង់យាងទៅកាន់ទីចង្ក្រម ។ អម្ពដ្ឋមាណព ក៏ចេញអំពីវិហារទៅកាន់ទីចង្ក្រមដែរ ។ លំដាប់នោះ អម្ពដ្ឋមាណព ក៏ចង្ក្រមតាមព្រះមានព្រះភាគដែលកំពុងចង្ក្រម បានសង្កេតមើលនូវមហាបុរិសលក្ខណៈ ៣២ ប្រការ ក្នុងព្រះកាយ របស់ព្រះមានព្រះភាគ ។ លុះអម្ពដ្ឋមាណពបាន ឃើញនូវមហាបុរិសលក្ខណៈ ៣២ ប្រការ ក្នុងព្រះកាយ របស់ព្រះមាន

លក្ខណានិ យេភុយ្យេន ឋបេត្វា ទ្វេ ទ្វីសុ មហាបុរិសលក្ខណេសុ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ កោសោហិតេ ច វត្ថគុយ្ហេ បហូតជិវ្ហតាយ ច ។ អថខោ ភគវតោ ឯតទហោសិ បស្សតិ ខោ មេ អយំ អម្ពដ្ឋោ មាណវោ ទ្វត្តឹសមហាបុរិសលក្ខណានិ យេភុយ្យេន ឋបេត្វា ទ្វេ ទ្វីសុ មហាបុរិសលក្ខណេសុ អម្ពដ្ឋោ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ កោសោហិតេ ច វត្ថគុយ្ហេ បហូតជិវ្ហតាយ ចាតិ ។ អថខោ ភគវា តថារូបំ ឥទ្ធាភិសង្ខារំ អភិសង្ខារេសិ(១) យថា អទ្ទស អម្ពដ្ឋោ មាណវោ ភគវតោ កោសោហិតវត្ថគុយ្ហំ(២) ។ អថខោ ភគវា ជិវ្ហំ និន្នាមេត្វា ឧភោបិ កណ្ណសោតានិ អនុមសិ បដិមសិ ឧភោបិ នាសិកសោតានិ អនុមសិ បដិមសិ កេវលម្បិ នលាដមណ្ឌលំ ជិវ្ហាយ ឆាទេសិ ។

១ ឱ. អភិសង្ខាសិ ។ ម. អភិសង្ខាតិ ។ ២ ឱ. ម. កោសោហិតំ វត្ថគុយ្ហំ ។

ព្រះភាគដោយច្រើន វៀរលែងតែមហាបុរិសលក្ខណៈ ២ ប្រការ គឺវត្ថុ-គុយ្ហប្រទេសដែលស្រោបដោយស្រោម[1] ១ ព្រះជិវ្ហាល្មមល្វន់ល្វៃ[2] ១ ក៏មានសេចក្តីងឿងឆ្ងល់សង្ស័យ មិនស៊ប់ចិត្ត មិនជ្រះថ្លា ។ គ្រានោះ ព្រះមានព្រះភាគ មានសេចក្តីត្រិះរិះដូច្នេះថា អម្ពដ្ឋមាណពនេះ បានឃើញនូវមហាបុរិសលក្ខណៈ ៣២ ប្រការ របស់តថាគតដោយច្រើនហើយ វៀរលែងតែមហាបុរិសលក្ខណៈ ២ ប្រការ គឺវត្ថុគុយ្ហប្រទេស ដែលស្រោបដោយស្រោម ១ ព្រះជិវ្ហាល្មមល្វន់ល្វៃ ១ ក៏មានសេចក្តីងឿងឆ្ងល់សង្ស័យ មិនស៊ប់ចិត្ត មិនជ្រះថ្លា ។ អម្ពដ្ឋមាណពបានឃើញវត្ថុគុយ្ហប្រទេសដែលលិបចូលទៅក្នុងស្រោម របស់ព្រះមានព្រះភាគយ៉ាងណា លំដាប់នោះ ព្រះមានព្រះភាគក៏ទ្រង់និម្មិតនូវរូប ដែលសម្រេចដោយឫទ្ធិយ៉ាងនោះ ។ គ្រានោះ ព្រះមានព្រះភាគទ្រង់លៀននូវព្រះជិវ្ហា ហើយមូរស៊ក តាមរន្ធព្រះកាណ៌ទាំងពីរផង មូរស៊កតាមរន្ធព្រះនាសិកទាំងពីរផង បិទបាំងនូវមណ្ឌលនៃព្រះនលាដទាំងអស់ ដោយព្រះជិវ្ហាផង ។

---

១ អដ្ឋកថា ថា គុយ្ហប្រទេស របស់ព្រះមានព្រះភាគ ដូចជាអង្គជាតនៃគោ និងដំរី ដែលលិបចូល ឬបិទបាំងដោយស្រោម ស្រដៀងនឹងផ្ទៃនៃផ្កាឈូកមាស ។ ២ អណ្តាតពួកជនឯទៀត ក្រាស់ក៏មាន ស្តើងក៏មាន ខ្លីក៏មាន មិនស្មើក៏មាន ។ ឯព្រះជិវ្ហារបស់ព្រះមហាបុរសទន់ វែង ទាំងធំទូលាយ ប្រកបដោយសម្បុរ ។ ព្រះអង្គអាចមូរព្រះជិវ្ហានោះ ឲ្យស្រួចបាន ព្រោះព្រះជិវ្ហានោះទន់ ហើយស៊កចូលទៅដល់រន្ធព្រះនាសិក និងរន្ធព្រះកាណ៌ទាំងពីរបាន ព្រោះព្រះជិវ្ហារបស់ព្រះអង្គវែង អាចបិទបាំងនូវព្រះនលាដ ត្រឹមដើមព្រះកេសាបាន ព្រោះព្រះជិវ្ហាធំទូលាយ ។

(១៧១) អថខោ អម្ពដ្ឋស្ស មាណវស្ស ឯតទហោសិ សមន្នាគតោ ខោ សមណោ គោតមោ ទ្វត្តឹសមហាបុរិសលក្ខណេហិ បរិបុណ្ណេហិ នោ អបរិបុណ្ណេហីតិ ។ ភគវន្តំ ឯតទវោច ហន្ទ ចទានិ មយំ ភោ គោតម គច្ឆាម ពហុកិច្ចា មយំ ពហុករណីយាតិ ។ យស្សទានិ ត្វំ អម្ពដ្ឋ កាលំ មញ្ញសីតិ ។ អថខោ អម្ពដ្ឋោ មាណវោ វឡវារថមារុយ្ហ[១] បក្កាមិ ។

(១៧២) តេន ខោ បន សមយេន ព្រាហ្មណោ បោក្ខរសាតិ ឧដ្ឋាយ និក្ខមិត្វា មហតា ព្រាហ្មណគណេន សទ្ធឹ សកេ អារាមេ និសិន្នោ ហោតិ អម្ពដ្ឋំយេវ មាណវំ បដិមានេន្តោ ។ អថខោ អម្ពដ្ឋ មាណវោ យេន សកោ អារាមោ តេន បាយាសិ យាវតិកា យានស្ស ភូមិ យានេន គន្ត្វា យានា បច្ចោរោហិត្វា បត្តិកោវ យេន ព្រាហ្មណោ បោក្ខរសាតិ តេនុបសង្កមិ ឧបសង្កមិត្វា ព្រាហ្មណំ បោក្ខរសាតឹ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អម្ពដ្ឋំ មាណវំ ព្រាហ្មណោ

---

១ ឱ. ម. វឡភរថំ អារុយ្ហ ។

(១៧១) គ្រានោះ អម្ពដ្ឋមាណព មានសេចក្តីត្រិះរិះដូច្នេះថា ព្រះសមណគោតម ប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ គ្រប់គ្រាន់ មិនមែនមិនគ្រប់គ្រាន់ទេ ។ អម្ពដ្ឋមាណព បានក្រាបបង្គំទូលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន ណ្ហើយចុះ យើងជាអ្នកមានកិច្ចច្រើន យើងជាអ្នកមានការងារត្រូវធ្វើច្រើន សូមលាទៅក្នុងកាលឥឡូវនេះ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអម្ពដ្ឋ អ្នកសំគាល់មើលនូវកាលដ៏សមគួរ ក្នុងវេលានេះចុះ ។ លំដាប់នោះ អម្ពដ្ឋមាណព ក៏ឡើងជិះរថ ទឹមដោយសេះ បរចេញទៅ ។

(១៧២) សម័យនោះឯង បោក្ខរសាតិព្រាហ្មណ៍ ក្រោកឡើង ដើរចេញទៅ ជាមួយនឹងពួកព្រាហ្មណ៍ច្រើននាក់ ទៅអង្គុយក្នុងអារាមរបស់ខ្លួន រង់ចាំអម្ពដ្ឋមាណពនោះដែរ ។ គ្រានោះ អម្ពដ្ឋមាណព បររថសំដៅទៅរកអារាមរបស់ខ្លួន បរយានទៅទល់ត្រឹមទី ដែលល្មមឈប់យាន ហើយក៏ចុះអំពីយាន ដើរទៅដោយជើងទទេ ចូលសំដៅទៅរកបោក្ខរសាតិព្រាហ្មណ៍ លុះចូលទៅដល់ហើយ ក៏សំពះបោក្ខរសាតិព្រាហ្មណ៍ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះអម្ពដ្ឋមាណព អង្គុយក្នុងទីដ៏សមគួរស្រេចហើយ បោក្ខរសាតិព្រាហ្មណ៍ក៏បានពោលពាក្យនេះថា

ពោក្ខរសាតិ ឯតទវោច កច្ចិ តាត អម្ពដ្ឋ អទ្ទស តំ ភវន្តំ គោតមន្តិ ។ អទ្ទសាម ខោ មយំ ភោ តំ ភវន្តំ គោតមន្តិ ។ កច្ចិ តាត អម្ពដ្ឋ តំ ភវន្តំ គោតមំ តថាសន្តំយេវ សទ្ទោ អព្ភុគ្គតោ នោ អញ្ញថា កច្ចិ បន សោ ភវំ គោតមោ តាទិសោ នោ អញ្ញាទិសោតិ ។ តថាសន្តំយេវ ភោ តំ ភវន្តំ គោតមំ តថាសទ្ទោ អព្ភុគ្គតោ នោ អញ្ញថា តាទិសោ ច សោ ភវំ គោតមោ នោ អញ្ញាទិសោ សមន្នាគតោ ច សោ ភវំ គោតមោ ទ្វត្តឹសមហាបុរិសលក្ខណេហិ បរិបុណ្ណេហិ នោ អបរិបុណ្ណេហីតិ ។ អហុ បន តេ តាត អម្ពដ្ឋ សមណេន គោតមេន សទ្ធឹ កោចិទេវ កថាសល្លាបោតិ ។ អហុ ខោ មេ ភោ សមណេន គោតមេន សទ្ធឹ កោចិទេវ កថាសល្លាបោតិ ។ យថាកថំ បន តេ តាត អម្ពដ្ឋ អហុ សមណេន គោតមេន សទ្ធឹ កោចិទេវ កថាសល្លាបោតិ ។ អថខោ អម្ពដ្ឋោ មាណវោ

ម្នាលអម្ពដ្ឋ អ្នកបានឃើញព្រះគោតមដ៏ចំរើននោះដែរឬ ។ អម្ពដ្ឋមាណពឆ្លើយថា បពិត្រលោកដ៏ចំរើន យើងខ្ញុំបានឃើញព្រះគោតមដ៏ចំរើននោះហើយ ។ ពោក្ខរសាតិព្រាហ្មណ៍សួរថា ម្នាលអម្ពដ្ឋ កិត្តិសព្ទសសើរព្រះគោតមដ៏ចំរើននោះ ល្បីខ្ចរខ្ចាយមានដូច្នោះមែនឬ ឬមិនមែនដូច្នោះទេ ម្នាលអ្នកដ៏ចំរើន ចុះព្រះគោតមដ៏ចំរើននោះ ព្រះអង្គប្រាកដដូច្នោះមែន មិនមែនផ្សេងពីនោះទេឬ ។ អម្ពដ្ឋមាណពឆ្លើយថា បពិត្រលោកដ៏ចំរើន កិត្តិសព្ទសសើរព្រះគោតមដ៏ចំរើននោះ ល្បីខ្ចរខ្ចាយទៅមានដូច្នោះមែន មិនមែនជាយ៉ាងដទៃទេ បពិត្រលោកដ៏ចំរើន ព្រះគោតមដ៏ចំរើននោះ ព្រះអង្គប្រាកដដូច្នោះមែន មិនមែនផ្សេងពីនោះទេ បពិត្រលោកដ៏ចំរើន ព្រះគោតមដ៏ចំរើននោះ ប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ ដ៏បរិបូណ៌ មិនមែនមិនបរិបូណ៌ទេ ។ ពោក្ខរសាតិព្រាហ្មណ៍សួរថា ម្នាលអម្ពដ្ឋ ចុះអ្នកបាននិយាយចរចា ជាមួយនឹងព្រះសមណគោតមខ្លះដែរឬ ។ អម្ពដ្ឋមាណពឆ្លើយថា បពិត្រលោកដ៏ចំរើន ខ្ញុំបាននិយាយចរចា ជាមួយនឹងព្រះសមណគោតមខ្លះដែរ ។ ពោក្ខរសាតិព្រាហ្មណ៍សួរថា ម្នាលអម្ពដ្ឋ ចុះអ្នកនិយាយចរចា ជាមួយនឹងព្រះសមណគោតម ថាដូចម្តេចខ្លះ ។ លំដាប់នោះ អម្ពដ្ឋមាណពបាន

យាវតកោ(១) អហោសិ ភគវតា សទ្ធឹ កថាសល្លាបោ តំ សព្វំ ព្រាហ្មណស្ស បោក្ខរសាតិស្ស អារោចេសិ ។

(១៧៣) ឯវំ វុត្តេ ព្រាហ្មណោ បោក្ខរសាតិ អម្ពដ្ឋំ មាណវំ ឯតទវោច អហោ វត រេ អម្ហាកំ បណ្ឌិតក អហោ វត រេ អម្ហាកំ ពហុស្សុតក អហោ វត រេ អម្ហាកំ តេវិជ្ជក ឯវរូបេន កិរ ភោ បុរិសោ អត្ថ-ចរកេន កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យ យទេវ ខោ ត្វំ អម្ពដ្ឋ តំ ភវន្តំ គោតមំ ឯវំ អាសជ្ជ អាសជ្ជ អវចាសិ អថខោ(២) ភវំ គោតមោ អម្ហេបិ ឯវំ ឧបនេយ្យំ ឧបនេយ្យំ អវច អហោ វត រេ អម្ហាកំ បណ្ឌិតក អហោ វត រេ អម្ហាកំ ពហុស្សុតក អហោ វត រេ អម្ហាកំ តេវិជ្ជក ឯវរូបេន កិរ ភោ បុរិសោ អត្ថច-រកេន កាយស្ស ភេទា បរំ មរណា អបាយំ ទុគ្គតឹ វិនិបាតំ និរយំ ឧបបជ្ជេយ្យាតិ ។ កុបិតោ(៣) អនត្តម-នោ អម្ពដ្ឋំ មាណវំ បទសាយេវ បវត្តេសិ ឥច្ឆតិ ច

១ ម. យាវតិកោ ។ ២ ឱ. ឯត្ថន្តរេ សោតិ ទិស្សតិ ។ ៣ ឱ. សោ កុបិតោ ។

ដំណាលពាក្យដែលខ្លួនបានចរចា ជាមួយនឹងព្រះមានព្រះភាគ ប្រាប់បោក្ខរសាតិព្រាហ្មណ៍ ដោយសព្វគ្រប់ ។

(១៧៣) កាលដែលអម្ពដ្ឋមាណព ពោលយ៉ាងនេះហើយ បោក្ខរសាតិព្រាហ្មណ៍ ក៏ពោលពាក្យនេះ នឹងអម្ពដ្ឋមាណពថា ឱ អាចារ្យ អ្នកប្រាជ្ញយើង ឱ អាចារ្យ អ្នកពហុស្សូតយើង ឱ អាចារ្យ អ្នកត្រៃវិជ្ជាយើង នៃអ្នកដ៏ចំរើន បានឮថា ព្រោះតែការប្រព្រឹត្តនូវប្រយោជន៍ មានសភាពយ៉ាងនេះ បុរស លុះទំលាយរាងកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ ត្រូវចូលទៅកាន់តិរច្ឆាន ប្រេត អសុរកាយ នរក ម្នាលអម្ពដ្ឋ អ្នកបានពោលស្ទាក់ទទឹងណាស់ យ៉ាងនេះ នឹងព្រះគោតមដ៏ចំរើននោះ ដោយពាក្យណា ខណៈនោះ ព្រះគោតមដ៏ចំរើន ត្រូវរួបយកពាក្យនោះ មកនិយាយជាគ្រឿងប្រៀបធៀបនឹងពួកយើងយ៉ាងនោះ ៗ ឱ អាចារ្យ អ្នកប្រាជ្ញយើង ឱ អាចារ្យ អ្នកពហុស្សូតយើង ឱ អាចារ្យ អ្នកត្រៃវិជ្ជាយើង នៃអ្នកដ៏ចំរើន បានឮថា ព្រោះតែការប្រព្រឹត្តនូវប្រយោជន៍ មានសភាពយ៉ាងនេះ បុរស លុះទំលាយកាយ បន្ទាប់អំពីសេចក្ដីស្លាប់ទៅ ត្រូវចូលទៅកាន់តិរច្ឆាន ប្រេត អសុរកាយ នរក ។ បោក្ខរសាតិព្រាហ្មណ៍ ក៏ខឹងអាក់អន់ចិត្ត ធាក់អម្ពដ្ឋមាណពផ្ដួល រួចក៏ចង់ចូលទៅ

តាវទេវ ភគវន្តំ ទស្សនាយ ឧបសង្កមិតុំ ។ អថខោ តេ ព្រាហ្មណា ព្រាហ្មណំ ពោក្ខរសាតឹ ឯតទវោចុំ អតិវិកាលោ ខោ ភោ អជ្ជ សមណំ គោតមំ ទស្សនាយ ឧបសង្កមិតុំ ស្វេទានិ ភវំ ពោក្ខរសាតិ សមណំ គោតមំ ទស្សនាយ ឧបសង្កមិស្សតីតិ ។

(១៧៦) អថខោ ព្រាហ្មណោ ពោក្ខរសាតិ សកេ និវេសនេ បណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា យានេ អារោបេត្វា ឧក្កាសុ ធារិយមានាសុ ឧក្កដ្ឋាយ និយ្យាសិ យេន ឥច្ឆានង្គលវនសណ្ឌោ តេន បាយាសិ យាវតិកា យានស្ស ភូមិ យានេន គន្ត្វា យានា បច្ចោរោហិត្វា បត្តិកោវ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ព្រាហ្មណោ ពោក្ខរសាតិ ភគវន្តំ ឯតទវោច អាគមា នុ ខ្វិធ ភោ គោតម

គាល់ព្រះមានព្រះភាគ ក្នុងវេលាមួយរំពេចនោះ ។ គ្រានោះ ព្រាហ្មណ៍ទាំងនោះ បានពោលពាក្យនេះនឹងពោក្ខរសាតិព្រាហ្មណ៍ថា បពិត្រលោកដ៏ចំរើន ថ្ងៃនេះហួសកាល នឹងដើរទៅរកព្រះសមណគោតមហើយ ចាំព្រឹកស្អែកសិន សូមលោកពោក្ខរសាតិដ៏ចំរើន អញ្ជើញទៅជួបនឹងព្រះសមណគោតមចុះ ។

[១៧៤] លំដាប់នោះពោក្ខរសាតិព្រាហ្មណ៍ឲ្យគេចាត់ចែងខាទនីយៈ ភោជនីយាហារដ៏ផ្ចិតផ្ចង់ ក្នុងលំនៅរបស់ខ្លួន ហើយឲ្យលើកដាក់ក្នុងរទេះ មានមនុស្សកាន់គប់ភ្លើងនាំមុខ បរចេញអំពីឧក្កដ្ឋនគរ សំដៅទៅរកដងព្រៃឈ្មោះឥច្ឆានង្គលៈ បរយានទៅទល់ត្រឹមទី ដែលល្មមឈប់យានហើយ ក៏ចុះអំពីយាន ដើរទៅដោយជើងទទេ ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ហើយ ក៏ពោលពាក្យសំណេះសំណាល នឹងព្រះមានព្រះភាគ លុះបញ្ចប់ពាក្យសំណេះសំណាល នឹងពាក្យដែលគួររលឹកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ។ លុះពោក្ខរសាតិព្រាហ្មណ៍អង្គុយក្នុងទីដ៏សមគួរហើយ ក៏ពោលពាក្យនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះគោតម

អម្ហាកំ អន្តេវាសី អម្ពដ្ឋោ មាណវកោតិ ។ អាគមា ខោ តេធ ព្រាហ្មណ អន្តេវាសី អម្ពដ្ឋោ មាណវកោតិ ។ អហុ បន តេ ភោ គោតម អម្ពដ្ឋេន មាណវេន សទ្ធឹ កោចិទេវ កថាសល្លាបោតិ ។ អហុ ខោ មេ ព្រាហ្មណ អម្ពដ្ឋេន មាណវេន សទ្ធឹ កោចិទេវ កថាសល្លាបោតិ ។ យថាកថំ បន តេ ភោ គោតម អហុ អម្ពដ្ឋេន មាណវេន សទ្ធឹ កោចិទេវ កថា-សល្លាបោតិ ។ អថខោ ភគវា យាវតកោ អហោសិ អម្ពដ្ឋេន មាណវេន សទ្ធឹ កថាសល្លាបោ តំ សព្វំ ព្រាហ្មណស្ស បោក្ខរសាតិស្ស អារោចេសិ ។

(១៧៤) ឯវំ វុត្តេ ព្រាហ្មណោ បោក្ខរសាតិ ភគវន្ត-មេតទវោច ពាលោ ភោ គោតម អម្ពដ្ឋោ មាណវោ ខមតុ ភវំ គោតមោ អម្ពដ្ឋស្ស មាណវស្សាតិ ។ សុខី ហោតុ ព្រាហ្មណ អម្ពដ្ឋោ មាណវកោតិ ។ អថខោ

ដ៏ចំរើន អម្ពដ្ឋមាណពជាកូនសិស្សរបស់ខ្ញុំ បានមកកាន់ទីនេះដែរឬ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ អម្ពដ្ឋមាណព ជាកូនសិស្សរបស់អ្នកបានមកកាន់ទីនេះដែរ ។ បោក្ខរសាតិព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចំរើន ចុះព្រះអង្គបានពោលចរចាពាក្យណាមួយ ជាមួយនឹងអម្ពដ្ឋមាណពដែរឬ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ តថាគតបានពោលចរចាពាក្យទីមួយ នឹងមាណពខ្លះដែរ ។ បោក្ខរសាតិព្រាហ្មណ៍ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចំរើន ពាក្យទីមួយដែលព្រះអង្គបានពោលចរចា ជាមួយនឹងអម្ពដ្ឋមាណពនោះ តើដូចម្ដេចខ្លះ ។ លំដាប់នោះ ព្រះមានព្រះភាគ ក៏បានប្រាប់ពាក្យដែលបានពោលចរចា ជាមួយនឹងអម្ពដ្ឋមាណពទាំងអម្បាលនោះ ដល់បោក្ខរសាតិព្រាហ្មណ៍ដោយសព្វគ្រប់ ។

(១៧៥) កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ទើបបោក្ខរសាតិព្រាហ្មណ៍ពោលពាក្យយ៉ាងនេះ នឹងព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន អម្ពដ្ឋមាណពជាមនុស្សល្ងង់ សូមព្រះគោតមដ៏ចំរើនអត់ទោស ដល់អម្ពដ្ឋមាណពផងចុះ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ សូមឲ្យអម្ពដ្ឋមាណព មានសេចក្ដីសុខចុះ ។ លំដាប់នោះ

ព្រាហ្មណោ បោក្ខរសាតិ ភគវតោ កាយេ ទ្វត្តឹសមហាបុរិសលក្ខណានិ សមន្នេសិ ៗ អទ្ទសា ខោ ព្រាហ្មណោ បោក្ខរសាតិ ភគវតោ កាយេ ទ្វត្តឹសមហាបុរិសលក្ខណានិ យេភុយ្យេន ឋបេត្វា ទ្វេ ទ្វីសុ មហាបុរិសលក្ខណេសុ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ កោសោហិតេ ច វត្ថគុយ្ហេ បហូតជិវ្ហតាយ ច ៗ អថខោ ភគវតោ ឯតទហោសិ បស្សតិ ខោ មេ អយំ ព្រាហ្មណោ បោក្ខរសាតិ ទ្វត្តឹសមហាបុរិសលក្ខណានិ យេភុយ្យេន ឋបេត្វា ទ្វេ ទ្វីសុ មហាបុរិសលក្ខណេសុ កង្ខតិ វិចិកិច្ឆតិ នាធិមុច្ចតិ ន សម្បសីទតិ កោសោហិតេ ច វត្ថគុយ្ហេ បហូតជិវ្ហតាយ ចាតិ ៗ អថខោ ភគវា តថារូបំ ឥទ្ធាភិសង្ខារំ អភិសង្ខាសិ យថា អទ្ទស ព្រាហ្មណោ បោក្ខរសាតិ ភគវតោ កោសោហិតំ វត្ថគុយ្ហំ ៗ អថខោ ភគវា ជិវ្ហំ និន្នាមេត្វា ឧភោបិ កណ្ណសោតានិ អនុមសិ បដិមសិ ឧភោ នាសិកសោតានិ អនុមសិ បដិមសិ កេវលម្បិ នលាដមណ្ឌលំ ជិវ្ហាយ ឆាទេសិ ៗ

អម្ពដ្ឋសូត្រ រឿងព្រាហ្មណ៍ឈ្មោះពោក្ខរសាតិ

ពោក្ខរសាតិព្រាហ្មណ៍ បានសង្កេតមើល នូវមហាបុរិសលក្ខណៈ ៣២ ប្រការ ក្នុងព្រះកាយរបស់ព្រះមានព្រះភាគ ៗ ពោក្ខរសាតិព្រាហ្មណ៍ ក៏បានឃើញមហាបុរិសលក្ខណៈ ៣២ ប្រការ ក្នុងព្រះកាយរបស់ព្រះមានព្រះភាគដោយច្រើនហើយ វៀរលែងតែមហាបុរិសលក្ខណៈ ២ ប្រការ គឺវត្ថគុយ្ហប្រទេស ដែលស្រោបដោយស្រោម ១ ព្រះជិវ្ហាល្មមល្វន់ល្វៃ ១ ក៏មានសេចក្តីងឿងឆ្ងល់សង្ស័យ មិនស៊ប់ចិត្ត មិនជ្រះថ្លា ៗ គ្រានោះ ព្រះមានព្រះភាគមានសេចក្តីត្រិះរិះដូច្នេះថា ពោក្ខរសាតិព្រាហ្មណ៍នេះ បានឃើញមហាបុរិសលក្ខណៈ ៣២ ប្រការ របស់តថាគតដោយច្រើនហើយ វៀរលែងតែមហាបុរិសលក្ខណៈ ២ ប្រការ គឺវត្ថគុយ្ហប្រទេសដែលស្រោបដោយស្រោម ១ ជិវ្ហាល្មមល្វន់ល្វៃ ១ ក៏មានសេចក្តីងឿងឆ្ងល់សង្ស័យ មិនស៊ប់ចិត្ត មិនជ្រះថ្លា ៗ ពោក្ខរសាតិព្រាហ្មណ៍បានឃើញនូវវត្ថគុយ្ហប្រទេស ដែលស្រោបដោយស្រោម របស់ព្រះមានព្រះភាគ យ៉ាងណា លុំដាប់នោះ ព្រះមានព្រះភាគ ក៏ទ្រង់និម្មិតនូវរូបដែលសម្រេចដោយឫទ្ធិ យ៉ាងនោះឯង ៗ គ្រានោះ ព្រះមានព្រះភាគ ទ្រង់លៀននូវព្រះជិវ្ហា ហើយមូសឹកចូលតាមរន្ធព្រះកាណ៌ទាំងពីរ មូសឹកចូលតាមរន្ធព្រះនាសិកទាំងពីរ ទាំងបិទបាំងនូវមណ្ឌលនៃព្រះនលាដទាំងអស់ ដោយព្រះជិវ្ហា ៗ

អថខោ ព្រាហ្មណស្ស បោក្ខរសាតិស្ស ឯតទហោសិ សមន្នាគតោ ខោ សមណោ គោតមោ ទ្វត្តិំសមហាបុរិសលក្ខណេហិ បរិបុណ្ណេហិ នោ អបរិបុណ្ណេហីតិ ។ ភគវន្តំ ឯតទវោច អធិវាសេតុ មេ ភវំ គោតមោ អជ្ជតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ ព្រាហ្មណោ បោក្ខរសាតិ ភគវតោ អធិវាសនំ វិទិត្វា ភគវតោ កាលំ អារោចេសិ កាលោ ភោ គោតម និដ្ឋិតំ ភត្តន្តិ ។

(១៧៦) អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សទ្ធឹ ភិក្ខុសង្ឃេន យេន ព្រាហ្មណស្ស បោក្ខរសាតិស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ ព្រាហ្មណោ បោក្ខរសាតិ ភគវន្តំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសិ សម្បវារេសិ មាណវកាបិ ភិក្ខុសង្ឃំ ។ អថខោ ព្រាហ្មណោ បោក្ខរសាតិ ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ

លំដាប់នោះ បោក្ខរសាតិព្រាហ្មណ៍ មានសេចក្តីត្រិះរិះដូច្នេះថា ព្រះសមណគោតមប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ ដ៏បរិបូណ៌មែន មិនមែនខ្វះខាតទេ ។ គាត់ក៏ពោលពាក្យនេះនឹងព្រះមានព្រះភាគថា សូមព្រះគោតមដ៏ចំរើន ព្រមទាំងភិក្ខុសង្ឃ ទទួលភត្តរបស់ខ្ញុំព្រះអង្គ ដើម្បីឆាន់ក្នុងថ្ងៃនេះ ។ ព្រះមានព្រះភាគ ទ្រង់ទទួលដោយតុណ្ហីភាព ។ កាលបើបោក្ខរសាតិព្រាហ្មណ៍ បានដឹងថា ព្រះមានព្រះភាគ ទទួលនិមន្តហើយ ក៏បង្គាប់ឲ្យគេក្រាបបង្គំទូលភត្តកាល ចំពោះព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន កាលដល់ហើយ ភត្តក៏សម្រេចហើយ ។

(១៧៦) វេលានោះ ក្នុងបុព្វណ្ហសម័យ ព្រះមានព្រះភាគ ទ្រង់ស្បង់ ប្រដាប់បាត្រនិងចីវរ ស្តេចចូលទៅកាន់លំនៅនៃបោក្ខរសាតិព្រាហ្មណ៍ ព្រមដោយព្រះភិក្ខុសង្ឃ លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈ ដែលគេក្រាលថ្វាយ ។ កាលនោះបោក្ខរសាតិព្រាហ្មណ៍ បានអង្គាសព្រះមានព្រះភាគ ដោយខាទនីយភោជនីយាហារដ៏ផ្ចិតផ្ចង់ ដោយដៃខ្លួនឯង ឲ្យឆ្អែតស្កប់ស្កល់ ចំណែកពួកមាណព ក៏អង្គាសភិក្ខុសង្ឃឲ្យឆ្អែតស្កប់ស្កល់ ។ កាលបើបោក្ខរសាតិព្រាហ្មណ៍ ដឹងថា ព្រះមានព្រះភាគ សោយរួចហើយ លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏កាន់យក

អម្ពដ្ឋសុត្តេ អនុបុព្វីកថា ធម្មចក្ខុ

អញ្ញតរំ នីចំ អាសនំ គហេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នស្ស ខោ ព្រាហ្មណស្ស បោក្ខរសាតិស្ស ភគវា អនុបុព្វីកថំ កថេសិ សេយ្យថីទំ ទានកថំ សីលកថំ សគ្គកថំ កាមានំ អាទីនវំ ឱការំ សង្កិលេសំ នេក្ខម្មេ អានិសំសំ បកាសេសិ ។ យទា ភគវា អញ្ញាសិ ព្រាហ្មណំ បោក្ខរសាតឹ កល្លចិត្តំ មុទុចិត្តំ វិនីវរណចិត្តំ ឧទគ្គចិត្តំ បសន្នចិត្តំ អថស្ស យា ពុទ្ធានំ សាមុក្កំសិកា ធម្មទេសនា តំ បកាសេសិ ទុក្ខំ សមុទយំ និរោធំ មគ្គំ ។ សេយ្យថាបិ នាម សុទ្ធំ វត្ថំ អបគតកាឡកំ សម្មទេវ រជនំ បដិគ្គណ្ហេយ្យ ឯវមេវ ខោ[១] ព្រាហ្មណស្ស បោក្ខរសាតិស្ស តស្មឹយេវ អាសនេ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យំ កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ។

១ ឱ. ម. ខោសទ្ទោ ន ទិស្សតិ ។

អាសនៈមួយទាបជាង អង្គុយគង់ទីដ៏សមគួរ ។ ព្រះមានព្រះភាគបាន ទ្រង់សំដែង នូវអនុបុព្វីកថា ចំពោះបោក្ខរសាតិព្រាហ្មណ៍ ដែលអង្គុយគង់ទីដ៏សមគួរ អនុបុព្វីកថានោះ តើដូចម្តេច គឺព្រះអង្គប្រកាសនូវទានកថា ១ សីលកថា ១ សគ្គកថា ១ កាមាទីនវកថា ដ៏លាមក អាក្រក់ សៅហ្មង ១ នេក្ខម្មានិសង្សកថា ១ ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបថា បោក្ខរសាតិព្រាហ្មណ៍ មានចិត្តស្រួល មានចិត្តទន់ មានចិត្តប្រាសចាកនីវរណធម៌ មានចិត្តរីករាយ មានចិត្តជ្រះថ្លាក្នុងកាលណា ព្រះអង្គក៏ទ្រង់ប្រកាសព្រះធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយ ទ្រង់លើកឡើងសំដែងដោយព្រះអង្គឯង គឺទុក្ខសច្ច ១ សមុទយសច្ច ១ និរោធសច្ច ១ មគ្គសច្ច ១ ដល់បោក្ខរសាតិព្រាហ្មណ៍នោះ ក្នុងកាលនោះ ។ សំពត់ដ៏ស្អាតប្រាសចាកពណ៌ខ្មៅ គួរទទួលនូវគ្រឿងជ្រលក់ដោយល្អ យ៉ាងណាមិញ ធម្មចក្ខុ គឺសោតាបត្តិមគ្គ ដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើង ដល់បោក្ខរសាតិព្រាហ្មណ៍ លើអាសនៈនោះឯងថា ធម្មជាតណានីមួយដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះ រមែងរលត់ទៅវិញជាធម្មតា មានឧបមេយ្យដូច្នោះឯង ។

(១៧៧) អថខោ ព្រាហ្មណោ បោក្ខរសាតិ ទិដ្ឋ-
ធម្មោ បត្តធម្មោ វិទិតធម្មោ បរិយោគាឡ្ហធម្មោ តិណ្ណវិ-
ចិកិច្ឆោ វិគតកថំកថោ វេសារជ្ជប្បត្តោ អបរប្បច្ចយោ
សត្ថុ សាសនេ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម
អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ
វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អា-
ចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុ-
មន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ ភោតា គោតមេន
អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភោ
គោតម សបុត្តោ សភរិយោ សបរិសោ សាមច្ចោ
ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច
ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ
បាណុបេតំ សរណំ គតំ យថា ច ភវំ គោតមោ

(១៧៧) គ្រានោះ បោក្ខរសាតិព្រាហ្មណ៍ ឃើញអរិយសច្ចធម៌ច្បាស់ហើយ បានដល់អរិយសច្ចធម៌ហើយ បានដឹងច្បាស់អរិយសច្ចធម៌ហើយ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ហើយ ឆ្លងផុតសេចក្តីសង្ស័យ មិនមានសេចក្តីងឿងឆ្ងល់ ដល់នូវសេចក្តីក្លៀវក្លា មិនបាច់មានអ្នកដទៃដឹកនាំក្នុងពាក្យប្រៀនប្រដៅ របស់ព្រះសាស្តា ទើបក្រាបបង្គំទូលព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចំ-រើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចំរើន ធម៌ដែលព្រះគោតមដ៏ចំរើនទ្រង់ប្រកាសដោយអនេកបរិយាយនេះឯង ប្រៀបដូចជាបុគ្គលបើករបស់ដែលផ្កាប់ឲ្យផ្ងារឡើង ឬដូចគេបើកបង្ហាញរបស់ដែលគេបិទបាំងទុក ឬដូចជាគេប្រាប់ផ្លូវដល់អ្នកវង្វេងផ្លូវ ពុំនោះសោត ដូចជាគេទ្រោលប្រទីបក្នុងទីងងឹតដោយគិតថា មនុស្សដែលមានភ្នែក (ភ្លឺ) នឹងមើលឃើញនូវរូបទាំងឡាយបាន បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គព្រមទាំងបុត្រភរិយានឹងបរិសទ្យ ព្រមទាំងអាមាត្យ សូមដល់នូវព្រះគោតមដ៏ចំរើនផង នូវព្រះធម៌ផង នូវព្រះភិក្ខុសង្ឃផង ជាសរណៈ សូមព្រះគោតមដ៏ចំរើន ចាំទុកនូវខ្ញុំព្រះអង្គ ថាជាឧបាសកអ្នកដល់នូវព្រះរតនត្រ័យជាសរណៈស្មើដោយជីវិត តាំងពីថ្ងៃនេះជាដើមរៀងទៅ ម្យ៉ាងទៀត (បើ) ព្រះគោតមដ៏ចំរើន

ឧក្កដ្ឋាយំ អញ្ញានំ ឧបាសកកុលានំ ឧបសង្កមតិ ឯវមេវ ខោ ភវំ គោតមោ បោក្ខរសាតិកុលំ ឧប-សង្កមតុ តត្ថ យេ តេ មាណវកា វា មាណវិកា វា ភវន្តំ គោតមំ អភិវាទេស្សន្តិ វា បច្ចុដ្ឋិស្សន្តិ វា អាសនំ វា ឧទកំ វា ទស្សន្តិ ចិត្តំ វា បសាទេស្សន្តិ តេសំ តំ ភវិស្សតិ ទីឃរត្តំ ហិតាយ សុខាយាតិ ។ កល្យាណំ វុច្ចតិ ព្រាហ្មណាតិ ។

អម្ពដ្ឋសុត្តំ និដ្ឋិតំ តតិយំ ។

ស្តេចចូលទៅរកត្រកូលឧបាសកឯទៀត ក្នុងឧក្កដ្ឋនគរយ៉ាងណា សូមព្រះគោតមដ៏ចំរើន ចូលមករកត្រកូលពោក្ខរសាតិ ក៏យ៉ាងនោះដែរ នឹងបានពួកមនុស្សកំលោះក្រមុំណា ក្នុងត្រកូលនោះៗ ក្រាបថ្វាយបង្គំ ក្រោកទទួល ឬថ្វាយអាសនៈ ឬទឹក ឬធ្វើចិត្តជ្រះថ្លាចំពោះព្រះគោតមដ៏ចំរើន កិច្ចមានការថ្វាយបង្គំជាដើមនោះ គង់ជាប្រយោជន៍ និងសេចក្តីសុខ ដល់ពួកជនកំលោះក្រមុំទាំងនោះ អស់កាលជាអង្វែង ។ ព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពាក្យដែលអ្នកនិយាយ(មកនេះ)ពីរោះហើយ ។

ចប់ អម្ពដ្ឋសូត្រ ទី ៣ ។

# សោណទណ្ឌសុត្តំ ចតុត្ថំ

(១៧៨) ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា អង្គេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ យេន ចម្បា តទវសរិ ។ តត្រ សុទំ ភគវា ចម្បាយំ វិហរតិ គគ្គរាយ បោក្ខរណិយា តីរេ ។

(១៧៩) តេន ខោ បន សមយេន សោណទណ្ឌោ ព្រាហ្មណោ ចម្បំ អជ្ឈាវសតិ សត្តុស្សទំ សតិណកដ្ឋោទកំ សធញ្ញំ រាជភោគ្គំ រញ្ញា មាគធេន សេនិយេន ពិម្ពិសារេន ទិន្នំ រាជទាយំ ព្រហ្មទេយ្យំ ។ អស្សោសុំ ខោ ចម្បេយ្យកា ព្រាហ្មណគហបតិកា សមណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ អង្គេសុ ចារិកញ្ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ បញ្ចមត្តេហិ ភិក្ខុសតេហិ ចម្បំ

# សោណទណ្ឌសូត្រ ទី ៤

(១៧៨) (សូត្រនេះ) ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ក្នុងអង្គជនបទ ព្រមដោយភិក្ខុសង្ឃច្រើន ចំនួន ៥០០ រូប បានស្តេចទៅដល់ក្រុងចម្បា[1] ។ ព្រះមានព្រះភាគ ទ្រង់គង់ទៀបឆ្នេរនៃស្រះបោក្ខរណី ឈ្មោះគគ្គរា[2] ជិតក្រុងចម្បានោះ ។

(១៧៩) សម័យនោះឯង សោណទណ្ឌព្រាហ្មណ៍អាស្រ័យនៅក្នុងក្រុងចម្បា ដែលជាក្រុងកុះករ ដោយមនុស្សសត្វ បរិបូណ៌ដោយស្មៅ ឈើ និងទឹក ព្រមទាំងធញ្ញជាតិ ជាព្រះរាជទ្រព្យដែលព្រះបាទមាគធៈសេនិយពិម្ពិសារ ទ្រង់ប្រទាន ជារាជរង្វាន់ដ៏ប្រសើរ ។ ព្រាហ្មណ៍និងគហបតីទាំងឡាយអ្នកក្រុងចម្បា បានឮថា ព្រះសមណគោតម ជាសក្យបុត្រ ចេញចាកសក្យត្រកូលទៅទ្រង់ព្រះផ្នួសហើយ ទ្រង់ពុទ្ធដំណើរមកកាន់ចារិកក្នុងដែនអង្គៈ ព្រមដោយភិក្ខុសង្ឃច្រើន ចំនួន៥០០រូប ទ្រង់ពុទ្ធ-

---

១ ដីកាពន្យល់ថា នគរនោះបានជាឈ្មោះដូច្នោះ ព្រោះមានដើមចម្បាដុះជាច្រើន តាំងពីកាលដែលសាងនគរនោះមក ។ ២ អដ្ឋកថាពន្យល់ថា ស្រះនោះបានជាឈ្មោះដូច្នោះ ព្រោះព្រះរាជមហេសីព្រះនាម គគ្គរា ឲ្យជីកជិតក្រុងចម្បានោះ ទៅជុំវិញឆ្នេរស្រះនោះមានព្រៃចម្បាធំធំ ប្រួងាប់ដោយដើមឈើមានផ្កា៥ពណ៌ មានពណ៌ខៀវជាដើម ។

អនុប្បត្តោ ចម្បាយំ វិហរតិ គគ្គរាយ បោក្ខរណិយា
តីរេ តំ ខោ បន ភវន្តំ គោតមំ ឯវំកល្យាណោ
កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ
សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោក-
វិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ
ពុទ្ធោ ភគវាតិ សោ ឥមំ លោកំ សទេវកំ សមារកំ
សព្រហ្មកំ សស្សមណព្រាហ្មណឹ បជំ សទេវមនុស្សំ
សយំ អភិញ្ញា សច្ឆិកត្វា បវេទេតិ សោ ធម្មំ ទេសេ-
តិ អាទិកល្យាណំ មជ្ឈេកល្យាណំ បរិយោសាន-
កល្យាណំ សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ
ព្រហ្មចរិយំ បកាសេតិ សាធុ ខោ បន តថារូបានំ
អរហតំ ទស្សនំ ហោតីតិ ។ អថខោ ចម្បេយ្យកា

ដំណើរ មកដល់ក្រុងចម្បាហើយ គង់នៅទៀបឆ្នេរស្រះពោក្ខរណីឈ្មោះ គគ្គរា ជិតក្រុងចម្បា កិត្តិសព្ទដ៏ពីរោះសរសើរព្រះគោតមដ៏ចំរើននោះ ឮខ្ចរខ្ចាយសុសសាយយ៉ាងនេះថា ព្រះមានព្រះភាគនោះ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈគឺសេចក្តីចេះដឹងនិងកិរិយាដែលបុគ្គលគប្បីប្រព្រឹត្ត ព្រះអង្គមានដំណើរល្អទៅកាន់ព្រះនិព្វាន ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាសារថីអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀត ព្រះអង្គបានត្រាស់ដឹង បានធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វានចំពោះព្រះអង្គ ហើយញុំាងលោកនេះព្រមទាំងទេវលោក មារលោក ព្រហ្មលោក ញុំាងប្រជាជន ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេសឲ្យបានត្រាស់ដឹងផង ទ្រង់សំដែងធម៌មានលំអបទដើម បទកណ្តាល និងបទចុង ទ្រង់ប្រកាសនូវព្រហ្មចរិយធម៌ព្រមទាំងអត្ថទាំងព្យញ្ជនៈដ៏ពេញបរិបូណ៌បរិសុទ្ធទាំងអស់ ក៏ដំណើរដែលបានឃើញ បានជួបប្រទះព្រះអរហន្តទាំងឡាយ មានសភាពដូច្នោះ ជាការប្រពៃណាស់ ។ គ្រានោះ

ព្រាហ្មណគហបតិកា ចម្បាយ និក្ខមិត្វា សង្ឃាសង្ឃីគណីភូតា យេន គគ្គរា បោក្ខរណី តេនុបសង្កមន្តិ ។

(១៨០) តេន ខោ បន សមយេន សោណទណ្ឌោ ព្រាហ្មណោ ឧបរិបាសាទេ ទិវាសេយ្យំ ឧបគតោ ហោតិ ។ អទ្ទសា ខោ សោណទណ្ឌោ ព្រាហ្មណោ ចម្បេយ្យកេ ព្រាហ្មណគហបតិកេ ចម្បាយ និក្ខមិត្វា សង្ឃាសង្ឃីគណីភូតេ យេន គគ្គរា បោក្ខរណី តេនុបសង្កមន្តេ ទិស្វា ខត្តំ អាមន្តេសិ កិំ នុ ខោ ភោ ខត្តេ ចម្បេយ្យកា ព្រាហ្មណគហបតិកា ចម្បាយ និក្ខមិត្វា សង្ឃាសង្ឃីគណីភូតា យេន គគ្គរា បោក្ខរណី តេនុបសង្កមន្តីតិ ។ អត្ថិ ខោ ភោ សមណោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ អង្គេសុ ចារិកំ ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ

ពួកព្រាហ្មណ៍និងគហបតីអ្នកក្រុងចម្បា នាំគ្នាចេញពីក្រុងចម្បា ជាពួកជាកង ដើរត្រសងចូលសំដៅទៅត្រង់ស្រះបោក្ខរណី ឈ្មោះគគ្គរានោះ ៗ

(១៨០) សម័យនោះឯង សោណទណ្ឌព្រាហ្មណ៍ ចូលទៅកាន់ដំណេកក្នុងវេលាថ្ងៃ ក្នុងប្រាសាទជាន់ខាងលើ ៗ សោណទណ្ឌព្រាហ្មណ៍បានឃើញពួកព្រាហ្មណ៍គហបតី អ្នកក្រុងចម្បា ចេញអំពីក្រុងចម្បា ជាពួកជាកង ដើរត្រសងចូលសំដៅទៅត្រង់ស្រះបោក្ខរណីឈ្មោះ គគ្គរា លុះឃើញហើយ ទើបហៅខត្តមហាមាត្យ(១)មកសួរថា នែខត្តៈដ៏ចំរើន ដូចម្តេចហ្ន៎ ក៏បានជាពួកព្រាហ្មណ៍គហបតីអ្នកក្រុងចម្បា ចេញអំពីក្រុងចម្បា ជាពួកជាកង ដើរត្រសងចូលសំដៅទៅត្រង់ស្រះបោក្ខរណីឈ្មោះគគ្គរា ៗ ខត្តមហាមាត្យឆ្លើយថា បពិត្រលោកដ៏ចំរើន ដ្បិតព្រះសមណគោតមជាសក្យបុត្រ ទ្រង់ចេញចាកសក្យត្រកូលទៅទ្រង់ព្រះផ្នួស ហើយទ្រង់ពុទ្ធដំណើរទៅកាន់ចារិកក្នុងដែនអង្គៈ ព្រមដោយភិក្ខុសង្ឃច្រើនចំនួន

---

១ អដ្ឋកថាពន្យល់ថា អាមាត្យនេះជាអាមាត្យធំ អាចដោះសា អាចឆ្លើយប្រស្នា ដែលសោណទណ្ឌព្រាហ្មណ៍សួរបាន ។ ដីកាពន្យល់ថា បុរសណាដែលជាអ្នកប្រាជ្ញក្នុងអាជ្ញារបស់ឥស្សរជនទាំងឡាយមានស្តេចទ្រង់រាជ្យ និងស្តេចដែលមិនបានអភិសេកជាដើម ជាអ្នករក្សាអង្គនៃឥស្សរជនទាំងនោះ បុរសនោះហៅថា ខត្តៈ ។ បុរសនោះបើឥស្សរជន មានការប្រើឲ្យទៅទីណា ៗ បេះការពារទោស របស់ឥស្សរជនទាំងនោះ ក្នុងទីនោះ ៗ ។ (ហៅវិថាអមាត្យខួណៈផ្នួង) ។

បញ្ចមត្តេហិ ភិក្ខុសតេហិ ចម្បំ អនុប្បត្តោ ចម្បាយំ វិហរតិ គគ្គរាយ បោក្ខរណិយា តីរេ តំ ខោ បន ភវន្តំ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណ-សម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្ម-សារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ តមេតេ ភវន្តំ គោតមំ ទស្សនាយ ឧបសង្កមន្តិ ។ តេនហិ ភោ ខត្តេ យេន ចម្បេយ្យកា ព្រាហ្មណគហបតិកា តេនុ-បសង្កម ឧបសង្កមិត្វា ចម្បេយ្យកេ ព្រាហ្មណគហ-បតិកេ ឯវំ វទេហិ សោណទណ្ឌោ ភោ(១) ព្រាហ្ម-ណោ ឯវមាហ អាគមេន្តុ កិរ ភវន្តោ សោណទណ្ឌោបិ ព្រាហ្មណោ សមណំ គោតមំ ទស្សនាយ ឧបសង្ក-

---

១ ឱ. ភោសទ្ទោ ន ទិស្សតិ ។

ប្រាំរយរូប ឥឡូវទ្រង់ពុទ្ធដំណើរ មកដល់ក្រុងចម្បាហើយ ព្រះអង្គគង់សម្រាន្តព្រះឥរិយាបថនៅក្បែរឆ្នេរស្រះបោក្ខរណី ឈ្មោះគគ្គរា ជិតក្រុងចម្បា កិត្តិសព្ទដ៏ពីរោះសរសើរព្រះគោតមដ៏ចំរើននោះ ឮខ្ចរខ្ចាយសុសសាយយ៉ាងនេះថា ព្រះមានព្រះភាគនោះ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ គឺសេចក្តីចេះដឹងនឹងក្រឹត្យដែលបុគ្គលគប្បីប្រព្រឹត្ត ព្រះអង្គមានដំណើរល្អទៅកាន់ព្រះនិព្វាន ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណរកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាសារថីអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងវិលមកកាន់ភពថ្មីទៀត ពួកព្រាហ្មណ៍គហបតីទាំងនោះ ក៏នាំគ្នាទៅគាល់ព្រះគោតមដ៏ចំរើនអង្គនោះ ។ សោណទណ្ឌព្រាហ្មណ៍ ប្រើខត្តមហាមាត្យថា នែខត្តៈដ៏ចំរើន បើដូច្នោះអ្នកចូលទៅរកពួកព្រាហ្មណ៍គហបតីអ្នកក្រុងចម្បា លុះចូលទៅដល់ហើយ ប្រាប់ពួកព្រាហ្មណ៍និងគហបតីអ្នកក្រុងចម្បា យ៉ាងនេះថា នែអ្នកទាំងឡាយដ៏ចំរើន សោណទណ្ឌព្រាហ្មណ៍និយាយយ៉ាងនេះថា ឲ្យពួកអ្នកដ៏ចំរើនបង្អង់ចាំមួយរំពេចសិន ដ្បិតសោណទណ្ឌព្រាហ្មណ៍នឹងចូលទៅគាល់ព្រះ

មិស្សតីតិ ។ ឯវំ ភោតិ ខោ សោ ខត្តា សោណទណ្ឌស្ស ព្រាហ្មណស្ស បដិស្សុត្វា យេន ចម្បេយ្យកា ព្រាហ្មណគហបតិកា តេនុបសង្កមិ ឧបសង្កមិត្វា ចម្បេយ្យកេ ព្រាហ្មណគហបតិកេ ឯតទវោច សោណទណ្ឌោ ភោ ព្រាហ្មណោ ឯវមាហ អាគមេន្តុ កិរ ភវន្តោ សោណទណ្ឌោបិ ព្រាហ្មណោ សមណំ គោតមំ ទស្សនាយ ឧបសង្កមិស្សតីតិ ។

(១៨១) តេន ខោ បន សមយេន នានាវេរជ្ជកានំ ព្រាហ្មណានំ បញ្ចមត្តានិ ព្រាហ្មណសតានិ ចម្បាយំ បដិវសន្តិ កេនចិទេវ ករណីយេន ។ អស្សោសុំ ខោ តេ ព្រាហ្មណា សោណទណ្ឌោ ព្រាហ្មណោ សមណំ គោតមំ ទស្សនាយ ឧបសង្កមិស្សតីតិ ។ អថខោ តេ ព្រាហ្មណា យេន សោណទណ្ឌោ ព្រាហ្មណោ តេនុបសង្កមឹសុ ឧបសង្កមិត្វា សោណទណ្ឌំ ព្រាហ្មណំ ឯតទវោចុំ សច្ចំ កិរ ភវំ សោណទណ្ឌោ សមណំ គោតមំ ទស្សនាយ ឧបសង្កមិស្សតីតិ ។

សមណគោតមដែរ ។ ខត្តមហាមាត្យនោះក៏ទទួលពាក្យរបស់សោណ-ទណ្ឌព្រាហ្មណ៍ថា បពិត្រលោកដ៏ចំរើន យ៉ាងហ្នឹងហើយ រួចក៏ចូលសំដៅទៅ ត្រង់ទីដែលពួកព្រាហ្មណ៍និងគហបតីអ្នកក្រុងចម្បានៅ លុះចូលទៅដល់ហើយ ក៏បានសាកសួរដំណើរនុ៎ះ ចំពោះពួកព្រាហ្មណ៍ និងគហបតីអ្នកក្រុងចម្បាថា នែអ្នកទាំងឡាយដ៏ចំរើន សោណទណ្ឌព្រាហ្មណ៍និយាយយ៉ាងនេះថា ឲ្យពួកអ្នកដ៏ចំរើន បង្អង់ចាំមួយរំពេចសិន ដ្បិតសោណទណ្ឌព្រាហ្មណ៍ នឹងចូលទៅគាល់ព្រះសមណគោតមដែរ ។

(១៨១) ជួនជាសម័យនោះឯង ព្រាហ្មណ៍ទាំងឡាយ ដែលមកអំពីដែនសីមាផ្សេង ៗ គ្នា (មានដែនកាសីនិងដែនកោសលជាដើម) ចំនួន ៥០០ នាក់ មកនៅអាស្រ័យក្នុងក្រុងចម្បា ដោយករណីយកិច្ច[1]ឯណានីមួយ ៗ ពួកព្រាហ្មណ៍ទាំងនោះបានឮថា សោណទណ្ឌព្រាហ្មណ៍នឹងចូលទៅគាល់ព្រះសមណគោតម ។ លំដាប់នោះ ពួកព្រាហ្មណ៍ទាំងនោះក៏នាំគ្នាចូលសំដៅទៅត្រង់ទី ដែលសោណទណ្ឌព្រាហ្មណ៍នៅ លុះចូលទៅដល់ហើយ ក៏បានសួរសោណទណ្ឌព្រាហ្មណ៍ដូច្នេះថា បានឮថា សោណទណ្ឌដ៏ចំរើន នឹងទៅគាល់ព្រះសមណគោតមពិតមែនឬ ។

---

១ អដ្ឋកថា ថា ពួកព្រាហ្មណ៍ដែលមកប្រជុំគ្នានៅនគរនោះ ដោយមានករណីយកិច្ច២យ៉ាង គឺដើម្បីបរិភោគនូវគ្រឿងបូជាយញ្ញ ១ ដើម្បីស្វាធ្យាយនូវមន្ត ១ ។ ឯក្នុងនគរនោះនៅវេលានោះ ឥតមានគ្រឿងបូជាយញ្ញទេ តែព្រាហ្មណ៍ទាំងនោះទៅប្រជុំគ្នា បម្រុងនឹងស្វាធ្យាយមន្ត ។ ព្រោះលោកសំដៅយកកិច្ចទាំង ២ យ៉ាងនោះ ទើបពោលថា ដោយមានករណីកិច្ចឯណានីមួយ ។

ឯវំ ខោ មេ ភោ ហោតិ អយម្បិ សមណំ គោតមំ ទស្សនាយ ឧបសង្កមិស្សាមីតិ ។ មា ភវំ សោណទណ្ឌោ សមណំ គោតមំ ទស្សនាយ ឧបសង្កមិ ន អរហតិ ភវំ សោណទណ្ឌោ សមណំ គោតមំ ទស្សនាយ ឧបសង្កមិតុំ សចេ ភវំ សោណទណ្ឌោ សមណំ គោតមំ ទស្សនាយ ឧបសង្កមិស្សតិ ភោតោ សោណទណ្ឌស្ស យសោ ហាយិស្សតិ សមណស្ស គោតមស្ស យសោ អភិវឌ្ឍិស្សតិ យម្បិ ភោតោ សោណទណ្ឌស្ស យសោ ហាយិស្សតិ សមណស្ស គោតមស្ស យសោ អភិវឌ្ឍិស្សតិ ឥមិនា ចង្គេន[១] ន អរហតិ ភវំ សោណទណ្ឌោ សមណំ គោតមំ ទស្សនាយ ឧបសង្កមិតុំ សមណោ ត្វេវ គោតមោ អរហតិ ភវន្តំ សោណទណ្ឌំ ទស្សនាយ ឧបសង្កមិតុំ ភវំ ហិ សោណទណ្ឌោ ឧភតោ សុជាតោ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន

១ ឱ. ម. បង្គេន ។

## សោណទណ្ឌសូត្រ គុណកថារបស់សោណទណ្ឌព្រាហ្មណ៍

សោណទណ្ឌព្រាហ្មណ៍ឆ្លើយថា (អើ អ្នកទាំងឡាយដ៏ចំរើន ខ្ញុំមានសេចក្ដីត្រិះរិះយ៉ាងហ្នឹងមែន ខ្ញុំនឹងចូលទៅគាល់ព្រះសមណគោតមដែរ ។ ពួកព្រាហ្មណ៍ទាំងនោះក៏ឃាត់ថា សោណទណ្ឌដ៏ចំរើន កុំចូលទៅជួបនឹងព្រះសមណគោតមឡើយ សោណទណ្ឌដ៏ចំរើន មិនគួរចូលទៅជួបនឹងព្រះសមណគោតមទេ ប្រសិនបើសោណទណ្ឌដ៏ចំរើន ចបេសតែចូលទៅជួបនឹងព្រះសមណគោតម សោណទណ្ឌដ៏ចំរើន នឹងសាបសូន្យយស ឯព្រះសមណគោតមរឹងរឹតតែចំរើនយសឡើង សោណទណ្ឌដ៏ចំរើន នឹងសាបសូន្យយស ព្រះសមណគោតម នឹងរឹងរឹតតែចំរើនយសឡើង ហេតុនេះបានជាសោណទណ្ឌដ៏ចំរើន មិនគួរចូលទៅជួបនឹងព្រះសមណគោតមទេ ព្រះសមណគោតមទេតើ ទើបគួរចូលមកជួបនឹងសោណទណ្ឌដ៏ចំរើនវិញ ប្រការមួយទៀត សោណទណ្ឌដ៏ចំរើន ជាឧភតោសុជាត (មានជាតិដ៏ល្អទាំងពីរចំណែក) គឺចំណែកខាងមាតានឹងចំណែកខាងបិតា កើតអំពីផ្ទៃដ៏បរិសុទ្ធស្អាត តាំងអំពីគំណនៃជីដូនជីតា ៧ ជួរ(១)មក មិនដែលនរណាមួយ ពោលទោសតិះដៀល ដោយពោល ដល់ជាតិកំណើតឡើយ

---

១ អដ្ឋកថា ថា មាតា ជីដូន ជីដូនទួត ជាព្រាហ្មណី បិតា ជីតា ជីតាទួត ជាព្រាហ្មណ៍ ជា ៦ (ជាតំរប់ ៧ ជួរនឹងខ្លួន) ហៅថា ឧភតោសុជាត ។

យម្បិ ភវំ សោណទណ្ឌោ ឧភតោ សុជាតោ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន ឥមិនា បង្គេន អយំ ភវំ សោណទណ្ឌោ សមណំ គោតមំ ទស្សនាយ ឧបសង្កមិតុំ សមណោ ត្វេវ គោតមោ អរហតិ ភវន្តំ សោណទណ្ឌំ ទស្សនាយ ឧបសង្កមិតុំ ភវំ ហិ សោណទណ្ឌោ អឌ្ឍោ មហទ្ធនោ មហាភោគោ ។ បេ ។ ភវំ ហិ សោណទណ្ឌោ អជ្ឈាយកោ មន្តធរោ តិណ្ណំ វេទានំ បារគូ សនិឃណ្ឌុកេដុភានំ សាក្ខរប្បភេទានំ ឥតិហាសបញ្ចមានំ បទកោ វេយ្យាករណោ លោកាយតមហាបុរិសលក្ខណេសុ អនវយោ ភវំ ហិ សោណទណ្ឌោ អភិរូបោ ទស្សនីយោ បាសាទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ ព្រហ្មវណ្ណី ព្រហ្មវច្ឆសី(១) អខុទ្ទាវកាសោ ទស្សនាយ ភវំ ហិ

១ ម. ព្រហ្មវណ្ណី ព្រហ្មវច្ចសី ។

ក៏ឯសោណទណ្ឌដ៏ចំរើន ជាឧភតោសុជាត ខាងមាតានឹងបិតា កើតអំពីផ្ទៃដ៏បរិសុទ្ធស្អាត តាំងអំពីតំណនៃដូនជីតា ៧ ជួរមក មិនដែលមាននរណាមួយ ពោលតិះដៀល ដោយពោលដល់ជាតិកំណើតបាន ហេតុនេះ បានជាសោណទណ្ឌដ៏ចំរើន មិនគួរចូលទៅជួប នឹងព្រះសមណគោតមឡើយ ព្រះសមណគោតមទេតើ ទើបគួរចូលមកជួបសោណទណ្ឌដ៏ចំរើនវិញ ប្រការមួយទៀត សោណទណ្ឌដ៏ចំរើន ជាអ្នកស្តុកស្តម្ភ មានទ្រព្យសម្បត្តិច្រើន មានគ្រឿងប្រើប្រាស់ច្រើន ។ បេ ។ ប្រការមួយទៀត សោណទណ្ឌដ៏ចំរើន ជាអ្នកកយមន្ត ចេះចាំមន្ត ជាអ្នកដល់នូវត្រើយនៃត្រៃវេទ ព្រមទាំងគម្ពីរនិឃណ្ឌុ គម្ពីរកេតុភៈ ព្រមទាំងអក្ខរប្បភេទ គឺសិក្ខានិងនិរុត្តិ ដែលមានគម្ពីរឥតិហាសៈជាគំរប់ ៥ ជាអ្នកស្ទាល់បទនឹងវេយ្យាករណ៍ ជាអ្នកមិនខុសថយ គឺជាអ្នកបច្ចេកទេស ស្ទាត់ជំនាញ ក្នុងលោកាយតសាស្ត្រ និងមហាបុរិសលក្ខណព្យាករណសាស្ត្រ ប្រការមួយទៀត សោណទណ្ឌដ៏ចំរើន មានរូបល្អ គួរពិតពិល រមិលមើល គួរជ្រះថ្លា ប្រកបដោយសម្បុរល្អក្រៃលែង មានសម្បុរដ៏ប្រសើរ មានសរីរៈស្រដៀងនឹងព្រហ្ម មានសព៌ាង្គកាយ គួរឲ្យចង់មើលមិនលែង

សោណទណ្ឌោ សីលវា វុឌ្ឍសីលី(១) វុឌ្ឍសីលេន សមន្នាគតោ ភវំ ហិ សោណទណ្ឌោ កល្យាណវាចោ កល្យាណវាក្ករណោ បោរិយា វាចាយ សមន្នាគតោ វិស្សដ្ឋាយ អនេលគលាយ អត្ថស្ស វិញ្ញាបនិយា ភវំ ហិ សោណទណ្ឌោ ពហូនំ អាចរិយបាចរិយោ តីណិ មាណវកសតានិ មន្តេ វាចេតិ ពហុកា ខោ(២) បន នានាទិសា នានាជនបទា មាណវកា អាគច្ឆន្តិ ភោតោ សោណទណ្ឌស្ស សន្តិកេ មន្តត្ថិកា មន្តេ អធិយិតុកាមា ភវំ ហិ សោណទណ្ឌោ ជិណ្ណោ វុឌ្ឍោ មហល្លកោ អទ្ធគតោ វយោអនុប្បត្តោ សមណោ គោតមោ តរុណោ ចេវ តរុណបព្វជិតោ ច ភវំ ហិ សោណទណ្ឌោ រញ្ញោ មាគធស្ស សេនិយស្ស ពិម្ពិសារស្ស សក្កតោ គរុកតោ មានិតោ បូជិតោ អបចិតោ ភវំ ហិ សោណទណ្ឌោ ព្រាហ្មណស្ស បោក្ខរសាតិស្ស សក្កតោ គរុកតោ មានិតោ បូជិតោ អបចិតោ

---

១ ឱ. ម. វុទ្ធសីលី ។ ២ ឱ. ម. ពហូ ខោ ។

ប្រការមួយទៀត សោណទណ្ឌដ៏ចំរើន ជាអ្នកមានសីលធម៌ មានសីលធម៌ដ៏ចំរើន ប្រកបដោយសីលធម៌ដ៏ចំរើន ប្រការមួយទៀត សោណទណ្ឌដ៏ចំរើន មានវាចាសុភាព មានពាក្យពីរោះក្បោះក្បាយ ប្រកបដោយសំដីជារបស់អ្នកក្រុង ជាវាចាច្បាស់លាស់ប្រាសចាកទោស ជាវាចាអាចញុំាងអ្នកស្តាប់ឲ្យប្បូលចិត្តសេចក្តីបានជាក់លាក់ ប្រការមួយទៀត សោណទណ្ឌដ៏ចំរើន ជាអាចារ្យធំជាងអាចារ្យរបស់ជនជាច្រើន បានបង្រៀនមន្តមាណព ៣រយនាក់ មាណពជាច្រើនដែលមានសេចក្តីត្រូវការដោយមន្ត មានប្រាថ្នានឹងរៀនមន្តក្នុងសំណាក់នៃសោណទណ្ឌដ៏ចំរើន ហើយនាំគ្នាមកអំពីទិសផ្សេងៗ អំពីជនបទផ្សេងៗ ប្រការមួយទៀត សោណទណ្ឌដ៏ចំរើន ជាមនុស្សចាស់ព្រឹទ្ធាចារ្យ មានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានអាយុក៏ជ្រុលចូលមក ក្នុងបច្ឆិមវ័យហើយ ឯព្រះសមណគោតមនៅក្មេងផង ទើបនឹងបួសថ្មីៗផង ប្រការមួយទៀត សោណទណ្ឌជាមនុស្សដែលព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់ធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ប្រការមួយទៀត សោណទណ្ឌដ៏ចំរើន ជាមនុស្សដែលបោក្ខរសាតិព្រាហ្មណ៍បានធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង

ភវញ្ហិ សោណទណ្ឌោ ចម្បំ អជ្ឈាវសតិ សត្តុស្សទំ សតិណកដ្ឋោទកំ សធញ្ញំ រាជភោគ្គំ រញ្ញា មាគធេន សេនិយេន ពិម្ពិសារេន ទិន្នំ រាជទាយំ ព្រហ្មទេយ្យំ យម្បិ ភវំ សោណទណ្ឌោ ចម្បំ អជ្ឈាវសតិ សត្តុស្សទំ សតិណកដ្ឋោទកំ សធញ្ញំ រាជភោគ្គំ រញ្ញា មាគធេន សេនិយេន ពិម្ពិសារេន ទិន្នំ រាជទាយំ ព្រហ្មទេយ្យំ ឥមិនាបង្គេន ន អរហតិ ភវំ សោណទណ្ឌោ សមណំ គោតមំ ទស្សនាយ ឧបសង្កមិតុំ សមណោ ត្វេវ គោតមោ អរហតិ ភវន្តំ សោណទណ្ឌំ ទស្សនាយ ឧបសង្កមិតុន្តិ ។

(១៨២) ឯវំ វុត្តេ សោណទណ្ឌោ ព្រាហ្មណោ តេ ព្រាហ្មណេ ឯតទវោច តេនហិ ភោ មមបិ សុណាថ យថា មយមេវ អរហាម តំ ភវន្តំ គោតមំ ទស្សនាយ ឧបសង្កមិតុំ ន ត្វេវ អរហតិ សោ ភវំ គោតមោ អម្ហាកំ ទស្សនាយ ឧបសង្កមិតុំ សមណោ ខលុ ភោ គោតមោ ឧភតោ សុជាតោ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ

ប្រការមួយទៀត សោណទណ្ឌដ៏ចំរើន នៅគ្រប់គ្រងក្រុងចម្បា ដែលជាក្រុងគុះករ ដោយប្រជាជននិងសត្វ សម្បូណ៌ដោយស្មៅ ឈើ និងទឹក បរិបូណ៌ ដោយធញ្ញាហារ ជាព្រះរាជទ្រព្យដែលព្រះបាទមាគធសេនិយ-ពិម្ពិសារ ទ្រង់ព្រះរាជទានឲ្យ ជាព្រះរាជបំណាច់ដ៏ប្រសើរ ប្រការមួយទៀត សោណទណ្ឌដ៏ចំរើន នៅគ្រប់គ្រងក្រុងចម្បា ដែលជាក្រុងគុះករ ដោយប្រជាជននិងសត្វ ព្រមទាំងស្មៅ ឈើ ទឹក បរិបូណ៌ដោយធញ្ញាហារ ជាព្រះរាជទ្រព្យដែលព្រះបាទមាគធសេនិយពិម្ពិសារ ទ្រង់ព្រះរាជទានឲ្យ ជាព្រះរាជបំណាច់ដ៏ប្រសើរ ព្រោះហេតុនេះ ទើបថា សោណទណ្ឌដ៏ចំរើន មិនគួរចូលទៅជួបនឹងព្រះសមណគោតមឡើយ ព្រះសមណគោតមទេតើ ទើបគួរចូលមកជួបនឹងសោណទណ្ឌដ៏ចំរើនវិញ ។

(១៨២) កាលដែលពួកព្រាហ្មណ៍និយាយយ៉ាងនេះហើយ សោណ-ទណ្ឌព្រាហ្មណ៍ បាននិយាយនឹងព្រាហ្មណ៍ទាំងនោះដូច្នេះថា នែអ្នកទាំងឡាយដ៏ចំរើន បើដូច្នោះ ចូរអ្នកទាំងឡាយស្តាប់ខ្ញុំសិន ដូចយ៉ាងយើងគួរនឹងចូលទៅជួបនឹងព្រះគោតមដ៏ចំរើននោះដោយពិត ឯព្រះគោតមដ៏ចំរើននោះ មិនគួរនឹងចូលមកជួបនឹងយើងទេ បានឮថា ព្រះសមណគោតមដ៏ចំរើន ជាឧភតោសុជាតអំពីខាងព្រះមាតានិងខាងព្រះបិតា កើតអំពីផ្ទៃ

សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន យម្បិ ភោ សមណោ គោតមោ ឧភតោ សុជាតោ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន ឥមិនាបង្គេន ន អរហតិ សោ ភវំ គោតមោ អម្ហាកំ ទស្សនាយ ឧបសង្កមិតុំ អថខោ មយមេវ អរហាម តំ ភវន្តំ គោតមំ ទស្សនាយ ឧបសង្កមិតុំ សមណោ ខលុ ភោ គោតមោ មហន្តំ ញាតិសង្ឃំ ឱហាយ បព្វជិតោ ។ បេ ។ សមណោ ខលុ ភោ គោតមោ បហូតំ ហិរញ្ញសុវណ្ណំ ឱហាយ បព្វជិតោ ភូមិគតញ្ច វេហាសដ្ឋញ្ច សមណោ ខលុ ភោ គោតមោ ទហរោវ សមានោ សុសុ(១) កាឡកេសោ ភទ្រេន យោព្វនេន សមន្នាគតោ បឋមេន វយសា អគារស្មា អនគារិយំ បព្វជិតោ សមណោ ខលុ ភោ គោតមោ អកាមកានំ មាតាបិតូនំ អស្សុមុខានំ រុទន្តានំ

---

១ ឱ. សុសុ ។ ម. យុវា សុសុ ។

## សោណទណ្ឌសូត្រ ពុទ្ធគុណកថា

ដ៏បរិសុទ្ធស្អាត តាំងអំពីគំណានៃជីដូនជីតា ៧ ជួរមកដែរ មិនដែលមាននរណាមួយ ពោលទោសតិះដៀល ដោយពោលដល់ជាតិកំណើតឡើយ ព្រះសមណគោតមដ៏ចំរើន ជាឧភតោសុជាត អំពីខាងព្រះមាតានិងខាងព្រះបិតា កើតអំពីផ្ទៃដ៏បរិសុទ្ធស្អាត តាំងអំពីគំណានៃជីដូនជីតា ៧ ជួរមកដែរ មិនដែលមាននរណាមួយ ពោលទោសតិះដៀល ដោយពោលដល់ជាតិកំណើតបាន ព្រោះហេតុនេះបានជាព្រះគោតមដ៏ចំរើននោះ មិនគួរស្តេចចូលមកជួបនឹងយើងទេ តាមដែលពិតនោះ មានតែយើងទេតើ ទើបគួរចូលទៅជួបនឹងព្រះគោតមដ៏ចំរើននោះវិញ បានឮថា ព្រះសមណគោតមដ៏ចំរើន ទ្រង់លះបង់ពពួកញាតិដ៏ច្រើន ហើយ ( ចេញទៅ ) ទ្រង់ព្រះផ្នួស ។ បេ ។ បានឮថា ព្រះសមណគោតមដ៏ចំរើន ទ្រង់លះបង់ប្រាក់នឹងមាសដ៏ច្រើន ដែលបិតនៅក្នុងផែនដី បិតនៅឯអាកាស ( ប្រាសាទជាន់លើ ) ហើយទ្រង់ព្រះផ្នួស បានឮថា ព្រះសមណគោតមដ៏ចំរើន ទ្រង់នៅក្មេងកម្លោះ មានព្រះកេសាខ្មៅស្រស់ ប្រកបដោយវ័យដ៏ចំរើន តាំងនៅក្នុងបឋមវ័យនៅឡើយ ទ្រង់ស្តេចចេញចាកគេហដ្ឋាន ហើយទ្រង់ព្រះផ្នួស បានឮថា ព្រះសមណគោតមដ៏ចំរើន កាលដែលព្រះមាតា នឹងព្រះបិតាមិនពេញព្រះទ័យ ( នឹងឲ្យទៅទ្រង់ព្រះផ្នួស ) កំពុងមានព្រះភក្ត្រដោកដោយទឹកព្រះនេត្រ ទ្រង់ព្រះកន្សែងសោយសោក ព្រះអង្គក៏ទ្រង់

កេសមស្សុំ ឱហារេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា អគារស្មា អនគារិយំ បព្វជិតោ សមណោ ខលុ ភោ គោតមោ អភិរូបោ ទស្សនីយោ បាសាទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ ព្រហ្មវណ្ណី ព្រហ្មវច្ចសី អខុទ្ទាវកាសោ ទស្សនាយ សមណោ ខលុ ភោ គោតមោ សីលវា អរិយសីលី កុសល-សីលី កុសលសីលេន សមន្នាគតោ សមណោ ខលុ ភោ គោតមោ កល្យាណវាចោ កល្យាណវាក-ករណោ បោរិយា វាចាយ សមន្នាគតោ វិស្សដ្ឋាយ អនេលគលាយ អត្ថស្ស វិញ្ញាបនិយា សមណោ ខលុ ភោ គោតមោ ពហូនំ អាចរិយបាចរិយោ សម-ណោ ខលុ ភោ គោតមោ ខីណកាមរាគោ វិគតចា-បល្លោ សមណោ ខលុ ភោ គោតមោ កម្មវាទី កិរិ-យវាទី អបាបបុរេក្ខារោ ព្រហ្មញ្ញាយ បជាយ សម-ណោ ខលុ ភោ គោតមោ ឧច្ចា កុលា បព្វជិតោ អភិន្នខត្តិយកុលា(១) សមណោ ខលុ ភោ គោតមោ

១ ឱ. អាទីនក្ខត្តិយកុលា ។ ម. អសម្ភិន្នខត្តិយកុលា ។

ដាក់ព្រះកេសានិងព្រះមស្សុ ហើយទ្រង់ព្រះពស្ត្រជ្រលក់ទឹកអម្ចត់ ទ្រង់ចេញចាកគេហដ្ឋានទៅទ្រង់ព្រះផ្នួស បានឮថា ព្រះសមណគោតម មានព្រះរូបឆោមល្អ គួរពិតពិល មើលមើល គួរជ្រះថ្លា ប្រកបដោយព្រះឆវីដ៏ល្អក្រៃលែង មានព្រះឆវីដ៏ប្រសើរ មានព្រះសរីរៈស្រដៀងនឹងព្រហ្ម មានព្រះសណ្ឋានកាយគួរឲ្យចង់មើលមិនលែង បានឮថា ព្រះសមណគោ-តមដ៏ចំរើន មានសីល មានសីលដ៏ប្រសើរ មានសីលជាកុសល ព្រះអង្គប្រកបដោយសីលជាកុសល បានឮថា ព្រះសមណគោតមដ៏ចំរើន មានព្រះវាចាសុភាព មានពាក្យពីរោះក្បោះក្បាយ ព្រះអង្គប្រកបដោយសំដីជារបស់អ្នកក្រុង ជាវាចាច្បាស់លាស់ប្រាសចាកទោស ជាវាចាអាចញុំាងអ្នកស្តាប់ឲ្យចូលចិត្តសេចក្តីបានជាក់លាក់ បានឮថា ព្រះសមណគោតមដ៏ចំរើន ជាអាចារ្យធំជាងអាចារ្យរបស់ជនជាច្រើន បានឮថា ព្រះសមណ-គោតមដ៏ចំរើន អស់កាមរាគៈហើយ ប្រាសចាកសេចក្តីស្រើបស្រាលហើយ បានឮថា ព្រះសមណគោតមដ៏ចំរើន ជាកម្មវាទី ជាកិរិយវាទី ធ្វើនូវលោកុត្តរធម៌ឲ្យជាប្រធានដល់ប្រជាជនអ្នកដ៏ប្រសើរ បានឮថា ព្រះសមណគោតមដ៏ចំរើន ទ្រង់ចេញចាកត្រកូលដ៏ខ្ពង់ខ្ពស់ជាត្រកូលក្សត្រិយ៍ដែលមិនបានលាយច្រឡំដោយត្រកូលដទៃ មកទ្រង់ព្រះផ្នួស បានឮថា

អឌ្ឍា(១) កុលា បព្វជិតោ មហទ្ធនា មហាភោគា សមណំ ខលុ ភោ គោតមំ តិរោរដ្ឋា តិរោជនបទា សំបុច្ឆិតុំ អាគច្ឆន្តិ សមណំ ខលុ ភោ គោតមំ អនេកានិ ទេវតាសហស្សានិ បាណេហិ សរណង្គតានិ សមណំ ខលុ ភោ គោតមំ ឯវំ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ សមណោ ខលុ ភោ គោតមោ ទ្វត្តឹសមហាបុរិសលក្ខណេហិ សមន្នាគតោ សមណោ ខលុ ភោ គោតមោ ឯហិសាគតវាទី(២) សខិលោ សម្មោទកោ

១ អឌ្ឍាតិបិ អទ្ធកុលាតិបិ អឌ្ឍកុលាតិបិ បាឋោ ។ ២ ឯហិស្វាគតវាទី ឥតិបិ បាឋោ ។

## សោណទណ្ឌសូត្រ ពុទ្ធគុណកថា

ព្រះសមណគោតមដ៏ចំរើន ទ្រង់ចេញចាកត្រកូលដ៏ស្តុកស្តម្ភ មាំមួនមានទ្រព្យច្រើន មានគ្រឿងប្រើប្រាស់ច្រើន មកទ្រង់ព្រះផ្នួស បានឮថា ពួកមនុស្សដែលនៅក្នុងដែនដទៃ ក្នុងជនបទដទៃ នាំគ្នាមកសាកសួរ (ប្រស្នា) នឹងព្រះសមណគោតម បានឮថា ពួកទេវតាច្រើនពាន់បានដល់នូវព្រះសមណគោតមជាសរណៈស្មើដោយជីវិត បានឮថា កិត្តិសព្ទដ៏ពីរោះសរសើរព្រះគោតម ពុទ្ធខ្ចរខ្ចាយសុសសាយយ៉ាងនេះថា ព្រះមានព្រះភាគអង្គនោះ ព្រះអង្គឆ្ងាយចាកសេចក្តីសៅហ្មងគ្រប់យ៉ាង ព្រះអង្គត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ព្រះអង្គបរិបូណ៌ដោយវិជ្ជានិងចរណៈ គឺសេចក្តីចេះដឹងនឹងក្រិត្យដែលបុគ្គលគប្បីប្រព្រឹត្ត ព្រះអង្គមានព្រះដំណើរល្អទៅកាន់ព្រះនិព្វាន ព្រះអង្គជ្រាបច្បាស់នូវត្រៃលោក ព្រះអង្គប្រសើរដោយសីលាទិគុណ រកបុគ្គលណាមួយស្មើគ្មាន ព្រះអង្គជាសារថីអ្នកទូន្មាននូវបុរសដែលគួរទូន្មានបាន ព្រះអង្គជាគ្រូនៃទេវតានិងមនុស្សទាំងឡាយ ព្រះអង្គបានត្រាស់ដឹងនូវអរិយសច្ចធម៌ ព្រះអង្គលែងត្រឡប់មកកាន់ភពថ្មីទៀត បានឮថា ព្រះសមណគោតមដ៏ចំរើន ប្រកបដោយមហាបុរិសលក្ខណៈ ៣២ ប្រការ បានឮថា ព្រះសមណគោតមដ៏ចំរើន រមែងមានព្រះវាចាពក់ទាក់ថា អ្នកចូរមកចុះ មកល្អហើយ ទ្រង់មានព្រះវាចាទន់ ទ្រង់ឈ្លាសវៃក្នុងការទទួលពក់ទាក់

អព្ភាកុដិកោ ឧត្តានមុខោ បុព្ពភាសី សមណោ ខលុ ភោ គោតមោ ចតុន្នំ បរិសានំ សក្កតោ គរុកតោ មានិតោ បូជិតោ អបចិតោ សមណំ ខលុ ភោ គោតមំ(១) ពហូ ទេវា ច(២) មនុស្សា ច អភិប្បសន្នា សមណោ ខលុ ភោ គោតមោ យស្មឹ គាមេ វា និគមេ វា បដិវសតិ ន តស្មឹ គាមេ វា និគមេ វា អមនុស្សា មនុស្សេ វិហេឋេន្តិ សមណោ ខលុ ភោ គោតមោ សង្ឃី គណី គណាចរិយោ បុថុតិត្ថករានំ អគ្គមក្ខាយតិ យថា ខោ បន ភោ ឯតេសំ សមណព្រាហ្មណានំ យថា វា តថា វា យសោ សមុទាគច្ឆតិ ន ហេវំ សមណស្ស គោតមស្ស យសោ សមុទាគតោ អថខោ អនុត្តរាយ វិជ្ជាចរណសម្បទាយ សមណស្ស គោតមស្ស យសោ សមុទាគតោ សមណំ ខលុ ភោ គោតមំ រាជា មាគធោ សេនិយោ ពិម្ពិសារោ សបុត្តោ សភរិយោ សបរិសោ សាមច្ចោ បាណេហិ សរណង្គតោ សមណំ ខលុ ភោ គោតមំ

១ ឱ. សមណោ ខលុ ភោ គោតមេ ។ ម. សមណោ ខលុ ភោ គោតមោ ។
២ ឱ. បសន្នា ន ទិស្សតិ ។

ទ្រង់មានព្រះកក្រីកកាយ ទ្រង់មានព្រះឱស្ឋស្សកាយ ទ្រង់មានព្រះវាចាមុនគេ (តែក្នុងកាលគួរ) បានឮថា ព្រះសមណគោតមដ៏ចំរើន មានបរិសទ្យទាំង ៤ ពួក ធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង បានឮថា ពួកទេវតា នឹងមនុស្សជាច្រើន ជ្រះថ្លានឹងព្រះសមណគោតម បានឮថា (បើ) ព្រះសមណគោតមដ៏ចំរើន នៅអាស្រ័យក្នុងស្រុកណា ឬនិគមណា ពួកអមនុស្សមិនហ៊ានបៀតបៀន ដល់មនុស្សទាំងឡាយក្នុងស្រុក ឬនិគមនោះឡើយ បានឮថា ព្រះសមណគោតម មានពួកមានក្រុម នឹងអាចារ្យនៃពួកក្រុម (ជាច្រើន) ប្រជុំជនតែងពោលថា ព្រះអង្គប្រសើរជាងពួកតិរ្ថិយដ៏ច្រើន នៃអ្នកទាំងឡាយដ៏ចំរើន ក៏យសរបស់សមណព្រាហ្មណ៍ទាំងនេះ តែងចំរើនរុងរឿងឡើង ដោយហេតុតាមតែបាន យ៉ាងណាមិញ ឯយសរបស់ព្រះសមណគោតម មិនមែនចំរើនរុងរឿងឡើងយ៉ាងនោះទេ តាមដែលពិតនោះ យសរបស់ព្រះសមណ-គោតម ចំរើនរុងរឿងឡើង ព្រោះការបរិបូណ៌ ដោយវិជ្ជានឹងចរណៈដ៏ប្រសើរ បានឮថា ព្រះបាទមាគធសេនិយពិម្ពិសារ ព្រមទាំងព្រះរាជបុត្រ ព្រះអគ្គមហេសី រាជបរិសទ្យនឹងរាជអាមាត្យ បានដល់នូវព្រះសមណ-គោតមជាសរណៈ ស្មើដោយជីវិត បានឮថា ព្រះបាទបសេនទិកោសល

រាជា បសេនទិកោសលោ សបុត្តោ សភរិយោ សប-
រិសោ សាមច្ចោ បាណេហិ សរណង្គតោ សមណំ
ខលុ ភោ គោតមំ ព្រាហ្មណោ បោក្ខរសាតិ សបុត្តោ
សភរិយោ សបរិសោ សាមច្ចោ បាណេហិ សរណង្គតោ
សមណោ ខលុ ភោ គោតមោ រញ្ញោ មាគធស្ស
សេនិយស្ស ពិម្ពិសារស្ស សក្កតោ គរុកតោ មានិតោ
បូជិតោ អបចិតោ សមណោ ខលុ ភោ គោតមោ
រញ្ញោ បសេនទិកោសលស្ស សក្កតោ គរុកតោ
មានិតោ បូជិតោ អបចិតោ សមណោ ខលុ ភោ
គោតមោ ព្រាហ្មណស្ស បោក្ខរសាតិស្ស សក្កតោ
គរុកតោ មានិតោ បូជិតោ អបចិតោ សមណោ
ខលុ ភោ គោតមោ ចម្បំ អនុប្បត្តោ ចម្បាយំ
វិហរតិ គគ្គរាយ បោក្ខរណិយា តីរេ យេ ខោ បន
ភោ(១) កេចិ សមណា វា ព្រាហ្មណា វា អម្ហាកំ
គាមក្ខេត្តំ អាគច្ឆន្តិ អតិថិនោ តេ ហោន្តិ អតិថី
ខោ(២) បនម្ហេហិ សក្កាតព្វា គរុកាតព្វា មានេតព្វា

---

១ ឱ. ភោសទ្ទោ ន ទិស្សតិ ។ ២ ឱ. អតិថីបិ ខោ ។

ព្រមទាំងព្រះរាជបុត្រ ព្រះអគ្គមហេសី រាជបរិស័ទ្យទាំងអាមាត្យ បានដល់នូវព្រះសមណគោតមដ៏ចំរើនជាសរណៈ ស្មើដោយជីវិត បានឮថា ពោក្ខរ-សាតិព្រាហ្មណ៍ព្រមទាំងបុត្រភរិយា បរិស័ទ្យទាំងអាមាត្យ បានដល់នូវព្រះសមណគោតមជាសរណៈស្មើដោយជីវិត បានឮថា ព្រះបាទមាគធសេនិ-យពិម្ពិសារ ទ្រង់បានធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែងព្រះសមណគោតម បានឮថា ព្រះបាទបសេនទិកោសល ទ្រង់បានធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែងព្រះសមណគោតម បានឮថា ពោក្ខរសាតិ-ព្រាហ្មណ៍បានធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែងព្រះសមណ-គោតម បានឮថា ព្រះសមណគោតម ទ្រង់ពុទ្ធដំណើរមកដល់ក្រុងចម្បាហើយ ឥឡូវទ្រង់គង់ទៀបឆ្នេរស្រះបោក្ខរណី ឈ្មោះគគ្គរា ជិតក្រុងចម្បានៃគ្នាយើងដ៏ចំរើន ពួកសមណៈឬព្រាហ្មណ៍ឯណានីមួយ ដែលមកដល់តាមក្ខេត្តរបស់យើងហើយ ពួកសមណព្រាហ្មណ៍អម្បាលនោះ សុទ្ធតែជាភ្ញៀវរបស់យើង ធម្មតាភ្ញៀវ គួរតែយើងធ្វើសក្ការៈ គោរព រាប់អាន

បូជេតព្វោ អបចេតព្វោ យម្បិ ភោ សមណោ គោតមោ ចម្បំ អនុប្បត្តោ ចម្បាយំ វិហរតិ គគ្គរាយ បោក្ខរ-ណិយា តីរេ អតិថិម្ហាកំ សមណោ គោតមោ អតិថី ខោ បនម្ហេហិ សក្កាតព្វោ គរុកាតព្វោ មានេតព្វោ បូជេតព្វោ អបចេតព្វោ ឥមិនា បង្គេន ន អរហតិ សោ ភវំ គោតមោ អម្ហាកំ ទស្សនាយ ឧបសង្កមិតុំ អថខោ មយមេវ អរហាម តំ ភវន្តំ គោតមំ ទស្សនាយ ឧបសង្កមិតុំ ឯត្តកេ ខោ អហំ ភោតោ គោតមស្ស វណ្ណេ បរិយាបុណាមិ នោ ច ខោ សោ ភវំ គោតមោ ឯត្តកវណ្ណោ អបរិមាណវណ្ណោ ហិ សោ ភវំ គោតមោតិ ។

(១៨៣) ឯវំ វុត្តេ តេ ព្រាហ្មណា សោណទណ្ឌំ ព្រាហ្មណំ ឯតទវោចុំ យថា ខោ ភវំ សោណ-ទណ្ឌោ សមណស្ស គោតមស្ស វណ្ណេ ភាសតិ ឥតោ បិ សោ ភវំ គោតមោ យោជនសតេ វិហរតិ

បូជា កោតក្រែង នៃគ្នាយើងដ៏ចំរើន ព្រះសមណគោតម ទ្រង់ពុទ្ធដំណើរមកដល់ក្រុងចម្បាហើយ ឥឡូវទ្រង់គង់ទៀបឆ្នេរស្រះបោក្ខរណីឈ្មោះគគ្គរា ជិតក្រុងចម្បា ព្រះសមណគោតមឈ្មោះថា ជាភ្ញៀវរបស់យើងហើយ ធម្មតាភ្ញៀវ គួរតែយើងធ្វើសក្ការៈ គោរព រាប់អាន បូជា កោតក្រែង ព្រោះហេតុនេះ ព្រះសមណគោតមដ៏ចំរើននោះ មិនគួរចូលមកជួបនឹងយើងទេ តាមដែលពិតនោះ យើងទេតើ ទើបគួរចូលទៅគាល់ព្រះសមណគោតមដ៏ចំរើននោះវិញ ខ្ញុំរៀបរាប់គុណរបស់ព្រះគោតមដ៏ចំរើន បានតែប៉ុណ្ណេះ ឯព្រះគោតមដ៏ចំរើននោះ មិនមែនមានគុណត្រឹមប៉ុណ្ណេះទេ ព្រោះថា ព្រះគោតមដ៏ចំរើននោះ មានគុណនឹងប្រមាណពុំបាន ។

(១៨៣) កាលដែលសោណទណ្ឌព្រាហ្មណ៍ និយាយយ៉ាងនេះហើយ ពួកព្រាហ្មណ៍ទាំងនោះ បាននិយាយទៅ នឹងសោណទណ្ឌព្រាហ្មណ៍ ដូច្នេះថា អម្បាលយ៉ាងសោណទណ្ឌដ៏ចំរើន ម្តេចគង់ពោលសរសើរគុណព្រះសមណគោតមទៅហើយ ព្រោះហេតុនោះ បើទុកជាព្រះសមណ-គោតមដ៏ចំរើននោះ គង់នៅក្នុងទីឆ្ងាយមួយរយយោជន៍ អំពីទីនេះក្តី

អលមេវ សទ្ធេន កុលបុត្តេន ទស្សនាយ ឧប-
សង្កមិតុំ អបិ បុដោសេនាតិ(១) ។ តេនហិ ភោ
សព្វេវ មយំ សមណំ គោតមំ ទស្សនាយ
ឧបសង្កមិស្សាមាតិ ។ អថខោ សោណទណ្ឌោ
ព្រាហ្មណោ មហតា ព្រាហ្មណគណេន សទ្ធឹ យេន
គគ្គរា បោក្ខរណី តេនុបសង្កមិ ។ អថខោ សោណ-
ទណ្ឌស្ស ព្រាហ្មណស្ស តិរោវនសណ្ឌគតស្ស ឯវំ
ចេតសោ(២) បរិវិតក្កោ ឧទបាទិ អហញ្ចេវ ខោ
បន សមណំ គោតមំ បញ្ហំ បុច្ឆេយ្យំ តត្រ ចេ
មំ សមណោ គោតមោ ឯវំ វទេយ្យ ន ខោ
ឯសោ(៣) ព្រាហ្មណ បញ្ហោ ឯវំ បុច្ឆិតព្វោ ឯវំ
នាមេស ព្រាហ្មណ បញ្ហោ បុច្ឆិតព្វោតិ តេន មំ
អយំ បរិសា បរិភវេយ្យ ពាលោ សោណទណ្ឌោ
ព្រាហ្មណោ អព្យត្តោ នាសក្ខិ សមណំ គោតមំ
យោនិសោ បញ្ហំ បុច្ឆិតុន្តិ យំ ខោ បនាយំ បរិសា
បរិភវេយ្យ យសោបិ តស្ស ហាយេថ យស្ស

---

១ ឱ. បុដំសេនាតិ ។ ម. ផុដោសេនាតិ ។ ២ ឱ. បេតសា ។ ៣ ឱ. ឥ បេស ។

កុលបុត្រដែលមានសទ្ធា គួរណាស់តែរកស្បៀងយកទៅ ដើម្បីនឹងចូលទៅគាល់ឲ្យបាន ៗ សោណទណ្ឌព្រាហ្មណ៍និយាយថា នែអ្នកទាំងឡាយដ៏ចំរើន បើដូច្នោះយើងទាំងអស់គ្នា នឹងចូលទៅគាល់ព្រះសមណគោតម ៗ លំដាប់នោះ សោណទណ្ឌព្រាហ្មណ៍ ព្រមទាំងពួកព្រាហ្មណ៍ជាច្រើន បានចូលសំដៅទៅត្រង់ស្រះបោក្ខរណីឈ្មោះគគ្គរា ៗ លុះសោណទណ្ឌព្រាហ្មណ៍ ចូលទៅដល់ខាងក្រៅដងព្រៃ(១) ក៏កើតសេចក្តីត្រិះរិះក្នុងចិត្តយ៉ាងនេះថា ប្រសិនជាអាត្មាអញ សួរប្រស្នាចំពោះព្រះសមណគោតម បើព្រះសមណគោតម ពោលយ៉ាងនេះ នឹងអាត្មាអញក្នុងប្រស្នានោះថា ម្នាលព្រាហ្មណ៍ ប្រស្នានុ៎ះ អ្នកមិនត្រូវសួរ យ៉ាងនេះទេ ម្នាលព្រាហ្មណ៍ ធម្មតាប្រស្នាបែបនុ៎ះ គេគួរសួរយ៉ាងនេះវិញ (បើដូច្នេះ) បរិសទ្យនេះមុខជានឹងមើលងាយអាត្មាអញ ដោយហេតុនោះ ថាសោណទណ្ឌព្រាហ្មណ៍ជាមនុស្សល្ងង់ខ្លៅ មិនឈ្លាសវៃ មិនអាច ដើម្បីនឹងសួរប្រស្នាចំពោះព្រះសមណគោតម ដោយយោបល់បាន បរិសទ្យនេះ បើមើលងាយបុគ្គលណាហើយ យសរបស់បុគ្គលនោះ គប្បីសាបសូន្យ

១ បើតាមអដ្ឋកថាពន្យល់ថា ខាងក្នុង គឺព្រៃដែលនៅត្រង់ចន្លោះទីដែលព្រះអង្គគង់ ។

ខោ បន យសោ ហាយេថ ភោគាបិ តស្ស ហា-
យេយ្យុំ យសោលទ្ធា ខោ បនម្ហាកំ ភោគា មញ្ចេ
បន(១) សមណោ គោតមោ បញ្ហំ បុច្ឆេយ្យ តស្ស
ចាហំ បញ្ហស្ស វេយ្យាករណេន ចិត្តំ ន អារាធេយ្យំ
តត្រ ចេ មំ សមណោ គោតមោ ឯវំ វទេយ្យ
ន ខោ ឯស(២) ព្រាហ្មណ បញ្ហោ ឯវំ ព្យាកា-
តព្វោ ឯវំ នាមេស ព្រាហ្មណ បញ្ហោ ព្យាកាតព្វោតិ
តេន មំ អយំ បរិសា បរិភវេយ្យ ពាលោ សោណ-
ទណ្ឌោ ព្រាហ្មណោ អព្យត្តោ នាសក្ខិ សមណស្ស
គោតមស្ស បញ្ហស្ស វេយ្យាករណេន ចិត្តំ អារា-
ធេតុន្តិ យំ ខោ បនាយំ បរិសា បរិភវេយ្យ យសោ-
បិ តស្ស ហាយេថ យស្ស ខោ បន ឯវំ យសោ
ហាយេថ ភោគាបិ តស្ស ហាយេយ្យុំ យសោលទ្ធា
ខោ បនម្ហាកំ ភោគា អហមេវ ខោ បន ឯវំ
សមីបគតោ សមានោ អទិស្វា វ សមណំ គោតមំ
និវត្តេយ្យំ តេន មំ អយំ បរិសា បរិភវេយ្យ ពាលោ

---

១ ម. មំ ចេវ ខោ បន ។ ម មមញ្ចេវ ខោ បន ។ ២ ម. ន បេស ។

យសរបស់បុគ្គលណា ដែលសាបសូន្យហើយ ភោគៈទាំងឡាយរបស់បុគ្គលនោះគប្បីសាបសូន្យដែរ ដ្បិតភោគៈទាំងឡាយរបស់យើង សុទ្ធតែបានដោយយស មួយទៀត បើព្រះសមណគោតម សួរប្រស្នានឹងអាត្មាអញ ។ មុខជានឹងធ្វើព្រះទ័យរបស់ព្រះអង្គ ឲ្យត្រេកអរដោយបញ្ហា-វេយ្យាករណ៍នោះមិនបានទេ បើព្រះសមណគោតម ពោលនឹងអាត្មាអញក្នុងប្រស្នានោះ យ៉ាងនេះថា ម្នាលព្រាហ្មណ៍ ប្រស្នានុះ អ្នកមិនត្រូវឆ្លើយយ៉ាងនេះទេ ម្នាលព្រាហ្មណ៍ ធម្មតាប្រស្នាបែបនុះ គេគួរឆ្លើយយ៉ាងនេះវិញទេតើ (បើដូច្នេះ) បរិសទ្យនេះមុខជានឹងមើលងាយអាត្មាអញ ដោយហេតុនោះ ថា សោណទណ្ឌព្រាហ្មណ៍ ជាមនុស្សល្ងង់ខ្លៅ មិនឈ្លាសវៃ មិនអាចដើម្បីធ្វើព្រះទ័យ របស់ព្រះសមណគោតម ឲ្យត្រេកអរដោយបញ្ហាវេយ្យាករណ៍ទេ បរិសទ្យនេះ បើមើលងាយបុគ្គលណាហើយ យសរបស់បុគ្គលនោះគប្បីសាបសូន្យ យសរបស់បុគ្គលណាសាបសូន្យហើយ ភោគៈទាំងឡាយរបស់បុគ្គលនោះ ក៏គប្បីសាបសូន្យដែរ ដ្បិតភោគៈទាំងឡាយរបស់យើង សុទ្ធតែបានដោយយស មួយវិញទៀត បើអាត្មាអញបានទៅដល់ទីជិតយ៉ាងនេះហើយ តែមិនទាន់បានឃើញព្រះសមណគោ-តមនៅឡើយ ក៏ស្រាប់តែត្រឡប់មកវិញ បរិសទ្យនេះមុខជានឹងមើលងាយ

សោណទណ្ឌោ ព្រាហ្មណោ អព្យត្តោ មានថទ្ធោ កឹតោ នោ វិសហិ សមណំ គោតមំ ឧស្សហាយ ឧបសង្កមិតុំ តាវញ្ហិ នាម ឃរំ សមីបគតោ សមានោ អធិស្វា សមណំ គោតមំ និវត្តិស្សតីតិ យំ ខោ បនាយំ បរិសា បរិភវេយ្យ យសោបិ តស្ស ហាយេថ យស្ស ខោ បន យសោ ហាយេថ ភោគាបិ តស្ស ហាយេយ្យុំ យសោលទ្ធា ខោ បនម្ហាកំ ភោគាតិ ។

(១៨៤) អថខោ សោណទណ្ឌោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ចម្បេយ្យកាបិ ខោ ព្រាហ្មណគហបតិកា អប្បេកច្ចេ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិំសុ អប្បេកច្ចេ ភគវតា សទ្ធឹ សម្មោទិំសុ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ

អាត្មាអញ ដោយហេតុនោះ ថា សោណទណ្ឌព្រាហ្មណ៍ជាមនុស្សល្ងង់ខ្លៅ មិនឈ្លាសវៃ មានមានះរឹងត្អឹង ខ្លាច មិនហ៊ានចូលទៅគាល់ព្រះសមណគោតមទេ មិនសមបើសោណទណ្ឌព្រាហ្មណ៍ ចូលមកដល់ទីជិតយ៉ាងនេះហើយ មិនទាន់បានឃើញព្រះសមណគោតមនៅឡើយ ក៏ស្រាប់តែត្រឡប់មកវិញសោះ បរិសទ្យនេះ បើមើលងាយបុគ្គលណាហើយ យសរបស់បុគ្គលនោះគប្បីសាបសូន្យ យសរបស់បុគ្គលណាសាបសូន្យហើយ ភោគៈទាំងឡាយរបស់បុគ្គលនោះ ក៏គប្បីសាបសូន្យដែរ ដ្បិតភោគៈទាំងឡាយរបស់យើង សុទ្ធតែបានដោយយស ។

(១៨៤) លំដាប់នោះ សោណទណ្ឌព្រាហ្មណ៍ ដើរចូលសំដៅទៅត្រង់ទីដែលព្រះមានព្រះភាគគង់ លុះចូលទៅដល់ហើយ ក៏ពោលពាក្យពក់ទាក់ សំណេះសំណាល ទៅរកព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹក ល្មមឲ្យកើតសេចក្តីស្និទ្ធស្នាលហើយ ក៏អង្គុយក្នុងទីដ៏សមគួរ ។ ចំណែកខាងព្រាហ្មណ៍គហបតីទាំងឡាយអ្នកក្រុងចម្បា ពួកខ្លះក្រាបថ្វាយបង្គំព្រះមានព្រះភាគហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះពោលពាក្យពក់ទាក់សំណេះសំណាលទៅរកព្រះមានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ នឹងពាក្យដែលគួររលឹកល្មមឲ្យកើតសេចក្តីស្និទ្ធស្នាលហើយ ក៏អង្គុយក្នុងទីដ៏សមគួរ

និសីទឹសុ អប្បេកច្ចេ យេន ភគវា តេនញ្ជលិម្បណា-
មេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ នាមគោត្តំ
សាវេត្វា ឯកមន្តំ និសីទឹសុ អប្បេកច្ចេ តុណ្ហីភូតា
ឯកមន្តំ និសីទឹសុ ។ តត្រ សុទំ សោណទណ្ឌោ
ព្រាហ្មណោ ឯតទេវ(១) ពហុលមនុវិតក្កេន្តោ និសិន្នោ
ហោតិ អហញ្ចេវ ខោ បន សមណំ គោតមំ បញ្ហំ
បុច្ឆេយ្យំ តត្រ ចេ មំ សមណោ គោតមោ ឯវំ វទេយ្យ
ន ខោ ឯស ព្រាហ្មណ បញ្ហោ ឯវំ បុច្ឆិតព្ពោ ឯវំ
នាមេស ព្រាហ្មណ បញ្ហោ បុច្ឆិតព្ពោតិ តេន មំ អយំ
បរិសា បរិភវេយ្យ ពាលោ សោណទណ្ឌោ ព្រាហ្មណោ
អព្យត្តោ នាសក្ខិ សមណំ គោតមំ យោនិសោ បញ្ហំ
បុច្ឆិតុន្តិ យំ ខោ បនាយំ បរិសា បរិភវេយ្យ យសោបិ
តស្ស ហាយេថ យស្ស ខោ បន យសោ ហាយេថ
ភោគាបិ តស្ស ហាយេយ្យុំ យសោលទ្ធា ខោ បនម្ហាកំ
ភោគា មញ្ចេវ ខោ បន សមណោ គោតមោ

១ ឱ. ឯតទេវាតិ ន ទិស្សតិ ។

ពួកខ្លះប្រណម្យអញ្ជលី ឆ្ពោះទៅរកព្រះមានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះប្រកាសនាមនិងគោត្រ (របស់ខ្លួន) ហើយអង្គុយក្នុងទីដ៏សមគួរ ពួកខ្លះអង្គុយស្ងៀម ក្នុងទីដ៏សមគួរ ។ សោណទណ្ឌព្រាហ្មណ៍អង្គុយត្រិះរិះ នូវហេតុមានប្រមាណច្រើន ក្នុងទីនោះ ដូច្នេះថា ប្រសិនបើអាត្មាអញ សួរប្រស្នានឹងព្រះសមណគោតម បើព្រះសមណគោតមពោលយ៉ាងនេះនឹងអាត្មាអញ ក្នុងប្រស្នានោះ ថា ម្នាលព្រាហ្មណ៍ ប្រស្នានុ៎ះ អ្នកមិនត្រូវសួរយ៉ាងនេះទេ ម្នាលព្រាហ្មណ៍ ធម្មតាប្រស្នាបែបនុ៎ះ គេគួរសួរយ៉ាងនេះវិញទេតើ បរិសទ្យនេះមុខជានឹងមើលងាយអាត្មាអញ ដោយហេតុនោះ ថា សោណទណ្ឌព្រាហ្មណ៍ជាមនុស្សល្ងង់ខ្លៅ មិនឈ្លាសវៃ មិនអាចនឹងសួរប្រស្នានឹងព្រះសមណគោតម ដោយយោ-បល់បាន បរិសទ្យនេះ បើមើលងាយបុគ្គលណាហើយ យសរបស់បុគ្គលនោះគប្បីសាបសូន្យ យសរបស់បុគ្គលណាសាបសូន្យហើយ ភោគៈទាំងឡាយរបស់បុគ្គលនោះ ក៏គប្បីសាបសូន្យដែរ ដ្បិតភោគៈទាំងឡាយរបស់យើងសុទ្ធតែបានដោយយស មួយវិញទៀត បើព្រះសមណគោតម

បញ្ហំ បុច្ឆេយ្យ តស្ស ចាហំ បញ្ហស្ស វេយ្យាករណេន
ចិត្តំ ន អារាធេយ្យំ តត្រ មំ សមណោ គោតមោ
ឯវំ វទេយ្យ ន ខោ ឯស ព្រាហ្មណ បញ្ហោ ឯវំ ព្យា-
កាតព្វោ ឯវំ នាមេស ព្រាហ្មណ បញ្ហោ ព្យាកា-
តព្វោតិ តេន មំ អយំ បរិសា បរិភវេយ្យ ពាលោ
សោណទណ្ឌោ ព្រាហ្មណោ អព្យត្តោ នាសក្ខិ សម-
ណស្ស គោតមស្ស បញ្ហស្ស វេយ្យាករណេន ចិត្តំ
អារាធេតុន្តិ យំ ខោ បនាយំ បរិសា បរិភវេយ្យ
យសោបិ តស្ស ហាយេថ យស្ស ខោ បន យសោ
ហាយេថ ភោគាបិ តស្ស ហាយេយ្យុំ យសោលទ្ធា
ខោ បនម្ហាកំ ភោគា អហោ វត មំ សមណោ
គោតមោ សកេ អាចរិយកេ តេវិជ្ជកេ មំ បញ្ហំ
បុច្ឆេយ្យ អទ្ធា វតស្សាហំ ចិត្តំ អារាធេយ្យំ បញ្ហស្ស
វេយ្យាករណេនាតិ ។

សោណទណ្ឌសូត្រ សេចក្តីត្រិះរិះរបស់សោណទណ្ឌព្រាហ្មណ៍

សួរប្រស្នានឹងអាត្មាអញ ។ មុខជាធ្វើព្រះទ័យរបស់ព្រះអង្គឲ្យត្រេកអរ ដោយបញ្ហាវេយ្យាករណ៍មិនបានឡើយ បើព្រះសមណគោតមពោលនឹងអាត្មាអញ ក្នុងប្រស្នានោះថា ម្នាលព្រាហ្មណ៍ ប្រស្នានុ៎ះអ្នកមិនត្រូវឆ្លើយយ៉ាងនេះទេ ម្នាលព្រាហ្មណ៍ ធម្មតាប្រស្នាបែបនុ៎ះ គេគួរឆ្លើយយ៉ាងនេះវិញទេតើ បរិសទ្យនេះមុខជានឹងមើលងាយអាត្មាអញ ដោយហេតុនោះថា សោណទណ្ឌព្រាហ្មណ៍ ជាមនុស្សល្ងង់ខ្លៅ មិនឈ្លាសវៃ មិនអាចធ្វើព្រះទ័យរបស់ព្រះសមណគោតមឲ្យត្រេកអរ ដោយបញ្ហាវេយ្យាករណ៍បាន បរិសទ្យនេះ បើមើលងាយបុគ្គលណាហើយ យសរបស់បុគ្គលនោះគប្បីសាបសូន្យ យសរបស់បុគ្គលណាសាបសូន្យហើយ ភោគៈទាំងឡាយរបស់បុគ្គលនោះ គប្បីសាបសូន្យដែរ ដ្បិតភោគៈទាំងឡាយរបស់យើង សុទ្ធតែបានដោយយស ។ ធ្វើម្តេចហ្ន៎ នឹងបានព្រះសមណគោតមសួរប្រស្នានឹងអាត្មាអញ ត្រង់ត្រៃវេទដែលអាត្មាអញបានសិក្សាមកអំពីសំណាក់អាចារ្យរបស់ខ្លួនអេះ អាត្មាអញមុខជានឹងធ្វើព្រះទ័យនៃព្រះសមណគោតម ឲ្យត្រេកអរដោយបញ្ហាវេយ្យាករណ៍បានដោយពិត ។

(១៨៩) អថខោ ភគវតោ សោណទណ្ឌស្ស ព្រាហ្មណស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ ឯតទហោសិ វិហញ្ញតិ ខោ អយំ សោណទណ្ឌោ ព្រាហ្មណោ សកេន ចិត្តេន យន្នូនាហំ សោណទណ្ឌំ ព្រាហ្មណំ សកេ អាចរិយកេ តេវិជ្ជកេ បញ្ហំ បុច្ឆេយ្យន្តិ ។ អថខោ ភគវា សោណទណ្ឌំ ព្រាហ្មណំ ឯតទវោច កតីហិ បន ព្រាហ្មណ អង្គេហិ សមន្នាគតំ ព្រាហ្មណា ព្រាហ្មណំ បញ្ញាបេន្តិ ព្រាហ្មណោស្មីតិ ច វទមានោ សម្មា វទេយ្យ ន ច បន មុសាវាទំ អាបជ្ជេយ្យាតិ ។ អថខោ សោណទណ្ឌស្ស ព្រាហ្មណស្ស ឯតទហោសិ យំ វត នោ អហោសិ ឥច្ឆិតំ យំ អាកង្ខិតំ យំ អធិប្បេតំ យំ អភិបត្ថិតំ អហោ វត មំ សមណោ គោតមោ សកេ អាចរិយកេ តេវិជ្ជកេ បញ្ហំ បុច្ឆេយ្យ អទ្ធា វតស្សាហំ ចិត្តំ អារាធេយ្យំ បញ្ហស្ស វេយ្យាករណេនាតិ

[១៨៥] គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបសេចក្តីត្រិះរិះក្នុងចិត្ត របស់សោណទណ្ឌព្រាហ្មណ៍ ដោយព្រះហឫទ័យហើយ ក៏ទ្រង់ព្រះតម្រិះ យ៉ាងនេះថា សោណទណ្ឌព្រាហ្មណ៍នេះចង្អៀតចង្អល់ ព្រោះតែគំនិត របស់ខ្លួន បើដូច្នោះ គួរតថាគត សួរប្រស្នានឹងសោណទណ្ឌព្រាហ្មណ៍ ត្រង់ត្រៃវេទ ដែលគាត់បានសិក្សា មកអំពីសំណាក់អាចារ្យ របស់ខ្លួន (ឲ្យត្រូវតាមបំណងចុះ) ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់ ត្រាស់សួរសោណទណ្ឌព្រាហ្មណ៍ថា ម្នាលព្រាហ្មណ៍ ពួកព្រាហ្មណ៍ បញ្ញត្តមនុស្សប្រកបដោយអង្គប៉ុន្មាន ថាជាព្រាហ្មណ៍ (មនុស្សដែល ប្រកបដោយអង្គប៉ុន្មាន) កាលបើពោលថា ខ្ញុំជាព្រាហ្មណ៍ដូច្នេះ ឈ្មោះថា និយាយដោយប្រពៃផង មិនត្រូវមុសាវាទផង ។ គ្រានោះ សោណទណ្ឌព្រាហ្មណ៍ មានសេចក្តីត្រិះរិះ ដូច្នេះថា នុ៎ហ្ន៎ អាត្មាអញ មានសេចក្តីប្រាថ្នា សេចក្តីប៉ុនប៉ង សេចក្តីពេញចិត្ត សេចក្តីប្រុង ទុកណា រួមមកហើយថា នុ៎ ធ្វើដូចម្តេចហ្ន៎ នឹងបានព្រះសមណ-គោតម សួរប្រស្នានឹងអាត្មាអញ ត្រង់ត្រៃវេទ ដែលអាត្មាអញបាន សិក្សាមក អំពីសំណាក់អាចារ្យរបស់ខ្លួន អាត្មាអញនឹងធ្វើព្រះទ័យនៃ ព្រះសមណគោតមឲ្យត្រេកអរ ដោយបញ្ហាវេយ្យាករណ៍បានដោយពិត

តត្រ ចេ មំ សមណោ គោតមោ សកេ អាចរិយកេ តេវិជ្ជកេ បញ្ហំ បុច្ឆតិ អទ្ធា វ តស្សាហំ ចិត្តំ អារាធេស្សាមិ បញ្ហស្ស វេយ្យាករណេនាតិ ។

(១៨៦) អថខោ សោណទណ្ឌោ ព្រាហ្មណោ អព្ភុន្នាមេត្វា កាយំ អនុវិលោកេត្វា បរិសំ ភគវន្តំ ឯតទវោច បញ្ចហិ ភោ គោតម អង្គេហិ សមន្នាគតំ ព្រាហ្មណា ព្រាហ្មណំ បញ្ញាបេន្តិ ព្រាហ្មណោស្មីតិ ច វទមានោ សម្មា វទេយ្យ ន ច បន មុសាវាទំ អាបជ្ជេយ្យ កតមេហិ បញ្ចហិ ឥធ ភោ គោតម(១) ព្រាហ្មណោ ឧភតោ សុជាតោ ហោតិ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន អជ្ឈាយកោ ច(២) ហោតិ មន្តធរោ តិណ្ណំ វេទានំ បារគូ សនិឃណ្ឌុកេដុភានំ សាក្ខរប្បភេទានំ ឥតិហាសបញ្ចមានំ បទកោ វេយ្យាករណោ លោកាយតមហាបុរិសលក្ខណេសុ អនវយោ អភិរូបោ ច(៣) ហោតិ

១ ឱ. គោតមាតិ ន ទិស្សតិ ។ ២-៣. ឱ ម. ចសទ្ទោ ន ទិស្សតិ ។

ក៏ឥឡូវនេះ ព្រះសមណគោតម សួរប្រស្នានឹងអាត្មាអញត្រង់ត្រៃវេទ ដែលអាត្មាអញបានសិក្សាមក អំពីសំណាក់អាចារ្យរបស់ខ្លួន ត្រូវចំសេចក្តីប្រាថ្នាអញនោះហើយ អាត្មាអញមុខជាធ្វើព្រះទ័យ នៃព្រះសមណគោតម ឲ្យត្រេកអរដោយបញ្ហាវេយ្យាករណ៍ បានដោយពិត ៗ

(១៨៦) លំដាប់នោះ សោណទណ្ឌព្រាហ្មណ៍ ក៏បង្ហើបខ្លួនអើតមើលបរិសទ្យ ហើយក្រាបបង្គំទូលព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ពួកព្រាហ្មណ៍ រមែងបញ្ញត្តមនុស្សដែលប្រកបដោយអង្គ ៥ ថាជាព្រាហ្មណ៍ ( មនុស្សដែលប្រកបដោយអង្គ ៥ នោះ) កាលបើពោលថា ខ្ញុំជាព្រាហ្មណ៍ដូច្នេះ ឈ្មោះថា និយាយដោយប្រពៃផង មិនត្រូវមុសាវាទផង អង្គទាំង ៥ នោះតើដូចម្តេច បពិត្រព្រះគោតមដ៏ចំរើន ព្រាហ្មណ៍ក្នុងលោកនេះ មានជាតិដ៏ល្អទាំងពីរចំណែក គឺចំណែកខាងមាតានឹងចំណែកខាងបិតា កើតអំពីផ្ទៃដ៏បរិសុទ្ធស្អាត ដរាបអំពីតំណនៃជីដូនជីតាជាគំរប់ ៧ មក មិនដែលមាននរណា ពោលទោសតិះដៀល ដោយពោលដល់ជាតិកំណើត ១ ជាអ្នករាយមន្ត ចេះចាំមន្ត ជាអ្នកដល់នូវត្រើយនៃត្រៃវេទ ព្រមទាំងគម្ពីរនិឃណ្ឌុ គម្ពីរកេតុភៈ អក្ខរប្បភេទគឺសិក្ខានឹងនិរុត្តិ ដែលមានគម្ពីរឥតិហាសៈជាគំរប់ ៥ ជាអ្នកស្គាល់បទនឹងវេយ្យាករណ៍ ជាអ្នកមិនខុនថយគឺស្ទាត់ជំនាញ ក្នុងលោកាយតសាស្ត្រ នឹងមហាបុរិសលក្ខណព្យាករណសាស្ត្រ ១ ជាអ្នកមានរូបល្អ

ទស្សនីយោ បាសាទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ ព្រហ្មវណ្ណី ព្រហ្មវច្ឆសី អខុទ្ទាវកាសោ ទស្សនាយ សីលវា ច ហោតិ វុឌ្ឍសីលី វុឌ្ឍសីលេន សមន្នាគតោ បណ្ឌិតោ ច ហោតិ មេធាវី បឋមោ វា ទុតិយោ វា សុជំ(១) បគ្គណ្ហន្តានំ ឥមេហិ ខោ ភោ គោតម បញ្ចហិ អង្គេហិ សមន្នាគតំ ព្រាហ្មណា ព្រាហ្មណំ បញ្ញាបេន្តិ ព្រាហ្មណោស្មីតិ ច វទមានោ សម្មា វទេយ្យ ន ច បន មុសាវាទំ អាបជ្ជេយ្យាតិ ។

(១៨៧) ឥមេសំ បន ព្រាហ្មណ បញ្ចន្នំ អង្គានំ សក្កា ឯកំ អង្គំ ឋបយិត្វា ចតូហិ អង្គេហិ សមន្នាគតំ ព្រាហ្មណំ បញ្ញាបេតុំ ព្រាហ្មណោស្មីតិ ច វទមានោ សម្មា វទេយ្យ ន ច បន មុសាវាទំ អាបជ្ជេយ្យាតិ ។ សក្កា ភោ គោតម ឥមេសំ ហិ ភោ គោតម បញ្ចន្នំ អង្គានំ វណ្ណំ ឋបយាម កឹ ហិ វណ្ណោ ករិស្សតិ យតោ ខោ ភោ គោតម

---

១ ម. សុជំ ។

គួរឲ្យពិតពិលរមិលមើល គួរឲ្យជ្រះថ្លា ប្រកបដោយសម្បុរដ៏ស្អាតក្រៃលែង មានសម្បុរដ៏ប្រសើរ មានសរីរៈស្រដៀងនឹងព្រហ្ម មានសណ្ឋានកាយគួរឲ្យចង់មើលមិនលែង ១ ជាអ្នកមានសីល មានសីលដ៏ចំរើន ប្រកបដោយសីលដ៏ចំរើន ១ ជាអ្នកប្រាជ្ញមានប្រាជ្ញា ជាបុគ្គលទី ១ ឬទី ២ របស់ពួកព្រាហ្មណ៍ អ្នកទទួលគ្រឿងបូជា ១ បពិត្រព្រះគោតមដ៏ចំរើន ពួកព្រាហ្មណ៍ រមែងបញ្ញត្តមនុស្សដែលប្រកបដោយអង្គទាំង ៥ នេះឯង ថាជាព្រាហ្មណ៍ (មនុស្សដែលប្រកបដោយអង្គ ៥នេះ) កាលបើពោលថា ខ្ញុំជាព្រាហ្មណ៍ដូច្នេះ ឈ្មោះថា និយាយដោយប្រពៃផង មិនត្រូវមុសាវាទផង ។

(១៨៧) ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បណ្តាអង្គទាំង៥ប្រការនេះ អ្នកអាចលើកអង្គ ១ ចេញ ហើយបញ្ញត្តមនុស្សដែលប្រកបដោយអង្គត្រឹមតែ ៤ ថាជាព្រាហ្មណ៍វិញ (មនុស្សដែលប្រកបដោយអង្គ ៤ នោះ) កាលបើពោលថា ខ្ញុំជាព្រាហ្មណ៍ដូច្នេះ ឈ្មោះថា និយាយដោយប្រពៃផង មិនត្រូវមុសាវាទផង តើបានឬទេ ។ សោណទណ្ឌព្រាហ្មណ៍ទូលថា បពិត្រព្រះគោតមដ៏ចំរើន អាចបញ្ញត្តបាន បពិត្រព្រះគោតមដ៏ចំរើន ក៏បណ្តាអង្គទាំង៥ យើងលើកអង្គគឺសម្បុរចេញ ដ្បិតសម្បុរនឹងយកជាការពុំបាន បពិត្រព្រះគោតមដ៏ចំរើន

ព្រាហ្មណោ ឧភតោ សុជាតោ ហោតិ មាតិតោ ច បិតិតោ ច សំសុទ្ធគហណិកោ យាវ សត្តមា បិតា-មហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន អជ្ឈាយ-កោ ច ហោតិ មន្តធរោ តិណ្ណំ វេទានំ បារគូ សនិឃ-ណ្ឌុកេដុភានំ សាក្ខរប្បភេទានំ ឥតិហាសបញ្ចមានំ បទកោ វេយ្យាករណោ លោកាយតមហាបុរិសលក្ខ-ណេសុ អនវយោ សីលវា ច ហោតិ វុឌ្ឍសីលី វុឌ្ឍសី-លេន សមន្នាគតោ បណ្ឌិតោ ច ហោតិ មេធាវី បឋមោ វា ទុតិយោ វា ស្រុជំ(១) បគ្គណ្ហន្តានំ ឥមេហិ ខោ ភោ គោតម ចតូហិ អង្គេហិ សមន្នាគតំ ព្រាហ្មណា ព្រាហ្មណំ បញ្ញបេន្តិ ព្រាហ្មណោស្មីតិ ច វទមានោ សម្មា វទេយ្យ ន ច បន មុសាវាទំ អាបជ្ជេយ្យាតិ ។

(១៨៨) ឥមេសំ បន ព្រាហ្មណ ចតុន្នំ អង្គានំ សក្កា ឯកំ អង្គំ ឋបយិត្វា តីហិ អង្គេហិ សមន្នាគតំ ព្រាហ្មណំ បញ្ញបេតុំ ព្រាហ្មណោស្មីតិ ច វទមានោ

---

១ ឱ. ម. សុជំ ។

ព្រាហ្មណ៍ (ដែលប្រកប ដោយអង្គត្រឹមតែ ៤ នោះ) គឺជាអ្នកមានជាតិដ៏ល្អ ទាំងពីរចំណែក គឺចំណែកខាងមាតា និងចំណែកខាងបិតា កើតអំពីផ្ទៃដ៏បរិសុទ្ធស្អាត ដរាបអំពីតំណនៃជីដូនជីតាជាគំរប់ ៧ មក មិនដែលមាននរណា ពោលទោសតិះដៀល ដោយពោលដល់ជាតិកំណើតបាន ១ ជាអ្នករាយមន្ត ចេះចាំមន្ត ជាអ្នកដល់នូវត្រើយនៃត្រៃវេទព្រមទាំងគម្ពីរនិឃណ្ឌុ គម្ពីរកេតុភៈ ព្រមទាំងអក្ខរប្បភេទគឺសិក្ខានិងនិរុត្តិ ដែលមានគម្ពីរឥតិហាសៈជាគំរប់ ៥ ជាអ្នកស្គាល់បទនិងវេយ្យាករណ៍ ជាអ្នកមិនខ្វះថយ គឺស្ទាត់ជំនាញក្នុងលោកាយតសាស្ត្រ និងមហាបុរិសលក្ខណ-ព្យាករណសាស្ត្រ ១ ជាអ្នកមានសីល មានសីលដ៏ចំរើន ប្រកបដោយសីលដ៏ចំរើន ១ ជាអ្នកប្រាជ្ញមានប្រាជ្ញា ជាបុគ្គលទី ១ ឬទី ២ របស់ពួកព្រាហ្មណ៍អ្នកទទួលនូវគ្រឿងបូជា ១ បពិត្រព្រះគោតមដ៏ចំរើន ពួកព្រាហ្មណ៍បញ្ញត្តមនុស្ស ដែលប្រកបដោយអង្គត្រឹមតែ ៤ នេះឯង ថាជាព្រាហ្មណ៍ (មនុស្សដែលប្រកបដោយអង្គ៤នេះ) កាលបើពោលថា ខ្ញុំជាព្រាហ្មណ៍ដូច្នេះ ឈ្មោះថា និយាយដោយប្រពៃផង មិនត្រូវមុសាវាទផង ។

(១៨៨) ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលព្រាហ្មណ៍ បណ្តាអង្គទាំង ៤ នេះ អ្នកអាចលើកអង្គ ១ចេញ ហើយបញ្ញត្តមនុស្ស ដែលប្រកប ដោយអង្គត្រឹមតែ ៣ ថាជាព្រាហ្មណ៍វិញ (មនុស្ស

សម្មា វទេយ្យ ន ច បន មុសាវាទំ អាបជ្ជេយ្យាតិ ។ សក្កា ភោ គោតម ឥមេសំ ហិ ភោ គោតម ចតុន្នំ អង្គានំ មន្តេ ឋបយាម កឹ ហិ មន្តា ករិស្សន្តិ យតោ ខោ ភោ គោតម[១] ព្រាហ្មណោ ឧភតោ សុជាតោ ហោតិ មាតិតោ ច បិតិតោ ច សំសុទ្ធគ-ហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន សីលវា ច ហោតិ វុឌ្ឍសីលី វុឌ្ឍសីលេន សមន្នាគតោ បណ្ឌិតោ ច ហោតិ មេធាវី បឋមោ វា ទុតិយោ វា សុជំ[២] បគ្គណ្ហន្តានំ ឥមេ-ហិ ខោ ភោ គោតម ទ្វីហិ អង្គេហិ សមន្នាគតំ ព្រាហ្មណា ព្រាហ្មណំ បញ្ញាបេន្តិ ព្រាហ្មណោស្មីតិ ច វទមានោ សម្មា វទេយ្យ ន ច បន មុសាវាទំ អាបជ្ជេយ្យាតិ ។

---

១ ឱ. គោតមាតិ ន ទិស្សតិ ។ ២ ឱ. ម. សុជំ ។

ដែលប្រកបដោយអង្គ៣នោះ) កាលបើពោលថា ខ្ញុំជាព្រាហ្មណ៍ដូច្នេះ ឈ្មោះថា និយាយដោយប្រពៃផង មិនត្រូវមុសាវាទផង តើបានឬទេ ។ សោណទណ្ឌព្រាហ្មណ៍ទូលថា បពិត្រព្រះគោតមដ៏ចំរើន អាចបញ្ញត្តបាន បពិត្រព្រះគោតមដ៏ចំរើន ក៏បណ្ដាអង្គទាំង ៤ នេះ យើងលើកអង្គ គឺមន្តចេញ ដ្បិតមន្តនឹងធ្វើអ្វីកើត បពិត្រព្រះគោតមដ៏ចំរើន ព្រាហ្មណ៍ (ដែលប្រកបដោយអង្គត្រឹមតែ ៣ នោះ) គឺជាអ្នកមានជាតិដ៏ល្អទាំងពីរចំណែក គឺចំណែកខាងមាតានិងចំណែកខាងបិតា កើតអំពីផ្ទៃដ៏បរិសុទ្ធស្អាត ដរាបអំពីតំណវៃដ៏ដូនជីតាជាគំរប់ ៧ មក មិនដែលមានគេណា ពោលទោសតិះដៀល ដោយពោលដល់ជាតិកំណើតបាន ១ ជាអ្នកមានសីល មានសីលដ៏ចំរើន ប្រកបដោយសីលដ៏ចំរើន ១ ជាអ្នកប្រាជ្ញមានប្រាជ្ញា ជាបុគ្គលទី ១ ឬទី ២ របស់ពួកព្រាហ្មណ៍ អ្នកទទួលគ្រឿងបូជា ១ បពិត្រព្រះគោតមដ៏ចំរើន ពួកព្រាហ្មណ៍ រមែងបញ្ញត្តមនុស្សដែលប្រកបដោយអង្គត្រឹមតែ ៣ នេះឯង ថាជាព្រាហ្មណ៍ (មនុស្សដែលប្រកបដោយអង្គ ៣ នេះ) កាលបើពោលថា ខ្ញុំជាព្រាហ្មណ៍ដូច្នេះ ឈ្មោះថា និយាយដោយប្រពៃផង មិនត្រូវមុសាវាទផង ។

(១៨៩) ឥមេសំ បន ព្រាហ្មណ តិណ្ណំ អង្គានំ សក្កា ឯកំ អង្គំ ឋបយិត្វា ទ្វីហិ អង្គេហិ សមន្នាគតំ ព្រាហ្មណំ បញ្ញបេតុំ ព្រាហ្មណោស្មីតិ ច វទមានោ សម្មា វទេយ្យ ន ច បន មុសាវាទំ អាបជ្ជេយ្យាតិ ។ សក្កា ភោ គោតម ឥមេសំ ហិ ភោ គោតម តិណ្ណំ អង្គានំ ជាតឹ ឋបយាម កឹ ហិ ជាតិ ករិស្សតិ យតោ ខោ ភោ គោតម ព្រាហ្មណោ សីលវា ច ហោតិ វុឌ្ឍសីលី វុឌ្ឍសីលេន សមន្នាគតោ បណ្ឌិតោ ច ហោតិ មេធាវី បឋមោ វា ទុតិយោ វា សុជំ បគ្គណ្ហន្តានំ ឥមេហិ ខោ ភោ គោតម ទ្វីហិ អង្គេហិ សមន្នាគតំ ព្រាហ្មណា ព្រាហ្មណំ បញ្ញបេន្តិ ព្រាហ្មណោស្មីតិ ច វទមានោ សម្មា វទេយ្យ ន ច បន មុសាវាទំ អាបជ្ជេយ្យាតិ ។

(១៨៩) ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលព្រាហ្មណ៍ បណ្ដាអង្គទាំង ៣ នេះ អ្នកអាចលើកអង្គ ១ ចេញ ហើយបញ្ញត្តមនុស្ស ដែលប្រកបដោយអង្គត្រឹមតែ ២ ថាជាព្រាហ្មណ៍វិញ (មនុស្សប្រកបដោយអង្គ ២ នោះ) កាលបើពោលថា ខ្ញុំជាព្រាហ្មណ៍ ដូច្នេះ ឈ្មោះថា និយាយដោយប្រពៃផង មិនត្រូវមុសាវាទផង តើបានឬទេ ។ សោណទណ្ឌព្រាហ្មណ៍ទូលថា បពិត្រព្រះគោតមដ៏ចំរើន អាចបញ្ញត្តបាន បពិត្រព្រះគោតមដ៏ចំរើន ក៏បណ្ដាអង្គទាំង ៣ នេះ យើងលើកអង្គ គឺជាតិចេញ ដ្បិតជាតិនឹងធ្វើអ្វីកើត បពិត្រព្រះគោតមដ៏ចំរើន ព្រាហ្មណ៍ (ដែលប្រកបដោយអង្គត្រឹមតែ ២ នោះ) គឺជាអ្នកមានសីល មានសីលដ៏ចំរើន ប្រកបដោយសីលដ៏ចំរើន ១ ជាអ្នកប្រាជ្ញមានប្រាជ្ញា ជាបុគ្គលទី ១ ឬទី ២ របស់ពួកព្រាហ្មណ៍ អ្នកទទួលគ្រឿងបូជា ១ បពិត្រព្រះគោតមដ៏ចំរើន ពួកព្រាហ្មណ៍ រមែងបញ្ញត្តមនុស្សដែលប្រកបដោយអង្គ ត្រឹមតែ ២ នេះឯង ថាជាព្រាហ្មណ៍ (មនុស្សដែលប្រកបដោយអង្គ ២ នេះ) កាលបើពោលថា ខ្ញុំជាព្រាហ្មណ៍ដូច្នេះ ឈ្មោះថា និយាយដោយប្រពៃផង មិនត្រូវមុសាវាទផង ។

(១៩០) ឯវំ វុត្តេ តេ ព្រាហ្មណា សោណទណ្ឌំ ព្រាហ្មណំ ឯតទវោចុំ មា ភវំ សោណទណ្ឌោ ឯវំ អវច មា ភវំ សោណទណ្ឌោ ឯវំ អវច អបវទតិ ភវំ សោណទណ្ឌោ វណ្ណំ អបវទតិ មន្តេ អបវទតិ ជាតឹ ឯកំសេន ភវំ សោណទណ្ឌោ សមណស្សយេវ(១) គោតមស្ស វាទំ អនុបក្ខន្ទតីតិ ។ អថខោ ភគវា តេ ព្រាហ្មណេ ឯតទវោច សចេ ខោ តុម្ហាកំ ព្រាហ្មណានំ ឯវំ ហោតិ អប្បស្សុតោ ច សោណទណ្ឌោ ព្រាហ្មណោ អកល្យាណវាក្ករណោ ច សោណទណ្ឌោ ព្រាហ្មណោ ទុប្បញ្ញោ ច សោណទណ្ឌោ ព្រាហ្មណោ ន ច បហោតិ សោណទណ្ឌោ ព្រាហ្មណោ សមណេន គោតមេន សទ្ធឹ អស្មឹ វចនេ បតិមន្តេតុំ តិដ្ឋតុ សោណទណ្ឌោ ព្រាហ្មណោ តុម្ហេ មយា សទ្ធឹ មន្តេថ សចេ បន តុម្ហាកំ ព្រាហ្មណានំ ឯវំ ហោតិ ពហុស្សុតោ ច សោណទណ្ឌោ ព្រាហ្មណោ កល្យាណវាក្ករណោ ច សោណទណ្ឌោ ព្រាហ្មណោ

១ ឱ. សមណស្សេវ ។ ម. សមណស្ស ។

[១៩០] កាលដែលសោណទណ្ឌព្រាហ្មណ៍ ពោលយ៉ាងនេះហើយ ពួកព្រាហ្មណ៍ទាំងនោះ ក៏បាននិយាយនឹងសោណទណ្ឌព្រាហ្មណ៍ដូច្នេះថា សោណទណ្ឌដ៏ចំរើន កុំនិយាយយ៉ាងនេះ សោណទណ្ឌដ៏ចំរើន កុំនិយាយយ៉ាងនេះឡើយ សោណទណ្ឌដ៏ចំរើន និយាយបង្អាប់សម្បុរ និយាយបង្អាប់មន្ត្រ និយាយបង្អាប់ជាតិ សោណទណ្ឌដ៏ចំរើន បណ្តោយតាមពាក្យ របស់ព្រះសមណគោតម ដោយចំណែកមួយហើយតើ ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ត្រាស់នឹងពួកព្រាហ្មណ៍ទាំងនោះដូច្នេះថា បើអ្នកទាំងឡាយជាព្រាហ្មណ៍មានសេចក្តីយល់ឃើញថា សោណទណ្ឌព្រាហ្មណ៍ ជាមនុស្សចេះដឹងតិចផង សោណទណ្ឌព្រាហ្មណ៍ ពោលពាក្យមិនពីរោះផង សោណទណ្ឌព្រាហ្មណ៍ជាអ្នកឥតប្រាជ្ញាផង សោណទណ្ឌព្រាហ្មណ៍ មិនល្មមនឹងនិយាយឆ្លើយឆ្លងពាក្យនេះ ជាមួយនឹងព្រះសមណគោតមបានផង សោណទណ្ឌព្រាហ្មណ៍ ចូរឈប់ចុះ អ្នកទាំងឡាយចូរនិយាយឆ្លើយឆ្លងជាមួយនឹងតថាគតវិញ តែបើអ្នកទាំងឡាយជាព្រាហ្មណ៍មានសេចក្តីយល់ឃើញយ៉ាងនេះថា សោណទណ្ឌព្រាហ្មណ៍ជាមនុស្សចេះដឹងច្រើនផង សោណទណ្ឌព្រាហ្មណ៍ ពោលពាក្យពីរោះផង

បណ្ឌិតោ ច សោណទណ្ឌោ ព្រាហ្មណោ បហោតិ ច សោណទណ្ឌោ ព្រាហ្មណោ សមណេន គោតមេន សទ្ធឹ អស្មឹ វចនេ បដិមន្តេតុំ តិដ្ឋថ តុម្ហេ សោណ-ទណ្ឌោ ព្រាហ្មណោ មយា សទ្ធឹ បដិមន្តេតូតិ ។

(១៩១) ឯវំ វុត្តេ សោណទណ្ឌោ ព្រាហ្មណោ ភ-គវន្តំ ឯតទវោច តិដ្ឋតុ ភវំ គោតមោ តុណ្ហី ភវំ គោត-មោ ហោតុ អហមេវ តេសំ សហធម្មេន បដិវចនំ ករិស្សាមីតិ ។ អថខោ សោណទណ្ឌោ(១) តេ ព្រាហ្ម-ណេ ឯតទវោច មា ភវន្តោ ឯវំ អវចុត្ថ មា ភវន្តោ ឯវំ អវចុត្ថ អបវទតិ ភវំ សោណទណ្ឌោ ព្រាហ្មណោ វណ្ណំ អបវទតិ មន្តេ អបវទតិ ជាតឹ ឯកំសេន ភវំ សោណទណ្ឌោ ព្រាហ្មណោ សមណស្សេវ គោតមស្ស វាទំ អនុបក្ខន្ទតីតិ នាហំ ភោ អបវទាមិ វណ្ណំ វា មន្តេ វា ជាតឹ វាតិ ។

---

១. ម. សោណទណ្ឌោ ព្រាហ្មណោ ។

សោណទណ្ឌព្រាហ្មណ៍ ជាអ្នកប្រាជ្ញផង សោណទណ្ឌព្រាហ្មណ៍ល្មមនឹងនិយាយឆ្លើយឆ្លងពាក្យនេះ ជាមួយនឹងព្រះសមណគោតមបានផង អ្នកទាំងឡាយ ចូរឈប់ចុះ ចូរឲ្យសោណទណ្ឌព្រាហ្មណ៍និយាយឆ្លើយឆ្លងជាមួយនឹងតថាគតវិញ ។

(១៩១) កាលដែលព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ សោណទណ្ឌព្រាហ្មណ៍ បានក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះថា សូមព្រះគោតមដ៏ចំរើន បង្អង់សិនចុះ សូមព្រះគោតមដ៏ចំរើន គង់ស្ងៀមចុះ ខ្ញុំព្រះអង្គនឹងឆ្លើយទូវពាក្យតបត ប្រកបដោយហេតុ ដល់ព្រាហ្មណ៍ទាំងនោះវិញ ។ លំដាប់នោះ សោណទណ្ឌព្រាហ្មណ៍បាននិយាយនឹងពួកព្រាហ្មណ៍ទាំងនោះដូច្នេះថា នែអ្នកទាំងឡាយដ៏ចំរើន អ្នកទាំងឡាយកុំពោលយ៉ាងនេះឡើយ នែអ្នកទាំងឡាយដ៏ចំរើន អ្នកទាំងឡាយកុំពោលយ៉ាងនេះថា សោណទណ្ឌព្រាហ្មណ៍ដ៏ចំរើន និយាយបង្អាប់សម្បុរ និយាយបង្អាប់មន្ត និយាយបង្អាប់ជាតិ សោណទណ្ឌព្រាហ្មណ៍ដ៏ចំរើនបណ្តោយតាមវាទៈរបស់ព្រះសមណគោតម ដោយចំណែកមួយដូច្នេះឡើយ ម្នាលអ្នកដ៏ចំរើនទាំងឡាយ ខ្ញុំមិនមែននិយាយបង្អាប់សម្បុរ ឬមន្តនឹងជាតិទេ ។

(១៩២) តេន ខោ បន សមយេន សោណទណ្ឌស្ស ព្រាហ្មណស្ស ភាគិនេយ្យោ អង្គកោ នាម មាណវកោ តស្សំ បរិសាយំ និសិន្នោ ហោតិ ។ អថខោ សោណទណ្ឌោ ព្រាហ្មណោ តេ ព្រាហ្មណេ ឯតទវោច បស្សន្តិ នោ ភោន្តោ ឥមំ អង្គកំ មាណវកំ អម្ហាកំ ភាគិនេយ្យន្តិ ។ ឯវំ ភោ ។ អង្គកោ ខោ ភោ មាណវកោ អភិរូបោ ទស្សនីយោ បាសាទិកោ បរមាយ វណ្ណបោក្ខរតាយ សមន្នាគតោ ព្រហ្មវណ្ណី ព្រហ្មវច្ឆសី អក្ខុទ្ទាវកាសោ ទស្សនាយ នាស្ស ឥមិស្សំ បរិសាយំ(១) សមសមោ អត្ថិ វណ្ណេន ឋបេត្វា សមណំ គោតមំ ។ អង្គកោ ខោ ភោ មាណវកោ អជ្ឈាយកោ មន្តធរោ តិណ្ណំ វេទានំ បារគូ សនិឃណ្ឌុកេដុភានំ សាក្ខរប្បភេទានំ ឥតិហាសបញ្ចមានំ បទកោ វេយ្យាករណោ លោកាយតមហាបុរិសលក្ខណេសុ អនវយោ អហមស្ស មន្តេ វាចេតា

១ ឱ. ឥមិស្សា បរិសាយ ។

(១៩២) សម័យនោះឯង មានមាណព (មនុស្សជំទង់) ម្នាក់ ឈ្មោះអង្គកៈ ត្រូវជាក្មួយសោណទណ្ឌព្រាហ្មណ៍ អង្គុយក្នុងពួកបរិសទ្យនោះដែរ ។ លំដាប់នោះ សោណទណ្ឌព្រាហ្មណ៍ បាននិយាយនឹងពួកព្រាហ្មណ៍ទាំងនោះដូច្នេះថា អ្នកដ៏ចំរើនទាំងឡាយ បានឃើញមាណពឈ្មោះអង្គកៈនេះជាក្មួយយើងដែរឬទេ ។ ព្រាហ្មណ៍ទាំងនោះ ក៏ឆ្លើយថា បពិត្រលោកដ៏ចំរើន បានឃើញដែរ បពិត្រលោកដ៏ចំរើន អង្គកមាណព មានរូបល្អ គួរពិតពិល រមិលមើល គួរជ្រះថ្លា ប្រកបដោយសម្បុរដ៏ល្អក្រៃលែង មានសម្បុរដ៏ប្រសើរ មានសរីរៈស្រដៀងនឹងព្រហ្ម មានសណ្ឋានកាយ គួរឲ្យចង់មើលមិនលែង ក្នុងបរិសទ្យនេះ រកអ្នកណាឲ្យមានសម្បុរស្មើនឹងអង្គកមាណពនេះ គ្មានឡើយ លើកលែងតែព្រះសមណគោតមចេញ ។ សោណទណ្ឌព្រាហ្មណ៍ពោលថា ម្នាលអ្នកទាំងឡាយដ៏ចំរើន អង្គកមាណព ជាអ្នករាយមន្ត បេះចាំមន្ត ជាអ្នកដល់នូវត្រើយនៃត្រៃវេទ ព្រមទាំងគម្ពីរ និឃណ្ឌុ គម្ពីរ កេតុភៈ អក្ខរប្បភេទគឺសិក្ខានិងនិរុត្តិ ដែលមានគម្ពីរឥតិហាសៈជាគំរប់ ៥ ជាអ្នកចាំស្ទាត់នូវបទនឹងវេយ្យាករណ៍ ជាអ្នកស្ទាត់ជំនាញ ក្នុងលោកាយតសាស្ត្រ និងមហាបុរិសលក្ខណព្យាករណសាស្ត្រ ឯខ្ញុំជាអ្នកបង្រៀនមន្ត ដល់វា

អង្គកោ ខោ ភោ មាណវកោ ឧភតោ សុជាតោ មាតិតោ ច បិតិតោ ច សំសុទ្ធគ្គហណិកោ យាវ សត្តមា បិតាមហយុគា អក្ខិត្តោ អនុបក្កុដ្ឋោ ជាតិវាទេន អហមស្ស មាតាបិតរោ ជានាមិ អង្គកោ ខោ ភោ មាណវកោ បាណំបិ ហនេយ្យ អទិន្នំបិ អាទិយេយ្យ បរទារំបិ គច្ឆេយ្យ មុសាបិ ភណេយ្យ មជ្ជំបិ បិវេយ្យ ឯត្ថទានិ(១) កឹ វណ្ណោ ករិស្សតិ កឹ មន្តា(២) កឹ ជាតិ យតោ ខោ ភោ ព្រាហ្មណោ សីលវា ច ហោតិ វុឌ្ឍសីលី វុឌ្ឍសីលេន សមន្នាគតោ បណ្ឌិតោ ច ហោតិ មេធាវី បឋមោ វា ទុតិយោ វា សុជំ បគ្គណ្ហន្តានំ ឥមេហិ ខោ ភោ ទ្វីហិ អង្គេហិ សមន្នាគតំ ព្រាហ្មណា ព្រាហ្មណំ បញ្ញបេន្តិ ព្រាហ្មណោស្មីតិ ច វទមានោ សម្មា វទេយ្យ ន ច បន មុសាវាទំ អាបជ្ជេយ្យាតិ ។

---

១ ឱ. ម. ឯត្ថទានិ ភោ ។ ២ ឱ. មន្តំ ។

ម្នាលអ្នកទាំងឡាយដ៏ចំរើន ឯអង្គកមាណពមានជាតដ៏ល្អទាំងពីរចំណែក គឺចំណែកខាងមាតានឹងចំណែកខាងបិតា កើតអំពីផ្ទៃដ៏បរិសុទ្ធស្អាត ដរាប អំពីតំណនៃដីដូនដីតាជាគំរប់ ៧មក មិនដែលមាននរណាមួយពោលទោស តិះដៀល ដោយពោលដល់ជាតិកំណើតបាន ខ្ញុំក៏ស្គាល់មាតាបិតារបស់ក ម្នាលអ្នកទាំងឡាយដ៏ចំរើន តែអង្គកមាណពសម្លាប់សត្វខ្លះ យកទ្រព្យ ដែលគេមិនបានឱ្យខ្លះ ប្រព្រឹត្តខុសក្នុងកិរិយាអ្នកដទៃខ្លះ និយាយកុហក ខ្លះ ផឹកទឹកស្រវឹងខ្លះ ឥឡូវបើលើកយកសេចក្ដីនេះមកនិយាយ វណ្ណៈ នឹងយកជាការអ្វីបាន មន្តនឹងយកជាការអ្វីបាន ជាតិនឹងយកជាការអ្វីបាន ម្នាលអ្នកទាំងឡាយ ដ៏ចំរើន ព្រាហ្មណ៍ (ដែលប្រកបដោយអង្គ២) គឺជាអ្នកមានសីល មានសីលដ៏ចំរើន ប្រកបដោយសីលដ៏ចំរើន ១ ជា អ្នកប្រាជ្ញមានប្រាជ្ញា ជាបុគ្គលទី ១ ឬទី ២ របស់ពួកព្រាហ្មណ៍ អ្នកទទួល គ្រឿងបូជា ១ ម្នាលអ្នកទាំងឡាយដ៏ចំរើន ពួកព្រាហ្មណ៍ រមែងបញ្ញត្ត មនុស្ស ដែលប្រកបដោយអង្គ ត្រឹមតែ ២ នេះឯង ថាជាព្រាហ្មណ៍ (មនុស្សដែលប្រកបដោយអង្គ ២ នេះ) កាលបើពោលថា ខ្លួនខ្ញុំជា ព្រាហ្មណ៍ដូច្នេះ ឈ្មោះថា និយាយដោយប្រពៃផង មិនត្រូវមុសាវាទ ផង ។

(១៩៣) ឥមេសំ បន ព្រាហ្មណា ទ្វិន្នំ អង្គានំ សក្កា ឯកំ អង្គំ ឋបយិត្វា ឯកេន អង្គេន សមន្នាគតំ ព្រាហ្មណំ បញ្ញាបេតុំ ព្រាហ្មណោស្មីតិ ច វទមានោ សម្មា វទេយ្យ ន ច បន មុសាវាទំ អាបជ្ជេយ្យាតិ ។ នោ ហិទំ ភោ គោតម សីលបរិធោតា ហិ ភោ គោតម បញ្ញា បញ្ញាបរិធោតំ(១) សីលំ យត្ថ សីលំ តត្ថ បញ្ញា យត្ថ បញ្ញា តត្ថ សីលំ សីលវតោ បញ្ញា បញ្ញាវតោ សីលំ សីលបញ្ញាណញ្ច បន លោកស្មឹ អគ្គមក្ខាយតិ សេយ្យថាបិ ភោ គោតម ហត្ថេន វា ហត្ថំ ធោវេយ្យ បាទេន វា បាទំ ធោវេយ្យ ឯវមេវ ខោ ភោ គោតម សីលបរិធោតា បញ្ញា បញ្ញាបរិធោតំ សីលំ យត្ថ សីលំ តត្ថ បញ្ញា យត្ថ បញ្ញា តត្ថ សីលំ សីលវតោ បញ្ញា

១ ម. បញ្ញាបរិធោតំ ។

(១៩៣) ព្រះមានព្រះភាគ ទ្រង់ត្រាស់សួរថា ម្នាលព្រាហ្មណ៍ បណ្តាអង្គទាំង២នេះ អ្នកអាចលើកអង្គមួយចេញ ហើយបញ្ញត្តមនុស្ស ដែលប្រកបដោយអង្គត្រឹមតែ១ ថាជាព្រាហ្មណ៍វិញ (ទាំងមនុស្សដែលប្រកបដោយអង្គតែ១នោះ) កាលបើពោលថា ខ្ញុំជាព្រាហ្មណ៍ដូច្នេះ ឈ្មោះថា និយាយដោយប្រពៃផង មិនត្រូវមុសាវាទផង តើបានឬទេ ។ សោណទណ្ឌព្រាហ្មណ៍ ក្រាបបង្គំទូលថា បពិត្រព្រះគោតមដ៏ចំរើន អង្គទាំង២នេះ នឹងលើកអង្គណាមួយចេញមិនបានទេ បពិត្រព្រះគោតមដ៏ចំរើន ដ្បិតប្រាជ្ញារមែងជំរះសីលឲ្យបរិសុទ្ធ សីលសោតក៏រមែងជំរះប្រាជ្ញាឲ្យបរិសុទ្ធដែរ សីលនៅត្រង់ណា ប្រាជ្ញាក៏នៅត្រង់នោះ ប្រាជ្ញានៅត្រង់ណា សីលក៏នៅត្រង់នោះដែរ អ្នកមានសីលក៏មានប្រាជ្ញា អ្នកមានប្រាជ្ញាក៏មានសីល ឯសីលនឹងប្រាជ្ញា ប្រាកដជាគុណធម៌ប្រសើរក្នុងលោក បពិត្រព្រះគោតមដ៏ចំរើន បុគ្គលលាងដៃ ដោយដៃក្តី លាងជើង ដោយជើងក្តី សេចក្តីនេះមានឧបមាយ៉ាងណាមិញ បពិត្រព្រះគោតមដ៏ចំរើន មានឧបមេយ្យដូចជា ប្រាជ្ញា រមែងជំរះសីលឲ្យបរិសុទ្ធ សីលសោតក៏រមែងជំរះប្រាជ្ញាឲ្យបរិសុទ្ធដែរ សីលនៅត្រង់ណា ប្រាជ្ញាក៏នៅត្រង់នោះ ប្រាជ្ញានៅត្រង់ណា សីលក៏នៅត្រង់នោះដែរ អ្នកមានសីលក៏មានប្រាជ្ញា

បញ្ញវតោ សីលំ សីលប្បញ្ញាណញ្ច បន លោកស្មឹ អគ្គមក្ខាយតីតិ ។

(១៩៦) ឯវមេតំ ព្រាហ្មណ ឯវមេតំ ព្រាហ្មណ សីលបរិធោតា ហិ ព្រាហ្មណ បញ្ញា បញ្ញាបរិធោតំ សីលំ យត្ថ សីលំ តត្ថ បញ្ញា យត្ថ បញ្ញា តត្ថ សីលំ សីលវតោ បញ្ញា បញ្ញវតោ សីលំ សីល-ប្បញ្ញាណញ្ច បន លោកស្មឹ អគ្គមក្ខាយតិ សេយ្យ-ថាបិ ព្រាហ្មណ ហត្ថេន វា ហត្ថំ ធោវេយ្យ បាទេន វា បាទំ ធោវេយ្យ ឯវមេវ ខោ ព្រាហ្មណ សីល-បរិធោតា បញ្ញា បញ្ញាបរិធោតំ សីលំ យត្ថ សីលំ តត្ថ បញ្ញា យត្ថ បញ្ញា តត្ថ សីលំ សីល-វតោ បញ្ញា បញ្ញវតោ សីលំ សីលប្បញ្ញាណញ្ច បន លោកស្មឹ អគ្គមក្ខាយតីតិ កតមំ បន តំ ព្រាហ្មណ សីលំ កតមា បន សា បញ្ញាតិ ។

អ្នកមានប្រាជ្ញាក៏មានសីល ឯសីលនឹងប្រាជ្ញានេះ អ្នកប្រាជ្ញតែងពោលថាជាគុណធម៌ដ៏ប្រសើរ ក្នុងលោក ។

(១៩៤) ព្រះមានព្រះភាគ ទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ សេចក្តីនុ៎ះយ៉ាងហ្នឹងហើយ ម្នាលព្រាហ្មណ៍ សេចក្តីនុ៎ះយ៉ាងហ្នឹងហើយ ម្នាលព្រាហ្មណ៍ ដ្បិតប្រាជ្ញា រមែងជំរះសីលឲ្យបរិសុទ្ធ សីលសោត ក៏រមែងជំរះប្រាជ្ញាឲ្យបរិសុទ្ធដែរ សីលនៅត្រង់ណា ប្រាជ្ញាក៏នៅត្រង់នោះ ប្រាជ្ញានៅត្រង់ណា សីលក៏នៅត្រង់នោះដែរ អ្នកមានសីលក៏មានប្រាជ្ញា អ្នកមានប្រាជ្ញាក៏មានសីល ឯសីលនឹងប្រាជ្ញា អ្នកប្រាជ្ញតែងពោលថាជាគុណធម៌ដ៏ប្រសើរ ក្នុងលោក ម្នាលព្រាហ្មណ៍ បុគ្គលលាងដៃដោយដៃក្តី លាងជើងដោយជើងក្តី សេចក្តីនេះមានឧបមាយ៉ាងណាមិញ ម្នាលព្រាហ្មណ៍ មានឧបមេយ្យដូចជាប្រាជ្ញា រមែងជំរះសីលឲ្យបរិសុទ្ធ សីលសោត ក៏រមែងជំរះប្រាជ្ញាឲ្យបរិសុទ្ធដែរ សីលនៅត្រង់ណា ប្រាជ្ញាក៏នៅត្រង់នោះ ប្រាជ្ញានៅត្រង់ណា សីលក៏នៅត្រង់នោះដែរ អ្នកមានសីលក៏មានប្រាជ្ញា អ្នកមានប្រាជ្ញាក៏មានសីល ឯសីលនឹងប្រាជ្ញា អ្នកប្រាជ្ញតែងពោលថាជាគុណធម៌ដ៏ប្រសើរ ក្នុងលោក ម្នាលព្រាហ្មណ៍ ចុះសីលនោះដូចម្តេច ប្រាជ្ញានោះដូចម្តេច ។ សោណទណ្ឌព្រាហ្មណ៍ ក្រាប

ឯត្តកបរមា ច(១) មយំ ភោ គោតម តិស្មឹ(២) អត្ថេ សាធុ វត ភវន្តំយេវ(៣) គោតមំ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោតិ ។

(១៩៤) តេនហិ ព្រាហ្មណ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ ភោតិ ខោ សោណទណ្ឌោ ព្រាហ្មណោ ភគវតោ បច្ចស្សោសិ ។ ភគវា ឯតទវោច ឥធ ព្រាហ្មណ តថាគតោ លោកេ ឧប្បជ្ជតិ អរហំ សម្មាសម្ពុទ្ធោ ។ បេ ។ (យថា សាមញ្ញផលេ ឯវំ វិត្ថារេតព្វំ) ។ បេ ។ ឯវំ ខោ បន ព្រាហ្មណ ភិក្ខុ សីលសម្បន្នោ ហោតិ ។ ឥទំបិ ខោ តំ ព្រាហ្មណ សីលំ ។ បឋមំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ ទុតិយំ ឈានំ ។ តតិយំ ឈានំ ។ ចតុត្ថំ ឈានំ ឧបសម្បជ្ជ វិហរតិ ។ បេ ។ ញាណទស្សនាយ ចិត្តំ អភិនីហរតិ អភិនិន្នាមេតិ ។ បេ ។ ឥទម្បិស្ស ហោតិ បញ្ញាយ ។ បេ ។

---

១ ឱ. ម. វ ។ ២ ឱ. ម. ឯតស្មឹ ។ ៣ ឱ. ភវន្តំយេវ ភោ ។

បង្គំទូលថា បពិត្រព្រះគោតមដ៏ចំរើន ខ្ញុំព្រះអង្គគ្រាន់តែបានដឹងថា សីល នឹងប្រាជ្ញាប៉ុណ្ណេះ ឯត្រង់សេចក្ដីអធិប្បាយ (មិនដឹងថា) ដូចម្ដេចទេ សូមព្រះគោតមដ៏ចំរើន ទ្រង់ត្រាស់បកសេចក្ដីអធិប្បាយនៃភាសិតនុ៎ះឲ្យទាន ។

(១៩៤) ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ បើដូច្នោះ ចូរអ្នកប្រុងស្ដាប់ ចូរអ្នកយកចិត្តទុកដាក់ឲ្យប្រពៃចុះ តថាគតនឹងសំដែងប្រាប់ ។ សោណទណ្ឌព្រាហ្មណ៍ ទទួលព្រះពុទ្ធដីការបស់ព្រះមានព្រះភាគថា យ៉ាងហ្នឹងហើយ ព្រះអង្គ ។ ព្រះមានព្រះភាគទ្រង់ត្រាស់ពាក្យនេះថា ម្នាលព្រាហ្មណ៍ ព្រះតថាគតបានកើតឡើងក្នុងលោកនេះ ជាអរហន្តសម្មាសម្ពុទ្ធ ។បេ។ (រឿងនេះ អ្នកប្រាជ្ញគប្បីសំដែងឲ្យពិស្ដារដូចក្នុងសាមញ្ញផលសូត្រផងចុះ) ។ បេ ។ ម្នាលព្រាហ្មណ៍ ភិក្ខុរមែងជាអ្នកបរិបូណ៌ដោយសីល យ៉ាងនេះឯង ។ ម្នាលព្រាហ្មណ៍ នេះឯង ដែលហៅថាសីលនោះ ។ ភិក្ខុបានសម្រេចបឋមជ្ឈាន សម្រេចឥរិយាបថនៅ ។ ទុតិយជ្ឈាន ។ តតិយជ្ឈាន ។ បានសម្រេចចតុត្ថជ្ឈាន សម្រេចឥរិយាបថទៅ ។ បេ ។ ភិក្ខុទាញនាំបង្អោនចិត្តទៅ ដើម្បីញាណទស្សនៈ ។ បេ ។ នេះឯង ជា (សេចក្ដីអធិប្បាយ) នៃប្រាជ្ញារបស់ភិក្ខុនោះ ។ បេ ។

នាបរំ ឥត្ថត្តាយាតិ បជានាតិ ។ ឥទម្បិស្ស ហោតិ បញ្ញាយ ។ អយំ ខោ សា ព្រាហ្មណ បញ្ញាតិ ។

(១៩៦) ឯវំ វុត្តេ សោណទណ្ឌោ ព្រាហ្មណោ ភគវន្តំ ឯតទវោច អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលបជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវំ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ អធិវាសេតុ ច មេ ភវំ គោតមោ ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។ អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ សោណទណ្ឌោ ព្រាហ្មណោ

ភិក្ខុដឹងច្បាស់ថា កិច្ចដទៃក្រៅអំពីនេះមិនមានទេ ។ នេះឯង (ជាសេចក្តីអធិប្បាយ) នៃប្រាជ្ញារបស់ភិក្ខុនោះ ។ ម្នាលព្រាហ្មណ៍ នេះឯងដែលហៅថា ប្រាជ្ញានោះ ។

(១៩៦) កាលបើព្រះមានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ សោណទណ្ឌព្រាហ្មណ៍ បានក្រាបបង្គំទូលចំពោះព្រះមានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចំរើន ពីរោះណាស់ បពិត្រព្រះគោតមដ៏ចំរើន ធម៌ដែលព្រះគោតមដ៏ចំរើនទ្រង់សំដែង ដោយអនេកបរិយាយ (នេះ) គួរនាដូចជាមនុស្សផ្ងារវត្ថុដែលផ្កាប់ ឬបើកបង្ហាញវត្ថុដែលកំបាំង ឬក៏ប្រាប់ផ្លូវដល់អ្នកវង្វេងទិស ពុំនោះសោត ដូចជាមនុស្ស កាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹតដោយគិតថា មនុស្សដែលមានភ្នែក(ក្តី) មើលឃើញរូបទាំងឡាយបាន ខ្ញុំព្រះអង្គសូមដល់ព្រះគោតមដ៏ចំរើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាសរណៈ សូមព្រះគោតមដ៏ចំរើន ជ្រាបថា ខ្ញុំព្រះអង្គជាឧបាសក ដល់សរណគមន៍ស្មើដោយជីវិត ចាប់ដើមអំពីថ្ងៃនេះទៅ មួយទៀត សូមព្រះគោតមដ៏ចំរើន ព្រមទាំងភិក្ខុសង្ឃទ្រង់ទទួលបង្អាន់របស់ខ្ញុំព្រះអង្គ ក្នុងថ្ងៃស្អែក ។ ព្រះមានព្រះភាគ ទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ លុះសោណទណ្ឌព្រាហ្មណ៍

ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។

(១៩៧) អថខោ សោណទណ្ឌោ ព្រាហ្មណោ តស្សា រត្តិយា អច្ចយេន សកេ និវេសនេ ប-ណីតំ ខាទនីយំ ភោជនីយំ បដិយាទាបេត្វា ភគវ-តោ កាលំ អារោចាបេសិ កាលោ ភោ គោតម និដ្ឋិតំ ភត្តន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ សទ្ធឹ ភិក្ខុសង្ឃេន យេន សោណទណ្ឌស្ស ព្រាហ្មណស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ សោណទណ្ឌោ ព្រាហ្មណោ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសិ សម្បវារេសិ ។

(១៩៨) អថខោ សោណទណ្ឌោ ព្រាហ្មណោ ភគវន្តំ ភុត្តាវឹ ឱនីតបត្តបាណឹ អញ្ញតរំ នីចំ អាសនំ គហេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោណទណ្ឌោ ព្រាហ្មណោ ភគវន្តំ ឯតទវោច

ដឹងច្បាស់ថា ព្រះអង្គទទួលនិមន្តហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំលាព្រះមានព្រះភាគ ធ្វើប្រទក្សិណហើយដើរចេញទៅ ។

(១៩៧) លុះដល់វេលាព្រឹកឡើង សោណទណ្ឌព្រាហ្មណ៍ បង្គាប់ជនទាំងឡាយ ឲ្យតាក់តែងធ្វើខាទនីយភោជនីយាហារ ដ៏ឆ្ងាញ់ពិសា ក្នុងលំនៅរបស់ខ្លួនស្រេចហើយ ទើបចាត់បម្រើឲ្យទៅក្រាបបង្គំទូលកត្តកាល ចំពោះព្រះមានព្រះភាគថា បពិត្រព្រះគោតមដ៏ចំរើន កត្តកាលដល់ហើយ ចង្ហាន់ក៏បានរៀបចំស្រេចហើយ ។ លំដាប់នោះ លុះដល់បុព្វណ្ហសម័យ ព្រះមានព្រះភាគ ទ្រង់បាត្រនិងចីវរហើយ ស្តេចចូលទៅកាន់លំនៅនៃសោណទណ្ឌព្រាហ្មណ៍ ព្រមដោយភិក្ខុសង្ឃ ទ្រង់គង់លើអាសនៈដែលគេរៀបចំថ្វាយ ។ វេលានោះ សោណទណ្ឌព្រាហ្មណ៍បានអង្គាសខាទនីយភោជនីយាហារ ដ៏ឆ្ងាញ់ពិសា ដោយដៃខ្លួនឯង ប្រគេនព្រះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ឲ្យឆ្អែតស្កប់ស្កល់ គ្រាតែប្រកែកលែងទទួលទៀត ។

(១៩៨) លំដាប់នោះ សោណទណ្ឌព្រាហ្មណ៍ លុះព្រះមានព្រះភាគ ទ្រង់សោយស្រេច លែងលូកព្រះហស្តទៅក្នុងបាត្រហើយ ក៏កាន់យកអាសនៈទាបមួយ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះសោណទណ្ឌព្រាហ្មណ៍ អង្គុយស្ងប់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះមានព្រះ

អហញ្ចេ ខោ បន ភោ គោតម បរិសគតោ សមានោ អាសនា វុដ្ឋហិត្វា ភវន្តំ គោតមំ អភិវាទេយ្យំ តេន មំ សា បរិសា បរិភវេយ្យ យំ ខោ បន សា បរិសា បរិភវេយ្យ យសោបិ តស្ស ហាយេថ យស្ស ខោ បន យសោ ហាយេថ ភោគាបិ តស្ស ហាយេយ្យុំ យសោលទ្ធា ខោ បនម្ហាកំ ភោគា អហញ្ចេ ខោ បន ភោ គោតម បរិសគតោ សមានោ អញ្ជលឹ បគ្គណ្ហេយ្យំ អាសនា មេ តំ ភវំ គោតមោ បច្ចុដ្ឋានំ ធារេតុ អហញ្ចេ ខោ បន ភោ គោតម បរិសគតោ សមានោ វេដ្ឋនំ ឱមុញ្ចេយ្យំ សិរសា មេ តំ ភវំ គោតមោ អភិវាទនំ ធារេតុ អហញ្ចេ ខោ បន ភោ គោតម យានគតោ សមានោ យានា បច្ចោរោហិត្វា ភវន្តំ គោតមំ អភិវាទេយ្យំ តេន មំ សា បរិសា បរិភវេយ្យ យំ ខោ បន សា បរិសា បរិភវេយ្យ យសោបិ តស្ស ហាយេថ យស្ស ខោ បន យសោ ហាយេថ ភោគាបិ តស្ស

ភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចំរើន បើខ្ញុំព្រះអង្គកំពុងនៅក្នុងបរិសទ្យ ហើយនឹងក្រោកចាកអាសនៈ ថ្វាយបង្គំព្រះគោតមដ៏ចំរើន បរិសទ្យនោះ មុខជានឹងមើលងាយខ្ញុំព្រះអង្គ ព្រោះហេតុនោះឯង បរិសទ្យនោះ (បើ) មើលងាយបុគ្គលណាហើយ យសរបស់បុគ្គលនោះ ក៏នឹងសាបសូន្យទៅផង (បើ) យសរបស់បុគ្គលណាសាបសូន្យហើយ ភោគៈទាំងឡាយរបស់បុគ្គលនោះ ក៏នឹងសាបសូន្យទៅផង ដ្បិតភោគៈទាំងឡាយរបស់យើងខ្ញុំ សុទ្ធតែបានមកដោយសារយសតែប៉ុណ្ណោះ បពិត្រព្រះគោតមដ៏ចំរើន តែបើខ្ញុំព្រះអង្គកំពុងនៅក្នុងបរិសទ្យ គួរប្រណម្យអញ្ជលីបាន សូមព្រះគោតមដ៏ចំរើន ចាំទុកនូវការប្រណម្យអញ្ជលីនោះ ថាជាការក្រោកអំពីអាសនៈរបស់ខ្ញុំព្រះអង្គចុះ បពិត្រព្រះគោតមដ៏ចំរើន មួយទៀត (បើ) ខ្ញុំព្រះអង្គកំពុងនៅក្នុងបរិសទ្យ គួរដោះឈ្នួតក្បាលបាន សូមព្រះគោតមដ៏ចំរើន ចាំទុកនូវការដោះឈ្នួតក្បាលនោះ ថាជាការថ្វាយបង្គំដោយសិរ្សៈរបស់ខ្ញុំចុះ បពិត្រព្រះគោតមដ៏ចំរើន (បើ) ខ្ញុំព្រះអង្គកំពុងឋិតនៅលើយានហើយ ចុះពីលើយានមកថ្វាយបង្គំព្រះគោតមដ៏ចំរើន បរិសទ្យនោះមុខជានឹងមើលងាយខ្ញុំព្រះអង្គ ព្រោះហេតុនោះឯង បរិសទ្យនោះ (បើ) មើលងាយបុគ្គលណាហើយ យសរបស់បុគ្គលនោះ ក៏នឹងសាបសូន្យទៅផង យសរបស់បុគ្គលណាសាបសូន្យហើយ ភោគៈទាំងឡាយ របស់បុគ្គលនោះ

ហាយេយ្យុំ យសោលទ្ធា ខោ បនម្ហាកំ ភោគា អហ-ញ្ចេ ខោ ភោ គោតម យានគតោ សមានោ បតោទលដ្ឋឹ អព្ភុន្នាមេយ្យំ យានា មេ តំ ភវំ គោតមោ បច្ចោរោហនំ ធារេតុ អហញ្ចេ ខោ ភោ គោតម យានគតោ សមានោ ឆត្តំ អបនាមេយ្យំ សិរសា មេ តំ ភវំ គោតមោ អភិវាទនំ ធារេតូតិ ។ អថខោ ភគវា សោណទណ្ឌំ ព្រាហ្មណំ ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំ-សេត្វា ឧដ្ឋាយាសនា បក្កាមីតិ ។

សោណទណ្ឌសុត្តំ ចតុត្ថំ និដ្ឋិតំ ។

ក៏នឹងសាបសូន្យទៅផង ដ្បិតភោគៈទាំងឡាយរបស់យើងសុទ្ធតែបានមក ដោយសារតែយសប៉ុណ្ណោះ បពិត្រព្រះគោតមដ៏ចំរើន មួយទៀត បើខ្ញុំព្រះអង្គកំពុងឋិតនៅលើយានហើយ នឹងលើកដងជន្ទួញឡើង សូមព្រះគោតមដ៏ចំរើន ទ្រង់ចាំទុកនូវកិរិយាលើកដងជន្ទួញនោះ ថាជាកិរិយាចុះអំពីយានរបស់ខ្ញុំព្រះអង្គចុះ បពិត្រព្រះគោតមដ៏ចំរើន មួយទៀត (បើ) ខ្ញុំព្រះអង្គកំពុងឋិតនៅលើយានហើយ គួរដំឡោះឆត្របាន សូមព្រះគោតមដ៏ចំរើន ទ្រង់ចាំទុកនូវការដំឡោះឆត្រនោះ ថាជាកិរិយាថ្វាយបង្គំដោយសិរ្ស:របស់ខ្ញុំព្រះអង្គចុះ ។ លំដាប់នោះ ព្រះមានព្រះភាគ ទ្រង់សំដែងពន្យល់សោណទណ្ឌព្រាហ្មណ៍ (ឲ្យយល់ប្រយោជន៍ក្នុងបច្ចុប្បន្ននឹងបរលោក) ឲ្យជឿជាក់ (ក្នុងកុសលធម៌) ឲ្យសង្វាតធ្វើការកុសល ឲ្យរីករាយ (ដោយគុណដែលមានក្នុងខ្លួន) ដោយធម្មីកថា រួចទ្រង់ក្រោកអំពីអាសនៈ ហើយទ្រង់ពុទ្ធដំណើរចេញទៅ ។

ចប់ សោណទណ្ឌសូត្រ ទី ៤ ។

## មាតិកាបត្តានិ

# សុត្តន្តបិដកេ ទីឃនិកាយស្ស បឋមោ ភាគោ

## សីលក្ខន្ធវគ្គោ

### ព្រហ្មជាលសុត្តំ បឋមំ


| | | |
|---|---|---|
| | | អង្កេ |
| ព្រហ្មជាលសុត្តេ | សុត្តនិទានំ . . . . . . . . | ៣ |
| | ចូឡសីលំ . . . . . . . . | ៧ |
| | មជ្ឈិមសីលំ ពីជគាមភូតគាមសមារម្ភាទិ .. | ១៣ |
| | មជ្ឈិមសីលំ ជូតប្បមាទដ្ឋានានុយោគោ .. | ១៥ |
| | មជ្ឈិមសីលំ មណ្ឌនវិភូសនដ្ឋានានុយោគោ | ១៧ |
| | មជ្ឈិមសីលំ វិគ្គាហិកកថា . . . . | ១៩ |
| | មជ្ឈិមសីលំ កុហនលបនាទិ . . . . | ២១ |
| | មហាសីលំ តិរច្ឆានវិជ្ជា . . . . . | ២៣ |
| | បុព្វន្តកប្បិកា បុព្វេនិវាសានុស្សតិ . . . | ៣១ |
| | បុព្វន្តកប្បិកា ចត្តារិ វត្ថូនិ . . . . | ៤៣ |

# សង្ក្រាចផ្តុលមាតិកា

# សុត្តន្តបិដក ទីឃនិកាយ បឋមភាគ

## សីលក្ខន្ធវគ្គ

### ព្រហ្មជាលសូត្រ ទី ១

លេខទំព័រ


| | | |
|---|---|---|
| ព្រហ្មជាលសូត្រ | សុត្តនិទាន . . . . . . . | ៣ |
| | ចូឡសីល. . . . . . . . | ៧ |
| | មជ្ឈិមសីល ការធ្វើពីជគាមនិងភូតគាមឲ្យវិនាស ជាដើម | ១៣ |
| | មជ្ឈិមសីល ការប្រកបល្បែងបាស្កាដែលជាហេតុជាទីតាំងនៃសេចក្ដីប្រមាទ. . . . . . . | ១៥ |
| | មជ្ឈិមសីល ប្រកបនូវវត្ថុជាទីតាំងនៃការប្រដាប់ស្អិតស្អាងរាងកាយ . . . . . . . | ១៧ |
| | មជ្ឈិមសីល និយាយអំពីពាក្យប្រណាំងប្រជែង . . | ១៩ |
| | មជ្ឈិមសីល ការពោលកុហក និងការពោលពាក្យរាក់ទាក់ជាដើម . . . . . . . . | ២១ |
| | មហាសីល តិរច្ឆានវិជ្ជា. . . . . . . | ២៣ |
| | ការកំណត់នូវចំណែកនៃខន្ធខាងដើម បុព្វេនិវាសានុស្សតិ . | ៣១ |
| | ការកំណត់នូវចំណែកនៃខន្ធខាងដើម ហេតុ ៤ យ៉ាង . | ៤៣ |

# មាតិកាបត្តាធិ


| | | អង្កេ |
|---|---|---|
| ព្រហ្មជាលសុត្ត | បុព្វន្តកប្បិកា បុព្វេនិវាសានុស្សតិ . . . | ៤៥ |
| | បុព្វន្តកប្បិកា ចត្តារិ វត្ថូនិ . . . . . | ៤៧ |
| | បុព្វន្តកប្បិកា អមរាវិក្ខេបិកា . . . . | ៦៣ |
| | អធិច្ចសមុប្បន្និកា . . . . . . . | ៧១ |
| | អបរន្តកប្បិកា . . . . . . . . | ៧៥ |
| | ឧទ្ធមាឃាតនិកា អសញ្ញីវាទា . . . . | ៧៧ |
| | ឧទ្ធមាឃាតនិកា នេវសញ្ញីនាសញ្ញីវាទា . . | ៧៩ |
| | ឧច្ឆេទវាទា . . . . . . . . | ៨១ |
| | ទិដ្ឋធម្មនិព្វានវាទា . . . . . . | ៨៧ |
| | អបរន្តកប្បិកា ទិដ្ឋធម្មនិព្វានវាទា . . . | ៩១ |
| | សស្សតវាទា . . . . . . . | ៩៣ |
| | អមរាវិក្ខេបិកាទយោ . . . . . . | ៩៥ |
| | ឧទ្ធមាឃាតនិកាទយោ . . . . . . | ៩៧ |
| | បុព្វន្តកប្បិកាទយោ . . . . . . | ៩៩ |
| | អបរន្តកប្បិកាទយោ . . . . . . | ១០៧ |

# សន្ទឹកាចន្ទុលមាតិកា


| | | លេខទំព័រ |
|---|---|---|
| ព្រហ្មជាលសូត្រ | កំណត់នូវចំណែកនៃខន្ធខាងដើម បុព្វេនិវាសានុស្សតិ . . | ៤៥ |
| | កំណត់នូវចំណែកនៃខន្ធខាងដើម ហេតុ ៤ យ៉ាង . . . | ៤៧ |
| | កំណត់នូវចំណែកនៃខន្ធ ខាងដើម ប្រកបដោយអមរា-វិក្ខេបទិដ្ឋិ. . . . . . . . . . . . . . | ៦៣ |
| | ប្រកបដោយអធិច្ចសមុប្បន្នទិដ្ឋិ . . . . . . . . | ៧១ |
| | ប្រកបដោយអបរន្តកប្បទិដ្ឋិ . . . . . . . . | ៧៥ |
| | ប្រកបដោយឧទ្ធមាឃតនទិដ្ឋិ ជាអសញ្ញីវាទ . . . . | ៧៧ |
| | ប្រកបដោយឧទ្ធមាឃតនទិដ្ឋិ ជានេវសញ្ញីនាសញ្ញីវាទ . . | ៧៩ |
| | ឧច្ឆេទវាទ . . . . . . . . . . . . . . | ៨១ |
| | ទិដ្ឋធម្មនិព្វានវាទ . . . . . . . . . . . . | ៨៧ |
| | ប្រកបដោយអបរន្តកប្បទិដ្ឋិ ទិដ្ឋធម្មនិព្វានវាទ . . . . | ៩១ |
| | សស្សតវាទ . . . . . . . . . . . . . | ៩៣ |
| | ប្រកបដោយអមរាវិក្ខេបទិដ្ឋិ ជាដើម . . . . . . . | ៩៥ |
| | ប្រកបដោយឧទ្ធមាឃតនទិដ្ឋិ ជាដើម. . . . . . . | ៩៧ |
| | ប្រកបដោយបុព្វន្តកប្បទិដ្ឋិ ជាដើម . . . . . . | ៩៩ |
| | ប្រកបដោយអបរន្តកប្បទិដ្ឋិ ជាដើម . . . . . . . | ១០៧ |

# មាតិកាបត្តាធិ


អង្កៈ

ព្រហ្មជាលសុត្តេ បុព្វន្តាបរន្តកប្បិកាទយោ . . . . . . ១០៩

បុព្វន្តកប្បិកាទយោ . . . . . . . . ១១១

ភគវតោ ភាសិតំ អភិនន្ទុំ . . . . ១១៣


## សាមញ្ញផលសុត្តំ ទុតិយំ


សាមញ្ញផលសុត្តេ អជាតសត្តុវត្ថុ . . . . . . . . ១១៥

ពុទ្ធគុណកថា . . . . . . . . ១១៩

អជាតសត្តុទានំ . . . . . . . ១២១

សន្ទិដ្ឋិកសាមញ្ញផលបុច្ឆា . . . . . ១២៣

បូរណវាទោ . . . . . . . . ១២៥

មក្ខលិវាទោ . . . . . . . . ១២៩

អជិតវាទោ . . . . . . . . ១៣៥

បកុធវាទោ . . . . . . . . ១៣៩

និគណ្ឋវាទោ . . . . . . . . ១៤១

សញ្ជយវាទោ . . . . . . . . ១៤៣

សន្ទិដ្ឋិកសាមញ្ញផលបុច្ឆា . . . . . ១៤៧

# សង្ខិតចុល្លមាតិកា

លេខទំព័រ

ព្រហ្មជាលសូត្រ ប្រកបដោយបុព្វន្តាបរន្តកប្បទិដ្ឋិ ជាដើម . . . ១០៨
ប្រកបដោយបុព្វន្តកប្បទិដ្ឋិ ជាដើម . . . . ១១១
ការត្រេកអរចំពោះភាសិតរបស់ព្រះមានព្រះភាគ . . ១១៣

## សាមញ្ញផលសូត្រ ទី ២

សាមញ្ញផលសូត្រ រឿងព្រះបាទអជាតសត្តុ . . . . . ១១៥
ពុទ្ធគុណកថា . . . . . . . ១១៩
ព្រះឧទាននៃព្រះបាទអជាតសត្តុ . . . . ១២១
ការសួរអំពីផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់
ដោយខ្លួនឯង . . . . . . . ១២៣
វាទៈរបស់គ្រូឈ្មោះបូរណៈ . . . . . ១២៨
វាទៈរបស់គ្រូឈ្មោះមក្ខលិ . . . . . ១២៩
វាទៈរបស់គ្រូឈ្មោះអជិតៈ . . . . . ១៣៥
វាទៈរបស់គ្រូឈ្មោះបកុធៈ . . . . . ១៣៩
វាទៈរបស់គ្រូឈ្មោះនិគណ្ឋៈ . . . . . ១៤១
វាទៈរបស់គ្រូឈ្មោះសញ្ជ័យ . . . . . ១៤៣
ការសួរអំពីផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់
ដោយខ្លួនឯង . . . . . . . ១៤៧

# មាតិកាបត្តាធំ

| | | អង្កេ |
|---|---|---|
| សាមញ្ញផលសុត្តេ | សន្ទិដ្ឋិកសាមញ្ញផលទេសនា . . . . . | ១៤៩ |
| | ពុទ្ធគុណកថា . . . . . . . | ១៥៥ |
| | សីលក្ខន្ធកថា ចូឡសីលំ . . . . . | ១៥៧ |
| | សីលក្ខន្ធកថា មជ្ឈិមសីលំ . . . . | ១៦១ |
| | សីលក្ខន្ធកថា មហាសីលំ . . . . . | ១៦៩ |
| | ឥន្ទ្រិយសំវរោ . . . . . . . | ១៧៧ |
| | សតិសម្បជញ្ញំ សន្តុដ្ឋិ . . . . . . | ១៧៩ |
| | បញ្ចនីវរណូបមា . . . . . . . | ១៨១ |
| | បញ្ចនីវរណប្បហានំ . . . . . . . | ១៨៥ |
| | ទុតិយជ្ឈានំ ឧទករហទោបមា . . . . | ១៨៧ |
| | ចតុត្ថជ្ឈានំ . . . . . . . . | ១៨៩ |
| | ញាណទស្សនាភិនិហារណំ . . . . | ១៩១ |
| | មនោមយាភិនិម្មិននំ . . . . . . , | ១៩៣ |
| | ឥទ្ធិវិធញាណំ . . . . . . . | ១៩៥ |
| | ទិព្វសោតធាតុ . . . . . . . . | ១៩៧ |

# សន្ធិកាចផ្តុំលមាតិកា


| | | លេខទំព័រ |
|---|---|---|
| សាមញ្ញផលសូត្រ | ការទ្រង់សំដែងផលនៃសមណប្បដិបត្តិ ដែលឃើញច្បាស់ ដោយខ្លួនឯង . . . . . . | ១៤៩ |
| | ពុទ្ធគុណកថា . . . . . . | ១៥៥ |
| | សីលក្ខន្ធកថា ចូឡសីល . . . . . | ១៥៧ |
| | សីលក្ខន្ធកថា មជ្ឈិមសីល . . . . | ១៦១ |
| | សីលក្ខន្ធកថា មហាសីល . . . . | ១៦៩ |
| | សេចក្តីសង្រួមក្នុងឥន្ទ្រិយ . . . . | ១៧៧ |
| | សតិសម្បជញ្ញៈ សេចក្តីសន្តោស . . . | ១៧៩ |
| | សេចក្តីឧបមានៃនីវរណធម៌ទាំង ៥ . . . | ១៨១ |
| | ការលះបង់នូវនីវរណធម៌ទាំង ៥ . . . | ១៨៥ |
| | ទុតិយជ្ឈាន សេចក្តីប្រៀបដោយអន្លង់ទឹក . . | ១៨៧ |
| | ចតុត្ថជ្ឈាន . . . . . . . | ១៨៩ |
| | ការបង្អោនចិត្តទៅ ដើម្បីញាណទស្សនៈ . . | ១៩១ |
| | ការនិម្មិតនូវកាយដែលសម្រេចអំពីចិត្ត . . . | ១៩៣ |
| | ញាណជាគ្រឿងពាក់តែងឫទ្ធិ . . . . | ១៩៥ |
| | សោតធាតុ ជាទិព្វ . . . . . | ១៩៧ |

# មាតិកាបត្តាធិ


| | | អង្ក |
|---|---|---|
| សាមញ្ញផលសុត្តេ | ចេតោបរិយញ្ញាណំ | ១៩៩ |
| | បុព្វេនិវាសានុស្សតិញ្ញាណំ | ២០១ |
| | ចុតូបបាតញ្ញាណំ | ២០៤ |
| | អាសវក្ខយញ្ញាណំ | ២០៩ |
| | អជាតសត្តុស្ស ឧបាសកត្តទេសនា | ២១១ |
| | អជាតសត្តុស្ស អនុមោទនា | ២១៣ |


## អម្ពដ្ឋសុត្តំ តតិយំ


| | | |
|---|---|---|
| អម្ពដ្ឋសុត្តេ | និទានំ អម្ពដ្ឋមាណវវត្ថុ | ២១៧ |
| | ទុតិយតតិយឥព្ភវាទនិបាតនំ | ២២៤ |
| | សក្យវំសកថា | ២២៧ |
| | ទាសីបុត្តវាទនិម្មាទនំ | ២២៩ |
| | អម្ពដ្ឋមាណវវំសកថា | ២៣១ |
| | វិជ្ជាចរណសម្បទា | ២៤១ |
| | វិជ្ជាចរណសម្បទាយ អបាយមុខានិ | ២៤៣ |
| | បុព្វកឥសយោ | ២៤៩ |

# សន្លឹកបញ្ជីមាតិកា

លេខទំព័រ


សាមញ្ញផលសូត្រ ចេតោបរិយញ្ញាណ . . . . . ១៩៩

បុព្វេនិវាសានុស្សតិញ្ញាណ . . . . . ២០១

ចុតូបបាតញ្ញាណ . . . . . . ២០៥

អាសវក្ខយញ្ញាណ . . . . . . ២០៩

ការទ្រង់សំដែងព្រះអង្គជាឧបាសករបស់ព្រះបាទអជាតសត្តុ. ២១១

ការទ្រង់អនុមោទនារបស់ព្រះបាទអជាតសត្តុ . . ២១៣


## អម្ពដ្ឋសូត្រ ទី ៣


អម្ពដ្ឋសូត្រ និទាន រឿងអម្ពដ្ឋមាណព . . . . ២១៧

ការពោលបន្តុះបង្អាប់ថាជាពួកឥតហបតី ជាគំរប់២នឹងគំរប់ ៣ ២២៥

ពោលអំពីសក្យវង្ស . . . . . ២២៧

ការញាំញីដោយពាក្យថា កូនទាសី . . . ២២៩

ពោលអំពីវង្សរបស់អម្ពដ្ឋមាណព . . . . ២៣១

ការបរិបូណ៌ដោយវិជ្ជានិងចរណៈ . . . . ២៤១

ប្រមាណនៃសេចក្ដីសាបសូន្យនៃគុណសម្បទាគឺវិជ្ជានិងចរណៈ ២៤៣

ពួកឥសីដែលជាបុព្វបុរស . . . . . ២៤៩

# មាតិកាបត្តាធិ

អង្គ


អម្ពដ្ឋសុត្តេ ទ្វេ មហាបុរិសលក្ខណានិ , . . . . ២៥៣
បោក្ខរសាតិព្រាហ្មណវត្ថុ . . . . . ២៥៥
អនុបុព្វីកថា ធម្មចក្ខុ . . . . . . ២៦១
បោក្ខរសាតិស្ស អជ្ឈសនំ . . . . . ២៦៣


## សោណទណ្ឌសុត្តំ ចតុត្ថំ


សោណទណ្ឌសុត្តេ ពុទ្ធគុណកថា . . . . . . . . ២៦៥
ភគវតោ កិត្តិសទ្ទោ . . . . . . ២៦៧
សោណទណ្ឌព្រាហ្មណគុណកថា . . ២៦៩
ពុទ្ធគុណកថា . . . . . . . . ២៧៣
សោណទណ្ឌព្រាហ្មណបរិវិតក្កោ . . . ២៧៩
សោណទណ្ឌស្ស ភគវតុបសង្កមនំ . . ២៨១
សោណទណ្ឌព្រាហ្មណបរិវិតក្កោ . . . ២៨៣
ព្រាហ្មណបញ្ញត្តិយា បញ្ចង្គានិ . . . ២៨៥
ព្រាហ្មណបញ្ញត្តិយា តីណង្គានិ . . . ២៨៧
ព្រាហ្មណបញ្ញត្តិយា ទ្វេ អង្គានិ . . . ២៨៩

# សន្ធឹកជ្អុលមាតិកា


| | | លេខទំព័រ |
|---|---|---|
| អម្ពដ្ឋសូត្រ | មហាបុរិសលក្ខណៈ ២ ប្រការ . . . . . . | ២៥៣ |
| | រឿងព្រាហ្មណ៍ឈ្មោះពោក្ខរសាតិ. . . . . . | ២៥៥ |
| | អនុបុព្វីកថា ធម្មចក្ខុ . . . . . . . | ២៦១ |
| | ការអារាធនារបស់ព្រាហ្មណ៍ឈ្មោះពោក្ខរសាតិ. . . | ២៦៣ |


## សោណទណ្ឌសូត្រ ទី ៤


| | | |
|---|---|---|
| សោណទណ្ឌសូត្រ | ពុទ្ធគុណកថា . . . . . . . . | ២៦៥ |
| | កិត្តិសព្ទរបស់ព្រះមានព្រះភាគ . . . . . . | ២៦៧ |
| | គុណកថា របស់សោណទណ្ឌព្រាហ្មណ៍ . . . | ២៦៩ |
| | ពុទ្ធគុណកថា . . . . . . . | ២៧៣ |
| | សេចក្តីត្រិះរិះរបស់សោណទណ្ឌព្រាហ្មណ៍ . . . | ២៧៩ |
| | ការចូលទៅគាល់ព្រះមានព្រះភាគនៃសោណទណ្ឌព្រាហ្មណ៍ | ២៨១ |
| | សេចក្តីត្រិះរិះរបស់សោណទណ្ឌព្រាហ្មណ៍ . . . | ២៨៣ |
| | ការបញ្ញត្តិជាព្រាហ្មណ៍មានអង្គ ៥ . . . . | ២៨៥ |
| | ការបញ្ញត្តិជាព្រាហ្មណ៍មានអង្គ ៣ . . . . | ២៨៧ |
| | ការបញ្ញត្តិជាព្រាហ្មណ៍មានអង្គ ២ . . . . | ២៨៩ |

# មាតិកាបត្តាធំ


| | | អង្ក |
|---|---|---|
| សោណទណ្ឌសុត្ត | សោណទណ្ឌព្រាហ្មណស្ស បដិវចនំ . | ២៩១ |
| | អង្គកមាណវកគុណកថា . . . . | ២៩៣ |
| | សីលបញ្ញាកថា . . . . . . | ២៩៥ |
| | សោណទណ្ឌស្ស ឧបាសកត្តទេសនា . | ២៩៧ |
| | សោណទណ្ឌព្រាហ្មណាធិប្បាយោ . . | ២៩៩ |

# សន្ធិកបផ្ទុលមាតិកា


លេខទំព័រ

សោណទណ្ឌសូត្រ ការពោលតបតរបស់សោណទណ្ឌព្រាហ្មណ៍ . . . ២៨១

ការពោលអំពីគុណរបស់អង្គកមាណព . . . ២៨៣

ពោលអំពីសីលនឹងបញ្ញា . : . . . . ២៨៥

សោណទណ្ឌព្រាហ្មណ៍សំដែងខ្លួនជាឧបាសក . . ២៨៧

បំណាងរបស់សោណទណ្ឌព្រាហ្មណ៍ . . . ២៨៨

# វិរុទ្ធាវិរុទ្ធបត្រ

| វិរុទ្ធបាឋ | អវិរុទ្ធបាឋ | អង្គ | រដ្ឋលេខាយំ |
|---|---|---|---|
| តឹសម្បិ | បញ្ចបិ | ៣២ | ៦ |
| បញ្ចបិ | តឹសម្បិ | " | ៧ |
| ឯវមាហាក | ឯវមាហាកេ | ៣៨ | ១១ |
| ចរំ | ចិរំ | ៤៤ | " |
| ឥមហោរ | ឥមេហោរ | ៥៣ | ១៧ |
| ឥម | ឥមេ | ៥៤ | ២ |
| តេសម្ប | តេសម្បិ | ៦០ | ៩ |
| សិរិជ្ជា | សិរិជ្ជា | ១៦៩ | ៥ |
| សមណា | សមណោ | ២៧៧ | ៨ |
| ព្យាកាតញ្ញោតិ | ព្យាកាតញ្ញោតិ | ២៨០ | " |

# សន្លឹកប្រាប់ពាក្យខុសត្រូវ

| ពាក្យខុស | ពាក្យត្រូវ | ទំព័រ | បន្ទាត់ |
|---|---|---|---|
| ការៈនៃសត្វទាំងឡាយ | ការៈនៃសត្វទាំងឡាយ | ៣ | ១០ |
| ដូជា | ដូចជា | ៣៤ | ១២ |
| អមករិវេគ្ខបទិដ្ឋ | អមការីវេគ្ខបទិដ្ឋ | ៦៥ | ១ |
| ដោយវត្ត ៤ យ៉ាង | ដោយវត្ត ២ យ៉ាង | ៩៥ | ១២ |
| ដោយវត្ត ១៧ យ៉ាង | ដោយវត្ត ១៨ យ៉ាង | ៩៦ | ៦ |
| ដោយវត្ត ៦ យ៉ាង | ដោយវត្ត ១៦ យ៉ាង | ១០៥ | ១១ |
| ដូជាកំបិតកោរ | ដូចជាកំបិតកោរ | ១២៧ | ១៤ |
| អង្គុយទី | អង្គុយកន្ទី | ១៣៨ | ១២ |
| ចូលទៅកាក់ផ្ឈស | ចូលទៅកាន់ផ្ឈស | ១៥៣ | ៩ |
| ល្បែងកស់ដីខ្សាច់ | ល្បែងកល់ដីខ្សាច់ | ១៦២ | ១១ |
| ធ្វើទីពល | ធ្វើទីភល | ១៩៦ | ៣ |
| ជាគ្រ | ជាគ្រូ | ២១៨ | ៩ |

ពុទ្ធសាសនបណ្ឌិត្យ

INSTITUT BOUDDHIQUE